# បឋមកថា

# បឋមទស្សនា

## បុព្វកថា

ក្នុងច្បាប់ព្រះពុទ្ធសាសនា អំពីបញ្ហាវិបស្សនានោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយ បើនឹងចាត់ជាលំអក្នុងព្រះពុទ្ធសាសនា គឺលំអបទខាងចុង ។ វិបស្សនា គឺជាតួបញ្ញាហ្នឹងឯង ដែលជាគុណជាតិ គឺយោគាវចរ អ្នកត្រូវការព្រះនិព្វានដែលជាឋានផុតចាកទុក្ខគ្រប់យ៉ាង និងខានចម្រើនពុំបានឡើយ ព្រោះថា កិលេសតណ្ហាដែលមានក្នុងខន្ធសន្តាននៃសត្វទាំងឡាយ បើមិនមានបញ្ញាជាគ្រឿងកាត់បង់ទេ ក៏មិនអាចកាត់ផ្តាច់បានឡើយ ។

វិបស្សនាបញ្ញានេះ កាលបើព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយ ក៏ទ្រង់សម្តែងដល់មូលគឺធម៌ដែលជាឫសគល់របស់បញ្ញានោះថែមទៀត តាមសមគួរដល់អធ្យាស្រ័យរបស់សត្វទាំងឡាយដោយពិត ។

## ភ្នួចទសុទ្ធិមគ្គភាគ ៣

មានសេចក្តីយ៉ាងជាក់ប្រាកដថា: ធម៌ជាភូមិ-អារម្មណ៍របស់វិបស្សនា តើដូចម្តេច ?

ធម៌ជាឫសគល់និងជាតួរបស់វិបស្សនា តើដូចម្តេច? ភូមិរបស់បញ្ញាមាន ៦ យ៉ាងគឺ ខន្ធ ១, អាយតនៈ ១, ធាតុ ១, ឥន្ទ្រិយ ១, សច្ច ១, បដិច្ចសមុប្បាទ ១ ។ អារម្មណ៍របស់វិបស្សនា (បញ្ញា) មាន ៧៣ គឺ ខន្ធ ៥, អាយតនៈ ១២. ធាតុ ១៨. ឥន្ទ្រិយ ២២. សច្ច ៤. បដិច្ចសមុប្បាទ ១២ ។

– វិសុទ្ធិ ២ គឺសីលវិសុទ្ធិ ១. ចិត្តវិសុទ្ធិ ១. ជាឫសគល់របស់បញ្ញា។

– វិសុទ្ធិ ៥ គឺទិដ្ឋិវិសុទ្ធិ ១ កង្ខាវិតរណវិសុទ្ធិ ១. មគ្គាមគ្គញ្ញាណ-ទស្សនវិសុទ្ធិ ១. បដិបទាញាណទស្សនវិសុទ្ធិ ១. ញាណទស្សនវិសុទ្ធិ ១. ជាតួរបស់បញ្ញា ។

– វិសុទ្ធិ ៧ បើសង្គ្រោះចូលក្នុងត្រៃសិក្ខាដូច្នេះ សីលវិសុទ្ធិជាតួសីល. ចិត្តវិសុទ្ធិ ជាតួសមាធិ. វិសុទ្ធិ ៥ ជាតួបញ្ញា ។

– សីលជាលំអបទខាងដើមនៃព្រះពុទ្ធសាសនា ។

– សមាធិ ជាលំអបទកណ្តាលនៃព្រះពុទ្ធសាសនា ។

– បញ្ញាជាលំអបទខាងចុងនៃព្រះពុទ្ធសាសនា ។ វិសុទ្ធិ ៧ នេះជាបដិ-បត្តិកមោ (លំដាប់នៃការប្រតិបត្តិ) ធ្វើដំណើរឆ្ពោះទៅកាន់ព្រះនិព្វាន ប្រៀបដូចជារថ ៧ ដែលបុគ្គលជិះតាមលំដាប់មួយៗ ធ្វើដំណើរឆ្លងកាត់អំពីប្រទេសមួយទៅកាន់ប្រទេសមួយ សេចក្តីនេះមានក្នុងគម្ពីរមជ្ឈិមនិកាយ មូលបណ្ណាសក ទុតិយភាគ រថវិនីសូត្រ ។ ម្យ៉ាងទៀតមានសេចក្តីថា: ជាធម៌ ប្រព្រឹត្តក្នុងព្រះពុទ្ធសាសនាតាមលំដាប់ដូចច្រាំងសមុទ្រ ដូច្នេះធម្មតាច្រាំងសមុទ្រមានសភាពជ្រេមានជើងទេរជម្រាលរហូតដល់ទឹក មិនជ្រៅស្រឡូងដូចអណ្តូងទឹកឡើយ ងាយស្រួលដល់បុរសស្ត្រីដែលត្រូវការចុះកាន់ទឹកសមុទ្រយ៉ាងណា, សីល សមាធិ បញ្ញានេះជាធម៌ប្រតិបត្តិតាមលំដាប់របស់យោគី ដែលមិនទាន់ពាល់ត្រូវជាសេចក្តីប្រតិបត្តិជាកណ្តាល មិនតឹងពេក មិនធូរពេក មិនលំបាកក៏យ៉ាងនោះដែរ។ យោគាវចរដែលបានប្រតិបត្តិត្រូវទំនងតាមធម៌ សមគួរដល់ធម៌ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងហើយតាមលំដាប់ក៏រមែងដឹងនូវមគ្គ និងផលបានមិនលំបាកដោយពិត ។

ការពោលអំពីសេចក្តីប្រតិបត្តិតាមលំដាប់មកនេះ គឺជាការពោលតាមសមគួរដល់អធ្យាស្រ័យនៃសត្វទាំងឡាយដោយច្រើនក្នុងលោក តែបើថាពិនិត្យទៅតាមព្រះសូត្រជាច្រើនក្នុងគម្ពីរព្រះត្រៃបិដក ក្នុងសម័យពុទ្ធកាលក៏ឃើញមានសេចក្តីខ្លះបញ្ជាក់ថា: ពួកជនដែលមានឧបនិស្ស័យ មានការកសាងអភិនីហារសមគួរដល់ការត្រាស់ដឹងនូវមគ្គផល គ្រាន់តែស្តាប់ធម៌ទេសនាអំពីសំណាក់ព្រះដ៏មានព្រះភាគ ឬសាវក សាវិការបស់ព្រះអង្គ ក៏អាចត្រាស់ដឹងលោកុត្តរធម៌ បានចំនួនច្រើនកោដិ ។ បញ្ហានេះមានសេចក្តីបញ្ជាក់ឱ្យឃើញច្បាស់ថា: ធម៌បដិបត្តិគឺសីល សមាធិ បញ្ញា ជាគុណជាតិកើតឡើងស្រួលក្នុងសន្តានចិត្តសត្វព្រមគ្នាទាំងអស់តែម្តង ឬថាកើតតាមលំដាប់មួយខណៈៗ ភ្លាមៗ មួយរំពេចពេលកំពុងស្តាប់ធម៌ទេសនាតែម្តង ដោយមិនបាច់ទៅខំប្រឹងប្រតិបត្តិ រក្សាសីលចម្រើនសមាធិ ។ កាលបើសីល សមាធិ បរិសុទ្ធស្អាត ហើយទើបចម្រើនវិបស្សនាតាមលំដាប់តទៅទៀត។ ក្នុងបញ្ហារឿងនេះសាធុជន គប្បីជ្រាបថា: ពួកពុទ្ធបរិស័ទដែលបានត្រាស់ដឹងនូវមគ្គ និងផលងាយៗ ស្រួលៗ មិនលំបាកក្នុងសម័យពុទ្ធកាលនោះ មិនមែនក្នុងសម័យនេះទេ ព្រោះសាសនាកន្លងទៅបាន ២៥៤០ ឆ្នាំទៅហើយ ដោយអាស្រ័យនឹងការកសាងបារមីនៃពុទ្ធបរិស័ទ ទាំងនោះផងអាស្រ័យដោយព្រះដ៏មានបុណ្យទ្រង់ប្រកបដោយមហាករុណាទិគុណ មានវិជ្ជាគ្រប់គ្រាន់ដឹងអធ្យាស្រ័យរបស់សត្វ និងធម៌ដែលត្រូវសម្តែងតម្រូវឱ្យសត្វត្រាស់ដឹងផង ម្ល៉ោះហើយពេលដែលព្រះអង្គទ្រង់សម្តែងទេសនាម្តងៗ ពពួកសត្វក៏ត្រូវបានសម្រេចមគ្គផល តាមអធ្យាស្រ័យជាច្រើនរៀងៗខ្លួន រីឯបរិស័ទជំនាន់បច្ចុប្បន្នឥឡូវនេះ មានសភាពមិនដូចបរិស័ទជំនាន់សម័យពុទ្ធកាលនោះឡើយ។

សួរថា: ធម្មកថិក ឬ ធម្មាចារ្យ ឬ លោកអង្គឯណាមួយ ដែលជាអ្នកសម្តែងធម៌ក្នុងពេលឥឡូវនេះ ចប់ធម៌ទេសនាម្តងៗ តើមានពុទ្ធបរិស័ទប៉ុន្មាននាក់ដែលបានលុះក្នុងមគ្គ និងផលនោះ ។

ឆ្លើយថា: តាមសេចក្តីសន្និដ្ឋាន ប្រសិនបើយើងពិនិត្យតាមសភាពនៃអ្នកស្តាប់ធម៌ក្នុងជំនាន់នេះ កុំថាដល់បានសម្រេចមគ្គផលជាន់ខ្ពស់នោះ សូម្បីត្រឹមតែធ្វើនូវការយល់នូវធម៌តាមធម៌ដែលលោកសម្តែងនោះក៏មិនមានផង ច្រើនតែបរិស័ទ មានការភ្លេច. មិនចេះ. មិនចាំ. មិនយល់. តែបើប្រសិនមានសម្រេចមគ្គផលជាលោកុត្តរនោះ ពិតជាមានប្រមាណតិចក្រៃលែងក្នុងលោក ។ ព្រោះហេតុអ្វី? ព្រោះថាលោកអ្នកសំដែងធម៌ក៏មិនសូវជាអ្នកស្ទាត់ជំនាញក្នុងរឿងសម្តែងផង រីឯសត្វលោក ក៏មានបារមីនៅខ្ចីទៀតផង ។

តាមសេចក្តីក្នុងគម្ពីរព្រះត្រៃបិដក ពុទ្ធបរិស័ទដែលត្រូវបានលុះមគ្គផលជាលោកុត្តរនោះឃើញមានដំណើរ ៣ យ៉ាងតាមអធ្យាស្រ័យគឺ

១- ពុទ្ធបរិស័ទខ្លះ មានចិត្តតម្កល់ស៊ប់ក្នុងសីលដ៏បរិសុទ្ធ ស្តាប់ធម៌ទេសនាក៏មានចិត្តឃាងចុះស៊ប់ក្នុងសមថវិបស្សនាពិចារណាឃើញនូវធម៌តាមពិតក៏បានលុះក្នុងមគ្គផលតាមអធ្យាស្រ័យនៃខ្លួនទៅ ។

២- ពុទ្ធបរិស័ទខ្លះ មានចិត្តតម្កល់ស៊ប់ក្នុងសីលដ៏បរិសុទ្ធ ហើយក៏តម្កល់ចិត្តយ៉ាងមាំ ចម្រើនវិបស្សនាយកវិបស្សនាជាប្រធាន ក៏មានចិត្តឃាងចុះស៊ប់ក្នុងធម៌ ពិចារណាឃើញនូវធម៌តាមពិត ក៏បានសម្រេចមគ្គផលតាមអធ្យាស្រ័យនៃខ្លួនទៅ ។

៣- ពុទ្ធបរិស័ទខ្លះ មានចិត្តតម្កល់ក្នុងសីលហើយ ចម្រើនសមាធិ (សមាបត្តិ ៨) បន្ទាប់មកចម្រើនវិបស្សនាមានចិត្តយាងចុះស៊ប់ក្នុងធម៌ ពិចារណាឃើញធម៌តាមពិត ក៏ទម្លុះមគ្គផលតាមអធ្យាស្រ័យនៃខ្លួនទៅ ។

សូមយល់ថា ដំណើរនៃចិត្តរបស់ពុទ្ធបរិស័ទទាំងនោះ ដែលបានសម្រេចមគ្គផលតាមថ្នាក់ចាប់ពីសោតាបត្តិមគ្គឡើងទៅ មុននឹងបានសម្រេចមគ្គផលសុទ្ធតែជាបុគ្គលមានចិត្តយាងចុះស៊ប់ក្នុងធម៌ ពិចារណាឃើញនូវធម៌តាមពិតជាចិត្តនឹងធឹងមានអារម្មណ៍មូលតែមួយ ជាចិត្តបរិសុទ្ធប្រាសចាកសង្កិលេសធម៌ (ទុច្ចរិត ១០) . បរិយុដ្ឋានកិលេស (នីវរណៈ ៥) ទើបទម្លុះមគ្គផលបាន តែបើចិត្តប្រកបដោយសង្កិលេសធម៌ និងបរិយុដ្ឋានកិលេសនោះ ជាចិត្តរាយមាយ ហើយចិត្តនោះមិនយាងចុះស៊ប់ក្នុងធម៌ ពិចារណាឃើញធម៌តាមពិតទេ មិនអាចទម្លុះមគ្គផលបានឡើយ ។

បរិស័ទសម័យក្រោយពុទ្ធកាល ច្រើនជាបុគ្គលប្រកបដោយសង្កិលេសធម៌ និងប្រកបដោយនីវរណៈ ៥ កាលសមាទានសីលហើយ ប្រកាន់យកត្រឹមតែការស្តាប់ធម៌ទេសនា ឬ ប្រកាន់ត្រឹមតែការចំរើនវិបស្សនាសុទ្ធ ជាប្រធាន ជាធំមិនបានចម្រើនសមាធិចិត្ត ធ្វើចិត្តឱ្យនឹងធឹងជាមុនទេ យកតាមលំអានដំណើរក្នុងការសម្រេចរបស់ព្រះអរិយក្នុងសម័យពុទ្ធកាលតែម្យ៉ាងនោះ ក៏បានមកនូវការយឺតយូរក្នុងការត្រាស់ដឹងធម៌តាមពិតទៅវិញក៏សឹងមាន។ ព្រោះចិត្តនោះមិនបរិសុទ្ធ សង្កិលេសធម៌ និងនីវរណធម៌ចេះតែសង្គ្រុបសង្កត់ចិត្តរឿយៗ ធ្វើឱ្យយោគាវចរមិនបានបញ្ញា ។ ព្រោះថាបញ្ញាវិបស្សនាដែលនឹងកើតឡើងបានព្រោះអាស្រ័យនឹងចិត្តស្ងប់ចាកសង្កិលេសធម៌និងនីវរណធម៌នោះ ។

ដំណើរនេះសូមយល់ថា កាលបើចិត្តមិនទាន់ស្ងប់ យោគីមិនគួរចម្រើនវិបស្សនាឡើយ ព្រោះថាវិបស្សនាមានបរមត្ថធម៌ជាអារម្មណ៍ប្រាសចាកបញ្ញត្តារម្មណ៍ កាលបើសព្វសត្វមានការត្រាស់ដឹងនូវមគ្គផលដ៏តានតឹងដូចបានពោលមកដូច្នោះហើយ ទើបសម័យព្រះពុទ្ធសាសនាកន្លងទៅបាន ៩៥៦ ឆ្នាំ ព្រះមហាថេរៈ ១ ព្រះអង្គមានព្រះនាមថា " **ព្រះពុទ្ធឃោសាចារ្យ** " ដែលព្រះសង្ឃក្នុងសម័យនោះរាប់ពាន់អង្គគប្បីកំណត់ថា ជាតួអង្គ"**ព្រះពោធិសត្វអរិយមេត្តេយ្យ**" ដែលនឹងត្រូវត្រាស់ដឹងជាសព្វញ្ញុពុទ្ធក្នុងខាងចុងនៃភទ្ទកប្បនេះ ជាមហាបណ្ឌិត មហាអ្នកប្រាជ្ញ បានប្រែគម្ពីរព្រះត្រៃបិដក និងអដ្ឋកថាអំពីសីហឡភាសា មកជាតន្តិភាសា (បាលី) វិញ ដើម្បីងាយស្រួលក្នុងការរៀនសូត្រដល់កុលបុត្តអ្នកសិក្សាច្បាប់ និងប្រតិបត្តិក្នុងធម្មវិន័យក្នុងលោកនេះ ។ ព្រះមហាថេរបានធ្វើគម្ពីរមួយឈ្មោះ " វិសុទ្ធិមគ្គ " មាន ៣ ភាគ ដែលពោលអំពីកិច្ចប្រតិបត្តិ ៣ យ៉ាង គឺ សីល ១, សមាធិ ១, បញ្ញា ១, ឬវិសុទ្ធិ ៧ យ៉ាង ដែលជាផ្លូវប្រតិបត្តិតាមលំដាប់លំដោយដូចជាច្រាំងសមុទ្រ ឬដូចជារថ ៧ ដែលបុរសជិះតគ្នាតាមលំដាប់ ដើម្បីជាប្រយោជន៍ដល់សាធុជនច្រើនគ្នា អ្នកត្រូវការសេចក្តីស្ងប់មានបំណងធ្វើដំណើរឆ្ពោះទៅកាន់ឋានផុតចាកទុក្ខ គឺព្រះនិព្វានហោង ។

ដើម្បីបំពេញទៅតាមអធ្យាស្រ័យ របស់សាធុជនទាំងឡាយ ក្នុងជំនាន់នេះ ដែលជាអ្នកត្រូវការប្រតិបត្តិនូវធម៌តាមលំដាប់ គឺសីល ១, សមាធិ ១, បញ្ញា ១, ឬវិសុទ្ធិ ៧ យ៉ាង គឺសីលវិសុទ្ធិ ១ ចិត្តវិសុទ្ធិ ១ ទិដ្ឋិវិសុទ្ធិ ១ កង្ខាវិតរណវិសុទ្ធិ ១ មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ ១ បដិបទាញាណទស្សនវិសុទ្ធិ១, ញាណទស្សវិសុទ្ធិ ១ ខ្ញុំសូមពោលអធិប្បាយអំពីកិច្ចប្រតិបត្តិក្នុងធម៌ទាំងនោះដូចតទៅ:

# សាសនគុណកថា

ក្នុងខាងដើមនេះនឹងពណ៌នានូវគុណនៃព្រះពុទ្ធសាសនាដោយសង្ខេបទុកជាមុន ដើម្បីបង្ហូរនូវទឹកចិត្តនៃកុលបុត្រអ្នកមានសទ្ធាក្នុងព្រះពុទ្ធសាសនា ឱ្យយាងចុះដោយស្រួលកាន់ផ្លូវប្រតិបត្តិ ។

ធម្មជាតិដែលហៅថាព្រះពុទ្ធសាសនា បើពោលដោយរួបរួមមកសំដៅយកសីល, សមាធិ, បញ្ញា, តែ ៣ ប៉ុណ្ណោះឯង សីលជាខាងដើម សមាធិជាកណ្តាល បញ្ញាជាខាងចុងបំផុត។ ន័យម្យ៉ាងទៀតថាសីលចាត់ជាគុណល្អគួររាប់ថ្នាក់ខាងដើមនៃសាសនា[1] (អាទិកល្យាណ) ព្រោះនាំមកនូវអវិប្បដិសារាទិគុណ សមាធិចាត់ជាគុណល្អ គួររាប់ថ្នាក់កណ្តាលនៃសាសនា (មជ្ឈេកល្យាណ) ព្រោះនាំមកនូវឥទ្ធិវិធាទិគុណ បញ្ញាចាត់ជាគុណល្អ គួររាប់ថ្នាក់ខាងចុងបំផុតនៃសាសនា (បរិយោសានកល្យាណ) ព្រោះនាំមកនូវតាទិភាព ។

ព្រោះហេតុនោះ បុគ្គលដែលបានឈ្មោះថាជាអ្នកជឿកាន់តាមព្រះពុទ្ធសាសនានោះ លុះតែបានប្រតិបត្តិត្រង់ទៅតាមថ្នាក់នៃព្រះពុទ្ធសាសនាទាំង ៣ នេះ យ៉ាងហោចត្រឹមថ្នាក់ណានីមួយ ។

គុណនិងប្រយោជន៍នៃព្រះពុទ្ធសាសនា ទាំង ៣ ថ្នាក់ដែលកើតឡើងដល់បុគ្គលដែលប្រតិបត្តិតាមប្លែកគ្នាដូចតទៅៈ

សីលញ៉ាំងបុគ្គលដែលប្រតិបត្តិតាមឱ្យបាននូវវិជ្ជា ៣, សមាធិឱ្យបាននូវអភិញ្ញា ៦, បញ្ញាឱ្យបាននូវបដិសម្ភិទា ៤ ។

---

[1] - ព្រះពុទ្ធសាសនា

សីលញ៉ាំងបុគ្គលដែលប្រតិបត្តិតាម ឱ្យវៀរបង់នូវកាមសុខល្លិកានុយោគបាន,សមាធិឱ្យវៀរបង់នូវអត្តកិលមថានុយោគបាន, បញ្ញាឱ្យសេពនូវមជ្ឈិមាបដិបទាបាន ។

សីលញ៉ាំងបុគ្គលប្រតិបត្តិតាមឱ្យកន្លងនូវអបាយ ៤ បាន, សមាធិឱ្យកន្លងនូវកាមធាតុបាន បញ្ញាឱ្យកន្លងនូវភពទាំងអស់បាន ។

សីលញ៉ាំងបុគ្គលដែលប្រតិបត្តិតាមឱ្យលះបង់នូវកិលេសបានដោយតទង្គប្បហាន, សមាធិឱ្យលះបង់កិលេសបានដោយវិក្ខម្ភនប្បហាន, បញ្ញាឱ្យលះបង់នូវកិលេសបានដោយសមុច្ឆេទប្បហាន ។

សីលញ៉ាំងបុគ្គលដែលប្រតិបត្តិតាម ផ្ចាញ់នូវវិតិក្កមទោសនៃកិលេសទាំងឡាយ[2] បាន សមាធិឱ្យផ្ចាញ់នូវបរិយុដ្ឋាននៃកិលេសទាំងឡាយ[3] បាន, បញ្ញាឱ្យផ្ចាញ់នូវអនុសយនៃកិលេសទាំងឡាយ[4] បាន ។

សីលញ៉ាំងបុគ្គលដែលប្រតិបត្តិតាមឱ្យជម្រះនូវសង្កិលេសធម៌ គឺ ទុច្ចរិតទាំង ៣ បាន. សមាធិឱ្យជម្រះនូវសង្កិលេសធម៌ គឺតណ្ហាបាន បញ្ញាឱ្យជម្រះនូវសង្កិលេសធម៌ គឺទិដ្ឋិបាន ។

សីលញ៉ាំងបុគ្គលអ្នកប្រតិបត្តិតាមឱ្យដល់នូវភាពជាសោតាបន្ន និងសកទាគាមិបុគ្គលបាន សមាធិឱ្យដល់នូវភាពជាអនាគាមិបុគ្គលបាន បញ្ញាឱ្យដល់នូវភាពជាព្រះអរហន្តបាន ។

---

[2] - ទោសកំហុសដែលកិលេសយ៉ាងគ្រោតគ្រាតបណ្តាលឱ្យប្រតិបត្តិកន្លងទ្វារទាំង ៣ ។

[3] - កិរិយាដែលកិលេសយ៉ាងកណ្តាលគ្របសង្កត់នូវកុសលចិត្តទុកមិនឱ្យប្រព្រឹត្តទៅបាន។

[4] -កិរិយាដែលកិលេសយ៉ាងល្អិតតាមដេកត្រាំនៅក្នុងចិត្តទន្ទឹងចាំមានបច្ច័យគួរកើតឡើងបានក៏កើតឡើង

# ការសិក្សាវិបស្សនា

## ថ្នាក់ដំបូង

កិច្ចប្រតិបត្តិក្នុងវិបស្សនាកម្មដ្ឋានថ្នាក់បឋមនេះ ជាកិច្ចសម្រាប់គ្រហស្ថ, បព្វជិតជាអាទិកម្មិកបុគ្គល គឺបុគ្គលទើបតែនឹងចាប់ផ្តើមរៀនសូត្រប្រតិបត្តិធម៌ជាដំបូងគឺថាមិនទាន់ធ្លាប់មានការហាត់រៀនអប់រំចិត្ត ប្រតិបត្តិក្នុងកម្មដ្ឋានណាមួយឡើយក្នុងព្រះពុទ្ធសាសនានេះ ។

## កិច្ចខាងដើមនៃការរៀនយក
## នូវព្រះកម្មដ្ឋាន

សាធុជនទាំងឡាយក្នុងបច្ចុប្បន្នកាល ជាអ្នកជ្រះថ្លារៀនសូត្រប្រតិបត្តិធម៌ក្នុងព្រះពុទ្ធសាសនា កាលចូលរៀនកម្មដ្ឋានក្នុងសំណាក់នៃគ្រូធម្មាចារ្យមានសភាពផ្សេងៗ គ្នា សាធុជនខ្លះជាភិក្ខុ-សាមណេរ ឬជាឧបាសក ឧបាសិកាជាអ្នកមានសីលរក្សាហើយក្នុងព្រះពុទ្ធសាសនា បានចូលទៅប្រតិបត្តិធម៌ក៏មាន។ សាធុជនខ្លះមានចិត្តជ្រះថ្លាឱ្យត្រឹមតែទាន មិនដែលធ្លាប់រក្សាសីលសោះ ពេលឮឬឃើញសាធុជនដទៃចូលទៅរៀនព្រះកម្មដ្ឋាន ក្នុងសំណាក់នៃគ្រូធម្មាចារ្យណាមួយ ក៏មានចិត្តជ្រះថ្លា ក៏សូមចូលរៀនព្រះកម្មដ្ឋានជាមួយគេដែរក៏សឹងមាន ។ ហេតុដូច្នេះខ្ញុំសូមចែករបៀបវិធីសិក្សាវិបស្សនាកម្មដ្ឋាន ថ្នាក់ដំបូងជាកិច្ចខាងដើមនៃការរៀនយកព្រះកម្មដ្ឋានជា ២ ចំណែកដូចតទៅ:

១- ភិក្ខុ សាមណេរ ឬ ឧបាសក ឧបាសិកា ជាអ្នកដល់នូវព្រះរតនត្រ័យជាទីពឹងទីរលឹក បានធ្លាប់សមាទាននូវសីលរួចហើយ មានសេចក្តីប្រាថ្នាដើម្បីប្រតិបត្តិក្នុងវិបស្សនាថ្នាក់ដំបូងនេះ គប្បីប្រតិបត្តិតាមលំដាប់ដូចតទៅ:

ក- ជម្រះនូវសីលឱ្យបានបរិសុទ្ធរៀងៗខ្លួន ជាសីលដែលខ្លួនបានសមាទានកាន់យកតាមសទ្ធាជ្រះថ្លាជាមុន ។

ខ- លះបង់បលិពោធ គឺសេចក្តីកង្វល់ ១០ យ៉ាង ។

គ- សេពគប់នឹងកល្យាណមិត្រព្រះធម្មាចារ្យ ។

ឃ- ការគោរពប្រតិបត្តិចំពោះព្រះធម្មាចារ្យ សូមរៀនព្រះកម្មដ្ឋាន ។

## ក- កិច្ចជម្រះសីល

ព្រះយោគាវចរ (ភិក្ខុ សាមណេរ ឬ ឧបាសក ឧបាសិកា អ្នកប្រតិបត្តិធម៌) ជាអ្នកមានសេចក្តីប្រាថ្នាអប់រំចិត្ត ដោយការចម្រើនព្រះកម្មដ្ឋានក្នុងព្រះពុទ្ធសាសនា ត្រូវជម្រះសីលឱ្យបរិសុទ្ធជាមុនសិន ទើបអាចញ៉ាំងគុណវិសេសឱ្យកើតឡើងបាន កាលបើសីលមិនបរិសុទ្ធទេនោះមិនអាចញ៉ាំងគុណវិសេសឱ្យកើតបានឡើយព្រោះសន្តានចិត្តបុគ្គលទ្រុស្តសីល តែងមានវិប្បដិសារីអស់កាលជានិច្ច មិនមែនជាទីតាំងនៃគុណវិសេសឡើយ ធម្មតាទោសទ្រុស្តសីលកុំថាឡើយដល់ទោសធំនោះ សូម្បីតែទុក្កដាបត្តិ ១ យ៉ាងតូច ដែលប្រកបដោយចិត្តក្លែង ក៏ធ្វើអន្តរាយដល់គុណវិសេស មានសមាធិជាដើមបាន ហេតុនោះត្រូវជម្រះសីលឱ្យបរិសុទ្ធជាមុន តាមការគួរដល់ភេទជាគ្រហស្ថ ឬ បព្វជិតជាមុនសិន ។

## ខ- បលិពោធ ១០

បន្ទាប់មកយោគាវចរ គប្បីផ្តាច់បង់នូវបលិពោធ (ធមិជាគ្រឿងកង្វល់) ១០ យ៉ាងគឺៈ

១- **អាវាសបលិពោធ** កង្វល់ដោយការគ្រប់គ្រងលំនៅ ។

២- **កុលបលិពោធ** កង្វល់ដោយជាប់ជំពាក់នៅក្នុងត្រកូលញាតិ ឬ ត្រកូលរបស់ឧបដ្ឋាក ។

៣- **លាភបលិពោធ** កង្វល់ដោយការទទួលលាភ គឺកង្វល់ដោយការធ្វើអនុមោទនា ឬសម្តែងធមិដល់ទាយក ។

៤- **គណៈបលិពោធ** កង្វល់ដោយពួកអ្នករៀនព្រះសូត្រ ឬពួកលោករៀនអភិធម្ម គឺកង្វល់ដោយការបង្រៀន ។

៥- **កម្មបលិពោធ** កង្វល់ដោយការងារ គឺកង្វល់ដោយការធ្វើការងារខ្លួនឯង ឬចាត់បង្គាប់ឱ្យគេធ្វើ ។

៦- **អទ្ធានបលិពោធ** កង្វល់ដោយដើរដំណើរផ្លូវឆ្ងាយ ។

៧- **ញាតិបលិពោធ** កង្វល់ថែទាំព្យាបាលជំងឺរបស់ញាតិ គឺអាចារ្យ និងឧបជ្ឈាយ៍ ។

៨- **អាពាធបលិពោធ** កង្វល់ដោយព្យាបាលរោគរបស់ខ្លួន ។

៩- **គន្ថបលិពោធ** កង្វល់ដោយការរៀនព្រះបរិយត្តិ ។

១០- **ឥទ្ធិបលិពោធ** កង្វល់ដោយរក្សាទុកនូវឫទ្ធិជារបស់បុថុជ្ជន តែថាឫទ្ធិនេះ ជាកង្វល់ដល់វិបស្សនា មិនមែនជាកង្វល់ដល់សមាធិឡើយ គឺត្រូវលោកអ្នកចម្រើនវិបស្សនាត្រូវផ្តាច់បង់ចេញ ។

វិធីដែលនឹងផ្តាច់បង់ដោយហេតុ ២ យ៉ាងគឺ ដោយលះបង់ចេញម្យ៉ាង ដោយធ្វើបង្ហើយម្យ៉ាង (ណាដែលគួរលះបង់ចេញបានត្រូវលះបង់ចេញ ណាមិនគួរលះបង់ចេញបាន ត្រូវធ្វើបង្ហើយ) ។

## គ- ការសេពគប់នឹងកល្យាណមិត្ត ឥព្រះធម្មាចារ្យ

លោកដែលហៅថា " កល្យាណមិត្តនោះ " សំដៅយកលោកណាដែលមានសទ្ធាជឿប្រាជ្ញាពោធិញាណរបស់ព្រះតថាគត ជឿកម្មនិងផលរបស់កម្ម មានសីលបរិសុទ្ធជាទីស្រឡាញ់ និងជាទីគោរពសរសើរនៃមនុស្សទេវតាទាំងពួង ជាអ្នកតិះដៀលបុគ្គលបាប ជាអ្នកអត់ធ្មត់ ជាអ្នកចេះបរមត្ថធម៌ដ៏ជ្រាលជ្រៅ មិនដែលប្រកបការអាក្រក់ មានសេចក្តីសន្តោស ជាអ្នកប្រាថ្នាតិច មិនជំពាក់ដោយគ្រហស្ថ មានព្យាយាមមិនខ្ជិលច្រអូស មានស្មារតីតម្កល់ខ្ជាប់. មានចិត្តតម្កល់មាំមិនរាយមាយ. ជាអ្នកមានប្រាជ្ញាយល់ត្រូវ. ជាពហុស្សូតចេះចាំពុទ្ធវចនៈច្រើន, ជាអ្នកអៀនខ្មាសអំពើបាបគ្រប់ជំពូក បុគ្គលដែលជាកល្យាណមិត្តគួរយកធ្វើជាអាចារ្យបង្រៀន នូវកម្មដ្ឋានមានទំនងដូចនេះឯង ។

វេលាដែលចូលទៅកាន់សំណាក់អាចារ្យជាកល្យាណមិត្រ ដូចពោលមកហើយ ដើម្បីរៀនយកកម្មដ្ឋាននោះ បើជាបព្វជិត ត្រូវប្រតិបត្តិតាមគមិកវត្តនិងអាចរិយវត្តឱ្យសព្វគ្រប់ ( ការពោលមកនេះសំដៅយកព្រះធម្មាចារ្យជាភេទព្រះសង្ឃ ) ។

## ឃ- ការគោរពចំពោះព្រះធម្មាចារ្យ សូមរៀនកម្មដ្ឋាន

យោគាវចរទាំងឡាយដែលមានសេចក្ដីប្រាថ្នាដើម្បីចម្រើនកម្មដ្ឋាន ជាអ្នកនឿយណាយនឹងសេចក្ដីទុក្ខក្នុងខន្ធ ទុកជាបុគ្គលធ្លាប់បានសូមខមាទោសចំពោះព្រះរតនត្រ័យ ថ្វាយខ្លួនជាឧបាសក-ឧបាសិកានិងរក្សាសីលរួចហើយ កាលបើបានចូលមកសេពគប់នឹងកល្យាណមិត្រ គឺព្រះធម្មាចារ្យ ដើម្បីសូមរៀនព្រះកម្មដ្ឋាន បើគ្រហស្ថក៏គួរតែធ្វើកិច្ចសូមខមាទោសថ្វាយខ្លួនជាឧបាសក ឧបាសិកា សមាទានសីលម្ដងទៀត ក្នុងទីចំពោះមុខនៃព្រះធម្មាចារ្យ បន្ទាប់មកប្រគល់កាយថ្វាយខ្លួនសូមរៀនកម្មដ្ឋានតទៅ ឯវិធីសូមខមាទោសថ្វាយខ្លួនជាឧបាសក ឧបាសិកា ប្រគល់កាយថ្វាយខ្លួនសូមរៀនកម្មដ្ឋាននោះនឹងមានពោលក្នុងទីខាងមុខសព្វគ្រប់ហើយ ។

២. សាធុជនដែលមិនទាន់ដល់នូវព្រះត្រៃសរណគមន៍ និងមិនទាន់បានរក្សាសីលនៅឡើយ ជាអ្នកមានសទ្ធាជ្រះថ្លា ឱ្យត្រឹមតែទាន ឬក៏មិនមានទាំងការបរិច្ចាគនូវទេយ្យធម៌ដល់ជនដទៃនៅឡើយ កាលបើបានឮឬឃើញជនដទៃលាកូនចៅ ក្រុមគ្រួសាររបស់គេ ហើយធ្វើដំណើរស្វែងរកគ្រូរៀនព្រះកម្មដ្ឋានក្នុងទីណាមួយដែលគេបានដឹង ក៏មានសទ្ធាជ្រះថ្លាចង់រៀនប្រតិបត្តិព្រះកម្មដ្ឋានក្នុងព្រះពុទ្ធសាសនានឹងគេដែរ ក៏បានចូលទៅសេពគប់នឹងធម្មាចារ្យសូមរៀនកម្មដ្ឋាន ។ សាធុជននោះគប្បីធ្វើវិធីសូមខមាទោសចំពោះព្រះរតនត្រ័យ ថ្វាយខ្លួនជាឧបាសក-ឧបាសិកា ហើយសមាទានសីលតាមសទ្ធាជ្រះថ្លា បន្ទាប់មកត្រូវប្រគល់កាយថ្វាយអត្តភាពចំពោះនឹងគ្រូធម្មាចារ្យដើម្បីសូមរៀនកម្មដ្ឋានតទៅ ។

# កិច្ចគោរពប្រតិបត្តិក្នុងសំណាក់នៃព្រះធម្មាចារ្យ

សាធុជនទាំងឡាយ ទោះជាគ្រហស្ថ ឬបព្វជិតដែលមានសេចក្តីគោរព ប្រតិបត្តិសូមរៀនកម្មដ្ឋានក្នុងសំណាក់នៃព្រះធម្មាចារ្យគប្បីប្រព្រឹត្តដូចតទៅនេះ:

១- គ្រហស្ថត្រូវមានកិច្ចប្រតិបត្តិចំពោះភិក្ខុ សាមណេរ ដែលជាព្រះធម្មាចារ្យរបស់ខ្លួនមានវិធីដូចតទៅ:

ក/ វិធីថ្វាយខ្លួនជាឧបាសក ឧបាសិកា

ខ/ វិធីសមាទានសីល

គ/ វិធីរៀនយកកម្មដ្ឋាន

### ក- **វិធីថ្វាយខ្លួនជាឧបាសក ឧបាសិកា**

បុរសឬស្ត្រីដែលមានសទ្ធាជ្រះថ្លាក្នុងព្រះរតនត្រ័យ គឺគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយមានប្រាថ្នាប្តេជ្ញាខ្លួនជាឧបាសក ឬ ឧបាសិកា ជាបុព្វភាគប្បដិបត្តិ គឺសេចក្តីប្រតិបត្តិជាចំណែកខាងដើម ឱ្យពេញស័ប់ជាអ្នកកាន់ព្រះពុទ្ធសាសនា ឬជាអ្នកតម្កល់នៅក្នុងព្រះពុទ្ធសាសនានោះ ត្រូវធ្វើដោយកិច្ច ២ យ៉ាងគឺ

១- មុនដំបូងនមស្ការចំពោះព្រះរតនត្រ័យ បន្ទាប់មកត្រូវបញ្ចេញវចីភេទសូមខមាទោសនឹងព្រះរតនត្រ័យក្នុងទីចំពោះមុខនៃព្រះធម្មាចារ្យ ។

## ពាក្យសម្រាប់ខមាទោស

ឯពាក្យសូមខមាទោសនឹងព្រះរតនត្រ័យនោះ បើបុរសតែម្នាក់ ឬ ស្ត្រីតែម្នាក់ត្រូវសូត្រថា:

អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមុឡ្ហំ

យថាអកុសលំ {យោ / យា}ហំ ភន្តេ កាយេន វា វាចាយ វា

មនសា វា ពុទ្ធស្ស វា ធម្មស្ស វា សង្ឃស្ស វា អគារវំ

អកាសឹ {តស្ស / តស្សា} មេ ភន្តេ អយ្យោ អច្ចយំ អច្ចយតោ

បដិគ្គណ្ហាតុ អាយតឹ សំវរាយ

ប្រែថា បពិត្រព្រះករុណាដ៏ចម្រើន ទោសកំហុសដែលប្រព្រឹត្តកន្លងគ្របសង្កត់ហើយនូវខ្ញុំព្រះករុណា តាមដោយខ្ញុំព្រះករុណាជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស បពិត្រព្រះករុណាដ៏ចម្រើន ក្រែងខ្ញុំព្រះករុណាបានធ្វើហើយនូវសេចក្តីល្មើស មិនគោរពដល់ព្រះពុទ្ធក្តី ដល់ព្រះធម៌ក្តី ដល់ព្រះសង្ឃក្តី ដោយកាយក្តី ដោយវាចាក្តី ដោយចិត្តក្តី បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាអត់នូវទោសកំហុសនោះដល់ខ្ញុំព្រះករុណា ព្រោះអំពើនៃទោសនោះជាសេចក្តីខុសពិត ដើម្បីនឹងបានសង្រួមគឺថានឹងប្រព្រឹត្តឱ្យល្អ តទៅក្នុងខាងមុខនោះហោង ។

**ធម្មាចារ្យ** ដែលគង់នៅក្នុងទីចំពោះមុខនោះ ត្រូវទទួលថា "**សាធុ**" ប្រែថា: ប្រពៃហើយ ។

- បើបុរសត្រូវសូត្រថា **យោហំ** ថា **តស្ស មេ**

– បើស្ត្រីត្រូវសូត្រថា **យាហំ** ឬ **តស្សា មេ**

តាមសមគួរដល់បាលីភាសា ដែលត្រូវផ្លាស់តាមបុរសស្ត្រី ។ បើសុទ្ធតែបុរសឬសុទ្ធតែស្ត្រីច្រើននាក់ ឬ បុរសនិងស្ត្រីច្រើននាក់លាយគ្នា តាំងពីពីរនាក់ឡើងទៅ ហើយសូមខមាទោសព្រមគ្នានោះ ត្រូវសូត្រថា: **អច្ចយោ ណោ**

**ភន្តេ អច្ចគមា យាថាពា** { លេ / លា } **យថា** { មុឡ្ហេ / មុឡ្ហា } **យថាអកុសល**

{ លេ / លា } { យេ / យា } **មយំ ភន្តេ កាយេន វា វាចាយ វា មនសា**

**វា ពុទ្ធស្ស វា ធម្មស្ស វា សង្ឃស្ស វា អគារវំ អករិម្ហា**

{ តេសំ / តាសំ } **ណោ ភន្តេ អយ្យោ អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ**

**អាយតឹ សំវរាយ** ប្រែដូចគ្នានឹងបែបមុន ប្លែកគ្នាតែត្រង់ពាក្យថា “ខ្ញុំព្រះករុណា” នោះ ក្នុងទីនេះត្រឡប់ប្រែថា “ខ្ញុំព្រះករុណាទាំងឡាយ” ដូច្នេះវិញ ក្រៅអំពីនេះទៅ ដូចគ្នាទាំងអស់ ។

បើបុរសត្រូវថា **យាថាពាលេ យថាមុឡ្ហេ យថាអកុសលេ យេ មយំ** ថា **តេសំ ណោ** បើស្ត្រីត្រូវថា **យថាពាលា យថាមុឡ្ហា យថាអកុសលា យា មយំ តាសំ ណោ** បើទុកជាគ្នាច្រើន មានបុរសមានស្ត្រីលាយគ្នា ហើយសូត្រសូមខមាទោសព្រមគ្នានោះ ក៏ត្រូវតែសូត្រខុសគ្នា

ត្រង់បទដែលគាបនោះដែរ តែបើគ្នាច្រើនហើយសូត្រសូមខមាទោសព្រមទាំងអស់គ្នានោះ បើមិនបាច់សូត្រដោយពាក្យជា **ពហុវចនៈ** តាមបែបខាងក្រោយនេះ នឹងសូត្រជា **ឯកវចនៈ** តាមបែបមុនក៏បាន ព្រោះសូត្រសូមខមាទោសព្រមគ្នាទាំងអស់ ។

២– បន្ទាប់អំពីសូមខមាទោសមក គប្បីបញ្ចេញវចីភេទប្តេជ្ញាខ្លួនជាអ្នកដល់ព្រះសរណគមន៍ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរឭក ដើម្បីនឹងឱ្យឡើង នាមបញ្ញត្តិជាឧបាសក ឬ ឧបាសិកាក្នុងព្រះពុទ្ធសាសនាតទៅក្នុងទីចំពោះមុខនៃធម្មាចារ្យរបស់ខ្លួន ។

បើបុរសតែម្នាក់ ឬស្ត្រីតែម្នាក់ ត្រូវប្តេជ្ញាដោយពាក្យថា: **ឯសាហំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបា{សកំ / សិកំ} មំ អយ្យោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ** ប្រែថា បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាសូមដល់នូវព្រះដ៏មានព្រះភាគដែលទ្រង់បរិនិព្វានទៅអស់កាលយូរអង្វែងហើយនោះផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក សូមព្រះករុណាជ្រាបនូវខ្ញុំព្រះករុណាថា ជាឧបា{សក / សិកា} បានដល់ហើយនូវព្រះរតនត្រ័យជាទីពឹងទីរឭកស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមតរៀងទៅ ។

ធម្មាចារ្យត្រូវទទួលថា **សាធុ** ប្រែដូចមុន បើបុរសថា **ឧបាសកំ** បើស្ត្រីថា **ឧបាសិកំ** បើគ្នាច្រើនតាំងពីពីរនាក់ឡើងទៅ ទោះសុទ្ធតែបុរសក្តី សុទ្ធតែស្ត្រីក្តី បុរសនិងស្ត្រីលាយគ្នាក្តី ត្រូវសូត្រថា: ឯ តេ / តា } មយំ ភន្តេ

**សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបា សកេ / សិកាយោ } ធារេតុ អជ្ជតគ្គេ បាណុបេ តេ / តា } សរណំ គ តេ / តា }** សេចក្តីប្រែដូចគ្នានឹងបែបមុន ប្លែកគ្នាតែត្រង់ពាក្យមុនថា: " ខ្ញុំព្រះករុណា " នៅក្នុងទីនេះថា: " ខ្ញុំព្រះករុណាទាំងឡាយ " ដូច្នេះវិញ ក្រៅពីនោះទៅដូចគ្នាទាំងអស់ ។

បុរស ឬ ស្ត្រី កាលបើបានពោលពាក្យប្តេជ្ញាជាអ្នកបានដល់ព្រះត្រ័យសរណគមន៍ជាទីពឹងទីរលឹកដូច្នេះហើយ ក៏បាននាមបញ្ញត្តិថា ឧបាសក ឬឧបាសិកាក្នុងខណៈនោះឯង ។ វិធីសូមខមាទោសក្តី វិធីប្តេជ្ញាខ្លួនជាឧបាសកក្តី ឬឧបាសិកាក្តី បើអ្នកដែលមិនចេះសូត្រជាបាលី នឹងសូត្រជាសេចក្តីសម្រាយតាមភាសារបស់ខ្លួននោះក៏បាន បើចេះសូត្រទាំងបាលី ទាំងសេចក្តីប្រែជាសម្រាយផងដូចបានពោលមកហើយនោះ ជាការប្រពៃពិត តែកុំសូត្រតែបាលីទទេដោយ

មិនដឹងសេចក្តីជាអ្វីនោះឡើយ ព្រោះកិច្ចដែលសូត្រសូមខមាទោស និងប្តេជ្ញាខ្លួននេះសំដៅយកសទ្ធា គឺសេចក្តីជឿជាក់ និង បញ្ញាជាសម្មាទិដ្ឋិដែលដឹងពិតយល់ត្រូវពិតជាប្រមាណ ។

**មុច្ឆា:** តើវិធីសូមខមាទោសចំពោះព្រះរតនត្រ័យ មានប្រយោជន៍ដូចម្តេច?

**វិស្សជ្ជនា:** ក្នុងព្រះពុទ្ធសាសនា កាលណាមានពុទ្ធបរិស័ទទើបតែនឹងចូលទៅសមាទានសីល មុនដំបូងលោកអាចារ្យតែងធ្វើវិធីសូមខមាទោសជាមុន ដោយមានប្រយោជន៍យ៉ាងសំខាន់ដូចតទៅ:

- ដើម្បីច្រានចេញនូវសេចក្តីអន្តរាយ ដែលកើតអំពីពាក្យសម្តី ដែលបានពោលទង្គិចដោយចិត្តបាបចំពោះព្រះរតនត្រ័យ ១។
- ដើម្បីញ៉ាំងចិត្តឱ្យចុះស៊ប់ក្នុងគុណព្រះរតនត្រ័យ ដោយបានដឹងខ្លួនថាទោសកំហុសទាំងឡាយដែលអាត្មាអញបានធ្វើហើយ ចំពោះព្រះត្រៃរតន៍រួចហើយឥឡូវនេះអញបានលាទោសកំហុសនោះ ដោយការសូមខមាទោសមែនពិត ១។
- ដើម្បីសេចក្តីចម្រើនក្នុងធម្មវិន័យនៃព្រះអរិយ មានឥន្ទ្រិយ ៥ មានសទ្ធិន្ទ្រិយ ជាដើម ១។

**មុច្ឆា:** តើពាក្យឧបាសក ឧបាសិកា មានន័យដូចម្តេច?

**វិស្សជ្ជនា:** ជនដែលមាននាមបញ្ញត្តិថា: " ឧបាសក ឬ ឧបាសិកា " ដោយហេតុបានដល់នូវព្រះរតនត្រ័យជាទីពឹង ទីរលឹកដូចព្រះពុទ្ធដីកាដែលទ្រង់សម្តែង

ក្នុងគម្ពីរសំយុត្តនិកាយ មហាវារវគ្គ ឯកាទសមភាគ ត្រង់ឈានសំយុត្តចំពោះមហានាមថា: **យតោ ខោ មហានាម ពុទ្ធំ សរណំ គតោ ហោតិ ធម្មំ សរណំ គតោ ហោតិ សង្ឃំ សរណំ គតោ ហោតិ ឯត្តាវតា ខោ មហានាម ឧបាសកោ ហោតិ** ប្រែថា ម្នាលមហានាម បុគ្គលជាអ្នកដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹង ព្រោះហេតុឯណា ម្នាលមហានាម បុគ្គលនោះឈ្មោះឧបាសក ព្រោះហេតុនោះឯង ។

ម្យ៉ាងទៀតមានពាក្យថា **រតនត្តយំ ឧបាសតីតិ ឧបាសកោ** ប្រែថា ជនឯណាមួយចូលទៅអង្គុយជិតព្រះរតនត្រ័យ ជននោះហៅថា: **ឧបាសក** ។

មានសេចក្តីថា: មិនមែនចូលទៅអង្គុយជិតព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជានិច្ចដោយរូបកាយនោះទេ គឺលោកសង្គ្រោះយកនាមកាយ បានដល់អរូបក្ខន្ធ ៤ ជាប្រមាណ, សូម្បីជននោះមានរូបកាយស្ថិតនៅក្នុងទីឆ្ងាយប៉ុន្មានក៏ដោយ តែមានសន្តានចិត្តប្រព្រឹត្តជាប់ក្នុងព្រះគុណព្រះរតនត្រ័យជានិច្ច ចិត្តនោះឱនទៅតោងយកគុណព្រះរតនត្រ័យជាទីពឹងទីរលឹកជានិច្ច ជននោះបានឈ្មោះថាបានចូលទៅអង្គុយជិតព្រះរតនត្រ័យដោយពិត តែបើគ្រាន់តែចូលទៅអង្គុយជិតព្រះពុទ្ធដោយរូបកាយ ឯសន្តានចិត្តនៃជននោះ ឃ្លាតចាកអំពីគុណព្រះរតនត្រ័យ មិនបង្អោនចិត្តទៅក្នុងគុណព្រះរតនត្រ័យទេនោះ ជននោះឈ្មោះថាស្ថិតនៅក្នុងទីឆ្ងាយអំពីគុណព្រះរតនត្រ័យ មិនមែនជាឧបាសក ឧបាសិកា ឡើយ ។

## ខ/ វិធីសមាទានសីល

ក្នុងកិច្ចសមាទានសីលនេះ ឧបាសក ឧបាសិកា ដែលមានសទ្ធាជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា គប្បីសមាទានសីលនឹងអាចារ្យ ឬ ភិក្ខុសាមណេរជាបុគ្គល ឬ គណៈ ឬសង្ឃដែលគង់នៅក្នុងទីនោះ ។

រីឯសីលនោះ គឺសីល ៥ សីល ៨ សីល ១០ ។

### សមាទាន និច្ចសីល ឬ បញ្ចសីល

ឧកាស { អហំ / មយំ } ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ

បញ្ច សីលានិ យាចា { មិ / ម } { ទុតិ / តតិ } យម្បិ { អហំ / មយំ } ភន្តេ វិសុំ វិសុំ

រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ យាចា { មិ / ម }

ប្រែថា សូមគោរព, បពិត្រព្រះករុណាដ៏ចំរើន { ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ }

សូមនូវសីលទាំងឡាយ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេង ៗ គ្នា បពិត្រករុណាដ៏ចម្រើន { ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ }

សូមនូវសីលទាំងឡាយ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗ គ្នាជាគម្រប់ (ពីរដងផង / បីដងផង) ។

## សមាទាន និច្ចសីលមួយបែបទៀត

ឧកាស (អហំ / មយំ) ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន

សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចា (មិ / ម) អនុគ្គហំ

កត្វា សីលំ ទេថ (មេ / នោ) ភន្តេ (ទុតិ / តតិ) យម្បិ (អហំ / មយំ) ភន្តេ វិសុំ

វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចង្គសមន្នាគតំ

និច្ចសីលំ យាចា (មិ / ម) អនុគ្គហំ កត្វា សីលំ ទេថ (មេ / នោ)

ភន្តេ ។

ប្រែថា សូមគោរព បពិត្រព្រះករុណាដ៏ចំរើន (ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ)

សូមនូវនិច្ចសីលប្រកបដោយអង្គ ៥ មួយអន្លើ ដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្ដីអនុគ្រោះ ឱ្យនូវសីលដល់ { ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ }

បពិត្រព្រះករុណាដ៏ចម្រើន { ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ } សូមនូវនិច្ចសីលប្រកបដោយអង្គ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេង ៗ គ្នាជាគម្រប់ { ពីរដងផង / បីដងផង } បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្ដីអនុគ្រោះ ឱ្យនូវសីលដល់ { ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ }

# អ្នកសមាទានតែម្នាក់គត់ត្រូវថា

**អហំ:** ខ្ញុំព្រះករុណា

**យាចាមិ:** សូម

**មេ** ដល់ខ្ញុំព្រះករុណា

**សមាទាន** ច្រើនគ្នា តាំងពីពីរនាក់ឡើងទៅក្ដី ឬ អ្នកសូត្រសូមសីល សូត្រតែម្នាក់ជាតំណាងជនច្រើនគ្នាក្ដី ត្រូវថា:

**មយំ** ខ្ញុំព្រះករុណាទាំងឡាយ

យាចាម	សូម

តេ	ដល់ខ្ញុំព្រះករុណាទាំងឡាយ	បើគ្នាច្រើនហើយសូត្រសូមសីលថាព្រមគ្នានោះប្រើជាឯកវចនៈ ដូច្នេះ ក៏បានថាៈ

អហំ	ខ្ញុំព្រះករុណា

យាចាមិ	សូម

មេ	ដល់ខ្ញុំព្រះករុណា

# ការទទួលសីល

ត្រូវថាតាមលោកឱ្យច្បាស់ ៗ កុំឱ្យខ្សឹបជាដាច់ខាត ។

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** (បីចប់)

វីតិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

**ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរលឹក

**ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរលឹក

**សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរលឹក ។

**ទុតិយម្បិ** { **ពុទ្ធំ / ធម្មំ / សង្ឃំ** } **សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវ

ព្រះ ពុទ្ធ ធម៌ សង្ឃ ជាទីពឹងទីរលឹកជាគម្រប់ពីរដងផង ។

តតិយម្បិ ពុទ្ធំ ធម្មំ សង្ឃំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវ

ព្រះ ពុទ្ធ ធម៌ សង្ឃ ជាទីពឹងទីរលឹកជាគម្រប់បីដងផង ។

## ហើយលោកពោលថា

**តិសរណគ្គហណំ បរិបុណ្ណំ** កិរិយាកាន់យកនូវព្រះត្រៃសរណគមន៍ បរិបូណ៌តែប៉ុណ្ណេះ ។

## ឧបាសក ឧបាសិកា ទទួលថា:

**អាម ភន្តេ** ករុណាលោកម្ចាស់ ។ លោកឱ្យនិច្ចសីលជាបច្ចេក សមាទានថា:

**បាណាតិបាតា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូម សមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះ កន្លង គឺសម្លាប់សត្វ ។

- **អទិន្នាទានា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឱ្យដោយកាយ ឬ ដោយវាចា ។

- **កាមេសុ មិច្ឆាចារា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តិខុសក្នុងកាមទាំងឡាយ ។

- **មុសាវាទា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

- **សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទគឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ។

## លោកសូត្ររលឹកថា

ឥមានិ បញ្ច សិក្ខាបទានិ សាធុកំ កត្វា អប្បមាទេន និច្ចកាលំ

សម្មារក្ខិតព្វំ — អ្នក / អ្នកទាំងឡាយ } គប្បីធ្វើសិក្ខាបទទាំងឡាយ ៥ នេះ ឱ្យប្រពៃ ត្រូវរក្សាឱ្យល្អអស់កាលជានិច្ច ដោយសេចក្តីមិនប្រមាទគឺថាកុំបីធ្វេសប្រហែសឡើយ។

## អានិសង្សសីល

សីលេន សុគតឹ យន្តិ    សីលេន ភោគសម្បទា

សីលេន និព្វុតឹ យន្តិ    តស្មា សីលំ វិសោធយេ ។

សត្វទាំងឡាយទៅកាន់ឋានសួគ៌បានក៏ព្រោះសីល សត្វទាំងឡាយបានបរិបូណ៌ដោយភោគៈក៏ព្រោះសីល សត្វទាំងឡាយបានទៅកាន់ទីរំលត់ទុក្ខ គឺព្រះនិព្វានក៏ព្រោះសីល ព្រោះហេតុនោះបុគ្គលជាសប្បុរស គប្បីជម្រះនូវសីលឱ្យបរិសុទ្ធ កុំឲ្យសៅហ្មង ។

## អ្នកសមាទានត្រូវទទួលថា

**សាធុ** ប្រពៃហើយ ។

សមាទាននិច្ចសីលជាបច្ចេកសមាទានចប់តែប៉ុណ្ណេះ ។

## សមាទាន ឧបោសថសីល

កាលបើឧបាសក ឧបាសិកា នឹងសមាទាននូវឧបោសថសីលប្រកបដោយអង្គ ៨ ជាបច្ចេកសមាទានអំពីភិក្ខុ ឬ សាមណេរនោះ ត្រូវសូមនូវឧបោសថសីលព្រមទាំងព្រះត្រៃសរណគមន៍ចំពោះភិក្ខុ ឬ សាមណេរថា:

ឱកាស { អហំ / មយំ } ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋ

សីលានិ យាចា { មិ / ម } { ទុតិ / តតិ } យម្បិ { អហំ / មយំ } ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ

តិសរណេន សហ អដ្ឋ សីលានិ យាចា { មិ / ម } ប្រែដូចវិធីសូមនិច្ចសីលខាងដើម

ប្លែកគ្នាតែត្រង់ពាក្យថា **អដ្ឋ សីលានិ** ប្រែថា នូវសីលទាំងឡាយ ៨ ។

## សមាទានមួយបែបទៀត

ឧកាស {អហំ / មយំ} ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន

សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចា {មិ / ម} អនុគ្គហំ កត្វា

សីលំ ទេថ {មេ / នោ} ភន្តេ {ទុតិ / តតិ} យម្បិ {អហំ / មយំ} ភន្តេ វិសុំ វិសុំ

រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចា {មិ / ម}

អនុគ្គហំ កត្វា សីលំ ទេថ {មេ / នោ} ភន្តេ ។

សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន {ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ} សូម

នូវឧបោសថសីលប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា

មេត្តាធ្វើនូវសេចក្ដីអនុគ្រោះឲ្យនូវសីលដល់ខ្ញុំព្រះ
ករុណា
ករុណាទាំងឡាយ
បពិត្រព្រះ

ករុណាដ៏ចម្រើន ខ្ញុំព្រះ
ករុណា
ករុណាទាំងឡាយ
សូមនូវឧបោសថសីលប្រកបព្រម

ដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេង ៗ

គ្នាជាគំរប់
ពីរដងផង
បីដងផង
បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តាធ្វើនូវសេច

ក្ដីអនុគ្រោះឲ្យនូវសីលដល់ខ្ញុំ
ករុណា
ករុណាទាំងឡាយ

នមោ ៣ ចប់ និងការកាន់យកព្រះត្រៃសរណគមន៍មានវិធីដូចនិច្ចសីល ឬសីល ៥ ដែរ ។

## ឧបោសថសីល

- បាណាតិបាតា វេរមណីសិក្ខាបទំ សមាទិយាមិ ( ប្រែដូច និច្ចសីល )
- អទិន្នាទានា វេរមណីសិក្ខាបទំ សមាទិយាមិ ( ប្រែដូច និច្ចសីល )

- អព្រហ្មចរិយា វេរមណីសិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាប្រព្រឹត្តិនូវធម៌ មិន ប្រសើរ គឺសេពនូវមេថុនធម្ម ។

- មុសាវាទា វេរមណីសិក្ខាបទំ សមាទិយាមិ ( ប្រែដូចនិច្ចសីល ) ។

- សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ សមាទិយាមិ (ប្រែដូចនិច្ចសីល ) ។

- វិកាលភោជនា វេរមណីសិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាបរិភោគ នូវភោជនាហារក្នុងកាលខុស ។

- និច្ចគីតវាទិតវិសូកទស្សនមាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណីសិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយារាំ និងច្រៀង និងប្រគំ និងមើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌ និងកិរិយាទ្រទ្រង់ និងប្រដាប់ តាក់តែងស្អិតស្អាងរាងកាយដោយផ្កាកម្រង និងគ្រឿងក្រអូប និងគ្រឿងលាបផ្សេង ៗ ។

- ឧច្ចាសយនមហាសយនា វេរមណីសិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកទីសេនាសនៈដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ ។

អ្នកសមាទានសូត្រកំណត់ឧបោសថថា:

- ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ ខ្ញុំព្រះករុណាសូម សមាទាននូវឧបោសថសីល ដ៏ប្រកបព្រមដោយអង្គ ៨ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់បញ្ញត្តទុកហើយនេះ ដើម្បីនឹងរក្សាឲ្យបរិបូណ៌ប្រពៃអស់កាលកំណត់ថ្ងៃនេះនិងយប់នេះ (សូមកុសលចូលជាឧបនិស្ស័យ ធ្វើឲ្យច្បាស់នូវព្រះនិព្វាន ឰដ៏អនាគតកាលទៅឯមុខនោះហោង ) ។

## ព្រះសង្ឃរំលឹកថា:

ឥមានិ អដ្ឋ សិក្ខាបទានិ ឧបោសថសីលវសេន ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សាធុកំ កត្វា អប្បមាទេន សម្មារក្ខិតព្វំ ។

អ្នក / អ្នកទាំងឡាយ } គប្បីធ្វើនូវសិក្ខាបទទាំងឡាយ ៨ នេះឲ្យប្រពៃ ត្រូវរក្សាឲ្យល្អ ដោយអំណាចនៃឧបោសថសីលអស់កាលកំណត់ត្រឹម ១ ថ្ងៃ ១ យប់នេះ ដោយសេចក្តីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។

អ្នកសមាទានត្រូវទទួល **អាម ភន្តេ** ( ប្រែដុចមុន ) ។

## អានិសង្សសីល

សីលេន សុគតឹ យន្តិ        សីលេន ភោគសម្បទា
សីលេន និព្វុតឹ យន្តិ        តស្មា សីលំ វិសោធយេ ។ (ប្រែដូចមុន)

អ្នកសមាទានត្រូវទទួលថា សាធុ ប្រពៃហើយ ។

## សមាទាននិច្ចសីលជាឯកជ្ឈសមាទាន

ឧកាស {អហំ / មយំ} ភន្តេ តិសរណេន សហ ឯកជ្ឈំ កត្វា

បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចា {មិ / ម} អនុគ្គហំ កត្វា សីលំ

ទេថ {មេ / នោ} ភន្តេ {ទុតិ / តតិ} យម្បិ {អហំ / មយំ} ភន្តេ តិសរណេន សហ

ឯកជ្ឈំ កត្វា បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចា {មិ / ម}

អនុគ្គហំ កត្វា សីលំ ទេថ {មេ / នោ} ភន្តេ សូមគោរព បពិត្រព្រះ

ករុណាដ៏ចម្រើន ខ្ញុំព្រះ {ករុណា / ករុណាទាំងឡាយ} សូមនូវនិច្ចសីលប្រកបព្រម

ដោយអង្គ ៥ ធ្វើឲ្យជាឯកជ្ឈៈ គឺសមាទានរួបតែម្តង មួយអន្លើដោយព្រះត្រៃសរណគមន៍ បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តី

អនុគ្រោះឲ្យនូវសីលដល់ខ្ញុំព្រះ { ករុណា / ករុណាទាំងឡាយ } បពិត្រព្រះករុណាដ៏ចម្រើន

ខ្ញុំព្រះ { ករុណា / ករុណាទាំងឡាយ } សូមនូវនិច្ចសីលប្រកបព្រមដោយអង្គ ៥ ធ្វើឲ្យជាឯកជ្ឈៈ

គឺសមាទានរួបតែម្តង មួយអន្លើដោយព្រះត្រៃសរណគមន៍ ជា

គំរប់ { ពីរដងផង / បីដងផង } បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តានូវ

សេចក្តីអនុគ្រោះឲ្យនូវសីលដល់ខ្ញុំព្រះ { ករុណា / ករុណាទាំងឡាយ }។

រួចលោកអ្នកឲ្យសីលលោកតាំង នមោ ៣ ចប់ រួចហើយ លោកឲ្យព្រះត្រៃសរណគមន៍ រួចប្រាប់អំពីកិច្ចកាន់យកនូវព្រះត្រៃសរណគមន៍ ដូចក្នុងវិធីបច្ចេកសមាទានខាងដើម រួចហើយលោកឲ្យនិច្ចសីលជាឯកជ្ឈសមាទានថា: **បញ្ចង្គ-សមន្នាគតំ និច្ចសីលំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវនិច្ចសីលប្រកបព្រមដោយអង្គ ៥ ។

អ្នកសមាទានត្រូវទទួលថាតាមលោក ឬលោកនឹងឲ្យថា:

**បញ្ច សីលានិ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសីលទាំងឡាយ ៥ ។

# លោករំលឹកថា

ឥមំ បញ្ចង្គសមន្នាគតំ និច្ចសីលំ សាធុកំ កត្វា អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ ប្រែថា

អ្នក<br>
អ្នកទាំងឡាយ } គប្បីធ្វើនូវនិច្ចសីលប្រកបព្រមដោយអង្គ ៥ នេះឲ្យប្រពៃ

ត្រូវរក្សាឲ្យល្អអស់កាលជានិច្ច ដោយសេចក្តីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែស ឡើយ ។

# អ្នកសមាទានថា:

អាម ភន្តេ ករុណាលោកម្ចាស់ ។ ឧបាសក ឧបាសិកា រៀនគ្រប់សិក្ខាបទទាំង ៥ មិនបាច់សូត្រញែកទេ ។

# សមាទាន ឧបោសថសីលជាឯកជ្ឈសមាទាន

ឧកាស អហំ<br>
ឧកាស មយំ } ភន្តេ តិសរណេន សហ ឯកជ្ឈំ កត្វា អដ្ឋង្គ-សមន្នាគតំ ឧបោសថំ យាចា មិ<br>
ម } អនុគ្គហំ កត្វា សីលំ ទេថ

មេ<br>
នោ } ភន្តេ ទុតិ<br>
តតិ } យម្បិ អហំ<br>
មយំ } ភន្តេ តិសរណេន សហ ឯកជ្ឈំ

កត្វា អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចា { មិ / ម } អនុគ្គហំ កត្វា

សីលំ ទេថ { មេ / នោ } ភន្តេ ប្រែដូចសមាទាននិច្ចសីលជាឯកជ្ជសមាទាន

ប្លែកគ្នាត្រង់បទថា: " **អដ្ឋង្គសមន្នាគតំ ឧបោសថំ** នូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨ " ។

លោកឲ្យ **នមោ** បីចប់ និងព្រះត្រៃសរណគមន៍ចប់ហើយ លោកឲ្យឧបោសថសីល ជាឯកជ្ជសមាទានថា **អដ្ឋង្គសមន្នាគតំ ឧបោសថំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨ ។

អ្នកសមាទានត្រូវទទួលថាតាមលោក ឬលោកនឹងឲ្យថា:

**អដ្ឋ សីលានិ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសីលទាំងឡាយ ៨ ។

សូត្រកំណត់ឲ្យឧបោសថកាល **ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ** ( ប្រែដូចមុន )។

**លោករំលឹកថា:**

ឥមំ អដ្ឋង្គសមន្នាគតំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សាធុកំ

កាត្វា អប្បមាទេន សម្មារក្ខិតព្វំ — អ្នក / អ្នកទាំងឡាយ } គប្បីធ្វើនូវឧបោសថ

សីលប្រកបព្រមដោយអង្គ ៨ នេះឲ្យប្រពៃ ត្រូវរក្សាឲ្យល្អអស់កាលកំណត់ត្រឹម ១ ថ្ងៃ ១ យប់នេះ ដោយសេចក្តីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។

អ្នកសមាទានត្រូវទទួលថា: "**អាម ភន្តេ**" ករុណាលោកម្ចាស់ ។

សមាទានឧបោសថសីលជាឯកជ្ឈសមាទាន មិនបាច់សូត្ររាយសិក្ខាបទទាំង ៨ នោះទេ ត្រូវរក្សាដោយតាំងចិត្តវិរតិចេតនា វៀរគ្រប់សិក្ខាបទទាំង ៨ ក្នុងឧបោសថសីលដែលខ្លួនបានចេះចាំស្ទាត់ ហើយនោះទៅ ។

## សមាទានសីល ១០

រីឯវិធីសមាទានសីល ១០ និងសីល ១០ នឹងមានពោលទុកក្នុងសៀវភៅនិយមសីល និងគហដ្ឋធុតង្គរួចហើយ សូមរកមើលផងចុះ ។

កិកីវ អណ្ឌំ ចមរីវ វាលធឹ

បិយំវ បុត្តំ នយនំវ ឯកកំ

តថេវ សីលំ អនុរក្ខមានកា

សុបេសលា ហោថ សទា សគារវា ។

" សត្វត្រដេវិចរក្សានូវស៊ុតវាយ៉ាងណាមិញ, សត្វចាមរីរក្សានូវរោមកន្ទុយវាយ៉ាងណាមិញ, កុដុម្ពិក៍រក្សានូវកូនជាទីស្រឡាញ់យ៉ាងណាមិញ, ជនមានភ្នែកតែម្ខាង រក្សានូវភ្នែកយ៉ាងណាមិញ, អ្នកទាំងឡាយកំពុងរក្សាសីល ជាអ្នកមានសីលជាទីស្រឡាញ់ក្រៃលែង ចូរជាអ្នកប្រកបដោយសេចក្តីគោរពសីល ឲ្យបានសព្វកាល ក៏យ៉ាងនោះដែរ ។

**សីលំ យោគិស្ស លង្ការោ សីលំ យោគិស្ស មណ្ឌនំ**
**សីលេហិ លង្កតោ យោគី មណ្ឌនេ អគ្គតំ គតោ ។**

សីលជាគ្រឿងអលង្ការរបស់ព្រះយោគី (អ្នករក្សាសីល), សីលជាគ្រឿប្រដាប់របស់យោគី (អ្នករក្សាសីល), យោគី (អ្នករក្សាសីល) ប្រដាប់តាក់តែងដោយសីលទាំងឡាយ បានដល់នូវភាពខ្ពង់ខ្ពស់ក្នុងការប្រដាប់ (រាងកាយ) ។

## អធិប្បាយសង្ខេប

សីលនេះលោករាប់ថាជាអរិយទ្រព្យ ជាទ្រព្យប្រសើរថ្លៃថ្លា ជាងទ្រព្យមានវិញ្ញាណឥតវិញ្ញាណរបស់បុរសស្ត្រីក្នុងលោកនេះ ។ ពុទ្ធសាសនិកជន អ្នកមានវិចារណញ្ញាណ គង់នឹងអាចរិះរយើញយល់បានដោយងាយ ។

**ន បុប្ផគន្ធោ បដិវាតមេតិ**
**ចន្ទនំ តគរមល្លិកា វា**
**សតញ្ច គន្ធោ បដិវាតមេតិ**
**សព្វា ទិសា សប្បុរិសោ បវាយតិ ។**

ក្លិនផ្កាបក់ផ្សាយច្រាសខ្យល់ពុំបានទេ, ក្លិនខ្លឹមចន្ទន៍ក្តី ក្លិនក្រស្នាក្តី ក្លិនផ្កាម្លិះរួតក្តី បក់ផ្សាយ

ច្រាសខ្យល់ពុំបានទេ មានតែក្លិននៃពួកសប្បុរស (អ្នកមានសីល) ទើបអាចបក់ច្រាសខ្យល់បាន. សប្បុរស (អ្នកមានសីល) បក់ផ្សាយក្លិនសព្វទិសានុទិសទាំងបណ្តោយខ្យល់ទាំងច្រាសខ្យល់ ។

ចន្ទនំ តគរំ វាបិ ឧប្បលំ អថ វស្សិកី
ឯតេសំ គន្ធជាតានំ សីលគន្ធោ អនុត្តរោ ។

ខ្លឹមចន្ទន៍ក្តី, ក្រស្នាក្តី ផ្កាឧប្បលក្តី ផ្កាម្លិះលាក្តី (សុទ្ធតែមានក្លិនក្រអូប) ប៉ុន្តែក្លិនសីល ក្រអូបក្រៃលែងជាងគន្ធជាតិទាំងនុ៎ះ ឥតមានគន្ធជាតិអ្វីក្រអូបដូចក្លិនសីលឡើយ ។

## បែបអ្នករក្សាសីល ១០

ឧបាសក ឧបាសិកាអ្នករក្សាសីល ១០ ត្រូវកោរសក់ បើមានពុកមាត់ពុកចង្កា ក៏ត្រូវកោរផងដែរ ត្រូវកាត់ក្រចកដៃជើងឲ្យស្មើនឹងសាច់ ត្រូវស្លៀកពាក់ស និងពានាសំពត់សផងក៏បាន តាមសមគួរដល់ការលៃលកសមរម្យតាមសភាពបុរសនិងស្ត្រី ។ សីលកើតឡើងដោយសារវិរតិចេតនា ពុំមែនដោយការកោរសក់ស្លៀកពាក់សទេក៏ពិតមែនហើយ ប៉ុន្តែការស្លៀកពាក់ស កោរសក់នេះជាប្រពៃណីមួយ សម្រាប់គ្រហស្ថអ្នកកាន់សីល ១០ ក្នុងព្រះពុទ្ធសាសនាជាគ្រឿងសម្គាល់ឱ្យឃើញប្លែកពីគ្រហស្ថទាំងពួង ទាំងជាភស្តុតាង ដល់ផ្លូវចិត្តរបស់គ្រហស្ថអ្នកកាន់សីល ១០ នោះឯងទៀត ប៉ុន្តែកុំយល់ថាដូចគ្នានឹង

អ្នកស្លៀកពាក់សតាមធម្មតា ឬ អ្នកដែលកោរសក់ កោរពុកមាត់ ពុកចង្កា តាមធម្មតាឥតមានសមាទានកាន់សីលនោះឡើយ ។ អ្នកកាន់សីលនិងអ្នកមិនកាន់សីល មានសភាពផ្សេងផ្ទុយដោយផ្លូវចិត្ត ដោយចរិយា និងគុណសម្បត្តិ សូម្បីអ្នកកាន់សីលផងគ្នា ក៏គង់ផ្សេងទីទៃពីគ្នាដោយថ្នាក់សីលធម៌ដែរ គឺភិក្ខុមានសីលខ្ពស់ជាងសាមណេរ សាមណេរមានសីលខ្ពស់ជាងគ្រហស្ថអ្នកកាន់សីល ១០, គ្រហស្ថអ្នកកាន់សីល ១០ មានថ្នាក់ខ្ពស់ជាងអ្នកកាន់សីល ៨, អ្នកកាន់សីល ៨ មានថ្នាក់ខ្ពស់ជាងអ្នកកាន់សីល ៥ ។

អ្នកកាន់សីលទាំងនេះ សុទ្ធតែគួរគោរពគ្នាតាមលំដាប់ថ្នាក់សីល ទាំងតាមលំដាប់ថ្នាក់អាយុវស្សាចាស់ក្មេង ហើយនិងគុណសម្បត្តិផ្សេងទៀតទើបសមគួរតាមលំដាប់គន្លងគារវធម៌ក្នុងព្រះពុទ្ធសាសនានិងបោរាណធម៌ ។ ក្នុងកាលព្រេងនាយ សូម្បីសត្វតិរច្ឆានធំតូច ដូចយ៉ាងសត្វទទា ស្វា ដំរី ដែលគោរពគ្នាតាមលំដាប់ តាមថ្នាក់អាយុ ចាស់ ក្មេង ក៏អាចបានសុគតិភពជាទិដ្ឋានុគតិ ឲ្យមនុស្សយកតម្រាប់បានដែរ ។

## គ- វិធីរៀនយកកម្មដ្ឋាន

កាលបើឧបាសក ឧបាសិកាបានសមាទានសីលរួចហើយនោះ ត្រូវសូមនិស្ស័យតម្កល់នូវលោកឲ្យជាអាចារ្យនៃខ្លួន និងប្រគល់កាយថ្វាយខ្លួន សូមរៀនកម្មដ្ឋានចំពោះលោកគ្រូអាចារ្យតទៅទៀត ត្រូវថ្វាយបង្គំដោយបញ្ចង្គបតិស្ឋាន ហើយក្រោកឡើងប្រណម្យអញ្ជលីធ្វើវចីបណាមដោយវចីភេទថា:

**ឧកាស វន្ទាមិ ភន្តេ សព្វំ អបរាធំ ខមថ មេ ភន្តេ មយា កតំ បុញ្ញំ សាមិនា អនុមោទិតព្វំ សាមិនា កតំ បុញ្ញំ មយ្ហំ ទាតព្វំ សាធុ សាធុ អនុមោទាមិ** ប្រែថា សូមទានគោរព បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំលោកម្ចាស់ បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ អត់នូវទោស គឺសេចក្ដីខុសទាំងពួងដល់ខ្ញុំព្រះករុណា បុណ្យដែលខ្ញុំព្រះករុណាបានធ្វើហើយ សូមលោកម្ចាស់អនុមោទនា (គ្រូគអរតាមចុះ) បុណ្យដែលលោកម្ចាស់បានធ្វើហើយ សូមលោកម្ចាស់ចែករំលែកឲ្យដល់ខ្ញុំព្រះករុណាផង នឹងបានសេចក្ដីល្អ ញ៉ាំងប្រយោជន៍ឲ្យសម្រេច ខ្ញុំព្រះករុណាសូមអនុមោទនា (គ្រូគអរតាម ) ។

ហើយពោលដូច្នេះតទៅទៀតថា:

**ឧកាស ការុញ្ញំ កត្វា និស្សយំទេថ មេ ភន្តេ** ប្រែថាសូមទានគោរព បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់មេត្តាប្រោសធ្វើនូវសេចក្ដីករុណាឲ្យនូវនិស្ស័យ គឺទីនៅអាស្រ័យដល់ខ្ញុំព្រះករុណា ។ ហើយអង្គុយច្រហោងផ្គងអញ្ជលីឡើងពោលដូច្នេះថា:

**អហំ ភន្តេ និស្សយំ យាចាមិ** បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណា សូមនូវនិស្ស័យ ។

**ទុតិ / តតិ } យម្បិ អហំ ភន្តេ និស្សយំ យាចាមិ** បពិត្រលោកម្ចាស់ដ៏ចម្រើន

ខ្ញុំព្រះករុណា សូមនូវនិស្ស័យជាគម្រប់ { ពីរដងផង / បីដងផង } ។

ក្រាបចុះម្តងរួចអង្គុយច្រហោងឡើងវិញ ពោលដូច្នេះតទៅទៀត **អាចរិយោ មេ ភន្តេ ហោហិ** បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ជាអាចារ្យរបស់ខ្ញុំព្រះករុណា ។ ហើយលោកអាចារ្យពោលដូច្នេះថា **សាធុ** អ្នកប្រព្រឹត្តនេះជាការសម្រេចប្រយោជន៍ល្អក្នុងព្រះពុទ្ធសាសនាហើយ (ឬលោកថា) **លហុ** អ្នកប្រព្រឹត្តនេះជាកិច្ចស្រាល គឺថាជាការចិញ្ចឹមជីវិតងាយក្នុងព្រះពុទ្ធសាសនា ហើយ (ឬលោកថា) **ឱបាយិកំ** អ្នកប្រព្រឹត្តប្រកបដោយឧបាយជាទីរលាស់នូវខ្លួនចេញចាកសំសារទុក្ខហើយ (ឬលោកថា) **បដិរូបំ** អ្នកសូមនូវអាចារ្យនេះ ជាកិច្ចដ៏សមគួរដល់សេចក្តីកោតក្រែងតាមបវេណីហើយ (ឬលោកពោលថា) **បាសាទិកេន សម្បាទេហិ** ចូរអ្នកញុំាងប្រជុំបីនៃសិក្ខា មានអធិសីលសិក្ខាជាដើមឲ្យសម្រេចល្អចុះ ។ ដោយក្នុងបទទាំង ៥ នេះ ព្រះអាចារ្យនឹងពោលតបដោយបទណាមួយក៏បាន តែត្រូវពោលឲ្យគ្រប់បីដង ។

**ឧបាសក ឧបាសិកា** ត្រូវទទួលថា:

**ឧកាស សម្បដិច្ឆាមិ** សូមទានគោរព ខ្ញុំព្រះករុណា សូមទទួលព្រមតាមដោយគោរព ។ ត្រង់បទពីរដងបន្ទាប់ត្រូវថាតែត្រឹម **សម្បដិច្ឆាមិ** ហើយត្រូវពោលដូច្នេះ ៣ ដង តទៅទៀតថា: ។

**អជ្ជតគ្គេ បានិ អាចរិយោ មយ្ហំ ភារោ អហំបិ អាចរិយស្ស ភារោ** ប្រែថា តាំងពីថ្ងៃនេះជាដើមទៅ ព្រះអាចារ្យជាភារៈនៃខ្ញុំព្រះករុណា គឺភារៈក្នុងកិច្ចដែលខ្ញុំព្រះករុណាគប្បីធ្វើវត្តប្រតិបត្តិកោតក្រែងជានិច្ច. ចំណែកខ្ញុំព្រះករុណាក៏ជាភារៈនៃលោកអាចារ្យ គឺភារៈក្នុងកិច្ចដែលលោកម្ចាស់គប្បីរំលឹកដាស់តឿនប្រៀនប្រដៅដល់ខ្ញុំព្រះករុណាជានិច្ច ។ រួចថ្វាយបង្គំចុះ ។

បន្ទាប់មកអង្គុយច្រហោងផ្គងអញ្ជលីប្រណម្យពោលថា:

**ឥមាហំ ភន្តេ អត្តភាវំ តុម្ហាកំ បរិច្ចជាមិ** ប្រែថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាសូមលះបង់នូវអត្តភាពនេះចំពោះលោកម្ចាស់ (៣ ដង) ហើយថ្វាយបង្គំ ៣ ដងចុះ ។

- បើភិក្ខុ ឬ សាមណេរវិញ មិនមានកិច្ចថ្វាយខ្លួនដូចឧបាសក ឧបាសិកាទេ មានតែកិច្ចគឺការកំណត់នូវសីលរបស់ខ្លួនហើយ សូមនិស្ស័យតម្កល់លោកឲ្យជាអាចារ្យ ថ្វាយខ្លួនសូមរៀនកម្មដ្ឋានអំពីសំណាក់អាចារ្យនៃខ្លួន ។ ដូចបានពោលរួចហើយនេះតែប៉ុណ្ណោះ ។

**បុច្ឆា** ក្នុងកិច្ចប្រគល់ខ្លួននេះមានអានិសង្សដូចម្ដេច?

**វិស្សជ្ជនា** មានអានិសង្សនឹងធ្វើខ្លួន ឲ្យលុះក្នុងអំណាចរបស់អាចារ្យ ឲ្យជាអ្នកប្រដៅងាយ មិនឲ្យប្រតិបត្តិទៅតាមអំពើចិត្ត អាចារ្យសោតក៏លោកសង្គ្រោះដោយផ្លូវអាមិស និងផ្លូវធម៌គ្រប់ជំពូក ។

**បុច្ឆា** បើបែរជាមិនប្រគល់ខ្លួនដូច្នេះវិញទេ នឹងមានទោសដូចម្ដេច ?

**ខស្សជ្ជនា** នឹងទៅជាបុគ្គលមិនគួរឲ្យអាចារ្យលោកគម្រាមកំហែងស្តីប្រដៅបាន ព្រះយោគាវចរកុលបុត្រនេះ នឹងទៅជាបុគ្គលប្រដៅក្រ មិនប្រព្រឹត្តតាមឱវាទ ចង់ទៅទីណាក៏ទៅតាមទំនើងចិត្ត ហើយអាចារ្យក៏លោកមិនសង្គ្រោះដោយផ្លូវអាមិសនិងផ្លូវធម៌ លោកមិនបង្រៀនផ្លូវណា ដែលជាអាថិកំបាំងជ្រាលជ្រៅ កាលបើដូចនេះ ព្រះយោគាវចរកុលបុត្តនោះនឹងទៅជាបុគ្គលមិនមានទីពឹងអាស្រ័យ នឹងបែរទៅជាប្រព្រឹត្តទ្រុស្តសីល ដាច់ចាកសេចក្តីល្អវិញក៏សឹងមានហេតុនោះត្រូវតែប្រគល់ខ្លួនដូចន័យដែលបានពោលមកនេះ ។

២- បើធម្មាចារ្យនោះជាគ្រហស្ថវិញ បរិស័ទត្រូវប្រតិបត្តិដូចតទៅ:

ក/ វិធីថ្វាយខ្លួនជាឧបាសក ឧបាសិកា មុនដំបូងត្រូវនមស្ការចំពោះព្រះរតនត្រ័យដោយសេចក្តីគោរព បន្ទាប់មកទៀតត្រូវធម្មាចារ្យនាំបុរស ឬស្ត្រីដែលត្រូវរៀនកម្មដ្ឋាននោះ ធ្វើវិធីសូមខមាទោសចំពោះព្រះរតនត្រ័យ និងប្រកាសខ្លួនជាឧបាសក ឧបាសិកា ក្នុងទីចំពោះមុខ ភិក្ខុ សាមណេរ ជាបុគ្គល ឬសង្ឃ ។ បើគ្មានភិក្ខុសាមណេរទេនោះ ត្រូវធ្វើវិធីនោះក្នុងទីចំពោះព្រះភ័ក្ត្រព្រះពុទ្ធរូប ឬចំពោះនឹងព្រះសថូប ព្រះចេតិយដែលបញ្ចុះព្រះសារីរិកធាតុព្រះសម្មាសម្ពុទ្ធ ។

**បើបុរសតែម្នាក់ ឬ ស្ត្រីតែម្នាក់ ត្រូវខស្សូត្រថា:**

អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមុឡ្ហំ

យថាអកុសលំ {យោ / យា} ហំ ភន្តេ កាយេន វា វាចាយ វា មនសា

ភា ភគវតោ / ពុទ្ធស្ស } ភា ធម្មស្ស ភា សង្ឃស្ស ភា អគារវំ អគាសឹ { តស្ស / តស្សា }

មេ ភន្តេ { ភគវា / អយ្យោ / អយ្យា / សង្ឃោ } អច្ចយំ អច្ចយតោ បដិគ្គណ្ហា { តុ / តុ / ន្តុ / តុ }

**អាយតឹ សំវរាយ** បពិត្រព្រះ { ដ៏មានព្រះភាគ / ករុណា / ករុណាទាំងឡាយ / សង្ឃ } ដ៏ចម្រើន ទោសកំហុសដែលប្រព្រឹត្តកន្លង គ្របសង្កត់ហើយ នូវខ្ញុំព្រះករុណា តាមដោយខ្ញុំព្រះករុណាជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស

បពិត្រព្រះ { ដ៏មានព្រះភាគ / ករុណា / ករុណាទាំងឡាយ / សង្ឃ } ដ៏ចម្រើន, ក្រែងខ្ញុំព្រះករុណាបានធ្វើហើយ

នូវសេចក្ដីល្មើសមិនគោរពដល់ព្រះ { ដ៏មានព្រះភាគ / ពុទ្ធជាម្ចាស់ } ក្ដី ដល់ព្រះធម៌ក្ដី ដល់ព្រះសង្ឃក្ដី ដោយកាយក្ដី ដោយវាចាក្ដី ដោយចិត្តក្ដី បពិត្រព្រះ

{ ដ៏មានព្រះភាគ / ករុណា / ករុណាទាំងឡាយ / សង្ឃ } ដ៏ចម្រើន, សូមព្រះ { ដ៏មានព្រះភាគ / ករុណា / ករុណាទាំងឡាយ / សង្ឃ } អត់នូវ

ទោសកំហុសនោះដល់ខ្ញុំព្រះករុណា ព្រោះអំពីនៃទោសនោះ ជាសេចក្តីខុសពិត ដើម្បីនឹងបានសង្រួម គឺថានឹងប្រព្រឹត្តឱ្យល្អតទៅក្នុងខាងមុខនោះហោង ។ រួចហើយបុគ្គល ឬគណៈ ឬសង្ឃ ដែលនៅជាប្រធាននៅទីនោះត្រូវទទួល **សាធុ** ប្រែថា ប្រពៃហើយ ។

បើបុរសត្រូវសូត្រថា យោហំ ថា តស្ស មេ បើស្ត្រីត្រូវសូត្រថា យាហំ ថា តស្សា មេ តាមគួរដល់បាលីភាសាដែលត្រូវផ្លាស់តាមបុរសស្ត្រី ទោះបីបុរសក្តី ស្ត្រីក្តី បើសូមខមាទោសក្នុងទីចំពោះព្រះភ័ក្ត្រព្រះពុទ្ធរូប ឬចំពោះនឹងព្រះសថូបព្រះចេតិយ ដែលបញ្ចុះព្រះសារីរិកធាតុ ព្រះសម្មាសម្ពុទ្ធនោះត្រូវសូត្រថា ភគវតោ វា ថា **បដិគ្គណ្ហាតុ** បើចំពោះនឹង ភិក្ខុ ១ រូប ត្រូវសូត្រថា ពុទ្ធស្ស វា ថា ភន្តេ អយ្យោ ថា **បដិគ្គណ្ហាតុ** បើចំពោះគណៈ គឺភិក្ខុ ២ រូប ឬ ៣ រូបត្រូវសូត្រថា ពុទ្ធស្ស វា ថា ភន្តេ អយ្យា ថា បដិគ្គណ្ហន្តុ បើចំពោះព្រះសង្ឃត្រូវសូត្រ ពុទ្ធស្ស វា ថា ភន្តេ សង្ឃោ ថា បដិគ្គណ្ហាតុ ត្រង់សេចក្តីប្រែក៏មានរបៀបតាមជួរបាលីដែលប្រែតាមនោះដែរ បើសុទ្ធតែបុរស ឬសុទ្ធតែស្ត្រីច្រើននាក់ ឬបុរសនិងស្ត្រីច្រើននាក់លាយគ្នា តាំងពីពីរនាក់ឡើងទៅ ហើយសូមខមាទោសព្រមគ្នានោះត្រូវសូត្រថា:

អច្ចយោ ដោ ភន្តេ អច្ចគមា យថាពា{លេ/លា} យថាមុ{ឡ្ហេ/ឡ្ហា}

យថាអកុស{លេ/លា} {យេ/យា} មយំ ភន្តេ កាយេន វា វាចាយ វា

មនសា វា {ភគវតោ/ពុទ្ធស្ស} វា ធម្មស្ស វា សង្ឃស្ស វា

អគារវំ អកាសិម្ហា {តេសំ/តាសំ} ដោ ភន្តេ {ភគវា/អយ្យោ/អយ្យា/សង្ឃោ} អច្ចយំ អច្ច-

យតោ បដិគ្គណ្ហា{តុ/តុ/ន្តុ/តុ} អាយតឹ សំវរាយ

សេចក្តីប្រែដូចគ្នានឹងបែបមុន ប្លែកគ្នាតែត្រង់ពាក្យថា " ខ្ញុំព្រះករុណា " នោះក្នុងទីនេះត្រឡប់ប្រែថា " ខ្ញុំព្រះករុណាទាំងឡាយ " ដូច្នេះវិញ ក្រៅអំពីនេះនៅដូចគ្នាទាំងអស់ ។

បើបុរសសូត្រថា: **យថាពាលេ យថាមុឡ្ហេ យថាអកុសលេ យេ មយំ** ថា **តេសំ ណោ** បើស្ត្រីត្រូវថា **យថាពាលា យថាមុឡ្ហា យថាអកុសលា យា មយំ ថា តាសំ ណោ** បើទុកជាគ្នាច្រើនមានបុរសស្ត្រីលាយគ្នា ហើយសូត្រខមាទោសព្រមគ្នានោះ ក៏ត្រូវតែសូត្រខុសគ្នាត្រង់បទ ដែលគាបនោះដែរ វៀរលែងតែបទដែលគាប ៣ អន្លើ គឺត្រង់បទថា **ភគវតោ វា ពុទ្ធស្ស វា ភគវា អយ្យោ អយ្យា សង្ឃោ បដិគ្គណ្ហាតុ បដិគ្គណ្ហន្តុ** នេះត្រូវសូត្រដូចគ្នាទាំងបុរស ទាំងស្ត្រី តែបើគ្នាច្រើនហើយសូត្រសូមខមាទោសព្រមទាំងអស់គ្នានោះ បើមិនបាច់សូត្រដោយជា ពហុវចនៈ តាមបែបខាងក្រោយនេះ នឹងសូត្រដោយពាក្យជា ឯកវចនៈ តាមបែបមុននោះក៏បាន ព្រោះសូត្រសូមខមាទោសព្រមទាំងអស់គ្នា ។

លុះបានសូមខមាទោសនឹងព្រះរតនត្រ័យដូច្នេះរួចហើយ គប្បីបញ្ចេញវចីភេទ ប្ដេជ្ញាខ្លួនជាអ្នកដល់ព្រះត្រៃសរណគមន៍ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរលឹក ដើម្បីនឹងឲ្យឡើងនាមបញ្ញត្តិជាឧបាសក ឬឧបាសិកាក្នុងព្រះពុទ្ធសាសនាតទៅ ។

ឯពាក្យប្ដេជ្ញាខ្លួនចំពោះមុខបុគ្គល គណៈ ឬសង្ឃ បានពោលរួចហើយ ។ រីឯការប្ដេជ្ញាខ្លួនជាឧបាសក ឧបាសិកា ចំពោះមុខព្រះពុទ្ធរូប ព្រះសថូប ព្រះចេតិយ ដែលបញ្ចុះព្រះសារីរិកធាតុព្រះដ៏មានព្រះបុណ្យ ។

បើបុរសតែម្នាក់ ស្ត្រីតែម្នាក់ ត្រូវពោលប្ដេជ្ញាដោយពាក្យថា:

ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច

សង្ឃញ្ច { ឧបាសកំ / ឧបាសិកំ } មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ

ប្រែថា បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន ខ្ញុំព្រះករុណាសូមដល់នូវព្រះដ៏មានព្រះភាគផង នូវព្រះធម៌ផង នូវព្រះសង្ឃផង ជាទីពឹងទីរលឹក សូមព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះករុណាថាជា ឧបា { សក / សិកា } បានដល់ហើយនូវព្រះរតនត្រ័យ ជាទីពឹងទីរលឹកស្មើដោយជីវិតតាំងអំពីថ្ងៃនេះជាដើម តរៀងទៅ។

បើគ្នាច្រើនក៏ត្រូវសូត្រដូចន័យមុន ខុសតែត្រង់ពាក្យថា ភគវន្តំ ថា ភគវា ប៉ុណ្ណោះ បើគ្នាច្រើនហើយ នឹងសូត្រប្តេជ្ញាខ្លួនព្រមគ្នាដោយពាក្យជា **ឯកវចនៈ** ក៏បានព្រោះសូត្រព្រមគ្នាទាំងអស់ ។

វិធីសូមខមាទោស និងថ្វាយខ្លួនជាឧបាសក ឧបាសិកា ធម្មាចារ្យ និងបុរសស្ត្រី អ្នកប្រាថ្នានឹងរៀនកម្មដ្ឋាននោះ សូត្រព្រមគ្នាក៏បាន មិនជាអ្វី ។

### ខ- វិធីសមាទានសីល

បន្ទាប់ពីបានថ្វាយខ្លួនជាឧបាសក ឧបាសិកាមក ព្រះធម្មាចារ្យ និងឧបាសក ឧបាសិកាទាំងអស់ត្រូវសមាទានសីលចំពោះ ភិក្ខុ[5] សាមណេរ បន្តទៅទៀត ។

( រីឯវិធីសមាទានសីលនោះ បានពោលរួចហើយ)

---

[5] បើគ្មានភិក្ខុសាមណេរ ឧបាសក ឧបាសិកា គប្បីសមាទានសីលនឹងព្រះធម្មាចារ្យជាឧបាសក ឧបាសកានោះក៏បាន ។

## គ- វិធីរៀនយកកម្មដ្ឋាន

ឧបាសក ឧបាសិកា ដែលបានសមាទានសីលរួចហើយ ប្រាថ្នានឹងរៀនព្រះកម្មដ្ឋាននោះ គប្បីប្រគល់កាយជូនអត្តភាពដល់ព្រះធម្មាចារ្យ ដោយពាក្យថា **ឥមាហំ អាចរិយ អត្តភាវំ តុម្ហាកំ បរិច្ចជាមិ ។**

១- បើគ្មានភិក្ខុសាមណេរ ឧបាសក ឧបាសិកា គប្បីសមាទានសីលនឹងព្រះធម្មាចារ្យជាឧបាសក ឧបាសិកានោះក៏បាន ។

បពិត្រលោកអាចារ្យដ៏ចម្រើន ខ្ញុំបាទ ( នាងខ្ញុំ ) សូមលះបង់នូវអត្តភាពនេះចំពោះលោកម្ចាស់ ។

ប្រសិនបើមានភិក្ខុសាមណេរសូមរៀនកម្មដ្ឋាន អំពីសំណាក់ធម្មាចារ្យជាគ្រហស្ថ មានតែកិច្ច គឺសូមប្រគល់ខ្លួន អញ្ជើញលោកអាចារ្យជួយដឹកនាំបង្រៀននូវកម្មដ្ឋានដោយត្រង់ជាពាក្យសាមញ្ញ (ធម្មតា) តែម្តងគួរ. បើនឹងទៅវន្ទា, ថ្វាយបង្គំប្រណម្យអញ្ជលី ដូចសាមណេរធ្វើកិច្ចវត្តចំពោះភិក្ខុមិនត្រូវទេ ព្រោះខ្លួនជាឧត្តមភេទ (បព្វជិត ) រីឯធម្មាចារ្យជាភេទគ្រហស្ថ ។

ឯធម្មាចារ្យវិញ ត្រូវលើកដៃថ្វាយបង្គំប្រណម្យអញ្ជលី ប្រកាសខ្លួនព្រមទទួលជួយបង្រៀនព្រះកម្មដ្ឋានដល់ភិក្ខុ សាមណេរទើបគួរ ព្រោះភិក្ខុក្តីសាមណេរក្តីជាសរណគមន៍របស់ខ្លួន ។

៣- បើព្រះធម្មាចារ្យជាសាមណេរ ហើយភិក្ខុអ្នកសូមរៀនព្រះកម្មដ្ឋានត្រូវប្រតិបត្តិដូចតទៅ:

ក្នុងព្រះវិន័យក្នុងព្រះពុទ្ធសាសនា ភិក្ខុក្រាបថ្វាយបង្គំចំពោះសាមណេរមិនត្រូវ ឯសាមណេរវិញឲ្យភិក្ខុក្រាបថ្វាយបង្គំក៏មិនត្រូវ មានទោសដូចគ្នា ។ កិច្ចប្រតិបត្តិក្នុងការរៀនព្រះកម្មដ្ឋាន កាលបើភិក្ខុមិនប្រគល់ខ្លួនឲ្យព្រះធម្មាចារ្យដឹកនាំរៀនកម្មដ្ឋាននោះទេ ហើយព្រះធម្មាចារ្យទៅពន្យល់ប្រដៅបង្រៀនភិក្ខុនោះតែម្តងក៏មិនគួរដែរ ។

ដូច្នេះភិក្ខុអ្នកប្រាថ្នាដើម្បីរៀនកម្មដ្ឋាននោះ ត្រូវផ្គងឡើងនូវអញ្ជលីប្រគល់កាយថ្វាយខ្លួន ដោយត្រឹមបញ្ចេញវចីភេទថា:

**ឥមាហំ { អាចរិយ / សប្បុរិស } អត្តភាវំ តុម្ហាកំ បរិច្ចជាមិ**

បពិត្រ { លោកអាចារ្យ / លោកដ៏សប្បុរស } ដ៏ចម្រើន ខ្ញុំព្រះករុណាសូមលះបង់នូវអត្តភាពនេះ ដល់លោកម្ចាស់ ។

ការផ្គងអញ្ជលី ប្រគល់កាយថ្វាយខ្លួននេះ យកតាមដំណើររឿងបោថិលត្ថេរ ដែលសូមរៀនព្រះកម្មដ្ឋាននឹងសាមណេរជាព្រះខីណាស្រព ១ អង្គដែលមានព្រះជន្មទើបតែ ៧ ព្រះវស្សាប៉ុណ្ណោះ ក្នុងគម្ពីរធម្មបទដ្ឋកថា ភាគ ៧។ ប្រសិនបើភិក្ខុទៅក្រាបថ្វាយបង្គំ ទៀបបាទានៃសាមណេរផងនោះ ក៏មិនគួរដែរ រីឯសាមណេរជាធម្មាចារ្យ ដែលមានសេចក្តីអនុគ្រោះចំពោះភិក្ខុនោះត្រូវ

ផ្គងអញ្ជលីក្រាបថ្វាយបង្គំចំពោះភិក្ខុ ហើយប្រកាសខ្លួនជួយបង្រៀនព្រះកម្មដ្ឋានគួរ ។ រីឯកិច្ចថ្វាយខ្លួនដូចជា ឧបាសក ឧបាសិកា និងសមាទានសីលមុនពេលប្រគល់ខ្លួនដល់ធម្មាចារ្យនោះក៏មិនមានដែរ មានត្រឹមតែការកំណត់ត្រឹមសីល ៨ របស់ខ្លួនឯងហើយ និងប្រកាសប្រគល់ខ្លួនដល់ធម្មាចារ្យប៉ុណ្ណោះ ។

កិច្ចទាំងអស់ដែលបានពោលមកហើយ អំពីបញ្ហាព្រះធម្មាចារ្យ និងបរិស័ទអ្នកប្រាថ្នារៀនកម្មដ្ឋាន ត្រូវធ្វើចំពោះគ្នាទៅវិញទៅមកនោះ សុទ្ធតែជាទីនាំមកនូវសេចក្ដីចម្រើនគ្រប់យ៉ាង ក្នុងការប្រតិបត្តិធម៌ក្នុងព្រះពុទ្ធសាសនាហោង ។ **ធម៌ដែលឧបាសក ឧបាសិកា ភិក្ខុ សាមណេរ គប្បីរៀនប្រតិបត្តិតាមលំដាប់ក្នុងវិបស្សនាថ្នាក់ដំបូងមានដូចតទៅ:**

### ការិយាតម្កល់ចិត្តក្នុងព្រះត្រៃសរណគមន៍

ពាក្យថា ត្រៃសរណគមន៍ « ត្រៃ + សរណ +គមន៍»

ត្រៃ <តិ ប្រែថា បី, សរណ ប្រែថា ជាទីពឹងទីរលឹក, គមន៍ < គមន ប្រែថា វត្ថុដែលដល់ រូមបទ តិសរណគមន> ត្រៃសរណគមន៍ (វត្ថុដែលដល់ជាទីពឹងទីរលឹកបី) ។

## សរណគមន៍មានបីយ៉ាង៖

ព្រះពុទ្ធ១, ព្រះធម៌ ១, ព្រះសង្ឃ ១.

១– លោកអ្នកប្រដៅពួកជនឲ្យប្រតិបត្តិល្អដោយកាយ វាចា ចិត្តតាមធម៌វិន័យ ហៅថា ព្រះពុទ្ធ ។

២- ធម៌វិន័យពាក្យប្រដៅរបស់ព្រះពុទ្ធ ហៅថាព្រះធម៌ ។

៣- ពួកជនដែលបានស្តាប់ពាក្យប្រដៅរបស់ព្រះពុទ្ធ ហើយបួសប្រតិបត្តិល្អតាមព្រះធម៌វិន័យ ហៅថាព្រះសង្ឃ ។

វត្ថុទាំង ៣ យ៉ាងនេះ ហៅថាព្រះត្រៃរតនៈ ប្រែថា កែវ ៣ ដ៏ប្រសើរក៏បាន។

- ព្រះត្រៃសរណគមន៍នោះ ដែលសម្រេចមានក្នុងសន្តានចិត្តនៃពុទ្ធបរិស័ទ[6] ទៅបាន លុះត្រាតែពុទ្ធបរិស័ទមានចិត្តឈានចុះស៊ប់ក្នុងសទ្ធា ។

សទ្ធាមាន ៤ យ៉ាងគឺ:

១- កម្មសទ្ធា ការជឿកម្ម ។

២- វិបាកសទ្ធា ការជឿផលនៃកម្ម ។

៣- កម្មស្សកតាសទ្ធា ការជឿថាសត្វទាំងឡាយ មានកម្មដែលខ្លួនធ្វើ ហើយជារបស់ខ្លួន ។

៤- តថាគតពោធិសទ្ធា ការជឿសេចក្តីត្រាស់ដឹងរបស់ព្រះតថាគត ។

## សេចក្តីអធិប្បាយ

១- **កម្មសទ្ធា** ‹**កម្ម** + **សទ្ធា** សទ្ធាប្រែថា ការជឿ ឬជំនឿ **កម្ម** ប្រែថា អំពើ គឺអំពើឬការងារដែលសត្វធ្វើ រួមជាកម្មសទ្ធា ប្រែថា ការជឿនូវអំពើដែលសត្វធ្វើ ។

កម្មគឺ អំពើនោះមាន ២ យ៉ាងគឺ **កុសលកម្ម** ១, **អកុសលកម្ម** ១

[6] ភិក្ខុ ភិក្ខុនី សាមណេរ សាមណេរី សិក្ខាមានា ឧបាសក ឧបាសិកា ។

**កុសលកម្ម** មានន័យថា: អំពើល្អ មានការមិនសម្លាប់សត្វមានជីវិត មិនកាន់យកទ្រព្យដែលម្ចាស់គេមិនបានឲ្យដោយកាយ ឬដោយវាចា ឬ ជាការបរិច្ចាគទាន រក្សាសីល ចម្រើនព្រះកម្មដ្ឋានជាដើម ។

**អកុសលកម្ម** អំពើអាក្រក់មានការសម្លាប់សត្វមានជីវិតជាដើម ។

ព្រះពុទ្ធដីកាទ្រង់ត្រាស់សម្តែងថា: កុសលកម្មតែងនាំសត្វឲ្យបាន សេចក្តីសុខចម្រើន បានញ៉ាំងសត្វឲ្យកើតក្នុងសុគតិសួគ៌ នាំឲ្យសត្វបានលុះក្នុង មគ្គជាលោកុត្តរថែមទៀត ។ **អកុសលកម្ម** រមែងញ៉ាំងសត្វឲ្យដល់នូវសេចក្តី វិនាសទុក្ខលំបាក មានការញ៉ាំងសត្វឲ្យកើតក្នុងអបាយភូមិ មាននរកជាដើម ។

**២-វិបាកសទ្ធា** <**វិបាក** + **សទ្ធា**

**សទ្ធា** ប្រែថាជំនឿ ឬការជឿ: **វិបាក** ប្រែថាផល **វិបាកសទ្ធា** ប្រែថា ការជឿនូវផល ផលគឺជាផលរបស់ **កុសលកម្ម** និង **អកុសលកម្ម** ។

ព្រះពុទ្ធដីកាទ្រង់ត្រាស់សម្តែងថា: សត្វទាំងឡាយកំពុងបាននូវ សេចក្តី សុខ និងសេចក្តីចម្រើន មានការសោយនូវសេចក្តីសុខក្នុងមនុស្សសម្បត្តិ ឬ សគ្គសម្បត្តិ (សម្បត្តិរបស់ទេវតា) ឬ កំពុងចម្រើនដោយ **អាយុ វណ្ណៈ សុខៈ ពលៈ** និង **បដិភាណៈ** ក្នុងឋាននៃមនុស្សជាដើម មកអំពីកម្មជាកុសលជាហេតុ បច្ច័យ ។ សត្វទាំងឡាយកំពុងដល់នូវសេចក្តីទុក្ខ និងសេចក្តីវិនាសដ៏ធំ មានសត្វ ដែលកំពុងសោយទុក្ខ ក្នុងមហានរកជាដើម ឬសត្វទាំងឡាយ ដែលកើតក្នុង ឋានមនុស្សកំពុងដល់នូវសេចក្តីវិនាស មានការវិនាសបាត់បង់ទ្រព្យសម្បត្តិ ឬ អាយុខ្លីមានជម្ងឺច្រើនជាដើម មកតែអំពីកម្មជាអកុសលជាហេតុបច្ច័យ ។

៣- **កម្មស្សកតា សទ្ធា** <**កម្មស្សកតា** + **សទ្ធា**, **សទ្ធា** ប្រែថា ការជឿ ឬជំនឿ **កម្មស្សកតា** ប្រែថា សត្វទាំងឡាយមានកម្មដែលខ្លួនធ្វើហើយជារបស់ខ្លួន រួមជា**កម្មស្សកតាសទ្ធា** ប្រែថា ការជឿថាសត្វទាំងឡាយមានកម្មដែលខ្លួនធ្វើហើយក្នុងលោក អំពើល្អ ឬអំពើអាក្រក់នោះ គឺជាអំពើរបស់សត្វនោះដោយពិតប្រាកដ មិនមែនជារបស់សត្វណាផ្សេងឡើយ ។

សេចក្តីថា: សត្វណាលូកកាន់រងើកភ្លើងដោយខ្លួនឯង សត្វនោះពិតជាក្តៅដោយខ្លួនឯង ជនណាមានខ្លួនប្រឡាក់ភក់ ហើយទៅងូតទឹកដុសសាប៊ូជម្រះកាយដោយខ្លួនឯង ជននោះពិតជាស្អាតដោយខ្លួនឯង ជនណាមានសេចក្តីស្រេកឃ្លានគ្របសង្កត់ហើយ បានបរិភោគនូវបាយនិងទឹក លុះដល់ឆ្អែតស្កប់ស្កល់ដោយខ្លួនឯង ជននោះក៏បាត់សេចក្តីស្រេកឃ្លានដោយខ្លួនឯងពិតមានសេចក្តីឧបមាយ៉ាងណា សត្វណាធ្វើនូវអំពើបាបដោយខ្លួនឯង រមែងសៅហ្មងដោយខ្លួនឯង សត្វណាមិនធ្វើអំពើបាបដោយខ្លួនឯង រមែងបរិសុទ្ធដោយខ្លួនឯង អំពើល្អ និងអាក្រក់ដែលខ្លួនធ្វើហើយ អំពើនោះជារបស់ខ្លួនមែនពិត បុគ្គលដទៃមិនគប្បីជម្រះនូវបុគ្គលដទៃឱ្យស្អាតបានឡើយ គឺជនចង់ស្អាតបរិសុទ្ធដោយកាយ ដោយវាចា ចិត្ត ជននោះត្រូវសង្រួមកាយ វាចា ចិត្តចាកបាបដោយខ្លួនឯង សត្វណាសាងបាបដោយខ្លួនឯង បន្ទាប់អំពើការបែកធ្លាយរាងកាយទៅហើយ ចូលទៅកើតក្នុងអបាយភូមិ ៤ មាននរក ជាដើមដោយខ្លួនឯង ។

សត្វណាកសាងបុណ្យដោយខ្លួនឯង បន្ទាប់អំពីការបែកធ្លាយរាងកាយទៅ ហើយចូលទៅកើតក្នុងសុគតិសួគ៌ទេវលោជាដើមដោយខ្លួនឯង ក៏មានសេចក្តីឧបមេយ្យក៏យ៉ាងនោះដែរ ។

### ៤- តថាគតពោធិសទ្ធា < តថាគត + ពោធិ + សទ្ធា

**តថាគត** < **តថា** + **អាគត** ប្រែថាទ្រង់មកហើយ ដោយប្រការដូច្នេះ **ពោធិ** ប្រែថាសេចក្តីត្រាស់ដឹង **សទ្ធា** ប្រែថា ការជឿ ឬជំនឿ រួមជា **តថាគតពោធិសទ្ធា** ប្រែថាការជឿសេចក្តីត្រាស់ដឹងរបស់ព្រះតថាគត ។

តថាគតពោធិសទ្ធា ចែកជាពីរយ៉ាងគឺ **កាលិកសទ្ធា** ១, **អកាលិកសទ្ធា** ១

១- **កាលិកសទ្ធា** គឺការជឿក្នុងព្រះនាមរបស់ព្រះពុទ្ធជាម្ចាស់ទាំង ១០ មាន **អរហំ** ទ្រង់ព្រះនាម **អរហំ** ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវ ពោលគឺកិលេសមាន ១៥០០ និង វាសនា គឺកាយបយោគ និងវចីបយោគជាដើម ។

ព្រះនាមទាំង ១០ មាន **អរហំ** ជាដើមនេះ គឺជាព្រះនាមរបស់ព្រះពុទ្ធមែនពិត ដែលកើតឡើងឯងព្រមគ្នាក្នុងសម័យដែលព្រះអង្គបានត្រាស់ដឹងនូវ **អនុត្តរសម្មាសម្ពោធិញ្ញាណ** ទ្រង់គង់លើរតនបល្ល័ង្កក្រោមដើមពោធិព្រឹក្សដ៏ប្រសើរ មិនមែនបានមកពីព្រះមាតា ឬបិតា ឬរាជត្រកូលណាមួយ ឬទេវតា ឬឥន្ទ្រព្រហ្មណាមួយដាក់ឈ្មោះព្រះអង្គឡើយ ។ ព្រះអង្គពិតជាព្រះពុទ្ធមែនទ្រង់ត្រាស់ដឹងនូវសច្ចធម៌ ហើយអាចទូន្មានប្រដៅសត្វដទៃដែលមានឧបនិស្ស័យឲ្យត្រាស់ដឹងផង ធម៌ណាដែលព្រះអង្គត្រាស់ដឹង សម្តែងហើយ មាន**សីល** ១ **សមាធិ** ១ **បញ្ញា** ១ ធម៌នោះជាធម៌ប្រព្រឹត្តទៅដើម្បីរួចចាកសេចក្តីទុក្ខបានសត្វណាប្រតិបត្តិតាមធម៌ សមគួរដល់ធម៌ ដែលព្រះអង្គទ្រង់សម្តែងហើយដោយប្រពៃ សត្វនោះក៏បានរួចចាកសំសារទុក្ខមែនពិត ។

**២- អកាលិកសទ្ធា** គឺការជឿនូវបារមីទាំង ១០ មាន ទាន ១, សីល ១, នេក្ខម ១, បញ្ញា ១, វិរិយ ១, ខន្តី ១, សច្ច ១, អធិដ្ឋាន ១, មេត្តា ១, ឧបេក្ខា ១. បារមីទាំង ១០ នេះ គឺព្រះតថាគតទ្រង់បានបំពេញបរិបូណ៌ហើយ ជាពុទ្ធការកធម៌ធ្វើឲ្យព្រះអង្គបានត្រាស់ដឹង បុគ្គលដែលមិនបានបំពេញ នូវបារមីទាំង ១០ នេះឲ្យបានពេញលេញបរិបូណ៌ទេនោះ បុគ្គលនោះនឹងមិនបានត្រាស់ដឹងមានឋានៈជាព្រះពុទ្ធដែរ ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ពិតជាព្រះពុទ្ធមែនពិត ដោយព្រះអង្គទ្រង់បានបំពេញបារមីទាំង ១០ បរិបូណ៌គ្រប់គ្រាន់ មិនមែនព្រះអង្គបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ បានដោយការសូកប៉ាន់ដោយប្រាក់កាក់អំពីសំណាក់នៃជនណាម្នាក់ក្នុងលោក ឬបានមកដោយសារការអង្វរបន់ស្រន់សូមអំពីសំណាក់នៃជនណាក្នុងលោក ឬថាជនណាម្នាក់ឃើញព្រះអង្គ ពេញចិត្តដោយហេតុណាមួយ ហើយក៏លើកព្រះអង្គ តម្កុំតម្កើងឲ្យបានឋានៈជាព្រះពុទ្ធក៏ទេដែរ ។ តាមសេចក្ដីពិតនោះគឺព្រះសម្មាសម្ពុទ្ធជាបរមគ្រូនៃយើងដែលព្រះអង្គបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ បានឋានៈជាព្រះពុទ្ធជាបរមគ្រូដ៏ប្រសើរនៃមនុស្ស និងទេវតា កាលព្រះអង្គនៅជាពោធិសត្វ (សត្វស្វែងរកការត្រាស់ដឹង) នៅឡើយ ទ្រង់បានបំពេញនូវបារមីទាំង ១០ មហាបរិច្ចាគ ៥ ចរិយា ៣ យ៉ាងក្លៀវក្លាបំផុតពិសេស អស់ ៤ អសង្ខេយ្យកម្រៃ ១ សែនកប្បហើយសុទ្ធតែបានទទួលការព្យាករណ៍អំពីសំណាក់នៃព្រះសព្វញ្ញុពុទ្ធ ២៤ ព្រះអង្គ មានព្រះពុទ្ធទ្រង់ព្រះនាមទីបង្ករដ៏ប្រសើរក្នុងលោកជាដើមមែនពិត ។

សេចក្តីអត្ថាធិប្បាយមកហើយទាំងប៉ុណ្ណេះ ក៏ដើម្បីបញ្ជាក់អំពីសទ្ធា ៤ យ៉ាងប៉ុណ្ណោះ សាធុជនទាំងឡាយអ្នកប្រតិបត្តិធម៌ក្នុងព្រះពុទ្ធសាសនា ដើម្បីធ្វើខ្លួនឲ្យរួចចាកសង្សារទុក្ខនោះ គប្បីធ្វើការពិចារណាតម្កល់ចិត្តឲ្យស៊ប់ក្នុងសទ្ធា ៤ យ៉ាងនេះ តម្កល់ចិត្តក្នុងសទ្ធា យកសទ្ធាជាធំ ជាប្រធានក្នុងការប្រតិបត្តិធម៌ កាលបើសាធុជនអ្នកមានចិត្តមិនបានតម្កល់ស៊ប់ក្នុងសទ្ធាទាំង ៤ យ៉ាងនេះទេ នោះសេចក្តីចម្រើននៃគុណធម៌ មានសីលជាដើមក្នុងការប្រតិបត្តិធម៌ ក៏មិនមានឡើយ ព្រោះថាគុណធម៌មានសីលជាដើម ដែលស្អាតបរិសុទ្ធចម្រើនឡើងលុះត្រាតែបុគ្គលអ្នករក្សាសីល មានការជឿក្នុងការប្រតិបត្តិរក្សា និង ដុសខាត់សីលនោះឲ្យស្អាតបរិសុទ្ធជាហេតុ ។

សាធុជនណាដែលបានញ៉ាំងសទ្ធា ៤ យ៉ាងនេះឲ្យកើតឡើងក្នុងសន្តាននៃខ្លួន សាធុជននោះឈ្មោះថា ជាអ្នកមានកិរិយាតម្កល់ចិត្តចុះស៊ប់ក្នុងព្រះត្រៃសរណគមន៍មែនពិត ។ ព្រោះហេតុអ្វី? ព្រោះថា កាលដែលព្រះបរមសាស្តាចារ្យនៃយើងទ្រង់ចូលកាន់បរិនិព្វានទៅហើយ មានតែព្រះធម៌ និង ព្រះវិន័យដែលព្រះអង្គទ្រង់សម្តែងហើយ អស់ ៤៥ ឆ្នាំនេះឯង ដែលជាវត្ថុតំណាងព្រះអង្គជាគ្រូបង្រៀនប្រដៅដល់ពុទ្ធបរិស័ទមែនពិត ។

ម្យ៉ាងទៀត កាលដែលព្រះអង្គគង់ធរមានព្រះជន្មនៅឡើយ ទ្រង់តែងតែសម្តែងព្រះធម៌ទេសនាដល់សត្វលោក ដែលជាសត្វមានឧបនិស្ស័យតិច មិនទាន់មានសទ្ធានៅឡើយ ឲ្យជឿកម្មនិងផលជានិច្ចជាធម្មតា ព្រះធម៌គឺ កម្ម និង ផលនៃកម្មនេះឯង សត្វណាមានចិត្តជឿស៊ប់ សត្វនោះឈ្មោះថាជាអ្នកធ្វើនូវសេចក្តីគោរព ជឿនូវព្រះធម៌នៃព្រះអង្គឈ្មោះថាមានព្រះធម៌ គឺសទ្ធាជា

ខាងដើមនៃកិច្ចប្រតិបត្តិជាទីពឹងហើយ កាលណាបើមានព្រះធម៌ជាទីពឹងហើយ ក៏ឈ្មោះថាមានព្រះពុទ្ធជាទីពឹងហើយដែរ សមនឹងព្រះពុទ្ធដីកា ដែលព្រះបរមសាស្តាចារ្យទ្រង់ត្រាស់ដាស់តឿនហើយចំពោះវក្កលីភិក្ខុ **យោ ខោ វក្កលិ ធម្មំ បស្សតិ សោ មំ បស្សតិ យោ មំ បស្សតិ សោ ធម្មំ បស្សតិ ។**

នែវក្កលិ ជនណាពិចារណាឃើញនូវធម៌ ជននោះឈ្មោះថាឃើញនូវតថាគត, ជនណាឃើញនូវតថាគត ជននោះលុះតែពិចារណាឃើញនូវ (ធម៌ដែលព្រះតថាគតទ្រង់សម្តែងហើយ) ។

ជនណាកាលបើមានព្រះពុទ្ធ ព្រះធម៌ជាទីពឹងហើយ ជននោះក៏ឈ្មោះថាមានព្រះសង្ឃជាទីពឹងដែរ ។ ព្រោះហេតុអ្វី ? ព្រោះថា ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគអង្គលោក ក៏លោកសម្តែងព្រះធម៌ទេសនាដល់សត្វដែលមិនទាន់មានសទ្ធាឲ្យជឿកម្ម និងផលនៃកម្មដែរជាដំបូង កាលបុគ្គលស្តាប់នូវធម៌ទេសនា ដោយគោរពមានចិត្តជឿស៊ប់ក្នុងកម្ម និងផលហើយ ក៏ឈ្មោះថាមានព្រះសង្ឃជាទីពឹងដោយពិត ។

ម្យ៉ាងទៀត កាលបើសត្វមានចិត្តជឿជាក់ក្នុងកម្ម និងផលនៃកម្មហើយក៏ត្រូវធ្វើនូវសេចក្តីគោរពកោតក្រែង បរិច្ចាគទានរក្សាសីលជាដើម ចំពោះសង្ឃក្នុងព្រះពុទ្ធសាសនា ។

## ភរិយាតម្កល់ចិត្តក្នុងព្រះត្រៃសរណាគមន៍

## ចប់

# កិរិយាតម្កល់ចិត្តក្នុងសីល

កិច្ចប្រតិបត្តិក្នុងព្រះពុទ្ធសាសនាដែលជាគោលសំខាន់បំផុត មាន ៣ យ៉ាង គឺ **សីល** ១, **សមាធិ** ១, **បញ្ញា** ១ ។ គុណជាតិទាំង ៣ នេះ គឺសីលជាគុណជាតិដែលយោគាវចរត្រូវរក្សាមុនជាងគុណជាតិដទៃទាំងអស់ក្នុងកិច្ចប្រតិបត្តិ ដើម្បីប្រព្រឹត្តទៅធ្វើឲ្យជាក់ច្បាស់នូវផ្លូវព្រះនិព្វាន ដែលជាទីរលត់បង់នូវសេចក្តីទុក្ខទាំងពួង ។

- ព្រោះហេតុអ្វី ?

- ព្រោះថា កាលបើសីលមិនមានក្នុងសន្តានចិត្តនៃយោគាវចរហើយ **សមាធិ** (ការតម្កល់ចិត្តនឹង) ក៏មិនមាន នឹងមិនអាចញ៉ាំង**វិបស្សនាបញ្ញា**ឲ្យកើតឡើងបានដោយពិត ។

មានសេចក្តីនៅក្នុងគម្ពីរវិសុទ្ធមគ្គភាគ ១ ថា: បុរសឈរស៊ប់នៅលើផែនដី លើកនូវកាំបិតដែលបានសំលៀងយ៉ាងមុត ហើយកាប់នូវគុម្ពឫស្សីយ៉ាងធំបាន មានសេចក្តីឧបមាយ៉ាងណា យោគាវចរដែលស្ថិតនៅលើផែនដីគឺ សីល លើកឡើងនូវកាំបិត គឺ**វិបស្សនាបញ្ញា** ដែលបានសំលៀងយ៉ាងមុតល្អដោយថ្មសំលៀង គឺ**សមាធិ** ដោយដៃគឺ **ចារិហារិកាបញ្ញា** ដែលផ្គងឡើងដោយកម្លាំងនៃសេចក្តីព្យាយាមកាត់ផ្តាច់នូវបណ្តាញគឺតណ្ហា ដែលធ្លាក់ចុះក្នុងសន្តាននៃខ្លួននោះទាំងអស់បាន ក៏មានសេចក្តីឧបមេយ្យយ៉ាងនោះ ។ ព្រះពុទ្ធដីកាថា:

ចំណេះទូទៅ

សីលេ បតិដ្ឋាយ នរោ សបញ្ញោ ចិត្តំ បញ្ញញ្ច

**ភាវយំ អាតាបី និបកោ ភិក្ខុ សោ ឥមំ វិជដយេ ជដំ** នរៈ ប្រកបដោយបញ្ញា[7]ស្ថិតនៅស៊ប់ក្នុងសីល កាលចម្រើននូវចិត្តផង បញ្ញា[8]ផង ជាអ្នកមានសេចក្ដីព្យាយាម ជាគ្រឿងដុតកំដៅនូវកិលេសជាប្រក្រតី មានប្រាជ្ញា[9]ជាគ្រឿងរក្សាខ្លួន ឃើញភ័យក្នុងសង្សារ នរៈនោះគប្បីកាត់ផ្ដាច់នូវបណ្ដាញ[10] នេះបាន ។

បណ្ដាធម៌ទាំង ៣ នេះសូមលើកយកត្រង់ពាក្យថា សីល ដែលជាកិច្ចប្រតិបត្តិដំបូងរបស់ពុទ្ធបរិស័ទក្នុងសាសនានេះមកបកស្រាយមុនដូចតទៅ:

## **សួរថាអ្វីជាតួសីល ?**

ឆ្លើយថា: ធម៌ ៤ យ៉ាងគឺ **ចេតនា** ១, **ចេតសិក** ១, **សំវរៈ** ១, **អវីតិក្កមៈ** ១ របស់បុគ្គលវៀរចាកអំពើមាន បាណាតិបាតជាដើម ឬថា របស់បុគ្គលកាលបំពេញនូវវត្តប្រតិបត្តិហៅថា សីល, ន័យក្នុង**បដិសម្ភិទា** មានពោលថា " **ចេតនា សីលំ ចេតសិកំ សីលំ សំវរោ សីលំ អវីតិក្កមោ សីលំ** " ប្រែថាចេតនាជាតួសីល, ចេតសិកជាតួសីល, សេចក្ដីសង្រួមជាតួសីល ការមិនប្រព្រឹត្តិកន្លងជាតួសីល ។

---

[7] សជាតិបញ្ញា បញ្ញាជាប់មកជាមួយនឹងបដិសន្ធិជាត្រៃហេតុកកើតអំពីកម្មចាស់ ដែលបានកសាងទុកមកក្នុងអតីតកាល ។

[8] វិបស្សនាបញ្ញា បញ្ញាដែលសម្រេចមកអំពីពិចារណាឃើញតាមពិតក្នុងបច្ចុប្បន្ននេះ ។

[9] បញ្ញានេះ គឺ បារិហារិកប្បញ្ញាហ្នឹងឯង ។

[10] បណ្ដាញ គឺតណ្ហាដែលជាគ្រឿងចាក់ស្រេះ ។

# សេចក្ដីពន្យល់អំពីសីល

១- **ចេតនា សីលំ** ចេតនាជាតួសីល ព្រះពុទ្ធដីកាថា: " **ចេតនាហំ ភិក្ខវេ សីលំ វទាមិ** " ម្នាលភិក្ខុទាំងឡាយ តថាគត ហៅចេតនាថាជាតួសីល ។ ចេតនាមានន័យថា ធម្មជាតិអ្នកគិត, អ្នកចាត់ចែង, អ្នកសន្សំ វិគ្គហថា: "**អភិសង្ខហាតីតិ ចេតនា**" ធម្មជាតិចាត់ចែងហៅថា: ចេតនា បានសេចក្ដីថា ធម្មជាតិដែលញ៉ាំងសម្បយុត្តធម៌ គឺចិត្តនិងចេតសិក ដែលប្រកបជាមួយឲ្យហូរចុះទៅក្នុងសីល ។

ការគិត គំនិត ការចាត់ចែងរបស់បុគ្គលវៀរចាកបញ្ចវេរា គឺសម្លាប់សត្វ ១, ការកាន់យកទ្រព្យសម្បត្តិដែលគេមិនបានឲ្យ ១, ការប្រព្រឹត្តិខុសក្នុងកាម ១, ការពោលពាក្យកុហក ១, ការផឹកនូវទឹកស្រវឹង មានស្រា និង មេរ័យ ១, តាមផ្លូវកាយ ឬផ្លូវវាចា ហៅថា សីល ។

ម្យ៉ាងទៀត ចេតនាក្នុងកម្មបថ ៧ យ៉ាង គឺ**កាយកម្ម** ៣ និង **វចីកម្ម** ៤ របស់បុគ្គល កាលលះបង់នូវអំពើ មានកិរិយាញ៉ាំងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លងគឺសម្លាប់សត្វជាដើម ក៏ហៅថា សីល ។ **កាយកម្ម** ៣, **វចីកម្ម** ៤ ចូរមើលត្រង់កុសលកម្មបថ ១០ ក្នុងសៀវភៅនេះ ។

ម្យ៉ាងទៀត ការគិត គំនិត ការចាត់ចែងរបស់បុគ្គល អ្នករក្សាឧបោសថសីល (សីល ៨) ក្ដី សីល ១០ ក្ដី ការលះបង់នូវអំពើមានបាណាតិបាត (សម្លាប់សត្វ) ជាដើម ហៅថាសីល ។

ម្យ៉ាងទៀត ការគិត គំនិត ការចាត់ចែងរបស់បុគ្គល កាលបំពេញនូវវត្តប្រតិបត្តិ មាន**ឧបជ្ឈាយវត្ត** ដោយកាយ, វាចា, អាចរិយវត្តជាដើម ក្នុងព្រះពុទ្ធសាសនានេះ ក៏ហៅថាសីល ។

**២- ចេតសិកំ សីលំ** ចេតសិកជាតួសីល ចេតសិកមានន័យថា ធម្មជាតិមានសេចក្តីកើត និងសេចក្តីរលត់ និងអារម្មណ៍ និងវត្ថុជាមួយគ្នាដោយចិត្ត ហៅថាចេតសិក តែក្នុងទីនេះបានដល់ធម៌ ៣ យ៉ាងគឺ:

១- **អនភិជ្ឈា** ការមិនសម្លឹងរំពៃចង់បានទ្រព្យរបស់គេមកធ្វើជាទ្រព្យរបស់ខ្លួន ដែលជាអលោភចេតសិក ។

២- **អព្យាបាទោ** ការមិនចងគំនុំចង់ឲ្យសត្វដទៃវិនាស ដែលជាអទោសចេតសិក ។

៣- **សម្មាទិដ្ឋិ** ការយល់ឃើញត្រូវ ដែលជាអមោហចេតសិក ហៅថាសីល ដូចមានព្រះពុទ្ធដីកាជាដើមថា "ចេតសិកសីលំ នាម អភិជ្ឈំ បហាយ វិគតាភិជ្ឈេន ចេតសា វិហរតិ" បុគ្គលលះបង់នូវអភិជ្ឈាមានចេតនាដែលមានអភិជ្ឈាទៅប្រាសហើយ គង់នៅឈ្មោះថា ចេតសិកសីល។

**៣- សំវរោ សីលំ** សេចក្តីសង្រួមជាតួសីល សេចក្តីសង្រួម ៥ យ៉ាងគឺ:

១- **បាតិមោក្ខសំវរោ** សេចក្តីសង្រួមនូវកាយ វាចា ទៅតាមសិក្ខាបទដែលមាននៅក្នុងបាដិមោក្ខ បានដល់ **បារាជិក** ៤, **សង្ឃាទិសេស** ១៣, **អនិយត** ២, **និស្សគ្គិយបាចិត្តិយ** ៣០, **សុទ្ធិកបាចិត្តិយ** ៩២, **បាដិទេសនីយ** ៤, **សេក្ខិយវត្ត** ៧៥, **អធិករណសមថ** ៧, **រួមជា** ២២៧ និងសេចក្តីសង្រួមនូវ**កាយ វាចា** មិន

ប្រព្រឹត្តកន្លងនូវសិក្ខាបទ ដែលព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយ ខាងក្រៅបាតិមោក្ខបានដល់ពួកសិក្ខាបទ ដែលជាពួក**ថុល្លច្ចយាបត្តិ**, **ទុក្កដាបត្តិ**, **ទុព្ភា-សិតាបត្តិ** សីលនេះជា **បាតិមោក្ខសំវរសីល** ។

២- **សតិសំវរោ** សេចក្ដីសង្រួមសតិ បានដល់ការសង្រួមឥន្ទ្រិយទាំង ៦ គឺ **ចក្ខុន្ទ្រិយ** ១, **សោតន្ទ្រិយ** ១, **ឃានិន្ទ្រិយ** ១, **ជិវ្ហិន្ទ្រិយ** ១, **កាយិន្ទ្រិយ** ១ **មនិន្ទ្រិយ** ១, គឺជាការសង្រួមស្មារតីតាមផ្លូវភ្នែក-ត្រចៀក-ច្រមុះ-អណ្ដាត-កាយ និងចិត្ត ហាមឃាត់មិនឲ្យអកុសលធម៌ គឺអភិជ្ឈា និងទោមនស្ស និងបាបធម៌កើតឡើងគ្របសង្កត់ចិត្តបាន ក្នុងខណៈដែលមានអារម្មណ៍ មានរូបា-រម្មណ៍ជាដើម មកប៉ះខ្ទប់នឹងទ្វារ មានចក្ខុទ្វារជាដើម ។ សីលនេះជា **ឥន្ទ្រិយសំវរ-សីល** ។

៣- **ញាណសំវរោ** សេចក្ដីសង្រួមញាណ (ការដឹង) បានដល់ប្រាជ្ញាដែលតម្កល់ដោយប្រពៃ ពិចារណាក្នុងការប្រើប្រាស់នូវបច្ច័យ ៤ គឺ: **ចីវរប្បច្ច័យ** ១, **បិណ្ឌបាតបច្ច័យ** ១, **សេនាសនបច្ច័យ** ១, **គិលានភេសជ្ជបច្ច័យ** ១, តាមសមគួរដល់ធម៌នៃការប្រើប្រាស់បច្ច័យ របស់អ្នកបួសមាន**ធាតុបច្ចវេក្ខណៈ**ជាដើម ។ សីលនេះជា **បច្ចយសន្និស្សិតសីល** ។

៤- **ខន្តិសំវរោ** សេចក្ដីសង្រួមក្នុងការអត់ទ្រាំគ្រប់យ៉ាងចំពោះត្រជាក់និងក្ដៅ លោកធម៌ ៨ គឺ **លាភ** ១, **អលាភ** ១, **យស** ១, **អយស** ១, **និន្ទា** ១, **សរសើរ** ១, **សុខ** ១, **ទុក្ខ** ១ ជាដើម ដែលកើតឡើងដល់ខ្លួន ។

៤- **វីរិយសំវរោ** សេចក្តីសង្រួមនូវការព្យាយាម បានដល់ការព្យាយាមអត់សង្កត់កម្ចាត់បង់នូវ **អកុសលវិតក្កៈ** ៣ គឺ **កាមវិតក្កៈ** សេចក្តីត្រិះរិះពីកាម ១, **ព្យាបាទវិតក្កៈ** សេចក្តីត្រិះរិះពីព្យាបាទ ១, **វិហិង្សាវិតក្កៈ** សេចក្តីត្រិះរិះបៀតបៀនសត្វ ១, ដែលកើតឡើងគ្របសង្កត់ចិត្ត ។ មួយ៉ាងទៀតសេចក្តីបរិសុទ្ធនៃការរស់នៅរបស់អ្នកបួស ដោយការលះបង់នូវ **ចាបជម៌** ៤ និង **អនេសនៈ** ២១ ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ក្នុង **អាជីវចារិសុទ្ធិ-សីល** ក៏រាប់សង្គ្រោះក្នុង **វីរិយសំវរៈ** នេះដែរ ។

សេចក្តីសំរួម ៥ យ៉ាង និងចេតនាវៀរចាកចំពោះវត្ថុដែលដល់ព្រមរបស់កុលបុត្ត ដែលជាអ្នកភ័យខ្លាចក្នុងបាប ក៏ហៅថាសំវរសីលទាំងអស់ ។

៤- **អវីតិក្កមោ សីលំ:** ការមិនប្រព្រឹត្តិកន្លងជាតួសីល បានដល់ការមិនប្រព្រឹត្តិកន្លង ដែលប្រកបដោយកាយវាចារបស់បុគ្គល ដែលបានសមាទានសីល មានសីល ៥, សីល ៨, សីល ១០, ហ្នឹងឯង ។ ឧបាសក ឧបាសិកា ដែលបានសមាទានសីលអំពីបុគ្គល ឬគណៈ ឬព្រះសង្ឃហើយ ក៏ប្រឹងសង្រួមកាយវាចាដោយប្រពៃតាមសិក្ខាបទ ៥, ៨, ១០, ដែលខ្លួនបានសមាទានហើយ គឺមិនប្រព្រឹត្តកន្លងនូវសិក្ខាបទណាមួយឡើយ។ សីលរបស់ឧបាសក ឧបាសិកា ដែលកើតឡើងនេះឯងហៅថា **អវីតិក្កមសីល** ។

## ការបែងចែកសីលតាមប្រភេទអ្នកកាន់

សីលទាំងអស់ដែលបានពោលរួចហើយ បើនឹងបែងចែកតាមប្រភេទ តាមថ្នាក់ របស់បុគ្គលអ្នកសមាទានកាន់យកដោយសទ្ធា ឃើញថាមាន ៤ យ៉ាងគឺ សីល ៥, សីល ៨, សីល១០, សីល ៤ ដោយពិត ។

**សីល ៥** និង**សីល ១០** ហៅថា **និច្ចសីល** គឺជាសីលដែលបុគ្គលអ្នកសមាទាន ត្រូវរក្សារៀងរាល់ថ្ងៃ រាល់ពេលវេលាជានិច្ចតាមសទ្ធា បើខ្លួនត្រូវរក្សាសីលនោះប៉ុន្មានថ្ងៃ ឬប៉ុន្មានខែ ឬរហូតអស់ជីវិត ក៏ត្រូវរក្សាសីលនោះដែលខ្លួនបានសមាទានកាន់យកហើយ រហូតគ្រប់ពេលវេលា រាល់ថ្ងៃ រាល់ខែ ឬរហូតអស់ជីវិត តាមការកំណត់ ឥតមានពេលវេលាឬ ថ្ងៃ ឬខែណាចន្លោះឡើយ

**សីល ៨** ហៅថា **ឧបោសថសីល** ជាសីលដែលបុគ្គលអ្នកសមាទាន ត្រូវរក្សាតាមវេលានៃថ្ងៃឧបោសថ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់បញ្ញត្តហើយ ។

**សីល ៤** ហៅថា **អធិសីល** ជាសីលដ៏ក្រៃលែងរបស់**ភិក្ខុ** និង **ភិក្ខុនី** ដែលជាញត្តិសីល។ រីឯសីលរបស់សាមណេរវិញក៏មានសភាពដូចជាសីលរបស់ភិក្ខុដែរ គ្រាន់តែសីលរបស់សាមណេរមានសិក្ខាបទតិចជាងសិក្ខាបទរបស់ភិក្ខុ។

សីល របស់សាមណេរ គឺ សាមណេរត្រូវសង្រួមតាម**សិក្ខាបទ ១០** [11] **ទណ្ឌកម្ម ១០**, **នាសនង្គ ១០**, **សេខិយវត្ត ៧៥** និងសិក្ខាបទជា **លោកវជ្ជ ៤៩** ដែលមានក្នុង **បាតិមោក្ខ** របស់ភិក្ខុដែរ ។

សាមណេរក៏ត្រូវមានការសង្រួមនូវឥន្ទ្រិយ ៦ មានចក្ខុន្ទ្រិយជាដើម មានការចិញ្ចឹមជីវិតដ៏ស្អាត លះបង់នូវធមិដ៏លាមក ដែលជាសត្រូវដល់កុសលធម៌. មានការពិចារណាក្នុងការប្រើប្រាស់នូវបច្ច័យ ៤ មាន **ធាតុបច្ចវេក្ខណៈ**ជាដើមដូចភិក្ខុដែរ ។

---

[11] មើលក្នុងសាមណេរវិន័យ ។

# អត្ថន័យរបស់សីល

សីលមានន័យថា ទម្លាប់ ឬប្រក្រតី ដោយសេចក្តីពីរយ៉ាងគឺ:

១- **សមាធាន:** កិរិយាតម្កល់ដោយប្រពៃ ។

២- **ឧបធារណៈ:** កិរិយាចូលទៅទ្រទ្រង់ ។

## សេចក្តីពន្យល់អំពីអត្ថរបស់សីល

**សមាធាន:** កិរិយាតម្កល់ដោយប្រពៃ មានសេចក្តីថា ភាពមិនរាត់រាយនៃកាយកម្ម វចីកម្ម មនោកម្ម ដោយអំណាចនៃខ្លួនជាអ្នកមានសីលល្អបរិសុទ្ធ។

**ឧបធារណៈ:** កិរិយាចូលទៅទ្រទ្រង់ មានសេចក្តីថា: ភាពទ្រទ្រង់ដោយអំណាចនៃការតម្កល់នូវធម៌ជាកុសលទាំងឡាយ កុសលទាំងនោះទុកជា ***វដ្ដចារកុសល***ក្តី ដែលតាំងនៅស្ថិតស្ថេរបានអាស្រ័យមានសីលជាឫសគល់ បើគ្មានសីលជាឫសគល់ទេ កុសលទាំងអស់នោះក៏រលត់រលាយបាត់ទៅ ព្រោះហេតុដូច្នោះ សាធុជនអ្នកចង់បានសេចក្តីសុខ ដែលត្រូវញ៉ាំងកុសលជា ***វដ្ដចារ*** ឬ***លោកុត្តរ*** ឲ្យកើតឡើងក្នុងសន្តាននៃខ្លួន ក៏គប្បីជម្រះសីលដែលខ្លួនបានសមាទានហើយឲ្យស្អាត បរិសុទ្ធផូរផង់ កុំគប្បីឲ្យមានសេចក្តីសៅហ្មងឡើយ ។

##ម្យ៉ាងទៀតមានសេចក្តីដទៃទៀតថា:

- ***សិរដ្ឋោ*** សីលមានអត្ថថា កំពូល ។
- ***សីសដ្ឋោ*** សីលមានអត្ថថាក្បាល ។

- **សីតលដ្ឋោ** សីលមានអត្ថថា ត្រជាក់ ។

- **សិរដ្ឋោ** សីលមានអត្ថថា ក្បេមក្សាន្ត ។

**សិរដ្ឋោ** មានអត្ថថា កំពូល មានសេចក្តីថា:

សីលជាគុណជាតិមួយ ជាគ្រឿង ប្រក់រក្សាទុកនូវកុសលដទៃមានកុសលថ្នាក់**សមាធិ** ឬកុសលថ្នាក់**វិបស្សនា**ជាដើម ព្រោះហេតុថាកុសលទាំងអស់នោះកាលបើគ្មានសេចក្តីសង្រួមគឺសីលជាខាងដើមទេ នោះក៏មិនកើតឡើងបាន ។

ប្រសិនណាបើកុសលទាំងអស់នោះ បានកើតឡើងហើយ ដោយមានសីលជាហេតុខាងដើម តែដល់ពេលក្រោយ សីលជាគ្រឿងប្រក់រក្សាទុករលត់បាត់ទៅ កុសលទាំងអស់នោះក៏ត្រូវសាបសូន្យត្រឡប់ទៅវិញដែរ ។

មានសេចក្តីថា ផ្ទះកាលបើកំពូលនៃផ្ទះដែលគេបិទបាំងជិតល្អហើយ អ្វីៗ ក្នុងផ្ទះ ឬតួគ្រឿងផ្ទះទាំងមូលក៏ត្រូវតាំងនៅស្ថិតស្ថេរ មិនខូចមិនពុកផុយរលួយដោយទឹកភ្លៀងនិងកម្តៅថ្ងៃ តែបើកំពូលនៃផ្ទះត្រូវលិចបាក់បែកខូចអស់ វត្ថុអ្វីក្នុងផ្ទះទាំងអស់ ឬតួគ្រឿងផ្ទះទាំងមូល ក៏ត្រូវខូចពុកផុយរលួយជាបន្តបន្ទាប់ដោយត្រូវទឹកភ្លៀងនិងកម្តៅថ្ងៃ មានសេចក្តីឧបមាយ៉ាងណា កុសលទាំងអស់មានកុសលថ្នាក់**សមាធិ**ជាដើម តែងតែកើតនិងចម្រើនឡើងព្រោះអាស្រ័យនឹងសីលមែនពិត ។

កាលបើសីលជាគ្រឿងប្រក់រក្សាទុកវិនាសហើយ កុសលទាំងអស់នោះក៏វិនាសសាបសូន្យអស់ទៅ តាមសេចក្តីឧបមេយ្យ ក៏យ៉ាងនោះ ។

**សីសដ្ឋោះ** សីលមានអត្ថថា ក្បាល មានសេចក្ដីថា ធម្មតារាងកាយនៃមនុស្សទាំងមូលដែលអាចរស់នៅបានដោយអាស្រ័យមានក្បាលជាធំ ព្រោះក្បាលជាទីអាស្រ័យនៅនៃភ្នែកផង ត្រចៀកផង ច្រមុះផង អណ្ដាតផង មនុស្សតែងដកដង្ហើមចេញចូលតាមច្រមុះ, ទំពាស៊ីភោជនមានបាយនិងទឹកជាដើមដើម្បីចិញ្ចឹមសរីរៈទាំងមូលតាមផ្លូវអណ្ដាត, គិតការងារអ្វី ៗ អាស្រ័យនឹងការិយាល័យ គឺខួរក្បាល មានការរស់នៅយ៉ាងសុខស្រួលត្រជាក់ត្រជុំមែនពិត, សត្វទាំងឡាយបានសេចក្ដីត្រជាក់កាយ ត្រជាក់ចិត្តរស់នៅសុខស្រួល ក៏ព្រោះតែក្បាលហ្នឹងឯង សត្វទាំងឡាយ ប្រសិនបើគ្មានក្បាលទេនោះ ក៏ត្រូវស្លាប់អស់ជីវិតទៅ មានសេចក្ដីឧបមាយ៉ាងណា, កុសលទាំងអស់ក្នុងព្រះពុទ្ធសាសនាមានកុសលថ្នាក់ **សមាធិ បញ្ញា** និង **លោកុត្តរ** ដែលកើតឡើង និងមានការប្រព្រឹត្តិរីកចម្រើនទៅបានក៏ព្រោះតែសីល កាលបើគ្មានសីលហើយកុសលទាំងនោះក៏ត្រូវរលត់សាបសូន្យទៅ ក៏មានសេចក្ដីឧបមេយ្យយ៉ាងនោះដែរ ។

**សីតលដ្ឋោះ** សីលមានអត្ថថា ត្រជាក់ មានសេចក្ដីថា សីលជាគុណជាតិមួយបដិបក្ខនឹងទោសៈ កាលបើសីលកើតឡើងក្នុងសន្ដានចិត្តហើយ ទោសៈ (ធម្មជាតិប្រទូស្តក្នុងអារម្មណ៍) ក៏រលត់ទៅ **កិលេស** គឺ**ទោសៈ**នេះហើយ ដែលជាតួភ្លើងមួយ តែងដុតកម្ដៅនូវចិត្តសត្វ ឲ្យក្ដៅក្រហាល់ក្រហាយឆេះឡើងបណ្ដោយឲ្យសត្វទាំងឡាយសាងនូវអំពើបាបប្រកបដោយ កាយ វាចា ចិត្ត មានការសម្លាប់សត្វ ជេរ ប្រទេចជាដើម ដែលឲ្យផលជាទុក្ខក្នុងសង្សារវដ្ដ ។

សព្វសត្វទាំងអស់ កាលបើបានធ្វើនូវសេចក្តីសង្រួម**កាយ វាចា ចិត្ត** ឲ្យផុតចាកបាបកម្ម ជាអ្នកមិនមានទោសៈ មានចិត្តស្ងប់ស្រួល, កាយកម្មក៏ស្ងប់, វចីកម្មក៏ស្ងប់, មនោកម្មក៏ស្ងប់, ម្ល៉ោះហើយសព្វសត្វទាំងនោះ ក៏ដល់នូវការត្រជាក់សុខស្រួល ផុតចាកពៀរវេរាគ្រប់យ៉ាងដែលកើតអំពីបាបកម្ម រស់នៅជាសុខក្នុងបច្ចុប្បន្នជាតិនេះនឹងបានសុខស្រួលតទៅក្នុងលោកខាងមុខថែមទៀត។

**សិវង្គោ:** សីលមានអត្ថថា ក្សេមក្សាន្ត ព្រះពុទ្ធដីកាទ្រង់សម្តែងថាៈ

"**សីលេន និព្វុតឹ យន្តិ** សត្វទាំងឡាយទៅដល់ព្រះនិព្វានជាទីរលត់បង់នូវសេចក្តីទុក្ខគ្រប់យ៉ាងក៏ព្រោះតែសីល"

ព្រះនិព្វានជាទីសុខក្សេមក្សាន្ត ចាកសេចក្តីទុក្ខគ្រប់យ៉ាង ព្រះយោគាវចរដែលបានដល់ទីនោះ មិនមែនបានដល់ដោយហេតុដទៃឡើយ តាមសេចក្តីពិតនោះ យោគាវចរដែលបានដល់នូវព្រះនិព្វាន ដោយអាស្រ័យសេចក្តីប្រតិបត្តិក្នុង**សមថវិបស្សនាកម្មដ្ឋាន** ដែលមានការរក្សាសីលជាហេតុហ្នឹងឯង ។

- ម្យ៉ាងទៀត សូម្បីសត្វទាំងឡាយដែលនៅអន្ទោលទៅអន្ទោលមកក្នុងភពបី ដែលបានទទួលសោយនូវសេចក្តីសុខដោយច្រើន ក៏ព្រោះអាស្រ័យដោយការរក្សាសីលជាហេតុ ដូចពុទ្ធដីកាថា "**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា**" សត្វទាំងឡាយទៅកាន់សុគតិ ក៏ព្រោះតែសីល, ការបរិបូណ៌ដោយភោគសម្បត្តិ ក៏ព្រោះតែសីល ។

- សត្វទាំងឡាយដែលមិនបានសេចក្តីសុខ តែងជួបនូវសេក្តីទុក្ខលំបាក និងមហន្តរាយ គឺសេចក្តីវិនាសដ៏ធំ មានការកើតក្នុង **មហានរក ប្រេត អសុរកាយ តិរិច្ឆាន** ព្រោះហេតុតែគ្មានសីលហ្នឹងឯង សត្វទាំងឡាយដែលកើតក្នុងភពហើយ បានសោយនូវទោស ៥ យ៉ាងគឺ អាយុខ្លី ១, វិនាសទ្រព្យ ១, ខ្ជីយ ឬច្រើនដោយការជាប់ទោសអំពីសំណាក់នៃជនដទៃ ១, ការពោលបង្កាច់បង្ខូចចំពោះពាក្យដែលខ្លួនពោលពិតហើយ ១, ការឆ្កួតលីលាវង្វេង ១, ព្រោះទោស គឺការប្រព្រឹត្តិនូវបញ្ចវេរាជាហេតុ ក៏ពៀរ ៥ យ៉ាងនោះគឺ:

- សម្លាប់សត្វ ១ ។
- កាន់យកទ្រព្យសម្បត្តិដែលគេមិនបានឲ្យ ១ ។
- ប្រព្រឹត្តខុសក្នុងកាម ១ ។
- ពោលពាក្យកុហក ១ ។
- ផឹកទឹកស្រវឹង ១ ។

កាលបើសត្វទាំងឡាយក្នុងភពបានរក្សាសីលឲ្យបរិសុទ្ធជានិច្ច ជាសីលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុះហើយក្នុងជាតិនីមួយ ៗ ដែលខ្លួនកើតហើយគ្រប់ ៗ ជាតិ សត្វទាំងនោះក៏រស់នៅជាសុខក្សេមក្សាន្តក្នុងភព ព្រោះអាស្រ័យបានរួចចាកពៀរទាំង ៥ ហ្នឹងឯង ។

ដោយអាស្រ័យសេចក្តីអធិប្បាយប៉ុណ្ណេះជាដើម ទើបលោកពោលថា **សិវង្គោ** សីលមានអត្ថថា ក្សេមក្សាន្ត ។

## លក្ខណៈ, រស, អាការប្រាកដ,ហេតុជិត របស់សីល

*សីលៈ* មានសេចក្តីថា ប្រក្រតីជាលក្ខណៈ

## សេចក្តីពន្យល់

ពាក្យថា **សីលន** ប្រក្រតីនេះ គឺលោកពោលហើយ ដោយអំណាចនៃការតម្កល់ដោយប្រពៃនូវកម្ម មានកាយកម្មជាដើម ១ ដោយអំណាចនៃការតម្កល់នូវកុសលធម៌ ១ ។

ពាក្យថា **កិច្ច** ឬ **សម្បត្តិ** លោកហៅថា រសរបស់សីល ។

*សីលៈ* មានកិរិយាកម្ចាត់បង់នូវភាពទ្រុស្តសីលជាកិច្ច ។

*សីលៈ* មានគុណ គឺការមិនមានទោសជាសម្បត្តិ ។

*សីលៈ* មានភាពស្អាត ជាអាការប្រាកដ គឺផល ។

### ភាពស្អាតមាន ៣ យ៉ាងគឺ

១- **កាយសោចេយ្យ** ភាពស្អាតកាយ ។

២- **វចីសោចេយ្យ** ភាពស្អាតវាចា ។

៣- **មនោសោចេយ្យ** ភាពស្អាតចិត្ត ។

### សីលមានធម៌ ២ យ៉ាងជាបទដ្ឋាន (ហេតុជិត)

១- **ហិរិ** សេចក្តីខ្មាស់បាប

២- **ឱត្តប្ប** សេចក្ដីតក់ស្លុតនឹងអំពើបាប ។

តាមសេចក្ដីពិតថា កាលដែលហិរិ និងឱត្តប្បមាន សីលរមែងកើតឡើងផង ស្ថិតនៅផង តែបើហិរិនិងឱត្តប្បមិនមានទេនោះ សីលក៏មិនកើតឡើងមិនស្ថិតនៅ។

## អានិសង្សរបស់សីល

សីលរបស់បុគ្គលដែលបានសមាទានហើយ ដុសខាត់ឲ្យស្អាតផូរផង់ បរិសុទ្ធ នឹងមានអានិសង្សច្រើន ក្នុងគម្ពីរវិសុទ្ធិមគ្គមានសេចក្ដីថា កាលបើសីលបរិសុទ្ធហើយ ជាបច្ច័យកើតឡើងអវិប្បដិសារៈ សេចក្ដីមិនក្ដៅក្រហាយស្ដាយក្រោយ ។

- កាលបើអវិប្បដិសារៈកើតឡើងហើយ ជាបច្ច័យឲ្យកើត ចាមោជ្ជៈ សេចក្ដីរីករាយទន់, កាលបើ ចាមោជ្ជៈ កើតឡើងហើយ ជាបច្ច័យឲ្យកើត **បីតិ** សេចក្ដីឆ្អែតចិត្ត, កាលបើ **បីតិ** កើតឡើងហើយ ជាបច្ច័យឲ្យកើត បស្សទ្ធិ សេចក្ដីស្ងប់កាយស្ងប់ចិត្ត, កាលបើ បស្សទ្ធិ កើតឡើងហើយ ជាបច្ច័យឲ្យកើត សុខ សេចក្ដីស្រួល **កាយ-ចិត្ត** កាលបើសុខកើតឡើងហើយ ជាបច្ច័យឲ្យកើត **សមាធិ** ការតម្កល់ចិត្តនឹង កាលបើ**សមាធិ**កើតឡើងហើយ ជាបច្ច័យឲ្យកើត**យថាភូត-ញ្ញាណទស្សន** ប្រាជ្ញាដែលដឹងច្បាស់ឃើញច្បាស់នូវធម៌តាមពិត, កាលបើ **យថាភូតញ្ញាណទស្សន** កើតឡើងហើយ ជាបច្ច័យឲ្យកើត **និព្វិទា** សេចក្ដីនឿយណាយ កាលបើ**និព្វិទា**កើតឡើងហើយ ជាបច្ច័យកើត **វិរាគ** ការប្រាសចាកតម្រេក, កាលបើ **វិរាគ** កើតឡើងហើយ ជាបច្ច័យឲ្យកើត **វិមុត្តិ** ការរួចផុតស្រឡះចាកកិលេស. កាលបើ **វិមុត្តិ** កើតឡើងហើយ ជាបច្ច័យឱ្យ **វិមុត្តិញ្ញាណ-ទស្សន** ប្រាជ្ញាដឹងច្បាស់ឃើញច្បាស់ថា រួចផុតស្រឡះចាកកិលេស។

## អានិសង្សសីលមានចំនួន ៥ ប្រការដទៃទៀតថា:

១- សីលវា សីលសម្បន្នោ អប្បមាទាធិការណំ មហន្តំ ភោគក្ខន្ធំ អធិគច្ឆតិ បុគ្គលអ្នកមានសីល មានសីលបរិបូណ៌ រមែងបាននូវគំនរភោគសម្បត្តិដ៏ច្រើន ដែលមានសេចក្តីមិនប្រមាទជាហេតុ ។

២- សីលវតោ សីលសម្បន្នស្ស កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ កល្យាណកិត្តិសព្ទរបស់អ្នកមានសីល មានសីលពេញលេញ រមែងផុសផុលឡើង ។

៣- សីលវា សីលសម្បន្នោ យញ្ញទេវ បរិសំ ឧបសង្កមតិ យទិ ខត្តិយបរិសំ យទិ ព្រាហ្មណបរិសំ យទិ គហបតិបរិសំ យទិ សមណបរិសំ វិសារទោ ឧបសង្កមតិ អមង្កុភូតោ ។ អ្នកមានសីល មានសីលពេញលេញបរិបូណ៌ រមែងចូលទៅកាន់បរិស័ទណាមួយ ទុកជាខត្តិយបរិស័ទក្តី ព្រាហ្មណបរិស័ទក្តី គហបតីបរិស័ទក្តី សមណបរិស័ទក្តី ជាអ្នកក្លៀវក្លា មិនអៀនអន់ចូលទៅរក ។

៤- សីលវា សីលសម្បន្នោ អសម្មុឡ្ហោ កាលំ ករោតិ អ្នកមានសីល មានសីលពេញបរិបូណ៌ ជាអ្នកមិនវង្វេងធ្វើកាលកិរិយា ( ស្លាប់ ) ។

៥- សីលវា សីលសម្បន្នោ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ អ្នកមានសីល មានសីលពេញបរិបូណ៌ បន្ទាប់អំពីបែកធ្លាយកាយទៅ រមែងចូលទៅកើតក្នុងសុគតិសួគ៌ទេវលោក ។

*សីលៈ* បើចែកតាមប្រភេទឃើញថា មានច្រើនពួក ក្នុងគម្ពីរវិសុទ្ធិមគ្គភាគ ១ មាននិយាយរហូតដល់សីល ៥ ពួក ក្នុងពួកមួយ ៗ មានការបែងចែកច្រើនប្រការទៅទៀត តែក្នុងទីនេះ សូមលើកយកតែសីលត្រង់ពួក ៤ ទី ២ មកសម្តែងដោយសេចក្តីសង្ខេប ។

## សីលមាន ៤ យ៉ាងគឺ

១- *ភិក្ខុសីលំ* សីលរបស់ភិក្ខុ ។
២- *ភិក្ខុនីសីលំ* សីលរបស់ភិក្ខុនី ។
៣- *អនុបសម្បន្នសីលំ* សីលរបស់សាមណេរ និងសាមណេរី ។
៤- *គហដ្ឋសីលំ* សីលរបស់គ្រហស្ថ ។

## សេចក្តីពន្យល់អំពីសីល ៤ យ៉ាង

សិក្ខាបទទាំងឡាយ ដែលព្រះដ៏មានព្រះភាគប្រារព្ធចំពោះពួកភិក្ខុ ហើយទ្រង់បញ្ញត្តឡើង សិក្ខាបទទាំងនោះ គឺពួកភិក្ខុត្រូវរក្សាប្រព្រឹត្តឲ្យល្អមិនឲ្យទាស់ខុស សីលដែលកើតឡើងដោយការសង្រួមតាម **ពុទ្ធប្បញ្ញត្តិ** និង **ពុទ្ធានុញ្ញាត** ហៅថាសីលរបស់ភិក្ខុ ។

សិក្ខាបទទាំងឡាយ ដែលព្រះដ៏មានព្រះភាគទ្រង់ប្រារព្ធនឹងពួកភិក្ខុនី ហើយទ្រង់បញ្ញត្តឡើង សិក្ខាបទទាំងនោះគឺ ពួកភិក្ខុនីត្រូវរក្សាប្រព្រឹត្តឲ្យល្អមិនអាចទាស់ខុស សីលដែលកើតឡើង ដោយការសង្រួមតាមសិក្ខាបទ ដែលហាមប្រាម ឬ **អនុញ្ញាត** ហៅថា **ភិក្ខុនីសីល** ។

សីលទាំងឡាយ ១០ មានការវៀរចាកធ្វើសត្វមានជីវិតឲ្យធ្លាក់កន្លងគឺសម្លាប់សត្វជាដើម របស់សាមណេរនិងសាមណេរី ហៅថា **អនុបសម្បន្នសីល** ។

សិក្ខាបទ ៥ ក្តី, សិក្ខាបទ ១០ ក្តី, សិក្ខាបទ ៨ ដោយអំណាចនៃអង្គឧបោសថក្តី សីលដែលកើតឡើងដោយការសង្រួម តាមសិក្ខាបទទាំងនេះ ហៅថា **គហដ្ឋសីល** ។

## សិក្ខាបទ និងសីល

ពាក្យថា **សិក្ខាបទ** និងសីលមានសេចក្តីផ្សេងគ្នាដូចតទៅនេះ

សិក្ខាបទមានន័យថា **វិនយបញ្ញត្តិ** ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់លើកឡើងជាមាត្រាមួយ ៗ មានសិក្ខាបទ ៥ ដែលទ្រង់សម្តែងហើយ ដោយអំណាចនៃសីល ៥ សិក្ខាបទ ១០ ទ្រង់សម្តែងដោយអំណាចនៃសីល ១០. សិក្ខាបទ ៨ ទ្រង់សម្តែងដោយអំណាចនៃអង្គឧបោសថជាដើម ។ សីលបានដល់ធម៌មាន **វិរតិចេតនា** ជាដើមដែលប្រព្រឹត្តទៅតាមសិក្ខាបទដែល ព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងហើយ ។

## សិក្ខាបទ ៥

### ១- បាណាតិបាតា វេរមណី

ចេតនាជាហេតុវៀរចាក កិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លងគឺសម្លាប់សត្វ ។

### ២- អទិន្នាទានា វេរមណី

ចេតនាជាហេតុវៀរចាក កិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យដោយកាយ ឬដោយវាចា ។

៣- កាមេសុ មិច្ឆាចារា វេរមណី

ចេតនាជាហេតុវៀរចាក កិរិយាប្រព្រឹត្តិខុសក្នុងកាមទាំងឡាយ ។

៤- មុសាវាទា វេរមណី

ចេតនាជាហេតុវៀរចាក កិរិយាពោលនូវពាក្យកុហាក ។

៥ - សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី

ចេតនាជាហេតុវៀរចាក ហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ។

## សិក្ខាបទ ១០

១- បាណាតិបាតា វេរមណី ( ប្រែដូចក្នុងសិក្ខាបទ ៥ ) ។

២- អទិន្នាទានា វេរមណី ( ប្រែដូចក្នុងសិក្ខាបទ ៨ ) ។

៣- អព្រហ្មចរិយា វេរមណី

ចេតនាជាហេតុវៀរចាក កិរិយាប្រព្រឹត្តិធម៌មិនប្រសើរ គឺសេពនូវមេថុនធម្ម ។

៤- មុសាវាទា វេរមណី ( ប្រែដូចក្នុងសិក្ខាបទ ៥ ) ។

៥- សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី ( ប្រែដូចក្នុងសិក្ខាបទ ៥ ) ។

៦- វិកាលភោជនា វេរមណី

ចេតនា ជាហេតុវៀរចាក កិរិយាបរិភោគនូវភោជនាហារក្នុងកាលខុស ។

៧- នច្ចគីតវាទិតវិសូកទស្សនា វេរមណី

ចេតនាជាហេតុវៀរចាកកិរិយារាំ និងច្រៀង និងប្រគំ និងមើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌ ។

៨- មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណី

ចេតនាជាហេតុវៀរចាកកិរិយាទ្រទ្រង់ និងប្រដាប់តាក់តែងនិងស្អិតស្អាង ( រាងកាយ ) ដោយផ្កាកម្រងនិងគ្រឿងក្រអូប និងគ្រឿងលាបផ្សេង ៗ ។

៩- ឧច្ចាសយនមហាសយនា វេរមណី

ចេតនាជាហេតុវៀរចាកទីសេនាសនៈ ដ៏ខ្ពស់ហួសប្រមាណ និង សេនាសនៈដ៏ប្រសើរ ។

១០- ជាតរូបរជតប្បដិគ្គហណា វេរមណី

ចេតនាជាហេតុវៀរចាក កិរិយាទទួលកាន់យកនូវមាស និង ប្រាក់ដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យទទួលកាន់យកហើយត្រេកអរចំពោះមាស និងប្រាក់នោះ ។

## សិក្ខាបទ ៨

១- បាណាតិបាតា វេរមណី ( ប្រែដូចក្នុងសិក្ខាបទ ៥ ) ។

២- អទិន្នាទានា វេរមណី ( ប្រែដូចក្នុងសិក្ខាបទ ៥ ) ។

៣- អព្រហ្មចរិយា វេរមណី ( ប្រែដូចក្នុងសិក្ខាបទ ១០ ) ។

១- **មុសាវាទា វេរមណី** ( ប្រែដូចក្នុងសិក្ខាបទ ៥ ) ។

១- **សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី** ( ប្រែដូចក្នុងសិក្ខាបទ ៥ ) ។

១- **វិកាលភោជនា វេរមណី** ( ប្រែដូចក្នុងសិក្ខាបទ ១០ ) ។

៧- **នច្ចគីតវាទិតវិសូកទស្សនមាលាគន្ធវិលេបនធារណមណ្ឌន-វិភូសនដ្ឋានា វេរមណី**

ចេតនាជាហេតុវៀរចាក កិរិយា រាំ និង ច្រៀង និង ប្រគំ និង មើលនូវល្បែង ដែលជាសត្រូវដល់កុសលធម៌ និងទ្រទ្រង់ និងប្រដាប់តាក់តែងស្អិតស្អាង (រាងកាយ) ដោយផ្កាកម្រងនិងគ្រឿងក្រអូបនិងគ្រឿងលាបផ្សេង ៗ ។

១- **ឧច្ចាសយនមហាសយនា វេរមណី** (ប្រែដូចក្នុងសិក្ខាបទ ១០)។

សិក្ខាបទទាំង ៨ នេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែង ដោយអំណាចនៃអង្គ **ឧបោសថ** ចំពោះ **ឧបាសក ឧបាសិកា** ក្នុងព្រះពុទ្ធសាសនា ។

## ឧបោសថសីល ៣ យ៉ាងគឺ

**ឧបោសថសីល** ជាសីលមួយមានសភាពផ្សេងអំពីសីល ៥ និងសីល ១០ ។ សីល ៥ និង ១០ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហៅថា **និច្ចសីល** ជាសីលរបស់បុគ្គលដែល **សមាទាន** ហើយត្រូវរក្សាជាប់ជានិច្ចរៀងរាល់ថ្ងៃខែឆ្នាំ តាមការកំណត់ដែលខ្លួនមានសទ្ធាត្រូវកាន់យក ។ រី **ឧបោសថសីល** វិញ គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយ ដោយកំណត់តាមកាល ។

ក្នុងគម្ពីរមង្គលត្ថទីបនីភាគ ៣ ត្រង់ អដវជ្ជកម្មកថា មានសេចក្តីថា ឧបោសថមានន័យថា ធមិជាទីនៅអាស្រ័យ ឬជាទីរក្សា (ឧបោសថ) ឧបវសន្តិ ឯត្ថាតិ ឧបោសថោ ឬធមិជាទីកម្ចាត់បង់នូវអកុសល ។ ឧបោសថសីលមាន ៣ យ៉ាងគឺ បកតិឧបោសថ ១ បដិជាគរុបោសថ ១ បាដិហារិយុបោសថ ១

## សេចក្តីពន្យល់អំពីឧបោសថសីល

១- **បកតិឧបោសថ: ឧបោសថ** តាមធម្មតា កាលនៃបកតិឧបោសថនេះ ១ ខែ មាន ៨ ថ្ងៃ គឺ **ជុណ្ហបក្ខ** (បក្សខ្នើត) ៤ថ្ងៃ **កាឡបក្ខ** (បក្សរនោច) មាន ៤ ថ្ងៃ ។ បក្សខ្នើត ៤ ថ្ងៃគឺ: ៥កើត, ៨កើត, ១៤កើត, ១៥កើត, ។ បក្សរនោច ៤ថ្ងៃគឺ: ៥, ៨, ១៤, ១៥រោច ។ ថ្ងៃ **បកតិឧបោសថ** នេះ ក្នុងសម័យពុទ្ធកាលមានតែ ៦ថ្ងៃ. ថ្ងៃ ៥ កើតនិង ថ្ងៃ ៥ រោច ជាកាលនៃការស្តាប់ធមិទេសនាក្នុងពេលនោះ ក្រោយមក**ព្រះធម្មសង្គាហកត្ថេរ**ទាំងឡាយលោក លើកឡើងរាប់បញ្ចូលជាថ្ងៃ **ឧបោសថ** ទើប **បកតិឧបោសថ** មានដល់ ១ ខែ ៨ ថ្ងៃ។

២- **បដិជាគរុបោសថ:** ឧបោសថរបស់បុគ្គលអ្នកភ្ញាក់រលឹក ។ ជនទាំងឡាយ កាលរក្សានូវឧបោសថនេះ រមែងរក្សាដោយអំណាចនៃកិរិយាក្រោកឡើងទទួល និងជូនតាមនៃថ្ងៃបោសថ ចំនួន ៤ ក្នុងកន្លះខែ នៃខែមួយ ។

កាលនៃ **បដិជាគរុបោសថ** មានចំនួន ១១ ថ្ងៃ ក្នុង ១ ខែ ។ **ជុណ្ហបក្ខ** (បក្សខ្នើត) មាន ៥ ថ្ងៃគឺ ៤កើត, ៦, ៧, ៩, ១៣ កើត **កាឡបក្ខ** (បក្សរនោច) បើខែពេញមាន ៦ ថ្ងៃ គឺបាដិបទ (១រោច) ៤, ៦, ៧, ៩, ១៣ រោច កាលបើខែមិនពេញមាន ៦ ថ្ងៃគឺ បាដិបទ (១រោច) ៤, ៦, ៧, ៩, ១២ រោច ។

កាលបើរួមថ្ងៃឧបោសថទាំងពីរត្រូវជាមួយខែ មានថ្ងៃឧបោសថ ១៩ ។ ថ្ងៃដទៃអំពីនោះខែមិនពេញ មាន ១០ ថ្ងៃ ក្នុងមួយខែ គឺ ១ កើត ២, ៣,១០, ១១,១២ កើត. ២រោច ៣, ១០, ១១ រោច បើខែពេញមាន ១១ ថ្ងៃក្នុងមួយខែ គឺ ១ កើត ២, ៣, ១០, ១១, ១២ កើត. ២ រោច ៣, ១០, ១១, ១២ រោច មិនមែនជាកាលនៃ **ឧបោសថ** ទេ ។

**សួរថា:** កាលបើមួយខែ មានថ្ងៃ**ឧបោសថ**មានតែ ១៩ ថ្ងៃ ប៉ុណ្ណោះ ចុះថ្ងៃនៅសល់ ១០ ឬ ១១ ថ្ងៃក្នុងមួយខែនោះ តើជាថ្ងៃអ្វី?

**ឆ្លើយថា:** សេចក្ដីក្នុង **គម្ពីរមង្គលត្ថទីបនី** បានបញ្ជាក់ថា ខែទាំងអស់គឺ បុគ្គលកាលមិនសមាទាននូវឧបោសថសីលទេ គួរដើម្បីរក្សានូវសីល ៥ ។ មែនពិត ខែទាំងអស់ជាកាលរបស់សីល ៥ ពាក្យដែលពោលមកហើយនេះដោយអំណាច នៃបុគ្គល កាលមិនរក្សានូវបាដិហារិយបក្ខ ។ តាមដំណើរសេចក្ដីនេះ បញ្ជាក់ឲ្យ ឃើញថា ថ្ងៃដែលសល់ពីការរក្សានូវឧបោសថសីល ជាថ្ងៃដែលបុគ្គលត្រូវរក្សា សីល ៥ ជានិច្ច ។

៣- **បាដិហារិយុបោសថ:** ឧបោសថដែលបុគ្គលគប្បីរក្សា ។ ខែប្រកប ដោយរដូវភ្លៀង ៤ ខែ គឺ អាសាឍ ១. ស្រាពណ៍ ១. ភទ្របទ ១. អស្សុជ ១. កត្តិក ១. ជាកាលនៃបាដិហារិយបក្ខ ។

ក្នុង**រាជសុត្តវណ្ណនា** មានសេចក្ដីថា **និពន្ធុបោសថ** គឺឧបោសថដែលគេ រក្សាជាប់ជានិច្ច មិនដាច់អស់កាល ៣ ខែ ក្នុងខាងក្នុងវស្សាក្ដី ឧបោសថ ដែល

បុគ្គលរក្សាជាប់ជានិច្ច មិនដាច់អស់កាល ១ ខែ ត្រង់ចន្លោះបវារណាទាំងពីរក្តី ឧបោសថដែលគេរក្សាជាប់ជានិច្ច មិនដាច់ត្រឹមកន្លះខែ ចាប់ពីថ្ងៃបវារណាទី ១ ទៅក្តី ហៅថា**ចាដិហារិយបក្ខ** ។

ក្នុងតដ្ឋិកាបានបញ្ជាក់ថា **ជិពន្ធុបោសថ** ឈ្មោះថា **ចាដិហារិយបក្ខ** នោះ ព្រោះថាឧបោសថ គឺបុគ្គលគប្បីរក្សា គឺថាប្រព្រឹត្តជាប់រៀងរាល់ឆ្នាំ ។

**ចាដិហារិយបក្ខ** មានន័យថា បក្សនៃ **ចាដិហារិយុបោសថ** បានដល់បក្សទាំងពីរយ៉ាងគឺ **ឧបនីយហរណាគបក្ខ** ១, **ចាជិជត្តជគាបក្ខ** ១ ។

**ឧបនីយហរណាគបក្ខ** បានដល់បក្សនៃការរក្សាបកតិឧបោសថ ជុណ្ហ-បក្ស មាន ៤ ថ្ងៃ កាឡបក្សមាន ៤ ថ្ងៃ ។

**ចាជិជត្តជគាបក្ខ** បានដល់បក្សនៃការរក្សានូវបាដិជាគរុបោសថ ជុណ្ហបក្ស មាន ៥ ថ្ងៃ កាឡបក្សមាន ៦ ថ្ងៃ ។

អាចារ្យដទៃពោលថា ខែ ៣ គឺ អាសាឍ ១, កត្តិក ១, ផល្គុណ ១, ជា **ចាដិហារិយបក្ខ** ។

អាចារ្យដទៃទៀតពោលថា ថ្ងៃ ៤ ៗ ពោលគឺ ១៣ កើត, ១រោច, ៧ រោច ៩ រោច រៀងរាល់បក្ស ដោយអំណាចនៃថ្ងៃខាងដើម និងខាងចុងនៃថ្ងៃ បក្ខុបោសថជា **ចាដិហារិយបក្ខ** ។ ពាក្យណាគាប់ចិត្ត បុគ្គលអ្នកមានសេចក្តីប្រាថ្នានូវបុណ្យគប្បីកាន់យកពាក្យនោះតាមសេចក្តីគាប់ចិត្តចុះ ។

ក្នុង **វេស្សន្តរជាតកវណ្ណនា** មានសេចក្ដីថា ជនទាំងឡាយរក្សានូវឧបោសថក្នុងមួយខែ ៦ ថ្ងៃ ក្នុង **សុក្កបក្ខ** បក្សខ្នើត ៣ ថ្ងៃ គឺ ១៥, ៨, ១១ ។ **កាលបក្ខ** បក្ខរនោចមាន ៣ ថ្ងៃគឺ ១៥, ៨, ១១ ដូចគ្នា ។

ឧបោសថក្នុងមួយខែមាន ៦ ថ្ងៃ ដូចបានពោលមកហើយនេះ មានក្នុងទីដទៃ ក្រៅអំពីពុទ្ធកាល ។

រីឯសេចក្ដីសម្រេចក្នុង **គម្ពីរមង្គលត្ថទីបនី** បានបញ្ជាក់អំពីឧបោសថដែលមានក្នុងសម័យនៃការកើតឡើងនៃព្រះពុទ្ធថាៈ កាលនៃ **បកតិឧបោសថ** ក្នុងមួយខែ ៨ ថ្ងៃ, កាលនៃ **បដិជាគរុបោសថ** ក្នុងមួយខែ ១១ ថ្ងៃ, ខែប្រកបដោយរដូវភ្លៀងទាំងអស់ ជាកាលនៃ **បាដិហារិយុបោសថ** មែនពិត ។

អាចារ្យពួកខ្លះពោលថា ការធ្វើឧបោសថសីល គួរធ្វើក្នុងថ្ងៃណា ៗ ក៏បានដែរ ឲ្យតែមានសទ្ធាកាន់យក ពាក្យដែលលោកអាចារ្យពោលយ៉ាងនេះ មិនគួរឡើយ បើបុគ្គលរក្សាឧបោសថក្នុងថ្ងៃណាក៏បានយ៉ាងនេះ ពុទ្ធឱវាទដែលកំណត់ក្នុងការរក្សាឧបោសថមាន **អដ្ឋមី ចាតុទ្ទសី បណ្ណរសី** ជាដើម ជាពាក្យគ្មានប្រយោជន៍ទៅហើយឬ ?

ថ្ងៃដែលត្រូវរក្សាឧបោសថសីល ដែលព្រះសម្មាសម្ពុទ្ធ ជាម្ចាស់នៃយើងទ្រង់បានកំណត់ហើយនោះ ពិតជាពាក្យមានប្រយោជន៍ ហេតុដូច្នេះ ពុទ្ធបរិស័ទដែលជាអ្នកស្រឡាញ់ព្រះពុទ្ធសាសនា ដើម្បីកុំឲ្យធម៌វិន័យនៃព្រះពុទ្ធបរមគ្រូជាម្ចាស់សាបសូន្យ គួរតែគោរពប្រតិបត្តិតាមកាលកំណត់ នៃថ្ងៃឧបោសថដែលព្រះអង្គទ្រង់ត្រាស់សម្ដែងហើយ ។

**សួរថា:** **ចាដិហារិយុបោសថ** មានសេចក្ដីប្លែកពី **បកតិឧបោសថ** និង **បដិជាគរុបោសថ** ដូចម្ដេច ? សូមពន្យល់ ។

**ឆ្លើយថា:** សេចក្ដីផ្សេងគ្នាដូច្នេះគឺ បុគ្គលកាលរក្សានូវ **បកតិឧបោសថ** កាលនៃ **បកតិឧបោសថ** ១ ខែ មាន ៨ ថ្ងៃ ។

បុគ្គលកាលរក្សានូវ **បដិជាគរុបោសថ** ១ ខែ មាន ១១ ថ្ងៃ ។ ឯបុគ្គលរក្សានូវ**ចាដិហារិយុបោសថ** ត្រូវរក្សាឧបោសថសីលគ្រប់ថ្ងៃនៃឧបោសថទាំងអស់ តាម**ចាដិហារិយបក្ស** មិនបានលះបង់នូវថ្ងៃឧបោសថ សូម្បីមួយថ្ងៃឡើយ ហើយត្រូវប្រកបដោយខែ ជារដូវភ្លៀង ៤ ខែផង ។

## អង្គនៃនិច្ចសីល

## ចាណាតិចាត មានអង្គ ៥

១- ចាណោ — សត្វមានជីវិត ។

២- ចាណសញ្ញិតា — សេចក្ដីដឹងថា សត្វមានជីវិត ។

៣- វធកចិត្តំ — គិតនឹងសម្លាប់ ។

៤- ឧបក្កមោ — ព្យាយាមនឹងសម្លាប់ ។

៥- តេន មរណំ — សត្វស្លាប់ដោយព្យាយាមនោះ ។

## អទិន្នាទាន មានអង្គ ៥

១- បរបរិគ្គហិតំ — ទ្រព្យដែលម្ចាស់របស់គេហួងហែងរក្សា ។

២- បរបរិគ្គហិតសញ្ញិតា — សេចក្ដីដឹងថាទ្រព្យមានម្ចាស់គេហួងហែងរក្សា។

៣- ថេយ្យចិត្តំ គិតនឹងលួច ។

៤- ឧបក្កមោ ព្យាយាមនឹងលួច ។

៥- តេន ហរណំ លួចបានមកដោយព្យាយាមនោះ ។

## កាមេសុមិច្ឆាចារ មានអង្គ ៤

១- អគមនីយដ្ឋានំ ស្ត្រីដែលមិនគួរនឹងគប់រកគឺស្ត្រីដែលមានគេហួងហែងរក្សា ។

២- តស្មឹ សេវនចិត្តំ គិតនឹងសេពនូវមេថុនធម្មនឹងស្ត្រីនោះ ។

៣- ឧបក្កមោ ព្យាយាមនឹងសេពនូវមេថុនធម្ម ។

៤- មគ្គេន មគ្គប្បដិចាទនំ ញ៉ាំងមគ្គនឹងមគ្គឱ្យដល់គ្នា ។

## មុសាវាទ មានអង្គ ៤

១- អតថំ វត្ថុ វត្ថុមិនពិត ។

២- វិសំវាទនចិត្តំ គិតនឹងពោលឲ្យខុស ។

៣- តជ្ជោ វាយាមោ ព្យាយាមនឹងពោលឲ្យខុសនោះ ។

៤- បរស្ស តទត្ថវិជាននំ ញ៉ាំងអ្នកដទៃឲ្យដឹងច្បាស់នូវសេចក្ដីនោះ ។

## សុរាមេរយ មានអង្គ ៤

១- មជ្ជនីយវត្ថុ វត្ថុទីតាំងនៃសេចក្ដីស្រវឹង គឺសុរា និងមេរ័យ ។

២- ចាតុកម្យតាចិត្តំ ចិត្តប្រាថ្នាដើម្បីនឹងផឹក ។

៣- តជ្ជោ វាយាមោ ព្យាយាមនឹងផឹកនូវទឹកស្រវឹងនោះ ។

៤- តស្ស ចានំ បានផឹកនូវទឹកស្រវឹងនោះឲ្យកន្លងបំពង់កចូលទៅ ។

## អង្គនៃឧបោសថសីល

អង្គនៃបាណាតិបាតនិង អទិន្នាទានដូចនិច្ចសីលខាងដើម ។

## អព្រហ្មចរិយ មានអង្គ ៤

១- ភេទនវត្ថុ វត្ថុជាទីទម្លាយនៃសីល គឺទ្វារមគ្គ ៣០[12] ចំពោះទ្វារណាមួយ ។

២- សេវនចិត្តំ គិតនឹងសេព ។

៣- តជ្ជោ វាយាមោ ព្យាយាមនឹងសេពនូវមេថុនធម្មនោះ ។

៤- មគ្គេន មគ្គប្បដិបាទនំ ញ៉ាំងមគ្គនិងមគ្គឲ្យដល់គ្នា ។

អង្គនៃមុសាវាទ និងសុរាមេរ័យ ដូចនិច្ចសីលខាងដើម ។

## វិកាលភោជន មានអង្គ ៣

១- វិកាលោ កាលខុស គឺព្រះអាទិត្យជ្រេទៅហើយដរាបទល់នឹងអរុណរះ ។

២- យាវកាលិកំ របស់ដែលគួរបរិភោគបានក្នុងកាល គឺតាំងពីអរុណរះឡើង ដរាបដល់ថ្ងៃត្រង់ ។

៣- អជ្ឈោហរណំ បានលេបចូលទៅក្នុងបំពង់ក ។

[12] ទ្វារមគ្គមាន ៣០ គឺមនុស្ស ១០, អមនុស្ស ១០, សត្វតិរច្ឆាន ១០
ទ្វារមគ្គមនុស្ស ១០ នោះគឺ ។
បុរសមានទ្វារ ២ បានដល់ទ្វារមាត់ ១, ទ្វារលាមក ១, ស្ត្រីមានទ្វារ ៣ បានដល់ទ្វារមាត់ ១, ទ្វារមូត្រ ១, ទ្វារលាមក ១ ។ ខ្ទើយមានទ្វារ ២ បានដល់ទ្វារមាត់ ១, ទ្វារលាមក ១, ឧភតោព្យញ្ជនកមានទ្វារ ៣ បានដល់ទ្វារមាត់ ១, ទ្វារមូត្រ ១, ទ្វារលាមក ១។ ឯអមនុស្ស ១០ សត្វតិរច្ឆាន ១០ ក៏មានរបៀបរាប់តាមភេទដូចមនុស្សដែរ ។

## និច្ចគីតព្រមទាំងមាលាទូមគ្នាចាងជាសិក្ខាបទ ១ មានអង្គ ៦

១- និច្ចគីតាទិ ការល្បែងមានរាំនិងច្រៀងជាដើម ។

២- កាតុកាម្យតាចិត្តំ គិតបម្រុងនឹងធ្វើ ។

៣- សុតទស្សនត្ថាយ គមនំ ទៅដើម្បីនឹងស្តាប់ឬមើល ហើយបានស្តាប់ឬមើល

៤- មាលាទិ វត្ថុសម្រាប់ប្រដាប់កាយ មានផ្កាកម្រងជាដើម ។

៥- ធារណាឆន្ទតា សេចក្តីប្រាថ្នានឹងប្រដាប់តាក់តែង ។

៦- តស្ស ធារណំ បានប្រដាប់តាក់តែងនូវវត្ថុសម្រាប់ប្រដាប់កាយ មានផ្កាកម្រងជាដើមនោះ ។

## ឧច្ចាសយន មានអង្គ ៣

១- ឧច្ចាសយនមហាសយនំ ទីដេក ទីអង្គុយដ៏ខ្ពស់ ដ៏ប្រសើរ ហួសប្រមាណ[13] ។

២- បរិភោគចិត្តំ គិតនឹងដេកឬអង្គុយ ។

៣- បរិភោគករណំ បានដេកឬអង្គុយ ។

---

[13] ទីដេកអង្គុយ មានគ្រែ ឬតាំងជាដើម ដែលខ្ពស់លើសជាង ៨ ធ្នាប់ព្រះសុគត ឡើងទៅ ហៅថាទីដេក ទីអង្គុយ ដ៏ខ្ពស់ហួសប្រមាណ ។
ខ្នាត ៨ ធ្នាប់ព្រះសុគតនោះ គឺរាប់ចាប់ពីមេគ្រែ ឬតាំងព្វដ៏ខាងក្រោមចុះមក ស្មើនឹង ១ ហត្ថក្តាប់ដៃ និង ១ ចំអាមនៃបុរសធម្មតា ។

# អង្គនៃសីល ១០

អង្គ ចាណាតិចាត រហូតដល់អង្គ វិកាលភោជន ដូចគ្នានឹងអង្គនៃឧបោសថសីលដែរ អង្គ នច្ចគីត មាន ៣ អង្គ, មាលា មាន ៣ ដូចគ្នានឹងអង្គ នច្ចគីតមាលា នៃឧបោសថសីលដែរ ខុសគ្នាខ្លះ គ្រាន់តែឧបោសថសីល អង្គ នច្ចគីត និងអង្គ មាលា រួមចូលគ្នាជាអង្គ ៦ ជាសិក្ខាបទ ១ ។ ឯសីល ១០ ត្រូវបំបែកជាសិក្ខាបទ ២ គឺ នច្ចគីត ជាសិក្ខាបទ ១ មានអង្គ ៣, មាលា ជាសិក្ខាបទ ១ មានអង្គ ៣ ប៉ុណ្ណោះ។ អង្គឧច្ចាសយន មាន ៣ ដូចក្នុងឧបោសថសីលដែរ។

## ជាតរូប មានអង្គ ៣

១- ជាតរូបរជតំ មាសឬប្រាក់ជាអកប្បិយភណ្ឌ ។

២- អត្តុទ្ទិសតា ចំពោះជារបស់ខ្លួន ។

៣- បដិគណ្ហាតិ បានទទួលកាន់យកដោយខ្លួនឯង ឬប្រើគេឲ្យទទួលកាន់យកទុកដាក់ឲ្យ ហើយត្រេកអរចំពោះមាស ឬប្រាក់នោះដោយឧបាយឯណានីមួយ ។

កាលបើឧបាសក ឧបាសិកា ប្រព្រឹត្តឲ្យកន្លងសិក្ខាបទណាៗ លុះតែព្រមដោយអង្គក្នុងសិក្ខាបទនោះៗ ទើបឈ្មោះថាកន្លង បើមិនទាន់ព្រមដោយអង្គនោះទេ ក៏មិនបានឈ្មោះថាកន្លងនូវសិក្ខាបទនោះៗ ឡើយ ។

## សេចក្តីវិនិច្ឆ័យក្នុងសិក្ខាបទ

### បយោគ

សេចក្តីព្យាយាមនឹងប្រព្រឹត្តឲ្យកន្លងសិក្ខាបទឈ្មោះថា បយោគៗ នោះមាន ២ គឺ សាហត្ថិកប្បយោគ ១. អាណត្តិកប្បយោគ ១. ។

ការធ្វើឲ្យកន្លងដោយខ្លួនឯង ហៅថា សាហត្ថិកប្បយោគ. ប្រើអ្នកដទៃឲ្យធ្វើ ហៅថា អាណត្តិកប្បយោគ ។

# ក្នុងសិក្ខាបទទាំង ១០ នោះ

សិក្ខាបទទី ៣ គឺ **អព្រហ្មចរិយ** ។

សិក្ខាបទទី ៤ គឺ **មុសាវាទ** ។

សិក្ខាបទទី ៥ គឺ **សុរាមេរយ** ។

សិក្ខាបទទី ៦ គឺ **វិកាលភោជន** ។

សិក្ខាបទទី ៨ គឺ **មាលា** និងសិក្ខាបទទី ៩ គឺ **ឧច្ចាសយន** ទាំង ៧ សិក្ខាបទនេះ ជា **សាហត្ថិកប្បយោគ** ។

សិក្ខាបទទី ១ គឺ **ចាណាតិចាត**

សិក្ខាបទទី ២ គឺ **អទិន្នាទាន** និងសិក្ខាបទទី ១០ **ជាតរូប** ទាំង ៣ នេះជា **អាណត្តិកប្បយោគ** ។

ម្យ៉ាងទៀត សិក្ខាបទទាំង ១០ នោះ លោកចែកចេញជាពីរពួកគឺ សាណត្តិកៈ ពួក ១, ជា**អនាណត្តិកៈ** ពួក ១ ។ សិក្ខាបទឯណាដែលជា **អាណត្តិកប្បយោគ** សិក្ខាបទនោះជា **សាហណត្តិក** ព្រោះអ្នករក្សាធ្វើដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យធ្វើក្តី ឈ្មោះថាកន្លងដូចគ្នា ។

សិក្ខាបទឯណាដែលជា **សាហត្ថិកប្បយោគ** សិក្ខាបទនោះជា **អនាណត្តិកៈ** ព្រោះអ្នករក្សាធ្វើដោយខ្លួនឯង ទើបឈ្មោះថាកន្លង បើប្រើអ្នកដទៃឲ្យធ្វើនោះមិនបានឈ្មោះថាកន្លងទេ ។

# កម្មបថ

**កម្មបថ** < **កម្ម** + **បថ** កម្មប្រែថា អំពើ, **បថ** ប្រែថា គន្លង ឬផ្លូវ រួមជា **កម្មបថ** ប្រែថា គន្លង ឬផ្លូវនៃអំពើ ដែលគេធ្វើមាន ២ យ៉ាងគឺ **អកុសលកម្មបថ ១ កុសលកម្មបថ ១ ។**

**អកុសលកម្មបថ:** ប្រែថា គន្លង ឬផ្លូវនៃអំពើអាក្រក់ **កុសលកម្មបថ** ប្រែថា គន្លង ឬ ផ្លូវនៃអំពើល្អ ។

## អកុសលកម្មបថមាន ១០ យ៉ាងគឺ

## កាយកម្ម ៣ យ៉ាង

១- **ចាណាតិបាតោ:** កិរិយាសម្លាប់សត្វដោយកាយរបស់ខ្លួន ឬប្រើគេឲ្យសម្លាប់ដោយវាចា ។

២- **អទិន្នាទានំ:** កិរិយាលួចលាក់ ឆក់ដណ្តើមទ្រព្យគេ ដោយកាយរបស់ខ្លួន ឬប្រើគេឲ្យលួចលាក់ឆក់ដណ្តើមដោយវាចា ។

៣- **កាមេសុ មិច្ឆាចារោ:** កិរិយាប្រព្រឹត្តិខុសក្នុងកាមទាំងឡាយ គឺធ្វើនូវ **មេថុនសេវន** នឹងស្ត្រីដែលមានគេហួងហែងរក្សា ។

## វចីកម្ម ៤ យ៉ាង

១- **មុសាវាទោ:** កិរិយាពោលនូវពាក្យកុហក ។

២- **បិសុណាវាចា:** កិរិយាពោលនូវពាក្យញុះញង់សឹកសៀត បំបែកបំបាក់អ្នកដទៃ ។

៣- ផរុសវាចា: កិរិយាពោលនូវពាក្យអាក្រក់ មានពាក្យត្រគោះបោះបោក ជេរប្រទេចអ្នកដទៃជាដើម ។

៤- សម្ផប្បលាបោ: កិរិយាពោលនូវពាក្យរោយរាយឥតប្រយោជន៍ ។

## មនោកម្ម ៣ យ៉ាង

១- អភិជ្ឈា: ចិត្តសម្លឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបម្រុងនឹងឲ្យបានមកជាទ្រព្យរបស់ខ្លួន ។

២- ព្យាបាទោ: ចិត្តចងគំនុំគុំគួន គឺប៉ងនឹងឲ្យអ្នកដទៃដល់នូវសេចក្ដីវិនាស

៣- មិច្ឆាទិដ្ឋិ: គំនិតយល់ខុស ហើយប្រកាន់ឡើងថាជាត្រូវ ។

កម្មបថ ១០ យ៉ាងនេះ ជាផ្លូវអាក្រក់មិនត្រូវប្រព្រឹត្តឡើយ ។

## កុសលកម្មបថ ១០ យ៉ាង

## កាយកម្ម ៣ យ៉ាង

១- បាណាតិបាតា វេរមណី: ចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

២- អទិន្នាទានា វេរមណី: ចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនឲ្យដោយកាយ ឬ ដោយវាចា ។

៣- កាមេសុ មិច្ឆាចារា វេរមណី: ចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តិខុសក្នុងកាមទាំងឡាយ ។

## វចីកម្ម ៤ យ៉ាង

១- **មុសាវាទា វេរមណី:** ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

២- **បិសុណាយ វាចាយ វេរមណី:** ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យញុះញង់ស៊កសៀតបំបែកបំបាក់អ្នកដទៃ ។

៣- **ផរុសាយ វាចាយ វេរមណី:** ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោកជេរប្រទេចអ្នកដទៃជាដើម ។

៤- **សម្ផប្បលាបា វេរមណី:** ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យរោយរាយឥតប្រយោជន៍ ។

## មនោកម្ម ៣ យ៉ាង

១- **អនភិជ្ឈា:** មិនមានចិត្តគិតសម្លឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបម្រុងនឹងឲ្យបានមកជាទ្រព្យរបស់ខ្លួនឡើយ ។

២- **អព្យាបាទោ:** មិនមានចិត្តចងគំនុំគុំគួន គិតប៉ងនឹងឲ្យអ្នកដទៃដល់នូវសេចក្ដីវិនាសឡើយ ។

៣- **សម្មាទិដ្ឋិ:** គំនិតយល់ឃើញត្រូវពិត ហើយប្រកាន់ឡើងថាត្រូវមែន ។ ឧបាសក ឧបាសិកាទាំងឡាយ ដែលបានសមាទាននូវសីល ៥ ឬ ៨ ឬ ជាសីល ១០ គប្បីសិក្សាកម្មបថ ២០ ដូចបានពោលហើយថែមទៀត ត្រូវវៀរចាក អកុសលកម្មបថ ១០ ហើយតម្កល់ខ្លួនឲ្យស៊ប់ល្អក្នុង កុសលកម្មបថ ១០ ទើបប្រពៃ ។

## អង្គនៃអកុសលកម្មបថ

អង្គនៃ ចាណាតិបាត, អទិន្នាទាន, កាមេសុមិច្ឆាចារ និង មុសាវាទ មានពោលខាងដើមហើយ ។

## បិសុណាវាចា មានអង្គ ៤

១- ភិន្ទិតព្វោ បរោៈ អ្នកដទៃដែលមានរូប គឺខ្លួនគប្បីញុះញង់បំបែក ។

២- ភេទនបុរេក្ខារតាៈ គិតនឹងញុះញង់បំបែកបំបាក់អ្នកដទៃនោះ ។

៣- តជ្ជោ វាយាមោៈ ព្យាយាមបំបែកបំបាក់អ្នកដទៃនោះ ។

៤- តស្ស តទត្ថវិជាននំៈ ញ៉ាំងអ្នកដទៃឲ្យដឹងច្បាស់នូវដំណើរដែលញុះញង់នោះ ។

## ផរុសវាចា មានអង្គ ៣

១- អក្កោសិតព្វោ បរោៈ អ្នកដទៃដែលមានរូបគឺ ខ្លួនគប្បីជេរប្រទេច ។

២- កុបិ្បតចិត្តំៈ ចិត្តខឹងរន្ធត់ ។

៣- អក្កោសនាៈ បានជេរប្រទេច ។

## សម្ផប្បលាប មានអង្គ ២

១- ភារតយុទ្ធសិតាហរណាទិនិរត្ថកថាៈ ពាក្យឥតប្រយោជន៍ មានរឿងចម្បាំងនៃភារត និង រឿងរាពណ៍លួចនាងសេដាយកទៅជាដើម ។

២- តថារូបីកាថាកថនំ: បានពោលនូវពាក្យឥតប្រយោជន៍ មានសភាពដូច្នេះ ។

## អភិជ្ឈា មានអង្គ ២

១- បរភណ្ឌំ: ទ្រព្យជារបស់អ្នកដទៃ ។

២- អត្តនោ បរិណាមនំ: គិតចង់បង្អោនទ្រព្យរបស់អ្នកដទៃនោះ ឲ្យបានមកជាទ្រព្យរបស់ខ្លួន ដោយកលឧបាយផ្សេង ៗ ។

## ព្យាបាទ មានអង្គ ២

១- បរសត្តោ: អ្នកដទៃក្រៅពីខ្លួន ។

២- តស្ស តំ តំ វិនាសចិន្តា: គិតចងគំនុំគុំគួននឹងឱ្យអ្នកនោះ ដល់នូវសេចក្ដីវិនាសដោយហេតុនោះ ។

## មិច្ឆាទិដ្ឋិ មានអង្គ ២ យ៉ាង

១- វត្ថុនោ ច គហិតាការវិបរិតតា: ចិត្តប្រែប្រួលដោយអាការខុសអំពីព្រះរតនត្រ័យជាដើម ។

២- យថា ច នំ គណ្ហាតិ តថាភាវេន តស្សុបដ្ឋានំ: គំនិតដែលយល់ខុសនោះ ឃើញខុសយ៉ាងណា ក៏ប្រកាន់សេចក្ដីខុសនោះថាជាត្រូវវិញ ។

## កម្មបថ ៨០

**កម្មបថ** ពោលដោយសង្ខេបមាន ៨០ ដូចបានពោលមកហើយ តែក្នុងព្រះពុទ្ធសាសនា កម្មបថ បើពោលឲ្យពិស្តារសព្វគ្រប់នោះ មានដល់ ៨០ គឺ**អកុសលកម្មបថ ៤០, កុសលកម្មបថ ៤០ ។**

## កុសលកម្មបថ ៤០

### កុសលកម្មបថ ៤០ ចាត់ជា **កាយកម្ម ១២ វចីកម្ម ១៦ មនោកម្ម ១២**

### កាយកម្មមាន ១២ គឺ

១- កិរិយាវៀរចាក ការសម្លាប់សត្វមានជីវិតដោយខ្លួនឯង ។

២- កិរិយាវៀរចាក ការប្រើគេឲ្យសម្លាប់សត្វមានជីវិត ។

៣- កិរិយាវៀរចាក ការពេញចិត្តក្នុងការសម្លាប់សត្វមានជីវិត ។

៤- កិរិយាវៀរចាក ការពិពណ៌នាសរសើរគុណនៃការសម្លាប់សត្វមានជីវិត។

៥- កិរិយាវៀរចាក ការកាន់យកទ្រព្យ ដែលម្ចាស់គេមិនបានឲ្យដោយខ្លួនឯង ។

៦- កិរិយាវៀរចាក ការប្រើគេកាន់យកទ្រព្យដែលម្ចាស់គេមិនបានឲ្យ ។

៧- កិរិយាវៀរចាក ការពេញចិត្តក្នុងការកាន់យកទ្រព្យ ដែលម្ចាស់គេមិនបានឲ្យ។

៨- កិរិយាវៀរចាក ការពិពណ៌នាសរសើរគុណនៃការកាន់យកទ្រព្យ ដែលម្ចាស់គេមិនបានឲ្យ ។

៩- កិរិយាវៀរចាក ការប្រព្រឹត្តិខុសក្នុងកាមទាំងឡាយដោយខ្លួនឯង។

១០- កិរិយាវៀរចាក ការប្រើគេឲ្យប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

១១- កិរិយាវៀរចាក ការពេញចិត្តក្នុងការប្រព្រឹត្តិខុសក្នុងកាមទាំងឡាយ ។

១២- កិរិយាវៀរចាក ការពិពណ៌នាសរសើរគុណនៃការប្រព្រឹត្តិខុសក្នុងកាមទាំងឡាយ ។

## វចីកម្ម មាន ១៦

១- កិរិយាវៀរចាក ការនិយាយកុហកដោយខ្លួនឯង ។

២- កិរិយាវៀរចាក ការប្រើគេឲ្យនិយាយកុហក ។

៣- កិរិយាវៀរចាក ការពេញចិត្តក្នុងការនិយាយកុហក ។

៤- កិរិយាវៀរចាក ការពិពណ៌នាសរសើរគុណនៃការនិយាយកុហក ។

៥- កិរិយាវៀរចាក ការនិយាយញុះញង់ដោយខ្លួនឯង ។

៦- កិរិយាវៀរចាក ការប្រើគេឲ្យនិយាយញុះញង់ ។

៧- កិរិយាវៀរចាក ការពេញចិត្តក្នុងការនិយាយញុះញង់។

៨- កិរិយាវៀរចាក ការពិពណ៌នាសរសើរគុណនៃការនិយាយញុះញង់ ។

៩- កិរិយាវៀរចាក ការនិយាយពាក្យអាក្រក់ដោយខ្លួនឯង ។

១០- កិរិយាវៀរចាក ការប្រើគេឲ្យនិយាយពាក្យអាក្រក់ ។

១១- កិរិយាវៀរចាក ការពេញចិត្តក្នុងការនិយាយពាក្យអាក្រក់ ។

១២- កិរិយាវៀរចាក ការពិពណ៌នាសរសើរគុណនៃការនិយាយពាក្យអាក្រក់ ។

១៣- កិរិយាវៀរចាក ការនិយាយពាក្យឥតប្រយោជន៍ដោយខ្លួនឯង ។

១៤- កិរិយាវៀរចាក ការប្រើគេឲ្យនិយាយពាក្យឥតប្រយោជន៍ ។

១៥- កិរិយាវៀរចាក ការពេញចិត្តក្នុងការនិយាយពាក្យឥតប្រយោជន៍ ។

១៦- កិរិយាវៀរចាក ការពិពណ៌នាសរសើរគុណនៃការនិយាយពាក្យឥតប្រយោជន៍ ។

## មនោកម្ម មាន ១២

១- កិរិយាវៀរចាក ការសម្លឹងរំពៃចង់បានទ្រព្យរបស់គេដោយខ្លួនឯង ។

២- កិរិយាវៀរចាក ការប្រើគេឲ្យសម្លឹងរំពៃចង់បានទ្រព្យរបស់គេ ។

៣- កិរិយាវៀរចាក ការពេញចិត្តក្នុងការសម្លឹងរំពៃចង់បានទ្រព្យរបស់គេ។

៤- កិរិយាវៀរចាក ការពិពណ៌នាសរសើរគុណ នៃការសម្លឹងរំពៃចង់បានទ្រព្យរបស់គេ ។

៥- កិរិយាវៀរចាក ការចងចិត្តគុំគួនគេ ដោយខ្លួនឯង ។

៦- កិរិយាវៀរចាក ការប្រើគេឲ្យចងចិត្តគុំគួនគេ ។

៧- កិរិយាវៀរចាក ការពេញចិត្តក្នុងការចងចិត្តគុំគួនគេ ។

៨- កិរិយាវៀរចាក ការពិពណ៌នាសរសើរនៃការចងចិត្តគុំគួនគេ ។

៩- កិរិយាវៀរចាក ការឃើញខុសចាកគន្លងធម៌ដោយខ្លួនឯង ។

១០- កិរិយាវៀរចាក ការប្រើគេឲ្យឃើញខុសចាកគន្លងធម៌ ។

១១- កិរិយាវៀរចាក ការពេញចិត្តក្នុងការឃើញខុសចាកគន្លងធម៌ ។

១២- កិរិយាវៀរចាក ការពិពណ៌នាសរសើរគុណ នៃការឃើញខុសចាកគន្លងធម៌ ។

រួម កាយកម្ម ១២. វចីកម្ម ១៦. មនោកម្ម ១២ ត្រូវជា ៤០ ខាង កុសលកម្មបថ ។

ចំណែកឯ អកុសលកម្មបថ ក៏មាន ៤០ ដូចគ្នា គ្រាន់តែពាក្យផ្ទុយគ្នាតែប៉ុណ្ណោះ ។

## សេចក្តីបំភ្លឺអំពី

### ក- កាមេសុមិច្ឆាចារ:

**កាមេសុមិច្ឆាចារ** ការប្រព្រឹត្តិខុសក្នុងកាមទាំងឡាយ បានដល់ការប្រព្រឹត្តិគឺការសេពមេថុន ក្នុងស្ត្រី ២០ ជំពូកគឺ

១- **មាតុរក្ខិតា:** ស្រីដែលមាតាថែរក្សា ។

២- **បិតុរក្ខិតា:** ស្រីដែលបិតាថែរក្សា ។

៣- **មាតាបិតុរក្ខិតា:** ស្រីដែលមានមាតាបិតាថែរក្សា ។

៤- **ភាតុរក្ខិតា:** ស្រីដែលមានបងប្រុស ឬប្អូនប្រុសថែរក្សា ។

៥- **ភគិនិរក្ខិតា:** ស្រីដែលមានបងស្រី ឬ ប្អូនស្រីថែរក្សា ។

៦- **ញាតិរក្ខិតា:** ស្រីដែលញាតិថែរក្សា ។

៧- **គោត្តរក្ខិតា:** ស្រីដែលមានគោត្តថែរក្សា (អ្នកមានសែដូចគ្នាថែរក្សា) ។

៨- **ធម្មរក្ខិតា:** ស្រីដែលមានសង្ឃថែរក្សា ។ ស្រីទាំង ៨ ពួកនេះ បើបុរសណាណាមួយសេពហើយ ត្រូវទោស **កាមេសុមិច្ឆាចារ** តែខាងបុរសឯស្រីមិនត្រូវទោសអ្វីឡើយ ។

៩- **សារក្ខា:** ស្រីដែលមានប្ដីថែរក្សា ។

១០- **សបរិទណ្ឌា:** ស្រីដែលមានស្ដេចដាក់អាជ្ញាថា យកធ្វើជាទេពី ។

១១- **ធនក្កីតា:** ស្រីដែលគេទិញដោយទ្រព្យ ។

១២- **ឆន្ទវាសិនី:** ស្រីដែលនៅដោយស្ម័គ្រចិត្តគ្នានិងគ្នា ។

១៣- **ភោគវាសិនី:** ស្រីដែលនៅដោយសម្បត្តិ ។

១៤- **បដវាសិនី:** ស្រីដែលនៅនឹងគ្នាដោយសំពត់ស្លៀកដណ្ដប់ ។

១៥- **ឱទបត្តកិនី:** ស្រីដែលគេផ្ដោមដៃជាមួយបុរសហើយ ជ្រលក់ទៅក្នុងពាងទឹក ឬផ្តិលទឹក ។

១៦- **ឱភតចុម្ពដា:** ស្រីដែលគេដាក់ទ្រនូលពីក្បាល គឺស្រីអ្នករកឧសជាដើម ។

១៧- **ទាសី ច ភរិយា ច:** ស្រីដែលជាទាសីគេផង ជាភរិយាគេផង គឺស្រីដែលជាទាសីរបស់បុរសណាមួយ ហើយបុរសនោះយកធ្វើជាភរិយា ។

១៨- **កម្មការីភរិយា:** ស្រីដែលជាកូនឈ្នួលរបស់បុរសណាមួយ ហើយបុរសនោះយកធ្វើជាភរិយា ។

១៩- **ធជាហដា:** ស្រីនោះគេចាប់ពីក្នុងទ័ព ។

២០- **មុហុត្តិកា:** ស្រីដែលនៅជាមួយគ្នាជាប្ដីប្រពន្ធតែមួយវេលា ស្រីទាំង ១២ នេះ បើបុរសណាមួយទៅសេពហើយ ត្រូវទោស **កាមេសុមិច្ឆាចារ** ទាំងបុរសទាំងស្ត្រី ។

**សួរថា:** ស្រីទាំង ៨ ជំពូកនេះ បើបុរសណាមួយសេពហើយ ត្រូវ **កាមេសុមិច្ឆាចារ:** ចុះហេតុអ្វីចំណែកខាងស្រីក៏មិនត្រូវផង? ចំណែកខាងស្រី ១២ ជំពូកនោះ ហេតុអ្វីក៏ត្រូវទាំងបុរសទាំងស្ត្រី? ចូរអធិប្បាយមកមើល ។

**ឆ្លើយ:** ឯស្រីទាំង ៨ ជំពូកនោះ បានជាត្រូវទោសក្នុង **កាមេសុមិច្ឆាចារ** ចំពោះតែបុរស. ស្ត្រីមិនត្រូវ ព្រោះថា ស្រីនោះ មាតាបិតាគ្រាន់តែឃុំគ្រងរក្សាកេរ្តិ៍មារយាទខាងក្រៅ ៗ ប៉ុណ្ណោះ មិនមែនជាម្ចាស់សម្ភស្សរបស់ស្រីនោះទេ គឺថាគ្មានស្វាមីគ្រប់គ្រង បានជាលោកសំដែងថា បើបុរសណាមួយទៅសេពនឹងស្រីនោះ ត្រូវទោសក្នុង **កាមេសុមិច្ឆាចារ** តែបុរស ឯស្រីមិនត្រូវទោសឡើយ ។

ឯស្រីទាំង ១២ ជំពូកនេះ ដែលថាត្រូវទោសក្នុង **កាមេសុមិច្ឆាចារ** ទាំងបុរសទាំងស្រី ព្រោះថា ស្រីនោះមានស្វាមីគ្រប់គ្រងថែរក្សា ឈ្មោះថា លួចសម្ភស្សរបស់ស្វាមី ។ ដូច្នេះហើយបានជាលោកសម្តែងថា ស្រីពួកនេះ បើបុរសណាមួយទៅសេព ត្រូវ **កាមេសុមិច្ឆាចារ** ទាំងបុរសទាំងស្ត្រី គឺស្ត្រីនោះឈ្មោះថាលួចសម្ភស្សប្តីទៅឲ្យបុរសដទៃ ។

**ខ- មិច្ឆាទិដ្ឋិ:** គំនិតយល់ខុស ហើយប្រកាន់ឡើងថាជាត្រូវ ។

គំនិតយល់ខុសនោះ គឺជាការខុសចាកសភាពពិតក្នុងលោក សភាពណាដែលពិតក្នុងលោក បែរជាយល់ថាមិនពិត សភាពណាដែលមិនពិត បែរជាយល់ចូលចិត្តថាមានពិតក្នុងលោកទៅវិញ ។

# មិច្ឆាទិដ្ឋិនោះមាន ១០ គឺ

១- **នត្ថិ ទិន្នំ** ទានដែលគេឲ្យហើយមិនមានផល ។

២- **នត្ថិ យិដ្ឋំ** ការបូជាធំមិនមានផល ។

៣- **នត្ថិ ហុតំ** សក្ការៈដ៏ល្មមគ្រាន់ដែលគេបូជាហើយមិនមានផល ។

៤- **នត្ថិ សុកតទុក្កដានំ កម្មានំ ផលំវិបាកោ** ផលក្តី វិបាកក្តី នៃកម្មល្អនិងកម្មអាក្រក់ ដែលគេធ្វើមិនមាន ។

៥- **នត្ថិ អយំ លោកោ** លោកនេះមិនមាន (លោកនេះនៃជនដែលស្ថិតនៅក្នុងបរលោកមិនមាន) ។

៦- **នត្ថិ បរោ លោកោ** លោកដទៃមិនមាន (បរលោកនៃជនដែលស្ថិតនៅក្នុងលោកនេះមិនមាន) ។

ន័យទាំងពីរបទនេះថា សេចក្តីយល់ថា សត្វទាំងអស់នោះ រមែងដាច់សូន្យនៅក្នុងភពនោះ ៗ ។

៧- **នត្ថិ មាតា** មាតាមិនមាន ។

៨- **នត្ថិ បិតា** បិតាមិនមាន ទាំងពីរបទនេះមានសេចក្តីថា: " សេចក្តីប្រតិបត្តិត្រូវខុស ក្នុងមាតានិងបិតាមិនមានផល " ។

៩- **នត្ថិ សត្តា ឱបបាតិកា** សត្វដែលច្យុតហើយ ចូលទៅកើតឡើងមិនមាន ។

១០- **នត្ថិ លោកោ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តិ** សមណៈ និងព្រាហ្មណ៍ទាំងឡាយជាអ្នកប្រតិបត្តិត្រូវ ដឹងច្បាស់ដោយខ្លួននូវលោកនេះនិងលោកដទៃ រមែងធ្វើឲ្យជាក់ច្បាស់ហើយដឹងច្បាស់ មិនមានក្នុងលោក ។

កាលបើឧបាសកឧបាសិកា ដែលបានសមាទាននូវសីល ៥ ឬ សីល ៨ ឬ សីល ១០ ត្រូវសិក្សាគោរពប្រតិបត្តិក្នុង **កម្មបថ ៨០** ថែមទៀត ព្រោះថាសីលដែលបុគ្គលសមាទានហើយ ដឹងថាបរិសុទ្ធ ឬមិនបរិសុទ្ធនោះ ទាល់តែបុគ្គលនោះធ្វើការឆ្លុះបញ្ចាំង ពិចារណានូវអង្គនៃសីលមួយៗ ផង និងពិចារណាក្នុង**កម្មបថ ៨០** ថែមទៀត ទើបដឹងបាន ។ មិនត្រឹមតែប៉ុណ្ណោះទេ យោគាវចរដែលជាអ្នកនឿយណាយចំពោះសេចក្ដីទុក្ខក្នុងខន្ធ ប្រាថ្នាដើម្បីឲ្យជាក់ច្បាស់នូវព្រះនិព្វានជាស្ថានរំលត់បង់នូវសេចក្ដីទុក្ខ កាលបានសមាទាននូវសីលហើយគប្បីរក្សា កាយ វាចា ចិត្ត ឲ្យស្ថិតនៅក្នុងកុសលធម៌ ហើយត្រូវធ្វើនូវសេចក្ដីសង្រួមក្នុងឥន្ទ្រិយ ៦ មាន **ចក្ខុន្ទ្រិយ** ជាដើម ។ នៅពេលដែលអារម្មណ៍មានរូបជាដើមមកប៉ះផ្ទប់ កុំឲ្យ **អភិជ្ឈា** និង **ទោមនស្ស** (សេចក្ដីតូចចិត្ត) កើតឡើងគ្របសង្កត់ចិត្តបាន. ហើយត្រូវការលះបង់នូវ **មិច្ឆាជីវៈ** (ការចិញ្ចឹមជីវិតខុស) **សមាទាន** (កាន់យក) នូវ **សម្មាជីវៈ** (ការចិញ្ចឹមជីវិតត្រូវ) ថែមទាំងធ្វើការពិចារណាក្នុងការប្រើប្រាស់សម្លៀកបំពាក់ បរិភោគភោជន ប្រើប្រាស់ទីដេក និងទីអង្គុយ ផឹកនូវភេសជ្ជៈឲ្យឃើញត្រឹមតែជាធាតុ ជាវត្ថុគួរខ្ពើមរអើមពន់ពេក បរិភោគ

ប្រើប្រាស់មានប្រយោជន៍គ្រាន់តែញុំាងអត្តភាពគឺសរីរៈនេះ ឲ្យមានជីវិតប្រព្រឹត្តទៅដោយឥរិយាបថ ៤ គឺ ដេក ដើរ ឈរ និងអង្គុយ ក្នុងការអប់រំចិត្តដោយការចម្រើន **ព្រះកម្មដ្ឋាន** ដើម្បីកុំឲ្យឧបក្កិលេសមានសេចក្តីល្មោភជាប់ចិត្តជាដើម ក្នុងវត្ថុកើតឡើងគ្របសង្កត់ចិត្តបាន ។

## សេចក្តីពន្យល់អំពីន័យខ្លះ
## ឥន្ទ្រិយប្រែថាភាពជាធំមាន ៦ គឺ

១- ចក្ខុន្ទ្រិយំ: ភ្នែកជាសភាវៈធំ ។
២- សោតិន្ទ្រិយំ: ត្រចៀកជាសភាវៈធំ ។
៣- ឃានិន្ទ្រិយំ: ច្រមុះជាសភាវៈធំ ។
៤- ជិវ្ហិន្ទ្រិយំ: អណ្តាតជាសភាវៈធំ ។
៥- កាយិន្ទ្រិយំ: កាយជាសភាវៈធំ ។
៦- មនិន្ទ្រិយំ: ចិត្តជាសភាវៈធំ ។

ឥន្ទ្រិយទាំង ៦ មានចក្ខុជាដើម បានជាសភាវៈធំ ព្រោះថាចក្ខុ គឺភ្នែកមានតួនាទីធំសម្រាប់ខាងឃើញរូប និងញុំាង ចក្ខុវិញ្ញាណ ឲ្យកើតឡើង ។

សោត គឺត្រចៀកមានតួនាទីធំសម្រាប់ខាងឮសម្លេង និងញុំាង សោតវិញ្ញាណ ឲ្យកើតឡើង ។

ឃាន គឺច្រមុះ មានតួនាទីធំសម្រាប់ខាងធុំក្លិន ស្រូបក្លិន និងញុំាង ឃានវិញ្ញាណ ឲ្យកើតឡើង ។

ជិវ្ហា គឺអណ្ដាត មានតួនាទីធំសម្រាប់ខាងក្រេបជញ្ជក់នូវរស និង ញុំាង ជិវ្ហាវិញ្ញាណ ឲ្យកើតឡើង ។

កាយ គឺរាងកាយ មានតួនាទីធំសម្រាប់ខាងដឹងនូវវត្ថុដែលប៉ះ និង ញុំាង កាយវិញ្ញាណ ឲ្យកើតឡើង ។

មន គឺចិត្ត មានតួនាទីធំខាងទទួលពិចារណានូវធម៌ ។

អារម្មណ៍មាន ៦ នឹងពោលនៅខាងមុខ ។

## សំវរធម៌ ធម៌សម្រាប់កំណត់ឲ្យដឹងថាសង្រួមមាន ៥ យ៉ាង៖

១- **សីលសំវរៈ** ធម៌សង្រួមគឺ **សីល** ។

២- **សតិសំវរៈ** ធម៌សង្រួមគឺ **សតិ** ។

៣- **ញាណសំវរៈ** ធម៌សង្រួមគឺ ប្រាជ្ញា ។

៤- **ខន្តិសំវរៈ** ធម៌សង្រួមគឺ សេចក្ដីអត់ធ្មត់ ។

៥- **វិរិយសំវរៈ** ធម៌សង្រួមគឺ ព្យាយាម ។

យោគាវចរដែលធ្វើសេចក្ដីសង្រួមនូវឥន្ទ្រិយនោះ គឺជាអ្នកមានចិត្តជឿស៊ប់ក្នុងគុណព្រះរតនត្រ័យ និងសេចក្ដីប្រតិបត្តិតម្កល់ចិត្ត វៀរចាកតាមសិក្ខាបទដែលខ្លួនបានសមាទានហើយគ្រប់សិក្ខាបទទាំងអស់ មានសតិស្មារតី និងប្រាជ្ញាជាគ្រឿងរលឹក ធ្វើការពិចារណានូវអារម្មណ៍ដែលមកប៉ះតាមទ្វារទាំង ៦ មានចក្ខុទ្វារជាដើម ជ្រើសរើសនូវអារម្មណ៍មិនបានកាន់នូវនិមិត្ត និងអនុព្យញ្ជនៈនៃឥត្ថីភាពឬបុរិសភាពណាមួយ ដែលជាហេតុញុំាងរាគៈជាដើមឲ្យកើតឡើង និងមានប្រាជ្ញាពិចារណាបដិកូលភាព ក្នុងការប្រើប្រាស់នូវវត្ថុមានសំលៀកបំពាក់ជា

ដើម ហើយជាអ្នកអត់ធ្មត់ចំពោះក្ដៅនិងត្រជាក់ ដែលកើតអំពីរដូវឬក៏លោកធម៌ ៨ មានលាភ និងអលាភជាដើម ដែលជាគ្រឿងបង្វិលសត្វលោក ឲ្យវិលវល់ ហើយ ជាអ្នកមានសេចក្ដីព្យាយាមប្រឹងប្រែងអត់សង្កត់ ហាមឃាត់នូវ**អកុសលវិតក្កៈ** (សេចក្ដីត្រិះរិះអាក្រក់) មិនឲ្យកើតឡើងគ្របសង្កត់ចិត្តបានមែនពិត ។

## អាជីវៈនៃ ឧបាសក

កិរិយាលះបង់នូវជំនួញខុស ៥ ប្រការ ហើយប្រកបកិច្ចការចិញ្ចឹមជីវិតដោយត្រឹមត្រូវតាមធម៌ ឈ្មោះថា " **អាជីវនៃឧបាសក** " ដូចមានពុទ្ធប្បញ្ញត្តិដែលព្រះសម្មាសម្ពុទ្ធទ្រង់ហាមចំពោះភិក្ខុទាំងឡាយថា:

**បញ្ចិមា ភិក្ខវេ វណិជ្ជា**

**ឧបាសកេន អករណីយា**

ម្នាលភិក្ខុទាំងឡាយ ជំនួញខុសទាំងឡាយ ៥ ប្រការ គឺ ឧបាសកមិនគប្បីធ្វើឡើយ ។

## ជំនួញខុស ៥ ប្រការនោះគឺ

១- **សត្ថវណិជ្ជា:** ជួញគ្រឿងសស្ត្រាវុធសម្រាប់ប្រហារ គឺធ្វើគ្រឿងសស្ត្រាវុធនោះដោយខ្លួនឯង ឬប្រើអ្នកដទៃគេធ្វើឲ្យ ឬបានមកដោយហេតុឯណាមួយ ហើយលក់នូវគ្រឿងសស្ត្រាវុធនោះ ។

២- **សត្តវណិជ្ជា:** ជួញមនុស្ស

៣- **មំសវណិជ្ជា:** ជួញសាច់ គឺចិញ្ចឹមនូវសត្វទាំងឡាយមានជ្រូកជាដើម លុះដល់សត្វទាំងឡាយនោះចម្រើនធំឡើង ក៏សម្លាប់យកសាច់លក់ ។

៤- **មជ្ជវណិជ្ជា:** ជួញទឹកស្រវឹង គឺផ្សំគ្រឿងណាមួយឲ្យកើតឡើងជាទឹកស្រវឹងដោយខ្លួនឯង ឬទិញគេយកមកហើយលក់នូវទឹកស្រវឹងនោះ ។

៥- **វិសវណិជ្ជា:** ជួញថ្នាំពិស គឺចាត់ចែងផ្សំថ្នាំពិសឲ្យកើតឡើងដោយខ្លួនឯង ឬឲ្យគេផ្សំឲ្យ ឬបានមកដោយហេតុឯណាមួយ ហើយលក់នូវថ្នាំពិសនោះ។

ឧបាសក កាលវៀរចាកជំនួញខុសទាំង ៥ ប្រការនេះ ហើយបានប្រព្រឹត្តការចញ្ចឹមជីវិតដោយធម៌ ឈ្មោះថា មានអាជីវធម៌ដោយប្រពៃ ។

សូម្បីឧបាសិកា ក៏មានអាជីវៈដូចគ្នានឹងឧបាសក ដែរ ។

ម្យ៉ាងទៀត ការចិញ្ចឹមជីវិតឯណាដែលជាប់ដោយសីលនិងវត្ត ក្នុងសាសនាដទៃ ដូចយ៉ាងសេចក្តីប្រតិបត្តិព្រហ្មញ្ញសាសនា មានការទស្សន៍ទាយនូវនក្ខត្តឫក្សមានថ្ងៃ ខែ លិច ឬអណ្តែតល្អ អាក្រក់ដោយអំណាចដំណើរនៃព្រះអាទិត្យ ឬ ព្រះចន្ទ ដែលរះឡើង និងលិចចុះ ឬមានការរៀនមន្តអាគមអូមអាម ស្តោះព្រួស បួងសួង បន់ស្រន់អង្វរករ ធ្វើពលីកម្មផ្សេងៗ ជាដើម ដែលរាប់ចូលទៅក្នុងមិច្ឆាទិដ្ឋិ ជាមង្គលដទៃក្រៅចាកព្រះពុទ្ធសាសនា ដើម្បីចិញ្ចឹមជីវិត ។

កាលបើឧបាសកឧបាសិកា ស្វែងរកនូវមង្គលដទៃដោយហេតុ ព្រោះតែការរស់នៅមានសភាពបែបនេះ ឧបាសកឧបាសិកានោះ ក៏ឈ្មោះថាជាអ្នកមានត្រ័យ

សរណគមន៍ដាច់អស់ មិនឈ្មោះថា ឧបាសកឧបាសិកា ដោយពិតៗ ក្នុងព្រះពុទ្ធសាសនាឡើយ ។

កាលបើសទ្ធាក្នុងគុណព្រះត្រៃរតន៍រលត់ហើយ សីលក៏រលត់ដែរ កាលបើសីលមិនមានហើយ គុណធម៌ដទៃមានសមាធិ វិបស្សនា ក៏ដាច់សូន្យទៅតាមលំដាប់ កាលបើគុណធម៌ទាំងអស់នោះសាបសូន្យទៅហើយនោះ ឧបាសកឧបាសិកានោះ ក៏ក្លាយទៅជាជនអភ័ព្វចាកមគ្គផលក្នុងព្រះពុទ្ធសាសនាមែនពិត។

## អនុបសម្បន្នសីល

សីលរបស់ **អនុបសម្បន្ន** បានដល់សីល១០ របស់ **សាមណេរ** និង **សាមណេរី** ទាំងឡាយ តែក្នុងកាលបច្ចុប្បន្ននេះមានត្រឹម **សាមណេរ** ប៉ុណ្ណោះ មិនឃើញមាន **សាមណេរី** ឡើយ ។

បើយោគាវចរមានភាពនៃខ្លួនជាសាមណេរ ត្រូវកាន់តាមសីលរបស់ខ្លួន កុំប្រព្រឹត្តកន្លង ឲ្យទាស់ខុសក្នុងវិន័យរបស់សាមណេរឡើយ ឯវិន័យរបស់សាមណេរនោះគឺ **សិក្ខាបទ** ១០, **ទណ្ឌកម្ម** ១០, **នាសនង្គ** ១០, **សេខិយវត្ត** ៧៥ **លោកវជ្ជសិក្ខាបទ** ៤៩ (ចូររកមើលក្នុង *វិន័យសាមណេរ* លោករៀបរៀងសព្វគ្រប់ហើយ) ។

សាមណេរ ត្រូវមានការសង្រួមឥន្ទ្រិយទាំង ៦ មាន **ចក្ខុន្ទ្រិយ** ជាដើម បិទកុំឲ្យ **អកុសលធម៌** មាន **អភិជ្ឈា** និងទោមនស្សជាដើមកើតគ្របសង្កត់ចិត្តបាន ក្នុងសម័យដែលអារម្មណ៍ ៦ មានរូបារម្មណ៍ជាដើម មកប៉ះផ្ទប់នឹងទ្វារ ៦ មានចក្ខុទ្វារជាដើមផង, ត្រូវមានការចិញ្ចឹមជីវិត ត្រូវលះបង់នូវការចិញ្ចឹមជីវិតខុសចាកគន្លងធម៌ផង ហើយត្រូវមានការពិចារណាក្នុងការទទួលប្រើប្រាស់នូវ

បច្ច័យ ៤ មាន **ចីវរប្បច្ច័យ** ជាដើម ឲ្យត្រឹមត្រូវល្អកុំឲ្យ **ឧបក្កិលេស** មានការឈ្លក់ជាប់វង្វេងជាដើម កើតឡើងគ្របសង្កត់ចិត្ត ក្នុងការប្រើប្រាស់នូវបច្ច័យ ៤ នោះផងទៀត ។

ការសង្រួមឥន្ទ្រិយក្តី ការលះបង់នូវ **មិច្ឆាជីវៈ** សមាទានកាន់យកនូវសម្មាជីវៈក្តី ការពិចារណានូវបច្ច័យទាំង ៤ ក្តី នឹងមានពោលក្នុងសីលរបស់ភិក្ខុក្នុងទីខាងមុខ ។

## ភិក្ខុសីល សីលរបស់ភិក្ខុ មាន ៤ យ៉ាងគឺ

១- **បាដិមោក្ខសំវរសីលៈ** សីលសម្រេចអំពីសង្រួមតាមសិក្ខាបទ ក្នុង **បាដិមោក្ខ** ។

២- **ឥន្ទ្រិយសំវរសីលៈ** សីលសម្រេចអំពីសង្រួម **ឥន្ទ្រិយ** ។

៣- **អាជីវបារិសុទ្ធិសីលៈ** សីលសម្រេចអំពីព្យាយាមជាគ្រឿងចិញ្ចឹមជីវិតស្អាត ។

៤- **បច្ច័យសន្និស្សិតសីលៈ** សីលអាស្រ័យដោយការកើតឡើងដោយការពិចារណា ហើយទើបបរិភោគប្រើប្រាស់នូវបច្ច័យ ។

ក៏សីលទាំង ៤ នេះ ខ្ញុំនឹងសូមវិនិច្ឆ័យអំពី **បាដិមោក្ខសំវរសីល** ជាមុន ។ សីលដែលព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងទុកជា **បុគ្គលាធិដ្ឋាន**ថា " ភិក្ខុក្នុងសាសនានេះ បានសង្រួមហើយ ដោយគ្រឿងសង្រួមគឺ **បាដិមោក្ខ** អ្នកឃើញ

ភ័យសូម្បីទោសបន្តិចបន្តួច បានសមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ប៉ុណ្ណោះ ហៅថា **ចាដិមោក្ខសំវរសីល**” ។

## សេចក្តីអធិប្បាយ

ពាក្យថាបានសង្រួមដោយគ្រឿងសង្រួម **គឺចាដិមោក្ខ** ក្នុងពាក្យថាបានសង្រួម គឺ **ចាដិមោក្ខ** នោះ ត្រង់ពាក្យថា “**ចាដិមោក្ខ**” បានសេចក្តីដូចម្តេច សំដៅយកអ្វី ព្រោះហេតុយ៉ាងណា ?

ពាក្យថា “**ចាដិមោក្ខ**[14]” បានសេចក្តីថា ធម្មជាតិដែលបុគ្គលណារក្សា តែងញ៉ាំងបុគ្គលនោះឲ្យរួចចាកទុក្ខទាំងពួង មានទុក្ខក្នុងអបាយជាដើមផង, ឲ្យរួចភ័យទាំងពួងមាន **អត្តានុវាទភ័យ** ជាដើមផង គឺសំដៅយកសិក្ខាបទទាំងប៉ុន្មានដែលព្រះពុទ្ធទ្រង់បញ្ញត្តមកដោយអាជ្ញារបស់ព្រះអង្គនោះឯង ព្រោះថាសិក្ខាបទទាំងនោះ សុទ្ធតែមានអំណាចនឹងញ៉ាំងអ្នកថែរក្សាតាមឲ្យរួចចាកទុក្ខ និងភ័យទាំងពួង ដូចបានពោលមកហើយ ។ ព្រោះហេតុអ្វីបានជាព្រះអង្គទ្រង់សម្តែងចាត់**ចាដិមោក្ខ**នេះទុកជាគ្រឿងសង្រួម ?

បានជាព្រះអង្គចាត់**ចាដិមោក្ខ**ទុកជាគ្រឿងសង្រួមដូច្នេះ ព្រោះសិក្ខាបទទាំងប៉ុន្មានដែលសង្រួមមកឲ្យឈ្មោះថា **ចាដិមោក្ខ** នោះ សុទ្ធតែសម្រាប់ឲ្យ

---

[14] បាដិមោក្ខមាន ២ យ៉ាងគឺ សីលបាដិមោក្ខ បានដល់សីលសម្រេចមកអំពីសង្រួមតាម ច្បាប់មាត្រា ព្រះវិន័យ ១, គន្ថបាដិមោក្ខ បានដល់ច្បាប់មាត្រា ព្រះវិន័យ ១, (ក្នុងទីនេះសំដៅយកសីលបាដិមោក្ខ) ។បាតិមោក្ខទ្វេសមាន ២ យ៉ាង គឺឱវាទបាតិមោក្ខ បានដល់ដំបូន្មានរបស់ព្រះអង្គមានពាក្យខន្តិ បរមំ តបោ តីតិក្ខា ជាដើម ។ អាណាបាដិមោក្ខ បានដល់បាដិមោក្ខ ដែលភិក្ខុសម្តែងក្នុងថ្ងៃឧបោសថ មានពាក្យថា សុណាតុ មេ ភន្តេ ជាដើម ។

សង្រួមបិទនូវសេចក្ដីប្រព្រឹត្តិល្មើសតាមទ្វារកាយ និងតាមទ្វារវាចាទាំងអស់ ។ រួបរួមមកពាក្យថា "បានសង្រួមដោយគ្រឿងសង្រួម" គឺ**បាដិមោក្ខ** នោះ សំដៅយកបានសង្រួមតាមសិក្ខាបទព្រះសម្ពុទ្ធទ្រង់បញ្ញត្តទុកមកនោះឯង ។

- ពាក្យបរិបូណ៌ដោយអាចារនិងគោចរនោះ អ្វីហៅថាអាចារ អ្វីហៅថាគោចរ មានសេចក្ដីយ៉ាងណា?

-ដែលនឹងវិសជ្ជនា ក្នុងពាក្យទាំង ២ នេះ សូមវិសជ្ជនាអំពីពាក្យថា អាចារជាមុន ហើយសន្សឹមវិសជ្ជនាអំពីពាក្យថា គោចរជាបន្ទាប់តទៅ ។

## អាចារ និងអនាចារ

មារយាទ ឬសណ្ដាប់ ដែលត្រូវការដោយប្រយោជន៍ទាំងឡាយ សូមនិយាយអំពី ***អាចារ*** ជាដំបូងសិន ព្រោះធម៌ទាំង ២ ជាគូបដិបក្ខនឹងគ្នាគឺ ***អាចារ*** ប៉ែកខាងកុសល ***អនាចារ*** ប៉ែកខាងអកុសល។ ក៏ពាក្យថា ***អនាចារ*** នេះលោកសំដៅយកសេចក្ដីប្រព្រឹត្តិល្មើសដោយកាយ ឬវាចា ឬព្រមទាំងកាយទាំងវាចា ។ ន័យមួយទៀតថា: សំដៅយកភាពដែលទ្រុស្តសីលទាំងអស់។ តែបើពោលអំពីការចិញ្ចឹមជីវិតវិញ សំដៅយកអំពើដែលភិក្ខុចិញ្ចឹមជីវិត ដោយការឲ្យឬស្សី ឲ្យស្លឹកឈើ, ឲ្យផ្កាឈើ, ផ្លែឈើ, ឲ្យគ្រឿងលំអិតសម្រាប់ងូតទឹក ឲ្យឈើស្ទន់ដល់ត្រកូល ។ ពុំនោះដោយសម្ដែងអាការបន្ទាបខ្លួនទៅរកទាយកហាក់ដូចជាខ្ញុំកំដរគេ ឬដោយជួយផ្គត់ផ្គង់អែបអប ការពារពាក្យភ្លាត់របស់បុគ្គលដទៃ ដើម្បីឲ្យគេស្រឡាញ់ដោយពោលពាក្យឡេះឡោះពិតខ្លះ ទេខ្លះ ដូចជាសម្លសណ្ដែក ឆ្អិនខ្លះ ឆៅខ្លះ ដោយតាំងខ្លួនជាអ្នកថែរក្សាទារកឲ្យគ្រហស្ថ

ដោយធ្វើជាជើងសា នាំដំណឹងឲ្យគ្រហស្ថ ឬដោយគ្រឿងចិញ្ចឹមជីវិតខុសណាមួយ ក្រៅអំពីនេះ ដែលព្រះសម្មាសម្ពុទ្ធទ្រង់តិះដៀល ដូចធ្វើគ្រូពេទ្យមើលជម្ងឺយកទ្រព្យជាដើម។ ទាំងនេះហៅថា **អនាចារ** ទាំងអស់។ **អនាចារ** នេះមានខ្លះលោកចែកចេញជា ២ យ៉ាងគឺ:

១- **កាយិកៈ** ប្រព្រឹត្តល្មើសតាមទ្វារកាយ ។

១- **វាចសិកៈ** ប្រព្រឹត្តល្មើសតាមទ្វារវាចា ។

**សេចក្តីថា:** ភិក្ខុអង្គខ្លះ វេលាដែលចូលទៅក្នុងជំនុំសង្ឃ សម្តែងសេចក្តីមិនគោរព ឈរ ឬអង្គុយប្រគៀកប្រគងនឹងភិក្ខុចាស់, ឈរ ឬអង្គុយលើអាសនៈខ្ពស់ជាងភិក្ខុចាស់ អង្គុយទទូរក្បាល ឈរនិយាយ និយាយវាសដៃ ភិក្ខុចាស់ចង្រ្កមជើងទទេ ខ្លួនពាក់ស្បែកជើង ភិក្ខុចាស់ចង្រ្កមលើទីទាប ខ្លួនចង្រ្កមលើទីខ្ពស់ ភិក្ខុចាស់ចង្រ្កមផ្ទាល់ដី ខ្លួនចង្រ្កមលើទីចង្រ្កម. ឈរ ឬ អង្គុយជ្រៀតជ្រែកភិក្ខុចាស់ ហាមអាសនៈភិក្ខុខ្ចី ដាក់ឧសក្នុងរោងភ្លើង ឬបិទទ្វាររោងភ្លើងមិនបានប្រាប់ភិក្ខុចាស់ ចុះទៅកាន់កំពុងទឹកជ្រៀតជ្រែកភិក្ខុចាស់ ចុះមុនភិក្ខុចាស់។ វេលាងូតទឹកឡើងមកវិញទៅកាន់ស្រុក និងចេញអំពីស្រុកក៏មានន័យដូចគ្នា ។ ពុំនោះដើរចូលទៅកាន់បន្ទប់របស់ត្រកូល ដែលគេបិទបាំងទុកមានស្រ្តីអង្គុយត្រង់ទីណា ស្ទុះចូលទៅត្រង់ទីនោះ ច្រមស្ទាបអង្អែលក្បាលកូនក្មេងប្រុសៗ ទាំងអស់នេះ ចាត់ជាប្រព្រឹត្ត **អនាចារ** តាមទ្វារកាយ ។

ភិក្ខុអង្គខ្លះ វេលាចូលទៅកាន់ជំនុំសង្ឃសម្តែងសេចក្តីមិនគោរព មិនប្រាប់ភិក្ខុចាស់មុនហើយនិយាយធម៌ សួរប្រស្នា សម្តែង**បាដិមោក្ខ** ឈរនិយាយ

និយាយវាសដៃ។ បើចូលទៅកាន់ស្រុកឃើញស្ត្រីចាស់ក្តី ក្មេងក្តី ពោលពាក្យចចាកអារ៉ាកថា "នែស្ត្រីឈ្មោះនេះ នែស្ត្រីគោត្រនេះមានបបរទេ? មានបាយទេ? មានបង្អែមទេ? យើងបានអ្វីផឹក? បានអ្វីទំពាស៊ី? បានអ្វីបរិភោគ?

អ្នកនាងទាំងឡាយបានអ្វីប្រគេនយើង? ទាំងនេះ ចាត់ជាប្រព្រឹត្ត **អនាចារ** តាម **ទ្វារវាចា**" ។ ខាងឯ **អាចារ** វិញលោកសំដៅយក សេចក្តីសង្រួមសីលទាំងអស់ដែលខុសចាក **អនាចារ** ដូចបានពោលមកហើយនោះ ហើយលោកមានចែកចេញជាពីរយ៉ាងតាមទ្វារកាយ និងទ្វារវាចាដូចគ្នា តែសេចក្តីអធិប្បាយផ្ទុយគ្នានឹង **អនាចារ** ទាំងពីរនុ៎ះ អ្នកសិក្សាគប្បីផ្ទេរដាក់អំពីគ្នាមកពិចារណាផងចុះ។ ន័យមួយទៀត លោកសំដៅយកភិក្ខុដែលប្រកបដោយសេចក្តីគោរព ប្រកបដោយសេចក្តីកោតក្រែង បរិបូណ៌ដោយ **ហិរិ** និង **ឧត្តប្ប** ស្លៀកដណ្តប់ល្អតាមសេក្ខិយវត្ត ឈានទៅមុខ ត្រឡប់ថយក្រោយ ក្រឡេកមើលទៅមុខ ក្រឡេកមើលទៅទិសផ្សេងៗ បត់អង្គុយ លាតសណ្តូក ជាទីនាំមកនូវសេចក្តីជ្រះថ្លា មានចក្ខុសម្លឹងចុះក្រោម បរិបូណ៌ដោយឥរិយាបថ គ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំង ៦ ដឹងប្រមាណក្នុងភោជន ប្រកបរឿយៗ នូវសេចក្តីភ្ញាក់រលឹក ប្រកបដោយ**សតិសម្បជញ្ញៈ** មានសេចក្តីប្រាថ្នាតិច មានសេចក្តីសន្តោសមិនច្រឡូកច្រឡំដោយគ្រហស្ថ ឬដោយពួក ប្រារព្ធសេចក្តីព្យាយាម ធ្វើដោយផ្ចិតផ្ចង់ក្នុងអភិសមាចារិកវត្ត ច្រើនដោយសេចក្តីគោរពកោតក្រែង ដល់បុគ្គលដែលមានគុណគួរគោរពកោតក្រែងទាំងនោះហៅថា **អាចារ** ទាំងអស់ ។

# គោចរនិងអគោចរ

សភាពដែលជាកន្លែងទីត្រេចទៅរបស់ឥន្ទ្រិយទាំង ៦ មានចក្ខុន្ទ្រិយជាដើម បើពោលឲ្យអស់ជើងទៅ មានទាំងអាក្រក់ទាំងល្អ គឺអារម្មណ៍ដែលជាហេតុឲ្យកើតទោសមានទ្រុស្តសីលជាដើមក៏មាន ជាហេតុឲ្យកើតគុណមានសីលគុណក៏មាន តែក្នុងទីនេះលោកសំដៅយកតែអារម្មណ៍ជាហេតុឲ្យកើតគុណមានសីលគុណជាដើមតែម៉្យាងប៉ុណ្ណោះ ឯអារម្មណ៍ដែលជាហេតុនឹងឲ្យកើតទោសមានទ្រុស្តសីលជាដើមនោះ លោកមិនសំដៅយកឡើយ គឺលោកឲ្យឈ្មោះ ថា "**អគោចរ**" ដូច្នេះវិញ ព្រោះហេតុនោះដែលនឹងអាចពន្យល់ឲ្យងាយចូលចិត្តអំពីគោចរនេះបាន តោងតែអធិប្បាយអំពីអគោចរទុកជាមុនសិន ។

អារម្មណ៍ដែលជាអគោចរនោះ ព្រះវិជិតមារទ្រង់តាស់សម្ដែងទុកជាបុគ្គលាធិដ្ឋានដូច្នេះថា មានភិក្ខុអង្គខ្លះក្នុងសាសនានេះ មានស្ត្រីពេស្យា[15] ស្ត្រីមេម៉ាយ ស្ត្រីក្រមុំចាស់[16] មនុស្សខ្ទើយ នាងភិក្ខុនី រោងសុរាជាទីគោចរ ឬនៅជាប់ដោយស្ដេចដោយអាមាត្យធំៗ របស់ស្ដេច ដោយពួកតិរ្ថិយ ដោយសាវកនៃតិរ្ថិយ ដោយគ្រហស្ថដែលមិនសមគួរ ពុំនោះទៅសេពគប់រាប់រកត្រកូលដែលមិនមានសទ្ធា មិនជ្រះថ្លាក្នុង **គុណព្រះរតនត្រ័យ** តែងជេរប្រទេចផ្ដាសា រករឿងរកហេតុអំពី **ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា** ទាំងឡាយ ទាំងនោះចាត់ជា

---

[15] ស្ត្រីសាធារណៈ ។

[16] ច្រើនហៅតាមពាក្យសៀមថា ស្ត្រីសៅកែ ។

**អគោចរ** ទាំងអស់ **ឯគោចរ** គប្បីដឹងតាមលំអានដែលខុសគ្នាអំពី **អគោចរ** នេះចុះ ។

- ន័យមួយទៀតចែកចេញជា ៣ យ៉ាងគឺៈ

១- **ឧបនិស្សយគោចរៈ** អារម្មណ៍ឧបនិស្ស័យនៃសីលគុណជាដើម បានដល់ **កល្យាណមិត្ត** ។

២- **អារក្ខគោចរៈ** អារម្មណ៍ជាគ្រឿងរក្សាទុកនូវចក្ខុទ្វារជាដើម បានដល់ **សតិ** ។

៣- **ឧបនិពន្ធគោចរៈ** អារម្មណ៍ជាគ្រឿងចងទុកនូវចិត្តបានដល់ **សតិបដ្ឋាន**[17] ។

## សេចក្តីអធិប្បាយ

លោកដែលជាកល្យាណមិត្តបរិបូណ៌ដោយគុណ គឺ**កថាវត្ថុ** ១០[18] ក្តី លោកដែលជាពហុស្សូតតែងណែនាំអ្នក ដែលចូលទៅនៅជ្រកកោនអាស្រ័យផង

---

[17] ក្នុងទីខ្លះលោកពោលថាបានដល់កម្មដ្ឋាន ។

[18] កថាវត្ថុ ១០ គឺអប្បិច្ឆកថា ពាក្យនាំឲ្យមានសេចក្តីប្រាថ្នាតិច ១, សន្តុដ្ឋិកថា ពាក្យនាំឲ្យមានសេចក្តីសន្តោស ១, បវិវេគកថា ពាក្យនាំឲ្យមានសេចក្តីស្ងប់ស្ងាត់ ១, អសំសគ្គកថា ពាក្យនាំមិនឲ្យជាប់ជំពាក់ ១, វិរិយារម្ភកថា ពាក្យនាំប្រារព្ធព្យាយាម ១, សីលកថា ពាក្យនាំឲ្យតាំងនៅក្នុងសីល ១, សមាធិកថា ពាក្យនាំឲ្យសមាធិកើត ១, បញ្ញាកថា ពាក្យនាំបញ្ញា

ឲ្យបានស្តាប់នូវធម៌ដែលមិនទាន់បានស្តាប់ ដែលបានស្តាប់ហើយឲ្យកាន់តែផូរផង់ឡើង ឲ្យឆ្លងផុតចាកសេចក្តីសង្ស័យក្នុងធម៌ដែលគួរសង្ស័យ ឲ្យបានតម្រង់

សេចក្តីយល់ឲ្យត្រង់ ឲ្យបានញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លាឡើងក្តី លោកដែលបរិបូរដោយ **សទ្ធា, សីល, សុត, ចាគ, បញ្ញា**, កាលបើបានបុគ្គលណាមួយ សិក្សាតាមទៅហើយ មុខជានឹងបានចម្រើនដោយគុណទាំងនោះក្តី លោកទាំងនេះចាត់ជា **ឧបនិស្ស័យគោចរ** ដោយបុគ្គលាធិដ្ឋានទេសនា ។

**អារក្ខគោចរ** សោត ក៏ព្រះសក្យមុនីទ្រង់ត្រាស់សម្តែងទុក បុគ្គលាធិដ្ឋានទេសនាដូចគ្នាថា ភិក្ខុក្នុងសាសនានេះ វេលាចូលទៅកាន់ស្រុកក្តី ដើរទៅតាមថ្នល់ក្តី តែងមានចក្ខុសម្លឹងចុះក្រោម ក្រឡេកមើលប្រមាណមួយជួរនឹម ដើរសង្រួមប្រយ័ត្នដោយល្អ មិនបានក្រឡេកមើល ដំរី សេះ រថ អ្នកថ្មើរជើង ស្រីប្រុសជាដើម មិនមើលទៅលើ មិនអើតឈ្ងោកមើលទៅក្រោម មិនក្រឡេកមើលទៅទិសផ្សេងៗ ទាំងនេះចាត់ជា **អារក្ខគោចរ** ។

ឯ**ឧបនិពន្ធគោចរ** សំដៅយក **សតិបដ្ឋាន** ទាំង ៤ ដោយត្រង់ៗ ព្រោះ**សតិបដ្ឋាន** ទាំង ៤ នោះព្រះសម្ពុទ្ធទ្រង់ត្រាស់ទុកថា ជាអារម្មណ៍ដែលព្រះអង្គជាបិតាទ្រង់ប្រទានទុកឲ្យ សម្រាប់ចងក្រៀកទុកនូវភាវនាចិត្ត សមដូចជាគាថាដែលលោកនិពន្ធទុកដូច្នេះ ។

---

កើត ១, វិមុត្តិកថា ពាក្យនាំឲ្យវិមុត្តិកើតឡើង ១, វិមុត្តិញាណទស្សនកថា ពាក្យនាំឲ្យវិមុត្តិញាណទស្សនកើត ១ ។

យថា ថម្ភេ និពន្ធេយ្យ វច្ឆំ ទមន្នរោ ឥធ ពន្ធេយ្យវំ សកំ ចិត្តំ សិយារម្មណេ ទឡ្ហំ ។

**សេចក្ដីថា:** នរជនក្នុងលោកនេះ កាលដែលទូន្មាននូវកូនគោ គេរមែងចងក្រៀកទុកឲ្យយ៉ាងមាំនឹងសសរស្ដម្ភដូចម្ដេចមិញ ឯព្រះយោគាវចរកុលបុត្តសោត កាលទូន្មាននូវចិត្តរបស់ខ្លួន ក៏ត្រូវតែចងក្រៀកនូវចិត្តនោះដោយសតិយ៉ាងមាំក្នុងអារម្មណ៍របស់ **សតិបដ្ឋាន** ដូច្នោះ ទើបអាចដើម្បីនឹងទូន្មានបាន។ ទាំងនេះចាត់ជា **ឧបនិពន្ធគោចរ** ។

ត្រង់ដែលថាប្រកបដោយ **អាចារ** និង **គោចរ** នោះគឺប្រកបដោយ **អាចារ** និង **គោចរ** ដូចបានពណ៌នាមកទាំងនេះឯង ។

**អាចារ** និង**គោចរ** ទាំងពីរនេះ ព្រះពុទ្ធទ្រង់បានរាប់បញ្ចូលក្នុង **បាដិមោក្ខ** ព្រោះ **អាចារសម្បទា** និង **គោចរសម្បទា** ជាជំនួយដល់ **បាដិមោក្ខសំវរសីល** គឺថា **បាដិមោក្ខសំវរសីល** ដែលនឹងសម្រេចទៅបាន ក៏អាស្រ័យដោយភិក្ខុបានប្រតិបត្តិតាមលំអាន **អាចារ** និង**គោចរ** នេះផង កាលបើមិនប្រតិបត្តិតាមទេ **បាដិមោក្ខសំវរសីល** ក៏រកសម្រេចទៅពុំបានឡើយមែនពិត ។

## ឃើញភ័យក្នុងទោសបន្តិចបន្តួច

**អធិប្បាយ:** **សេក្ខិយវត្ត** និង **ខន្ធកវត្ត** ត្រង់សិក្ខាបទណាដែលជា **អចិត្តក** សូម្បីប្រព្រឹត្តកន្លងមិនចាំបាច់មានចិត្តក្លែងក៏គង់ត្រូវ **អាបត្តិ** ឬ **អកុសលចិត្តុប្បាទ** ទាំង ១២ ជាដើមហៅថា ទោសបន្តិចបន្តួច ។

អើ ! ថ្វីបើទោសយ៉ាងតូចបន្តិចបន្តួចជាបរមាណុ[19] យ៉ាងនេះក៏លោកមិនហ៊ានមើលមិនហ៊ានប្រព្រឹត្តកន្លងឡើយ ប្រាកដហាក់ដូចជាទោសទាំងនោះទំហំស្មើដោយភ្នំសិនេរុ ដែលមានកំពស់ដល់ ៦៨ សែនយោជន៍ ពុំនោះអាបត្តិដែលជាទោសយ៉ាងតូចបំផុត ដូច **អាបត្តិទុក្កដសិត** ក៏លោកក្រឡេកមើលទៅឃើញគួរឲ្យខ្លាច ហាក់ដូចជាទំហំស្មើដោយ **អាបត្តិបារាជិក** មិនតែប៉ុណ្ណោះឡើយ សូម្បីតែអំពើណាដែលមិនទំនង តែព្រះពុទ្ធបានបដិសេធថា មិនមែនជាអាបត្តិ មិនមែនជាការល្មើស ក៏លោកមិនហ៊ានប្រព្រឹត្តកន្លងដែរ ។ ដំណើរដែលលោកឃើញភ័យក្នុងទោសបន្តិចបន្តួចនោះបែបនេះឯង ។

ត្រង់ពាក្យថា សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ មានសេចក្ដីថាសមាទានសិក្សានូវកិច្ចឯណានីមួយ ដែលជាគ្រឿងជំនួយដល់សិក្ខាបទទាំងឡាយ ដូចយ៉ាងបញ្ញត្តិ ៩[20] មានមូលបញ្ញត្តិជាដើម ហើយកាន់តាមប្រតិបត្តិតាមកិច្ចទាំងនេះ ឈ្មោះ សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ។

---

[19] ពាក្យថា " បរមាណុ " នេះជាវិធីគិតប្រមាណ ឬ បែបពាក្យអដ្ឋកថា អង្គុលី ១ មានធញ្ញមាស ៧, ធញ្ញមាស ១ មានឩកា ៧. ឩកា ១ មានលិក្ខា ៧. លិក្ខា ១ មានរថរេណុ ៣៦, រថរេ ១ មានតជ្ជារី ៣៦. តជ្ជារី ១ មានអណុ ៣៦, អនុ ១ មានបរមាណុ ៣៦ ។

[20] បញ្ញត្តិ ៩ យ៉ាងគឺ មូលបញ្ញត្តិ បញ្ញត្តិដើមក្នុងសិក្ខាបទនីមួយ ៗ ១, អនុប្បញ្ញត្តិ បញ្ញត្តិថែមបន្ទាប់ក្នុងសិក្ខាបទណាដែលច្រើនលើក ១, អនុប្បន្នប្បញ្ញត្តិ បញ្ញត្តិបង្ការហេតុដែលមិនទាន់កើតបានដល់គរុធម៌ ៨ របស់នាងភិក្ខុនី ។ សព្វត្ថប្បញ្ញត្តិ បញ្ញត្តិចំពោះភិក្ខុដែលនៅគ្រប់ប្រទេសទាំងអស់ ១. បរទេសប្បញ្ញត្តិ បញ្ញត្តិទូទៅទាំងភិក្ខុទាំងនាងភិក្ខុនី១, អសាធារណប្បញ្ញត្តិ បញ្ញត្តិចំពោះតែភិក្ខុ ឬចំពោះតែនាងភិក្ខុនីមិនទូទៅដល់គ្នានិងគ្នា ១, ឯកតោបញ្ញត្តិ បញ្ញត្តិតែខាងភិក្ខុនី ឬ តែខាងនាងភិក្ខុនីមួយផ្នែក ១. ឧភតោបញ្ញត្តិ បញ្ញត្តិចំពោះទាំងពីរផ្នែក ១ ។

សេចក្តីដែលបានពោលរួបរួមមកទាំងប៉ុន្មាននេះចាត់ជា **ចាដិមោក្ខសំវរសីល។**

**ចាដិមោក្ខសំវរសីល** នេះមានសទ្ធាសេចក្តីជឿ **ពុទ្ធប្បញ្ញត្តិ** ជាគ្រឿងជំនួយឲ្យសម្រេច គឺថាភិក្ខុអាចឲ្យសម្រេចបរិបូណ៌បានដោយអំណាចសទ្ធា ជឿក្នុងសិក្ខាបទដែលព្រះពុទ្ធទ្រង់បញ្ញត្តទុកមក ព្រោះថាការដែលបញ្ញត្តនូវសិក្ខាបទនេះផុតវិស័យរបស់សាវក មានតែព្រះពុទ្ធទើបអាចបញ្ញត្តបាន ហេតុនោះត្រូវតែភិក្ខុជឿតាម ហើយសមាទានប្រតិបត្តិតាមកុំបីអាឡោះអាល័យក្នុងជីវិតរបស់ខ្លួនឡើយ ឲ្យសមដូចគាថាដែលលោកនិពន្ធទុកដូច្នេះ ។

ចាដិមោក្ខំ វិសោធេន្តោ អប្បេវ ជីវិតំ ជហេ
បញ្ញត្តំ លោកនាថេន ន ភិន្ទេ សីលសំវរំ ។

**សេចក្តីថា:** កុលបុត្រអ្នកមានសទ្ធា កាលដែលជម្រះ **ចាតិមោក្ខសំវរសីល** សូវប្រថុយលះបង់ជីវិតរបស់ខ្លួន កុំតែទម្លាយនូវសីល ដែលព្រះបរមលោកនាថទ្រង់ត្រាស់បញ្ញត្តទុកមកនោះឡើយ ។

កិកីវ អណ្ឌំ ចមរីវ វាលធិំ
បិយំវ បុត្តំ នយនំវ ឯកកំ
តថេវ សីលំ អនុរក្ខមានកា
សុបេសលា ហោថ សទា សគារវា

**សេចក្តីថា:** មេបក្សីត្រដេវរ៉ិច ស៊ូប្រថុយលះបង់ជីវិត ខំរក្សានូវពង របស់ខ្លួនយ៉ាងណា, មេម្រឹគចាមរី ស៊ូប្រថុយលះបង់ជីវិត ខំរក្សានូវកន្ទុយរបស់ខ្លួនយ៉ាងណា កុដុម្ពិកខំរក្សាកូនប្រុសតែមួយជាទីស្រឡាញ់យ៉ាងណា, បុរស

ខ្វាក់ភ្នែកម្ខាងខំរក្សានូវភ្នែកមួយដែលសល់នៅយ៉ាងណា, លោកទាំងឡាយចូររក្សាសីលរបស់ខ្លួន ជាទីស្រឡាញ់ពេញចិត្តឲ្យណាស់ ចូរឲ្យប្រកបដោយសេចក្តីគោរពសព្វកាល ឲ្យបានដូចជាមេបក្សីត្រដេវរ៉ិចរក្សាពងជាដើមនោះចុះ ។

## ឥន្ទ្រិយសំវរសីល

សីលដូចម្តេចហៅថា *ឥន្ទ្រិយសំវរសីល* ?

សីលដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែង ដោយបុគ្គលាធិដ្ឋានទេសនាថា: ភិក្ខុដែលបានស្ថិតនៅក្នុង *ចាដិមោក្ខសំវរសីល* រួចហើយនោះ កាលបើបានឃើញរូបដោយភ្នែក ឮសម្លេងដោយត្រចៀក ធុំក្លិនដោយច្រមុះ ស្រស់ស្រូបរសដោយអណ្តាត ប៉ះពាល់ផ្សព្វដោយកាយ ដឹងអារម្មណ៍ដោយចិត្តហើយ មិនបានកាន់យកនូវ**និមិត្ត** និង**អនុព្យញ្ជនៈ**ក្នុងអារម្មណ៍ទាំងនោះ ខំតែប្រតិបត្តិរក្សានូវឥន្ទ្រិយទាំង ៦ មិនឲ្យអកុសលធម៌ដ៏លាមក គឺ**អភិជ្ឈា** និង**ទោមនស្ស** តាមជិះជាន់គ្របសង្កត់ចិត្តបាន " ប៉ុណ្ណោះហៅថា *ឥន្ទ្រិយសំវរសីល* " ។

## សេចក្តីអធិប្បាយថា

ត្រង់ពាក្យថា មិនបានកាន់យកនូវនិមិត្ត និងអនុព្យញ្ជនៈ មានសេចក្ដីថាៈ ហេតុដែលអាស្រ័យនៅក្នុងសន្ដានល្មមឲ្យចំណាំដឹងបានថាជាស្រ្ដី ឬបុរសហៅថានិមិត្ត ។ ហេតុដែលអាស្រ័យនៅក្នុងសន្ដានរបស់ស្រ្ដីហៅថា **ឥត្ថីនិមិត្ត**។ ដែលអាស្រ័យនៅក្នុងសន្ដានរបស់បុរសហៅថា **បុរិសនិមិត្ត** តួយ៉ាងទម្រង់រូបដែលប្លែកគ្នា ភាពដែលមានសាច់ដោះដុសខ្លោតឡើង និងមិនខ្លោតឡើង ភាពដែលមិនមានពុកមាត់ ពុកចង្កា និងមានពុកមាត់ ពុកចង្កា មានសំពត់សម្រាប់ចងសក់ និងមិនមានសំពត់សម្រាប់ចងសក់ជាដើម ។ ពុំនោះហេតុជាទីកើតនៃកិលេស ក៏ហៅថានិមិត្តដែរ គឺហេតុជាទីកើតនៃរាគៈហៅថា **សុភមិត្ត**[21] ដែលជាទីកើតនៃ**ទោសៈ**ហៅថា **បដិឃនិមិត្ត**[22] ដែលជាទីកើតនៃ**មោហៈ** ហៅថា **ឧបេក្ខានិមិត្ត**[23] អាការមានដៃ, ជើង, ក្បាល, សំណើច, សម្ដីនិយាយ, សម្ដីវាចាទៅមក និងអាការក្រឡេកចុងភ្នែកដើមភ្នែកជាដើមរបស់ស្រ្ដីនិងបុរស ដែលជាគ្រឿងធ្វើនូវភាពរបស់កិលេសឲ្យប្រាកដឡើងហៅថាអនុព្យញ្ជនៈ ។

ត្រង់ដែលថា មិនកាន់យកនោះ គឺមិនសម្គាល់ថា " នេះស្រ្ដី នេះប្រុស នេះស្អាត នេះមិនស្អាត នេះពីរោះ នេះមិនពីរោះ " ដូច្នេះជាដើម គឺឲ្យនៅតែត្រឹមឃើញត្រឹមឮប៉ុណ្ណោះ ឬអាការណាដែលមាននៅក្នុងសរីរៈដូចសក់ និងរោមជាដើមក៏សម្គាល់ថា "នេះសក់ នេះរោមជាដើមប៉ុណ្ណោះឯង" ។ ឯអារម្មណ៍

---

21 អាការជាទីប្រាថ្នាដែលជាហេតុឲ្យកើតរាគៈ

22 អាការមិនជាទីប្រាថ្នាដែលជាហេតុឲ្យកើតទោសៈ

23 អារម្មណ៍ដែលជាវត្ថុនៃអញ្ញាណុបេក្ខា ។

ឯទៀត ដែលមកប៉ះពាល់ដល់ទ្វារឯទៀតក្រៅពីនេះ ក៏គប្បីត្រិះរិះយកតាមលំអាន ដែលពោលមកនេះផងចុះ ។

ត្រង់ពាក្យថា ខំប្រតិបត្តិរក្សានូវឥន្ទ្រិយទាំង ៦ នោះ មានសេចក្តីថា ត្រូវប្រុងប្រយ័ត្នស្មារតី យកស្មារតីជាសន្ទះសម្រាប់បិទនូវទ្វារទាំង ៦ មានចក្ខុ

ទ្វារជាដើម ការពារមិនឲ្យអារម្មណ៍ដែលជាគ្រឿងសត្រូវគួរឲ្យកើតសេចក្តីស្ងប់ស្រឡាញ់ចូលទៅលុកលុយក្នុង **ហទយវត្ថុ** បាន កាលបើមានអារម្មណ៍ទាំងនោះមកប៉ះពាល់ ត្រូវយកស្មារតីទប់ឲ្យនៅទើតែត្រឹមទ្វារប៉ុណ្ណោះ គឺថាមិនត្រូវភ្លេចស្មារតីបណ្តោយចិត្តឲ្យលង់ឈ្លក់ទៅក្នុងអារម្មណ៍ទាំងនោះ ដោយស្ថានណានីមួយៗ ឡើយ ។ មិនត្រឹមតែប៉ុណ្ណោះត្រូវឲ្យបំពេញនូវ **អាចារ** និង**គោចរ**ដូចពោលរួចមកហើយក្នុង **បាដិមោក្ខសំវរសីល** នោះថែមទៀតផង ទើបអាចនឹងរក្សានូវឥន្ទ្រិយទាំង ៦ នោះបានដោយល្អ ។ ដែលខំរក្សាយ៉ាងនេះមិនមែនដើម្បីប្រយោជន៍អ្វីដទៃទៀតឡើយ ដើម្បីតែនឹងបិទទុកនូវឥន្ទ្រិយទាំងនោះកុំឲ្យ **អកុសលធម៌** ដ៏លាមក គឺ**អភិជ្ឈា** និង **ទោមនស្ស** ចូលទៅលុកលុយដល់ **កុសលធម៌** ទាំងពួងក្នុងសន្តានប៉ុណ្ណោះ ព្រោះថា **អកុសលធម៌** ទាំងនេះតែបណ្តោយឲ្យចូលទៅដល់ក្នុងសន្តានបានហើយ មុខជានឹងបំផ្លាញនូវ **កុសលធម៌** ទាំងពួងមិនឲ្យមានសេសសល់ឡើយ ហាក់ដូចជាបណ្តោយឲ្យចោរចូលស្រុកដូច្នោះឯង ។

## សង្រួមនិងមិនសង្រួម

ក្នុង **ឥន្ទ្រិយសំវរសីល** នេះ មានគ្រឿងកំណត់ថាជាសង្រួម ឬមិនសង្រួម ដោយអំណាចនៃ **សំវរធម៌** និង **អសំវរធម៌** ណា ១ កើតឡើង កាលបើធម៌ទាំងនេះមិនទាន់កើតឡើងទេ នឹងហៅថាជាសង្រួម ឬមិនសង្រួមមិនទាន់បានឡើយ ។

ធម៌ដែលសម្រាប់កំណត់ឲ្យដឹងថាជាសង្រួមហៅថា "**សំវរធម៌**" ដែលសម្រាប់កំណត់ឲ្យដឹងថាជាមិនសង្រួមហៅថា "**អសំវរធម៌**" ហើយក្នុងធម៌នីមួយៗ ចែកចេញទៅទៀតមានប្រាំៗ ដូចគ្នា ។

## សំវរធម៌ ៥ គឺ

១- *សីលសំវរៈ* ធម៌សង្រួមគឺ *សីល* ។
២- *សតិសំវរៈ* ធម៌សង្រួមគឺ *ស្មារតី* ។
៣- *ញាណសំវរៈ* ធម៌សង្រួមគឺ *បញ្ញា* ។
៤- *ខន្តិសំវរៈ* ធម៌សង្រួមគឺ សេចក្តី *អត់ធ្ម័ន* ។
៥- *វីរិយសំវរៈ* ធម៌សង្រួមគឺ *ព្យាយាម* ។

## អសំវរធម៌ មាន ៥ គឺ

១- *ទុស្សីលៈ* ភាពជាអ្នកទ្រុស្ត *សីល* ។

២- មុទ្ធសច្ចៈ ភាពជាអ្នកភ្លេច **ស្មារតី** ។
៣- អញ្ញាណៈ សេចក្តីមិនដឹង ។
៤- អក្ខន្តិៈ សេចក្តីមិន **អត់ទ្រាំ** ។
៥- កោសជ្ជៈ សេចក្តីខ្ជិលច្រអូស ។

## សេចក្តីអធិប្បាយ

កាលបើអារម្មណ៍ទាំង ៦ អារម្មណ៍ណាមួយមកប៉ះពាល់ដល់ទ្វារទាំង ៦ មានចក្ខុទ្វារជាដើមទ្វារណាមួយ ហើយបណ្តាលឲ្យ **អសំវរធម៌** ទាំង ៥ យ៉ាង កើតឡើង សូម្បីធម៌ណាមួយក្តី ក៏ត្រូវដឹងបានថាទ្វារនោះភិក្ខុមិនបានសង្រួម បិទដោយល្អទេ ព្រោះថា សេចក្តីសង្រួម និងមិនសង្រួមនោះ មិនមែនកើតតែត្រឹម ទ្វារមានចក្ខុទ្វារជាដើមនោះឡើយ ។

ចុះបើសេចក្តីសង្រួម និងមិនសង្រួមមិនមែនកើតតែត្រឹម **ចក្ខុទ្វារ** ជាដើម ទេ តើកើតដល់ទៅត្រឹមណាវិញ ?

ដំណើរនេះត្រូវដឹងតាមលំដាប់នៃ **វិថីចិត្ត** ដូចពោលតទៅនេះ តែនឹង ពោលតែក្នុង **ចក្ខុទ្វារ** មួយប៉ុណ្ណោះគ្រាន់ជាតួយ៉ាង ។

ក៏ក្នុង **ចក្ខុទ្វារ** នេះ កាលបើរូបារម្មណ៍មកប៉ះពាល់រង្វង់នៃចក្ខុបសាទ ហើយភវង្គក៏កើតឡើងហើយរលត់ទៅអស់វារៈ ២ ដងទៅតាមលំដាប់, **កិរិយា មនោធាតុ**ដែលជាចក្ខុទ្វារាវជ្ជនចិត្ត ញុំាងអាវជ្ជនកិច្ចគឺកិច្ចដែលពិចារណាវារក

នូវរូបារម្មណ៍នោះឲ្យស្រេចកើតឡើង ១ ខណៈរលត់ទៅ, បន្ទាប់មក **ចក្ខុវិញ្ញាណ** ញុំាង **ទស្សនកិច្ច** គឺកិច្ចដែលឃើញនូវរូបារម្មណ៍នោះឲ្យសម្រេចកើតឡើង ១ ខណៈរលត់ទៅ, បន្ទាប់មក **វិបាកមនោធាតុ** ដែលជាតួសម្បដិច្ឆន្នចិត្ត ញុំាង **សម្បដិច្ឆន្នកិច្ច** គឺកិច្ចដែលទទួលរងនូវរូបារម្មណ៍នោះឲ្យសម្រេចកើតឡើង ១ ខណៈរលត់ទៅ, ទើប **វិបាកអហេតុកមនោវិញ្ញាណធាតុ** ដែលជាតួសន្តីរណចិត្ត ញុំាង
**សន្តីរណកិច្ច** គឺកិច្ចដែលត្រិះរិះឈ្លេចឈ្លីនូវរូបារម្មណ៍នោះ ឲ្យសម្រេចកើតឡើង ១ ខណៈរលត់ទៅ, តមក**កិរិយាអហេតុកមនោវិញ្ញាណធាតុ** ដែលជាតួ **វោដ្ឋព្វនចិត្ត** ញុំាង **វោដ្ឋព្វនកិច្ច** គឺកិច្ចដែលកត់ត្រាទុកនូវរូបារម្មណ៍ ឲ្យសម្រេចកើតឡើង ១ ខណៈរលត់ទៅ, ខាងក្រោយបំផុត ទើប**ជវនៈ**ប្រព្រឹត្តទៅតាមភាពរបស់អារម្មណ៍ដែលគួរឲ្យកើត ***សំវរធម៌*** ឬ ***អសំវរធម៌*** ដូចបានពោលមកហើយ ។

ក្នុងសម័យនៃភវង្គជាដើមនោះ មិនទាន់បានឈ្មោះថា សង្រួម ឬមិនសង្រួមនៅឡើយទេ ដែលបានឈ្មោះថា សង្រួម ឬមិនសង្រួម ត្រាក្នុងសម័យរបស់ជវនៈ ព្រោះ ***សំវរធម៌*** ទាំង ៥ ក្តី ***អសំវរធម៌*** ទាំង ៥ ក្តី ដែលនឹងកើតឡើងក៏កើតក្នុងខណៈរបស់**ជវនៈ**តែម្យ៉ាង ហេតុនោះ កាលបើអារម្មណ៍ណាមួយចូលមកតាមទ្វារមានទ្វារចក្ខុជាដើម បណ្តាលឲ្យ **វិថីចិត្ត** កើតរៀងតាមលំដាប់ ដរាបដល់ជវនវិថីជាទីបំផុតហើយ ***សំវរធម៌*** ឬ ***អសំវរៈ*** ណាមួយកើតឡើង ទើបអាចនឹងឲ្យឈ្មោះថា "សង្រួម ឬមិនសង្រួម" បាន។

ក៏ប្រសិនបើធម៌ គឺ **ទុស្សីល** ក្តី, **មុដ្ឋសច្ច** ក្តី, **អញ្ញាណ** ក្តី, **អក្ខន្តិ** ក្តី, **កោសជ្ជ** ក្តី កើតឡើងក្នុងខណៈនៃជវនៈហើយ **អសំវរធម៌** ក៏ឈ្មោះថា កើតឡើងមែនពិត ។ **អសំវរធម៌** មានកាលយ៉ាងនេះ **អសំវរ**នេះលោក ហៅថាៈ **អសំវរធម៌** ក្នុង **ចក្ខុន្ទ្រិយ** ។ ព្រោះហេតុអ្វី?

ព្រោះកាលដែល **អសំវរធម៌** កាលមានទ្វារផង **ភវង្គ** ផង **វិថីចិត្ត** មាន **អាវជ្ជនចិត្ត** ជាដើមផង ជាធម្មជាតិ គឺភិក្ខុមិនបានគ្រប់គ្រងហើយ ។

តើមានសេចក្តីប្រៀបធៀបជាអ្វី ? ចូរពោល ។

កាលដែលទ្វារក្នុងនគរទាំង ៤ គឺគេមិនបានបិទល្អហើយនោះ រីឯរបស់ទាំងឡាយ មានទ្វារនៃផ្ទះនិងទ្វារនៃឃ្លាំងព្វដ៏ខាងក្នុងជាដើម ដែលគេបានបិទល្អក៏ពិតមែនហើយ ក៏ព្រោះថា ភណ្ឌៈទាំងអស់នោះ ព្វដ៏ខាងក្នុងនគរជាវត្ថុគឺគេមិនរក្សាពិតមែន ព្រោះថាចោរទាំងឡាយអាចចូលតាមទ្វារនគរនោះ បើប្រាថ្នាយកនូវវត្ថុណា គប្បីកាន់យកនូវវត្ថុនោះបាន មានឧបមាយ៉ាងណា **អសំវរធម៌** មានទុស្សីលជាដើម កើតឡើងហើយក្នុងជវនៈ កាលដែល **អសំវរធម៌** កាលមានយ៉ាងនេះ **ទ្វារ** ផង **ភវង្គ** ផង **វិថីចិត្ត** មាន **អាវជ្ជនៈ**ជាដើមផង ក៏ឈ្មោះថាភិក្ខុនោះមិនបានគ្រប់គ្រងហើយដែរ ក៏មានសេចក្តីឧបមេយ្យក៏យ៉ាងនេះ ។

ន័យមួយទៀត កាលដែលទ្វារនគរទាំងអស់ គឺគេបានបិទជិតល្អហើយ ចំណែកឯរបស់ទាំងឡាយ ផ្ទះព្វដ៏ខាងក្នុង ដែលគេមិនបានបិទបាំងការពារល្អទេ ក៏ឈ្មោះថា ភណ្ឌៈទាំងអស់ខាងក្នុងនគរ គឺគេបានរក្សាគ្រប់គ្រងល្អហើយ ចោរទាំងឡាយមិនអាចចូលទៅលួចយកភណ្ឌៈទាំងនោះបាន មានសេចក្តីឧបមាយ៉ាងណា កាលដែល **សំវរធម៌** មានសីលជាដើមកើតឡើងក្នុងជវនហើយ ឬ ទ្វារមាន

ទ្វារចក្ខុជាដើមផង **ភវង្គ** ផង **វិថីចិត្ត** មាន **អាវជ្ជន** ជាដើមផង ជាធម្មជាតិគឺភិក្ខុគ្រប់គ្រងល្អហើយ ក៏មានសេចក្ដីឧបមេយ្យក៏យ៉ាងនោះ ។

ការពោលមកហើយនេះ គឺជាការពោលអំពី **សំវរជម៌** និង **អសំវរជម៌** ដែលកើតតាមចក្ខុទ្វារប៉ុណ្ណោះ រីឯ **សំវរជម៌** ដែលកើតតាមទ្វារឯទៀត មានសោតទ្វារជាដើម សូមអ្នកសិក្សា គប្បីយល់តាមដំណើរនៃការកើតឡើងនៃ **សំវរជម៌** និង **អសំវរជម៌** តាមចក្ខុទ្វារនេះផងចុះ ។

ក៏ **ឥន្ទ្រិយសំវរសីល** នេះ ភិក្ខុគប្បីឲ្យសម្រេចដោយសតិ គឺថាមានសតិជាជំនួយឲ្យសំរេច ព្រោះថា **ឥន្ទ្រិយ** ទាំង ៦ បើភិក្ខុតាំងទុកដោយសតិហើយ **អសំវរជម៌**ទាំងឡាយ មាន **អភិជ្ឈា**ជាដើម មិនគប្បីតាមជិះជាន់បានឡើយ ។

មានសេចក្ដីសរសើរថា: **ឥន្ទ្រិយសំវរ** នេះ កាលបើបានសម្រេចដោយល្អហើយ នឹងបានជាជំនួយដល់ **បាដិមោក្ខសំវរសីល** ផងទៀត គឺថាអាចនឹងញុំាង **បាដិមោក្ខសំវរសីល** ឲ្យតាំងនៅខ្ជាប់ខ្ជួនអស់កាលយូរ ហាក់ដូចសន្ទូងដែលគេបានបិទបាំងជិតល្អដោយរបង ។ មិនត្រឹមតែប៉ុណ្ណោះ ព្រះយោគាវចរភិក្ខុអង្គនោះ ក៏ចោរពោលគឺកិលេសមិនអាចចូលមកបៀតបៀនបាន ហាក់ដូចជាស្រុកដែលគេបានបិទទ្វារជិតដោយល្អហើយ មិនមានឱកាសល្មមឲ្យចោរចូលទៅរឹបជាន់បានឡើយ ។ សមដូចជាគាថាដែលលោកពោលទុកដូច្នេះ

> រូបេសុ សទ្ទេសុ អថោ រសេសុ,
> គន្ធេសុ ផស្សេសុ ច រក្ខតិន្ទ្រិយំ
> ឯតេ ហិ ទ្វារា បិធហិតា សុសំវុតា

ន ហន្តិ គាមំវ បរស្ស ហារិនោ

សេចក្តីថា: បុគ្គលត្រូវតែរក្សានូវ **ឥន្ទ្រិយ** ការពារកុំឲ្យអន្តរាយកើតឡើងព្រោះតែរូប សម្លេង ក្លិន រស និងផ្សព្វផ្សាយទាំងឡាយ ព្រោះថាទ្វារទាំងឡាយមាន **ចក្ខុទ្វារ** ជាដើមនេះ តែបុគ្គលណាបិទរាំងល្អហើយ នឹងបៀតបៀននូវបុគ្គលនោះវិញមិនបាន ហាក់ដូចជាស្រុកដែលគេបានបិទទ្វារជិតល្អហើយ ចោរទាំងឡាយ ក៏មិនអាចដើម្បីនឹងបៀតបៀននូវអ្នកស្រុកបានឡើយ ។

ន័យមួយទៀត ឥន្ទ្រិយសំវរសីលនេះ បើភិក្ខុអង្គណាបានធ្វើឲ្យសម្រេចហើយ **រាគៈ** ក៏មិនអាចចាក់ទម្លុះចិត្តរបស់ភិក្ខុអង្គនោះបានឡើយ ហាក់ដូចជាដំណក់ទឹកភ្លៀង ដែលមិនអាចនឹងលិចស្រោចនូវផ្ទះដែលគេប្រក់យ៉ាងជិតល្អនោះឯង ។ មានគាថាដែលព្រះពុទ្ធដ៏មានព្រះភាគទ្រង់ត្រាស់ទុកជាគ្រឿងពិសោធន៍ដូច្នេះ

យថា អគារំ សុច្ឆន្នំ វុដ្ឋិ ន សមតិវិជ្ឈតិ
ឯវំ សុភាវិតំ ចិត្តំ រាគោ ន សមតិវិជ្ឈតិ

សេចក្តីថា: ដំណក់ទឹកភ្លៀងមិនអាចលិចស្រោចនូវផ្ទះ ដែលគេប្រក់ជិតដោយល្អយ៉ាងណា រាគក៏មិនអាចនឹងចាក់ទម្លុះនូវចិត្ត ដែលបុគ្គលបានចម្រើនដោយល្អដូច្នោះឯង ។

## អាជីវបារិសុទ្ធិសីល

អំពើដែលភិក្ខុចិញ្ចឹមជីវិតដោយល្អ វៀរចាកព្យាយាមជាគ្រឿងចិញ្ចឹមជីវិតខុស ដែលប្រព្រឹត្តទៅដោយអំណាចនៃកិរិយាប្រព្រឹត្តិកន្លងនូវសិក្ខាបទ ដែលព្រះ

ជិនស្រីទ្រង់បញ្ញត្ត ព្រោះហេតុតែគ្រឿងចិញ្ចឹមជីវិតនោះ ដោយអំណាចនៃបាបធម៌ ៥ មាន **តិរច្ឆានវិជ្ជា** ក្ដីជាដើម ហៅថា **អាជីវចារិសុទ្ធិសីល** ។

## អធិប្បាយសិក្ខាបទ ៦

បានពោលមកហើយក្នុងខាងលើនេះថា សិក្ខាបទដែលព្រះជិនស្រីទ្រង់បញ្ញត្តព្រោះតែគ្រឿងចិញ្ចឹមជីវិត តើសិក្ខាបទ ៦ នោះ សិក្ខាបទណាខ្លះ ?

សិក្ខាបទ ៦ ដែលព្រះជិនស្រីទ្រង់បញ្ញត្ត ព្រោះហេតុគ្រឿងចិញ្ចឹមជីវិតនោះដូច្នេះគឺ

១- ភិក្ខុមានសេចក្ដីប្រាថ្នាលាមក ឲ្យសេចក្ដីប្រាថ្នាគ្របសង្កត់បាន ហើយពោលអួតនូវ **ឧត្តរិមនុស្សធម្ម** គឺ **មហគ្គតធម៌** និង **លោកុត្តរធម៌** ដែលមិនមានក្នុងខ្លួន ព្រោះហេតុតែការចិញ្ចឹមជីវិត ត្រូវ **អាបត្តិបារាជិកា** ។

២- ភិក្ខុដល់នូវភាពជាអ្នកត្រេកអរ ប្រព្រឹត្តទៅក្នុងចន្លោះស្ត្រីនិងបុរស ប្រាប់នូវសេចក្ដីត្រូវការរបស់បុរសដល់ស្ត្រី ឬប្រាប់នូវសេចក្ដីត្រូវការរបស់ស្ត្រីដល់បុរស គឺធ្វើមេអណ្ដើកដឹកនាំឲ្យបុរសនិងស្ត្រីបានគ្នាជាប្ដីប្រពន្ធ ឬគ្រាន់តែឲ្យបានជាសហាយស្មន់ ព្រោះហេតុតែការចិញ្ចឹមជីវិត ត្រូវ**អាបត្តិសង្ឃាទិសេស** ។

៣- ភិក្ខុពោលអួត **ឧត្តរិមនុស្សធម្ម** មិនចំៗ តែណែបបញ្ឆៀងមកដាក់ខ្លួនថា "មើលតែភិក្ខុអង្គណា ដែលនៅក្នុងវិហាររបស់អ្នក ភិក្ខុអង្គុយនោះជា **ព្រះអរហន្ត** ហើយ ពោលអួតដូច្នេះ ព្រោះហេតុតែការចិញ្ចឹមជីវិត ត្រូវ **អាបត្តិថុល្លច្ច័យ** " ។

៤- ភិក្ខុឥតជំងឺ សូមបណីតភោជនទាំងឡាយ ដើម្បីប្រយោជន៍នៃខ្លួន ហើយឆាន់ព្រោះហេតុតែការចិញ្ចឹមជីវិតត្រូវ **អាបត្តិថាចិត្តយ** ។

៥- ភិក្ខុនីមិនមានជំងឺ សូមនូវបណីតភោជនទាំងឡាយ ដើម្បីប្រយោជន៍នៃខ្លួន ហើយឆាន់ព្រោះហេតុតែចិញ្ចឹមជីវិតត្រូវ **អាបត្តិថាដិទេសនីយ**។

៦- ភិក្ខុមិនមានជំងឺ សូមសម្លក្តី បាយក្តី ដើម្បីប្រយោជន៍នៃខ្លួន ហើយឆាន់ព្រោះហេតុតែចិញ្ចឹមជីវិតត្រូវ **អាបត្តិទុក្កដ** ។

## ចាបធម៌

ពាក្យថា: **ចាបធម៌** បានសេចក្តីថា ធម៌លាមកអាក្រក់មាន ៥យ៉ាងគឺ

១- **កុហនា:** ការកុហកដោយឫក ។

២- **លបនា:** ការលួងលោមដោយវាចា ។

៣- **នេមិត្តិកតា:** ភាពជាអ្នកប្រើកលឧបាយដោយកាយខ្លះ ដោយវាចាខ្លះ។

៤- **និប្បេសិកតា:** ភាពជាអ្នកប្រើសម្តីជាខ្នោសសម្រាប់កោសយកលាភ។

៥- **លាភេនលាភំ និជិគឹសនតា:** ភាពនៃការស្វែងរកលាភ ដោយយកលាភជានុយ ឬ ជាផ្លាក់ ។

### ១- កុហនា:

**អធិប្បាយ:** ភិក្ខុប្រាថ្នាចង់បានលាភ ចង់បានគេគោរព ចង់ឲ្យគេសរសើរ ចង់សម្តែងគុណដែលមិនមានក្នុងខ្លួន ហើយប្រើ **កុហនវត្ថុ** (ឫកកុហក) ៣ យ៉ាងគឺ ។

១- **បច្ច័យបដិសេវនៈ** ឫកកុហកប៉ែកខាងសេពនូវបច្ច័យ ៤ ។

សេចក្តីថា: ភិក្ខុខ្លះក្នុងសាសនានេះ កាលបើគហបតីទាំងឡាយ គេនិមន្តដោយបច្ច័យ ៤ បើទុកជាខ្លួនត្រូវការដោយបច្ច័យនោះក្តី ក៏ប្រកែកមិនព្រមទទួលដោយសម្តែងឫកខ្លួន ឲ្យគេដឹងថាជាអ្នកសន្តោសយ៉ាង **ឧក្រិដ្ឋ** មិនត្រូវការដោយបច្ច័យដែលថ្លៃថ្លា ត្រូវការតែបច្ច័យដែលសៅហ្មងដូច **ចីវរបំសុកូល** ជាដើម យល់ដឹងថាគហបតីទាំងនោះ មានសទ្ធាតម្កល់ស៊ប់មកលើខ្លួន លុះមតែបង្អោនបច្ច័យមកឲ្យជាន់ក្រោយ ចំនួនជាទាល់តែដឹកដោយរទេះ ទើបបែរជាទទួលវិញ ដោយប្រកាសខ្លួនថា "អាត្មាមិនជាអ្នកត្រូវការដោយបច្ច័យទាំងនេះទេ ប៉ុន្តែដោយអាត្មាទទួលនេះ គឺដោយសេចក្តីសង្គ្រោះដល់អ្នកទាំងឡាយ ព្រោះថាបើអាត្មាមិនទទួលទៅ អ្នកទាំងឡាយនឹងស្ថិតនៅជាខាងក្រៅអំពីបុណ្យស្រឡះ ព្រោះហេតុនោះបានជាអាត្មាទទួល "។ មិនត្រឹមតែវាយឫកដោយសម្តីដូច្នេះឡើយ ទោះបីធ្វើទឹកមុខស្រងូតស្រងាត់ស្រគត់ស្រគំ ហាក់ដូចជាមានគុណវិសេសក្នុងខ្លួន ដើម្បីឲ្យគេមានសទ្ធាជាប់ចិត្តលើខ្លួន ដោយសម្លឹងលាភសក្ការ: និងពាក្យសរសើរជាដើម ដែលមានទំនងយ៉ាងនេះ ហៅថាឫកកុហកប៉ែកខាងសេពនូវបច្ច័យទាំងអស់ ។

២- **សាមន្តជប្បនៈ** ឫកកុហកប៉ែកខាងពាក្យខ្សឹបខៀវក្បែរៗ បង្អើបមុខឲ្យគេដឹងថាខ្លួនជាអ្នកត្រាស់នូវ **ឧត្តរិមនុស្សធម្ម** ។

សេចក្តីថា: ភិក្ខុអង្គខ្លះក្នុងសាសនានេះ មានប្រាថ្នាចង់បានលាភ ចង់ឲ្យគេសរសើរ ហើយពោលពាក្យផ្អែមដោយ **អរិយធម៌** ជម្រាលមកដាក់ខ្លួនថា "អ្នកទាំងឡាយចូរមើលតែលោកអង្គណា ដែលប្រើប្រាស់ចីវរ បាត្រជាដើម បែបនេះៗ ឧបជ្ឈាយ៍និងអាចារ្យជាដើមរបស់លោកបែបនេះៗ លោកនៅក្នុងវត្ត បែបនេះៗ ជាដើម លោកអង្គនោះហើយ ជាសមណៈដ៏ប្រសើរមានសក្តិធំ ដោយលោកបាននូវគុណវិសេសបែបនេះៗ ពុំនោះពោលពាក្យប្រប៉ាច់ប្រប៉ោច ហួសហេតុ ឬអួតថា គេសរសើរខ្លួនតែដោយមាត់ខ្លួនជាដើម ដែលមានទំនង សសៀរចូលទៅជិត **លោកុត្តរធម៌** បែបនេះក៏ហៅថា ឬកកុហកប៉ែកខាងពាក្យ ខ្សឹបខ្សៀវក្បែរទាំងអស់" ។

៣- **ឥរិយាបថសន្និស្សិត:** ឬកកុហកអាស្រ័យដោយឥរិយាបថ ។

សេចក្តីថា: ភិក្ខុអង្គខ្លះក្នុងសាសនានេះ មានសេចក្តីប្រាថ្នាដ៏លាមក ចង់ឲ្យគេសរសើរថាខ្លួនជាអ្នកបាននូវគុណវិសេសផ្សេងៗ ហើយផ្គត់ផ្គង់ **ឥរិយាបថ** ដេក ដើរ ឈរ អង្គុយ យកតម្រាប់លោកអ្នកបាននូវគុណវិសេស ហាក់ជាបរិបូណ៌ដោយ **សតិ** និង **សម្បជញ្ញៈ** ពុំនោះហាក់ដូចជាមានចិត្តតម្កល់នៅមាំដោយ **សមាធិ** ជូនណានៅក្នុងកណ្តាលប្រជុំធ្វើអាការដូចជាចូលឈាន យ៉ាងនេះហៅថា ឬកកុហកអាស្រ័យដោយ **ឥរិយាបថ** ។

អំពើដែលភិក្ខុអ្នកប្រាថ្នានូវលាភសក្ការៈនិងកេរ្តិ៍ឈ្មោះ ប្រព្រឹត្តធ្វើដោយឬកកុហកទាំង ៣ យ៉ាងណា ១ ដូចពណ៌នាមកដោយសង្ខេបហៅថា **កុហនា** ។

## ២- លបនា:

**អធិប្បាយថា:** ភិក្ខុមានសេចក្តីប្រាថ្នាដ៏លាមក ចង់បានលាភសក្ការៈ និងកេរ្តិ៍ឈ្មោះ កាលបើឃើញមនុស្សគេដើរមកកាន់វត្ត ក៏ស្រែកសួរគេមុន បើគេប្រាប់ថាមកនិមន្តភិក្ខុ ខ្លួនធានានិមន្តជំនួសឲ្យគេក្តី និយាយអួតដាក់ខ្លួនថាអាត្មាឈ្មោះនេះ ស្តេច មន្ត្រីតូចធំឯណោះៗ សុទ្ធតែជ្រះថ្លានឹងអាត្មាទាំងអស់ដូច្នេះក្តី និយាយបញ្ជោរ និយាយកៀរ និយាយចងជើង និយាយពើ និយាយលលើកាប់ក្រោមជាដើម ដើម្បីនឹងគោះយកបច្ច័យអំពីទាយកក្តីទាំងនេះហៅថា លបណា ។

## ៣- នេមិត្តកតា

**អធិប្បាយថា:** ភិក្ខុចង់បាននូវ *លាភសក្ការៈ* និងកេរ្តិ៍ឈ្មោះ មានសេចក្តីប្រាថ្នាលាមក ហើយសម្តែងអាការណាមួយដោយកាយ ឬដោយវាចា ដែលជាហេតុនឹងញ៉ាំងបច្ច័យឲ្យកើត តួយ៉ាងដូចភិក្ខុបានឃើញមនុស្សកាន់បង្អែម ហើយទុកជាខ្លួនស្គាល់ប្រាកដ ក៏ធ្វើជាសួរដើម្បីឲ្យគេដឹងថាត្រូវការ ឬនិយាយត្អូញត្អែរប្រាប់ទាយចំពោះបច្ច័យត្រង់ៗ ក្តី និយាយពាក្យបញ្ឆិតបញ្ឆៀងនាយអាយឲ្យគេយល់ថាខ្លួនត្រូវការដោយបច្ច័យក្តី និយាយពាក្យកៀសជិតៗ បច្ច័យឲ្យគេទើសទាល់មិនហ៊ានខានឲ្យក្តី ទាំងនេះហៅថា **នេមិត្តិកតា** ។

## ៤- និប្បេសិកតា

**អធិប្បាយថា:** ភិក្ខុចង់បាននូវ *លាភសក្ការៈ* និងកេរ្តិ៍ឈ្មោះ មានសេចក្តីប្រាថ្នាដ៏លាមក ដោយសម្តែងអំណាចជេរប្រទេចដល់ទាយក ដោយ *អក្កោសវត្ថុ*[24] យ៉ាងណាមួយក្តី និយាយបង្រ្គប និយាយតិះដៀលលើកទោសថា គេមិនមានសទ្ធា មិនមានជ្រះថ្លាជាដើមក្តី និយាយដើមអាក្រក់អំពីផ្ទះនេះប្រាប់ដល់ផ្ទះនោះក្តី ទាំងនេះហៅថា **និប្បេសិកតា** ។

## ៥- លាភេន លាភំ និជិគីសនតា

**អធិប្បាយថា:** ភិក្ខុចង់បាននូវ *លាភសក្ការៈ* និងកេរ្តិ៍ឈ្មោះ មានសេចក្តីប្រាថ្នាដ៏លាមក ហើយលាភដែលខ្លួនបានអំពីផ្ទះឯណោះយកទៅប្រាប់ដល់ផ្ទះឯណោះ យកមកឲ្យដល់ផ្ទះឯណោះ ដើម្បីនឹងបណ្តុះលាភនោះឲ្យកាន់តែចំរើនកើនឡើងៗ យ៉ាងនេះហៅថា **លាភេនលាភំ និជិគីសនតា** ។

ត្រង់ដែលថា **មិច្ឆាជីវ** ប្រព្រឹត្តទៅដោយអំណាចនៃ **ចាបធម៌ ៥** ជាដើមនោះ ដូចន័យបានអធិប្បាយមកហើយដោយសង្ខេបនេះឯង ។

## តិរច្ឆានវិជ្ជា

**តិរច្ឆានវិជ្ជា** គឺចំណេះដែលថោកទាប ទុកដូចជាចំណេះរបស់ **សត្វតិរច្ឆាន** ព្រោះមិនមានប្រយោជន៍ ។

---

[24] អក្កោសវត្ថុ ពាក្យសម្រាប់ជេរ ១០ យ៉ាងគឺ ឯងជាចោរ ១, ឯងជាពាល ១, ឯងជាអ្នកវង្វេង ១, ឯងជាសត្វអូដ្ឋ ១, ឯងជាសត្វគោ ១, ឯងជាសត្វលា ១, ឯងជាសត្វនរក ១, ឯងជាតិរច្ឆាន ១, សុគតិរបស់ឯងគ្មាន ១, ទុគ្គតិប្រាកដដល់ឯង ១ ។

**តិរច្ឆានវិជ្ជា** នោះមានច្រើនជាអនេកពេកណាស់ តាមន័យដែលព្រះដ៏មានជោគទ្រង់ត្រាស់សម្ដែងទុកក្នុង **ព្រហ្មជាលសូត្រ** ទី ១ ក្នុង **គម្ពីរទីឃនិកាយ សីលក្ខន្ធវគ្គ** ឬក្នុង **សុភសូត្រ** ទី ១០ ក្នុង **គម្ពីរទីឃនិកាយ** តែក្នុងទីនេះពោលទុកដោយសង្ខេបតែត្រឹម ៨ យ៉ាង ប៉ុណ្ណោះគឺៈ

១- **អង្គំៈ** តម្រានិយាយអំពី **សរីរាវយវៈ** មានដៃនិងជើងជាដើម ។

២- **និមិត្តំៈ** តម្រាសម្រាប់ទាយនូវហេតុផ្សេងៗ ។

៣- **ឧប្បាតំៈ** តម្រានិយាយអំពីឧប្បត្តិហេតុ ដូចធ្លាក់កេតុ មេឃក្រហមដាលឡើងក្នុងទិសផ្សេងៗ នោះ និងផែនដីញ័រជាដើម ។

៤- **សុបិនំៈ** តម្រាសម្រាប់ទាយយល់សប្តិ ។

៥- **លក្ខណំៈ** តម្រាសម្រាប់ទាយលក្ខណៈរបស់ស្ត្រីនិងបុរស ។

៦- **មូសិកាច្ឆិន្នំៈ** តម្រាសម្រាប់ទាយនូវសំពត់ ដែលកណ្ដុរកាត់ ។

៧- **អគ្គិហោមំៈ** វិធីបូជាភ្លើង ។

៨- **ទព្វិហោមំៈ** វិធីបូជាវែក ។

**សមណៈ** អ្នកបរិភោគប្រើប្រាស់នូវបច្ច័យ ៤ ដែលទាយកគេឲ្យមកដោយសទ្ធា មិនត្រូវរៀនទន្ទេញ ឬចិញ្ចឹមជីវិតដោយ **តិរច្ឆានវិជ្ជា** ទាំងនេះឡើយ។

អំពើដែលភិក្ខុចិញ្ចឹមជីវិតដោយល្អវៀរចាក**ចាបធម៌**ទាំង ៥ និង**តិរច្ឆានវិជ្ជា** ទាំង ៨ ជាដើមនេះហៅថា **អាជីវចារិសុទ្ធិសីល** ។

**អាជីវចារិសុទ្ធិសីល** ភិក្ខុគប្បីឲ្យសម្រេចបរិបូណ៌បានដោយអំណាចនៃ **វីរិយ** គឺ(សេចក្តីព្យាយាម) គឺថាមានវីរិយជាជំនួយសម្រេច ព្រោះសីលនេះ លុះតែលោកអ្នកមានព្យាយាមប្រារព្ធដោយល្អ លោកលះបង់នូវ**មិច្ឆាជីវៈ** ដូចបានពោលមកហើយនោះ ហើយស្វែងរកនូវបច្ច័យដែលកើតឡើងបរិសុទ្ធប្រកបដោយធម៌ ទើបអាចឲ្យសម្រេចបាន ។ ហេតុនោះកុលបុត្រអ្នកប្រាថ្នានូវប្រយោជន៍ មិនត្រូវសេពនូវបច្ច័យ ដែលកើតឡើងមិនបរិសុទ្ធនោះឡើយ ព្រោះបច្ច័យដែលកើតឡើងមិនបរិសុទ្ធនោះ លោកទុកដូចជា អាសិរ្វិស ។

## សេចក្តីពន្យល់

- បើភិក្ខុមិនរក្សានូវធុតង្គ បច្ច័យដែលកើតអំពីសំណាក់សង្ឃ សំណាក់គណៈ ឬកើតអំពីគ្រហស្ថ ដែលគេជ្រះថ្លាដោយធម៌ទេសនា ដោយការចេះដឹងពុទ្ធវចនៈ ដោយកិរិយាបំពេញនូវវត្តនិងបដិបត្តិ ដោយសម្បត្តិនៃឥរិយាបថជាដើម ឈ្មោះថាបច្ច័យកើតឡើងបរិសុទ្ធទាំងអស់ តែមានសេចក្តីសរសើរថា បើបច្ច័យដែលកើតអំពីត្រេចដើរបិណ្ឌបាត ចាត់ជាបរិសុទ្ធយ៉ាងក្រៃលែង ។ បើភិក្ខុរក្សានូវធុតង្គ បច្ច័យដែលកើតអំពីត្រេចបិណ្ឌបាត កើតអំពីសំណាក់មិត្ត **សព្រហ្មចារី** អំពីដើរបំសុកូល អំពីសំណាក់គ្រហស្ថដែលគេជ្រះថ្លាក្នុងធុតង្គគុណនោះៗ ឈ្មោះថាបច្ច័យកើតឡើង **បរិសុទ្ធ**. តែបើបច្ច័យដ៏ឧត្តម និងបច្ច័យដ៏សៅហ្មងកើតឡើងជាមួយគ្នា ហើយភិក្ខុនោះលះបង់នូវបច្ច័យដ៏ឧត្តមឲ្យភិក្ខុដទៃ

ខ្លួនឯងប្រើប្រាស់តែបច្ច័យដែលសៅហ្មងយ៉ាងនេះ ចាត់ជាអ្នកប្រកបក្នុង **អរិយវង្ស** ជាន់ខ្ពស់ ។

ឯបច្ច័យដែលកើតឡើងមិនបរិសុទ្ធនោះ សំដៅយកបច្ច័យដែលកើតអំពី **មិច្ឆាជីវ** ដូចបានអធិប្បាយរួចមកហើយក្នុង **អនាចារ** ដែលរាប់បញ្ចូលក្នុង **បាដិមោក្ខសំវរសីល** ខាងដើមនោះខ្លះ ក្នុង **សិក្ខាបទ ៦ បាបធម៌ ៤ តិរច្ឆានវិជ្ជា ៨** ជាដើម ក្នុង **អាជីវបារិសុទ្ធិសីល** ខ្លះ ឬបច្ច័យដែលកើតអំពី **កុលទូសកកម្ម** គឺធ្វើជាអ្នកប្រចុបប្រចែងត្រកូល **ទូតកម្ម** គឺធ្វើជាជើងសា **វេជ្ជកម្ម** គឺធ្វើពេទ្យ និងទិញដូរផ្លាស់ខ្លួនជាដើម ក៏បានឈ្មោះថាកើតឡើងមិនបរិសុទ្ធដូចគ្នា ។ មានគាថាលោកនិពន្ធទុកថា:

អនេសនាយ ចិត្តម្បិ អជនេត្វា វិចក្ខណោ
អាជីវំ បរិសោធេយ្យ សទ្ធាបព្វជិតោ យតិ

**សេចក្ដីថា:** ព្រះយោគី អ្នកមានប្រាជ្ញាចូលមកបួសក្នុងព្រះពុទ្ធសាសនាដោយសទ្ធាពិតប្រាកដ គប្បីជម្រះនូវ **អាជីវបារិសុទ្ធិសីល** ឲ្យម៉ត់ចត់ កុំគប្បីញ៉ាំងចិត្តឲ្យកើតក្នុង **អនេសន** អំពើដែលស្វែងរកនូវបច្ច័យមិនសមគួរនោះឡើយ

## បច្ច័យសន្និស្សិតសីល

សីលដែលអាស្រ័យនូវបច្ច័យ ៤ ហៅថា **បច្ច័យសន្និស្សិតសីល** បានដល់កិរិយាបរិភោគ ប្រើប្រាស់នូវបច្ច័យ ៤ ដែលបរិសុទ្ធដោយកិរិយាពិចារណា ។

ពាក្យថាបច្ច័យបានសេចក្ដីថា គ្រឿងដែលសត្វត្រូវអាស្រ័យបរិភោគប្រើប្រាស់ហើយប្រព្រឹត្តទៅបាន ។

# បច្ច័យមាន ៤ យ៉ាង៖

១- ចីវរៈ គ្រឿងសម្រាប់ស្លៀកពាក់បិទបាំងអត្តភាព ។

២- បិណ្ឌបាតៈ គ្រឿងសម្រាប់បរិភោគកំដរអត្តភាព ។

៣- សេនាសនៈ ទីដេកទីអង្គុយសម្រាប់ជ្រកកោនអត្តភាព ។

៤- គិលានភេសជ្ជៈ ថ្នាំកែជំងឺសម្រាប់ជំនួយអត្តភាព ។

**សេចក្ដីថាៈ** សត្វទាំងឡាយក្នុងលោកសុទ្ធតែត្រូវអាស្រ័យរបស់ទាំង ៤ យ៉ាងនេះ ទើបអាចប្រព្រឹត្តទៅបាន បើមិនអាស្រ័យនូវបច្ច័យទាំងនោះសោះទេ មិនអាចរស់នៅបានឡើយ ព្រោះហេតុនោះរបស់ទាំង ៤ នេះទើបបានឈ្មោះថា បច្ច័យ ។

ភិក្ខុដែលបួសដោយសទ្ធាជាអ្នកឃើញភ័យក្នុងសង្សារវដ្ដ កាលបើបានទទួលនិងបរិភោគប្រើប្រាស់នូវបច្ច័យទាំង ៤ ដែលកើតឡើងហើយ ធ្វើការពិចារណាក្នុងការទទួលនិងប្រើប្រាស់ឲ្យបានល្អឲ្យបានសព្វគ្រប់ ទើបឈ្មោះថា ជាអ្នកទទួលប្រើប្រាស់នូវបច្ច័យ ៤ ដោយសេចក្ដី **បរិសុទ្ធ** ឥតមានទោស ។

## បច្ចវេក្ខណវិធី

វិធីដែលត្រូវពិចារណានូវបច្ច័យទាំង ៤ នេះ មានបែបដែលលោកបានរៀបរៀងទុក ក្នុងពេលមុនៗ មកគ្រប់គ្រាន់ហើយ (មើលក្នុង *សាមណេរវិន័យ* ឬ *អនាគារិយវិន័យ*) ។

ឯក្នុងទីនេះ សូមលើកឡើងពោលតែត្រង់សេចក្ដីដែលប្លែក ឬកើនលើស អំពីនោះប៉ុណ្ណោះ ។

ក៏ **បច្ចវេក្ខណវិធី** គឺវិធីដែលសម្រាប់ពិចារណាក្នុងបច្ច័យមួយៗ នោះមានបួនៗ គឺក្នុងចីវរបច្ច័យ ៤ បិណ្ឌបាតបច្ច័យ ៤. សេនាសនបច្ច័យ ៤. គិលានភេសជ្ជបច្ច័យ ៤ ហើយមានឈ្មោះថា ធាតុបច្ចវេក្ខណៈ បដិកូលបច្ចវេក្ខណៈ តំខណិកបច្ចវេក្ខណៈ អតីតបច្ចវេក្ខណៈដូចគ្នា រួមទាំងអស់ត្រូវជា**បច្ចវេក្ខណ** ១៦ ។

**បច្ចវេក្ខណកាល** គឺកាលដែលត្រូវពិចារណាក្នុងបច្ច័យមួយៗ នោះ មានបីៗ ហើយមានឈ្មោះថា **បដិលាភកាល** កាលដែលកំពុងបាន ឬកំពុងទទួលនូវបច្ច័យ ១, **បរិភោគកាល** កាលដែលកំពុងប្រើប្រាស់នូវបច្ច័យ ១, **អតីតកាល** កាលដែលបរិភោគ ប្រើប្រាស់កន្លងហើយ ១ ដូចគ្នាគ្រប់បច្ច័យទាំង ៤ រួមទាំងអស់ត្រូវជាកាល ១២ ។

បណ្តាកាលទាំង ៣ នោះ ក្នុង**បដិលាភកាល** ត្រូវពិចារណាដោយធាតុបច្ចវេក្ខណក៏បាន បដិកូលបច្ចវេក្ខណក៏បាន ក្នុង**បរិភោគកាល** ត្រូវពិចារណាដោយតំខណិកបច្ចវេក្ខណៈ ក្នុង**អតីតកាល** ត្រូវពិចារណាដោយអតីតបច្ច-វេក្ខណៈ ។

**ធាតុបច្ចវេក្ខណៈ** ត្រូវពិចារណាផ្ទៀបមកជាមួយនឹងកាយរបស់ខ្លួន ឲ្យឃើញថា គ្រាន់តែជាធាតុ ដើម្បីនឹងលះបង់នូវសេចក្តីប្រកាន់ថាខ្លួន និងរបស់ខ្លួនរាប់បញ្ចូលក្នុង **ធាតុមនសិការកម្មដ្ឋាន** ឬ **ចតុធាតុវវដ្ឋានកម្មដ្ឋាន**[25] ។

[25] មើលក្នុងសតិបដ្ឋានសូត្រ ត្រង់ធាតុបព្វ និងសមាធិនិទ្ទេស ត្រង់ចតុធាតុវវដ្ឋានកម្មដ្ឋាន ។

**បដិក្កូលបច្ចវេក្ខណៈ** ត្រូវពិចារណាផ្ទៀបមកជាមួយនិងកាយរបស់ខ្លួនឲ្យឃើញថាជារបស់មិនស្អាត គួរខ្ពើមរអើម ដើម្បីនឹងលះបង់សេចក្តីសម្គាល់ខុសថាជាល្អស្អាត បើក្នុង **បិណ្ឌបាតបច្ច័យ** រាប់បញ្ចូលក្នុង **អាហារេបដិក្កូលសញ្ញា**[26] ឯក្នុងបច្ច័យឯទៀតរាប់បញ្ចូលក្នុង **បដិក្កូលមនសិការកម្មដ្ឋាន**[27] ។

**តំខណិកបច្ចវេក្ខណៈ** និង **អតីតបច្ចវេក្ខណៈ** ត្រូវពិចារណាឲ្យដឹងនូវដែនរបស់ប្រយោជន៍ក្នុងការបរិភោគប្រើប្រាស់នូវបច្ច័យ ៤ ដូចគ្នាមិនឲ្យសម្គាល់ប្រយោជន៍ក្នុងការបរិភោគ ប្រើប្រាស់នូវបច្ច័យ ៤ ដូចគ្នា មិនឲ្យសម្គាល់ប្រយោជន៍ហួសកំរិត តែ **តំខណិកបច្ចវេក្ខណៈ** ត្រូវពិចារណាក្នុងកាលកំពុងបរិភោគប្រើប្រាស់ ឯអតីតបច្ចវេក្ខណៈ ត្រូវពិចារណាបន្ថែមក្នុងកាលដែលបរិភោគប្រើប្រាស់

រួចហើយក្នុងថ្ងៃដដែល ការពារក្រែងភ្លេចភ្លាំងស្មារតី មិនបានពិចារណាក្នុងកាលដែលកំពុងបរិភោគប្រើប្រាស់នោះ ដើម្បីនឹងបិទនូវក្រសែរបស់តណ្ហាមិនឲ្យសេចក្តីប្រាថ្នាជាប់ចិត្តក្នុងបច្ច័យទាំងនោះ និងប្រហារនូវឧបនិស្ស័យរបស់ **រាគៈ ទោសៈ មោហៈ** និង **មានៈ** ជាដើម មិនឲ្យកើតឡើង ព្រោះតែបរិភោគប្រើប្រាស់នូវបច្ច័យទាំងនោះ ។ កាលបើភិក្ខុបរិភោគប្រើប្រាស់នូវបច្ច័យទាំងនោះហើយ មិនបានពិចារណា ក៏អំពើដែលភិក្ខុបរិភោគប្រើប្រាស់នោះ មិនមែននាំយកនូវសេចក្តីសុខមកប្រគល់ឲ្យឡើយ មានតែនាំមកនូវសេចក្តីទុក្ខក្នុងអបាយមកប្រគល់ឲ្យដោយពិត តួយ៉ាងដូចពុទ្ធភាសិត ដែលលោកអាងទុកមកដូច្នេះ ។

**អយសាវ មលំ សមុដ្ឋាយ តទុដ្ឋាយ តមេវ ខាទតិ**

[26] មើលក្នុងសមាធិនិទ្ទេស ត្រង់អាហារេបដិក្កូលសញ្ញាកម្មដ្ឋាន ។

[27] មើលក្នុងសតិបដ្ឋានសូត្រ ត្រង់បដិក្កូលបព្វ ។

ឯវំ អតិធោនចារិនំ សាធិ កម្មានិ នយន្តិ ទុគ្គតឹ ។

**សេចក្តីថា:** មន្ទិលដែលតាំងឡើងអំពីដែក ចេញមកអំពីដែក ត្រឡប់ស៊ីដែកដដែលនោះវិញ យ៉ាងណាមិញ អំពើកម្មទាំងឡាយ ដែលតាំងឡើងខាងក្នុងខ្លួនរមែងដឹកនាំនូវបុគ្គល ដែលប្រព្រឹត្តកន្លងនូវប្រាជ្ញាគ្រឿងពិចារណានូវបច្ច័យ ហើយបរិភោគប្រើប្រាស់នោះ ឲ្យទៅកាន់ទុគ្គតិ យ៉ាងនោះឯង ។

## ដែនរបស់ប្រយោជន៍ក្នុងការប្រើប្រាស់នូវបច្ច័យ

ក្នុង **តំខណិកាបច្ចវេក្ខណៈ** និង **អតីតបច្ចវេក្ខណៈ** នឹងពោលត្រឹមតែ **តំខណិកាបច្ចវេក្ខណៈ** ១ ប៉ុណ្ណោះ ទុកជាតួយ៉ាង ឯ**អតីតបច្ចវេក្ខណៈ** មិនចាំបាច់ពោលឡើយ ព្រោះមានសេចក្តីដូចគ្នា ។

## ក្នុងចីវរបច្ច័យកំណត់ដែនតាមប្រយោជន៍ ៤ យ៉ាងគឺ

១- **សីតស្ស បដិឃាតាយ** ដើម្បីការពាររត្រជាក់ ។

២- **ឧណ្ហស្ស បដិឃាតាយ** ដើម្បីការពារនូវកម្តៅ ។

៣- **ឌំសមកសវាតាតបសិរីសបសម្ផស្សានំ បដិឃាតាយ**

ដើម្បីការពារនូវសម្ផស្ស របោម មូស ខ្យល់ កម្តៅថ្ងៃ ពស់តូច និងពស់ធំទាំងឡាយ ។

៤- **ហិរិកោបិនប្បដិច្ឆាទនត្ថំ** ដើម្បីបិទបាំងនូវអវយវៈ ដែលធ្វើនូវសេចក្តីខ្មាសឲ្យកម្រើក ។

ក្នុង **បិណ្ឌចាតបច្ច័យ** ចាត់ជាអង្គដែលត្រូវឃាត់ ៤ ដែលជាដែនរបស់ប្រយោជន៍ ៨ រួមទាំងអស់ត្រូវជាអង្គ១២ ដូច្នេះគឺ:

១- **នេវ ទវាយ** មិនមែនដើម្បីលេងដូចក្មេងអ្នកស្រុក ។

២- **ន មទាយ** មិនមែនដើម្បីឲ្យកើតបុរិសមានៈ ស្រវឹងដូចអ្នកប្រដាល់ ។

៣- **ន មណ្ឌនាយ** មិនមែនដើម្បីប្រដាប់តាក់តែងរាងកាយដូចស្រ្តីក្នុងបុរី។

៤- **ន វិភូសនាយ** មិនមែនដើម្បីស្អិតស្អាងរាងកាយឲ្យផូរផង់ពណ៌សម្បុរដូចអ្នកលេងរបាំ ។

ទាំង ៤ នេះ ជាអង្គត្រូវឃាត់ មិនមែនជាដែនរបស់ប្រយោជន៍ ។

៥- **ឥមស្ស កាយស្ស ឋិតិយា** ដើម្បីនឹងតាំងនៅនៃកាយនេះ ។

៦- **យាបនាយ** ដើម្បីញ៉ាំងជីវិតិន្ទ្រិយ ឲ្យប្រព្រឹត្តទៅ ។

៧- **វិហឹសុបរតិយា** ដើម្បីបំបាត់បង់នូវសេចក្តីលំបាក ។

៨- **ព្រហ្មចរិយានុគ្គហាយ** ដើម្បីអនុគ្រោះដល់មគ្គព្រហ្មចរិយា និងសាសនព្រហ្មចរិយា ។

៩- **ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ** ដូច្នេះអញនឹងកម្ចាត់បង់នូវវេទនាចាស់ គឺសេចក្តីឃ្លានដែលមានហើយផង ។

១០- **នវញ្ច វេទនំ ន ឧប្បាទេស្សាមិ** អញនឹងញ៉ាំងវេទនាថ្មី គឺឆ្អែតហួសប្រមាណមិនឲ្យកើតឡើងបានផង ។

១១- **យាត្រា ច មេ ភវិស្សតិ** កិរិយាប្រព្រឹត្តិទៅនៃឥរិយាបថទាំង ៤ នឹងមានដល់អញផង ។

១២- **អនវជ្ជតា ច** សេចក្ដីមិនមានទោស មានមិនច្រអូសកាយមិនច្រអូសចិត្តជាដើម (នឹងមានដល់អញផង) ។

អង្គទាំង ៨ នេះជាដែនរបស់ប្រយោជន៍ ។ នៅមានសល់អង្គ ១ ទៀតគឺ: **សុផាវិហារោ ច** កិរិយានៅសប្បាយក្នុងឥរិយាបថទាំង ៤ (នឹងមានដល់អញ) តែអង្គនេះលោកមិនបានរាប់បញ្ចូលមកផង ព្រោះលោកចាត់ជាអានិសង្សរបស់ភោជន។ បណ្ដាអង្គទាំង ១២ អង្គដែលត្រូវឃាត់ ៤ ខាងដើម សម្រាប់ប្រហារ

ឧបនិស្ស័យរបស់កិលេស គឺអង្គទី១ សម្រាប់ប្រហារនូវ ឧបនិស្ស័យរបស់ **មោហ**. អង្គទី ២ សម្រាប់ប្រហារនូវឧបនិស្ស័យរបស់ **ទោស**. អង្គទី ៣ និង អង្គទី ៤ សម្រាប់ប្រហារនូវឧបនិស្ស័យរបស់ **រាគៈ** ឯអង្គក្រៅអំពីនេះសម្រាប់កំណត់តែដែនរបស់ប្រយោជន៍ប៉ុណ្ណោះ ។

## ក្នុងសេនាសនបច្ច័យកំណត់ដែនត្រឹមប្រយោជន៍ ៥ យ៉ាងគឺ

១- **សីតស្ស បដិឃាតាយ** ដើម្បីការពារនូវត្រជាក់ ។

២- **ឧណ្ហស្ស បដិឃាតាយ** ដើម្បីការពារនូវកម្ដៅ ។

៣- **ឧំសមកសភាតាតបសិរិសប្បសម្ផស្សាធំ បដិឃាតាយ** ដើម្បីការពារនូវសម្ផស្ស របោម មូស ខ្យល់ កម្តៅថ្ងៃ ពស់តូច និងពស់ធំទាំងឡាយ ។

៤- **ឧតុបរិស្សយវិនោទនំ** ដើម្បីបន្ទោបង់នូវគ្រោះថ្នាក់ក្រវាយដែលកើតអំពីរដូវ ។

៥- **បដិសល្លានារាមត្ថំ** ដើម្បីប្រមូលចិត្តអំពីអារម្មណ៍ផ្សេង ៗ ហើយអភិរម្យនៅក្នុងកម្មដ្ឋាន ។

## ក្នុចគលានបច្ច័យ ដែនរបស់ប្រយោជន៍កំណត់ត្រឹមតែ ១ គឺ

**ឧប្បន្នានំ វេយ្យាពាធិកានំ វេទនានំ បដិឃាតាយ អព្យាបជ្ឈបរមតាយ** ដើម្បីការពារនូវទុក្ខវេទនាទាំងឡាយ ដែលបៀតបៀនផ្សេងៗ ដែលកើតឡើង ហើយដរាបទៅដល់ត្រឹមប្រាសចាកសេចក្តីទុក្ខ ។

ប្រយោជន៍ក្នុងការប្រើប្រាស់បច្ច័យ ៤ ត្រូវព្រះយោគីសង្ឃឹមតែត្រឹមដែនបានកំណត់ទុកមកទាំងនេះឯង មិនត្រូវសង្ឃឹមឲ្យជ្រុលហួសអំពីដែនទាំងនេះទៅឡើយ ។

## បរិភោគ ៤

ការបរិភោគប្រើប្រាស់នូវបច្ច័យនេះ ចែកចេញតាមប្រភេទរបស់បុគ្គលអ្នកបរិភោគប្រើប្រាស់មាន ៤ យ៉ាងគឺ:

១- **ថេយ្យបរិភោគ** បរិភោគដោយការលួច បានដល់បរិភោគរបស់ភិក្ខុដែលទ្រុស្តសីល ។

២- **ឥណបរិភោគ** បរិភោគដោយបំណុល បានដល់បរិភោគរបស់ភិក្ខុដែលមានសីល តែមិនបានពិចារណា ។

៣- **ទាយជ្ជបរិភោគ** បរិភោគនូវមត៌កដែលត្រូវបាន បានដល់បរិភោគរបស់សេក្ខបុគ្គល ៧ ពួក ។

២- **សាមិបរិភោគ** បរិភោគរបស់ជនជាម្ចាស់ បានដល់បរិភោគរបស់ព្រះខីណាស្រព ។

## សេចក្តីអធិប្បាយ

១- **ថេយ្យបរិភោគ:** ភិក្ខុដែលទ្រុស្តសីល ហើយនៅបំបាំងខ្លួនពួនសំងំបរិភោគនូវបច្ច័យរបស់ទាយកជាមួយនឹងសង្ឃ ហៅថា លួចបច្ច័យរបស់

ទាយកមកបរិភោគ ព្រោះថា ទាយកដែលគេបូជានូវបច្ច័យមក គេចំពោះរកតែលោកដែលមានសីល ដោយគេប្រាថ្នាចង់បានផលច្រើន គេមិនបានចំពោះរកភិក្ខុដែលទ្រុស្តសីលនោះឡើយ ហើយភិក្ខុដែលទ្រុស្តសីលនៅក្លែងបំភាន់យកបច្ច័យរបស់គេមកបរិភោគ ទើបបានឈ្មោះថា លួចយកនូវបច្ច័យរបស់ទាយកមកបរិភោគ មិនត្រឹមប៉ុណ្ណោះសោត បានឈ្មោះថា លួចយកបច្ច័យរបស់ភិក្ខុដែលមានសីលទាំងប៉ុន្មានមកបរិភោគទៀតផង ព្រោះបច្ច័យដែលទាយកគេឲ្យមកដោយសទ្ធានោះ ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាត ទុកឲ្យភិក្ខុដែលមានសីលតែម្យ៉ាង ព្រះអង្គមិនបានអនុញ្ញាត ទុកឲ្យដល់ភិក្ខុដែលទ្រុស្តសីលនោះឡើយ ហើយភិក្ខុដែលទ្រុស្តសីលនោះ មកនៅបំបាំងរាំងមុខស្កាត់យកបច្ច័យទាំងនោះ

មកបរិភោគ ទើបបានឈ្មោះថា លួចយកនូវបច្ច័យរបស់ភិក្ខុ ដែលមានសីលមកបរិភោគ ។

២- **ឥណបរិភោគ:** ភិក្ខុដែលមានសីលបរិសុទ្ធហើយ តែបរិភោគប្រើប្រាស់នូវបច្ច័យមិនបានពិចារណាក្នុងកាលទាំង ៣ ដោយបច្ចវេក្ខណៈ ទាំង ៤ ឯណានីមួយសោះ បែបនេះហៅថា បរិភោគដោយបំណុល ទុកដូចជាជំពាក់បំណុលរបស់ទាយក មិនអាចនឹងរលាស់ខ្លួនឲ្យរួចអំពីសំសារទុក្ខទៅបាន ប្រៀបដូចបុគ្គលដែលជំពាក់បំណុលរបស់អ្នកដ៏ទៃ ក៏មិនងាយនឹងទៅកាន់ប្រទេសណាដែលខ្លួនត្រូវការទៅនោះ តាមសេចក្ដីគាប់ចិត្តរបស់ខ្លួននោះបានឡើយ ហេតុនោះភិក្ខុដែលមានសីលបរិសុទ្ធ គប្បីពិចារណាក្នុង**ចីវរបច្ច័យ** ឲ្យរាល់ប្រយោគ

ដែលប្រើប្រាស់ ក្នុង**បិណ្ឌបាតបច្ច័យ** ឲ្យរាល់ពំនូត ក្នុង**សេនាសនបច្ច័យ** ឲ្យរាល់វារៈដែលចូលទៅ ឯក្នុង**ភេសជ្ជបច្ច័យ** ឲ្យពិចារណាទាំងក្នុងកាលដែលបានទទួលផង ក្នុងកាលដែលបរិភោគផង ។

៣- **ទាយជ្ជបរិភោគ:** សេក្ខបុគ្គល ៧ ពួក ទុកជាបុត្ររបស់ព្រះដ៏មានព្រះភាគ ដែលត្រូវទទួលនូវមត៌ករបស់ព្រះអង្គ បច្ច័យទាំង ៤ ដែលទាយកគេឲ្យដោយសទ្ធា ទុកថាជាមត៌កដែលព្រះអង្គប្រទានទុកឲ្យដល់បុត្រ ព្រោះហេតុនោះ កិរិយាបរិភោគនូវបច្ច័យទាំង ៤ របស់សេក្ខបុគ្គល ៧ ពួក ហៅថាបរិភោគនូវមត៌កដែលលោកត្រូវការបាន ។ ឯបរិភោគរបស់ភិក្ខុដែលមានសីលហើយ

បានពិចារណានោះ នឹងហៅថា **អាណណ្យបរិភោគ** (ប្រែថា) បរិភោគមិនមានបំណុលដូច្នេះក៏បាន ព្រោះជាបដិបក្ខដល់ **ឥណបរិភោគ** ឬ នឹងហៅថា **ទាយជ្ជបរិភោគ** ដូច្នេះផងក៏បាន ព្រោះភិក្ខុដែលមានសីល លោកប្រកបដោយសីលសិក្ខា ហាក់ដូចជាសេក្ខបុគ្គលដែរ ។

៤- សាមិបរិភោគៈ ព្រះខីណាស្រពទាំងឡាយ លោកកន្លងផុតហើយនូវភាពជាខ្ញុំនៃ **តណ្ហា** លោកបាននាមថា ជាម្ចាស់នៃបច្ច័យ ព្រោះលោកបរិភោគរបស់បុគ្គលណា អាចញ៉ាំងសេចក្តីប្រាថ្នារបស់បុគ្គលនោះឲ្យពេញបរិបូណ៌បាន។

ក្នុងបរិភោគទាំង ៤ យ៉ាងនេះ **សាមិបរិភោគ** ប្រសើរជាងគេបំផុត **ទាយជ្ជបរិភោគ** ប្រសើរបន្ទាប់ ឯ**ថេយ្យបរិភោគ** និង**ឥណបរិភោគ** មិនប្រសើរឡើយ ។

## ការមិនបែកធ្លាយនិងបែកធ្លាយនៃបច្ចយសន្និស្សិតសីល

**បច្ចយសន្និស្សិតសីល** មានការបរិសុទ្ធិដោយពិចារណា ឲ្យតែបានពិចារណាហើយទាំងបី យ៉ាងហោចទៅត្រឹម **បច្ចវេក្ខណ** ណាមួយ ក្នុងបច្ច័យណាមួយ តែត្រឹមមួយចប់ក្តី ពីរចប់ក្តី ក៏បានឈ្មោះថា មិនទាន់បែកធ្លាយនៅឡើយ ត្រាតែមិនបានពិចារណាទទេសោះ រហូតដល់អរុណរះឡើង ទើបបានឈ្មោះថាបែកធ្លាយ ហើយភិក្ខុនោះក៏ស្ថិតនៅក្នុង **ឥណបរិភោគ** ផងទៀត ។ ការពោលមកនេះចំពោះតែបច្ច័យឯទៀតក្រៅពីភេសជ្ជបច្ច័យប៉ុណ្ណោះ ឯភេសជ្ជបច្ច័យ ត្រូវពិចារណាក្នុងកាលទទួលផង ក្នុងកាលបរិភោគផងទើបគួរ ឬបើមិនបានពិចារណា

ក្នុងកាលដែលទទួល ឲ្យតែបានពិចារណាក្នុងកាលដែលបរិភោគក៏បាន បើមិនបានពិចារណាក្នុងកាលដែលបរិភោគ ទុកជាបានពិចារណាក្នុងកាលដែលទទួល ក៏គង់ត្រូវ**អាបត្តិទុក្កដ** ហើយ**ចាដិមោក្ខសំវរៈ** ក៏បែកធ្លាយផង តែ**បច្ចយសន្និស្សិតសីល**មិនទាន់បែកធ្លាយនៅឡើយ ត្រាតែផុតដែនរបស់**អតីតបច្ចវេក្ខណៈ** ទៀតទើបបែកធ្លាយ ព្រោះតំខណិកបច្ចវេក្ខណៈ ក្នុងគិលានភេសជ្ជបច្ច័យនេះ រក្សាទាំងចាដិមោក្ខសំវរសីល ទាំងបច្ចយសន្និស្សិតសីល ឯអតីតបច្ចវេក្ខណៈ រក្សាបានតែត្រឹម បច្ចយសន្និស្សិតសីលតែម្យ៉ាង គឺថាបើបានពិចារណាតែតំខណិកបច្ចវេក្ខណៈ ហើយ អតីតបច្ចវេក្ខណៈ មិនបាច់ពិចារណាក៏បាន សីលទាំង ២ នឹងមិនបែកធ្លាយឡើយ បើតំខណិកបច្ចវេក្ខណៈ មិនបានពិចារណាហើយ ទុកជាបានពិចារណាអតីតបច្ចវេក្ខណៈ ក៏មិនបែកធ្លាយតែបច្ចយសន្និស្សិតសីលប៉ុណ្ណោះ ឯចាដិមោក្ខសំវរៈសីល នៅបែកធ្លាយដដែល ព្រោះភិក្ខុនោះត្រូវអាបត្តិទុក្កដ រួចហើយ ។

**បច្ចយសន្និស្សិតសីល**នេះព្រះយោគាវចរភិក្ខុគប្បីឲ្យសម្រេចដោយអំណាចនៃបញ្ញា គឺថាមានបញ្ញាជាគ្រឿងជំនួយឲ្យសម្រេច ព្រោះសីលនេះត្រាតែលោកដែលមានប្រាជ្ញាឃើញទោសនិងអានិសង្សក្នុងបច្ច័យទាំង ៤ ជាក់ច្បាស់ ទើបអាចពិចារណាធ្វើឲ្យសម្រេចទៅបាន ព្រោះហេតុនោះព្រះយោគី គប្បីលះបង់នូវសេចក្តីប្រាថ្នា ឈ្លក់ក្នុងបច្ច័យទាំង ៤ ហើយពិចារណាដោយប្រាជ្ញាតាមវិធីដែលលោកបានរៀបរៀងទុកនោះជាមុនសិន ហើយសន្សឹមបរិភោគប្រើប្រាស់ ។

មានពាក្យសរសើរថា បើភិក្ខុអង្គណាមួយ បានប្រព្រឹត្តធ្វើតាមបែបនេះ ភិក្ខុអង្គនោះ បានឈ្មោះថា ជាអ្នកបានធ្វើនូវកិច្ចដ៏សមគួរ ដល់ពាក្យប្តេជ្ញាដើមរបស់ខ្លួន សមដូចគាថាដែលលោកនិពន្ធទុកដូច្នេះ

បិណ្ឌំ វិហារំ សយនាសនញ្ច
អាបញ្ច សង្ឃាដិរជូបវាហនំ
សុត្វាន ធម្មំ សុគតេន ទេសិតំ
សង្ខាយ សេវេ វរបញ្ញសាវកោ ។
តស្មា ហិ បិណ្ឌេ សយនាសនេ ច
អាបេ ច សង្ឃាដិរជូបវាហនេ
ឯតេសុ ធម្មេសុ អនូបលិត្តោ
ភិក្ខុ យថា បោក្ខរេ វារិពិន្ទុ ។
កាលេន លទ្ធា បរតោ អនុគ្គហា
ខជ្ជេសុ ភោជ្ជេសុ ច សាយនេសុ ច
មត្តំ ស ជញ្ញា សតតំ ឧបដ្ឋិតោ
វណស្ស អាលេបនរូហនេ យថា ។
កន្តារេ បុត្តមំសំវ អក្ខស្សព្ភញ្ជនំ យថា
ឯវំ អាហរេ អាហារំ យាបនាយ អមុច្ឆិតោ

**សេចក្ដីថា:** ភិក្ខុជាសាវកអ្នកមានប្រាជ្ញដ៏ប្រសើរ ស្ដាប់នូវព្រះធម៌ដែលព្រះសុគតទ្រង់សម្ដែងហើយ ត្រូវពិចារណាជាមុនសិន ហើយសេពនូវបិណ្ឌបាត ទីដេក ទីអង្គុយ និងទឹកសម្រាប់លាងធូលីដែលជាប់សំពត់សង្ឃាដី, ព្រោះហេតុនោះឯងភិក្ខុមិនត្រូវជំពាក់ក្នុងធម៌ទាំងឡាយនេះ គឺក្នុងអាហារបិណ្ឌបាត ទីដេក ទីអង្គុយ និងទឹកសម្រាប់លាងធូលីដែលជាប់សំពត់សង្ឃាដី ដូចដំណក់ទឹក ដែលមិនជាប់នៅលើស្លឹកឈូកយ៉ាងនោះឯង ។ ភិក្ខុនោះបានទទួលបច្ច័យទាំងឡាយតាមកាល ដោយសេចក្ដីអនុគ្រោះអំពីជនដទៃហើយ ជាអ្នកតម្កល់ស្មារតីខ្ជាប់រឿយៗ គប្បីដឹង

ប្រមាណក្នុងវត្ថុដែលគប្បីទំពាសី ក្នុងវត្ថុដែលគប្បីបរិភោគ និងក្នុងវត្ថុដែលគប្បីក្រេបជញ្ជក់ ប្រៀបដូចអ្នកមានដំបៅ ដឹងប្រមាណក្នុងការបំពកថ្នាំថែដំបៅដូច្នោះឯង។

ភិក្ខុមិនគប្បីជាប់ចិត្តក្នុងអាហារ ឆាន់អាហារគ្រាន់តែដើម្បីញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅបាន ប្រៀបដូចមាតាបិតាអ្នកធ្វើដំណើរផ្លូវកន្តារ បរិភោគនូវសាច់របស់កូនខ្លួនឯង (ដើម្បីកំដរអត្តភាពទាំងទើសទាល់) និងប្រៀបដូចអ្នកបររទេះ លាបខ្លាញ់ភ្លៅរទេះ (សោះតែខានមិនបាន) យ៉ាងនោះឯង។

## **សុទ្ធិកថា**

នៅទីបំផុតនេះ នឹងសូមពណ៌នាអំពី **សុទ្ធិ** ៤ យ៉ាង ជាសេចក្ដីបន្ទាប់បន្សំត្រួតថែមទៀត ដើម្បីជាការមាំដល់គំនិតប្រាជ្ញារបស់លោកអ្នកសិក្សា **ប្រតិបត្តិ**តទៅ:

ក៏សីលទាំង ៤ ដូចបានពណ៌នាមកនុ៎ះ បើចាត់ឲ្យល្អមឈ្មោះតាម **សុទ្ធិ** គឺកិច្ចដែលត្រូវតែឲ្យស្អាតឡើងវិញ ក្នុងវេលាដែលបែកធ្លាយម្ដងៗ នោះ មាន ៤ យ៉ាង មានឈ្មោះដោយឡែកៗ អំពីគ្នាដូច្នេះគឺ

១- **ទេសនាសុទ្ធិ** សីលបរិសុទ្ធដោយកិរិយាសម្ដែង បានដល់ **បាដិមោក្ខសំវរសីល**។

២- **សំវរសុទ្ធិ** សីលបរិសុទ្ធដោយសង្រួម បានដល់ **ឥន្ទ្រិយសំវរសីល**។

៣- **បរិយេដ្ឋិសុទ្ធិ** សីលបរិសុទ្ធដោយកិរិយាស្វែងរក បានដល់ **អាជីវបារិសុទ្ធិសីល**។

៤- **បច្ចវេក្ខណសុទ្ធិ** សីលបរិសុទ្ធដោយកិរិយាពិចារណា បានដល់ បច្ចយសន្និស្សិតសីល ។

## សេចក្តីអធិប្បាយ

**បាដិមោក្ខសំវរសីល** បានឈ្មោះថា **ទេសនាសុទ្ធិ** បរិសុទ្ធដោយកិរិយាសម្តែង ព្រោះថាកាលបើបែកធ្លាយហើយ ត្រូវតែសម្តែងចំពោះមុខសង្ឃ គណៈ ឬបុគ្គល ទើបអាចកែឲ្យបរិសុទ្ធឡើងវិញបាន ។

**ឥន្ទ្រិយសំវរសីល** បានឈ្មោះថា**សំវរសុទ្ធិ** បរិសុទ្ធដោយកិរិយាសង្រួម ព្រោះថា បើបែកធ្លាយហើយ ត្រូវតែអធិដ្ឋានតាំងចិត្តថា អញនឹងមិនធ្វើយ៉ាងនេះទៀត ហើយប្រុងប្រយ័ត្នសង្រួមតទៅ ទើបអាចកែឲ្យបរិសុទ្ធឡើងវិញបាន ។

**អាជីវបារិសុទ្ធិសីល**បានឈ្មោះថា**បរិយេដ្ឋិសុទ្ធិ**បរិសុទ្ធដោយកិរិយាស្វែងរក ព្រោះថាបើបែកធ្លាយហើយ ត្រូវតែលះបង់នូវ **អនេសនៈ** ដែលជាហេតុនាំឲ្យបែកធ្លាយនោះចេញ ហើយស្វែងរកនូវបច្ច័យដែលកើតឡើយ ប្រកបដោយធម៌ យកមកបរិភោគ ទើបអាចកែឲ្យបរិសុទ្ធឡើងវិញ ។

**បច្ចយសន្និស្សិតសីល** មានឈ្មោះថា**បច្ចវេក្ខណសុទ្ធិ** បរិសុទ្ធដោយកិរិយាពិចារណា ព្រោះសីលនេះ ដែលនឹងធ្វើឲ្យបរិសុទ្ធឡើងបាន ត្រាតែបានពិចារណាតាម**បច្ចវេក្ខណវិធី** ដែលពោលរួចមកហើយនោះ ។

កាលបើដូច្នេះ ព្រះយោគាវចរភិក្ខុ ដែលមានសីលទាំង ៤ ណាមួយធ្លុះធ្លាយមិនបរិសុទ្ធនោះ គួរតែកែឲ្យបរិសុទ្ធឡើងវិញ តាមទំនងដែលបានអធិប្បាយមកនេះ មិនគួរសម្ងំឲ្យយកគ្រឿងមិនស្អាតនោះទុកក្នុងខ្លួនឡើយ ។

## គ្រឿងសៅហ្មងនៃសីល

១- ការកើតឡើងធម៌ គឺ **ខណ្ឌ** ដាច់ **ឆិទ្ទ** ធ្លុះ **សពល** ពពាល **កម្មាស** ពព្រុះនៃសីល ព្រោះហេតុតែ**លាភ** **យស** **ញាតិ** **រាងកាយ** ជីវិតផងដោយ **មេថុនសំយោគ ៧** ផង ហៅថាគ្រឿងសៅហ្មងរបស់សីល ។

## សេចក្តីពន្យល់
## អំពីគ្រឿងសៅហ្មងនៃសីល

**សីលដាច់** គឺដាច់ត្រង់សិក្ខាបទខាងដើម ឬត្រង់ទីបំផុតក្នុងអាបត្តិទាំង ៧ កង ដូចជាសំពត់សាដក ដែលដាច់ត្រង់ជាយ ។

**សីលធ្លុះ** គឺបែកធ្លាយត្រង់សិក្ខាបទកណ្តាល ដូចជាសំពត់សាដក ដែលធ្លុះចំកណ្តាល ។

សីលពពាល គឺបែកធ្លាយត្រង់សិក្ខាបទពីរបីតាមលំដាប់ ដូចមេគោពពាល ។

សីលពព្រុះ គឺដាច់ត្រង់សិក្ខាបទជាចន្លោះៗ ដូចមេគោពព្រុះ ។

## មេថុនសំយោគ ៧

១- អ្នកប្រព្រឹត្ត **ព្រហ្មចរិយ** ហើយត្រេកអរនូវកិរិយាអប់ គក់ ផ្ងូត ច្របាច់ របស់មាតុគ្រាម ឬប្រាថ្នាចង់ឲ្យបាននូវអំពើទាំងនោះ ។

២- មិនដល់ម្ល៉ោះ ត្រឹមតែសើចក្អាកក្អាយលេងប្រឡែងជាមួយនឹងមាតុគ្រាម ហើយត្រេកអរតាមនោះ ។

៣- មិនដល់ម្លោះ ត្រឹមតែសំឡក់ភ្នែករបស់មាតុគ្រាម ដោយភ្នែករបស់ខ្លួន ឬ ញាក់ចិញ្ចើមឲ្យមាតុគ្រាម ហើយត្រេកអរតាមនោះ ។

៤- មិនដល់ម្លោះ ត្រឹមតែស្តាប់សំឡេងរបស់មាតុគ្រាមសើច និយាយស្តី ឬ ច្រៀងជាដើម ខំផ្ទៀងចាំស្តាប់អំពីខាងក្រៅជញ្ជាំង ឬ ខាងក្រៅកំពែង ជាដើម ហើយត្រេកអរតាមនោះ ។

៥- មិនដល់ម្លោះ ត្រឹមតែនឹកភ្នកដល់សំណើចសើច សំដីចចារ នឹងល្បែងលេងដែលខ្លួនធ្លាប់សើច ធ្លាប់ចចារ ធ្លាប់លេងជាមួយនឹងមាតុគ្រាមក្នុងកាលមុន ហើយត្រេកអរតាមនោះ ។

៦- មិនដល់ម្លោះ ត្រឹមតែឃើញគហបតី ដែលស្កប់ស្កល់ដោយកាមគុណ ៥ ជាដើម ហើយត្រេកអរចំពោះការស្កប់ស្កល់ដោយកាមគុណ ៥ នោះ ។

៧- មិនដល់ម្លោះ ត្រឹមតែប្រាថ្នាឲ្យបានជាទេវនិកាយណាមួយ ហើយប្រព្រឹត្ត **ព្រហ្មចរិយធម៌** ដោយប្រាថ្នា អញនឹងបានជាទេវតាបែបនេះ ឬ ទេវតាដែលមានសក្តិធំណាមួយដោយសីលនេះ វត្តនេះ តបៈនេះ **ព្រហ្មចរិយ** នេះ ដូច្នោះហើយត្រេកអរទៅតាមទំនងនោះ ។

ទាំង ៧ យ៉ាងនេះហើយដែលលោកហៅថា **មេថុនសំយោគ** ព្រោះស្រដៀងៗ តែនឹងប្រកបដោយមេថុន ។

កាលបើ **សមណព្រាហ្មណ៍** ណាមួយប្រព្រឹត្តតាមលំអាននេះ **សីល** ក្តី **ព្រហ្មចរិយ** ក្តី របស់ **សមណព្រាហ្មណ៍** នោះ បានឈ្មោះថាដាច់ផង ធ្លុះផង ពពាលផង ពព្រុះផង ។

# គ្រឿងផូរផង់នៃសីល

សីលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុះ គឺព្រះដ៏មានព្រះភាគ ទ្រង់សង្គ្រោះដោយការមិនទម្លាយនូវសិក្ខាបទ ដោយប្រការទាំងអស់ផង ដោយការធ្វើនូវការសំដែងនូវទោស ដែលបែកធ្លាយសិក្ខាបទហើយផង ដោយកិរិយាកើតឡើងនៃគុណ មាន**អប្បិច្ឆតា** ភាពនៃខ្លួនជាអ្នកប្រាថ្នាតិច **សន្តុដ្ឋិតា** ភាពនៃខ្លួនជាអ្នកសន្តោស **សល្លេខតា** ភាពនៃខ្លួនជាអ្នកជុសខាត់ជាដើម ព្រោះការមិនកើតឡើងនៃ**មេថុនសំយោគ ៧** ប្រការ និងកិរិយាមិនកើតឡើងនៃ **បាបធម៌** មាន **កោធៈ** សេចក្តីក្រោធ, **ឧបនាហៈ** ចងក្រោធទុក, **មក្ខ** រមិលគុណ, **បលាស** វាយឫកស្មើ, **ឥស្សា** សេចក្តីច្រណែន, **មច្ឆរិយ** សេចក្តីកំណាញ់, **មាយា** លាក់ពុត, **សាថេយ្យ** អួតអាង, **ថម្ភ** រឹងត្អឹង, **សារម្ភ** ប្រឡងវាសនា, **មានៈ** ប្រកាន់ខ្លួន, **អតិមានៈ** មើលងាយគេ, **មទៈ** ស្រវឹង, **បមាទៈ** ប្រហែសធ្វេសជាដើមផង ។

សេចក្តីពិតថាៈ សីលឯណាដែលមិនបែកធ្លាយ ដោយប្រយោជន៍ចំពោះមានលាភជាដើមក្តី សូម្បីបែកធ្លាយដោយទោសនៃសេចក្តីប្រមាទ ហើយដល់បានធ្វើការសំដែងទោសនោះហើយក្តី មិនប៉ះទង្គិចហើយដោយមេថុនសំយោគ ឬបាបធម៌ក្តី សីលនោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយថា សីលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុះមែនពិត ជាសីលមិនមានបំណុល គឺរួចចាកខ្ញុំនៃតណ្ហា សីលនោះជាសីលអ្នកប្រាជ្ញ មានព្រះពុទ្ធជាដើមទ្រង់ពោលសសើរ

មិនប៉ះពាល់ដល់ **តណ្ហា** និង **ទិដ្ឋិ** មានកិរិយាញ៉ាំង **ឧបចារសមាធិ** និង **អប្បនាសមាធិ** ឲ្យប្រព្រឹត្តទៅបាន ។

**តស្មា** ព្រោះហេតុនោះ វិភាពនៃសីលមិនដាច់ជាដើមនោះឯងជាគ្រឿងផូរផង់របស់សីលនោះឯង ។

ឯគ្រឿងផូរផង់របស់សីលនោះ រមែងសម្រេចដោយអាការ ២ យ៉ាងគឺ ការឃើញទោសនៃ **សីលវិបត្តិ** ១ ការឃើញអានិសង្សរបស់ **សីលសម្បត្តិ** ១ ។

## ១- ទោសរបស់សីលវិបត្ត

**សីលវិបត្តិ:** ការវិនាសនៃសីល ទោសនៃការវិនាសសីល របស់បុគ្គលអ្នកទ្រុស្តសីលតែងបាននូវទោស ៥ យ៉ាងគឺ

១- មិនបាននូវគំនរទ្រព្យសម្បត្តិ (ទ្រព្យសម្បត្តិចេះតែវិនាស) ។

២- កត្តិសព្ទអាក្រក់ផុសអណ្តែតឡើង ។

៣- តែងមានមុខអៀនអន់ ដាក់មុខសំយុងចុះ ក្នុងការចូលទៅកាន់ទីប្រជុំជន ។

៤- វង្វេងស្មារតី ក្នុងពេលធ្វើកាលកិរិយា (ស្លាប់) ។

៥- បន្ទាប់អំពីបែកធ្លាយ ទំលាយខន្ធទៅតែងចូលទៅកើតក្នុងអបាយភូមិ។

ម្យ៉ាងទៀតក្នុងសព្វលហុសូត្រ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងអំពីទោសរបស់បញ្ចវេរា ដោយមានសេចក្តីថា:

១- អំពើគឺការសម្លាប់សត្វមានជីវិតតែងនាំសត្វឲ្យកើតក្នុង **នរក** កំណើត **តិរច្ឆាន ប្រេតវិស័យ** បើសិនជាកម្មនោះជាកម្មស្រាលបំផុត កាលបើកើតជាមនុស្ស នាំឲ្យអាយុខ្លី ។

២- អំពើ គឺការលួចទ្រព្យគេ តែងនាំសត្វឲ្យទៅកើតក្នុង **នរក** កំណើត **តិរច្ឆាន ប្រេតវិស័យ** បើកម្មនោះជាកម្មស្រាលបំផុត កាលកើតជាមនុស្ស ក៏នាំមកនូវសេចក្ដីវិនាសទ្រព្យសម្បត្តិ ។

៣- គឺអំពើ ការប្រព្រឹត្តិខុសក្នុងកាម តែងនាំសត្វឲ្យកើតក្នុង **នរក** កំណើត **តិរច្ឆាន ប្រេតវិស័យ** បើកម្មនោះជាកម្មស្រាលបំផុត កាលកើតជាមនុស្ស ក៏នាំមកនូវពៀរមួយអន្លើដោយសត្រូវ ។

៤- អំពើ គឺការពោលពាក្យកុហក តែងនាំឲ្យកើតក្នុង **នរក កំណើត តិរច្ឆាន ប្រេតវិស័យ** បើកម្មនោះជាកម្មស្រាលបំផុត កាលកើតជាមនុស្ស តែងជួបប្រទះនូវការពោលបង្កាច់អំពីសំណាក់នៃជនដទៃ ។

៥- អំពើ គឺការផឹកទឹកស្រវឹង តែងនាំឲ្យកើតក្នុង **នរក** កំណើត**តិរច្ឆាន ប្រេតវិស័យ** បើកម្មនោះជាកម្មស្រាលបំផុត កាលកើតជាមនុស្ស ក៏នាំឲ្យទៅជាមនុស្សឆ្កួតសីលា ។

ម្យ៉ាងទៀតទោសរបស់សីល គឺបុគ្គលអ្នកទ្រុស្តសីល មិនជាទីគាប់ចិត្តរបស់ទេវតា និងមនុស្សទាំងឡាយ, ជាបុគ្គលគឺ **សព្រហ្មចារី** មិនគប្បីទូន្មានរឿយៗ, ប្រកបដោយទុក្ខដល់ **សព្រហ្មចារី**, ដែលកើតវិប្បដិសារីក្នុងពេលដែល

គេតិះដៀលបុគ្គលអ្នកទ្រុស្តសីល និងសរសើរនូវបុគ្គលអ្នកមានសីល, មានសម្បុរអាក្រក់ ដូចជាសំពត់សាដក ដែលគេធ្វើអំពីសំបកផ្ទៃ, មានកិរិយាប៉ះព្រមនូវទុក្ខ, មានតម្លៃតិច, មានការជម្រះលំបាក ដូចជារណ្តៅលាមក ដែលគេកប់អស់ឆ្នាំជាអនេក, ជាអ្នកបួសខាងក្រៅអំពី **ឧភតោសង្ឃ** ដូចជាអង្កត់អុសដែលគេដុតខ្មោចហើយ, សូម្បីប្តេជ្ញាខ្លួនឯងថាជាភិក្ខុក៏មិនមែនជាភិក្ខុ ដូចសត្វលាជាប់តាមហ្វូងគោ , មានសេចក្តីតក់ស្លុតរឿយៗ ដូចជាបុរសប្រកបដោយពៀរទាំងអស់, មិនគួររួមនៅជាមួយ ដូចជាសាកសពស្លាប់, សូម្បីប្រកបដោយគុណមានសុត:ជាដើម ក៏មិនគួរដល់ការបូជារបស់សព្រហ្មចារីទាំងឡាយ ដូចជាភ្លើងក្នុងព្រៃដុតខ្មោច មិនគួរដល់ការបូជារបស់ពួកព្រាហ្មណ៍ មិនគួរត្រាស់ដឹងនូវគុណវិសេស ដូចមនុស្សមិនគួរក្នុងការឃើញរូប អស់សង្ឃឹមក្នុងព្រះសទ្ធម្ម ឬដូចជាកុមារតូចនៃចណ្ឌាល អត់មានសង្ឃឹមក្នុងរាជ្យ សូម្បីកាលសម្គាល់នូវខ្លួនថា អញជាអ្នកប្រកបដោយសេចក្តីសុខក្នុងរាជ្យ ក៏ប្រកបដោយសេចក្តីទុក្ខតែម្យ៉ាងមែនពិត ។

## ២- អានិសង្សនៃសីលសម្បត្តិ

**សីលសម្បត្តិ** មានន័យថា ការដល់ព្រមដោយសីល រីឯអានិសង្សមានសភាពផ្ទុយនឹងទោសរបស់សីលវិបត្តិ គឺបុគ្គលគប្បីជ្រាបចុះ ។ **អានិសង្ស** មានពោលហើយក្នុងសៀវភៅនេះខាងដើមរួចហើយ កាលដែលបុគ្គលពិចារណាឃើញនូវទោសរបស់ **សីលវិបត្តិ** និងអានិសង្សនៃ **សីលសម្បត្តិ** ចិត្តដ៏តក់ស្លុតចំពោះ **សីលវិបត្តិ** ហើយឱនទេរចុះទៅក្នុងសីលសម្បត្តិពិត។

**តស្មា** ព្រោះហេតុដូច្នោះ សីលគឺបុគ្គលឃើញទោសរបស់ **សីលវិបត្តិ** និង ឃើញអានិសង្សរបស់ **សីលសម្បត្តិ** នេះ ដូចបានពោលរួចហើយគប្បីឲ្យផូរផង់ ។

## ការជម្រះសីល

**យោគាវចរ** ដែលជាអ្នកស្រឡាញ់សុខ ស្អប់ទុក្ខក្នុងសំសារវដ្ត កាលបើសមាទាននូវសីលហើយ គប្បីសង្រួមប្រុងប្រយ័ត្ន កុំប្រព្រឹត្តកន្លងនូវសិក្ខាបទដែលខ្លួនសមាទានហើយ តែថាកាលបើសេចក្ដីភ្លាំងភ្លាត់ដាច់សីលណាមួយដោយទោសនៃសេចក្ដីប្រហែសធ្វេស ត្រូវទៅប្រកាសប្រាប់អំពីទោសកំហុសរបស់ខ្លួនចំពោះអាចារ្យ ឬសព្រហ្មចារី ហើយសម្ដែងទោសនោះ ហើយត្រូវធ្វើនូវសេចក្ដីសង្រួមតទៅទៀត ។

ការជម្រះសីល គឺកាលជម្រះ **កាយកម្ម វចីកម្ម** និង **មនោកម្ម** ឲ្យស្អាតបរិសុទ្ធ ដូចមានសេចក្ដីសំដែងក្នុង **គម្ពីរមជ្ឈិមនិកាយ មូលបណ្ណាសក ភិក្ខុវគ្គ** ត្រង់ចូឡរាហុលោវាទសូត្រ ទី ១ ថា: ទឹកមានបន្តិចបន្តួចដក់ជាប់នៅក្នុងផ្តិលយ៉ាងណា ទឹកដែលគ្មានក្នុងផ្តិល ឬផ្តិលទឹកដែលគេផ្កាប់ ឬថាផ្តិលផ្ងារឡើងដែលគ្មានទឹកយ៉ាងណា, ពួកភិក្ខុដែលមិនមានសេចក្ដីអៀនខ្មាសក្នុង **សម្បជានមុសាវាទ** (ពោលពាក្យកុហកដោយដឹងខ្លួន) មាន **សមណធម៌** (ធម៌របស់អ្នកស្ងប់) មានប្រមាណតិចក៏យ៉ាងនោះ ។

ដំរីរបស់ស្ដេចចូលទៅកាន់សង្គ្រាម ធ្វើការគ្រប់អវយវៈទាំងអស់ តែនៅលាក់ប្រមោយ ព្រោះខ្លាចសេចក្ដីស្លាប់យ៉ាងណា, ភិក្ខុបួសក្នុងព្រះពុទ្ធសាសនាព្រះ

តថាគត គប្បីសិក្សាថា អាត្មាអញនឹងមិនពោលពាក្យកុហក សូម្បីបន្តិចបន្តួចក៏យ៉ាងនោះ ។

ការឆ្លុះមុខនឹងកញ្ចក់ ដើម្បីមើលមុខស្អាត និងមិនស្អាតយ៉ាងណា ជនអ្នករក្សាសីល គប្បីជម្រះ **កាយកម្ម**, **វចីកម្ម**, និង **មនោកម្ម** ត្រូវធ្វើការត្រិះរិះក្នុងទី ៣ ឋាន ក៏យ៉ាងនោះគឺ:

១- មុននឹងប្រារព្ធធ្វើការងារដោយ **កាយ វាចា ចិត្ត** ត្រូវធ្វើសេចក្ដីត្រិះរិះការងារនោះសិន តើល្អ ឬ អាក្រក់ ។

២- ពេលកំពុងធ្វើការងារដោយ **កាយ វាចា ចិត្ត** ត្រូវធ្វើសេចក្ដីត្រិះរិះក្នុងការងារនោះទៀត តើល្អឬអាក្រក់ ។

៣- ពេលធ្វើការងារនោះហើយ ត្រូវធ្វើសេចក្ដីត្រិះរិះក្នុងការងារនោះទៀត តើល្អឬអាក្រក់ ។

ប្រសិនបើធ្វើនូវសេចក្ដីត្រិះរិះក្នុងការងារនោះ ឃើញថាការងារនោះ ជាអកុសល (អាក្រក់) ត្រូវលះបង់ចេញ ឈប់ធ្វើ តែឃើញការងារនោះជាកុសល (ល្អ) ទេ ត្រូវព្យាយាមធ្វើចុះ ។

ម្យ៉ាងទៀត កាយកម្មនិងវចីកម្ម ដែលបានធ្វើកន្លងហើយជាអកុសល គឺខ្លួនត្រូវចូលទៅរកគ្រូ ឬសព្រហ្មចារី ឬជាអ្នកមានប្រាជ្ញាបណ្ឌិតណាមួយហើយសម្ដែងនូវទោសកំហុសរបស់ខ្លួននោះក្នុងទីចំពោះមុខ ដោយកុំលាក់លៀមឡើយ កាលបើសម្ដែងទោសនោះរួចហើយ គប្បីធ្វើសេចក្ដីសង្រួមឲ្យល្អតទៅខាងមុខ។

បើកម្មគឺអំពើដែលខ្លួនធ្វើរួចហើយនោះល្អទេ ត្រូវញ៉ាំង **បីតិចាមោជ្ជៈ** ឲ្យពោរពេញឡើងក្នុងសន្ដានតទៅ ។

ម្យ៉ាងទៀត យោគីដែលជម្រះសីលឲ្យបរិសុទ្ធនោះ ត្រូវធ្វើខ្លួនឲ្យមានសភាពជាអ្នកប្រាថ្នាតិច សន្ដោស ដុសខាត់ចិត្តគំនិតឲ្យស្អាតផូរផង់ រួចចាកអំពីមេថុនសំយោគ និងបាបធម៌លាមកមានកោធៈជាដើម ដោយការប្រព្រឹត្តិដូចតទៅនេះ

១- ការប្រព្រឹត្តិនូវធុតង្គវត្ត ។

២- ការចម្រើននូវកម្មដ្ឋាន ។

## ១- ការប្រព្រឹត្តិនូវធុតង្គវត្ត

ក៏អប្បិច្ឆតាគុណ និងសន្ដុដ្ឋិតាគុណជាដើម ជាគ្រឿងផូរផង់របស់សីល ឬជាគ្រឿងញ៉ាំងសីលឲ្យផូរផង់ ព្រោះថាសីលដែលនឹងស្អាតល្អទៅបាន ត្រាតែមានគុណទាំងអស់នោះជាទឹកសម្រាប់លាង ហើយគុណទាំងនោះ ដែលនឹងកើតឡើងបាន ព្រោះអាស្រ័យបុគ្គលជាអ្នកប្រព្រឹត្តនូវធុតង្គមែនពិត ។

## ធុតង្គវិនិច្ឆយកថា

ការលើកឡើងពោលអំពី **ធុតង្គ** ទុកក្នុងសៀវភៅ **វិបស្សនាកម្មដ្ឋាន** ថ្នាក់ដំបូងនេះ ដើម្បីបំពេញតាមអធ្យាស្រ័យ នៃកុលបុត្រអ្នកបួសក្នុងព្រះពុទ្ធសា-សនាតាមសទ្ធា ជាអ្នកប្រតិបត្តិតឹងរឹងក្នុងការអប់រំទូន្មានខ្លួនឲ្យបានល្អប៉ុណ្ណោះ

មិនមែនជាការបង្គាប់បញ្ជាជាដាច់ខាតថា "អ្នករៀន **វិបស្សនា** ត្រូវតែធ្វើ **ធុតង្គ** នោះទេ" បុគ្គលណាមានសទ្ធាប្រព្រឹត្ត **ធុតង្គវត្ត** ហើយចម្រើនកម្មដ្ឋានផងក៏បាន ឬមិនអាចទេ មានសទ្ធាត្រឹមតែរក្សាសីលចម្រើនកម្មដ្ឋានក៏បាន ក៏មិនទាស់អ្វី តែថាបើមានសេចក្តីនឿយណាយក្នុងខន្ធ ៥ ដែលប្រកបដោយមហាទុក្ខគ្រប់យ៉ាង ក៏គួរប្រព្រឹត្ត **ធុតង្គវត្ត** ផង ចម្រើន **កាម្មដ្ឋាន** ផងគួរ ព្រោះជាកិច្ចប្រតិបត្តិមួយនាំមកនូវសេចក្តីចម្រើន នៃសីលដ៏បរិសុទ្ធផង. ជាកិច្ចប្រតិបត្តិយ៉ាងហ្មត់ហ្មង ក្នុងការលះបង់កិលេសយ៉ាងឧក្រិដ្ឋផង, ជាកិច្ចប្រតិបត្តិក្នុងការត្រាស់ដឹងនូវលោកុត្តរធម៌ យ៉ាងឆាប់រហ័សផង. ហើយជាកិច្ចមួយដើម្បីរក្សាទុកនូវវត្តដ៏ប្រសើររបស់ព្រះអរិយបុគ្គលទាំងឡាយ មានព្រះពុទ្ធជាដើមផង ។

## ធុតង្គ ១៣

ពាក្យថា **ធុតង្គ** បានសេចក្តីថា អង្គរបស់បុគ្គលអ្នកកម្ចាត់បង់នូវកិលេស ឬថាធម្មជាតិមានញាណ សម្រាប់កម្ចាត់បង់នូវកិលេសជាអង្គ ។

ន័យមួយទៀតថា អង្គនៃសេចក្តីប្រតិបត្តិ សម្រាប់កម្ចាត់បង់នូវធម៌ជាសត្រូវ ។ រួបរួមយក **សមាទានចេតនា** គឺចេតនាសម្រាប់សមាទាននូវអង្គនោះៗ **ធុតង្គ** នោះមាន ១៣ គឺ:

១- **បំសុកូលិកង្គ:** អង្គរបស់ភិក្ខុមានកិរិយាទ្រទ្រង់ នូវចីវរដែលដល់នូវភាពគួរខ្ពើមដូចអាចម៍ដីជាប្រក្រតី។

២- **តេចីវរិកង្គ:** អង្គរបស់ភិក្ខុអ្នកមានចីវរបីគឺ **សង្ឃាដី ចីពរ ស្បង់** ជាប្រក្រតី។

៣- **បិណ្ឌចាតិកង្គ:** អង្គរបស់ភិក្ខុអ្នកមានកិរិយាត្រេចទៅ ដើម្បីបិណ្ឌបាតជាវត្ត ។

៤- **សបទានចារិកង្គ:** អង្គរបស់ភិក្ខុអ្នកមានកិរិយាត្រេចទៅដើម្បីបិណ្ឌបាតរៀងតាមលំដាប់នៃផ្ទះជាប្រក្រតី ។

៥- **ឯកាសនិកង្គ:** អង្គរបស់ភិក្ខុអ្នកមានកិរិយាបរិភោគនូវភោជនតែក្នុងអាសន ១ ជាប្រក្រតី ។

៦- **បត្តបិណ្ឌិកង្គ:** អង្គរបស់ភិក្ខុអ្នកមានកិរិយាបរិភោគនូវភោជនតែក្នុងបាត្រ[28] ។

៧- **ខលុបច្ឆាភត្តិកង្គ:** អង្គរបស់ភិក្ខុអ្នកមានកិរិយាមិនបរិភោគនូវភត្ត ដែលខ្លួនហាមនូវភោជនរួចហើយ ទើបបានមកជាខាងក្រោយជាប្រក្រតីដោយអំណាចនៃ **ធុតង្គសមាទាន** ។

៨- **អារញ្ញិកង្គ:** អង្គរបស់ភិក្ខុអ្នកមានកិរិយាអាស្រ័យក្នុងព្រៃជាប្រក្រតី ។

---

28 បាត្រក្នុងទីនេះ មិនសំដៅយកតែបាត្រត្រង់តែម្យ៉ាងឡើយ ទុកណាជាភាជន៍ដទៃ ក៏ហៅថា បាត្រដែរ ។

៩- **រុក្ខមូលិកង្គ:** អង្គរបស់ភិក្ខុអ្នកមានកិរិយានៅអាស្រ័យ ទៀបគល់នៃឈើជាប្រក្រតី ។

១០- **អព្ភោកាសិកង្គ:** អង្គរបស់ភិក្ខុអ្នកមានកិរិយាអាស្រ័យក្នុងទីវាលស្រឡះជាប្រក្រតី ។

១១- **សោសានិកង្គ:** អង្គរបស់ភិក្ខុអ្នកមានកិរិយានៅអាស្រ័យក្នុងព្រៃស្មសាន[29] ។

១២- **យថាសន្ថតិកង្គ:** អង្គរបស់ភិក្ខុអ្នកមានកិរិយានៅតែក្នុងទី **សេនាសន** ដែលភិក្ខុសម្ដែងឲ្យជាដំបូងដដែលមិនរើសរុះជាប្រក្រតី ។

១៣- **នេសជ្ជិកង្គ:** អង្គរបស់ភិក្ខុអ្នកមានកិរិយា ឃាត់នូវ **ឥរិយាបថ** ដេក ហើយនៅដោយ **ឥរិយាបថ** អង្គុយជាប្រក្រតី ។

## ធុតង្គលក្ខណាទិ

- **ធុតង្គ** ១៣ នេះមានចេតនាសម្រាប់សមាទានជាលក្ខណៈ ។
- មានកិរិយាកម្ចាត់បង់នូវភាពដែលល្មោភលោភលន់ជាកិច្ច ។
- អាចនឹងបង្ហាញផលឲ្យឃើញប្រាកដឡើងជាភាព ដែលមិនល្មោភមាន **អប្បិច្ឆតាធម៌** និង **អរិយធម៌** មានសីលដែលបរិសុទ្ធជាដើម ជាហេតុជួយបណ្ដុះបណ្ដាលឲ្យកើតឡើង ។

## វិធីសមាទានធុតង្គ

[29] កន្លែងសម្រាប់ដុតខ្មោច (ប៉ាឆា)

ព្រះយោគាវចរកុលបុត្រអង្គណា ដែលត្រូវការនឹងសមាទាន **ធុតង្គ** ទាំង ១៣ ណាមួយ កាលបើព្រះដ៏មានព្រះភាគគង់នៅឡើយ ត្រូវសមាទានក្នុងសំណាក់ព្រះអង្គ ដល់អំណើះអំពីព្រះអង្គទៅ ត្រូវតែសមាទានក្នុងសំណាក់ **មហាសាវក** អំណើះអំពីមហាសាវកទៅ **ព្រះខីណាស្រព**ដ៏សេស **ព្រះអនាគាមី ព្រះសកទាគាមី ព្រះសោតាបន្ន** លោកអ្នកទ្រទ្រង់នូវ **សង្គីតិ ព្រះអដ្ឋកថាចារ្យ** រៀងចុះមកជាលំដាប់ អំណើះអំពីលោកទាំងនោះទៅទៀត ត្រូវសមាទានក្នុងសំណាក់ លោកអ្នកទ្រទ្រង់នូវ **ធុតង្គ** មុនៗ មក. បើមិនមានលោកអ្នកទ្រទ្រង់នូវ **ធុតង្គ** មុនៗ មកទេ ត្រូវបោសសំអាតនូវលាន **ព្រះចេតិយ** ឲ្យស្អាត ហើយក្រាបថ្វាយបង្គំដោយគោរព ឲ្យដូចជាកាលដែល **ព្រះសម្ពុទ្ធ** ទ្រង់គង់នៅ រួចហើយអង្គុយច្រហោងប្រណម្យអញ្ជលីឡើង តាំងសមាទានក្នុងទីនោះចុះ ពុំនោះនឹងសមាទានតែដោយខ្លួនឯងក៏បាន ។

ឯវិធីសមាទានជាដើមក្នុង **ធុតង្គ** នោះៗ គប្បីដឹងលំអាន ដែលនឹងពោលទុកដូចតទៅនេះចុះ ។

## បំសុកូលិកង្គ

## វិធីសមាទានក្នុងបំសុកូលិកង្គ

ក៏ក្នុង **បំសុកូលិកង្គ** នេះ មានបាលីសម្រាប់សមាទានជាពីរបែបដូច្នេះ បែបទី ១ ថា **គហបតិទានចីវរំ បដិក្ខិបាមិ** (ប្រែថាខ្ញុំព្រះករុណាសូមឃាត់នូវចីវរ ដែលជាទានរបស់គហបតី) ។

បែបទី ២ ថា **បំសុកូលិកង្គំ សមាទិយាមិ** ប្រែថា ខ្ញុំព្រះករុណាសូមសមាទាននូវអង្គរបស់ភិក្ខុអ្នកមានកិរិយាទ្រទ្រង់នូវចីវរ ដែលដល់នូវភាពខ្ពើមដូចជាអាចម៍ដីជាប្រក្រតី ។

បាលីទាំង ២ បែបនេះប្រើបានដូចគ្នា ស្រេចហើយនឹងសេចក្តីពេញចិត្តរបស់ព្រះយោគីអ្នកសមាទាន ទោះបីសមាទានតាមបែបណាក៏ដោយ ។

ក៏ព្រះយោគី ដែលបានសមាទាននូវ **ធុតង្គ** នេះរួចហើយ ត្រូវស្វែងរកចីវរដែលកើតអំពី **បំសុកូលក្ខេត្ត** ទាំង ២៣ ណាមួយយកមកហែក រើសយកតែត្រង់ កន្លែងណាដែលមាំមួនយកទៅបោកគក់ ដេរជាចីវរឲ្យបានសម្រេច រួចផ្លាស់គហបតីចីវរចាស់របស់ខ្លួននោះចេញ ហើយគប្បីស្លៀកប្រើប្រាស់ចុះ ។

## ចីវរកើតអំពីបំសុកូលក្ខេត្ត ២៣

ចីវរដែលកើតអំពី **បំសុកូលក្ខេត្ត** ២៣ នោះដូច្នោះគឺ

១- **សោសានិកៈ** សំពត់ដែលធ្លាក់ចុះក្នុងព្រៃស្មសាន មានសំពត់ស្នបខ្មោចជាដើម ។

២- **ចាបណិកៈ** សំពត់ដែលធ្លាក់ចុះទៀបទ្វារនៃរានផ្សារ គឺសំពត់ដែលគេចោលក្បែរៗ រានផ្សារ ។

៣- **រថិយចោឡៈ** សំពត់ដែលបុគ្គលអ្នកត្រូវការដោយបុណ្យទាំងឡាយគេទម្លាក់តាមចន្លោះបង្អួចទៅត្រង់ផ្លូវរថ ។

៤- **សង្ការចោឡ:** សំពត់ដែលគេចោលទៅលើគំនរសម្រាម ។

៥- **សោត្ថិយ:** សំពត់ដែលគេជូតនូវមន្ទិលគតិ ហើយគេចោលទៅក្នុងទីណាមួយ ។

៦- **ឆ្ការចោឡ:** សំពត់ដែលពេទ្យបណ្ដោញភូត គេយកទៅទទួលគ្រប អ្នកជម្ងឺលិចទាំងក្បាល ហើយគេផ្ងូតទឹកឲ្យ ដល់ហើយកិច្ចនេះគេយកទៅចោលក្នុងទីណាមួយៗ ដោយសម្គាល់ថា ជាសំពត់ **កាឡកណ្ណី** ។

៧- **តិត្ថចោឡ:** កំណាត់សំពត់ដែលគេចោលទៅក្បែរកំពង់ងូតទឹក ។

៨- **គតបច្ចាគត:** សំពត់ដែលមនុស្ស គេទៅកាន់ព្រៃស្មសានដល់ត្រឡប់មកវិញ គេងូតទឹកហើយផ្លាស់ចោល ។

៩- **អគ្គិឌឌ្ឍ:** សំពត់ដែលភ្លើងឆេះត្រង់ណាមួយកន្លែង ហើយម្ចាស់គេចោល ។

១០- **គោខាយិត:** សំពត់ដែលគោអង្គាមត្រង់ណាមួយកន្លែងហើយម្ចាស់គេចោល ។

១១- **ឧបចិកាខាយិត:** សំពត់ដែលកណ្ដៀរកាត់ត្រង់ណាមួយកន្លែង ហើយម្ចាស់គេចោល ។

១២- **ឧន្ទូរខាយិត:** សំពត់ដែលកណ្ដុរកាត់ត្រង់ណាមួយកន្លែង ហើយម្ចាស់គេចោល ។

១៣- **អន្តច្ឆិន្នៈ** សំពត់ដែលដាច់រឹម ហើយម្ចាស់គេចោល ។

១៤- **ឧសច្ឆិន្នៈ** សំពត់ដែលរេចជាយ ហើយម្ចាស់គេចោល ។

១៥- **ធជាហដៈ** សំពត់ដែលមនុស្សអ្នកឡើងកាន់ទូក ឬ សំពៅចេញទៅប្រទេសណានីមួយ ហើយគេចងធ្វើទង់ជ័យនៅមាត់កំពង់ ពុំនោះសំពត់ដែលគេចងធ្វើទង់ជ័យនៅត្រង់ទីចម្បាំង[30] ។

១៦- **ថូបចីវរៈ** សំពត់ដែលគេរុំព័ទ្ធជុំបូក ហើយធ្វើពលិកម្ម ។

១៧- **សមណចីវរៈ** ចីវររបស់សមណ គឺចីវររបស់ភិក្ខុផងគ្នា[31] ។

១៨- **អាភិសេកិកៈ** សំពត់ដែលគេចោលត្រង់កន្លែងអភិសេកស្តេច ។

១៩- **ឥទ្ធិមយៈ** ចីវរដែលសម្រេចដោយឫទ្ធិ គឺចីវររបស់ឯហិភិក្ខុ[32] ។

២០- **បន្ថិកៈ** សំពត់ដែលគេឲ្យជ្រុះនៅកណ្តាលផ្លូវ[33] ។

២១- **វាតាហដៈ** សំពត់ដែលខ្យល់គួចអណ្តែតទៅធ្លាក់ចុះទៅក្នុងទីឆ្ងាយ ។

---

[30] សំពត់បែបនេះ ត្រាតែម្ចាស់គេចេញទៅផុតទើបយកបាន ។

[31] ចីវរដែលភិក្ខុផងគ្នា យកទៅតម្កល់ទុកទៀបបាទមូល ។

[32] សំដៅយកចីវរដែលឯហិភិក្ខុឲ្យ ។

[33] សំពត់នេះបើម្ចាស់គេឲ្យជ្រុះដោយភ្លេចស្មារតីរក្សាទុកចាំមើលម្ចាស់គេ មួយស្របក់សិន ។

២២- **នេវជត្តិយៈ** សំពត់ដែលទេវតាផ្តល់ឲ្យ[34] ។

២៣- **សាមុទ្ទិយៈ** សំពត់ដែលរលកសមុទ្រ ផាត់ច្រានទៅលើគោក សំពត់ទាំងប៉ុន្មាននេះ មិនសំដៅយកសំពត់ ដែលមានទាយកគេនាំយកមកប្រគេនដល់ដៃ ឬសំពត់ដែលសង្ឃត្រូវចែកទៅតាមលំដាប់ជាដើមនោះឡើយ សំដៅយកតែសំពត់ដែលមិនមានទាយកជាម្ចាស់ហើយ ភិក្ខុស្វែងរកបានដោយខ្លួនឯង ឬចីវរដែលភិក្ខុផងគ្នាឲ្យប៉ុណ្ណោះ ទើបបានឈ្មោះថា ***បំសុកូលចីវរ*** បើមានទាយកគេនាំមកប្រគេនដល់ដៃមិនបានឈ្មោះថា ***បំសុកូលចីវរ*** ឡើយ ។

## ប្រភេទនៃបំសុកូលិកភិក្ខុ

ភិក្ខុអ្នកប្រព្រឹត្តនូវ **បំសុកូលិកង្គ** នេះ លោកចែកជាបី ថ្នាក់គឺៈ

១- **ឧក្កដ្ឋោ** ថ្នាក់ឧក្រិដ្ឋ ឬថ្នាក់ជាន់ខ្ពស់ ។

២- **មជ្ឈិមោ** ថ្នាក់មធ្យម ឬថ្នាក់កណ្តាល ។

៣- **មុទុ** ថ្នាក់អន់ ឬថ្នាក់ជាន់ទាប ។

**សេចក្តីថាៈ** ភិក្ខុដែលរើសយកតែសំពត់ដែលធ្លាក់ក្នុងព្រៃស្មសានតែម្យ៉ាង មកធ្វើជាចីវរប្រើប្រាស់ ចាត់ជាថ្នាក់ឧក្រិដ្ឋ បើមានទាយកគេនាំយកសំពត់ទៅតម្កល់ទុកក្នុងទីណាមួយ ដោយបំណងថានឹងឲ្យអ្នកបួសរើសយក[35] ហើយភិក្ខុរើសយកនូវសំពត់នោះមកធ្វើជាចីវរប្រើប្រាស់ ចាត់ជាថ្នាក់មធ្យម ភិក្ខុដែលកាន់យកនូវសំពត់ ដែលទាយកគេនាំយកមកតម្កល់ទុកទៀបបាទមូល ទៅធ្វើជាចីវរប្រើប្រាស់ចាត់ជាថ្នាក់អន់។

---

[34] សំពត់បន្លង ។

[35] សំពត់បន្លង ។

# ធុតង្គបែកក្នុងបំសុកូលិកង្គ

ធុតង្គរបស់ភិក្ខុទាំង ៣ ថ្នាក់នេះ ត្រូវបែកធ្លាយខណៈដែលភិក្ខុទទួលត្រេកអរនូវចីវរដែលគ្រហស្ថគេឲ្យ តាមដោយសេចក្ដីពេញចិត្តរបស់ខ្លួនមែនពិត ។ ធុតង្គ គឺបំសុកូលិកង្គក្ដី ធុតង្គទាំង ១២ ឯទៀតក្ដី កាលបើបែកធ្លាយហើយ ព្រះយោគីមិនទាន់អស់អាល័យនឹងរក្សាតទៅទៀតទេ ក៏គប្បីតាំងសមាទានឡើងជាថ្មី ហើយប្រព្រឹត្តទៅតាមលំអាននៃធុតង្គនោះ ៗ តទៅខាងមុខទៀតចុះ ។

# អានិសង្សក្នុងបំសុកូលិកង្គ

ក្នុងបំសុកូលិកង្គនេះ ព្រះយោគីបានរក្សាទុកដោយល្អ មិនបានឲ្យបែកធ្លាយ និងមានអានិសង្ស ១២ យ៉ាងគឺ

១- **និស្សយានុរូបបដិបត្តិសព្ភាវោ:** សភាពជាអ្នកមានសេចក្តីប្រតិបត្តិដ៏សមគួរដល់និស្ស័យ ដែលឧបសម្បទាចារ្យប្រៀនប្រដៅអំពីខាងដើម ថា “**បព្វជ្ជា** ត្រូវអាស្រ័យនូវបំសុកូលចីវរ ដូច្នេះជាដើម ។

២- **បឋមេ អរិយវំសេ បតិដ្ឋានំ:** កិរិយាតាំងនៅក្នុងអរិយវង្ស ទី១ [36] ។

៣- **អារក្ខទុក្ខាភាវោ:** មិនមានទុក្ខ ព្រោះកិរិយារក្សានូវចីវរ ។

---

[36] អរិយវង្សមាន ៤ យ៉ាងគឺ: សន្តោសក្នុងចីវរ ១ សន្តោសក្នុង បិណ្ឌបាត ១ សន្តោសក្នុងសេនាសនៈ ១ សន្តោសក្នុងភេសជ្ជៈ ១ ។

៤- អបរាយត្តវុត្តិតា: ភាពជាអ្នកមិនប្រព្រឹត្តជាប់ដោយបុគ្គលដទៃ ។

៥- ចោរភយេន អភយតោ: ភាពជាអ្នកមិនមានភ័យ ព្រោះខ្លាចចោរ ។

៦- បរិភោគតណ្ហាយ អភាវោ: មិនមានតណ្ហាក្នុងគ្រឿងប្រើប្រាស់ ។

៧- សមណសារុប្បបរិក្ខារតា: ភាពជាអ្នកមានគ្រឿងបរិក្ខារដ៏សមគួរដល់សមណៈភេទ ។

៨- ភគវតា សំវណ្ណិតបច្ចយតា: ភាពជាអ្នកមានបច្ច័យដែលព្រះដ៏មានព្រះភាគទ្រង់សរសើរ ។

៩- បាសាទិកតា: ភាពជាអ្នកនាំមកនូវសេចក្តីជ្រះថ្លាដល់បុគ្គលដទៃ ។

១០- អប្បិច្ឆតាទីនំ ផលនិប្ផត្តិ: កិរិយាសម្រេចនូវផលនៃគុណមានអប្បិច្ឆតាគុណជាដើម ។

១១- សម្មាបដិបត្តិយា អនុព្រូហនំ: កិរិយាបង្កើតនូវសម្មាបដិបត្តិ ។

១២- បច្ឆិមាយ ជនតាយ ទិដ្ឋានុគតិអាបាទនំ: កិរិយាញុំាងប្រជុំជនជំនាន់ក្រោយឲ្យយកតម្រាប់តាម ។

## គាថាទីបំផុតក្នុងបំសុកូលិកង្គថា

មារសេនំ វិយាតាយ     បំសុកូលធរោ យតិ
សន្នទ្ធកវចោ យុទ្ធេ     ខត្តិយោ វិយ សោភតិ
បហាយ កាសិកាទីនិ     វរវត្ថានិ ធារិតំ
យំ លោកគរុនា កោ តំ     បំសុកូលំ ន ធារយេ
តស្មា ហិ អត្តនោ ភិក្ខុ     បដិញ្ញំ សមនុស្សរំ
យោគាចារានុកូលម្ហិ     បំសុកូលេ រតោ សិយា

សេចក្ដីថា: ព្រះបរមក្សត្រដែលទ្រង់នូវគ្រឿងក្រោះ ល្អក្នុងទីចម្បាំងយ៉ាងណា ព្រះយោគីអ្នកទ្រទ្រង់នូវបំសុកូលចីវរ ល្អក្នុងកិរិយាពិឃាដនូវមារសេនាយ៉ាងនោះ ។ អម្បាលតែព្រះពុទ្ធជាបរមគ្រូនៃសត្វលោក ម្ដេចគង់ព្រះអង្គអាចលះបង់នូវសំពត់ទាំងឡាយដ៏ថ្លៃថ្លា មានសំពត់ដែលបានមកអំពីដែនកាសីជាដើម ហើយមកទ្រទ្រង់នូវបំសុកូលចីវរ ចុះភិក្ខុអង្គណាសោត ក៏នឹងអាចហ៊ានអាក់ខានមិនទ្រទ្រង់នូវបំសុកូលចីវរនោះបាន ? ព្រោះហេតុនោះឯង ព្រះយោគាវចរភិក្ខុ កាលបើរលឹកឃើញនូវពាក្យប្ដេជ្ញារបស់ខ្លួន [37] ក៏គប្បីជាអ្នកត្រេកអរក្នុងបំសុកូលចីវរ ដ៏សមគួរដល់សេចក្ដីព្យាយាមចុះ ។

## បំសុក្ខូលិកង្គ ចប់

---

## តេចីវរិកង្គ
## វិធីសមាទានក្នុងតេចីវរិកង្គ

បន្ទាប់អំពីបំសុកូលិកង្គមក នឹងពណ៌នាអំពីតេចីវរិកង្គតទៅ ។ ក្នុងតេចីវរិកង្គនេះ ក៏មានបាលីសម្រាប់សមាទានជា ២ បែបដូចគ្នា ។

បែបទី ១ ថា: **ចតុត្ថកចីវរំ បដិក្ខិបាមិ** ប្រែថា ខ្ញុំព្រះករុណាសូមឃាត់នូវចីវរគម្រប់ ៤ ។

---

[37] សំដៅពាក្យប្ដេជ្ញា ដែលឧបសម្បទាចារ្យប្រាប់និស្ស័យថា "បំសុកូលចីវរ" និស្ស័យបព្វជ្ជា ១ ដូច្នេះជាដើម ហើយខ្លួនទទួលថា "អាម ភន្តេ" ដូច្នេះ ។

បែបទី ២ ថា: **តេចីវរិកង្គំ សមាទិយាមិ** ប្រែថា: ខ្ញុំព្រះករុណាសូមសមាទាននូវអង្គនៃភិក្ខុអ្នកមានតែចីវរ ៣ ជាប្រក្រតី ។

បាលីទាំងពីរបែបនេះ តាមតែព្រះយោគីត្រូវការ ទោះបីសមាទានតាមបែបណាក៏បាន ។

ក៏តេចីវរិកភិក្ខុ[38]នេះ ចាប់ដើមអំពីពេលដែលបានសមាទាននោះមក បើបានសំពត់ដែលបម្រុងនឹងធ្វើនូវចីវរ ក្រៅអំពីចីវរចាស់របស់ខ្លួនទាំង ៣ នោះហើយមិនទាន់បានធ្វើ ព្រោះមិនសប្បាយដោយហេតុឯណាមួយក្តី ចាត់ចែងវាស់កាត់ជាដើមមិនទាន់ក្តី នៅខ្វះចេសម្ទូលជាដើម មិនទាន់បានគ្រប់គ្រាន់ក្តី ត្រូវមានអំណាចទុកដាក់សំពត់នោះបានដរាប មិនមានទោស ក្នុងកិរិយាត្រេកអរនូវចីវរជាគម្រប់ ៤ ព្រោះហេតុតែទុកដាក់នូវចីវរនោះឡើយ តែតាំងអំពីត្រឹមជ្រលក់ហើយទៅ នឹងទុកដាក់តទៅទៀតមិនបានឡើយ បើទុកដាក់តទៅទៀត លោកចាត់ជាមហាចោរប៉ែកខាងធុតង្គ ។

## ប្រភេទនៃតេចីវរិកភិក្ខុ

តេចីវរិកភិក្ខុនេះ ក៏មានចាត់ជា ៣ ថ្នាក់ដូចបំសុកូលិកភិក្ខុដែរ ។

សេចក្តីថា: ភិក្ខុថ្នាក់ឧក្រិដ្ឋ ក្នុងកាលដែលជ្រលក់នូវចីវរ ត្រូវជ្រលក់ស្បង់មុន ឬចីពរមុនក៏បាន បើជ្រលក់ស្បង់មុន ត្រូវយកចីពរមកស្លៀកផងដណ្តប់ផងក៏បាន ស្លៀកចីពរដណ្តប់សង្ឃាដីក៏បាន រួចហើយសន្សឹមយកស្បង់មក

---

[38] ភិក្ខុអ្នកទ្រទ្រង់តែចីពរ ៣ ។

ស្លៀកផ្លាស់ យកចីពរទៅជ្រលក់វិញរួចស្រេចហើយទាំង ២ សន្សឹមស្លៀកស្បង់ដណ្តប់ចីពរ ហើយជ្រលក់សង្ឃាដី បើជ្រលក់ចីពរមុន ក៏មានន័យប្រហែលៗ គ្នា តែសង្ឃាដីលោកហាមមិនឲ្យស្លៀកឡើយ ។ ដែលពោលមកនេះ ចំពោះភិក្ខុដែលនៅក្នុងទីសេនាសនៈក្នុងចន្លោះនៃស្រុក បើភិក្ខុដែលនៅក្នុងព្រៃវិញ ទោះបីជ្រលក់ទាំងស្បង់ទាំងចីពរដំណាលគ្នាក៏បាន តែត្រូវអង្គុយទីជិតចីពរដែលជ្រលក់នោះឲ្យល្មមតែឃើញមនុស្សណាមួយដើរមក អាចនឹងទាញចីវរណាមួយមកគ្របអំពីលើខ្លួនបាន ។

ភិក្ខុថ្នាក់មធ្យម បើមានសំពត់កាសាវ សម្រាប់ប្រើប្រាស់ក្នុងរោងជ្រលក់ អាចនឹងស្លៀកដណ្តប់នូវសំពត់កាសាវនោះ ហើយជ្រលក់នូវចីវររបស់ខ្លួនបាន ។

ឯភិក្ខុថ្នាក់អន់ អាចស្លៀកដណ្តប់នូវចីវររបស់ភិក្ខុផងគ្នា ហើយជ្រលក់ចីវររបស់ខ្លួនបាន ឬនឹងស្លៀកដណ្តប់នូវសំពត់កម្រាលរបស់ខ្លួនក្តី របស់សង្ឃក្តី របស់បុគ្គលដទៃក្តី ដែលគេធ្វើមកអំពីសំពត់កាសាវៈតម្កល់ទុកសម្រាប់ជាគ្រឿងកម្រាលក្នុងទីសេនាសនៈនោះក៏បាន តែសំពត់កម្រាលនេះ ត្រូវប្រើប្រាស់បានតែក្នុងខណៈដែលជ្រលក់ចីវរប៉ុណ្ណោះ បើនឹងហួងហែងប្រើប្រាស់តែម្នាក់ឯងអស់កាលជានិច្ច នោះពុំបានឡើយ ។

តែចីវរិកភិក្ខុ ៣ ថ្នាក់នេះ បើនឹងបង្កើតសំពត់អង្សៈមួយមកទៀតឲ្យជាគម្រប់ ៤ ក៏បាន តែសំពត់អង្សៈនោះ ត្រូវធ្វើឲ្យមានកម្រិតទទឹង ១ ចំអាមបណ្តោយ ៣ ហត្ថទើបគួរ ។

# ធុតង្គបែកក្នុងតេចីវរិកង្គ

ធុតង្គទាំង ៣ ថ្នាក់នេះ ដែលនឹងបែកធ្លាយនោះ បែកធ្លាយក្នុងខណៈដែលទទួលត្រេកអរនូវចីវរជាគម្រប់ ៤ ដូចគ្នា ទាំង ៣ ថ្នាក់ ។

# អានិសង្សក្នុងតេចីវរិកង្គ

ធុតង្គគឺ តេចីវរិកង្គ កាលបើភិក្ខុបានរក្សាដោយល្អ មិនបានឲ្យបែកធ្លាយ នឹងមានអានិសង្ស ១១ យ៉ាងដូច្នេះគឺ:

**១-សន្តុដ្ឋោ:** បានឈ្មោះថា ជាអ្នកមានសេចក្តីសន្តោសដោយចីវរ ល្មមតែរក្សានូវកាយបាន[39] ។

**២-សមាទាយេវ គមនំ:** កិរិយាកាន់យកតែចីវរ ៣ ប៉ុណ្ណោះ ដើរទៅហាក់ដូចជាសត្វបក្សី[40] ។

**៣-អប្បសមារម្ភតា:** ភាពជាអ្នកមានរវល់តិច ព្រោះមិនមានកិច្ចដែលត្រូវហាលសំដិល ឬបត់ទុកនូវអតិរេកចីវរជាដើម ។

**៤- វត្ថសន្និធិបរិវជ្ជនំ:** កិរិយាវៀរបង់នូវកិរិយាសន្សំទុកនូវសំពត់ ។

**៥-សល្លហុកវុត្តិតា:** ភាពជាអ្នកប្រព្រឹត្តស្រាលរហ័ស ។

---

[39] មើលត្រង់ប្រយោជន៍ក្នុងកិរិយាប្រើប្រាស់ចីវរប្បច្ច័យ ក្នុងបច្ច័យសន្និស្សិតសីល ។

[40] សត្វបក្សីហើរទៅតែស្លាបទទេ ដែលល្មមយោងអត្តភាពទៅរួច មិនមានសន្សំអ្វីយកទៅជាមួយផង ។

៦- អតិរេកចីវរលោលុប្បបហានំ: កិរិយាលះបង់នូវសេចក្តីល្មោភហួសកម្រិតក្នុងអតិរេកចីវរ ។

៧- កាប្បិយេ មត្តការិតា: ភាពជាអ្នកប្រមាណក្នុងចីវរដែលគួរ[41] ។

៨- សល្លេខវុត្តិតា: ភាពជាអ្នកប្រព្រឹត្តក្បិលឬក្រីនូវកិលេសឲ្យស្តើងចុះ ។

៩- អប្បិច្ឆតាទីនំ ផលនិប្ផត្តិ: កិរិយាសម្រេចនូវផលនៃអប្បិច្ឆតាគុណជាដើម ។

១០- សម្មាបដិបត្តិយា អនុព្រូហនំ: កិរិយាបង្កើតនូវសម្មាបដិបត្តិ ។

១១- បច្ឆិមាយ ជនតាយ ទិដ្ឋានុគតិអាបាទនំ: កិរិយាញុំាងប្រជុំជនជំនាន់ក្រោយឲ្យយកតម្រាប់តាម ។

## គាថាជាទីបំផុតក្នុងតេចីវរិកង្គ

អតិរេកវត្ថតណ្ហំ បហាយ សន្និធិវិវជ្ជិតោ ធីរោ
សន្តោសសុខរសញ្ញូ តិចីវរធរោ ភវតិ យោគី
តស្មា សបត្តចរណោ បក្ខីវ សចីវរោវ យោតិវរោ
សុខមនុវិចរិតុកាមោ ចីវរនិយមេ រតិំ កយិរា ។

[41] សូម្បីចីវរដែលព្រះពុទ្ធទ្រង់អនុញ្ញាត បានច្រើនទៅទៀតដូចនិសីទនជាដើម ក៏ភិក្ខុនោះត្រេកអរតែក្នុងចីវរ ៣ ប៉ុណ្ណោះ ។

សេចក្ដីថាៈ ព្រះយោគីជាអ្នកប្រាជ្ញ អ្នកដឹងនូវរសនៃសេចក្ដីសុខ ដែលកើតអំពីសេចក្ដីសន្ដោស លោករមែងលះបង់នូវសេចក្ដីចំណង់ក្នុងសំពត់ដែលលើសកំណត់ លោករមែងវៀរបង់នូវកិរិយាសន្សំទុកនូវសំពត់ លោកទ្រទ្រង់តែចីវរ ៣ ប៉ុណ្ណោះ ព្រោះហេតុនោះ ព្រះយោគីដ៏ប្រសើរ (ក្នុងសាសនានេះ) កាលបើមានប្រាថ្នាដើម្បីត្រេចទៅជាសុខ ក៏ត្រូវឲ្យមានតែចីវរ ៣ ជាប់នៅជាមួយ ហាក់ដូចជាសត្វបក្សីដែលត្រេចទៅ មានតែស្លាបជាប់ទៅជាមួយនឹងខ្លួន ដូច្នោះ គប្បីធ្វើនូវសេចក្ដីត្រេកអរ តែក្នុងចីវរដែលមានកំណត់ ។

## បិណ្ឌបាតកង្គ

ក្នុងបិណ្ឌបាតិកង្គ ក៏មានបាលីសម្រាប់សមាទានជាពីរបែបដូចគ្នា ។

បែបទី ១ ថា **អតិរេកលាភំ បដិក្ខិបាមិ** (ប្រែថា) ខ្ញុំព្រះករុណា សូមឃាត់នូវលាភដែលលើស អំពីភោជនជាពំនូត[42] ។

បែបទី ២ ថាៈ **បិណ្ឌបាតិកង្គំ សមាទិយាមិ** (ប្រែថា) ខ្ញុំព្រះករុណា សូមសមាទានអង្គនៃភិក្ខុ អ្នកមានកិរិយាត្រេចទៅដើម្បីបិណ្ឌបាតជាវត្ត ។

បាលីទាំង ២ បែបនេះ តាមតែព្រះយោគីត្រូវការ ទោះបីសមាទានតាមបែបណាក៏បាន ។

ព្រះយោគីដែលបានសមាទាននូវបិណ្ឌបាតិកង្គនេះរួចហើយ នឹងទទួលត្រេកអរនូវភត្ត ដែលជាអតិរេកលាភ ១៤ យ៉ាងមិនបានឡើយ ។

---

[42] សំដៅយកបាយដែលគេរោយរាយចុះក្នុងបាត្ររដាច់រដាច ផ្ទះនេះបន្តិច នោះបន្តិច ។

# ភត្តជាអតិរេកលាភ ១៤ ឥ

១-សង្ឃភត្តៈ ភត្តដែលគេប្រគេនចំពោះសង្ឃមណ្ឌលទាំងអស់ ។

២- ឧទ្ទេសភត្តៈ ភត្តដែលគេឧទ្ទិសយកភិក្ខុ ១ អង្គក្តី អំពីសំណាក់សង្ឃ ហើយប្រគេន ។

៣- និមន្តនភត្តៈ ភត្តដែលគេនិមន្តភិក្ខុយកទៅប្រគេន ។

៤- សលាកភត្តៈ ភត្តដែលគេប្រគេនតាមស្លាក ។

៥- បក្ខិកភត្តៈ ភត្តដែលគេប្រគេនក្នុង ១ បក្ខកំណត់តែមួយថ្ងៃ ។

៦- ឧបោសថិកភត្តៈ ភត្តដែលគេប្រគេនរាល់ ៗ ថ្ងៃឧបោសថ ។

៧- បាដិបទិកភត្តៈ ភត្តដែលគេកំណត់ប្រគេនតែក្នុងថ្ងៃដើមបក្ខ គឺថ្ងៃ ១កើត ឬ ១រោច ។

៨- អាគន្តុកភត្តៈ ភត្តដែលគេប្រគេនដល់ភិក្ខុអាគន្តុក ។

៩- គមិកភត្តៈ ភត្តដែលគេប្រគេនដល់ភិក្ខុ ដែលរៀបដំណើរទៅកាន់ផ្លូវឆ្ងាយ ។

១០- គិលានភត្តៈ ភត្តដែលគេប្រគេនដល់ភិក្ខុដែលមានជំងឺ ។

១១- គិលានុបដ្ឋាកភត្តៈ ភត្តដែលគេប្រគេនដល់ភិក្ខុអ្នកថែជំងឺ ។

១២- វិហារភត្តៈ ភត្តដែលគេប្រគេនចំពោះវត្ត ឬ ចំពោះកុដិ ។

១៣- ធុរភត្ត[43] ភត្តដែលគេតម្កល់ទុក ក្នុងផ្ទះដែលមានធុរៈ ហើយប្រគេន ។

[43] ត្រង់នេះជួនកាលឃើញមានឈ្មោះថាធុរភត្តំ ឬនិច្ចភត្ត ភត្តដែលគេប្រគេនជានិច្ច ។

**១៤- វារកភត្ត:** ភត្តដែលគេដាក់វេនគ្នាប្រគេន ។

ភត្តទាំង ១៤ យ៉ាងនេះ មិនត្រូវឲ្យភិក្ខុ អ្នកសមាទាននូវបិណ្ឌបាតិកង្គនេះទទួលឡើយ តែបើទាយកអ្នកផ្សេងគេមិននិមន្តថា "សូមលោកម្ចាស់ទទួលនូវ **សង្ឃភត្ត**" ដូច្នេះជាដើម គេនិយាយដោយបរិយាយថា សូមព្រះសង្ឃទទួលនូវចង្ហាន់ក្នុងផ្ទះនៃយើងខ្ញុំទាំងឡាយ លោកម្ចាស់ក៏ដែរ សូមទទួលនូវចង្ហាន់ដូច្នេះវិញ ភិក្ខុនោះគួរនឹងទទួលបាន ពុំនោះស្លាកដែលប្រកបដោយភេសជ្ជៈជាដើម មិនមានអាមិសដែលជាយាវកាលិកកើតឡើងអំពីសំណាក់សង្ឃក្តី ភត្តដែលទាយកគេចំអិនក្នុងវត្តក្តី ក៏គួរភិក្ខុទទួលបាន ។

## ប្រភេទនៃបិណ្ឌបាតភិក្ខុ

បិណ្ឌបាតិកភិក្ខុនេះ ក៏មានចែកចេញជា ឧក្រិដ្ឋ ថ្នាក់ជាន់ខ្ពស់ មជ្ឈិមថ្នាក់កណ្តាល មុទុថ្នាក់អន់ដូចគ្នា ។

**សេចក្តីថា:** ភិក្ខុជាន់ខ្ពស់ទទួលចង្ហាន់ ដែលគេនាំមកអំពីខាងមុខ អំពីខាងក្រោយបាន ឈរនៅទៀបទ្វារផ្ទះនៃបុគ្គលដទៃ ហើយឲ្យបាត្រទៅទាយកគេនាំយកទៅដាក់ចង្ហាន់ ដល់ត្រឡប់មកវិញ ទើបគេនាំមកប្រគេន ក៏ទទួលបាន តែបើអង្គុយចុះហើយ នឹងទទួលមិនបានឡើយ ។

ភិក្ខុថ្នាក់កណ្តាល ទុកណាជាអង្គុយចុះហើយ ក៏គង់ទទួលបាន ឲ្យតែនៅក្នុងថ្ងៃនេះ តែបើទទួលនិមន្តទុកដល់ថ្ងៃស្អែកទៀតពុំបានឡើយ ។

ឯភិក្ខុថ្នាក់អន់ ទោះបីទទួលនិមន្ត ទុកដល់ទៅថ្ងៃស្អែក ឬខានស្អែកទៀតក៏បាន ។

បិណ្ឌបាតិកភិក្ខុទាំង ៣ ថ្នាក់នេះ មានសេចក្តីប្លែកគ្នាដូច្នេះគឺ ភិក្ខុថ្នាក់កណ្តាល នឹងភិក្ខុថ្នាក់អន់ មិនបាននៅជាសុខ តាមអំពើចិត្តរបស់ខ្លួនឡើយ ព្រោះនៅជាប់ជំពាក់ដោយបុគ្គលដទៃ ឯភិក្ខុថ្នាក់ជាន់ខ្ពស់ ទើបនៅសុខតាមអំពើចិត្តខ្លួនបាន ព្រោះមិនមានជាប់ជំពាក់ដោយបុគ្គលណាមួយ ។

## ធុតង្គបែកក្នុងបិណ្ឌបាតកង្គ

ធុតង្គរបស់ភិក្ខុទាំង ៣ ថ្នាក់នេះ បែកធ្លាយក្នុងខណៈ ដែលទទួលនូវភត្តជាអតិរេកលាភទាំង ១៤ យ៉ាងមានសង្ឃភត្តជាដើមដូចគ្នា ។

## អានិសង្សក្នុងបិណ្ឌបាតកង្គ

បិណ្ឌបាតិកង្គនេះ កាលដែលភិក្ខុសមាទានហើយ រក្សាមិនឲ្យបែកធ្លាយមានអានិសង្ស ១៥ យ៉ាងគឺ:

១- **និស្សយានុរូបប្បដិបត្តិសព្ភាវោ:** សភាពជាអ្នកមានសេចក្តីប្រតិបត្តិ ដ៏សមគួរដល់និស្ស័យ[44] ។

២- **ទុតិយេ អរិយវំសេ បតិដ្ឋានំ:** កិរិយាតម្កល់នៅក្នុងអរិយវង្ស ទី ២ ។

---

[44] សំដៅយកនិស្ស័យដែលឧបសម្បទាចារ្យ ប្រៀនប្រដៅក្នុងឧបសម្បទមណ្ឌលថា "បិណ្ឌិយាលោបភោជនំ និស្សាយ បព្វជ្ជា" ដូច្នេះជាដើម ។

៣- **អបរាយត្តវុត្តិតា:** ភាពជាអ្នកមិនមានកិរិយាប្រព្រឹត្តិជាប់ដោយបុគ្គលដទៃ ។

៤- **ភគវតា សំវណ្ណិតបច្ចយតា:** ភាពជាអ្នកមានបច្ច័យដែលព្រះដ៏មានព្រះភាគទ្រង់សរសើរ[45] ។

៥- **កោសជ្ជនិម្មទ្ទនតា:** ភាពនៃកិរិយាញុំាំញីនូវសេចក្តីខ្ជិលច្រអូស ។

៦- **បរិសុទ្ធាជីវតា:** ភាពជាអ្នកមានព្យាយាមជាគ្រឿងចិញ្ចឹមជីវិតដ៏ស្អាត ។

៧- **សេខិយបដិបត្តិបូរណំ:** កិរិយាបំពេញនូវសេចក្តីប្រតិបត្តិ ក្នុងសេក្ខិយវត្ត ។

៨- **អបរបោសិតា:** ភាពជាអ្នកមិនចិញ្ចឹមនូវបុគ្គលដទៃ ព្រោះដឹងប្រមាណក្នុងកិរិយាទទួល[46] ។

៩- **បរានុគ្គហកិរិយា:** កិរិយាធ្វើនូវសេចក្តីអនុគ្រោះដល់បុគ្គលដទៃព្រោះទទួលនូវបិណ្ឌបាតបន្តិចៗ ក្នុងត្រកូលនោះ ។

១០- **មានប្បហានំ:** កិរិយាលះបង់នូវមានៈ គឺមិនបានរឹងត្អឹងព្រោះមិនមានអាងភោជនដទៃទៀត ។

[45] ព្រះមានព្រះភាគទ្រង់សរសើរថា ជាបច្ច័យតិចផង បានងាយផង ឥតទោសផង ។

[46] មិនទទួលបិណ្ឌបាតឲ្យហួសប្រមាណ ដើម្បីនឹងចិញ្ចឹមអ្នកដទៃជាដើម ។

១១- វសេតណ្ហាយ និវារណំ: កិរិយាឃាត់នូវសេចក្ដីចំណង់ក្នុងរសរបស់ភោជនដទៃទៀត ។

១២- គណភោជនបរម្បរភោជនចារិត្តសិក្ខាបទេហិ អជាបត្តិតា: ភាពជាអ្នកមិនមានអាបត្តិដោយ គណភោជនសិក្ខាបទ បរម្បរភោជនសិក្ខាបទ និង ចារិត្តសិក្ខាបទ ព្រោះមិនមានទទួលនិមន្ត ។

១៣- អប្បិច្ឆតាទីនំ អនុលោមវុត្តិតា: ភាពជាអ្នកមានកិរិយាប្រព្រឹត្តដ៏សមគួរដល់អប្បិច្ឆតាគុណជាដើម ។

១៤- សម្មាបដិបត្តិព្រូហនំ: កិរិយាបង្កើតនូវសម្មាបដិបត្តិ ។

១៥- បច្ឆិមាជនតានុកម្បនំ: កិរិយាអនុគ្រោះដល់ប្រជុំជនជំនាន់ក្រោយ ។

## គាថាទីបំផុតក្នុងបិណ្ឌបាតកង្គ

បិណ្ឌាយាលោបសន្តុដ្ឋោ អបរាយត្តជីវកោ
បហីនាហារលោលុប្បោ ហោតិ ចាតុទ្ទិសោ យតិ
វិនោទយតិ កោសជ្ជំ អាជីវស្ស វិសុជ្ឈតិ
តស្មា ហិ នាតិមញ្ញេយ្យ ភិក្ខាចារំ សុមេធសោ ។

សេចក្ដីថា: ព្រះយោគី ដែលមានសេចក្ដីត្រេកអរស្មើៗ ក្នុងដុំបាយដែលគេធ្វើឲ្យពំនូតៗ មានកិរិយាចិញ្ចឹមជីវិត មិនជាប់ដោយបុគ្គលដទៃ មានសេចក្ដី

ល្មោភក្នុងអាហារលះបង់បានហើយ អាចប្រព្រឹត្តទៅក្នុងទិសទាំង ៤ បាន មិនមានទទាក់ទទាម លោកអាចនឹងបន្ទោបង់នូវសេចក្តីខ្ជិលច្រអូសបាន អាជីវៈរបស់លោកសោតក៏ស្អាតបរិសុទ្ធ ព្រោះហេតុនោះ លោកអ្នកមានប្រាជ្ញាល្អមិនគប្បីមើលងាយនូវដំណើរដែលត្រេចទៅដើម្បីភិក្ខានោះឡើយ ។

## បិណ្ឌបាតិកង្គ ចប់

------------------------------------

## សបទានចារិកង្គ
## វិធីសមាទានក្នុងសបទានចារិកង្គ

ក្នុងសបទានចារិកង្គនេះ ក៏មានបាលីសម្រាប់សមាទានជាពីរបែបដូចគ្នា

បែបទី ១ ថា: **លោលុប្បចារំ បដិក្ខិបាមិ** (ប្រែថា) ខ្ញុំព្រះករុណាសូមឃាត់នូវកិរិយាត្រេចទៅដើម្បីបិណ្ឌបាតតាមភាពដែលល្មោភ[47] ។

បែបទី ២ ថា: **សបទានចារិកង្គំ សមាទិយាមិ** (ប្រែថា) ខ្ញុំព្រះករុណាសូមសមាទាននូវអង្គនៃភិក្ខុអ្នកមានកិរិយាត្រេចទៅ ដើម្បីបិណ្ឌបាតរៀងតាមលំដាប់នៃផ្ទះជាប្រក្រតី ។ បាលីទាំង ២ បែបនេះ តាមតែព្រះយោគីត្រូវការ ទោះបីសមាទានបាលីបែបណាក៏បាន ។

---

[47] ត្រេចទៅដើម្បីបិណ្ឌបាតតាមទំនើង ។

ក៏សបទានចារិកភិក្ខុនេះ វេលាដែលចូលទៅដល់ទ្វារស្រុក ត្រូវឈរកំណត់មើល ក្រែងជួនមានអន្តរាយ[48] ប្រសិនបើជាឃើញមានអន្តរាយណាមួយ ហើយវិលងទៅកាន់ភូមិស្រុកដទៃទៀតក៏បាន ។ ពុំនោះបើផ្ទះណា ច្រកត្រង់ណា ស្រុកត្រង់ណា ដែលចំណាំតែមិនបានអ្វីបន្តិចបន្តួចសោះ នោះត្រូវសម្គាល់ថា មិនមែនជាស្រុក ហើយគប្បីហួសទៅកាន់ទីដទៃទៀតចុះ តែបើធ្លាប់បានអ្វីបន្តិចបន្តួចត្រង់ទីណា នឹងវិលងហួសទីនោះពុំបានឡើយ ហើយត្រូវឆាប់ចូលទៅកាន់ស្រុកអំពីព្រឹកបន្តិច ការពារក្រែងត្រូវលះបង់នូវទីដែលមិនសប្បាយដោយមានអន្តរាយជាដើម ហើយបង្ហួសទៅកាន់ទីដទៃទៀត កុំឲ្យហួសពេល ។ បើមានមនុស្សគេធ្វើទានក្នុងវត្ត ឬ គេជួបប្រទះកណ្ដាលផ្លូវ ហើយគេយកបាត្រទៅដាក់ចង្ហាន់មកប្រគេនក៏គួរទទួលបាន ។

ភិក្ខុនេះកាលកំពុងដើរទៅតាមផ្លូវ បើជួបប្រទះស្រុកក្នុងវេលាភិក្ខាចារ មិនត្រូវវិលងបង្ហួសឡើយ ទោះបីមិនបានភិក្ខាសោះក្ដី បានបន្តិចបន្តួចក្ដី ក៏ត្រូវតែត្រេចទៅតាមលំដាប់នៃស្រុក ។

## ប្រភេទនៃសបទានចារិកភិក្ខុ

សបទានចារិកភិក្ខុនេះ ក៏មានចែកចេញជា ៣ ថ្នាក់ដូចគ្នា

**សេចក្ដថា:** ភិក្ខុថ្នាក់ឧក្រិដ្ឋ និងទទួលនូវចង្ហាន់ ដែលគេនាំមកអំពីខាងមុខក្ដី អំពីខាងក្រោយក្ដីពុំបាន ពុំនោះដល់ពេលត្រឡប់មកវិញ ហើយទាយក

---

[48] មានឆ្កែកាចជាដើម ។

គេយកចង្ហាន់ តាមមកប្រគេនក្តី ក៏ទទួលពុំបានដូចគ្នា តែបើឈរនៅទៀបទ្វារផ្ទះ ហើយទាយកគេនាំយកបាត្រ ទៅដាក់ចង្ហាន់មកប្រគេនខ្លួន ចាំតែទទួលបាត្រនោះវិញបាន ។

ភិក្ខុថ្នាក់មធ្យម ទទួលចង្ហាន់បែបនេះបានទាំងអស់កុំតែអង្គុយរង់ចាំភិក្ខា ។ ឯថ្នាក់មុទុ ទោះបីអង្គុយរង់ចាំដូច្នោះក៏បាន ឲ្យតែនៅក្នុងថ្ងៃនោះ ។

## ធុតង្គបែកក្នុងសបទានចារិកង្គ

សបទានចារិកង្គធុតង្គ ដែលបែកធ្លាយនោះ គឺក្នុងខណៈដែលមានគំនិតកើតឡើង ថានឹងត្រេចទៅដើម្បីនឹងបិណ្ឌបាត តាមភាពដែលល្មោភដូចគ្នាទាំង ៣ ថ្នាក់ ។

## អានិសង្សក្នុងសបទានចារិកង្គ
## មានអានិសង្ស ៨ យ៉ាងគឺ

១- **កុលេសុ និច្ចនវកតា:** ភាពជាបុគ្គលថ្មោងអស់កាលជានិច្ចក្នុងត្រកូលទាំងឡាយ ។

២- **ចន្ទូបមតា:** ភាពដូចជាបុគ្គល ប្រៀបដូចព្រះចន្ទព្រោះមិនមានជាប់ជំពាក់នៅក្នុងត្រកូលទាំងពួង ។

៣- **កុលមច្ឆេរប្បហានំ:** កិរិយាលះបង់នូវសេចក្តីកំណាញ់ក្នុងត្រកូល ។

៤- **សមានុកម្បិតា:** ភាពជាអ្នកមានសេចក្តីអនុគ្រោះស្មើគ្រប់ត្រកូលទាំងអស់ ។

៥- កុលុបកាទីនវភាវោ: មិនមានទោសក្នុងកិរិយាចូលទៅកាន់ត្រកូល

៦- អវ្ហានានភិនន្ទនា: កិរិយាមិនទទួលត្រេកអរនូវពាក្យដែលគេហៅរកដោយការនិមន្ត ។

៧- អភិហារេ អនត្ថិកតា: ភាពជាអ្នកមិនមានសេចក្ដីត្រូវការដោយភិក្ខា ដែលគេនាំមកឲ្យ ។

៨- អប្បិច្ឆតាទីនំ អនុលោមវុត្តិតា: ភាពជាអ្នកមានកិរិយាប្រព្រឹត្តិដ៏សមគួរដល់អប្បិច្ឆតាគុណជាដើម ។

ទាំង ៨ នេះ ជាអានិសង្សក្នុងសបទានចារិកង្គ ដែលភិក្ខុបានរក្សាទុកដោយល្អ មិនបានឲ្យបែកធ្លាយទៅវិញ ។

ចន្ទូបមោ និច្ចនវោ កុលេសុ
អមច្ឆរី សព្វសមានុកម្បោ
កុលុបកាទីនវវិប្បមុត្តោ
ហោតីធ ភិក្ខុ សបទានចារី
លោលុប្បចារំ បជហាយ តស្មា
ឱក្ខិត្តចក្ខុ យុគមត្តទស្សី
អាកង្ខមានោ ភុវិ សេរិចារំ
ចរេយ្យ ធីរោ សបទានចារំ ។

សេចក្ដីថា: សបទានចារិកភិក្ខុក្នុងសាសនានេះ ជាបុគ្គលប្រៀបដូចជាព្រះចន្ទ្រ ជាបុគ្គលថ្មោងជានិច្ចក្នុងត្រកូលទាំងឡាយ ជាអ្នកមិនកំណាញ់ត្រកូល មានសេចក្ដីអនុគ្រោះស្មើគ្រប់ត្រកូលទាំងអស់ ជាបុគ្គលផុតស្រឡះចាក

ទោសដែលកើតអំពីកិរិយាចូលទៅកាន់ត្រកូល ព្រោះហេតុនោះ អ្នកប្រាជ្ញដែលមានប្រាជ្ញា មានចក្ខុសម្លឹងចុះក្រោម ក្រឡេកមើលតែត្រឹមមួយជួរនឹម ហើយជាអ្នក កាលលះបង់ដាច់ស្រឡះនូវការប្រព្រឹត្តិល្មោភ ហើយប្រាថ្នានូវការប្រព្រឹត្តិដោយសេរី គប្បីប្រព្រឹត្តនូវសបទានចារិកង្គនេះចុះ ។

## សបទានចារិកង្គ ចប់

----------------------------------

# ឯកាសនិកង្គ

## វិធីសមាទានក្នុងឯកាសនិកង្គ

ក្នុងការសនិកង្គនេះ ក៏មានបាលីសមាទានជា ២ បែប ដូចគ្នា ។

បែបទី ១ ថាៈ **នានាសនភោជនំ បដិក្ខិបាមិ** ប្រែថា ខ្ញុំព្រះករុណាសូមឃាត់នូវកិរិយាបរិភោគភោជនក្នុងអាសនៈផ្សេងៗ ។

បែបទី ២ ថាៈ **ឯកាសនិកង្គំ សមាទិយាមិ** ប្រែថា ខ្ញុំព្រះករុណាសូមសមាទាននូវអង្គ នៃភិក្ខុអ្នកមានកិរិយាបរិភោគ នូវភោជនតែក្នុងអាសនៈមួយជាប្រក្រតី ។

បាលីទាំង ២ បែបនេះ តាមតែព្រះយោគីត្រូវការ ទោះសមាទានតាមបាលីបែបណាក៏បាន ។

ក៏ឯកាសនិកភិក្ខុនុ៎ះ កាលបើអង្គុយក្នុងអាសនៈសាលា មិនត្រូវអង្គុយលើថេរាសនៈឡើយ ត្រូវកំណត់អាសនដ៏សមគួរដល់ខ្លួនជាមុនសិន សន្សឹមអង្គុយ បើកំពុងឆាន់មិនទាន់រួច ហើយអាចារ្យ ឬឧបជ្ឈាយ៍និមន្តមកដល់ ក៏គួរនឹងក្រោកទៅធ្វើវត្តបាន តែមិនត្រូវត្រឡប់មកឆាន់ទៀតឡើយ ។

## ប្រភេទនៃឯកាសនិកភិក្ខុ

សេចក្ដីថា: ភិក្ខុថ្នាក់ឧក្រិដ្ឋ តែលូកដៃចូលទៅក្នុងភោជនណាហើយ ទោះបីភោជននោះតិចក្ដី ច្រើនក្ដី ក៏ត្រូវតែឆាន់តែប៉ុណ្ណោះ នឹងទទួលភោជនដទៃទៀតពុំបានឡើយ តែបើមនុស្សទាំងឡាយ គេគិតឃើញថា ភិក្ខុនោះមិនបានឆាន់ចង្ហាន់សោះ ឬឆាន់តែបន្តិចបន្តួច ហើយគេនាំយកសប្បិ ជាដើមមកប្រគេន វត្ថុទាំងនោះ បើភិក្ខុទទួលដើម្បីប្រើប្រាស់ជាភេសជ្ជៈបាន បើនឹងទទួលធ្វើជាអាហារពុំបានឡើយ ។

ភិក្ខុថ្នាក់មធ្យម បើភត្តក្នុងបាត្រមិនទាន់អស់ដរាបណា ក៏អាចនឹងទទួលនូវភោជនដទៃបានដរាបនោះ ។

ភិក្ខុនោះឈ្មោះថា **ភោជនបរិយន្តិកា** មានទីបំផុតត្រឹមភោជន ។

ឯភិក្ខុថ្នាក់មុទុ បើមិនទាន់ក្រោកចាកអាសនៈដរាបណា ក៏អាចដើម្បីឆាន់នូវភោជនដទៃបានដរាបនោះ ។

ភិក្ខុនេះនឹងហៅ **ឧទកបរិយន្តិកា** មានទីបំផុតត្រឹមទឹកដូច្នេះក៏បាន ព្រោះថា បើមិនទាន់ទទួលទឹកសម្រាប់លាងបាត្រដរាបណា នៅឆាន់បានដរាបនោះឬនឹងហៅថា **អាសនបរិយន្តិកា** មានទីបំផុតត្រឹមអាសនៈដូច្នេះក៏បាន ព្រោះថាបើមិនទាន់ក្រោកចាកអាសនៈដរាបណា នៅឆាន់បានដរាបនោះ ។

# ធុតង្គបែកក្នុងឯកាសនិកង្គ

ធុតង្គរបស់ភិក្ខុទាំង ៣ ថ្នាក់នេះ កាលដែលបែកធ្លាយក្នុងខណៈដែលភិក្ខុទាំងនុ៎ះ បរិភោគនូវភោជនក្នុងសំណាក់ផ្សេងៗ ។

# អានិសង្សក្នុងឯកាសនិកង្គ

## មានអានិសង្ស ៨ យ៉ាងគឺ

១- **អប្បាពាធតា:** ភាពជាអ្នកមានអាពាធតិច ។

២- **អប្បាតង្កតា:** ភាពជាអ្នករស់នៅមិនលំបាក គឺមិនមានសេចក្ដីទុក្ខក្នុងសិរីរៈ។

៣- **លហុដ្ឋានំ:** កិរិយាក្រោកឡើងរហ័ស ។

៤- **ពលំ:** មានកម្លាំងក្នុងសរីរៈ ។

៥- **ផាសុវិហារោ:** កិរិយានៅជាសុខសប្បាយ ។

៦- **អនតិរិត្តបច្ចយា អនាបត្តិ:** មិនត្រូវអាបត្តិ ព្រោះបច្ច័យនៃកិរិយាបរិភោគនូវអនតិរិត្តភោជន[49] ។

៧- **រសតណ្ហាវិនោទនំ:** កិរិយាបង្អន់នូវសេចក្ដីចំណង់ក្នុងរស ។

៨- **អប្បិច្ឆតាទីនំ អនុលោមវុត្តិតា:** ភាពជាអ្នកមានកិរិយាប្រព្រឹត្តិដ៏សមគួរដល់អប្បិច្ឆតាគុណជាដើម ។

---

[49] ភោជនដែលភិក្ខុហាមភោជនរួចហើយ ដល់ក្រោកអាសនៈទើបបានមកជាខាងក្រោយ ហើយមិនបានធ្វើវិន័យកម្មឲ្យគួរ (មើលក្នុងបឋមបវារណាសិក្ខាបទ) ។

ទាំង ៨ នេះ ជាអានិសង្សក្នុងឯកាសនិកង្គ ដែលភិក្ខុបានរក្សាដោយល្អ មិនបានឲ្យបែកធ្លាយ ។

## គាថាជាទីបំផុតក្នុងឯកាសនិកង្គ

ឯកាសនភោជនេ រតំ
ន យតឹ ភោជនប្បច្ចយា រុជា
វិសហន្តិ រសេ អលោលុប្បោ
បរិហាបេតិ ន កម្មមត្តនោ
ឥតិ ផាសុវិហារការណេ
សុចិសល្លេខរតូបសេវិតេ
ជនយេថ វិសុទ្ធមានសោ
រតិមេកាសនភោជនេ យតិ ។

សេចក្តីថា: រោគទាំងឡាយ ដែលមានកិរិយាបរិភោគនូវភោជនជាបច្ច័យឲ្យកើត រមែងមិនបៀតបៀននូវព្រះយោគី អ្នកត្រេកអរក្នុងកិរិយាបរិភោគនូវភោជនតែក្នុងអាសនៈ ១ នោះឡើយ សេចក្តីមិនល្មោភក្នុងរសរមែងមិនញុាំងអំពើព្យាយាមរបស់លោកឲ្យសាបសូន្យ ព្រោះហេតុនោះ ព្រះយោគី អ្នកមានចិត្តដ៏បរិសុទ្ធ គប្បីញុាំងសេចក្តីត្រេកអរឲ្យកើតក្នុងឯកាសនិកង្គដែលជា ហេតុនៃកិរិយានៅជាសុខសប្បាយ ដែលភិក្ខុត្រេកអរក្នុងសល្លេខគុណដ៏ស្អាត ធ្លាប់ចូលទៅជិតសេពហើយ ។

## ឯកាសនិកង្គ ចប់

-------------------------------

# បត្តបិណ្ឌិកង្គ

## វិធីសមាទានក្នុងបត្តបិណ្ឌិកង្គ

ក្នុងបត្តបិណ្ឌិកង្គនេះ ក៏មានបាលីសម្រាប់សមាទាន ២ បែបដូចគ្នា ។

បែបទី ១ ថា: **ទុតិយភាជនំ បដិក្ខិបាមិ** (ប្រែថា) ខ្ញុំព្រះករុណាសូមឃាត់នូវភាជន៍ជាគម្រប់ពីរ ។

បែបទី ១ ថា: **បត្តបិណ្ឌិកង្គំ សមាទិយាមិ** (ប្រែថា) ខ្ញុំព្រះករុណាសូមសមាទាននូវអង្គនៃភិក្ខុអ្នកមានកិរិយាបរិភោគ នូវភោជនតែក្នុងបាត្រ ១ [50] ជាប្រក្រតី ។

បាលីទាំង ២ បែបនេះ ប្រើបានដូចគ្នា តាមតែព្រះយោគីត្រូវការ ទោះបីសមាទានតាមបែបណាក៏បាន ។

ក៏បត្តបិណ្ឌិកភិក្ខុ កាលដែលហុតនូវបបរ ត្រូវដាក់បបរក្នុងភាជន៍ បើបានម្ហូបគ្រៀមមានប្រហុក ឬផ្អកជាដើម ត្រូវឆាន់ម្ហូបគ្រៀមមុនក៏បាន ហុតបបរមុនក៏បាន បើដាក់ម្ហូបគ្រៀមក្នុងបបរក្រែងបដិកូលបែរទៅជាក្អួតចង្អោរវិញ តែប្រសិនបើចេះធ្វើមិនឲ្យបដិកូលដូច្នោះក៏គួរឆាន់បាន ។

---

[50] ពាក្យថា "បាត្រ" ក្នុងទីនេះ មិនចំពោះតែបាត្រមែនៗ តែម្យ៉ាងទេ ទោះបីភាជន៍ដទៃក៏ហៅថា បាត្របានក្នុងទីនេះ ។

បើដូចជាទឹកឃ្មុំ និងស្ករក្រាមជាដើម ដែលជារបស់មិនបដិកូលនោះ ក៏ត្រូវតែដាក់ចុះ ទៅជាមួយនឹងបបរ ហើយសន្សឹមឆាន់ តែវត្ថុទាំងនេះ ត្រូវភិក្ខុទទួលឲ្យគួរដល់ប្រមាណ ។ ក្នុងវេលាដែលឆាន់បាយ បើមានអន្លក់ និងមើមឈើស្រស់ ត្រូវកាន់ឆាន់នឹងដៃ បើកាន់ឆាន់មិនកើត ត្រូវដាក់ចុះក្នុងបាត្រឯភាជន៍ជាគំរប់ ២ ដោយហោចសូម្បីតែស្លឹកឈើក៏មិនបានឡើយ ។

## ប្រភេទនៃបត្តបិណ្ឌិកភិក្ខុ

បត្តបិណ្ឌិកភិក្ខុនេះ ក៏មានចែកជា ៣ ថ្នាក់ដូចគ្នា ។

សេចក្តីថា: ភិក្ខុជាឧក្រិដ្ឋ វេលាឆាន់នឹងរើសសំរាមចោលចេញអំពីភោជនមិនបាន រៀរតែវេលាដែលឆាន់អំពៅ ។ កុំថាដល់ម្លោះ សូម្បីតែបំបែកនូវដុំបាយ ដុំត្រី ដុំសាច់ និងនំទាំងឡាយ ហើយឆាន់ក៏មិនបាន ។

ភិក្ខុថ្នាក់មធ្យម បំបែកដោយដៃម្ខាងបាន ។

ភិក្ខុថ្នាក់មុទុ ភោជនឯណាដែលអាចដាក់ចុះក្នុងបាត្របាន ក៏អាចដើម្បីនឹងបំបែកនូវភោជននោះដោយដៃ ឬដោយធ្មេញ ហើយឆាន់បានទាំងអស់ ។

## ធុតង្គបែកក្នុងបត្តបិណ្ឌិកង្គ

ធុតង្គរបស់ភិក្ខុទាំង ៣ ថ្នាក់នេះ កាលដែលបែកធ្លាយទៅក្នុងខណៈដែលភិក្ខុទាំងនោះ ទទួលនូវភោជនជាគម្រប់ពីរ ។

# អានិសង្សក្នុងបត្តបិណ្ឌិកង្គ

មានអានិសង្ស ៦ យ៉ាងគឺ

១- **នានារសតណ្ហាវិនោទនំ:** កិរិយាបង្អន់នូវសេចក្តីចំណង់ក្នុងភោជន ដែលមានរសផ្សេងៗ ។

២- **អត្រិច្ឆតាយ បហានំ:** កិរិយាលះបង់នូវភាពជាអ្នកមានសេចក្តីប្រាថ្នាកន្លងភោជននោះ ។

៣- **អាហារេ បយោជនមត្តទស្សិតា:** ភាពជាអ្នកឃើញនូវប្រមាណនៃប្រយោជន៍ក្នុងអាហារ ។

៤- **ចាលកាទិបរិហរណេខេទាភាវោ:** សេចក្តីលំបាក ព្រោះកិរិយារក្សានូវភាជនៈជាដើម ។

៥- **អវិក្ខិត្តភោជិតា:** ភាពជាអ្នកមិនបរិភោគ មានចិត្តសាវាក្នុងភោជនផ្សេង ៗ ។

៦- **អប្បិច្ឆតាទីនំ អនុលោមវត្តិតា:** ភាពជាអ្នកមានកិរិយាប្រព្រឹត្តិដ៏សមគួរដល់អប្បិច្ឆតាគុណជាដើម ។

ទាំង ៦ នេះ ជាអានិសង្សក្នុងបត្តបិណ្ឌិកង្គ ដែលភិក្ខុបានរក្សាដោយល្អមិនបានឲ្យបែកធ្លាយទៅវិញ ។

## គាថាទីបំផុតក្នុងបត្តបិណ្ឌិកង្គ

ឆាតាភាជនវិក្ខេបំ ហិត្វា ឧក្ខិត្តលោចនោ
ខណាន្តោ វិយ មូលានិ រសតណ្ហាយ សុព្វតោ
សរូបំ វិយ សន្តុដ្ឋី ធារយន្តោ សុមានសោ
បរិភុញ្ជេយ្យ អាហារំ កោ អញ្ញោ បត្តបិណ្ឌិកោ ។

សេចក្តីថា: ព្រះយោគីអ្នកលះបង់នូវសេចក្តីសាវា ក្នុងភោជនផ្សេងៗ មានចក្ខុសម្លឹងចុះក្រោម មានវត្តដ៏ល្អ ទុកដូចជាជីករំលើងនូវឫសនៃតណ្ហា លោកជាអ្នកមានចិត្តល្អ ទ្រទ្រង់នូវសេចក្តីសន្តោស ហាក់ដូចជាទ្រទ្រង់នូវរូបកាយរបស់ខ្លួន (កាលបើដូច្នោះតើ) បត្តបិណ្ឌិកភិក្ខុឯទៀត អង្គណាសោតក៏នឹងគប្បីបរិភោគនូវអាហារ (ក្នុងភោជនផ្សេងបាន) ។

## បត្តបិណ្ឌិកង្គ ចប់

--------------------------------

## ខលុបច្ឆាភត្តិកង្គ

## វិធីសមាទានក្នុងខលុបច្ឆាភត្តិកង្គ

ក្នុងខលុបច្ឆាភត្តិកង្គ ក៏មានបាលីសម្រាប់សមាទាន ២ បែប ដូចគ្នា ។

បែបទី ១ **អតិរិត្តភោជនំ បដិក្ខិបាមិ** (ប្រែថា) ខ្ញុំព្រះករុណា សូមឃាត់នូវកិរិយាបរិភោគនូវអតិរិត្តភោជន[51] ។

---

[51] កាលបើភិក្ខុកំពុងឆាន់ហើយ មានទាយកគេយកភោជនចូលមកប្រគេនក្នុងហត្ថបាស ហើយប្រកែកមិនទទួលហៅថា ហាមភោជន ដល់ក្រោកចាកទីអង្គុយទៅ ។

បែបទី ២ ថា: **ខលុបច្ឆាភត្តិកង្គំ សមាទិយាមិ** (ប្រែថា)

ខ្ញុំព្រះករុណា សូមសមាទាននូវអង្គនៃភិក្ខុ អ្នកមានកិរិយាមិនបរិភោគនូវភត្ត ដែលខ្លួនហាមភោជនរួចហើយ ទើបបានមកក្នុងកាលខាងក្រោយជាប្រក្រតី ។

ក៏ខលុបច្ឆាភត្តិកភិក្ខុនុ៎ះ កាលបើហាមភោជនរួចហើយ មិនត្រូវឲ្យគេធ្វើភោជននោះឲ្យជាកប្បិយៈ ហើយបរិភោគទៀតឡើយ ។ ធុតង្គនេះមានសេចក្តីប្រហែលគ្នានឹងបឋមបវារណាសិក្ខាបទ តែធុតង្គនេះវិសេសជាង ។

មានសេចក្តីវិសេសជាដូច្នេះគឺ ក្នុងបឋមបវារណាសិក្ខាបទមានសេចក្តីថា ភិក្ខុដែលហាមភោជនរួចហើយ ដល់ក្រោកចាកទីអង្គុយនោះទៅ បើបានឲ្យគេធ្វើវិនយកម្មនូវភោជនឲ្យគួរឡើង ត្រឡប់ជាឆាន់វិញបាន ឯក្នុងធុតង្គនេះមិនមែនដូច្នេះទេ តែភិក្ខុហាមភោជនរួចហើយ ដល់ក្រោកចាកទីអង្គុយនោះទៅ មិនមានកិច្ចដែលនឹងត្រូវធ្វើវិនយកម្មឲ្យគួរ ហើយត្រឡប់ឆាន់វិញ នោះឯងហើយដែលចាត់ថាជាធុតង្គសមាទានក្នុងទីនោះ ។

---

បើត្រូវការចង់ឆាន់ភោជនដែលហាមនោះដដែលក្តី ភោជនដទៃក្តី ត្រូវឲ្យគេធ្វើវិនយកម្មឲ្យជាកប្បិយសិន ទើបឆាន់បាន បើមិនបានឲ្យគេធ្វើបែបនេះ ហើយឆាន់នឹងត្រូវអាបត្តិបាចិត្តិយតាមបឋមបវារណាសិក្ខាបទ ។ ភោជនដែលឲ្យគេធ្វើវិនយកម្មឲ្យជាកប្បិយ ដើម្បីនឹងឆាន់ទៀតបែបនេះហៅថា អតិរិត្តភោជន (មើលក្នុងសិក្ខាបទនុ៎ះទៀតនឹងឃើញសេចក្តីពិស្តារ) ។

# ប្រភេទនៃខលុបច្ឆាភត្តិកភិក្ខុ

ខលុបច្ឆាភត្តិកភិក្ខុនេះ ក៏មានចែកចេញទៅជា ៣ ថ្នាក់ដូចគ្នា ។

សេចក្តីថា: ដែលហៅថាហាមនូវភោជននោះ មិនដែលមានក្នុងដុំបាយជាដំបូងឡើយ ត្រាតែភិក្ខុកំពុងលេបចូលទៅនូវដុំបាយជាដំបូងនោះ ហើយឃាត់នូវភោជនដទៃទើបបានឈ្មោះថាហាម គឺថាបើភិក្ខុពុំទាន់បានឆាន់សោះទោះឃាត់នូវភោជនដទៃ ក៏មិនបានឈ្មោះថាហាម លុះតែបានឆាន់ខ្លះដោយយ៉ាងហោច សូម្បីតែត្រឹម ១ ដុំ ហើយឃាត់នូវភោជនដទៃ ទើបបានឈ្មោះថាហាម ព្រោះហេតុនោះ ភិក្ខុថ្នាក់ឧក្រិដ្ឋតែហាមភោជនយ៉ាងនេះហើយ កាលបើលេបចូលនូវដុំបាយជាដំបូងនោះហួសទៅហើយ នឹងឆាន់នូវដុំបាយជាគម្រប់ពីរមិនបានឡើយ ។

ភិក្ខុថ្នាក់មធ្យម ភោជនឯណាដែលខ្លួនកំពុងឆាន់ ហើយហាមនូវភោជនដទៃ ក៏អាចនឹងឆាន់នូវភោជនដែលខ្លួនកំពុងឆាន់នោះត្រាតែអស់បាន តែនឹងឆាន់ភោជនដទៃទៀតមិនបាន ។

ឯភិក្ខុថ្នាក់មុទុ បើមិនទាន់ក្រោកចាកអាសនៈដរាបណា ក៏នៅឆាន់បានដរាបនោះ ។

# ធុតង្គបែកធ្លាយក្នុងខលុបច្ឆាភត្តិកង្គ

ធុតង្គរបស់ភិក្ខុទាំង ៣ ថ្នាក់នេះ កាលបែកធ្លាយនោះ នឹងបែកធ្លាយក្នុងខណៈ ដែលខ្លួនហាមនូវភោជនរួចហើយ ដល់ក្រោកចាកទីអង្គុយនោះទៅហើយឲ្យគេធ្វើវិនយកម្ម[52] នូវភោជនជាកប្បិយហើយឆាន់ទៀតដូចគ្នា ។

---

[52] ត្រង់កិច្ចធ្វើវិនយកម្មនោះ ដូច្នេះគឺ ឲ្យភិក្ខុដទៃប្រាប់ថា "អលមេតំ សព្វំ" ភោជនទាំងអស់ហ្នឹងគួរហើយ ។

# អានិសង្សក្នុងខលុបច្ឆាភត្តិកង្គ
## មានអានិសង្ស ៥ យ៉ាង៖

១- អនតិរិត្តភោជនាបត្តិយា ទូរភាវោៈ ភាពជាអ្នកឆ្ងាយអំពី អាបត្តិដែលត្រូវ ព្រោះកិរិយាបរិភោគនូវ អនតិរិត្តភោជន[53] ។

២- ឱទរិកត្តាភាវោៈ មិនមែននៃភាពជាអ្នកមានអាហារច្រើនពោះ (ចាក់ច្រាស) ។

៣- និរាមិសសន្និធិតាៈ ភាពជាអ្នកមិនសន្សំទុកនូវអាមិស ។

៤- បុន បរិយេសនាយ អភាវោៈ មិនមានកិរិយាស្វែងរកទៀត ។

៥- អប្បិច្ឆតាទីនំ អនុលោមវុត្តិតាៈ ភាពជាអ្នកមានកិរិយាប្រព្រឹត្តិដ៏សមគួរដល់អប្បិច្ឆតាគុណជាដើម ។

ទាំង ៥ នេះ ជាអានិសង្សក្នុងខលុបច្ឆាភត្តិកង្គ ដែលបានរក្សាដោយល្អ មិនបានឲ្យបែកធ្លាយទៅវិញ ។

## គាថាទីបំផុតក្នុងខលុបច្ឆាភត្តិកង្គ

បរិយេសនាយ ខេទំ ន យាតិ ន ករោតិ សន្និធឹ ធីរោ
ឱទរិកត្តំ បជហតិ ខលុបច្ឆាភត្តិកោ យោគី
តស្មា សុគតប្បសត្ថំ សល្លេខគុណាភិវឌ្ឍិសញ្ជននំ
ធោសេ វិធុនិតុកាមោ ភជេយ្យ យោគី ធុតង្គមិទំ ។

[53] ភោជនដែលភិក្ខុហាមរួចហើយ ទើបបានមកជាខាងក្រោយ ហើយមិនឲ្យគេធ្វើវិនយកម្មហៅថា អនតិរិត្តភោជន ។

សេចក្ដីថា: ព្រះយោគីអ្នកមានប្រាជ្ញា ជាអ្នករក្សានូវខលុបច្ឆាភត្តិកង្គ លោកមិនដល់នូវសេចក្ដីលំបាក ព្រោះកិរិយាស្វែងរកបច្ច័យ លោកមិនធ្វើនូវកិរិយាសន្សំទុកនូវអាមិស លោកអាចលះបង់បាន នូវភាពជាអ្នកមានអាហារចើសពោះបាន ព្រោះហេតុនោះ ព្រះយោគីអ្នកមានប្រាថ្នាដើម្បីកម្ចាត់បង់ នូវទោសទាំងឡាយ គប្បីគប់ប្រសពនូវធុតង្គ (**ខលុបច្ឆាភត្តិកង្គ**) ដែលព្រះសុគតទ្រង់សរសើរហើយថា ជាធម្មជាតតែងញ៉ាំងសេចក្ដីចម្រើនដោយគុណទាំងឡាយមានសន្តោសគុណជាដើម ឲ្យកើតព្រមនេះចុះ ។

## ខលុបច្ឆាភត្តិកង្គ ចប់

---

## វិធីសមាទានក្នុងអារញ្ញិកង្គ

ក្នុងអារញ្ញិកង្គនេះ ក៏មានបាលីសម្រាប់សមាទាន ២ បែបដូចគ្នា ។

បែបទី ១ ថា: **គាមន្តសេនាសនំ បដិក្ខិបាមិ** ប្រែថា ខ្ញុំព្រះករុណាសូមឃាត់នូវកិរិយាញ៉ាំងអរុណឲ្យរះឡើងក្នុងសេនាសនៈ ជាចន្លោះនៃស្រុក ។

បែបទី ២ ថា: **អារញ្ញិកំ សមាទិយាមិ** ប្រែថា ខ្ញុំព្រះករុណាសូមសមាទាននូវអង្គនៃភិក្ខុអ្នកមានកិរិយានៅអាស្រ័យក្នុងព្រៃជាប្រក្រតី ។

បាលីទាំង ២ បែបនេះ ប្រើបានដូចគ្នាតាមតែព្រះយោគីត្រូវការ ទោះបីសមាទានតាមបែបណាក៏បាន ។

ក៏អារញ្ញិកភិក្ខុនុ៎ះ កាលបើបានសមាទានយ៉ាងនេះរួចហើយ ត្រូវកុំញ៉ាំងអរុណឲ្យរះឡើង ក្នុងទីសេនាសនៈជាចន្លោះនៃស្រុកឡើយ ត្រូវតែឲ្យរះឡើងក្នុងទីសេនាសនៈ ដែលតាំងនៅក្នុងព្រៃជាធម្មតា ។

## កំណត់សេនាសនៈក្នុងអារញ្ញិកង្គ

ទីសេនាសនៈ ជាចន្លោះនៃស្រុកនោះ លោកកំណត់យកទីសេនាសនៈដែលតាំងនៅក្នុងស្រុក ឬក្នុងទីដែលឧបចាររបស់ស្រុក ។ ដែលហៅថាព្រៃនោះ លោកកំណត់យកទីខាងក្រៅអំពីស្រុក និងឧបចាររបស់ស្រុកនោះចេញទៅ ។

ដែលហៅថាស្រុកនោះ ទោះបីស្រុកឯណានីមួយ មានតែផ្ទះ ១ ក្តី ច្រើនក្តី របង ឬកំពែងព័ទ្ធជុំវិញក្តី គ្មានក្តី មានមនុស្សនៅអាស្រ័យក្តី គ្មានក្តី យ៉ាងហោចត្រឹមតែមានពួកឈ្មួញទៅសំចតនៅជាង ៤ ខែប៉ុណ្ណោះ ក៏លោកកំណត់យកថាជាស្រុកទាំងអស់ បើមានព្រំព័ទ្ធជុំវិញកំណត់ទៅទល់ត្រឹមព្រំនោះ បើគ្មានទេ កំណត់ចម្ងាយអំពីផ្ទះចុងគេផុតចេញ ១ ជះទឹក[54] ឧបចាររបស់ផ្ទះចម្ងាយ ១ លេឌ្ឌុបាត[55] អំពីនោះទៅទៀតជាស្រុក ។

---

[54] ស្រីឈរនៅទៀបទ្វារផ្ទះ ដែលតាំងនៅខាងចុតគេបំផុត ហើយផ្ទះទឹកដោយភាជនទៅធ្លាក់ត្រឹមណា ត្រឹមចន្លោះហៅថា ១ ជះទឹក ។

[55] បុរសមានកម្លាំងជាកណ្តាល ចោលដុំដីអស់ទំហឹងដៃទៅធ្លាក់ត្រឹមណា ត្រង់ចន្លោះនោះហៅថា លេឌ្ឌុបាត ។

ឯឧបចារស្រុកនោះ បើស្រុកមានព្រំព័ទ្ធ[56] ជុំវិញកំណត់ ១ លេឌ្ឌុបាត អំពីព្រំនោះចេញទៅ បើស្រុកដែលគ្មានព្រំព័ទ្ធជុំវិញទេ កំណត់ ១ លេឌ្ឌុបាត ជាគម្រប់ពីរ អំពីលេឌ្ឌុបាតទី ១ ដែលជាដែនរបស់ស្រុកនោះតទៅទៀត ។ បើស្រុកដែលមានព្រំ ២ ជាន់ កំណត់ត្រឹម ១ ជាន់ខាងក្នុងជាស្រុក ។ ខាងក្រៅអំពីស្រុក និងឧបចារៈរបស់ស្រុកនោះចេញទៅហៅថា ព្រៃទាំងអស់ ។

**អារញ្ញិកសេនាសន**នេះ លោកមិនកំណត់តែត្រឹមរំលងដែនរបស់ស្រុក និងឧបចារៈរបស់ស្រុកប៉ុណ្ណោះឡើយ លោកកំណត់ឲ្យទុកឧបចារៈរបស់វិហារថែមទៀត បើវិហារនោះតាំងនៅក្នុងទីបំផុតនៃឧបចារៈរបស់ស្រុកតែម្តង មិនបានឈ្មោះថា **អារញ្ញិកសេនាសន** ព្រោះហេតុនោះ ឧបចារៈរបស់វិហារ លោកឲ្យកំណត់ដូចឧបចារៈរបស់ស្រុកដែរ គឺបើវិហារនោះ មានព្រំជុំវិញ ក្នុងរវាងខាងក្នុងព្រំនោះ ជាដែនរបស់វិហារ ចម្ងាយ ១ លេឌ្ឌុបាត អំពីនោះទៅជាឧបចារៈរបស់វិហារ បើវិហារដែលមិនមានព្រំជុំវិញកំណត់អំពីត្រឹមទីសេនាសនៈ ដែលតាំងនៅខាងចុងគេបំផុត ទោះរោងភត្តក្តី ទីសម្រាប់ប្រជុំក្តី ដើមពោធិព្រឹក្ស ឬចេតិយក្តី ចេញទៅខាងក្រៅចម្ងាយ ១ លេឌ្ឌុបាត ជាដែនរបស់វិហារ ១ លេឌ្ឌុបាតតទៅទៀតជាឧបចារៈរបស់វិហារ ។ ដែលនឹងកំណត់ដែនរបស់វិហារនឹងឧបចារៈរបស់វិហារ បែបនោះមិនត្រូវកំណត់ឲ្យសង្កត់លើដែនរបស់ស្រុក និងឧបចារៈរបស់ស្រុកនោះឡើយ ត្រូវកំណត់ឲ្យផុតអំពីគ្នាចេញទៅ ។ បើពោល

[56] ដែលហៅថាព្រំនោះសំដៅយក របងគោល ឬវត្ថុអ្វីមួយដែលគេតម្កល់ទុកសម្រាប់ខណ្ឌដែនរបស់ស្រុកនីមួយៗ ។

តាមបរិយាយរបស់ព្រះសូត្រ លោកឲ្យវាស់អំពីត្រឹមព្រំរបស់ស្រុកទៅទល់នឹងព្រំរបស់វិហារបានចម្ងាយ ៥០០ ធនុ[57] ។ បើមិនមានព្រំត្រូវវាស់អំពីត្រឹមទីបំផុតនៃលេឌ្ឌុបាតមួយៗ ទាំងពីរខាង ឲ្យបានម្ខាងចម្ងាយ ៥០០ ធនុដូចគ្នា ។ បើស្រុកនោះជិត ឬសម្លេងមនុស្សមកដល់តែរបាំងដោយភ្នំ និងស្ទឹងជាដើម មិនអាចនឹងដើរកាត់តម្រង់ទៅមកបាន លោកឲ្យវាស់តាមផ្លូវដែលទៅមកជាប្រក្រតី តែមិនត្រូវបិទរាំងផ្លូវរបស់ស្រុកដែលជិតៗ ធ្វើឲ្យបត់បែនក្រវិកក្រវ៉ក់ទៅជាឆ្ងាយនោះឡើយ បើធ្វើបែបនេះ លោកទុកថាជាមហាចោរប៉ែកខាងធុតង្គ ។ ភិក្ខុដែលនៅអាស្រ័យក្នុងអារញ្ញិកសេនាសនៈនេះ បើឧបជ្ឈាយ៍ ឬអាចារ្យមានជម្ងឺ ហើយនៅក្នុងព្រៃមិនបានសេចក្តីសប្បាយ ក៏គប្បីនាំទៅកាន់ទីសេនាសនៈដូចពោលហើយនោះវិញ តែបើវេលាដែលអរុណទៀបរះ ហើយអាពាធរបស់ឧបជ្ឈាយ៍ ឬអាចារ្យនោះចេះតែចម្រើនឡើង ត្រូវធ្វើកិច្ចអ្វីក្នុងវិធីថែជម្ងឺនោះតទៅទៀតចុះ មិនត្រូវខ្វល់ខ្វាយតែនឹងជំរះនូវធុតង្គនោះពេកឡើយ

## ប្រភេទនៃអារញ្ញិកភិក្ខុ

អារញ្ញិកភិក្ខុនេះ ក៏មានចែកចេញជា ៣ ថ្នាក់ដូចគ្នា ។

សេចក្តីថា: **ភិក្ខុថ្នាក់ឧក្រិដ្ឋ** ត្រូវតែញ៉ាំងអរុណឲ្យរះឡើងក្នុងព្រៃឲ្យសព្វកាល ។

**ភិក្ខុថ្នាក់មធ្យម** រវាង ៤ ខែ ក្នុងវស្សានរដូវ នៅក្នុងទីសេនាសនៈជាចន្លោះស្រុកបាន ។

**ភិក្ខុថ្នាក់មុទុ** នៅអស់រវាង ៤ ខែ ក្នុងហេមន្តរដូវតទៅទៀតបាន ។

---

[57] ធនុ នេះជាខ្នាតវាស់មួយបែបប្រវែង ២ ម៉ែត្រ ៥០០ ធនុត្រូវជា ១ គីឡូម៉ែត្រសព្វថ្ងៃនេះ

# ធុតង្គបែកក្នុងអារញ្ញិកង្គ

ភិក្ខុទាំង ៣ ថ្នាក់នេះ កាលបើចេញមកស្តាប់ធម៌ក្នុងទីសេនាសនៈជាចន្លោះនៃស្រុក បើកំពុងស្តាប់ហើយ អរុណរះឡើងក្តី ស្តាប់រួចហើយ ដើរទៅដល់ពាក់កណ្តាលផ្លូវទទួលអរុណរះឡើងក្តី ធុតង្គមិនបែកធ្លាយឡើយ ត្រាតែលោកជាធម្មកថិក សម្តែងធម៌ចប់ក្រោកចេញទៅហើយៗ ភិក្ខុទាំងនោះគិតថា "យើងសឹងបន្តិចសិន សន្សឹមទៅ" ដល់កំពុងតែសឹងលក់អរុណរះឡើង ឬភិក្ខុដែលញុំាងឲ្យអរុណឲ្យរះឡើងក្នុងទីសេនាសនៈជាចន្លោះស្រុក តាមទំនើងចិត្តរបស់ខ្លួន ទើបធុតង្គបែកធ្លាយ ។

# អានិសង្សក្នុងអារញ្ញិកង្គ

មានអានិសង្ស ៨ យ៉ាងគឺ

១- **ភព្វោ អលទ្ធំ វា សមាធឹ បដិលទ្ធុំៈ** ជាបុគ្គលគួរដើម្បីបាននូវសមាធិដែលមិនទាន់បាននៅឡើយ ។

២- **លទ្ធំ វា រក្ខិតុំៈ** ជាបុគ្គលគួរដើម្បីរក្សាទុកគង់នូវសមាធិ ដែលបានរួចហើយ ។

៣- **សត្ថាបិស្ស អត្តមនោៈ** ព្រះសាស្តាសោតនឹងពេញព្រះហឫទ័យចំពោះភិក្ខុនោះ[58] ។

[58] ប្រាថ្នាយកជំនាន់ដែលព្រះសម្ពុទ្ធទ្រង់ធរមាននៅឡើយ ។

៤- **អសប្បាយរូចាទយោ ចិត្តំ ន វិក្ខិបន្តិ:** រូបារម្មណ៍ដែលមិនជាទីសប្បាយជាដើម នឹងមិនពង្រាយនូវចិត្តរបស់ភិក្ខុនោះបាន ។

៥- **វិគតសន្តាសោ:** មានសេចក្តីតក់ស្លុតប្រាសចេញ ។

៦- **ជីវិតនិកន្តឹ បជហាតិ:** អាចលះបង់នូវសេចក្តីត្រេកអរក្នុងជីវិតបាន ។

៧- **បវិវេកសុខរសំ អស្សាទេតិ:** បានទទួលដោយនូវរសនៃសេចក្តីសុខក្នុងទីស្ងាត់ ។

៨- **បំសុកូលិកាទិភាវេ:** ភាពជាបុគ្គល ដើម្បីរក្សានូវបំសុកូលិកង្គជាដើមបានដោយងាយ ។

ទាំង៨ នេះ ជាអានិសង្សក្នុងអារញ្ញិកង្គ ដែលភិក្ខុបានរក្សាដោយល្អមិនបានឲ្យបែកធ្លាយ ។

## គាថាទីបំផុតក្នុងអារញ្ញិកង្គ

បវិវិត្តោ អសំសដ្ឋោ បន្តសេនាសនេ រតោ
អារាធយន្តោ នាថស្ស វនវាសេន មានសំ
ឯកោ អរញ្ញេ និវសំ យំ សុខំ លភតេ យតិ
រសំ តស្ស ន វិន្ទន្តិ អបិ ទេវា សឥន្ទកា ។
បំសុកូលញ្ច ឯសោវ ការចំ វិយ ធារយំ
អរញ្ញសង្គាមគតោ អវសេសធុតាយុធោ
សមត្ថោ ន ចិរស្សេវ ជេតុំ មារំ សវាហនំ
តស្មា អរញ្ញវាសម្ហិ រតឹ កយិរាថ បណ្ឌិតោ ។

សេចក្តីថាៈ ព្រះយោគី អ្នកមានចិត្តស្ងប់ស្ងាត់ មិនច្រឡូកច្រឡំដោយពួក ត្រេកអរតែក្នុងទីសេនាសនៈដ៏ស្ងាត់ លោកអាចញ៉ាំងព្រះទ័យនៃព្រះបរមលោកនាថឲ្យទ្រង់អំណរផងបាន ។ មានសេចក្តីសរសើរថា ព្រះយោគីអ្នកនៅអាស្រ័យម្នាក់ឯង រមែងបាននូវសេចក្តីសុខបែបណា អម្បាលតែទេវតាទាំងឡាយ ព្រមទាំងព្រះឥន្ទ ក៏មិនដែលបានសោយនូវរសនៃសេចក្តីសុខបែបនោះឡើយ ។ ព្រះយោគីអង្គនោះឯង កាលបើបានទ្រទ្រង់នូវបំសុកូលិកង្គ ទុកជាគ្រឿងក្រោះថែមទៀត ហើយចូលទៅកាន់ទីសង្គ្រាម ពោលគឺព្រៃ ព្រោះមានធុតង្គធម៌ក៏អាចដើម្បីច្បាំងនូវមារព្រមទាំងពាហនៈ ឲ្យចាញ់បាក់បបទៅបានដោយងាយមិនមែនយឺតយូរឡើយ ព្រោះហេតុនោះបណ្ឌិតគប្បីធ្វើនូវសេចក្តីត្រេកអរក្នុងកិរិយានៅក្នុងព្រៃចុះ ។

# អារញ្ញិកង្គចប់

------------------------------------

# រុក្ខមូលិកង្គ

## វិធីសមាទានក្នុងរុក្ខមូលិកង្គ

ក្នុងរុក្ខមូលិកង្គនេះ ក៏មានបាលីសម្រាប់សមាទាន ២ ដូចគ្នា ។

បែបទី ១ ថាៈ **ឆន្នំ បដិក្ខិបាមិ** ប្រែថា ខ្ញុំព្រះករុណាសូមឃាត់នូវទីលំនៅ ដែលគេប្រក់ដោយដំបូល ។

បែបទី ២ ថា: **រុក្ខមូលិកង្គំ សមាទិយាមិ** ប្រែថាខ្ញុំព្រះករុណាសូមសមាទាននូវអង្គ នៃភិក្ខុអ្នកមានកិរិយានៅអាស្រ័យ ទៀបគល់នៃឈើជាប្រក្រតី ។

បាលីទាំង ២ បែបនេះ អាចប្រើបានដូចគ្នា តាមតែព្រះយោគីត្រូវការទោះបីសមាទានតាមបែបណាក៏បាន ។

រុក្ខមូលិកភិក្ខុនុ៎ះ វេលាដែលសមាទានរួចហើយ ត្រូវប្រកាន់ដើមឈើណាមួយ ដែលតាំងនៅត្រង់ទីបំផុតនៃវិហារកំណត់ធ្វើជាទីលំនៅ តែត្រូវវៀរដើមឈើដែលស្ថិតនៅត្រង់ព្រំដែន ដើមឈើដែលគេធ្លាប់គោរព ដើមឈើដែលមានជ័រ មានផ្លែ មានផ្កាគេប្រើការ ដើមឈើដែលមានប្រចៀវ ឬជ្រឹងនៅអាស្រ័យនោះចេញ ព្រោះដើមឈើទាំងនោះ ប្រកបដោយអន្តរាយ ។

## ប្រភេទនៃរុក្ខមូលិកភិក្ខុ

រុក្ខមូលិកភិក្ខុនេះ ក៏មានចែកចេញជា ៣ ថ្នាក់ដូចគ្នា ។

សេចក្ដីថា: ភិក្ខុថ្នាក់ឧក្រិដ្ឋ បើប្រកាន់ដើមឈើណាមួយតាមពេញចិត្តរួចហើយនឹងប្រើឲ្យគេបោសច្រាសមិនបានឡើយ ត្រូវបោសតែកំញមស្លឹកឈើទុំដែលជ្រុះមកនោះដោយជើងរបស់ខ្លួន ហើយគប្បីនៅចុះ ។

ភិក្ខុថ្នាក់មធ្យម បើប្រើមនុស្សដែលដើរមកដល់ជិតនោះ ឲ្យបោសច្រាសឲ្យបាន ។

ភិក្ខុមុទុ ទោះបីហៅមនុស្សអ្នករក្សាអារាម ឬសាមណេរមកប្រើឲ្យជម្រះធ្វើឲ្យស្មើ ហើយរោយរាយដីខ្សាច់ ធ្វើរបងប្រកបទ្វាររួចហើយសន្សឹមនៅក៏បាន ។

វុក្ខមូលិកភិក្ខុទាំង ៣ ថ្នាក់នេះ បើដល់ថ្ងៃណាដែលមានមនុស្សគេនាំគ្នាចូលមកធ្វើមហាកម្ម[59] មិនត្រូវអង្គុយនៅក្នុងទីនោះឡើយ ត្រូវចេញទៅអង្គុយនៅក្នុងទីឯទៀតបិទបាំងខ្លួន កុំឲ្យគេដឹងថាខ្លួនជាអ្នករក្សានូវរុក្ខមូលិកង្គនោះឡើយ ។

# ធុតង្គបែកក្នុងរុក្ខមូលិកង្គ

ធុតង្គរបស់ភិក្ខុទាំង ៣ ថ្នាក់នេះ កាលដែលបែកធ្លាយ នឹងបែកធ្លាយក្នុងខណៈភិក្ខុទាំងនោះ សម្រេចកិរិយានៅក្នុងទីលំនៅ ដែលគេប្រក់ដោយដំបូលឬក៏បានដឹងប្រាកដ ហើយញ៉ាំងអរុណឱ្យរះឡើង ក្នុងទីដែលគេប្រក់ដោយដំបូលនោះឯង តែបើចូលទៅនៅក្នុងទីបែបនោះ ដើម្បីស្តាប់នូវធម៌ជាដើម ដល់ហើយកិច្ចត្រឡប់មកញ៉ាំងអរុណឲ្យរះឡើង ត្រង់កន្លែងរបស់ខ្លួនវិញបាន ពុំនោះនឹងចូលទៅនៅក្នុងទីសេនាសនៈ ដែលគេប្រក់ដោយដំបូល អស់រវាងវស្សានរដូវ ៤ ខែ ក៏បាន ធុតង្គពុំបានបែកធ្លាយឡើយ ។

[59] ធ្វើបូជា គឺថាគេធ្វើបុណ្យអ្វីនីមួយក្នុងទីនោះ ។

# អានិសង្សក្នុងរុក្ខមូលិកង្គ

## មានអានិសង្ស ៦យ៉ាង៖

១- **និស្សយានុរូបបដិបត្តិសព្ភាវោ:** សភាពជាអ្នកមានសេចក្តីប្រតបត្តិដ៏សមគួរដល់និស្ស័យ ដែលឧបសម្បទាចារ្យប្រៀនប្រដៅក្នុងឧបសម្បទមណ្ឌលថា "បព្វជ្ជា ត្រូវអាស្រ័យនូវរុក្ខមូលសេនាសនៈ" ដូច្នេះជាដើម ។

២- **ភគវតា សំវណ្ណិតបច្ចយតា:** ភាពជាអ្នកមានបច្ច័យដែលព្រះដ៏មានព្រះភាគទ្រង់សរសើរថា "តិចផង រកបានដោយងាយផង ឥតទោសផង"។

៣- **អនិច្ចសញ្ញាសមុដ្ឋាបនតា:** ភាពដែលញុំាងអនិច្ចសញ្ញាឲ្យកើតឡើងបាន ដោយបានឃើញនូវវិការៈរបស់ដើមឈើរឿយៗ ។

៤- **សេនាសនមច្ឆេរកម្មារាមតានំ អភាវោ:** មិនមានសេចក្តីកំណាញ់ក្នុងសេនាសន និងភាពជាអ្នកត្រេកអរក្នុងការងារ ។

៥- **ទេវតាហិ សហវាសិតា:** ភាពជាអ្នកបាននៅរួមជាមួយនឹងទេវតាទាំងឡាយ ។

៦- **អប្បិច្ឆតាទីនំ អនុលោមវុត្តិតា:** ភាពជាអ្នកមានកិរិយាប្រព្រឹត្តិដ៏សមគួរដល់អប្បិច្ឆតាគុណជាដើម ។

ទាំង ៦ យ៉ាងនេះ ជាអានិសង្សក្នុងរុក្ខមូលិកង្គ ដែលភិក្ខុបានរក្សាដោយល្អ មិនបានឲ្យបែកធ្លាយ ។

# គាថាទីបំផុតក្នុងរុក្ខមូលិកង្គ

វណ្ណិតោ ពុទ្ធសេដ្ឋេន    និស្សយោតិ ច ភាសិតោ
និវាសោ  បវីវិត្តស្ស    រុក្ខមូលសមោ កុតោ
អាវាសមច្ឆេរហរេ    ទេវតាបរិចាលិតេ
បវីវិត្តេ វសន្តោ ហិ    រុក្ខមូលម្ហិ  សុព្វតោ
អភិរត្តានិ  នីលានិ    បណ្ឌូនិ បតិតានិ ច
បស្សន្តោ  តរុបណ្ណានិ  និច្ចសញ្ញំ  បនូទតិ
តស្មា ហិ ពុទ្ធទាយជ្ជំ    ភាវនាភិរតាលយំ
វីវិត្តំ  នាតិមញ្ញេយ្យ    រុក្ខមូលំ វិចក្ខណោ ។

សេចក្តីថា: ទីនៅអាស្រ័យរបស់ភិក្ខុអ្នកមានចិត្តស្ងប់ស្ងាត់ ដែលព្រះពុទ្ធឆ្នើមទ្រង់សរសើរ ទ្រង់ត្រាស់ថាជានិស្ស័យរបស់បព្វជិតឲ្យបានស្មើដោយរុក្ខមូលសេនាសនៈនឹងមានមកអំពីណា? ព្រោះថាភិក្ខុកាលនៅអាស្រ័យក្នុងទីស្ងាត់ដែលកំចាត់បង់នូវសេចក្តីកំណាញ់ក្នុងអាវាសបាន រុក្ខទេវតាទាំងឡាយ តែងបីបាច់រក្សាផង (មិនត្រឹមតែប៉ុណ្ណោះ) ភិក្ខុអ្នកមានវត្តល្អនៅទៀបគល់នៃឈើកាលឃើញនូវស្លឹកឈើ ដែលកំពុងលាស់ខៀវខ្ចីខ្លះ ដែលទុំមានពណ៌លឿងខ្លះ ដែលជ្រុះចុះហើយខ្លះ នឹងអាចបន្ទោបង់នូវនិច្ចសញ្ញា[60] បាន ព្រោះហេតុនោះ អ្នកប្រាជដែលមានប្រាជ្ញាមិនគួរមើលងាយនូវទីស្ងាត់ទៀបគល់ឈើ ដែលជាតំណែលរបស់ព្រះពុទ្ធ ជាទីលំនៅរបស់លោកអ្នកត្រេកអរក្នុងភាវនានោះឡើយ។

[60] សេចក្តីសំគាល់ថាទៀងក្នុងសង្ខារទាំងឡាយដែលមិនទៀង ។

# រុក្ខមូលិកង្គចប់

---------------------------------

# អព្ភោកាសិកង្គ

# វិធីសមាទានក្នុងអព្ភោកាសិកង្គ

ក្នុងអព្ភោកាសិកង្គនេះ ក៏មានបាលីសំរាប់សមាទានជា ២ បែបដូចគ្នា ។

បែបទី ១ ថា: **ឆន្នញ្ច រុក្ខមូលញ្ច បដិក្ខិបាមិ** (ប្រែថា) ខ្ញុំករុណាសូមឃាត់នូវទីសេនាសនៈ ដែលគេប្រក់ដោយដំបូលផង នូវទីសេនាសនៈទៀបគល់នៃឈើផង ។

បែបទី ២ ថា: **អព្ភោកាសិកង្គំ សមាទិយាមិ** (ប្រែថា) ខ្ញុំព្រះករុណាសូមសមាទាននូវអង្គនៃភិក្ខុ អ្នកមានកិរិយានៅអាស្រ័យក្នុងទីវាលស្រឡះជាប្រក្រតី ។

បាលីទាំងពីរបែបនេះ ប្រើបានដូចគ្នា តាមតែព្រះយោគីត្រូវការ ទោះបីសមាទានតាមបែបណាក៏បាន ។

ក៏**អព្ភោកាសិកភិក្ខុ**នុ៎ះ បើចូលទៅកាន់រោងឧបោសថ ប្រយោជន៍ដើម្បីនឹងស្តាប់ធម៌ ឬធ្វើឧបោសថកម្មបាន បើចូលដល់ហើយទទួលមានភ្លៀងក៏កុំអាលចេញមក ត្រូវរង់ចាំឲ្យស្វាងភ្លៀងសិន សន្សឹមចេញមកវិញចុះ ពុំនោះបើចូលទៅកាន់រោងឆាន់ រោងភ្លើង ដើម្បីនឹងធ្វើកិច្ចវត្ត ដែលត្រូវធ្វើក្តី ចូលទៅបំរើភត្តដល់ភិក្ខុចាស់ ក្នុងរោងឆាន់ក្តី ចូលទៅបង្រៀនបាលីដល់បុគ្គលដទៃ ឬ

រៀនខ្លួនឯងក្នុងទីប្រក់ទីបាំងក្តី ជញ្ជូនគ្រែ ឬជើងតាំងជាដើម ដែលគេដាក់ខាងក្រៅមិនល្អ ចូលទៅទុកដាក់ខាងក្នុងទីប្រក់ទីបាំងក្តី ក៏សឹងតែបាន ឬបើទុកជាគ្មានកាន់គ្រឿងបរិក្ខាររបស់ភិក្ខុចាស់ ក៏គង់ចូលទៅជ្រកទំរាំរាំងភ្លៀងបានដែរ តែត្រូវដើរចូលទៅតាមដំណើរជាប្រក្រតី កុំតែដើរចូលទៅរលះរលាំងពេក ឬដោយគិតប្រុងនឹងនៅក្នុងសាលានោះ ។

## ប្រភេទនៃអព្ភោកាសិកភិក្ខុ

**អព្ភោកាសិកភិក្ខុ**នេះ ក៏មានចែកចេញជា ៣ ថ្នាក់ ដូចគ្នា ។

សេចក្តីថាៈ ភិក្ខុថ្នាក់ឧក្រិដ្ឋ បើនឹងចូលទៅនៅផ្អែបអាស្រ័យដោយសារដើមឈើ ដោយសារភ្នំ ឬផ្ទះពុំបានឡើយ ត្រូវតែធ្វើខ្ទមជាវិការនៃចីវរនៅក្នុងទីវាលស្រឡះតែម៉្យាង ។

ភិក្ខុថ្នាក់មធ្យម បើគ្រាន់តែនៅផ្អែបអាស្រ័យដោយសារដើមឈើ ដោយសារភ្នំ ឬដោយសារផ្ទះបែបនោះបាន កុំតែចូលទៅនៅខាងក្នុង ។

ភិក្ខុថ្នាក់មុទុ បង្ហាគ្មានបិទបាំងដោយជញ្ជាំង ជំរំធ្វើដោយមែកឈើ បារាំធ្វើដោយសំពត់សាដក ដែលគេត្បាញឲ្យបាយឱ្យក្រាស ខ្ទមដែលអ្នកចាំស្រែជាដើមបោះបង់ចោល បើនឹងទៅជ្រកបាន ។

## ធុតង្គបែកក្នុងអព្ភោកាសិកង្គ

ធុតង្គរបស់ភិក្ខុទាំង ៣ ថ្នាក់នេះ កាលបែកធ្លាយនឹងបែកធ្លាយក្នុងខណៈដែលភិក្ខុទាំងនោះចូលទៅកាន់ទីប្រក់ទីបាំង ឬគល់ឈើ ដើម្បីនឹងនៅ ឬបណ្តោយឲ្យអរុណរះឡើងក្នុងទីនោះដឹងខ្លួន ។

# អានិសង្សក្នុងអព្ភោកាសិកង្គ
## មានអានិសង្ស ៥ យ៉ាង៖

១- អាវាសបលិពោធុបច្ឆេទោ: កិរិយាផ្ដាច់បង់នូវសេចក្ដីកង្វល់ក្នុងអាវាស ។

២- ថីនមិទ្ធប្បនូទនំ: កិរិយាបង្អន់នូវសេចក្ដីច្រអូសកាយ និង ច្រអូសចិត្ត ។

៣- និសង្គតា: ភាពជាអ្នកមិនទទាក់ទទាម ដោយការហួងហែងនូវអាវាស ។

៤- ចាតុទ្ទិសតា: ភាពជាអ្នកត្រេចទៅកាន់ទិសទាំង ៤ បាន ឥតមានទើសទាស់ ដោយមិនព្រួយក្រែងគ្មានទីលំនៅ ។

៥- អប្បិច្ឆតាទីនំ អនុលោមវុត្តិតា: ភាពជាអ្នកមានកិរិយាប្រព្រឹត្តិទៅដ៏សមគួរដល់អប្បិច្ឆតាគុណជាដើម ។

ទាំង ៥ នេះជាអានិសង្សក្នុងអព្ភោកាសិកង្គ ដែលភិក្ខុរក្សាទុកដោយល្អមិនបានឲ្យបែកធ្លាយ ។

## គាថាទីបំផុតក្នុងអព្ភោកាសិកង្គ

អនគារិយភាវស្ស អនុរូបេ អនុល្លភេ
តារាមណិវិតាណម្ហិ ចន្ទទីបប្បភាសិតេ
អព្ភោកាសេ វសំ ភិក្ខុ មិគភូតេន ចេតសា
ថីនមិទ្ធំ វិនោទេត្វា ភាវនារាមតំ សិតោ
បវិវេករសស្សាទំ នចិរស្សេវ វិន្ទតិ
យស្មា តស្មា ហិ សប្បញ្ញោ អព្ភោកាសេ រតោ សិយា ។

សេចក្តីថា: ព្រះយោគាវចរភិក្ខុ អ្នកមានចិត្តឥតហ្មងហែងលំនៅដូចជាម្រឹគ អាស្រ័យភាពជាអ្នកត្រេកអរក្នុងភាវនា កាលនៅអាស្រ័យក្នុងទីវាលស្រឡះដែលរកបានដោយងាយ ជាទីសមគួរដល់ភាពជាបព្វជិត ដែលដួងផ្កាយជាពិដានដាំរំលេចដោយកែវមណី ដែលព្រះចន្ទជាប្រទីប សម្រាប់អុជបំភ្លឺ ក៏រមែងនឹងបន្ទោបង់នូវសេចក្តីច្រអូសកាយ ច្រអូសចិត្តបាន ហើយនឹងបានទទួលសោយនូវសេចក្តីត្រេកអរក្នុងរសរបស់ធម៌ ដែលស្ងប់ស្ងាត់ មិនមែនយឺតយូរសោះឡើយ ព្រោះហេតុឯណា ព្រោះហេតុនោះឯង ព្រះយោគី អ្នកប្រកបដោយប្រាជ្ញាគប្បីត្រេកអរក្នុងទីវាលស្រឡះបែបនោះចុះ ។

## អព្ភោកាសិកង្គចប់

------------------------------

# សោសានិកង្គ

## វិធីសមាទានក្នុងសោសានិកង្គ

ក្នុងសោសានិកង្គនេះ ក៏មានបាលីសម្រាប់សមាទាន ២ បែបដូចគ្នា ។

បែបទី ១ ថា: **នសុសានំ បដិក្ខិបាមិ** ប្រែថា ខ្ញុំព្រះករុណាសូមឃាត់នូវទីដែលមិនមែនជាស្មសាន[61] ។

[61] ពាក្យថា "ស្មសាន" នេះសំដៅយកតែកន្លែងដែលគេសម្រាប់ដុតខ្មោច ទោះបីទីវាលក្តី ព្រៃក្តី ស្រុកក្តី ក៏ហៅបានដូចគ្នា គឺត្រូវគ្នានឹងពាក្យដែលយើងធ្លាប់ហៅថា "ប៉ាឆា" នេះឯង ។

បែបទី ២ ថា: **សោសានិកង្គំ សមាទិយាមិ** (ប្រែថា) ខ្ញុំព្រះករុណាសូមសមាទាននូវអង្គនៃភិក្ខុអ្នកមានកិរិយានៅអាស្រ័យក្នុងទីស្មសានជាប្រក្រតី។

បាលីទាំង ២ បែបនេះ ប្រើបានដូចគ្នា តាមតែព្រះយោគីត្រូវការ ទោះបីសមាទានតាមបែបណាក៏បាន ។

ទីស្មសាន សំដៅយកទីដែលគេសម្រាប់ដុតនូវសាកសពអសុភ ទោះបីទីនោះគេនៅប្រើប្រាស់សព្វថ្ងៃក្តី គេបោះបង់ចោលយ៉ាងយូរ កំណត់ត្រឹម ១២ ឆ្នាំក្តី ក៏បានឈ្មោះថាទីស្មសាន តាំងអំពីកាលដែលគេផ្តេកសាកសពអសុភប្រុងនឹងដុតជរាបមក តែបើទីណាដែលគេទើបនឹងកំណត់ថាជាទីស្មសាន តែមិនទាន់បានដុតជរាបមក តែបើទីណាដែលគេទើបនឹងកំណត់ថាស្មសាន តែមិនទាន់បានដុតសាកសពអសុភម្តងសោះ ក៏មិនទាន់បានឈ្មោះថាជាទីស្មសានឡើយ ។

មែនពិត ភិក្ខុអ្នកនៅក្នុងទីស្មសាននោះ មិនត្រូវឲ្យគេធ្វើទីចង្ក្រម ធ្វើមណ្ឌល តាក់តែងគ្រែ ឬតាំងជាដើម មិនត្រូវតម្កល់ទុកនូវទឹកសម្រាប់ឆាន់ ទឹកសម្រាប់ប្រើប្រាស់ នឹងត្រូវបង្រៀនធម៌ដល់បុគ្គលដទៃឡើយ ព្រោះធុតង្គនេះមានទម្ងន់ពេកណាស់ ហេតុនោះនឹងការពារកុំឲ្យមានអន្តរាយ ត្រូវតែពិតទូលដល់សង្ឃត្ថេរក្នុងវត្ត និងមន្ត្រីអ្នករាជការក្នុងស្រុកជាមុន សន្សឹមចូលទៅនៅមិនត្រូវធ្វេសប្រហែសឡើយ ។ ក្នុងវេលាដែលដើរចូលទៅ កុំដើរតាមផ្លូវផ្លាវេលាថ្ងៃត្រង់ ត្រូវកំណត់អារម្មណ៍មានដើមឈើ និងដង្គត់ឈើជាដើម ក្នុងទីនោះទុកឲ្យហើយ បើអមនុស្សដើរស្រែកក្នុងវេលាយប់ មិនត្រូវប្រហារដោយវត្ថុ

អ្វីនីមួយឡើយ មិនត្រូវខានទៅកាន់ទីស្មសានក្នុងថ្ងៃណានីមួយៗ សោះ តែបើទៅនៅក្នុងទីស្មសានអស់មជ្ឈិមយាម ដល់បច្ឆិមយាមត្រឡប់មកវិញបាន មិនត្រូវបរិភោគល្ង ម្សៅភត្ត ដែលលាយដោយសណ្តែករាជមាស ត្រី សាច់ ឬបង្អែម ដែលលាយទៅដោយទឹកដោះស្រស់ ប្រេង ស្ករអំពៅជាដើម ដែលជាចំណូលរបស់អមនុស្សនោះឡើយ បើមានខ្ទមអ្នកតា កុំចូលទៅក្នុងទីនោះ ។

## ប្រភេទនៃសោសានិកង្គ

សោសានិកភិក្ខុនេះ ក៏មានចែកចេញជា ៣ ថ្នាក់ដូចគ្នា ។

សេចក្តីថាៈ ភិក្ខុថ្នាក់ឧក្រិដ្ឋ ទីស្មសានណា ដែលមានដុតសាកសពអសុភជានិច្ច មានសាកអសុភដែលគេចោលជានិច្ច មានមនុស្សទៅយំស្រែកជានិច្ច ត្រូវនៅតែក្នុងទីនោះ ។

ភិក្ខុថ្នាក់មធ្យម បណ្តាហេតុទាំង ៣ យ៉ាងនេះ ឲ្យទីស្មសានណាមានហេតុណាមួយក៏គួរទៅបាន ។

ភិក្ខុថ្នាក់មុទុ ទោះបីទីនោះគេបោះបង់ចោលហើយ តេមិនទាន់ហួសអំពី ១២ ឆ្នាំ ក៏គួរនៅបាន មិនចាំបាច់មានហេតុណានីមួយឡើយ ។

## ធុតង្គបែកក្នុងសោសានិកង្គ

ធុតង្គរបស់ភិក្ខុទាំង ៣ ថ្នាក់នេះ កាលដែលបែកធ្លាយ នឹងបែកធ្លាយក្នុងខណៈដែលភិក្ខុទាំងនេះ សម្រេចលំនៅក្នុងទីដែលមិនមែនជាទីស្មសាន ឬក្នុងថ្ងៃដែលមិនបានទៅកាន់ទីស្មសានដូចគ្នា ។

# អានិសង្សក្នុងសោសានិកង្គ

មានអានិសង្ស ១០ យ៉ាងគឺ

១- **មរណស្សតិបដិលាភោ:** កិរិយាបាននូវមរណស្សតិ ដោយបានឃើញនូវសាកអសុភអស់កាលជានិច្ច ។

២- **អប្បមាទវិហារតា:** ភាពជាអ្នកនៅដោយសេចក្តីមិនប្រមាទ ដោយកិរិយាបាននូវមរណស្សតិនោះ

៣- **អសុភនិមិត្តាធិគមោ:** កិរិយាបាននូវអសុភនិមិត្ត ដោយបានឃើញនូវសាកអសុភ ដែលគេចោលនៅក្នុងទីស្មសាននោះ ។

៤- **កាមរាគវិនោទនំ:** កិរិយាបង្អន់នូវកាមរាគ ដោយកិរិយាបាននូវអសុភនិមិត្តនោះ។

៥- **អភិណ្ហំ កាយសភាវទស្សនំ:** កិរិយាឃើញនូវសភាពរបស់កាយដែលមិនស្អាតជាដើមរឿយៗ ។

៦- **សំវេគពហុលតា:** ភាពជាអ្នកច្រើនដោយសេចក្តីសង្វេគដោយកិរិយាបាននូវមរណស្សតិ ។

៧- **អារោគ្យមទាទិប្បហានំ:** កិរិយាលះបង់នូវសេចក្តីស្រវឹងដោយភាពដែលមិនមានរោគជាដើមបាន ដោយបានឃើញនូវមនុស្សជំងឺជាដើមនៅក្នុងទីនោះ ។

៨- **ភយភេរវសហនតា:** ភាពជាអ្នកអាចអត់ទ្រាំនូវភ័យតូចនិងភ័យធំដែលគួរស្បើមបានដោយស៊ាំក្នុងការជួបប្រទះនឹងអារម្មណ៍ដែលគួរស្ញែង

៩- អមនុស្សាទំ តរុភាវនីយតា: ភាពជាបុគ្គលគួរឲ្យអមនុស្ស ទាំងឡាយគោរព និងកោតសរសើរ ។

១០- អប្បិច្ឆតាទីទំ អនុលោមវុត្តិតា: ភាពជាអ្នកមានកិរិយាប្រព្រឹត្តិដ៏សមគួរដល់អប្បិច្ឆតាគុណជាដើម ។

ទាំង ១០ យ៉ាងនេះ ជាអានិសង្សក្នុងសោសានិកង្គ ដែលភិក្ខុបានរក្សាដោយល្អ មិនបានឲ្យបែកធ្លាយ ។

**គាថាទីបំផុតក្នុងសោសានិកង្គ**

សោសានិកញ្ហិ មរណានុសតិប្បភាវា
និទ្ទាគតម្បិ ន ផុសន្តិ បមាទទោសា
សម្បស្សតោ ច កុណបានិ ពហូនិ តស្ស
កាមានុភាវវសគម្បិ ន ហោតិ ចិត្តំ
សំវេគមេតិ វិបុលំ ន មទំ ឧបេតិ
សម្មា អថោ ឃដតិ និព្វុតិមេសមានោ
សោសានិកង្គមិតិនេកគុណាវហត្តា
និព្វានិន្នហទយេន និសេវិតព្វំ ។

សេចក្ដីថា: ភិក្ខុអ្នកនៅក្នុងព្រៃស្មសាន បើទុកជាចូលទៅកាន់និទ្រាក៏ទោសព្រោះសេចក្ដីប្រមាទទាំងឡាយពាល់ត្រូវមិនបានឡើយ ដោយអានុភាពនៃមរណានុស្សតិ ដែលបានក្នុងទីស្មសាននោះ ។ មិនត្រឹមតែប៉ុណ្ណោះ ចិត្តរបស់ភិក្ខុអង្គនោះសោត កាលបើបានឃើញនូវសាកអសុភរឿយៗ មុខជាមិនលុះក្នុងអំណាចនៃកាមរាគ មានតែដល់នូវសេចក្ដីសង្វេគយ៉ាងធំទូលាយ មិនមែនដល់

នូវសេចក្តីស្រវឹងឡើយ ព្រោះហេតុនោះ ព្រះយោគីអ្នកស្វែងរកព្រះនិព្វានជាទីរលត់ទុក្ខ ត្រូវតែប្រឹងប្រែងសេពនូវសោសានិកង្គ ដោយហឫទ័យដែលខិនទៅរកព្រះនិព្វាន ដោយប្រពៃចុះ ព្រោះថាសោសានិកង្គនេះជាធម្មជាតតែងនាំមកនូវគុណជាអនេក ដូចពោលមកហើយ ។

## សោសានិកង្គ ចប់

------------------------

## យថាសន្ថតកង្គ

ក្នុងយថាសន្ថតិកង្គនេះ ក៏មានបាលីសម្រាប់សមាទានជា ២ បែបដូចគ្នា ។

បែបទី ១ ជា: **សេនាសនលោលុប្បំ បដិក្ខិបាមិ** (ប្រែថា) ខ្ញុំព្រះករុណា សូមឃាត់នូវភាពដែលល្មោភក្នុងសេនាសនៈ ។

បែបទី ២ ជា: **យថាសន្ថតិកង្គំ សមាទិយាមិ** (ប្រែថា) ខ្ញុំព្រះករុណា សូមសមាទាននូវអង្គនៃភិក្ខុ អ្នកមានកិរិយានៅតែក្នុងទីសេនាសនដែលសង្ឃសម្តែងឲ្យជាដំបូង ដដែលមិនរុះរើជាប្រក្រតី ។

បាលីទាំង ២ បែបនេះ ប្រើបានដូចគ្នា តាមតែព្រះយោគីត្រូវការ ទោះបីសមាទានតាមបែបណាក៏បាន ។

ភិក្ខុអ្នកសមាទាន រក្សានូវយថាសន្ថតិកង្គនេះ បើភិក្ខុដែលសង្ឃចាត់ឲ្យជាអ្នកចែកនូវទីសេនាសនៈ បានប្រគល់ទីសេនាសនៈបែបណាឲ្យ ត្រូវតែត្រេកអរដោយទីសេនាសនៈនោះប៉ុណ្ណោះ មិនត្រូវសួររក ឬ ដើរជ្រើសរើសរកទីសេនាសនៈដទៃទៀត ដោយយល់ថាល្អ ឬមិនល្អនោះឡើយ ។

# ប្រភេទនៃយថាសន្តិកភិក្ខុ

យថាសន្តិកភិក្ខុនេះ ក៏មានចែកចេញជា ៣ ថ្នាក់ដូចគ្នា ។

សេចក្ដីថា: ភិក្ខុថ្នាក់ឧក្រិដ្ឋ ទីសេនាសនៈណាដែលត្រូវបាន ខ្លួននឹងសួរអំពីឆ្ងាយ ឬជិត អមនុស្សនិងទីឃជាតិ(ពស់) ជាដើមបៀតបៀន ឬមិនបៀតបៀន ក្ដៅ ឬត្រជាក់ដូច្នេះនោះពុំបានឡើយ ។

ភិក្ខុថ្នាក់មធ្យម បើគ្រាន់តែសួរប៉ុណ្ណោះបាន កុំតែដើរទៅរមឹលមើលតាមអំពើចិត្តចង់ ។

ភិក្ខុថ្នាក់មុទុ គ្រាន់តែរមឹលមើលបាននៅ បើទីសេនាសនៈនោះមិនពេញចិត្តនឹងរើសរកទីដទៃទៀតមិនបាន ។

# ធុតង្គបែកក្នុងយថាសន្តិកង្គ

ធុតង្គរបស់ភិក្ខុទាំង ៣ ថ្នាក់នេះ កាលដែលបែកធ្លាយ នឹងបែកធ្លាយក្នុងខណៈដែលកើតសេចក្ដីល្មោភ និងជ្រើសរើសរកទីសេនាសនៈតាមពេញចិត្តដូចគ្នា។

# អានិសង្សក្នុងយថាសន្តិកង្គ

មានអានិសង្ស ៦ យ៉ាងគឺ

១- **ឱវាទករណំ:** បានឈ្មោះថាធ្វើតាមឱវាទដែលព្រះជិនស្រីទ្រង់ត្រាស់សម្ដែងថា ទីសេនាសនៈណាដែលខ្លួនបានមកហើយ ត្រូវតែត្រេកអរដោយទីសេនាសនៈនោះ កុំរើរុះដូច្នេះ ។

២- សព្រហ្មចារីនំ ហិតេសិតា: ភាពជាអ្នកស្វែងរកនូវប្រយោជន៍ទុកឲ្យសព្រហ្មចារីផងគ្នា គឺសំចៃទីសេនាសនៈ ដទៃទុកឲ្យភិក្ខុឯទៀត ។

៣- ហីនបណីតវិកប្បបរិច្ចតោ: កិរិយាលះបង់នូវសេចក្ដីកំណត់ថា ថោកថយ និងថ្កើងថ្កានបាន ។

៤- អនុរោធវិរោធប្បហានំ: កិរិយាប្រហារបង់នូវសេចក្ដីត្រេកអរ និងសេចក្ដីមិនត្រេកអរ ។

៥- អត្រិច្ឆតាយ ទ្វារបិទហានំ: កិរិយាបិទនូវទ្វារនៃសេចក្ដីប្រាថ្នាកន្លង ។

៦- អប្បិច្ឆតាទីនំ អនុលោមវុត្តិតា: ភាពជាអ្នកមានកិរិយាប្រព្រឹត្តិដ៏សមគួរដល់អប្បិច្ឆតាគុណជាដើម ។

ទាំង ៦យ៉ាងនេះជាអានិសង្សក្នុងយថាសន្ថតិកង្គ ដែលភិក្ខុបានសមាទានរក្សាដោយល្អ មិនបានឲ្យបែកធ្លាយ ។

## គាថាទីបំផុតក្នុងយថាសន្ថតកង្គ

យំ លទ្ធំ តេន សន្តុដ្ឋោ　　យថា សន្ថតិកោ យតិ
និព្វិកប្បោ សុខំ សេតិ　　តិណសន្ថរកេសុបិ
ន សោ រជ្ជតិ សេជ្ជម្ហិ　　ហីនំ លទ្ធា ន កុប្បតិ
សព្រហ្មចារិនវកេ　　ហិតេន អនុកម្បតិ
តស្មា អរិយសតាចិណ្ណំ　　មុនិបុង្គវវណ្ណិតំ
អនុយុញ្ជេថ មេធាវី　　យថាសន្ថតរាមតំ ។

សេចក្តីថា: ព្រះយោគីដែលសន្តោស ដោយសេនាសនៈតាមតែបាន ស្នាក់នៅតែក្នុងទីសេនាសនៈដែលសង្ឃសម្តែងឲ្យ មិនមានរើសអើងរកទីសេនាសនៈដ៏ថ្លៃថ្លា រមែងដេកនៅជាសុខ សូម្បីលើកម្រាលជាវិការៈនៃស្មៅទាំងឡាយ លោកមិនត្រេកអរក្នុងទីសេនាសនៈដ៏ប្រសើរថ្កើងថ្កាន បើទុកជាបាននូវសេនាសនៈដ៏ថោកទាប ក៏លោកមិនមានសេចក្តីខឹងក្រោធ មានឈ្មោះថា លោកជាអ្នកអនុគ្រោះនូវព្រហ្មចារី ដែលទើបបួសថ្មីៗ ទាំងឡាយ ដោយប្រយោជន៍ ព្រោះហេតុនោះ អ្នកប្រាជ្ញដែលមានប្រាជ្ញា គប្បីប្រកបរឿយៗនូវភាពជាអ្នកត្រេកអរក្នុងទីសេនាសនៈ ដែលសង្ឃសម្តែងឲ្យជាប្រវេណីនៃព្រះអរិយ ដែលព្រះពុទ្ធជាអ្នកប្រាជ្ញសរសើរហើយ ។

## យថាសន្ថតកង្គ ចប់

------------------------------------

# នេសជ្ជិកង្គ

## វិធីសមាទានក្នុងនេសជ្ជិកង្គ

ក្នុងនេសជ្ជិកង្គនេះ ក៏មានបាលីសម្រាប់សមាទាន ២ បែបដូចគ្នា ។

បែបទី ១ ថា: **សេយ្យំ បដិក្ខិបាមិ** ប្រែថា ខ្ញុំព្រះករុណាសូមឃាត់នូវឥរិយាបថដេក ។

បែបទី ២ ថា: **នេសជ្ជិកង្គំ សមាទិយាមិ:** ប្រែថា ខ្ញុំព្រះករុណាសូមសមាទាននូវអង្គនៃភិក្ខុ អ្នកមានកិរិយាឃាត់នូវឥរិយាបថដេក ហើយនៅដោយឥរិយាបថអង្គុយប្រក្រតី[62] ។

បាលីទាំង ២ បែបនេះប្រើបានដូចគ្នា តាមតែព្រះយោគីត្រូវការបើសមា-ទានតាមបែបណាក៏បាន ។

ក៏ព្រះយោគី ដែលបានសមាទាននូវនេសជ្ជិកង្គនេះរួចហើយ ក្នុងយាម ៣ នៃរាត្រី បើក្រោកចង្ក្រមអស់យាម ១ បាន កុំតែដេកមិនបានឡើយ ។

## ប្រភេទនៃនេសជ្ជិកង្គ

នេសជ្ជិកភិក្ខុនេះ ក៏មានចែកជា ៣ ដូចគ្នា ។

សេចក្តីថា: ភិក្ខុថ្នាក់ឧក្រិដ្ឋ ទីបង្អែកក្តី សំពត់សម្រាប់ត្របោមក្តី[63] សំពត់សម្រាប់ប្រតោងក្តី[64] ប្រើប្រាស់មិនបានឡើយ ។

ភិក្ខុថ្នាក់មធ្យម វត្ថុទាំង ៣ នេះ ប្រើប្រាស់វត្ថុណាមួយបាន ។

---

[62] ពាក្យត្រង់នេះ ដូចជាត្រូវប្រើឥរិយាបថអង្គុយ ១ ប៉ុណ្ណោះ ឥរិយាបថក្រៅអំពីនោះ ប្រើមិនបាន ។ តាមតែដែលពិតនោះ ត្រូវហាមតែឥរិយាបថដេក ១ ប៉ុណ្ណោះ ឯឥរិយាបថក្រៅអំពីនោះប្រើបាន ។

[63] សំពត់សម្រាប់ចងស្រាក់ឆ្អឹងក្បាលជង្គង់ ។

[64] សំពត់សាជកសម្រាប់ចងសំយុងចុះអំពីខាងលើ ហើយតោងបង្ហើយខ្លួនដើម្បីសម្រាលអង្គុយ ។

ភិក្ខុថ្នាក់មុទុ ទីបង្អែកក្តី សំពត់សម្រាប់ត្របោមក្តី សំពត់សម្រាប់ប្រគោងក្តី ខ្នើយក្តី កៅអីមានអង្គ ៥ ក្តី[65] កៅអីមានអង្គ ៧ ក្តី[66] ប្រើបានទាំងអស់ ។

## ធុតង្គបែកក្នុងនេសជ្ជិកង្គ

ធុតង្គរបស់ភិក្ខុទាំង ៣ ថ្នាក់នេះ កាលដែលបែកធ្លាយ នឹងបែកធ្លាយក្នុងខណៈដែលភិក្ខុទាំងនេះសម្រេចឥរិយាបថដេក ។

## អានិសង្សក្នុងនេសជ្ជិកង្គ

### មានអានិសង្ស ៥ យ៉ាងគឺ

១- **ចេតសោ វិនិពន្ធស្ស ឧបច្ឆេទនំ:** កិរិយាចូលទៅផ្តាច់បង់នូវគំនួចរបស់ចិត្ត ដែលធ្លាប់ដេកជាសុខជាដើម ។

២- **សព្វកម្មដ្ឋានានុយោគសប្បាយតា:** ភាពនៃឥរិយាបថជាទីសប្បាយ ដល់កិរិយាប្រកបព្យាយាមក្នុងកម្មដ្ឋានទាំងពួង[67] ។

---

[65] កៅអីមានជើង៤ ។

[66] ជើង ៤ ទុកជាអង្គ ៤ បង្អែកអំពីអង្គខាងក្រោយទុកជាអង្គ ១ ផ្ទាក់ដៃអមខាង ២ ទុកជាអង្គ ២ រួចត្រូវជាអង្គ ៧ ។

[67] វិធីចម្រើនគ្រប់កម្មដ្ឋានទាំងអស់សុទ្ធតែ ប្រើឥរិយាបថអង្គុយ កាលបើរក្សានូវធុតង្គ នេះងាយនឹងចម្រើនបាន ចម្រើនបានតាមសប្បាយ ព្រោះប្រើឥរិយាបថស្របគ្នា ។

៣- **ចាសាជិកឥរិយាបថតា:** ភាពជាអ្នកមានឥរិយាបថ ជាទីនាំមកនូវសេចក្តីជ្រះថ្លារបស់ប្រជុំជន ។

៤- **វីរិយារម្ភានុកូលតា:** ភាពដ៏សមគួរដល់បុគ្គលជាអ្នកប្រារព្ធនូវព្យាយាម។

៥- **សម្មាបដិបត្តិយា អនុព្រូហនំ:** កិរិយាបង្កើតនូវសម្មាបដិបត្តិ ។

ទាំង ៥ យ៉ាងនេះ ជាអានិសង្សក្នុងនេសជ្ជិកង្គ ដែលភិក្ខុរក្សាដោយល្អមិនបានឲ្យបែកធ្លាយ ។

## គាថាទីបំផុតក្នុងនេសជ្ជិកង្គ

អាភុជិត្វាន បល្លង្កំ      បណិធាយ ឧជុំ តនុំ
និសីទន្តោ វិកម្បេតិ      មារស្ស ហទយំ យតិ
សេយ្យសុខំ មិទ្ធសុខំ      ហិត្វា អារទ្ធវីរិយោ
និសជ្ជាភិរតោ ភិក្ខុ      សោភយន្តោ តបោវនំ
និរាមិសំ បីតិសុខំ      យស្មា សមធិគច្ឆតិ
តស្មា សមនុយុញ្ជេយ្យ      ធីរោ នេសជ្ជិកំ វតំ

សេចក្តី: ព្រះយោគីអ្នកអង្គុយពត់ភ្នែន តម្រង់កាយឲ្យត្រង់ រមែងញ៉ាំងហឫទ័យនៃមារឲ្យកម្រើកបាន ។ ភិក្ខុអ្នកមានព្យាយាមប្រារព្ធ លះបង់នូវកិរិយាដេកជាសុខ ត្រេកអរតែក្នុងឥរិយាបថអង្គុយ ញ៉ាំងព្រៃ គឺតបធម៌ឲ្យភ្លឺស្វាងរុងរឿង រមែងតែបាននូវបីតិនិងសុខ ដែលមិនមានអាមិស[68] ព្រោះហេតុឯណា ព្រោះហេតុនោះ អ្នកប្រាជ្ញដែលមានប្រាជ្ញា គប្បីប្រកបរក្សាឲ្យល្អ នូវធុតង្គឈ្មោះ

---

68 ក្នុងអដ្ឋកថាសតិបដ្ឋានសូត្រ សោមនស្សវេទនា ដែលមិនអាស្រ័យនូវកាមគុណ ៥ និងទោមនស្សវេទនាដែលជានេក្ខម្មសិត ៦ យ៉ាង ។

នេសជ្ជិកង្គនេះចុះ ។

## សមាសវិនិច្ឆយកថា

លំដាប់អំពីនេះ និងវិនិច្ឆយរួបរួមក្នុងធុតង្គទាំង ១៣ ដោយសេចក្ដីបំព្រួញតទៅ ។

ក៏ធុតង្គទាំង ១៣ នុ៎ះ បើបំព្រួញឲ្យតិចចុះ មកនៅត្រឹមតែ ៨ ចាត់ជាអង្គដែលជាប្រធាន ៣ ជាអង្គដែលមិនច្រឡំគ្នា ៥ ។ បំព្រួញមកទៀតមកនៅត្រឹមតែ ៤ ចាត់ ២ ជា**ចីវរបដិសំយុត្ត**, ៥ ជាបិណ្ឌបាតបដិសំយុត្ត, ៥ ទៀត ជាសេនាសនបដិសំយុត្ត, ១ ជាវិរិយបដិសំយុត្ត ។ បំព្រួញមកទៀតនៅត្រឹមតែ ២ចាត់ជា ១២ ជា**បច្ចយនិស្សិត**, ១ ជា**វិរិយបដិសំយុត្ត** ។ បំព្រួញចុះជា ២ មួយបែបទៀត ចាត់ធុតង្គណាដែលព្រះយោគីសេពទៅហើយ កម្មដ្ឋានចម្រើនឡើងជា **សេវិតព្វ** គឺត្រូវឲ្យសេព. ធុតង្គណាដែលយោគីសេពទៅហើយកម្មដ្ឋានសាបសូន្យជា**អសេវិតព្វ** គឺមិនត្រូវសេព តែបើធុតង្គណាដែលព្រះយោគីសេពក្ដី មិនសេពក្ដី កម្មដ្ឋានចេះតែចម្រើនឡើងមិនសាបសូន្យ នោះក៏ចាត់ជាសេវិតព្វ ត្រូវសេពដែរ ដោយអនុគ្រោះដល់បណ្ដាជនជំនាន់ក្រោយ ។ ពុំនោះធុតង្គណាដែលព្រះយោគីសេពក្ដី មិនសេពក្ដី កម្មដ្ឋាននៅតែសាបសូន្យដដែល ក៏ចាត់ជា **សេវិតព្វ** ត្រូវឲ្យសេពដូចគ្នា ដើម្បីជាវាសនាទៅខាងអនាគត ។ បើបំព្រួញឲ្យតិចចុះមកទៀតនៅត្រឹមតែ ១ សំដៅយកត្រង់ចេតនាដែលសមាទានរក្សានូវធុតង្គទាំងនោះឯង ។

ធុតង្គជាអង្គដែលប្រធានមាន ៣ គឺ សបទានចារិកង្គ ១ ឯកាសនិកង្គ ១ អព្ភោកាសិកង្គ ១ ព្រោះថា កាលបើរក្សានូវសបទានចារិកង្គហើយ នឹងរក្សានូវបិណ្ឌបាតិកង្គផងក៏បាន បើរក្សានូវឯកាសនិកង្គហើយ នឹងរក្សានូវបត្តបិណ្ឌិកង្គ និងខលុបច្ឆាភត្តិកង្គផងក៏បាន បើរក្សានូវអព្ភោកាសិកង្គ ហើយនឹងត្រូវរក្សារុក្ខមូលិកង្គ និងយថាសន្ថតិកង្គ ដូចម្ដេចនឹងកើត[69] ។

អារញ្ញិកង្គ ១, បំសុកូលិកង្គ ១, តេចីវរិកង្គ ១, នេសជ្ជិកង្គ ១, សោសានិកង្គ ១, ទាំង ៥នេះចាត់ជាអង្គដែលមិនច្រឡំគ្នា ព្រោះមិនស្រដៀងដោយធុតង្គដទៃ ។ រួមទាំងអង្គដែលជាប្រធាន៣ អង្គដែលមិនច្រឡំគ្នា៥ ត្រូវជា៨ ។

ធុតង្គ ២ គឺ បំសុកូលិកង្គ ១, តេចីវរិកង្គ ១ ទាំង ២ នេះចាត់ជាចីវរបដិសំយុត្ត ព្រោះទាក់ទងដោយចីវរ ។

ធុតង្គ ៥ គឺ បិណ្ឌិបាតិកង្គ ១, សបទានចារិកង្គ ១ ឯកាសនិកង្គ ១ អព្ភោកាសិកង្គ ១, ខលុបច្ឆាភត្តិកង្គ ១, ទាំង ៥ នេះ ចាត់ជាបិណ្ឌបាតបដិសំយុត្ត ព្រោះទាក់ទងដោយបិណ្ឌបាត ។

ធុតង្គ ៥ គឺៈ អារញ្ញិកង្គ ១, រុក្ខមូលិកង្គ ១, អព្ភោកាសិកង្គ ១, សោសានិកង្គ ១, យថាសន្ថតិកង្គ ១, ទាំង ៥ នេះចាត់ជា សេនាសនបដិសំយុត្ត ព្រោះទាក់ទងដោយ សេនាសនៈ ។

---

[69] រក្សាមិនកើតព្រោះដំណើរផ្ទុយគ្នា ។

នេសជ្ជិកង្គតែ ១ ចាត់ជា វិរិយបដិសំយុត្ត ព្រោះទាក់ទងដោយព្យាយាម ចីវរបដិសំយុត្ត ២ ចាត់ជា ១, បិណ្ឌបាតបដិសំយុត្ត ៥ ចាត់ជា ១, សេនាសនបដិសំយុត្ត ៥ ចាត់ជា ១, វិរិយបដិសំយុត្ត ១ ចាត់ជា ១ ដដែល រួមទាំងអស់ត្រូវជា ៤ ។

## ការបំព្រួញធុតង្គទាំងអស់ឲ្យនៅត្រឹមតែ ២ ដូច្នេះគឺ

លោកចាត់ធុតង្គ ១២ ខាងដើមជា **បច្ច័យសន្និស្សិត** ព្រោះអាស្រ័យដោយបច្ច័យ ។

**នេសជ្ជិកង្គ** ១ ខាងចុងចាត់ជា **វិរិយនិស្សិត** ព្រោះអាស្រ័យដោយព្យាយាម ។ **បច្ចយសន្និស្សិត** ១២ ចាត់ជា ១, **វិរិយនិស្សតិ** ១ ចាត់ជា ១ ដដែល រួចត្រូវជា ២ ។

ត្រង់ដែលលោកបំព្រួញចុះជា ២ មួយបែបទៀត ហើយចាត់ជា **សេវិតព្វ** ១ **អសេវិតព្វ** ១ និងបំព្រួញចុះជា ១ សំដៅយកចេតនា ដែលសមាទាននោះ បានអធិប្បាយខាងដើមរួចហើយ ចូររកមើលចុះ ។

## សមាសវិនិច្ឆយកថាចប់

---

## ព្យាសវិនិច្ឆយកថា

បន្ទាប់អំពីនេះ នឹងពោលវិនិច្ឆ័យរំលែកធុតង្គទាំង ១៣ ឲ្យពិស្តារតាមសមគួរដល់ភេទរបស់យោគីអ្នករក្សាតទៅ ។

ក៏ធុតង្គទាំង ១២ នុ៎ះ បើពោលរំលែកតាមសមគួរដល់ភេទរបស់ព្រះយោគីអ្នករក្សាដល់ ៤២ ដូច្នេះគឺ លោកចាត់ធុតង្គរបស់ភិក្ខុ ១៣, ភិក្ខុនី ៨ សាមណេរ ១២, សិក្ខមានា និងសាមណេរី ៧ ឧបាសក ឧបាសិកា ២ រួមទាំងអស់ជា ៤២ ។

សេចក្ដីថា: ធុតង្គទាំង ១៣ នុ៎ះ ភិក្ខុគួររក្សាបានទាំងអស់ លោកចាត់ទុកសម្រាប់ភិក្ខុគ្រប់ទាំង ១៣ ។ **អារញ្ញិកង្គ** ១, **ខលុបច្ឆាភត្តិកង្គ** ១, មានសិក្ខាបទហាមដល់ភិក្ខុនី **អព្ភោកាសិកង្គ** ១, **រុក្ខមូលិកង្គ** ១, **សោសានិកង្គ** ១, ភិក្ខុនីលំបាករក្សា ទើបចាត់ទុកសម្រាប់ភិក្ខុនីតែ ៨ ។ សាមណេរមិនមានវិនយកម្មដែលនឹងអធិដ្ឋាននូវចីវរ ៣ ទើបលើកតេចីវរចេញចាត់ទុកតែត្រឹម ១២ ។ សិក្ខមានា និងសាមណេរី មិនមានវិនយកម្ម ដែលនឹងត្រូវអធិដ្ឋាននូវចីវរ ៣ ដូចគ្នាសាមណេរដែរ ហើយជាឥត្ថីភាពដូចគ្នាភិក្ខុនី ទើបលើក**អារញ្ញិកង្គ** ១, **ខលុបច្ឆាភត្តិកង្គ** ១, **អព្ភោកាសិកង្គ** ១, **រុក្ខមូលិកង្គ** ១, **សោសានិកង្គ** ១, **តេចីវរិកង្គ** ១ ចេញ ចាត់ទុកតែ ៧ ក្រៅអំពីនេះ ។ ឧបាសក និងឧបាសិកា គួររក្សាបាន ២ គឺ **ឯកាសនិកង្គ** ១ **បត្តបិណ្ឌិកង្គ** ១ ។

## ព្យាសវនិច្ឆយកថា ចប់

## ធុតង្គកថា ចប់

---

## ២- ការចម្រើនកម្មដ្ឋាន

ពាក្យថា "**កម្មដ្ឋាន**" អារម្មណ៍ដែលគួរចម្រើនឲ្យកើតសតិសម្បជញ្ញៈ និងគុណវិសេសផ្សេងៗជាដើម មានសមាធិជាដើម លោកហៅថា "**កម្មដ្ឋាន**" ។

បានសេចក្តីថា: ហេតុជាទីតាំងនៃភាវនាកម្ម គឺជាអារម្មណ៍សម្រាប់បរិកម្មភាវនា. ម្យ៉ាងទៀតថា: ហេតុជាទីតាំងនៃអំពើព្យាយាមដើម្បីនឹងចម្រើននូវសមាធិភាវនា ឬជាហេតុដ៏ជិតនឹងកើតភាវនាកម្ម ចំណែកជាន់លើ ។ កម្មដ្ឋានក្នុងទីនេះមាន ២ យ៉ាងគឺ **សមថកម្មដ្ឋាន** ១, **វិបស្សនាកម្មដ្ឋាន** ១ **សមថកម្មដ្ឋាន** ជាឧបាយសម្រាប់ទូន្មានចិត្ត ឲ្យស្ងប់ចាកកិលេសមានកាមច្ឆន្ទៈជាដើម. ឯ**វិបស្សនាកម្មដ្ឋាន**ជាឧបាយសម្រាប់ធ្វើប្រាជ្ញាឲ្យត្រចះឡើង ដើម្បីលះបង់ នូវកិលេសមាន **ឧបាទាន** គឺសេចក្តីប្រកាន់ក្នុងខន្ធជាដើម ។

កម្មដ្ឋានទាំង ២ នេះ យោគាវចរជាអាទិកម្មិកបុគ្គល គប្បីសិក្សាប្រតិបត្តិក្នុង **សមថកម្មដ្ឋាន** ជាមុនសិន ទើបគួរប្រតិបត្តិក្នុង **វិបស្សនាកម្មដ្ឋាន** ជាខាងក្រោយ ។ ព្រោះហេតុអ្វី?

យោគីកុលបុត្រគប្បីសិក្សានូវអាការទាំង ១០ យ៉ាង នៃកម្មដ្ឋាននេះសិននឹងដឹងនូវចម្លើយក្នុងសំណួរនោះបានដោយពិតប្រាកដ ។

## អាការ ១០ យ៉ាង

អាការទាំង ១០ យ៉ាងគឺ

១- **សង្ខាតនិទ្ទេសៈ** ត្រូវដឹងអាការ ដែលលោកសម្តែងចេញរាប់ចំនួន ។

២- **ឧបចារប្បនាវហៈ** ត្រូវដឹងកម្មដ្ឋាន ដែលនាំមកនូវ **ឧបចារជ្ឈាន** និងកម្មដ្ឋានដែលនាំមក **អប្បនាឈាន** ។

៣- ឈានប្បភេទៈ ត្រូវដឹងប្រភេទរបស់ឈាន ។

៤- សមតិក្កមៈ ត្រូវដឹងវិធីប្រព្រឹត្តកន្លងរបស់កម្មដ្ឋាន ។

៥- វឌ្ឍនាវឌ្ឍនៈ ត្រូវដឹងកម្មដ្ឋាន ដែលគួរចម្រើនថែម និងមិនគួរចម្រើនថែម ។

៦- អារម្មណៈ ត្រូវដឹងអារម្មណ៍របស់កម្មដ្ឋាន ។

៧- ភូមិៈ ត្រូវដឹងភូមិរបស់កម្មដ្ឋាន ។

៨- គហណៈ ត្រូវដឹងកិច្ចដែលត្រូវរៀនយកនូវកម្មដ្ឋាន ។

៩- បច្ចយៈ ត្រូវដឹងបច្ច័យរបស់កម្មដ្ឋាន ។

១០- ចរិយានុកូលៈ ត្រូវដឹងកម្មដ្ឋានដែលសមគួរដល់ចរិត ។

## សេចក្តីអធិប្បាយនូវអាការ ទាំង ១០ តាមលំដាប់

ត្រង់ សង្ខាតនិទ្ទេសទី១ ដែលថាត្រូវឲ្យដឹង អាការដែលលោកសម្តែងចេញរាប់តាមចំនួននៃកម្មដ្ឋាននោះ គឺត្រូវឲ្យដឹងថា **កម្មដ្ឋាន** មាន ៤០ គឺ កសិណ ១០, អសុភ ១០, អនុស្សតិ ១០, ព្រហ្មវិហារ ៤ អារុប្ប ៤, សញ្ញា ១, វវត្ថាន ១, រួមជា ៤០ ។

## កសិណ ១០

១- បឋវីកសិណៈ យកដីធ្វើជាវង់កសិណ ។

២- អាបោកសិណៈ យកទឹកធ្វើជាវង់កសិណ ។

៣- តេជោកសិណៈ		យកភ្លើងធ្វើជាវង់កសិណ ។

៤- វាយោកសិណៈ		យកខ្យល់ធ្វើជាកសិណ ។

៥- នីលកសិណៈ		យកវត្ថុមានពណ៌ខៀវជាកសិណ ។

៦- បីតកសិណៈ		យកវត្ថុមានពណ៌លឿងជាកសិណ ។

៧- លោហិតកសិណៈ	យកវត្ថុមានពណ៌ក្រហមជាកសិណ ។

៨- ឱទាតកសិណៈ		យកវត្ថុមានពណ៌សជាកសិណ ។

៩- អាលោកកសិណៈ	យកពន្លឺជាកសិណ។

១០- អាកាសកសិណៈ	យកអាកាសដែលកំណត់ទុកជាកសិណ ។

## អសុភ ១០

១- ឧទ្ធុមាតកៈ		អសុភហើមពោរពងឡើង ។

២- វិនីលកៈ		អសុភហើមមានពណ៌ខៀវដោយច្រើន ។

៣- វិបុព្វកៈ		អសុភហើមមានខ្ទុះហូរទៅក្នុង ខាងលើ ខាងក្រោម។

៤- វិច្ឆិទ្ទកៈ		អសុភដែលគេកាត់ដាច់ពាក់កណ្តាលខ្លួន។

៥- វិក្ខាយិតកៈ		អសុភដែលសត្វខាំកកេរស៊ីមានសំណាម របុះ រលួយផ្សេងៗ ។

៦- វិក្ខិត្តកៈ អសុភដែលគេកាត់ដាច់ចេញ ពីគ្នាជាកំណាត់ៗ រាត់រាយទៅផ្សេងៗ ។

៧- ហតវិក្ខិត្តកៈ អសុភដែលគេកាប់សាប់មានស្នាមសាំរវាម ។

៨- លោហិតកៈ អសុភត្រូវប្រហារមានឈាមហូរស្រោចស្រព ។

៩- បុឡុវកៈ អសុភមានដង្កូវចោះហូរចេញតាមទ្វារទាំង ៩ ។

១០- អដ្ឋិកៈ អសុភមានតែរាងឆ្អឹងរាត់រាយខ្ចាត់ខ្ចាយទៅផ្សេងៗ ។

## អនុស្សតិ ១០

១- ពុទ្ធានុស្សតិៈ សេចក្ដីរលឹករឿយៗ មានពុទ្ធគុណជាអារម្មណ៍ ។

២- ធម្មានុស្សតិៈ សេចក្ដីរលឹករឿយៗ មានធម្មគុណជាអារម្មណ៍ ។

៣- សង្ឃានុស្សតិៈ សេចក្ដីរលឹករឿយៗ មានសង្ឃគុណជាអារម្មណ៍ ។

៤- សីលានុស្សតិៈ សេចក្ដីរលឹករឿយៗ មានសីលគុណជាអារម្មណ៍ ។

៥- ចាគានុស្សតិៈ សេចក្ដីរលឹករឿយៗ មានចាគគុណជាអារម្មណ៍ ។

៦- ទេវតានុស្សតិៈ សេចក្ដីរលឹករឿយៗ មានសទ្ធាទិគុណរបស់ទេវតា និងសទ្ធាទិគុណរបស់ខ្លួនជាអារម្មណ៍ ។

៧- មរណានុស្សតិៈ សេចក្ដីរលឹករឿយៗ មានសេចក្ដីស្លាប់ជាអារម្មណ៍

៨- កាយគតានុស្សតិៈ សេចក្ដីរលឹកតាំងចុះក្នុងកាយមានកោដ្ឋាស និមិត្ត[70] នៃអាការមានសក់ជាដើមជាអារម្មណ៍ ។

៩- អានាបានស្សតិៈ សេចក្ដីរលឹកមានអស្សាសបស្សាសនិមិត្ត[71] ជាអារម្មណ៍ ។

---

[70] និមិត្តរបស់ចំណែកនៃអាការទាំង ៣២ មានសក់ជាដើម ។

១០- **ឧបសមានុស្សតិៈ** សេចក្តីរលឹករឿយៗ មានគុណរបស់ព្រះនិព្វាន ដែលជាទីរម្ងាប់នូវទុក្ខទាំងពួងជាអារម្មណ៍ ។

## ព្រហ្មវិហារ ៤

១- មេត្តា ផ្សាយមេត្តាដល់សព្វសត្វទាំងអស់ ។

២- ករុណា ផ្សាយករុណាដល់សព្វសត្វទាំងអស់ ។

៣- មុទិតា ផ្សាយមុទិតាដល់សព្វសត្វទាំងអស់ ។

៤- ឧបេក្ខា ផ្សាយឧបេក្ខាដល់សព្វសត្វទាំងអស់ ។

## អារុប្ប ៤

១- **អាកាសានញ្ចាយតនៈ** យកអាកាសក្នុងបដិភាគនិមិត្ត ដែលកើតអំពីកសិណ ៩ លើកអាកាសកសិណចេញ ដែលមិនមានទីបំផុតជាអារម្មណ៍ ។

២- **វិញ្ញាណញ្ចាយតនៈ** ស្រាវយកអរូបវិញ្ញាណទី ១ ដែលផ្សាយទៅមិនមានទីបំផុតមកជាអារម្មណ៍ ។

៣- **អាកិញ្ចញ្ញាយតនៈ** កំណត់យកអរូបវិញ្ញាណទី ១ ដែលផ្សាយទៅមិនមានកង្វល់តិចតួចមកជាអារម្មណ៍ ។

៤- **នេវសញ្ញានាសញ្ញាយតនៈ** កំណត់យកសេចក្តីល្អិតរបស់អរូបវិញ្ញាណទី ៣ ដែលមានស្មើរតែនឹងមិនមានមកជាអារម្មណ៍ ។

---

[71] និមិត្តរបស់ខ្យល់ដង្ហើមចេញចូល ។

- **សញ្ញា** នេះ សំដៅយក **អាហារេបដិកូលសញ្ញា** ដែលយោគាវចរពិចារណាអាហារដោយបដិកូល ។

- **វវដ្ឋាន** ១ នោះ សំដៅយក **ចតុធាតុវវដ្ឋាន** ដែលព្រះយោគាវចរពិចារណាកំណត់ធាតុទាំង ៤ ក្នុងករជកាយ ។

រួមទាំងអស់ត្រូវជាកម្មដ្ឋាន ៤០

២- **ឧបចារប្បដាវហ** កម្មដ្ឋានដែលនាំមកបាន **ឧបចារជ្ឈាន** និង **អប្បដាឈាន** ត្រង់ **ឧបចារប្បដាវហា**ទី ២ ដែលថាត្រូវឲ្យដឹងកម្មដ្ឋាន ដែលនាំមកនូវ ឧបចារជ្ឈាន និងកម្មដ្ឋានដែលនាំមកនូវ អប្បដាឈាន នោះ គឺត្រូវដឹងថា:

**អនុស្សតិ** ៨ លើក **កាយគតាសតិ** ១ **អនាបានស្សតិ** ១ ចេញ, និង **សញ្ញា** ១ **វវដ្ឋាន** ១ រួមត្រូវជា ១០ **កម្មដ្ឋាន** ទាំង ១០ មានអំណាចនាំមកបានត្រឹម **ឧបចារជ្ឈាន**. កម្មដ្ឋាន ៣០ ក្រៅពីនេះ សុទ្ធតែមានអំណាចនាំមកដល់ **អប្បដាឈាន** ។

៣- **ឈានប្បភេទ** ប្រភេទរបស់ឈាន ។

ត្រង់ឈានប្បភេទទី ៣ ដែលថាត្រូវឲ្យដឹងប្រភេទរបស់ឈាន នោះគឺត្រូវឲ្យដឹងថា បណ្ដាកម្មដ្ឋានទាំង ៣០ ដែលបាននាំមកបានដល់ **អប្បដាឈាន** នោះកម្មដ្ឋាន ១១ គឺ **កសិណ** ១០. អានាបានស្សតិ ១ មានអំណាចឲ្យសម្រេចបានតាំងអំពី បឋមជ្ឈាន រហូតដល់ចតុត្ថជ្ឈាន បើ ឈានចតុក្កន័យ បើជាបញ្ចកន័យវិញ រហូតដល់ បញ្ចមជ្ឈាន ។ កម្មដ្ឋាន ១១ទៀតគឺ អសុភ ១០. កាយគតាសតិ ១។

មានអំណាចឲ្យសម្រេចត្រឹម បឋមជ្ឈាន ប៉ណ្ណោះ ។ **ព្រហ្មវិហារ ៣** ខាងដើម គឺ **មេត្តា** ១, **ករុណា** ១, **មុទិតា** ១, មានអំណាចឲ្យសម្រេចបានតាំងពីបឋម្ឈាន រហូតដល់ តតិយជ្ឈាន បើ ឈានចតុក្កន័យ បើជាបញ្ចកន័យរហូតដល់ចតុត្ថជ្ឈាន ព្រហ្មវិហារទី ៤ គឺឧបេក្ខា ១ និងអារុប្ប ៤ ត្រូវជា ៥ មានអំណាចឲ្យសម្រេច ដល់ ចតុត្ថជ្ឈាន ក្នុង ចតុក្កន័យ ឬ បញ្ចមជ្ឈាន ក្នុង បញ្ចកន័យតែម្តង តែថា ឧបេក្ខា ព្រហ្មវិហារ ឲ្យសម្រេចខាង រូបជ្ឈាន ឯ អារុប្ប ៤ ឲ្យសម្រេចខាង អរូបជ្ឈាន។

៤- **សមតិក្កម** កម្មដ្ឋានដែលកន្លងអង្គនិងកន្លងអារម្មណ៍ ត្រង់ **សមតិក្កម** ទី ៤ ដែលថាត្រូវឲ្យដឹងវិធីប្រព្រឹត្តកន្លងរបស់កម្មដ្ឋាននោះគឺ ត្រូវឲ្យ ដឹងថា:

វិធីប្រព្រឹត្តកន្លងរបស់កម្មដ្ឋានមាន ២ យ៉ាងគឺ:

១- **អង្គសមតិក្កម:** ប្រព្រឹត្តកន្លងនូវអង្គ ។

២- **អារម្មណសមតិក្កម:** ប្រព្រឹត្តកន្លងនូវអារម្មណ៍ ។

កម្មដ្ឋានដែលមានអំណាចឲ្យសម្រេចបានតាំងអំពី **បឋមជ្ឈាន** ដរាបដល់ **តតិយជ្ឈាន** និងកម្មដ្ឋានដែលមានអំណាចឲ្យសម្រេចបានតាំងពី **បឋមជ្ឈាន** ដរាបដល់ **ចតុត្ថជ្ឈាន** នោះ រមែងប្រព្រឹត្តកន្លងនូវអង្គ ព្រោះយោគាវចរនឹងចូល ដល់ឈានជាន់លើ លុះតែកន្លងអង្គរបស់ឈានជាន់ក្រោម មានវិតក្កៈនិងវិចារៈជា ដើមទៅជាលំដាប់ទើបចូលបាន ឯឧបេក្ខាព្រហ្មវិហារ ទៀតសោតក៏ដូចគ្នា ព្រោះ

យោគាវចរនឹងចូលទៅដល់បានលុះតែកន្លងនូវអង្គ សោមនស្សរបស់មេត្តាព្រហ្មវិហារជាដើម **អារុប្បកម្មដ្ឋាន**ទាំង ៤ រមែងប្រព្រឹត្តកន្លងនូវអារម្មណ៍ គឺ**អារុប្បជី ១** ប្រព្រឹត្តកន្លងកសិណទាំង ៩ ក្រៅអំពី**អាកាសកសិណ**ចេញ **អារុប្ប ៣** ខាងចុង ប្រព្រឹត្តកន្លងនូវអារម្មណ៍មានអាកាសជាដើម ព្រោះយោគាវចរដែលមានប្រាថ្នានឹងចូលកាន់ឈានក្នុងកម្មដ្ឋានទាំង ៤ នេះ លុះតែប្រព្រឹត្តកន្លងនូវអារម្មណ៍ដូចពោលមកហើយ យ៉ាងនេះទើបអាចចូលដល់បាន ។

៥- **វឌ្ឍនាវឌ្ឍនៈ** កម្មដ្ឋានដែលគួរចម្រើន និងមិនគួរចម្រើនបន្ថែម ត្រង់វឌ្ឍនាវឌ្ឍនទី ៥ នេះ ដែលថាត្រូវដឹងកម្មដ្ឋាន ដែលគួរចំរើនបន្ថែម និងកម្មដ្ឋានដែលមិនគួរចម្រើនបន្ថែមនោះ គឺត្រូវដឹងថា:

ក្នុងកម្មដ្ឋានទាំង ៤០ កាលបើព្រះយោគាវចរ បានចម្រើនឲ្យសម្រេចគុណវិសេសដល់ទីបំផុតរបស់កម្មដ្ឋាននោះៗ ហើយ បើមានប្រាថ្នានឹងចម្រើនបន្ថែមឲ្យកើតឡើងទៀត គប្បីចម្រើនតែក្នុងកសិណទាំង ១០ ប៉ុណ្ណោះ ព្រោះថាកសិណទាំង ១០ នោះ បើផ្សាយទៅកាន់ទីឱកាសត្រឹមណា ក៏អាចនឹងស្ដាប់សម្លេងដោយទិព្វសោតធាតុ មើលរូបឃើញដោយទិព្វចក្ខុ ដឹងចិត្តសត្វដទៃដោយបរចិត្តវិជ្ជាក្នុងទីឱកាសត្រឹមណោះបាន ឯកម្មដ្ឋានដទៃទៀតមិនគួរចម្រើនបន្ថែម ឲ្យកើតទៅទៀតទេ ព្រោះមិនមានអានិសង្សឲ្យបានដល់ទិព្វសោតធាតុ និងទិព្វចក្ខុជាដើម ដូចជាកសិណ ១០ នោះឡើយ ។

៦- **អារម្មណា** អារម្មណ៍របស់កម្មដ្ឋាន

ត្រង់អារម្មណ៍ទី ៦ នេះ ដែលថាត្រូវឲ្យដឹងអារម្មណ៍របស់កម្មដ្ឋាននោះ គឺត្រូវឲ្យដឹងថា **កម្មដ្ឋាន** ២២ គឺ **កសិណ** ១០, **អសុភ** ១០, **អានាបានស្សតិ** ១, **កាយគតាសតិ** ១, កាន់យកបដិភាគនិមិត្តជាអារម្មណ៍បាន. កម្មដ្ឋានក្រៅពីនោះ ១៨ កាន់យកបដិភាគនិមិត្តមកជាអារម្មណ៍មិនបានឡើយ ។ **កម្មដ្ឋាន** ១២ គឺ **អនុស្សតិ** ៨ លើក **អានាបានស្សតិ** និង**កាយគតាសតិ**ចេញ និង **អាហារេបដិក្កូល សញ្ញា** ១, **ចតុធាតុវវត្ថាន** ១, **វិញ្ញាណញ្ចាយតនៈ** ១, **នេវសញ្ញានាសញ្ញាយតនៈ** ១ កាន់យកសភាពធម៌មកជាអារម្មណ៍ ។

**កម្មដ្ឋាន** ២២ គឺ**កសិណ** ១០. **អសុភ** ១០ **អនាបានស្សតិ** ១. **កាយគតាសតិ** ១ កាន់យកនិមិត្តមកជាអារម្មណ៍. **កម្មដ្ឋាន** ៦ គឺ**ព្រហ្មវិហារ** ៤, **អាកាសានញ្ចាយតនៈ** ១ **អាកិញ្ចញ្ញាយតនៈ** ១ កាន់យកអារម្មណ៍ពោលកំណត់មិនបាន ។ **កម្មដ្ឋាន** ៨ គឺ**វិបុព្វកាសុភ** ១. **លោហិតកាសុភ** ១. **បុឡុវកាសុភ** ១ **អានាបានស្សតិ** ១ **អាបោកសិណ** ១ **តេជោកសិណ** ១ **វាយោកសិណ** ១. **អាលោកកសិណ** ត្រង់ដែលសម្លឹងយកមណ្ឌលរស្មីនៃព្រះអាទិត្យជាដើម មកជាអារម្មណ៍ ១ មុននឹងកើតនូវបដិភាគនិមិត្ត អារម្មណ៍ញ័រដល់បដិភាគនិមិត្តកើត អារម្មណ៍ស្ងប់មិនកម្រើក. កម្មដ្ឋានសល់អំពីនោះ ២២ មាន អារម្មណ៍ស្ងប់ឥតកម្រើក ។

**៧- ភូមិ** ភូមិរបស់កម្មដ្ឋាន

ត្រង់ភូមិទី ៧ នេះ ដែលថាត្រូវដឹងភូមិរបស់កម្មដ្ឋាននោះ គឺត្រូវឲ្យដឹងថា**កម្មដ្ឋាន** ១២ គឺ **អសុភ** ១០, **កាយគតាសតិ** ១, **អហារេបដិកូលសញ្ញា** ១ ប្រព្រឹត្តទៅក្នុងទេវលោកមិបាន[72] ។ **កម្មដ្ឋាន** ១៣ **គឺអសុភ** ១០, **កាយគតាសតិ** ១, **អនាបានស្សតិ** ១ ប្រព្រឹត្តទៅព្រហ្មលោកមិនបាន[73] កម្មដ្ឋានដទៃក្រៅអំពី**អារុប្បកម្មដ្ឋាន**ទាំង ៤ ចេញ ប្រព្រឹត្តទៅក្នុងអរូបភពមិនបាន[74] ឯក្នុងមនុស្សលោកប្រព្រឹត្តទៅបានទាំង ៤០ ។

**៨- គហណៈ** កិច្ចដែលត្រូវរៀនយកនូវកម្មដ្ឋាន

ត្រង់គហណៈ ទី ៨ នេះ ដែលត្រូវដឹងកិច្ចដែលត្រូវរៀនយកកម្មដ្ឋាននោះ គឺត្រូវឲ្យដឹងថា **កម្មដ្ឋាន** ១៩ គឺ **កសិណ** ៩ លើកវាយោកសិណចេញ និង**អសុភ** ១០ ត្រូវរៀនយកតាមដែលមើលឃើញខ្លះ តាមដែលស្តាប់ឮខ្លះ **អានាបានស្សតិ** ត្រូវរៀនយកខ្យល់ **អស្សាសបស្សាសៈ** ដែលពាល់ត្រូវចន្លោះកាយអំពីខាងក្នុង **វាយោកសិណ** ត្រូវរៀនយកតាមដែលមើលទៅឃើញខ្យល់បក់កម្រើកស្លឹកឈើខ្លះ បក់មកប៉ះពាល់ត្រូវកាយរបស់ខ្លួនខ្លះ កម្មដ្ឋានដែលសល់ពីនេះ ១៨ ត្រូវរៀនយកតាមដោយស្តាប់ឮអាចារ្យពន្យល់ប្រាប់កម្មដ្ឋាន ៥ គឺ **ឧបេក្ខាព្រហ្មវិហារ**១.

---

[72] ព្រោះភពទាំងនោះមិនមានអារម្មណ៍បែបនេះ ដែលល្មមនឹងចម្រើនបាន ។

[73] ៧៤ ព្រោះភពទាំងនោះមិនមានអារម្មណ៍បែបនេះ ដែលល្មមនឹងចម្រើនបាន ។

អារុប្យ ៤ ព្រះយោគាវចរកុលបុត្តដែលជា អាទិកម្មក[75] មិនត្រូវរៀនឡើយ ត្រូវរៀនតែកម្មដ្ឋាន ៣៥ ក្រៅពីនេះ ។

## ៩- បច្ចយ បច្ច័យរបស់កម្មដ្ឋាន

ត្រង់បច្ចយៈទី ៩ នេះ ដែលថា ត្រូវឲ្យដឹងនូវបច្ច័យរបស់កម្មដ្ឋាននោះគឺ ត្រូវឲ្យដឹងថា កសិណ ៩ ក្រៅអំពីអាកាសកសិណចេញ ជាបច្ច័យរបស់អារុប្យកម្មដ្ឋាន ៤, កសិណគ្រប់ទាំង ១០ ជាបច្ច័យរបស់ អភិញ្ញា៥, ព្រហ្មវិហារធម៌ ៣ ជាន់ក្រោយជាបច្ច័យដល់ ព្រហ្មវិហារធម៌ទី ៤, អារុប្យជាន់ក្រោមៗ ជាបច្ច័យដល់អារុប្យជាន់លើៗ នេវសញ្ញានាសញ្ញាយតនៈ ជាបច្ច័យដល់និរោធសមាបត្តិ កម្មដ្ឋានគ្រប់ទាំង ៤០ ជាបច្ច័យឲ្យព្រះខីណាស្រពនៅជាសុខក្នុងបច្ចុប្បន្ន, ជាបច្ច័យដល់វិបស្សនា បើយោគីចម្រើនមិនបានត្រាស់ដឹងគុណវិសេសអ្វីជាន់ខ្ពស់ក្នុងបច្ចុប្បន្នជាតិ ក៏គង់ជាបច្ច័យឲ្យកើតសម្បត្តិក្នុងភព ។

## ១០- ចរិយានុកូល កម្មដ្ឋានដែលសមគួរដល់ចរិត

ត្រង់ចរិយានុកូលទី ១០ នេះ ដែលថាត្រូវឲ្យដឹងកម្មដ្ឋាន ដែលសមគួរដល់ចរិតនោះ គឺត្រូវដឹងថា កម្មដ្ឋាន ១១ គឺអសុភ ១០, **កាយគតាសតិ ១** សមគួរដល់បុគ្គលជា **រាគចរិត**. កម្មដ្ឋាន ៨ គឺព្រហ្មវិហារ៤, **វណ្ណកសិណ ៤ គឺនីលកសិណ ១, បីតកសិណ ១, លោហិតកសិណ ១, ឱទាតកសិណ ១.**

[75] កុលបុត្តដែលមិនធ្លាប់សន្សំទុកមកអំពីអតីតជាតិ ទើបតែនឹងប្រារព្ធក្នុងបច្ចុប្បន្នជាតិនេះជាដំបូង ឬដែលមិនទាន់ចម្រើនកម្មដ្ឋានឯទៀតនៅឡើយ ។

សមគួរដល់ជា ទោសចរិត, អនុស្សតិ ៦ ខាងដើម គឺ ពុទ្ធានុស្សតិ ១, ធម្មានុស្សតិ ១, សង្ឃានុស្សតិ ១, សីលានុស្សតិ ១, ចាគានុស្សតិ ១, ទេវតានុស្សតិ ១ សមគួរដល់បុគ្គលជាសទ្ធាចរិត, កម្មដ្ឋាន ៤ គឺមរណានុស្សតិ ១, ឧបសមានុស្សតិ ១ ចតុធាតុវវដ្ឋាន ១, អាហារេបដិកូលសញ្ញា ១ សមគួរដល់បុគ្គលពុទ្ធិចរិត. កម្មដ្ឋានសល់អំពីនោះ ១០ គឺ បឋវីកសិណ ១, អាបោកសិណ ១, តេជោកសិណ ១, វាយោកសិណ ១, អាកាសកសិណ ១, អាលោកកសិណ ១, អារុប្ប ៤ សមគួរដល់បុគ្គលគ្រប់ចរិតទាំងអស់ តែបើបុគ្គលជា វិតក្កចរិត ត្រូវធ្វើវង់កសិណឲ្យតូច បើ មោហចរិត ត្រូវធ្វើវង់កសិណឲ្យធំ ទើបបានជាទីសប្បាយ ។

## បច្ច័យរបស់ទបស្សនា

ក្នុងវិសុទ្ធិមគ្គភាគ ២ ត្រង់អាការទី ៩ ដែលពោលអំពីបច្ច័យរបស់កម្មដ្ឋាននោះ មានសេចក្ដីថា:

*សព្វានិបិ សុខវិហារវិបស្សនាភវសម្បត្តីនំ:* បានសេចក្ដីថា: កម្មដ្ឋានគ្រប់ទាំងអស់ជាបច្ច័យ ឲ្យព្រះខីណាស្រពគង់នៅជាសុខក្នុងបច្ចុប្បន្ន ជាបច្ច័យដល់ វិបស្សនា និងជាបច្ច័យដល់សម្បត្តិក្នុងលោក ។ កម្មដ្ឋានជាបច្ច័យ ឲ្យព្រះខីណាស្រពគង់នៅជាសុខក្នុងបច្ចុប្បន្នក្ដី និងជាបច្ច័យដល់សម្បត្តិក្នុងលោក របស់យោគាវចរដែលចម្រើនកម្មដ្ឋាន មិនទាន់បានត្រាស់ដឹងនូវឧត្តរធម៌ឰដ៏ខាងលើក្តី លើកទុកចុះមិនពោល សូមលើកឡើងពោលអំពីកម្មដ្ឋានជាបច្ច័យដល់ វិបស្សនា ប៉ុណ្ណោះក្នុងទីនេះ ។

**កម្មដ្ឋាន** ទាំង ៤០ ដូចបានពោលមកហើយខាងដើម ក្នុងអាការទី១ កម្មដ្ឋានណាមួយ ដែលយោគាវចរចម្រើនបានសម្រេចនូវគុណវិសេសដល់ថ្នាក់ត្រឹមអានុភាពនៃកម្មដ្ឋាននោះៗ ហើយក៏សុទ្ធតែអាចបន្សាត់ចេញនូវកិលេសមាននីវរណធម៌ជាដើមដែលជាគ្រឿងគ្របសង្កត់ចិត្ត ធ្វើឲ្យសតិនិងបញ្ញាដែលជាអ្នកកំណត់ដឹង នឹងចាក់ធ្លុះនូវសភាវៈជាបរមត្ថ ដែលជាអារម្មណ៍របស់**វិបស្សនា**បានទាំងអស់ ។ យោគាវចរ ដែលជាអ្នកចម្រើននូវវិបស្សនា ដែលមិនបានចាក់ធ្លុះនូវសភាវៈធម៌តាមពិតនោះក្នុងសាសនានេះ ក៏មកតែអំពីសតិ និងបញ្ញាចេះតែរលត់ទៅដោយអំណាចនៃកិលេស ចេះតែគ្របសង្កត់ចិត្តរឿយៗ ហ្នឹងឯង ។ កិលេសទាំងឡាយមាន**កាមច្ឆន្ទៈ**ជាដើម ដែលកើតឡើងហើយគ្របសង្កត់ចិត្ត ដែលនឹងអាចទ្រោមចុះទៅវិញបាននោះ ក៏ដោយសារយោគាវចរចម្រើនអប់រំចិត្តដោយកម្មដ្ឋានណាមួយមែនពិត កាលបើចិត្តស្ងប់ចាកកិលេសជាគ្រឿងសៅហ្មងហើយ យោគាវចរប្រាថ្នាដើម្បីចម្រើនវិបស្សនា ពេលនោះសតិនិងបញ្ញាក៏ធ្វើការរលឹកពិចារណា បានកំណត់ដឹង និងចាក់ធ្លុះនូវសភាវធម៌ជាបរមត្ថបានភ្លាមៗ មួយរំពេច ព្រោះសេចក្ដីដែលបានពោលមកហើយហ្នឹងឯងទើបលោកពោលថា កម្មដ្ឋានទាំង ៤០ ជាបច្ច័យដល់ **វិបស្សនា** ។

**សមថធម៌** មិនមែនជា**វិបស្សនាធម៌** **សមថធម៌**ផ្សេង **វិបស្សនាធម៌**ផ្សេងដោយឡែកពីគ្នា មិនច្រឡំគ្នាមែនពិត តែថា**សមថធម៌**ជាបច្ច័យដល់**វិបស្សនាធម៌** កាលបើចិត្តមិនស្ងប់ចាកកិលេសហើយ ចម្រើន**វិបស្សនា** ក៏មិនបានសម្រេចឡើយ ព្រោះហេតុអ្វី?

ព្រោះថា កាលបើកិលេសកំពុងគ្របសង្កត់ចិត្តហើយ **សតិ** និង **បញ្ញា** អ្នកចម្រើនបញ្ញា (វិបស្សនា) ក៏រលត់ កាលបើ **សតិ** និង **បញ្ញា** រលត់ហើយ ឈ្មោះថាយោគាវចរបានត្រាស់ដឹងនូវ ***វិបស្សនាបញ្ញា*** ដូចម្ដេចកើត គឺត្រូវតែរលត់អត់បានសម្រេចនូវ***វិបស្សនាបញ្ញា***ហ្នឹងឯង ដូច្នេះហើយ ទើបលោកពោលថា **កម្មដ្ឋាន** ទាំងអស់ជាបច្ច័យដល់ ***វិបស្សនា*** ។

## ការរៀនយកនូវកម្មដ្ឋាន

កុលបុត្តដែលជា ***អាទិកម្មិក*** ដែលត្រូវប្រតិបត្តិសិក្សាក្នុងការអប់រំទូន្មានចិត្តថ្នាក់ដំបូងគួររៀនប្រតិបត្តិក្នុងកម្មដ្ឋាន តាមសមគួរដល់ចិត្តរបស់ខ្លួនឬថាតាមសមគួរដល់អធ្យាស្រ័យ ដែលខ្លួនធ្លាប់អប់រំសន្សំទុកនូវអារម្មណ៍ក្នុងអតីតជាតិ ។

## ចរិត

លំនាំប្រព្រឹត្តជាប្រក្រតី ឬ សំណាមវាសនា ដែលធ្លាប់សន្សំអប់រំទុកមកពីអតីតជាតិ ហើយមកផុសផុលឡើងក្នុងសន្ដានដោយច្រើន ក្នុងបច្ចុប្បន្នជាតិនេះហៅថា **ចរិត** ចែកដោយសង្ខេបមាន ៦ យ៉ាង[76] គឺ:

១- ***រាគចរិត:*** លំនាំរាគ:គឺច្រើនដោយសេចក្ដីតម្រេក ។

២- **ទោសចរិត:** លំនាំទោស:គឺច្រើនដោយសេចក្ដីប្រទូស្ត ។

៣- **មោហចរិត:** លំនាំមោហ:គឺច្រើនដោយសេចក្ដីវង្វេង ។

---

[76] ក្នុងអភិធម្មត្ថវិភាវិនី លោកសម្ដែងចរិតដោយពិស្ដារ មានដល់៦៣ អាចារ្យខ្លះថាមានដល់ ៦៤ ។

៤- **សទ្ធាចរិតៈ** លំនាំសទ្ធាគឺច្រើនដោយសេចក្ដីជឿ ។

៥- **ពុទ្ធិចរិតៈ** លំនាំប្រាជ្ញាគឺច្រើនដោយសេចក្ដីចេះដឹង ។

៦- **វិតក្កចរិតៈ** លំនាំវិតក្កគឺច្រើនដោយសេចក្ដីត្រិះរិះ ។

## សេចក្ដីបំភ្លឺអំពីបុគ្គល ៦ ពួកតាមចរិត

បុគ្គលក្នុងលោកបំព្រួញមកមានតែ ៦ ពួក បានឈ្មោះតាមចរិតទាំង ៦ នេះឯង គឺតាមដោយចរិតណាមួយផុសផុលឡើងក្នុងសន្ដានច្រើន ត្រូវសម្គាល់ដឹងបានថាបុគ្គលនេះជារាគចរិត ឬជាចរិតណាមួយនោះ ដោយពិនិត្យសង្កេតមើលឥរិយាបថ សង្កេតមើលស្នាដៃធ្វើការងារ សង្កេតមើលកិរិយាបរិភោគភោជន សង្កេតមើលកិរិយាក្រឡេកឃើញរូបជាដើម សង្កេតមើលធម៌ ដែលប្រព្រឹត្តទៅក្នុងសន្ដាន ។

- បុគ្គលដែល **រាគចរិត** ដំណើរដើរជាប្រក្រតី ទ្រង់រំពាស់ ញ៉េងញ៉ង លើកដាក់ជើងស្មើ ទ្រង់ថ្នមៗ ផ្ទៃបាតជើងផត ដានជើងកំពង់កណ្ដាល ជំហរនិងអង្គុយទ្រង់សុភាពរម្យទមគួរឲ្យជ្រះថ្លា តាក់តែងទីដំណេកស្មើៗ មិនរណ្ដូងរណាង ប្រមូលអវយវៈតូចធំឲ្យមូលគ្នាទើបប្រាសខ្លួនដេក ពេលក្រោកក៏សន្សឹមៗ និយាយពាក្យទ្រង់ស្រទន់ ធ្វើការងារច្រើនស្អាត ស្លៀកពាក្យច្រើនបរិមណ្ឌលទំពាហ្មត់ទើបលេប បានអ្វីបន្តិចបន្តួចឆាប់ត្រេកអរ ឃើញរូបល្អ ឮសំឡេងពីរោះ ជាដើម ឆាប់ជាប់ចិត្ត ខំសម្លក់ ឬផ្ទៀងស្ដាប់អស់កាលយូរ ផ្គាប់ផ្គុនបន្តិចបន្តួច ឆាប់គាប់ចិត្ត មិនសូវប្រកាន់ទោសគេ ចេញដើរទៅណាច្រើនអាល័យទីកន្លែង មានធម៌ប្រព្រឹត្តនៅក្នុងសន្ដានច្រើនបិទបាំងទោសខ្លួន ច្រើនអំនួត ច្រើនប្រកាន់ខ្លួនច្រើនប្រាថ្នាលាមក ច្រើនប្រាថ្នាធំ មិនសន្ដោស ច្រើនក្រអឺតក្រទមឆ្មើងឆ្មៃ ។

- បុគ្គលដែលជា **ទោសចរិត** ដើរដំណើរទ្រង់កាយដីដោយចុងម្រាម លើកដាក់ជើងរហ័ស និយាយសម្តីទ្រង់ដូចជាខឹង ធ្វើការងារដៃធ្ងន់មិនស្អាត ស្លៀកដណ្តប់ច្រើនរឹតណែន មិនបរិមណ្ឌល ច្រើនពេញចិត្តបរិភោគភោជនដែលសៅហ្មងនិងម្ជូរ បរិភោគធ្វើឲ្យទូញផ្តាល់ ឆាប់លេបមិននូវទំពាឲ្យហ្មត់ បានអ្វីមិនល្អឆាប់តូចចិត្ត ឃើញរូបឬស្តាប់សំឡេងមិនជាទីតម្រេក ចិត្តទ្រង់ដូចជាលំបាកណាស់ សំឡឹងឬស្តាប់មិនបានយូរ ឆាប់ប្រកាន់ទោសគេ ផ្តាប់ផ្តួនមិនសូវគាប់ចិត្ត ចេញដើរទៅទីណាមិនមានអាល័យទីកន្លែង មានធម៌ប្រព្រឹត្តទៅក្នុងសន្តានច្រើនក្រោធ ច្រើនសន្សំរឿងទុក ច្រើនបំភ្លេចគុណគេ ច្រើនលើកខ្លួនផ្ទឹមស្មើនឹងលោកអ្នកធំ ច្រើនច្រណែន ច្រើនកំណាញ់ ។

- បុគ្គលដែលជា **មោហចរិត** ដើរដំណើរទ្រង់រទ្បេមរទ្បាម លើកដាក់ជើងទ្រង់ដូចជាភ័យ ដានជើងធ្ងន់ខាងក្រោយ ជំហរនិងបង្គុយមានអាការទ្រង់រីករវខ្ជីខ្ជា រៀបចំដំណេកមានសណ្ឋានមិនល្អ ប្រាសខ្លួនដេកច្រើនច្រងេងច្រងាង ច្រើនដេកផ្កាប់មុខ គេដាស់ច្រើនថ្ងូរហ៊ឺះៗ ក្រោកឃើតធ្វើការងារចាប់កាន់ធូរៗ គ្រវីសគ្រវាស លំៗ ច្បោលៗ ស្លៀកដណ្តប់ទ្រង់រយីករយាកខ្ជីខ្ជាតាមបាន ពេញចិត្តបរិភោគមិនទៀង ម្តងនេះម្តងនោះ បរិភោគធ្វើពំនូតបាយតូចៗ ចោលគ្រាប់បាយរោយរាយក្នុងភាជន៍ ច្រើនបរិភោគធ្វើប្រឡាក់មាត់ ច្រើនបរិភោគមានចិត្តរាយមាយ គិតពីនេះពីនោះបណ្តើរ ឃើញរូប ឬស្តាប់សំឡេងជាដើមច្រើនបណ្តោយតាមគេ បើគេនិន្ទាក៏និន្ទាតាម បើគេសរសើរ

ក៏សរសើរតាម បើម្នាក់ឯងច្រើនព្រងើយៗ មានធម៌ប្រព្រឹត្តក្នុងសន្តានច្រើន ធុញទ្រាន់ងុយដេក មានចិត្តអណ្តែតអណ្តូង ច្រើនក្តៅក្រហាយស្តាយក្រោយ ច្រើនសង្ស័យ ប្រកាន់ត្រង់ណាមាំត្រង់ណោះ លះបង់បានក្រ ។

ឯបុគ្គលដែលជា *សទ្ធាចរិត ពុទ្ធិចរិត* និង *វិតក្កចរិត* ឥរិយាបថស្មាដៃធ្វើការងារ កិរិយាបរិភោគភោជន កិរិយាក្រឡេកមើលរូបជាដើម មានទំនងប្រហែលៗ គ្នា និង ចរិត ៣ ខាងដើមដែរ គឺ *សទ្ធាចរិត* ប្រហែលគ្នានឹង *រាគចរិត ពុទ្ធិចរិត* ប្រហែលគ្នានឹង *ទោសចរិត វិតក្កចរិត* ប្រហែលគ្នានឹង *មោហចរិត* តែបើទុកណាជាយ៉ាងនោះក៏គង់មានលំនាំផ្សេងគ្នាខ្លះ តួយ៉ាងដូច *រាគចរិត*តែងស្វែងរកវត្ថុកាម មិនលះបង់អំពើឥតប្រយោជន៍ ឯ*សទ្ធាចរិត* តែងស្វែងរកសីលាទិគុណ មិនលះបង់អំពើដែលមានប្រយោជន៍, *ទោសៈ* ក្នុងពួកខាងអកុសលមិនមានស្នេហាជាប់នៅក្នុងអារម្មណ៍ តែងស្វែងរកទោសដែលមិនពិត ប្រព្រឹត្តទៅដើម្បីវៀរបង់នូវសត្វ **ឯពុទ្ធិ** គឺបញ្ញាក្នុងពួកខាងកុសលមិនមានស្នេហាជាប់នៅក្នុងអារម្មណ៍ តែងស្វែងរកទោសដែលពិត ប្រព្រឹត្តទៅដើម្បីវៀរបង់នូវសង្ខារ **មោហ** តាំងនៅមិននឹងន៌ ដោយវង្វេងភាន់ តែងឃ្លេងឃ្លោង ឬឆ្លេឆ្លា ដោយគំនិតរហ័ស តែឯធម៌ដែលប្រព្រឹត្តទៅក្នុងសន្តានផ្សេងៗ គ្នាដូច្នេះគឺ

- បុគ្គលដែលជា **សទ្ធាចរិត** មានធម៌ប្រព្រឹត្តនៅក្នុងសន្តានច្រើនលះបង់បរិច្ចាគទាន ច្រើនប្រាថ្នាចង់ឃើញព្រះអរិយ ចង់ស្តាប់ព្រះសទ្ធម្ម ច្រើនដោយសេចក្តីអំណររីករាយ មិនអួតអាងខ្លួន មិនបិទបាំងទោសខ្លួន ជ្រះថ្លាក្នុងហេតុដែលគួរជ្រះថ្លា ។

បុគ្គលដែលជា **ពុទ្ធិចរិត** មានធម៌ប្រព្រឹត្តនៅក្នុងសន្តានជាអ្នកប្រដៅងាយ សេពគប់តែកល្យាណមិត្ត ដឹងប្រមាណក្នុងភោជន មានសតិសម្បជញ្ញៈ ជាអ្នកភ្ញាក់រលឹក តែងសង្វេគក្នុងហេតុដែលគួរសង្វេគ ច្រើនតាំងទុកនូវព្យាយាមដោយឧបាយប្រាជ្ញា ។

បុគ្គលដែលជា **វិតក្កចរិត** មានធម៌ប្រព្រឹត្តនៅក្នុងសន្តានច្រើនពោលតិរច្ឆានកថា លេងសើចច្រើន ត្រេកអរក្នុងពួក មិនសូវត្រេកអរក្នុងការកសាងកុសល ច្រើនកាន់ការមិនចំពោះ ពេលយប់បែកគំនិតហុយដូចផ្សែង ពេលថ្ងៃចាត់ការក្តៅក្រហាយដូចភ្លើងឆេះ គំនិតច្រើនរុះរើ ឆ្វេឆ្វានេះបន្តិចនោះបន្តិច ។

ត្រូវសម្គាល់ដឹងបានថា បុគ្គលនេះជាចរិតនេះ បុគ្គលនោះជាចរិតនោះ តាមលំអានដែលពោលមកហើយនះចុះ ។

## មូលហេតុនាំឲ្យបុគ្គលក្នុងលោកមានចរិតផ្សេងគ្នា

បុគ្គលក្នុងលោកបានជាមានចរិតផ្សេង ៗ គ្នានោះ ព្រោះកាលអតីតជាតិធ្លាប់ប្រព្រឹត្តបែបដូចនោះក៏ជិតជាប់តាមមក ឬការដែលគាត់តែងធ្វើកុសលណា ១ ក្នុងអតីតភពហើយធម៌ទាំងនោះណា ១ មានកម្លាំងក្លាតាំងនៅក្នុងសន្តាន ដល់ពេលដែលធ្វើមរណកាល បើកុសលនោះហុចបដិសន្ធិឲ្យមក សំណាមរបស់ធម៌នោះក៏ជាប់ដោយតាមមកផង ហេតុនោះទើបមនុស្សក្នុងលោកមានចរិតខុសគ្នាដូចនះឯង ។

# ការចម្រើននូវកម្មដ្ឋាននៃអាទិកម្មិកបុគ្គល

កម្មដ្ឋានដែលយោគាវចរជាអាទិកម្មិក គប្បីចម្រើនមានចំនួន ៣៥ គឺ **កម្មដ្ឋាន ៤០** ដកយក **ឧបេក្ខាព្រហ្មវិហារ** និង **អារុប្ប៤** ចេញ កម្មដ្ឋានទាំង ៣៥ នេះ គឺយោគាវចរគប្បីចម្រើនតាមសមគួរដល់ចរិតរបស់ខ្លួន ឬតាមសមគួរដល់អធ្យាស្រ័យដែលខ្លួនចូលចិត្ត ឬគាប់ចិត្តក្នុងការចម្រើន ។

យោគាវចរពួកខ្លះ មុននឹងចម្រើននូវកម្មដ្ឋាន លោកអាចារ្យជាកល្យាណមិត្តគប្បីពិនិត្យរាវរកនូវចរិតសិន តើយោគាវចរនោះ មានចរិតដូចម្ដេច **រាគចរិត** ឬ **ទោសចរិត** ជាដើម កាលបើស្គាល់ច្បាស់នូវចរិតនៃយោគាវចរនោះហើយ ទើបកំណត់នូវកម្មដ្ឋានឲ្យយោគាវចរនោះចម្រើនតទៅ ការបង្រៀននូវកម្មដ្ឋានតាមដំណើរនេះ យោគាវចរកុលបុត្រនោះក៏បានសម្រេចនូវគុណវិសេស តាមថ្នាក់មានឈានជាដើមក៏មាន តែថាការចម្រើននូវកម្មដ្ឋានតាមចរិតនៃយោគាវចរមិនមែនសុទ្ធតែបានសម្រេចទាំងអស់គ្នានោះទេ ក៏គង់មានយោគាវចរពួកខ្លះទៀតមិនបានសម្រេចនូវគុណវិសេសណាមួយ លុះត្រាតែចម្រើនកម្មដ្ឋានតាមសមគួរដល់អធ្យាស្រ័យដែលខ្លួនធ្លាប់សន្សំមកក្នុងអតីតជាតិឯណោះ ទើបបានសម្រេចនូវគុណវិសេសក៏សឹងមាន ដូចជាសទ្ធិវិហារិករបស់ព្រះសារីបុត្តជាអាទិ៍។

# សារីបុត្តត្ថេរស្ស សទ្ធិវិហារិកវត្ថុ

បានឮថា មានបុរសម្នាក់កូនជាងមាសមានរូបស្អាតដ៏ឆើត បានបួសក្នុងសំណាក់នៃព្រះសារីបុត្ត កាលបុរសនោះបួសហើយជាភិក្ខុ ក៏សូមរៀននូវកម្មដ្ឋានចំពោះព្រះថេរ ពេលនោះព្រះថេរក៏បានគិតពិចារណាពារកចរិត នៃភិក្ខុជាកូនសិស្សនោះ ក៏បានស្គាល់ច្បាស់ថា ជារាគចរិតដោយឥតសង្ស័យ ឲ្យភិក្ខុនោះចម្រើននូវ**អសុភកម្មដ្ឋាន** ដើម្បីកំចាត់បង់នូវរាគៈ ដែលកើតឡើងរឿយៗ ក្នុងសន្តាន។

ភិក្ខុនោះកាលបានទទួលយក នូវកម្មដ្ឋានអំពីព្រះថេរហើយ ក៏ចូលពួនសំងំក្នុងព្រៃដ៏ស្ងាត់ ជាអ្នកមិនប្រមាទ មានព្យាយាមយ៉ាងក្លៀវក្លា ឧស្សាហ៍ក្នុងការចំរើនកម្មដ្ឋាន គ្រប់ឥរិយាបថទាំង ៤ តែទុកជាភិក្ខុនោះ ខំប្រឹងព្យាយាមចម្រើននូវកម្មដ្ឋាននោះយ៉ាងណាក៏ដោយ ក៏មិនបានសម្រេចនូវគុណវិសេសអ្វីឡើយ សូម្បីសម្រេចត្រឹមតែ**ឯកគ្គតាចិត្ត**ប៉ុណ្ណោះក៏គ្មានផង ភិក្ខុនោះកាលបើខំប្រឹងចម្រើនកម្មដ្ឋានមិនបានសម្រេចយ៉ាងនោះហើយ ក៏វិលមកកាន់ព្រះថេរនិមន្តលោកសម្តែងកម្មដ្ឋានដទៃទៀត តែព្រះសារីបុត្តលោកយល់ជ្រាបច្បាស់ថាភិក្ខុនេះពិតជា **រាគចរិត** លោកនៅតែសម្តែង**អសុភកម្មដ្ឋាន**ឲ្យភិក្ខុជាកូនសិស្សនោះអនុវត្តដដែល ភិក្ខុនោះក៏ត្រឡប់ទៅកន្លែងដើមវិញ ខំប្រឹងព្យាយាមចម្រើនកម្មដ្ឋាននោះបន្តទៅទៀត តែទុកជាភិក្ខុនោះខំប្រឹងក្នុងការចម្រើនកម្មដ្ឋាននោះយ៉ាងណាក៏ដោយ ក៏នៅតែមិនបានសម្រេចនូវគុណវិសេសដដែល ។ ការប្រព្រឹត្តិទៅមកនៃភិក្ខុ និងនិមន្តព្រះថេរសម្តែងនូវកម្មដ្ឋានរហូតអស់វារៈ ៣ លើក ពេល

នោះព្រះថេរក៏ធ្វើការពិចារណាថា ភិក្ខុនេះពិតជាអ្នកប្រព្រឹត្តធម៌ មិនមែនខ្ជិលទេ តែភិក្ខុនេះចម្រើនកម្មដ្ឋានមិនបានសម្រេចនូវគុណនេះ មកតែអំពីអាត្មាអញ មិនស្គាល់អធ្យាស្រ័យរបស់ភិក្ខុនេះឯង ព្រះសារីបុត្តក៏ទាល់ក្នុងការបង្រៀននូវកម្មដ្ឋានចំពោះភិក្ខុនោះ ក៏នាំសិទ្ធិវិហារិករបស់ខ្លួននោះទៅថ្វាយដល់ព្រះសម្មាសម្ពុទ្ធឲ្យព្រះអង្គជួយដឹកនាំ ។ ព្រះសម្ពុទ្ធទ្រង់ស្គាល់អធ្យាស្រ័យ របស់សត្វលោកគ្មានចន្លោះ ព្រះអង្គប្រកបដោយករុណាទិគុណ ក៏ទទួលប្រោសប្រាណបានប្រទាននូវ**លោហិតកសិណកម្មដ្ឋាន**ដល់ភិក្ខុនោះ ព្រោះថាភិក្ខុនោះធ្លាប់កើតជាកូនជាងមាសអស់ ៥០០ ជាតិហើយ បានសន្សំនូវអារម្មណ៍ពណ៌មាស នោះអស់កាលដ៏យូរមកហើយ បន្ទាប់មកភិក្ខុនោះបានចម្រើននូវព្រះកម្មដ្ឋាន តាមរបៀបដែលព្រះអង្គទ្រង់ប្រទានឲ្យ ក៏បានញុំាំងនូវឈានចំនួន ៥ មានបឋមជ្ឈានជាដើមឲ្យកើតឡើងហើយតម្កល់នូវការអស់ទៅសូន្យទៅក្នុងអត្តភាព នេះចម្រើននូវ **វិបស្សនាកម្មដ្ឋាន** ដោយមានការឧបត្ថម្ភអំពីព្រះសាស្តា ក៏បានសម្រេចនូវព្រះអរហត្តផលក្នុងសាសនានេះឯងហោង រឿងនេះជាសេចក្តីសង្ខេប ឯសេចក្តីពិស្តារមានក្នុង **គម្ពីរធម្មបទដ្ឋកថា** ភាគទី ៧ ។

ការលើកឡើងនូវរឿងនេះឲ្យឃើញថា ការចម្រើននូវព្រះកម្មដ្ឋានតាមចរិតរបស់អ្នកចម្រើនកម្មដ្ឋានតែម្យ៉ាងនោះ មិនមែនសុទ្ធតែបានសម្រេចនោះទេ មិនមានសម្រេចខ្លះដែរ លុះតែចម្រើនកម្មដ្ឋានតាមអធ្យាស្រ័យគឺអារម្មណ៍ដែលខ្លួនធ្លាប់សន្សំទុកក្នុងចិត្តអស់ច្រើនជាតិហើយទើបអាចសម្រេចបាន ។

**បុច្ឆា:** ការកំណត់កម្មដ្ឋានតាមចរិតនៃយោគាវចរនោះ ដោយអាងទៅលើការសង្កេតពិនិត្យទៅលើកិច្ចការនិងឥរិយាបថជាដើមរបស់ជននោះ ចុះកាលកំណត់នូវកម្មដ្ឋាន ទៅតាមអធ្យាស្រ័យរបស់យោគាវចរនោះ តើធ្វើដូចម្ដេចទៅទើបអាចដឹងបាន?

**វិស្សជ្ជនា:** ក្នុងបញ្ហានេះជាការលំបាកយ៉ាងក្រៃលែងចំពោះអ្នកដែលធុញទ្រាន់ក្នុងការសង្កេតពិនិត្យ តែបើចូលចិត្តក្នុងការជួយស្រោចស្រង់សត្វលោកឲ្យផុតអំពីសំសារទុក គប្បីដឹងសេចក្ដីដូចតទៅនេះ មុននឹងធ្វើនូវធម៌អ្វីដែលយោគាវចរនោះគប្បីចម្រើនត្រូវស្គាល់ពាក្យថា អធ្យាស្រ័យជាមុនសិន ពាក្យថា **អធ្យាស្រ័យ** មកពីភាសាបាលីថា **អជ្ឈាសយ: អជ្ឈាសយ:** នោះមកពី **អធិ** និង **អា**បុព្វបទ + **សី** ធាតុ + **អ** បច្ច័យ ប្រែថាឆន្ទៈ ជាទីមកដេកនៃចិត្តដ៏ក្រៃលែង វិគ្គហៈថា **អាគន្ត្វា សេតិ ឯត្ថាតិ អាសយោ** ប្រែថា "ចិត្តមកដេកក្នុង**ឆន្ទ**:នោះ ដូច្នេះ**ឆន្ទ**:នោះជាទីមកដេកនៃចិត្ត" **អធិកោ អាសយោ អជ្ឈាសយោ** ប្រែថា **ឆន្ទ**:នោះជាទីមកដេកនៃចិត្តដ៏ក្រៃលែង ។ ម្យ៉ាងទៀតថា សភាវៈប្រព្រឹត្តអាស្រ័យនូវអារម្មណ៍ វិគ្គហៈថា **អារម្មណំ អធិកិច្ច សយតិ បវត្តតីតិ អជ្ឈាសយោ** ។ **ឆន្ទ**: មកពី **ឆន្ទ** ធាតុ + **អ** បច្ច័យ ប្រែថា សេចក្ដីប្រាថ្នា, សេចក្ដីប៉ុនប៉ង សេចក្ដីពេញចិត្ត ចំណង់ វិគ្គហៈថា **ឆន្ទនំ > ឆន្ទោ**

បានសេចក្ដីមកថា: **អជ្ឈាស្រ័យ** គឺជាសេចក្ដីប្រាថ្នា សេចក្ដីប៉ុនប៉ង ឬ សេចក្ដីពេញចិត្ត ឬ ថាចំណង់របស់ចិត្តដ៏ខ្លាំងក្លា ដែលចិត្តធ្លាប់សន្សំទុកមក ក្នុងកាលមុន ទៅលើអារម្មណ៍ណាមួយ តួយ៉ាងដូចជា ភិក្ខុដែលជាកូនសិស្សរបស់ព្រះសារីបុត្ត ដែលធ្លាប់សន្សំកាន់យកអារម្មណ៍ពណ៌មាសជាច្រើនជាតិណាស់មកហើយ ម្ល៉ោះហើយចិត្តរបស់ភិក្ខុនោះ រមែងចូលចិត្តក្នុងពណ៌មាសនោះដោយច្រើនយ៉ាងក្រៃលែង កាលដែលគ្រូរបស់ខ្លួនឲ្យចម្រើន**អសុភកម្មដ្ឋាន** បែរជាកន្ទះរា ពុំស្រណុកសុខសប្បាយក្នុងចិត្តសោះ ខំប្រឹងចម្រើនកម្មដ្ឋានទាំងបង្ខំចិត្ត ហេតុនោះទើបការចម្រើនកម្មដ្ឋានទាំងបង្ខំចិត្តនោះ មិនបានសម្រេចនូវលទ្ធផលអ្វីឡើយ ។ គ្រាក្រោយមក នៅពេលដែលព្រះបរមសាស្ដាចារ្យទ្រង់ប្រទាននូវ**លោហិតកសិណ** គឺកម្មដ្ឋាន ដែលមានវត្ថុពណ៌ក្រហមជាកសិណវិញ ភិក្ខុអង្គនោះដែលធ្លាប់សន្សំពណ៌ក្រហមដូចមាសនោះយូរណាស់មកហើយ គ្រាន់តែបានធ្វើទុកក្នុងចិត្តនូវពណ៌នោះ ក៏បានញ៉ាំងឈានឲ្យកើតឡើងមួយរំពេចភ្លាមពុំបានយឺតយូរឡើយ ។

នៅក្នុងគម្ពីរព្រះត្រៃបិដក មានសេចក្ដីជាច្រើន ដែលបានបញ្ជាក់អំពីរឿងអធ្យាស្រ័យរបស់សត្វទាំងឡាយថែមទៀតផង បុគ្គលពួកខ្លះមានអធ្យាស្រ័យត្រឹមតែការស្ដាប់ធម៌ទេសនាហើយ ធ្វើការពិចារណាតាមធម៌ដែលលោកសម្ដែងហើយនោះក៏មាន ចិត្តយាងចុះស៊ប់កើតបញ្ញាពិចារណានូវធម៌ កាត់បង់នូវអាសវកិលេសអស់ពីខន្ធសន្តាន បានភាពនៃខ្លួនជាព្រះអរិយបុគ្គល មាន **សោតាបន្ន**

ជាដើមក៏មាន, ខ្លះទៀតមានចិត្តតម្កល់ក្នុងសីលដ៏បរិសុទ្ធ តាំងសេចក្ដីព្យាយាមចម្រើនវិបស្សនាមានវិបស្សនាជាប្រធានតែម្យ៉ាង ក៏បានសម្រេចផលតាមអធ្យាស្រ័យនៃខ្លួនមានសោតាបន្នជាដើមក៏មាន ខ្លះទៀតស្ថិតក្នុងសីលតម្កល់ក្នុងសមាធិដ៏បរិសុទ្ធ បន្ទាប់មកក៏ចម្រើនវិបស្សនា បានសម្រេចមគ្គផលតាមថ្នាក់តាមជាន់មាន**សោតាបត្តិមគ្គ**រហូតដល់**អរហត្តផល**ក៏សឹងតែមាន ។

សូម្បីយោគី ដែលជាអ្នកចម្រើន **សមថកម្មដ្ឋាន** ដែលមានចរិតត្រូវគ្នាក៏ដោយ ក៏គង់កាន់យកប្រភេទកម្មដ្ឋានមកជាអារម្មណ៍ មានការចូលចិត្តផ្សេងគ្នាទៀត ក៏មានខ្លះដែរ ឯយោគាវចរដែលត្រូវចម្រើន**វិបស្សនាកម្មដ្ឋាន** ក៏គង់មានការកាន់យកនូវអារម្មណ៍របស់វិបស្សនាផ្សេងគ្នាដែរ អង្គខ្លះកាន់យកអារម្មណ៍បែបសង្ខេបមានសង្ខារ ឬនាមនិងរូបជាដើម អង្គខ្លះកាន់យកអារម្មណ៍បែបពិស្ដារមាន**ខន្ធ** ៥ ឬ **នាម** និង**រូប**ជាដើម អង្គខ្លះកាន់យកអារម្មណ៍បែបពិស្ដារមាន**ខន្ធ** ៥ ឬ **អាយតនៈ** ១២ ឬ **ធាតុ** ១៨ ជាដើម អង្គខ្លះមានចំណូលចូលចិត្តធ្វើការពិចារណានូវអារម្មណ៍ខាងក្រៅ ហើយប្រៀបមកអត្តភាពក្នុងនៃខ្លួនក៏មាន ។ តាមការបានពោលមកហើយទាំងប៉ុណ្ណោះ បញ្ជាក់ឲ្យឃើញថា សត្វទាំងឡាយមានអធ្យាស្រ័យផ្សេងៗ គ្នា ពុំសូវត្រូវគ្នា តែទោះជាយ៉ាងណាក៏ដោយ ការរៀននូវកម្មដ្ឋានទៅតាមចរិត ដែលលោកបានរៀបចំទុកហើយក្នុងគម្ពីរព្រះពុទ្ធសាសនា ដើម្បីអនុគ្រោះដល់អ្នកបង្រៀននិងអ្នករៀន ដែលជាអ្នកពុំសូវយល់ក្នុងរឿងអធ្យាស្រ័យរបស់សត្វលោកនោះ ក៏រមែងបានសម្រេចនូវ

គុណវិសេសជាលទ្ធផលដ៏ល្អយ៉ាងវិសេស ដែលកើតអំពីសេចក្ដីព្យាយាមក្នុងការប្រតិបត្តិធម៌នោះច្រើនយ៉ាងក្រៃលែងដោយពិត ។ ដើម្បីនឹងដឹងនូវអធ្យាស្រ័យរបស់ជនអ្នកចម្រើនធម៌ឲ្យធំ ៗ ប៉ែសនោះកុំឲ្យខុសសោះដែលប្រាកដមិនប្រែប្រួល គឺរឿងរបស់ព្រះសម្មាសម្ពុទ្ធតែម្យ៉ាង ព្រោះព្រះអង្គទ្រង់មានព្រះញាណទិព្វដ៏បរិសុទ្ធ អាចដឹងអធ្យាស្រ័យសត្វក្នុងបច្ចុប្បន្ន អតីត និងអនាគត គ្មានទើសទាក់ គ្មានចន្លោះឡើយ រីឯសាវកនៃព្រះអង្គដែលមានឈាន និងអភិញ្ញាគ្រប់គ្រាន់ អាចដឹងខ្លះមិនដឹងខ្លះ ទៅតាមអភិនិហារដែលលោកកសាង គឺលោកអ្នកដែលមាន**អភិញ្ញា**នោះ លោកអាចធ្វើការរំពឹងពិចារណារាវរកអំពីបុព្វកម្ម បានដល់ការកសាងកុសលផ្នែកខាងភាវនាកម្មណាមួយជាដើមរបស់ជនអ្នកចម្រើនកម្មដ្ឋាននោះបានខ្លះ ថាជននេះក្នុងកាលជាតិឯណោះធ្លាប់អប់រំចិត្ត ដោយចម្រើនកម្មដ្ឋានឈ្មោះនេះ ធ្លាប់ស្គាល់ហើយសន្សំនូវអារម្មណ៍បែបនេះ ដូច្នេះជាដើម បន្ទាប់មកលោកក៏ដាក់កម្មដ្ឋានឲ្យត្រូវទៅតាមចំណង់ចូលចិត្ត ដែលជននោះធ្លាប់អប់រំសន្សំទុកមកក្នុងកាលមុន ម្ល៉ោះហើយជននោះកាលបានចម្រើនកម្មដ្ឋានទៅក៏បានសម្រេចនូវគុណវិសេសដោយពិត ។

ម្យ៉ាងទៀតបើលោកគ្រូបង្រៀននោះ មិនមាន**អភិញ្ញា**សម្រាប់ដឹងអធ្យាស្រ័យរបស់ជនអ្នកចម្រើនធម៌ទេនោះ គួរធ្វើការសាកល្បងដូចតទៅនេះ

ឧទាហរណ៍ ដូចមានយោគាវចរម្នាក់ប្រកបដោយ **ទោសចរិត** ជាបុគ្គលប្រកបដោយអាការខឹងច្រើន ថ្នាំងថ្នាក់ច្រើនចំពោះអារម្មណ៍ ដែលមកប៉ះនឹង

ទ្វារ មាន**ចក្ខុទ្វារ**ជាដើម កម្មដ្ឋានដែលត្រូវយោគាវចរនោះចម្រើន មានចំនួន ៨ គឺ**វណ្ណកសិណ** ៤ និង**ព្រហ្មវិហារ** ៤ ក្នុងកម្មដ្ឋានណាមួយ ។ ក្នុងចំណោមកម្មដ្ឋានទាំងនោះ កម្មដ្ឋានខ្លះត្រូវតាមអធ្យាស្រ័យ ខ្លះមិនសូវត្រូវអធ្យាស្រ័យ កម្មដ្ឋានណាដែលត្រូវតាមអធ្យាស្រ័យ យោគាវចរអង្គនោះ កាលប្រារព្ធចម្រើននូវកមក្មដ្ឋាននោះ ក៏បានចិត្តជា**ឯកគ្គតា**ភ្លាម ដល់ពេលចម្រើនក៏អាចញ៉ាំងគុណវិសេសមានឈានជាដើមឱ្យកើតឡើងបាន បើកម្មដ្ឋានណាមិនសូវត្រូវតាមអធ្យាស្រ័យ ពេលប្រារព្ធចម្រើនក្តី កំពុងចម្រើនក្តី ចិត្តនៃយោគាវចរអង្គនោះ រាងមិនសូវរាក់ទាក់ មានចិត្តរាងកន្ទះរា មិនសូវពេញចិត្តក្នុងអារម្មណ៍ក្នុងការចម្រើនកម្មដ្ឋានក៏សឹងមាន ម្ល៉ោះហើយការចម្រើនកម្មដ្ឋានពុំសូវបានលទ្ធផលល្អឡើយ ដូច្នេះក្នុងរឿងយោគាវចរអង្គនេះ លោកគ្រូបង្រៀនកម្មដ្ឋានគួរធ្វើការសាកល្បងដូចតទៅ:

ត្រូវកំណត់ចរិតនៃយោគាវចរនោះឲ្យបាន ថាជា**ទោសចរិត**ហើយ ត្រូវសង្កេតពិនិត្យ នូវអារម្មណ៍ដែលត្រូវការដោយច្រើន នៃយោគាវចរនោះថែមទៀត តើយោគាវចរនោះ ចូលចិត្តពណ៌**ខៀវ** ឬ**លឿង** ឬ**ក្រហម** ឬពណ៌**ស** ជាដើម ដោយការឃើញឬស្តាប់ឬថាសាកសួរ ។ បើដឹងច្បាស់ប្រាកដថា យោគាវចរនោះ ចូលចិត្តពណ៌អ្វីត្រូវដាក់ពណ៌នោះទំនងហើយ ។

ម្យ៉ាងទៀត ត្រូវយោគាវចរអង្គនោះចម្រើនកម្មដ្ឋាន ដែលត្រូវតាមចរិតដោយសាកល្បងមើល ព្រោះថាយោគាវចរអង្គខ្លះ កាលដែលចម្រើនកម្មដ្ឋាន

ត្រូវទៅតាមចរិតហើយ ឧទាហរណ៍កាន់យកពណ៌**ស**ជាអារម្មណ៍ បែរជានិមិត្តប្រាកដដល់ចិត្តពណ៌**ខៀវ**ដោយច្រើនទៅវិញ ខុសចាកនិមិត្តខាងដើមស្រឡះ បញ្ហានេះហើយដែលត្រូវដឹងអធ្យាស្រ័យរបស់យោគាវចរអង្គនោះ ដូច្នេះលោកអ្នកបង្រៀនត្រូវផ្លាស់កម្មដ្ឋានឲ្យបរិកម្មទៅតាមនិមិត្ត ដែលកើតឡើងដល់ចិត្តនោះវិញ ព្រោះយោគាវចរនោះមានអធ្យាស្រ័យ សភាពបែបយ៉ាងនេះឯង ព្រោះថានិមិត្ត ដែលយោគាវចរអង្គនោះធ្លាប់សន្សំទុកមកហើយដោយច្រើន ដល់ពេលចម្រើនកម្មដ្ឋាន និមិត្តនោះតែងមានឱកាសកើតឡើងរឿយៗ ។ បើសិនជាមិនផ្លាស់ ប្រកាន់យកតែនិមិត្តខាងដើមតែម្យ៉ាង ឲ្យយោគាវចរនោះចម្រើន នឹងជាបច្ច័យនាំឲ្យយឺតយូរក្នុងការត្រាស់ដឹងនូវគុណវិសេស ។ ព្រោះហេតុអ្វី?

ព្រោះថា និមិត្តខាងដើមនេះ យោគាវចរអង្គនោះ ទើបតែចាប់ផ្ដើមរៀនបដិបត្តិជាដំបូង មិនធ្លាប់សន្សំអំពីកាលមុនមកមែនពិត ។

អធ្យាស្រ័យមាន ២ យ៉ាងគឺ អធ្យាស្រ័យចាស់ ១ អធ្យាស្រ័យថ្មី ១ អធ្យាស្រ័យចាស់ គឺចំណង់ដែលធ្លាប់សន្សំមកក្នុងកម្មដ្ឋានណាមួយ ដែលមានក្នុងអតីតជាតិ ។ អធ្យាស្រ័យថ្មី គឺចំណង់ដែលត្រូវសន្សំ ក្នុងអារម្មណ៍កម្មដ្ឋានណាៗ ដែលទើបតែចាប់ផ្ដើមរៀនក្នុងបច្ចុប្បន្នជាតិនេះ ។ រីឯចរិតដទៃមាន រាគចរិតជាដើម និងកម្មដ្ឋានដែលត្រូវចម្រើននោះ គប្បីដឹងតាមទំនងនៃពាក្យអធិប្បាយខាងដើមនេះចុះ ។

ម្យ៉ាងទៀត បើយោគាវចរនោះ មានចរិតផ្សេង ក៏គប្បីចម្រើននូវកម្មដ្ឋានតាមចរិត ឬកម្មដ្ឋានដែលត្រូវនឹងចរិតទូទៅ មាន**បឋវីកសិណ**ជាដើម កាលបើនិមិត្តណាៗ កើតឡើងដល់ចិត្តមានសភាពផ្សេងអំពីនិមិត្តនៃកម្មដ្ឋាន ដែលត្រូវលើកឡើងចម្រើននោះ ក៏គប្បីផ្លាស់កម្មដ្ឋានឲ្យទៅតាមនិមិត្តនៃកម្មដ្ឋានដែលកើតឡើងក្រោយ ក៏គួរដោយពិត ។

ម្យ៉ាងទៀតបើយោគាវចរ មិនធ្លាប់មានការកសាងក្នុងការអប់រំចិត្តក្នុងកម្មដ្ឋានណាមួយឡើយទាល់តែសោះក្នុងអតីតជាតិ ទើបតែនឹងចាប់ផ្តើមកសាងអប់រំចិត្តចម្រើនកម្មដ្ឋានក្នុងជាតិនេះតែម្យ៉ាង គប្បីចម្រើនតាមចរិតគួរ, ទុកជាបានសម្រេចគុណវិសេសក្តី មិនបានសម្រេចក្តី ក៏នឹងបានជាឧបនិស្ស័យ ដើម្បីសម្រេចនូវឧត្តរធម៌ទៅក្នុងអនាគតជាតិ ។ ម្យ៉ាងទៀតយោគាវចរពួកខ្លះសមប្រកបតែក្នុងការចម្រើននូវ**វិបស្សនាកម្មដ្ឋាន**តែម្យ៉ាង មិនមានការរាក់ទាក់ចំណូលចូលចិត្តក្នុងការចម្រើននូវ**សមថកម្មដ្ឋាន**សោះ បើសិនជាការចម្រើននូវ**វិបស្សនាកម្មដ្ឋាន** នោះបានសមប្រកប ត្រូវបានសម្រេចនូវគុណវិសេសនោះ ការចម្រើននោះជាការគួរ គប្បីចម្រើនតទៅទៀតចុះ ព្រោះត្រូវតាមអធ្យាស្រ័យរបស់យោគាវចរ ដែលបានសន្សំទុកហើយក្នុងកាលមុនមែនពិត តែបើការចម្រើន**វិបស្សនាកម្មដ្ឋាន** នោះគ្រាន់តែជាការកើតឡើងនៃចិត្ត ដោយការយល់ឃើញថាមានតែការចម្រើន**វិបស្សនាកម្មដ្ឋាន** សុទ្ធតែម្យ៉ាងទេ ដែលត្រូវបានដល់ទីរលត់ទុក្ខបានឆាប់រហ័ស តែការចម្រើននូវ**វិបស្សនាកម្មដ្ឋាន**នោះមិនបានសម្រេចនូវគុណវិសេសអ្វីសោះ

សូម្បីតែត្រឹមចិត្តជា **ឯកគ្គតា** ក៏មិនបានផង **នីវរណធម៌** មាន**កាមច្ឆន្ទៈ** ជាដើមចេះតែផុសផុលកើតឡើងរឿយៗ គ្របសង្កត់ចិត្ត គួរណាស់ត្រូវតែធ្វើសេចក្ដីចូលចិត្តក្នុងការចម្រើន**សមថកម្មដ្ឋាន**ឲ្យបានសមាធិ ដែលជាគ្រឿងធ្វើចិត្តស្ងប់រម្ងាប់ចាក**នីវរណធម៌**សិន បន្ទាប់មកសឹមចម្រើន**វិបស្សនាកម្មដ្ឋាន**ទើបគួរ ។ ព្រោះហេតុអ្វី? ព្រោះថាការអប់រំចិត្ត មិនត្រូវតាមទំនងនៃធម៌ប្រតិបត្តិ ក៏នាំឲ្យការត្រាស់ដឹង**ឧត្តរធម៌** ( ធម៌ជាន់ខ្ពស់ ) ត្រឡប់បែរទៅជាមានការយឺតយូរទៅវិញ ។

**ចរិត** សំដៅយកលំនាំ ឬស្នាមវាសនា ឬគំនូស ឬទម្លាប់ដែលបុគ្គលធ្លាប់សន្សំមកក្នុងអតីតជាតិហើយជាប់មកក្នុងខន្ធសន្តាន ក៏កើតផុសផុលឡើងរឿយៗជាប្រក្រតីក្នុងបច្ចុប្បន្នជាតិនេះ ឬនឹងហៅថាចរិយាក៏បាន ។

រីឯអធ្យាស្រ័យ សំដៅយកសេចក្ដីប៉ុនប៉ង ឬសេចក្ដីចូលចិត្ត ឬសេចក្ដីប្រាថ្នា ឬចំណង់ដ៏ក្រៃលែងដែលមានក្នុងចិត្ត ក្នុងការសន្សំនូវអារម្មណ៍ណាៗ ក្នុង អតីតជាតិ ឬក្នុងបច្ចុប្បន្នជាតិនេះ ឬថាជាសភាវៈ ដែលអាស្រ័យនូវអារម្មណ៍ទើបប្រព្រឹត្តទៅបាន ។

សេចក្ដីដែលបានអធិប្បាយមកហើយត្រឹមតែប៉ុណ្ណោះ គ្រាន់ជាគ្រឿងជួយផ្ដល់គំនិតរបស់លោកអ្នកបង្រៀន ឬរៀនប្រតិបត្តិក្នុងកម្មដ្ឋាននោះផង ដើម្បីនឹងដឹងច្បាស់នូវអធ្យាស្រ័យនៃជនអ្នកដែលត្រូវចម្រើនកម្មដ្ឋាន និងកម្មដ្ឋានដែលត្រូវចម្រើនប៉ុណ្ណោះឯង ។

# ចំណាត់ថ្នាក់ការសិក្សាសមថវិបស្សនាកម្មដ្ឋាន

ក្នុងកម្មវិធីសិក្សា **សមថវិបស្សនាកម្មដ្ឋាន**នេះ សូមចែកកិច្ចប្រតិបត្តិជា ៣ ថ្នាក់គឺ **បឋមវិបស្សនា** ១, **មជ្ឈិមវិបស្សនា** ១ និង**ឧត្តមវិបស្សនា** ។

យោគាវចរកុលបុត្តដែលត្រូវសិក្សា **វិបស្សនា** ថ្នាក់ដំបូងនោះ គប្បីចម្រើន **កម្មដ្ឋាន** ដែលខ្លួនត្រូវចម្រើននោះឲ្យបានសម្រេច ដល់គុណវិសេសថ្នាក់ **ឧបចារជ្ឈាន** សិន ។ រីឯគុណវិសេសថ្នាក់ **អប្បនាឈាន** ឡើងទៅ ទុកសម្រាប់យោគាវចរកុលបុត្តថ្នាក់ **មជ្ឈិមវិបស្សនា** និង **ឧត្តមវិបស្សនា** សិក្សាបន្តបន្ទាប់ទៅទៀតចុះ ព្រោះថាការទូន្មានចិត្តដោយការចម្រើនកម្មដ្ឋាននោះ មុននឹងបានដល់ចិត្តថ្នាក់ **អប្បនាឈាន** នោះ លុះត្រាតែបានឆ្លងកាត់ថ្នាក់ **ឧបចារជ្ឈាន** ជាមុនសិនទើបសម្រេចបាន។

- ការចាត់ថ្នាក់សិក្សា **សមថវិបស្សនាកម្មដ្ឋាន** ឲ្យមានរបៀបដូចពោលហើយនេះ ដើម្បីគ្រាន់ជាការសម្រួលក្នុងការសិក្សាប្រតិបត្តិតាមលំដាប់ចិត្ត របស់សាធុជនអ្នកប្រតិបត្តិធម៌នោះប៉ុណ្ណោះ ។ ម្យ៉ាងទៀតនឹងជួយសង្គ្រោះដល់សាធុជនដែលមានឧបនិស្ស័យត្រូវបានសម្រេចនូវគុណវិសេសត្រឹម **ឧបចារជ្ឈាន** ហើយចម្រើន **វិបស្សនា** កម្ចាត់បង់នូវកិលេស ធ្វើឲ្យជាក់ច្បាស់នូវព្រះ **និព្វាន** ។
- នឹងជួយសង្គ្រោះដល់សាធុជន ដែលមិនទាន់មានឧបនិស្ស័យក្នុងការកសាងចិត្តអំពីមុនមក ទើបតែចាប់ផ្តើមសិក្សាទូន្មានចិត្តក្នុងជាតិនេះ ដើម្បីឲ្យបានជាឧបនិស្ស័យ ជាបច្ច័យក្នុងការត្រាស់ដឹង **ឧត្តរធម៌** ក្នុងកាលខាងមុខ ។

- នឹងជួយសង្គ្រោះដល់សាធុជន ដែលត្រូវការទូន្មានចិត្តបណ្ដើរបន្ទាប់បន្សំដែលជាការទូន្មានចិត្តដំបូង ដើម្បីដកចិត្តចេញអំពីអារម្មណ៍ផ្សេងៗ មួយពេលៗ ស្ថិតនៅជាសុខក្នុងបច្ចុប្បន្នជាតិក្នុងការកសាងនូវជីវិតក្នុងសង្គមជាតិផង ។

- ក្នុងសៀវភៅច្បាប់ **បឋមវិបស្សនា** នេះ មានការលើកឡើងពោលអធិប្បាយ**កម្មដ្ឋាន**ចំនួន ៣៥ និងគុណវិសេសត្រឹមតែ**ឧបចារជ្ឈាន**ដែលកើតឡើងអំពីការចម្រើននូវកម្មដ្ឋានទាំង ៣៥ នោះប៉ុណ្ណោះ រីឯ**អប្បនាឈាន** នឹងមានពោលអធិប្បាយក្នុងសៀវភៅច្បាប់ **មជ្ឈិមវិបស្សនា** និង **ឧត្តមវិបស្សនា** ។

លំដាប់អំពីនេះទៅ នឹងសូមអធិប្បាយអំពីកិច្ចប្រតិបត្តិក្នុង **កម្មដ្ឋាន** ទាំង ៣៥ តែការអធិប្បាយក្នុងកិច្ចប្រតិបត្តិនេះ សូមលើកឡើងអធិប្បាយក្នុង**កម្មដ្ឋាន**ដែលមានអានុភាពឲ្យសម្រេចឈានតាមលំដាប់ទាបខ្ពស់ ទុកជាផ្លូវប្រតិបត្តិក្នុងព្រះពុទ្ធសាសនានោះដូចតទៅ:

កម្មដ្ឋានដែលមានអានុភាពឲ្យសម្រេចត្រឹម **ឧបចារជ្ឈាន** នោះមាន ១០ យ៉ាងគឺ: **ពុទ្ធានុស្សតិ** ១, **ធម្មានុស្សតិ** ១, **សង្ឃានុស្សតិ** ១, **សីលានុស្សតិ** ១, **ចាគានុស្សតិ** ១, **ទេវតានុស្សតិ** ១, **មរណានុស្សតិ** ១, **ឧបសមានុស្សតិ** ១, **អាហារេបដិកូលសញ្ញា** ១, **ចតុធាតុវវត្ថាន** ១ ។

## ពុទ្ធានុស្សតិ

មុននឹងពោលនូវ **កម្មដ្ឋាន** ដទៃ សូមពោលអំពី **ពុទ្ធានុស្សតិកម្មដ្ឋាន** មុនកាលបើព្រះយោគាវចរកុលបុត្រមានប្រាថ្នា ដើម្បីចម្រើននូវ **ពុទ្ធានុស្សតិកម្មដ្ឋាន**

គប្បីឲ្យមានចិត្តជ្រះថ្លាក្នុងគុណរបស់ព្រះពុទ្ធមិនឲ្យមានកម្រើក ហើយចូលទៅរកទីដែលស្ងាត់ចាកអារម្មណ៍ផ្សេងៗ តម្កល់ស្មារតីរលឹកដល់គុណរបស់ព្រះពុទ្ធថា:

**ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថាទេវមនុស្សានំ ពុទ្ធោ ភគវា ។**

បន្ទាប់មកត្រូវស្រង់យក ព្រះពុទ្ធគុណមួយៗ មករំពឹងពិចារណាបន្តទៅទៀត រីឯគុណរបស់ព្រះពុទ្ធនោះ មានដល់ ១០ ព្រះនាមដូច្នេះគឺ:

១- **សោ ភគវា ឥតិបិ អរហំ** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា "**អរហំ**" ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវ គឺកិលេសទាំងពួងផង ព្រោះព្រះអង្គបំបាក់បង់នូវកាំរបស់សំសារចក្របានផង ព្រោះព្រះអង្គមិនសម្ងំធ្វើបាបក្នុងទីស្ងាត់ផង ។

២- **សោ ភគវា ឥតិបិ សម្មាសម្ពុទ្ធោ** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា "**សម្មាសម្ពុទ្ធោ**" ព្រោះព្រះអង្គត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គឯង ។

៣- **សោ ភគវា ឥតិបិ វិជ្ជាចរណសម្បន្នោ** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា "**វិជ្ជាចរណសម្បន្នោ**" ព្រោះព្រះអង្គបរិបូរដោយ **វិជ្ជា** និង **ចរណៈ** ។

៤- សោ ភគវា ឥតិបិ សុគតោ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា "សុគតោ" ព្រោះព្រះអង្គមានដំណើរល្អផង ព្រោះព្រះអង្គមានព្រះបន្ទូលពីរោះផង ។

៥- សោ ភគវា ឥតិបិ លោកវិទូ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា "លោកវិទូ" ព្រោះព្រះអង្គជ្រាបច្បាស់នូវលោក ។

៦- សោ ភគវា ឥតិបិ អនុត្តរោ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា "អនុត្តរោ" ព្រោះព្រះអង្គប្រសើរវិសេសរកបុគ្គលណាប្រសើរជាងគ្មាន ។

៧- សោ ភគវា ឥតិបិ បុរិសទម្មសារថិ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា "បុរិសទម្មសារថិ" ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន ។

៨- សោ ភគវា ឥតិបិ សត្ថា ទេវមនុស្សានំ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា "សត្ថាទេវមនុស្សានំ" ព្រោះព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ។

៩- សោ ភគវា ឥតិបិ ពុទ្ធោ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា "ពុទ្ធោ" ព្រោះព្រះអង្គជាអ្នកភ្ញាក់រលឹកផង ជាបុគ្គលរីកផង ជាអ្នកត្រាស់ដឹងនូវ **ចតុរារិយសច្ច** ហើយញ៉ាំងអ្នកដទៃឲ្យត្រាស់ដឹងផង ។

១០- *សោ ភគវា ឥតិបិ ភគវា* ព្រះដ៏មានព្រះភាគអង្គនោះទ្រង់ព្រះនាមថា "*ភគវា*" ព្រោះព្រះអង្គមានព្រះភាគផង ព្រះអង្គជាអ្នកចែកផង, ព្រះអង្គមានជោគផង, ព្រះអង្គជាអ្នកបំបាក់បង់ផង ព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ទាក់ចោលហើយ ។

ក្នុងការពិចារណារលឹកគុណព្រះពុទ្ធ ត្រូវឲ្យដឹងសេចក្តីអធិប្បាយក្នុងគុណនោះៗ ឲ្យបានសព្វគ្រប់ផង ។ (រីឯសេចក្តីអធិប្បាយអំពីគុណទាំងនោះ គឺលោកអ្នកប្រាជ្ញបានរៀបរៀងមានក្នុងច្បាប់ត្រៃគុណជាដើម ក្នុងទីនេះមិនបានសរសេរដាក់ឡើយ សូមរកមើលផងចុះ) ។

ដោយអំណាចដែលយោគីនឹករលឹករឿយៗ នូវគុណនៃព្រះដ៏មានព្រះភាគតាមន័យដែលពោលមកហើយនេះ សម័យនោះចិត្តរបស់ព្រះយោគីសោតក៏ប្រាសចាកកិលេសគឺ *រាគៈ ទោសៈ មោហៈ* តម្កល់នៅត្រង់ចំពោះទៅរកព្រះតថាគត ព្រមទាំង **នីវរណធម៌** ក៏ទ្រោមចុះផង លំដាប់នោះ **វិតក្កៈ** និង **វិចារៈ** ក៏កើតឡើងត្រិះរិះពិចារណារឿយៗ នូវ **ពុទ្ធគុណ** មាន **អរហំ** ជាដើម ហើយបីតិក៏កើតឡើងជាបទដ្ឋានយ៉ាងនេះ **កាយបស្សទ្ធិ**និង**ចិត្តបស្សទ្ធិ** គឺសេចក្តីស្ងប់កាយនិងសេចក្តីស្ងប់ចិត្តក៏កើតឡើង បណ្តាលឲ្យព្រះយោគីប្រាសចាកសេចក្តីក្រវល់ក្រវាយស្ងប់រំងាប់យ៉ាងនេះហើយ សុខៈប្រព្រឹត្តទៅក្នុងកាយនិងចិត្តក៏កើតឡើងទៀត ពេលនោះចិត្តរបស់ព្រះយោគីក៏តម្កល់មាំក្នុងពុទ្ធគុណជាអារម្មណ៍ អង្គឈានកើតឡើងក្នុងខណៈជាមួយគ្នារៀរតាមលំដាប់ដូចនេះ តែក្នុង **ពុទ្ធានុស្សតិកម្មដ្ឋាន**

នេះមានអំណាចកើតឡើងត្រឹមតែ **ឧបចារជ្ឈាន** ប៉ុណ្ណោះ មិនអាចឲ្យកើតបានដល់ **អប្បនាឈាន** ឡើយ ព្រោះគុណរបស់ព្រះពុទ្ធជាគម្ភីរភាពក្រៃពេក ព្រះយោគីមិនអាចរលឹកឱ្យសព្វគ្រប់ទៅបាន ។

**កម្មដ្ឋាន** នេះដល់នូវកិរិយារាប់ថា **ពុទ្ធានុស្សតិ** ដូច្នេះ ព្រោះកើតឡើងដោយលំដាប់អំណាចរលឹកនូវ **ពុទ្ធគុណ** ។

## អានិសង្សនៃពុទ្ធានុស្សតិ

យោគីដែលមាន **ពុទ្ធានុស្សតិ** ប្រកបរឿយៗ ហើយជាអ្នកមានសេចក្ដីគោរពឱនលំទោនក្នុងព្រះសាស្ដាមែនពិត ថែមទាំងបាននូវ **សទ្ធា សតិ បញ្ញា** និងបុណ្យដ៏ទូលំទូលាយ, មិនត្រឹមតែប៉ុណ្ណោះ និងជាអ្នកអាចគ្របសង្កត់នូវភ័យជាពន្លឹក និងអត់សង្កត់នូវសេចក្ដីទុក្ខដែលកើតឡើង ហើយនិងបានចំពោះនូវ **សំវាសសញ្ញា** គឺសេចក្ដីសម្គាល់នៅរួមជាមួយនឹងព្រះសាស្ដាថែមទៀត, ម្យ៉ាងទៀតសូម្បីសរីរៈនៃយោគីនោះ ក៏គួរដល់កិរិយាបូជាដូចជាផ្ទះគឺចេតិយ ដែលជាទីជនអ្នកត្រូវការបុណ្យនាំគ្នាបូជា ហើយចិត្តសោតរបស់ភិក្ខុនោះរមែងឱនទេរ ទៅក្នុង **ពុទ្ធភូមិ** ។

ម្យ៉ាងទៀតយោគីនោះ ជាអ្នកហាក់ដូចជាឃើញព្រះសាស្ដា ក្នុងទីចំពោះមុខ មាន **ហិរិ** សេចក្ដីខ្មាសបាប **ឱត្តប្ប** សេចក្ដីស្លុតនឹងអំពើបាបមិនហ៊ានប្រព្រឹត្តកន្លងនូវអំពើខុសឆ្គងក្នុងធម៌វិន័យ, ប្រសិនបើមិនទាន់បានត្រាស់ដឹងនូវធម៌ជាន់ខ្ពស់ទេ នឹងមានសុគតិប្រព្រឹត្តទៅក្នុងខាងមុខដោយពិតទើបលោកចងគាថា ថា:

តស្មា ហវេ អប្បមាទំ កយិរាថ សុមេធសោ
ឯវំ មហានុភាវាយ ពុទ្ធានុស្សតិយា សទា ។

បានសេចក្ដីថា: ព្រោះហេតុនោះ យោគីអ្នកអ្នកមានប្រាជ្ញាល្អ គប្បីធ្វើនូវសេចក្ដីមិនប្រមាទតែម្យ៉ាងក្នុងកិរិយារលឹកនូវ**ពុទ្ធគុណ** ដែលមានអានុភាពធំយ៉ាងនេះឱ្យបានសព្វកាល ។

## ធម្មានុស្សតិ

កាលបើព្រះយោគាវចរកុលបុត្តមានប្រាថ្នា ដើម្បីចម្រើននូវ **ធម្មានុស្សតិកម្មដ្ឋាន** គប្បីឱ្យមានចិត្តជ្រះថ្លាក្នុងគុណរបស់ព្រះធម៌កុំឱ្យមានកម្រើក ហើយចូរទៅរកទីស្ងាត់ចាកអារម្មណ៍ផ្សេងៗ តម្កល់ស្មារតីរឭកដល់គុណរបស់ព្រះ**បរិយត្តិធម៌** និង **ព្រះធម៌លោកុត្តរធម៌** ចាប់ដើមអំពី **ស្វាក្ខាតោ ភគវតា ធម្មោ** ដរាបដល់ **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាទីបំផុត ។

បន្ទាប់មកត្រូវស្រង់យកគុណមួយៗ មករំពឹងពិចារណាឱ្យដឹងសេចក្ដីច្បាស់លាស់គ្រប់គុណនោះៗ រឹង **ធម្មគុណ** នោះមាន ៦ បទគឺ

១- **ស្វាក្ខាតោ ភគវតា ធម្មោ** ប្រែថា **ព្រះបរិយត្តិធម៌** និង **ព្រះធម៌លោកុត្តរធម៌** គឺព្រះដ៏មានព្រះភាគ ទ្រង់សម្ដែងទុកដំពីរោះ ឬដោយប្រពៃ ។

២- **សន្ទិដ្ឋិកោ** ប្រែថា ធម៌ដែល **ព្រះអរិយបុគ្គល** ឃើញច្បាស់ដោយខ្លួនឯង (បានដល់ **អរិយមគ្គ** និង **លោកុត្តរធម៌**) ។

៣- **អកាលិកោ** ប្រែថា ធម៌មិនមានកាលវេលា កាលបើ **ព្រះអរិយមគ្គ** កើតឡើងហើយ ព្រះអរិយផលក៏កើតឡើងក្នុងលំដាប់គ្នាពុំឃើតយូរឡើយ ។

៤- **ឯហិបស្សិកោ** ប្រែថា "គួរដល់ **ឯហិបស្សវិធី**" **ព្រះអរិយបុគ្គល** ដែលបានសម្រេច**មគ្គផល** ហើយ គួរនឹងហៅបុគ្គលដទៃឱ្យចូលមកមើលបាន ។

៥- **ឱបនយិកោ** ប្រែថា **ធម៌** គឺ**ព្រះអរិយបុគ្គល** គប្បីបង្អោនចូលមក ទុកក្នុងខ្លួន ដោយអំណាចនៃភាវនា ។

៦- **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ប្រែថា **ធម៌** គឺ**វិញ្ញូជន** ទាំងឡាយមាន **ឧគ្ឃដិតញ្ញូ** ជាដើម គប្បីដឹងគប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។ (ធម៌ទាំងអស់នេះ មានសេចក្តីអធិប្បាយពិស្តារក្នុងច្បាប់នៃត្រៃគុណ គឺអ្នកប្រាជ្ញលោកបានរៀបរៀងហើយ) ។

ដោយអំណាចដែលព្រះយោគីនឹករលឹករឿយៗ នូវគុណព្រះធម៌ តាមន័យដែលបានពោលមកនេះ គុណទាំងឡាយមានចិត្តដែលស្ងប់ចាកកិលេសគឺ **រាគៈ ទោសៈ មោហៈ** រហូតដល់បានសម្រេច **ឧបចារជ្ឈាន** កើតឡើងតាមលំដាប់ មានសភាពដូចក្នុង **ពុទ្ធានុស្សតិកម្មដ្ឋាន** ដែរ សូមយោគីគប្បីដឹងចុះ ។

**កម្មដ្ឋាន** នេះមានអានុភាពឱ្យសម្រេចដល់ **ឧបចារជ្ឈាន** ប៉ុណ្ណោះ មិនអាចនឹងឱ្យដល់ **អប្បនាឈាន** ឡើយ ព្រោះគុណរបស់ព្រះ **ធម៌** ជាគម្ភីរភាពក្រៃពេកព្រះយោគីមិនអាចនឹងរលឹកឱ្យបានសព្វគ្រប់បាន ។

**កម្មដ្ឋាន**នេះ ហៅថា "**ធម្មានុស្សតិ**" ព្រោះកើតឡើងដោយអំណាចនៃកិរិយារលឹករឿយៗក្នុង **ធម្មគុណ** ។

អានិសង្សនៃកិរិយារលឹកនូវ **ធម្មគុណ** យោគីដែលប្រកបក្នុង **ធម្មានុស្សតិ** រឿយៗ នឹងជាអ្នកមានសេចក្ដីគោរពកោតក្រែង ធ្វើនូវសេចក្ដីគោរពដ៏ធ្ងន់ក្នុងព្រះធម៌ ដល់នូវគុណមាន **សទ្ធាទិគុណ** ដ៏ទូលំទូលាយ ច្រើនដោយបីតិ និង **បាមោជ្ជៈ** គ្របសង្កត់នូវភ័យដ៏ពន្លឹកបាន, អាចអត់ទ្រាំនឹងទុក្ខដែលកើតឡើង ហើយបានចំពោះនូវសេចក្ដីសម្គាល់នៅរួមជាមួយព្រះ **ធម៌** មែនពិត ។

ម្យ៉ាងទៀត ឯសរីរៈរបស់យោគីនោះ នឹងគួរដល់កិរិយាបូជា ហាក់ដូចជាផ្ទះគឺព្រះ **ចេតិយ** ឯចិត្តរមែងឱនទេរទៅក្នុងកិរិយាត្រាស់ដឹងនូវ **អនុត្តរធម៌**, ហើយយោគីនោះ ជាអ្នកមាន **ហិរិ** និង **ឱត្តប្ប** មិនប្រព្រឹត្តកន្លងខុសចាក **ធម្មវិន័យ** ចិត្តនៃយោគីនោះកាលមិនទាន់ត្រាស់ដឹងនូវ **ឧត្តរធម៌** ទេ នឹងមានសុគតិប្រព្រឹត្តទៅក្នុងខាងមុខដោយពិត ។ ព្រោះហេតុនោះទើបលោកចងគាថាទុកថា

**តស្មា ហវេ អប្បមាទំ កយិរាថ សុមេធសោ**
**ឯវំ មហានុភាវាយ ធម្មានុស្សតិយា សទា ។**

បានសេចក្ដីថា: ព្រោះហេតុនោះ យោគីអ្នកមានប្រាជ្ញាល្អ គប្បីធ្វើនូវសេចក្ដីមិនប្រមាទក្នុង **ធម្មានុស្សតិ** ដែលមានអានុភាពធំយ៉ាងនេះ ឱ្យបាន សព្វកាល ។

# ៣- សង្ឃានុស្សតិ

កាលបើព្រះយោគាវចរកុលបុត្រមានប្រាថ្នា ដើម្បីចម្រើននូវ **សង្ឃានុស្សតិកម្មដ្ឋាន** គប្បីឱ្យមានចិត្តជ្រះថ្លាក្នុងគុណរបស់ព្រះសង្ឃកុំឱ្យកម្រើក ហើយចូលទៅរកទីដែលស្ងាត់ចាកអារម្មណ៍ផ្សេងៗ តម្កល់ស្មារតីរលឹកដល់គុណរបស់ព្រះ **អរិយសង្ឃ** ចាប់ផ្តើមអំពី **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ដរាបដល់ **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** ជាទីបំផុត ហើយត្រូវស្រង់យកគុណមួយៗ មករំពឹងពិចារណាឱ្យដឹងសេចក្តីច្បាស់លាស់គ្រប់គុណនោះៗ ។

## រីឯគុណព្រះសង្ឃមាន ៩ បទគឺ

១- សុបដិបន្នោ ភគវតោ សាវកសង្ឃោ ប្រែថាពួកសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយប្រពៃ ប្រតិបត្តិតាមគន្លងនៃ ព្រះនព្វលោកុត្តរធម៌ ។

២- ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ប្រែថា ពួកសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ ប្រតិបត្តិជា មជ្ឈិមាបដិបទាតាមផ្លូវប្រកបដោយអង្គ ៨ មាន សម្មាទិដ្ឋិ ជាដើម ។

៣- ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ ប្រែថា ពួកសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវ ព្រះនិព្វាន (ជាឋានក្សេមចាកទុក្ខទាំងពួង) ។

៤- សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ ប្រែថា ពួកសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់ **សាមីចិកម្ម** (ប្រតិបត្តិគួរដល់ សីល សមាធិ និង បញ្ញា) ។

# បទកំណត់នូវព្រះសង្ឃ

**យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា** បានសេចក្តីថា ព្រះសង្ឃដែលរាប់ជាគូ នៃបុរសមាន ៤ គឺលោកអ្នកដែលបានសម្រេចនូវ សោតាបត្តិមគ្គ និង សោតាបត្តិផលជាគូ ១ សកិទាគាមិមគ្គ និងសកិទាគាមិផលជាគូ ១ អនាគាមិមគ្គ និងអនាគាមិផលជាគូ ១ អរហត្តមគ្គ និងអរហត្តផលជាគូ ១ ។ បើរាប់រៀងជាបុរសបុគ្គលមាន ៨ គឺ លោកដែលបានសម្រេចនូវសោតាបត្តិមគ្គ ១, សោតាបត្តិផល ១, សកិទាគាមិមគ្គ ១, សកិទាគាមិផល ១, អនាគាមិមគ្គ ១, អនាគាមិផល ១, អរហត្តមគ្គ ១, និងអរហត្តផល ១ ។

**ឯស ភគវតោ សាវកសង្ឃោ** បានសេចក្តីថា ព្រះសង្ឃដែលបានពណ៌នាមកទាំងអម្បាលនេះ នុ៎ះជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ ។

៥- **អាហុណេយ្យោ** ប្រែថា លោកគួរទទួលនូវ **បច្ច័យ** ៤ ដែលបុគ្គលនាំមកបូជា ។

៦- **ចាហុណេយ្យោ** ប្រែថា លោកគួរទទួលនូវ **អាគន្តុកទាន** (ទានដែលបុគ្គលតាក់តែងដើម្បីញាតិ និងមិត្រដែលមកអំពីទិសផ្សេងៗ បង្អោនចូលមកបូជា) ។

៧- **ទក្ខិណេយ្យោ** ប្រែថា លោកគួរទទួលនូវ **ទក្ខិណាទាន** (ទានដែលបុគ្គលជឿនូវ **កម្ម** និង **ផល** នៃ **កម្ម** បង្អោនចូលមកបូជា) ។

៨- **អញ្ជលិករណីយោ** ប្រែថា លោកគួរដល់ **អញ្ជលិកម្ម** ដែលសត្វលោកគប្បីធ្វើ ។

៩- **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** ប្រែថា លោកជា **បុញ្ញក្ខេត្ត** នៃសត្វលោករកខេត្តដទៃក្រៃលែងជាងគ្មាន ។

(សេចក្តីពិស្តារមានក្នុងច្បាប់ត្រៃគុណ ដែលអ្នកប្រាជ្ញរៀបរៀងទុកហើយសូមរកមើលចុះ) ។

- ដោយអំណាចដែលយោគីនឹករលឹករឿយៗ នូវគុណនៃព្រះសង្ឃតាមន័យដែលពោលមកនេះ គុណធម៌ទាំងឡាយមានចិត្តដែលស្ងប់ចាកកិលេសគឺ **រាគៈ ទោសៈ មោហៈ** រហូតបានដល់ **ឧបចារជ្ឈាន** កើតឡើងតាមលំដាប់មានសភាពដូចក្នុង **ពុទ្ធានុស្សតិកម្មដ្ឋាន** ដែរ សូមព្រះយោគីគប្បីដឹងចុះ ។

**កម្មដ្ឋាន** នេះ មានអានុភាពឱ្យសម្រេចត្រឹមតែ **ឧបចារជ្ឈាន** ប៉ុណ្ណោះមិនអាចនឹងឱ្យដល់ **អប្បនាឈាន** ឡើយ ព្រោះគុណរបស់ព្រះសង្ឃ ជាគម្ភីរភាពក្រៃពេក ព្រះយោគីមិនអាចនឹករលឹកឱ្យសព្វគ្រប់ទៅបាន ។

**កម្មដ្ឋាន** នេះ ហៅថា "**សង្ឃានុស្សតិ**" ព្រោះកើតឡើងដោយអំណាចនៃកិរិយារឭករឿយៗ ក្នុង **សង្ឃគុណ** ។

## អានិសង្សកិរិយារឭកនូវសង្ឃគុណ

យោគីដែលបានប្រកបក្នុង **សង្ឃានុស្សតិ** រឿយៗ និងជាអ្នកមានសេចក្តីគោរពកោតក្រែង ធ្វើនូវសេចក្តីគោរពដ៏ធ្ងន់ក្នុងព្រះសង្ឃ ដល់នូវគុណមានសទ្ធា-

ទិគុណដ៏ទូលំទូលាយ ច្រើនដោយ **បីតិ** និង **បាមោជ្ជៈ** គ្របសង្កត់នូវភ័យដ៏ពន្លឹកបាន, អាចអត់ទ្រាំនឹងទុក្ខដែលកើតឡើងហើយ បានចំពោះនូវសេចក្ដីសម្គាល់នៅរួមជាមួយព្រះសង្ឃមែនពិត ។

ម្យ៉ាងទៀត ឯសរីរៈរបស់ព្រះយោគីនោះនឹងគួរដល់កិរិយាបូជា ហាក់ដូចជារោង **ឧបោសថ** ដែលព្រះសង្ឃមកជួបជុំគ្នា ។ ចិត្តរបស់ព្រះយោគីនោះរមែងឱនទេរទៅក្នុងកិរិយាត្រាស់ដឹងនូវ **សង្ឃគុណ** ហើយយោគីនោះជាអ្នកមាន **ហិរិ** និង **ឱត្តប្ប** មិនប្រព្រឹត្តកន្លងខុសចាកធម៌វិន័យ កាលមិនទាន់ត្រាស់ដឹងនូវ **ឧត្តរធម៌** និងមានសុគតិប្រព្រឹត្តទៅក្នុងខាងមុខដោយពិត ។

ព្រោះហេតុនោះហើយ ទើបលោកចងគាថាទុកថា

តស្មា ហវេ អប្បមាទំ    កយិរាថ សុមេធសោ
ឯវំ មហានុភាវាយ    សង្ឃានុស្សតិយា សទា ។

បានសេចក្ដីថា: ព្រោះហេតុនោះ ព្រះយោគីអ្នកមានប្រាជ្ញាល្អ គប្បីធ្វើនូវសេចក្ដីមិនប្រមាទតែម្យ៉ាង ក្នុងសង្ឃានុស្សតិ ដែលមានអានុភាពដ៏ធំយ៉ាងនេះឱ្យបានសព្វកាល ។

## សីលានុស្សតិ

កាលបើព្រះយោគាវចរកុលបុត្រមានប្រាជ្ញា ដើម្បីចម្រើននូវ **សីលា-នុស្សតិកម្មដ្ឋាន** គប្បីប្រព្រឹត្តដូចតទៅនេះ ។

ត្រូវជម្រះសីលរបស់ខ្លួនឱ្យបរិសុទ្ធ ហើយចូលទៅរកទីដែលស្ងាត់ចាកអារម្មណ៍ផ្សេងៗ តាំកល់ស្មារតីរលឹកដល់ **សីលគុណ** [77] ថា **អហោ វត មេ សីលានិ អខណ្ឌានិ អច្ឆិទ្ទានិ អសពលានិ អកម្មាសានិ ភុជិស្សានិ វិញ្ញុបសត្ថានិ អបរាមដ្ឋានិ សមាធិសំវត្តនិកានិ:** ឱ ហ្ន៎! សីលទាំងឡាយរបស់អញ មិនមានដាច់ មិនមានធ្លុះ មិនមានពពាល មិនមានពព្រុះ រួចផុតអំពីខ្ញុំរបស់ **តណ្ហា** គួរឱ្យអ្នកប្រាជ្ញមានព្រះពុទ្ធជាដើមលោកពោលសរសើរ **តណ្ហា** និង **ទិដ្ឋិ** ពាល់ត្រូវមិនបានប្រព្រឹត្តទៅព្រមដើម្បីបាននូវសមាធិ ដោយអំណាចដែលយោគីនឹករលឹករឿយៗ នូវសីលរបស់ខ្លួនតាមន័យដែល ពោលមកយ៉ាងនេះ គុណធម៌ទាំងឡាយមានចិត្តដែលស្ងប់ចាកកិលេស គឺ **រាគៈ ទោសៈ មោហៈ** រហូតបានសម្រេចដល់ **ឧបចារជ្ឈាន** កើតឡើងតាមលំដាប់មានសភាពដូចក្នុង **ពុទ្ធានុស្សតិកម្មដ្ឋាន** ដែរ សូមយោគីជ្រាបចុះ ។

កម្មដ្ឋាននេះមានអានុភាពឱ្យសម្រេចត្រឹមតែ **ឧបចារជ្ឈាន** ប៉ុណ្ណោះ មិនអាចនឹងឱ្យដល់ **អប្បនាឈាន** ឡើយ ព្រោះសីលគុណជាគម្ភីរភាពក្រៃពេកព្រះយោគីមិនអាចនឹងរលឹកឱ្យសព្វគ្រប់ទៅបាន ។

**កម្មដ្ឋាន** នេះ ហៅថា "**សីលានុស្សតិ**" ព្រោះកើតឡើងដោយអំណាចនៃកិរិយារលឹកនូវ **សីលគុណ** ។

---

[77] បើគ្រហស្ថត្រូវរលឹកដល់សីលរបស់គ្រហស្ថ បើជាអ្នកបួស ត្រូវរលឹកដល់សីលរបស់ អ្នកបួស ។

# អានិសង្សនៃសីលានុស្សតិ

យោគី ដែលបានប្រកបក្នុង **សីលានុស្សតិ** រឿយៗ នឹងជាអ្នកមានសេចក្ដីគោរពក្នុងសិក្ខា មានកិរិយាប្រព្រឹត្តិស្មើ មិនប្រមាទក្នុង **បដិសណ្ឋារៈ** ប្រាសចាកភ័យដែលកើតអំពីការតិះដៀលខ្លួនឯងជាដើម ជាអ្នកឃើញភ័យ សូម្បីក្នុងទោសបន្តិចបន្តួច តែងដល់នូវ **សទ្ធាទិគុណ** ដ៏ទូលំទូលាយ, ហើយច្រើនដោយ **បីតិ** និង **បាមោជ្ជៈ** កាលបើមិនទាន់ត្រាស់ដឹង **ឧត្តរធម៌** នឹងមានសុគតិប្រព្រឹត្តទៅខាងមុខដោយពិត ។ ព្រោះហេតុនេះ ទើបលោកចងគាថាទុកមកថាៈ

តស្មា ហវេ អប្បមាទំ    កយិរាថ សុមេធសោ
ឯវំ មហានុភាវាយ    សីលានុស្សតិយា សទា ។

បានសេចក្ដីថាៈ ព្រោះហេតុនោះ យោគីអ្នកមានប្រាជ្ញាល្អ គប្បីធ្វើនូវសេចក្ដីមិនប្រមាទតែម្យ៉ាងក្នុង **សីលានុស្សតិ** ដែលមានអានុភាពធំយ៉ាងនេះ ឱ្យបានសព្វកាល ។

# សេចក្ដីពន្យល់អំពីសីល

- **អខណ្ឌានិ** សីលមិនដាច់ ។ បានសេចក្ដីថាៈ ទុកជាសីលរបស់គ្រហស្ថក្ដី សីលរបស់បព្វជិតក្ដី ដែលមិនដាច់ គឺមិនបែកធ្លាយត្រង់សីលខាងដើម ឬសីលត្រង់ទីបំផុត ដូចជាសំពត់សាដក ដែលមិនដាច់ជាយដូច្នោះ ដូចតួយ៉ាង សីល ៥ សីលទី ១ គឺចេតនាជាហេតុវៀចាកកិរិយាញុំាងសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង

ជាសីលខាងដើម, សីលទី ៥ គឺចេតនាជាហេតុវៀចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង បានដល់សុរានិងមេរ័យ ជាសីលត្រង់ទីបំផុត ដែលមិនដាច់នោះ គឺមិនបែកធ្លាយត្រង់សីលទី ១ និងទី ៥ ហ្នឹងឯង ។

- **អច្ឆិទ្ទានិ** សីលមិនធ្លុះ ។ បានសេចក្ដីថា: មិនបែកធ្លាយត្រង់សីលចំកណ្ដាល ដូចជាសំពត់សាដក ដែលមិនធ្លុះត្រង់ពាក់កណ្ដាលសំពត់ដូច្នោះ ដូចតួយ៉ាងសីល ៥ គឺមិនបែកធ្លាយត្រង់សីលទី ៣ ហ្នឹងឯង ។

- **អសពលានិ** សីលមិនពពាល ។ បានសេចក្ដីថា: ដូចតួយ៉ាងសីល ៥ មិនបែកធ្លាយត្រង់សីល ២ ឬ ៣ តាមសំដាប់ដូចជាមេគោ មិនមានសម្បុរនៃសរីរៈ ពពាលត្រង់ទីណាមួយ ។ មេគោពពាលនោះ បានដល់មេគោដែលមានសម្បុរណាមួយ មានសម្បុរលឿងជាដើម ឆ្នូតត្រង់ពោះ ឬត្រង់សរីរៈណាមួយ មានសណ្ឋានវែង ឬមូល ។

- **អកម្មាសានិ** សីលមិនពព្រុះ ។ បានសេចក្ដីថា: មិនបែកធ្លាយត្រង់សីលជាចន្លោះៗ ដូចតួយ៉ាងសីល ៥ មិនបានបែកធ្លាយត្រង់សីលទី ២ ទី ៤ ជាដើម ដូចជាមេគោ ដែលមិនមានសម្បុរពព្រុះដូច្នោះ រីសីលពព្រុះនោះ បានដល់សីលដែលបែកធ្លាយជាចន្លោះៗ មិនបានតាមលំដាប់សីលឡើយ ដូចយ៉ាងសីល ៥ សីលទី ២ បែកធ្លាយ ហើយសីលទី៣ មិនបានបែកធ្លាយទេ ទៅបែកធ្លាយត្រង់សីលទី ៤ ដូចមេគោ ដែលមានសម្បុរអុចៗ បន្តក់ៗ ពព្រុះពេញរាងកាយដូច្នោះដែរ ។

- **កុជិស្សានិ** សីលរួចអំពីតណ្ហា ។ បានសេចក្តីថា: សីលដែលយោគីរក្សាមិនមានសេចក្តីប្រាថ្នាចង់បានសម្បត្តិអ្វីៗ ក្នុងភពឡើយ រីឯសីលដែលជាខ្ញុំតណ្ហានោះវិញ បានដល់សីលដែលបុគ្គលរក្សា ហើយប្រាថ្នាចង់បានសម្បត្តិក្នុងភពដែលកើតអំពីសីលនោះឯង ។

- **វិញ្ញូបសដ្ឋានិ** សីលគួរឱ្យអ្នកប្រាជ្ញមានព្រះពុទ្ធជាដើម លោកពោលសរសើរ ។ បានសេចក្តីថា: សីលដ៏ស្អាតបរិសុទ្ធ ជាសីលមិនដាច់ មិនធ្លុះមិនពពាលមិនពព្រុះរួចពីខ្ញុំតណ្ហា មិនប៉ះពាល់ដល់តណ្ហានិងទិដ្ឋិ ប្រព្រឹត្តទៅដើម្បីបានសមាធិហ្នឹងឯង ដែលជាសីលគួរឱ្យអ្នកប្រាជ្ញមានព្រះពុទ្ធជាដើមលោកពោលសរសើរ ។

- **អបរាមដ្ឋានិ** សីលដែលតណ្ហានិងទិដ្ឋិពាល់ត្រូវមិនបាន ។ បានសេចក្តីថា: សីលដែលតណ្ហា គឺសេចក្តីប្រាថ្នាសម្បត្តិក្នុងភព និង ទិដ្ឋិសេចក្តីយល់ឃើញប្រកាន់ថាសីលរបស់អញ ឬថាអញបរិសុទ្ធត្រឹមតែសីលប៉ុណ្ណោះប្រកាន់ស្អិតត្រឹមតែសីល និងវត្តប៉ុណ្ណោះឯងជាដើម ពាល់ត្រូវក្តី សីលដែលអ្នកណាមួយអាចចោទបានថា "នេះជាទោសក្នុងសីលរបស់អ្នកឯង" ដូច្នេះក្តី ហៅថា **បរាមដ្ឋានិ** រីឯ **អបរាមដ្ឋានិ** សីលដែលតណ្ហា និងទិដ្ឋិពាល់ត្រូវមិនបាននោះ គឺសីលដែលរួចចាកពីតណ្ហា និងទិដ្ឋិមានសភាពបែបហ្នឹងឯង ។

- **សមាធិសំវត្តនិកានិ** សីលដែលប្រព្រឹត្តទៅព្រម ដើម្បីឱ្យបាននូវសមាធិ ។ បានសេចក្ដីថា: សីលដែលញ៉ាំង**ឧបចារសមាធិ**ក្ដី **អប្បនាសមាធិ**ក្ដី ម្យ៉ាងទៀតញ៉ាំង**មគ្គសមាធិ**ក្ដី **ផលសមាធិ**ក្ដី ឱ្យប្រព្រឹត្តទៅបានហ្នឹងឯង ។

## ចាគានុស្សតិ

កាលបើយោគាវចរកុលបុត្រ ប្រាថ្នាចម្រើននូវ **ចាគានុស្សតិកម្មដ្ឋាន** គប្បីឱ្យមានចិត្តឈានចុះក្នុងការបរិច្ចាគទានជាប្រក្រតី, គប្បីចែករំលែកទានអស់កាលជានិច្ច ពេលដែលប្រារព្ធនឹងចម្រើនត្រូវ **អធិដ្ឋាន** ថា "តាំងអំពីពេលនេះជាដើម កាលបើមានបដិគ្គាហកអ្នកទទួលយកនូវទាន តែអញមិនទាន់បានឱ្យ ទោះបី១ពំនូតដោយយ៉ាងហោចជាមុន អញនឹងមិនបរិភោគខ្លួនឯងឡើយ" ។ កាលបើបានឱ្យទានដល់លោកអ្នកមានគុណវិសេសអង្គណាមួយ ទោះបីតិចក្ដី ច្រើនក្ដី រួចហើយចូលទៅរកទីដែលស្ងាត់ចាកអារម្មណ៍ផ្សេងៗ តម្កល់ស្មារតីរឭកចាកគុណរបស់ខ្លួនថា:

**លាភា វត មេ សុលទ្ធំ វត មេ, យោហំ មច្ឆេរមលបរិយុដ្ឋិតាយ បជាយ វិគតមលមច្ឆេរេន ចេតសា វិហារាមិ មុត្តចាគោ បយតបាណិ វោស្សគ្គរតោ យាចយោគោ ទានសំវិភាគរតោ**

អានិសង្ស ៥ ប្រការ[78] ដែលព្រះដ៏មានព្រះភាគទ្រង់សរសើរថាជាលាភរបស់ទាយកអ្នកឱ្យនូវទាន អានិសង្សទាំងនោះជាលាភរបស់អញពិត **ពុទ្ធសាសនា**ក្តី ភាពជាមនុស្សក្តី ដែលអញបានហើយនេះឈ្មោះថាបានដោយប្រពៃ ព្រោះថាពួកសត្វទាំងអស់កំពុងមានមន្ទិលគឺសេចក្តីកំណាញ់គ្របសង្កត់ជាប់ជានិច្ច ហើយអញម្នាក់ឯងមានចិត្តប្រាសចាកមន្ទិលគឺសេចក្តីកំណាញ់ បានបរិច្ចាគឱ្យទានមានដៃលាងសំអាត ដើម្បីឱ្យនូវទេយ្យធម៌ដោយគោរពដៃឯងសព្វកាល, ជាអ្នកត្រេកអរក្នុងការលះបង់ គួរដល់កិរិយាសូម ពេញចិត្តក្នុងការឱ្យនូវទាន និងការចែករំលែក សូម្បីវត្ថុដែលខ្លួនគប្បីបរិភោគ ។

ដោយអានុភាព ដែលយោគីនឹករលឹករឿយៗ នូវចាគរបស់ខ្លួន តាមន័យដែលបានពោលមកយ៉ាងនេះ គុណធម៌ទាំងឡាយ មានចិត្តដែលស្ងប់ចាកកិលេសគឺ **រាគៈ ទោសៈ មោហៈ** រហូតបានសម្រេចដល់ **ឧបចារជ្ឈាន** កើតឡើង តាមលំដាប់មានសភាពដូចក្នុង **ពុទ្ធានុស្សតិ** ដែរ សូមព្រះយោគីជ្រាបចុះ ។

[78] អានិសង្សរបស់ទាយកអ្នកឱ្យទានមាន ៥ ប្រការ គឺ អាយុវែង ១, សម្បុរល្អ ១, សេចក្តីសុខ, កម្លាំង ១, ប្រាជ្ញាឈ្លាសវៃ ១, ន័យមួយទៀតថា បានជាទីស្រឡាញ់ពេញចិត្តនៃមហាជន ១, លោកសប្បុរសតែងគប់រក ១, មានកិត្តិសព្ទល្អ ១, បានឈ្មោះថា មិនប្រាសចាកធម៌របស់គ្រហស្ថ ១, ដល់ទម្លាយកាយទៅនឹងបានទៅកើតក្នុងសុគតិភព។

**កម្មដ្ឋាន** នេះ មានអានុភាពឱ្យចម្រើនត្រឹមតែ **ឧបចារជ្ឈាន** ប៉ុណ្ណោះ មិនអាចនឹងឱ្យដល់ **អប្បនាឈាន** ឡើយ ព្រោះចាគគុណជាគម្ភីរភាពក្រៃពេក ព្រះយោគីមិនអាចនឹងរលឹកឱ្យសព្វគ្រប់ទៅបាន ។

**កម្មដ្ឋាន** នេះ ហៅថា "**ចាគានុស្សតិ**" ព្រោះកើតឡើងដោយអំណាច នៃកិរិយារលឹកនូវ **ចាគគុណ** ។

## អានិសង្សនៃចាគានុស្សតិ

យោគីដែលបានប្រកបក្នុង **ចាគានុស្សតិ** រឿយៗ នឹងជាអ្នកលះបរិច្ចាគឱ្យនូវទានយ៉ាងក្រៃលែង. មានអធ្យាស្រ័យមិនលោភ, មានកិរិយាធ្វើអនុលោមតាមដោយមេត្តាជ្រាបជាប្រក្រតី, ជាអ្នកអង់អាច, ច្រើនដោយ **បីតិ** និង **បាមោជ្ជៈ** កាលបើមិនបានត្រាស់ដឹងនូវធម៌ជាន់ខ្ពស់ក្នុងបច្ចុប្បន្នជាតិនេះ នឹងមានសុគតិប្រព្រឹត្តទៅក្នុងខាងមុខ ។

ព្រោះហេតុនោះ ទើបលោកចងគាថាទុកមកថា:

តស្មា ហវេ អប្បមាទំ　　កយិរាថ សុមេធសោ
ឯវំ មហានុភាវាយ　　ចាគានុស្សតិយា សទា ។

បានសេចក្តីថា: យោគីអ្នកមានប្រាជ្ញាល្អ គប្បីធ្វើនូវសេចក្តីមិនប្រមាទតែម្យ៉ាងក្នុង **ចាគានុស្សតិ** ដែលមានអានុភាពធំយ៉ាងនេះឱ្យបានសព្វកាល ។

# ទេវតានុស្សតិ

កាលបើព្រះយោគាវចរកុលបុត្ត មានប្រាថ្នាចើម្បីចម្រើននូវ **ទេវតា-នុស្សតិកម្មដ្ឋាន** គប្បីតាំងខ្លួនឱ្យតម្កល់ក្នុងគុណមានសទ្ធាជាដើម ហើយចូលទៅរកទីដែលស្ងាត់ចាកអារម្មណ៍ផ្សេងៗ តម្កល់ស្មារតីរលឹកដល់សទ្ធាទិគុណរបស់ទេវតាទុកជាបន្ទាល់ ហើយរលឹកសទ្ធាទិគុណរបស់ខ្លួនថា: ទេវតាទាំងឡាយក្នុងជាន់ **ចាតុមហារាជ** មានទេវតាទាំងឡាយក្នុងជាន់ **តាវតឹង្ស** ជាន់ **យាមា** ជាន់ **តុសិត** ជាន់ **និម្មានរតី** ជាន់ **បរនិម្មិតវសវត្តី** មានទេវតាទាំងឡាយលើសអំពីនេះតទៅទៀតក៏មាន ទេវតាទាំងឡាយនោះប្រកបដោយ **សទ្ធា សីល សុត ចាគ បញ្ញា** មានសភាពយ៉ាងណា ទើបច្យុតអំពីមនុស្សលោកនេះទៅកើតក្នុង **ទេវលោក** និង **ព្រហ្មលោក** នោះៗ មាន **សទ្ធា សីល សុត ចាគ បញ្ញា** មានសភាពយ៉ាងនេះរបស់អញក៏មានព្រម[79] ។

- ដោយអានុភាពដែលព្រះយោគីនឹករលឹករឿយៗ នូវគុណរបស់ទេវតាជាចំណែកមុន ហើយរលឹកនូវ **សទ្ធាទិគុណ** របស់ខ្លួនដែលកំពុងមានខាងក្រោយតាមន័យដែលបានពោលមកខាងលើនេះ សម័យនោះចិត្តរបស់ព្រះយោគីសោតក៏ប្រាសចាក **រាគាទិក្កិលេស** តម្កល់ទៅត្រង់ចំពោះ **សទ្ធាទិគុណ** ព្រមទាំង **នីវរណធម៌** ក៏ទ្រោមចុះផង អង្គនៃឈានទាំងឡាយក៏កើតឡើងក្នុង ១ ខណៈតាមលំដាប់ មានសភាពដូច **ពុទ្ធានុស្សតិ** ដែរ ។

---

79 ដែលតម្កល់ទុកនូវទេវតាទាំងឡាយជាបន្ទាល់ហើយ រហូតដល់សទ្ធាទិគុណរបស់ខ្លួនយ៉ាងនេះ ដើម្បីធ្វើសទ្ធាទិគុណរបស់ខ្លួនឱ្យកាន់តែមាំឡើង ។

**កម្មដ្ឋាន** នេះ មានអានុភាពឱ្យសម្រេចត្រឹមតែ **ឧបចារជ្ឈាន** ប៉ុណ្ណោះ មិនអាចឱ្យដល់ **អប្បនាឈាន** ឡើយ ព្រោះ **សទ្ធាទិគុណ** គម្ភីរភាពក្រៃពេក ព្រះយោគីមិនអាចនឹងរលឹកឱ្យសព្វគ្រប់បាន ។

**កម្មដ្ឋាន** នេះ ហៅថា "**ទេវតានុស្សតិ**" ដោយអំណាចនៃកិរិយារលឹករឿយក្នុង **សទ្ធាទិគុណ** ប្រៀបទៅនឹងគុណ ។

## អានិសង្សនៃទេវតានុស្សតិ

យោគីដែលបានប្រកបក្នុង **ទេវតានុស្សតិ** រឿយៗ នឹងបានជាទីស្រឡាញ់ពេញចិត្តដល់ពពួកទេវតា បាននូវ **សទ្ធាទិគុណ** ដ៏ទូលំទូលាយយ៉ាងក្រៃលែង, ហើយស្ថិតដោយឥរិយាបថទាំង ៤ ជាអ្នកច្រើនដោយ **បីតិ** និង **បាមោជ្ជៈ** ថែមទៀត ។ កាលបើមិនទាន់ត្រាស់ដឹងនូវ **ឧត្តរធម៌** (ធម៌ជាន់ខ្ពស់) ទេ ក៏នឹងបាននូវសុគតិ ប្រព្រឹត្តទៅក្នុងខាងមុខមិនខានដោយពិត ។ ព្រោះហេតុនោះ ទើបលោកចងគាថាទុកមកសម្រាប់ដាស់តឿនដល់សាធុជនថា:

**តស្មា ហវេ អប្បមាទំ កយិរាថ សុមេធសោ**
**ឯវំ មហានុភាវាយ ទេវានុស្សតិយា សទា ។**

បានសេចក្តីថា: ព្រោះហេតុនោះ យោគីអ្នកមានប្រាជ្ញាល្អ គប្បីធ្វើនូវសេចក្តីមិនប្រមាទតែម្យ៉ាងក្នុង **ទេវាស្សតិ** ដែលមានអានុភាពធំយ៉ាងនេះ ឱ្យបានសព្វកាល ។

ពាក្យថា **សទ្ធា** មានន័យថាសេចក្តីជឿ បានដល់ការជឿនូវ **កម្ម** និង **ផល** នៃ **កម្ម** ជាដើម ។

ពាក្យថា **សីល** មានន័យថាសេចក្តីសង្រួម **កាយ វាចា** ឱ្យប្រពៃ បានដល់ **សីល ៥. សីល ៨. សីល ១០.** ជាដើម ។

ពាក្យថា **សុត** មានន័យថាការ **ស្តាប់** មានស្តាប់ធម៌ទេសនាជាដើម ។

ពាក្យថា **ចាគ** មានន័យថាលះបង់ មានលះបង់នូវទ្រព្យសម្បត្តិធ្វើទានជាដើម ។

ពាក្យថា **បញ្ញា** មានន័យថា ដឹងច្បាស់នូវកងសង្ខារ មានឃើញកិរិយាកើត និង កិរិយារលត់នៃសង្ខារធម៌ជាដើម ។

## សេចក្តីបំភ្លឺក្នុងអនុស្សតិ ៦

ក្នុង **អនុស្សតិ** ទាំង ៦ មាន **ពុទ្ធានុស្សតិ** ជាដើមនេះ ខ្ញុំសូមលើកយកបញ្ហាខ្លះៗ ដែលជាបញ្ហាស្មុគ្រស្មាញក្នុងកិច្ចប្រតិបត្តិ ដែលព្រះយោគីអង្គខ្លះកត់សម្គាល់សេចក្តីពិតមិនបាន នាំឱ្យយឺតយូរក្នុងការធ្វើដំណើរទៅកាន់ព្រះនិព្វាន ក្នុងទីនេះសូមលើកយកក្នុង **ពុទ្ធានុស្សតិកម្មដ្ឋាន** មួយឱ្យជាតួយ៉ាងមកបកស្រាយមានសេចក្តីដូចតទៅនេះ

យោគីដែលចម្រើន **កម្មដ្ឋាន** ដើម្បីកម្ចាត់កិលេសក្នុងព្រះ **ពុទ្ធសាសនា** នេះដែលមិនមាន **សតិ** គឺសេចក្តីរលឹក. **ញាណ** គឺសេចក្តីដឹងខ្លួនទេ ការចម្រើន

**កម្មដ្ឋាន** នោះឈ្មោះថាការចម្រើនកម្មដ្ឋាន មិនបានលទ្ធផលអ្វីក្នុងកិច្ចប្រតិបត្តិនោះ ហើយព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា មិនមែនជា **សតិប្បដ្ឋាន** គឺថា មិនមែនជាផ្លូវក្នុងការធ្វើដំណើរទៅកាន់ព្រះនិព្វានឡើយ ។ ក្នុង **កម្មដ្ឋាន** ទាំងអស់ទោះជា **សមថកម្មដ្ឋាន ៤០** ក្តី **វិបស្សនាកម្មដ្ឋាន** ក្តី ដែលយោគីចម្រើនទៅហើយ បានសម្រេចគុណវិសេស មាន **សមាបត្តិ** ៨ ឬក៏ **មគ្គ ៤ ផល ៤** ជាដើម ក៏សុទ្ធតែ មាន **សតិ** និង **ញាណ** យាងចុះស៊ប់ក្នុងអារម្មណ៍នៃកម្មដ្ឋាននោះៗ ទាំងអស់ ព្រោះថាសតិមានភារកិច្ច ធ្វើការរលឹកនូវអារម្មណ៍ **ញាណ**មានភារកិច្ចធ្វើការដឹងជាក់ក្នុងអារម្មណ៍ក្នុងការចម្រើននូវកម្មដ្ឋាននោះៗ ទើបអង្គនៃធម៌ដទៃមានចិត្តប្រាសចាករាគជាដើមកើតឡើងជាបន្តបន្ទាប់ទៅបាន បើសិន **សតិ** និង **ញាណ** មិនមាននៅក្នុងការចម្រើននូវកម្មដ្ឋានទេនោះ ចិត្តរបស់យោគីក៏រីករាករសាត់អណ្តែតទៅតាមអារម្មណ៍ ដែលកើតឡើងរឿយៗ យ៉ាងពិតប្រាកដ ដូចជាទូកដែលមិនមានបង្គោលថ្នោល ជាគ្រឿងចងឱ្យតាំងនៅត្រង់ទីណាមួយ ម៉្លោះហើយ ទូកនោះចេះតែរសាត់ទៅតាមខ្សែទឹកហូរដូច្នេះដែរ ។

**បុច្ឆា** យោគីចម្រើន **កម្មដ្ឋាន** ដូចម្តេចឈ្មោះថា មិនមាន **សតិ** និង **ញាណ** ? សូមអធិប្បាយមកមើល ។

**វិសជ្ជនា** យោគី នៅពេលដែលខ្លួនត្រូវប្រារព្ធចម្រើន **កម្មដ្ឋាន** ណាមួយមិនមាន**សតិ**និង**ញាណ** ក្នុងការចម្រើននោះឯង ។ ឧទាហរណ៍ដូចជាយោគីដែលប្រាថ្នាដើម្បីចម្រើននូវ **ពុទ្ធានុស្សតិកម្មដ្ឋាន** នៅពេលដែលលើកឡើងនូវ

**ពុទ្ធគុណ** ទាំង ១០ ណាមួយមកពិចារណាធ្វើទុកក្នុងចិត្ត ព្រះយោគីនោះមានការបរិកម្មនូវពាក្យថា **អរហំៗ ឬ ពុទ្ធោៗ** ញាប់មាត់ស្អេក ឯចិត្តរបស់យោគីនោះ បែរជាមិនមាន **សតិ** ធ្វើការរលឹក **ញាណ** ធ្វើការដឹងក្នុង **ពុទ្ធគុណ** នោះឡើយ បែរជាទៅនឹករឿងរ៉ាវផ្សេងៗ មានកូនប្រពន្ធទ្រព្យសម្បត្តិជាដើមដែលមិនមែនជា **ពុទ្ធគុណ** នោះទៅវិញ ដំណើរនេះឈ្មោះថាយោគីចម្រើនព្រះ **កម្មដ្ឋាន** គ្មាន **សតិ** និង **ញាណ** មែនពិត ។

ម្យ៉ាងទៀត ដូចជាយោគីដែលត្រូវចម្រើន **កម្មដ្ឋាន** យក **ពុទ្ធគុណ** ជាអារម្មណ៍ ពេលដែលចម្រើននោះបានលើកបាលីយកមកបរិកម្មថា **អរហំៗ** ឬ **ពុទ្ធោៗ** ជារឿយៗទៅ ក៏ស្រាប់តែរលត់ស្មារតី និងញាណលែងដឹងខ្លួនប្រាណថាខ្លួនកំពុងតែចម្រើន**កម្មដ្ឋាន**នោះឡើយ បែរជាឃើញនិមិត្តរូបភាពស្រុកទេស ឬស្រះស្រង់ ព្រៃភ្នំ ឬនរក ប្រេត ឬទេវតា អង្គនេះអង្គនោះជាដើមដូច្នេះទៅវិញ ហើយក៏នៅរីករាយសប្បាយនឹងអារម្មណ៍នោះៗ ទាំងមិនដឹងខ្លួនក្នុងការចម្រើន**កម្មដ្ឋាន**មួយ អំណាចនៃចិត្តដែលទៅឃើញប៉ុណ្ណោះ ក៏ស្រាប់តែដឹងខ្លួនមកវិញជាធម្មតា ការចម្រើន**កម្មដ្ឋាន**បែបនោះក៏ឈ្មោះថា ការចម្រើន**កម្មដ្ឋាន** មិនមាន **សតិ** និង **ញាណ** ដែរ ការអធិប្បាយមកប៉ុណ្ណោះសូមជ្រាបចុះ ។

**បុច្ឆា** យោគីដែលចម្រើននូវ **ពុទ្ធានុស្សតិកម្មដ្ឋាន** នៅមានសេចក្ដីដឹងខ្លួនថាកំពុងចម្រើននូវ**កម្មដ្ឋាន**ដោយពិត មានទាំង**សតិ**មានទាំង**ញាណ** តែនៅពេលបរិកម្មថា **អរហំៗ ឬ ពុទ្ធោៗ** រឿយៗ ក៏ស្រាប់តែឃើញនិមិត្តមាន

ឃើញព្រៃ ភ្នំព្រះសិនេរុ នរក ប្រេត អសុរកាយ ឬ ទេវតាអង្គនេះ អង្គនោះ ដែលជារូបខាងក្រៅទៅវិញ តើការចម្រើន**កម្មដ្ឋាន**នោះខុសឬត្រូវ? សូមពន្យល់ផងមកមើល ។

**ចម្លើយ** ក្នុងបញ្ហានេះ សូមជ្រាបតាមសេចក្ដីដូចតទៅនេះ៖

ការចម្រើន **ពុទ្ធគុណ** ដោយការបរិកម្មថា ***អរហំ*** ឬ **ពុទ្ធោ** នោះ ដោយរឿយៗ ហើយឃើញនិមិត្តមានព្រៃជាដើមនោះ គឺមិនត្រូវតាមអារម្មណ៍របស់ **ពុទ្ធានុស្សតិកម្មដ្ឋាន** ទេ ដ្បិតថា **ពុទ្ធានុស្សតិកម្មដ្ឋាន** នេះ មានសភាពធម៌ជាអារម្មណ៍ មិនអាចកាន់និមិត្តជាអារម្មណ៍បានឡើយ ហើយកម្មដ្ឋាននេះមាន អានុភាពឱ្យសម្រេចត្រឹមតែ **ឧបចារជ្ឈាន** ប៉ុណ្ណោះ មិនអាចឱ្យសម្រេចដល់ **អប្បនាឈាន** បានឡើយ ។

ក្នុង **ពុទ្ធានុស្សតិកម្មដ្ឋាន** នេះ ក្នុងការចម្រើនត្រូវយោគីធ្វើការត្រិះរិះពិចារណាចំពោះ **ពុទ្ធគុណ** តែម្ដង គុណរបស់ព្រះពុទ្ធមានសភាពបែបណា ត្រូវធ្វើការត្រិះរិះពិចារណាចំពោះគុណនោះមានសភាពបែបនោះ កាលបើយោគីធ្វើការត្រិះរិះពិចារណាចំពោះ **ពុទ្ធគុណ** នោះរឿយៗទៅ កិលេសមាន ***រាគៈ*** ជាដើមក៏មិនអាចគ្របសង្កត់ចិត្តបាន ចិត្តរបស់យោគីក៏ស្ថិតនៅមូល ក្នុងអារម្មណ៍គឺ **ពុទ្ធគុណ** តែមួយ ***នីវរណៈ*** មាន **កាមឆន្ទៈ** ជាដើមក៏ទ្រោមចុះបន្ទាប់មកអង្គនៃឈានទាំង ៥ មាន ***វិតក្ក*** ១, ***វិចារៈ*** ១, **បីតិ** ១, ***សុខៈ*** ១, **ឯកគ្គតា** ក៏កើតឡើងរហូតដល់គ្រប់ ។

**វិតក្កៈ** គឺការត្រិះរិះក្នុង **ពុទ្ធគុណ** ហ្នឹងឯង **វិចារៈ** គឺការពិចារណានូវ **ពុទ្ធគុណ** ហ្នឹងឯង ពេលដែលយោគីកំពុងត្រិះរិះពិចារណានូវ **ពុទ្ធគុណ បីតិ** និង **សុខៈ** ក៏កើតឡើងតាមលំដាប់ផ្សាយនៅពេញករជកាយទាំងមូល សភាពនៃចិត្តរបស់ព្រះយោគីក៏មានអារម្មណ៍មូលតែមួយចំពោះ **ពុទ្ធគុណ** តាំងនៅយ៉ាងប្រពៃ តែកម្មដ្ឋាននេះបានសម្រេចចិត្តតែ **ឧបចារជ្ឈាន** ប៉ុណ្ណោះ មិនបានដល់ **អប្បនាឈាន**ឡើយ ព្រោះគុណរបស់ព្រះពុទ្ធជ្រៅល្អិតពេក យោគីមិនអាចពិចារណាដល់ទីបំផុតបាន ម្ល៉ោះហើយយោគីរមែងជាប់រវល់តែពិចារណារហូតដល់ឈប់ចម្រើនកម្មដ្ឋានតែម្តង មិនមានការតម្កល់ចិត្តក្នុងអារម្មណ៍មួយដែលត្រូវតម្កល់ដូចក្នុង **កសិណ** ឬ **អសុភកម្មដ្ឋាន** ឡើយ ព្រោះកម្មដ្ឋាននោះគ្មាននិមិត្តជាអារម្មណ៍ មានតែសភាពធម៌ជាអារម្មណ៍ប៉ុណ្ណោះ ។

ការពោលមកនេះ គឺជាដំណើរពិតនៃការកើតឡើងនៃគុណវិសេសក្នុង **ពុទ្ធានុស្សតិកម្មដ្ឋាន** ដែលយោគីចម្រើនត្រឹមត្រូវល្អតាមផ្លូវនៃ **ពុទ្ធានុស្សតិ-កម្មដ្ឋាន** នោះ ។

ដូច្នេះយោគីត្រូវចម្រើន **ពុទ្ធានុស្សតិកម្មដ្ឋាន** ត្រូវតែសិក្សាអំពី ពុទ្ធគុណនោះទាំងបាលីទាំងសេចក្តីអធិប្បាយ ទោះតិច ឬ ច្រើនតាមប្រាជ្ញា ឱ្យដឹងន័យសេចក្តី **ពុទ្ធគុណ** នោះៗ មានសេចក្តីថាដូចម្តេច បើលើកយកព្រះនាមមួយណាមកចម្រើន ត្រូវដឹងសេចក្តីនៃព្រះនាមនោះឱ្យច្បាស់លាស់ល្អ ហើយត្រូវមានចិត្តធ្វើការត្រិះរិះពិចារណា ទៅតាមគុណនោះតែម្យ៉ាងក្នុងពេលចម្រើនរហូតដល់កើតអង្គនៃ **ឧបចារជ្ឈាន** ។

កុំចម្រើន **ពុទ្ធគុណ** ដោយមិនស្គាល់សេចក្ដីនៃ **ពុទ្ធគុណ** ដែលខ្លួនត្រូវចម្រើននោះឡើយ ព្រោះថា កាលបើចម្រើនពុទ្ធគុណ មិនដឹងន័យសេចក្ដីរហូតដល់កើតនិមិត្តហើយ ក៏រីករាយនឹងនិមិត្តដែលកើតឡើងដល់ចិត្តនោះ គឺជាការខុសចាកតាមសភាពនៃ **ពុទ្ធានុស្សតិកម្មដ្ឋាន** មែនពិត ការចម្រើន **កម្មដ្ឋាន** របស់យោគីមានសភាពបែបនេះឈ្មោះថា ការចម្រើននូវ**កម្មដ្ឋាន**មាន ត្រឹមតែ **សទ្ធា** នៅខ្វះ **បញ្ញា**. កាលបើយោគីបានឃើញនូវនិមិត្តដូចបានពោលមកហើយៗ ប្រកាន់ស្អិតថា ព្រះធម៌ពិតជាលែងប្រែប្រួល ក៏នាំឱ្យកើតនូវ **និក្កន្តិ**:ដែលជា **អកុសលធម៌** នាំឱ្យយឺតយូរក្នុងការត្រាស់ដឹងនូវ **ឧត្តរធម៌** ថែមទៀតផង ។

ម្យ៉ាងទៀត សូម្បីយោគីចម្រើននូវ **ពុទ្ធានុស្សតិកម្មដ្ឋាន** មានពាក្យថា **អរហំ** ឬ **ពុទ្ធោ** ជាដើមឯណោះទេ តែដល់កើតនិមិត្តឃើញសាកសព គឺ**អសុភ** ឬ **អាការ ៣២** មានសក់ជាដើមដែលជារូបខាងក្នុង ។ ការចម្រើននេះក៏មិនទាន់ត្រូវតាមអារម្មណ៍របស់ ពុទ្ធានុស្សតិកម្មដ្ឋាន ដែរ ព្រោះ ពុទ្ធានុស្សតិកម្មដ្ឋាន មានសភាពធម៌ជាអារម្មណ៍តែម្យ៉ាង ។

ដូច្នេះបើយោគីប្រាថ្នាចម្រើននូវ **ពុទ្ធានុស្សតិកម្មដ្ឋាន** គប្បីធ្វើចិត្តឱ្យត្រង់ចំពោះ **ពុទ្ធគុណ** រហូតដល់បានសម្រេចនូវ **ឧបចារជ្ឈាន** បន្ទាប់មកបើប្រាថ្នានូវ **អសុភ ១០** ឬ **អាការ ៣២** គប្បីធ្វើទុកក្នុងចិត្តដោយការបរិកម្ម ចំពោះ **អសុភ** ឬអាការនោះចំៗ ត្រង់ៗ តែម្ដងទៅ ។

បើយោគីធ្វើការបរិកម្មនូវ**កម្មដ្ឋាន**នោះៗ រឿយៗទៅ និមិត្ត**កម្មដ្ឋាន** មាន**ឧគ្គនិមិត្ត** (និមិត្តជាប់ភ្នែក) និង **បដិភាគនិមិត្ត** (និមិត្តប្រៀបធៀប) កើតឡើងហើយ យោគីគប្បីមានចិត្តតម្កល់ក្នុងនិមិត្តដែលកើតឡើងនោះៗ ត្រឹមត្រូវប្រពៃតាមកម្មដ្ឋាននោះពិត ព្រោះថាកម្មដ្ឋានគឺ*អសុភ* ១០ ក្តី **កាយគតាសតិ** ក្តីមាននិមិត្តជាអារម្មណ៍ ។

សេចក្តីម្យ៉ាងទៀតថា កាលបើយោគីចម្រើននូវ **ពុទ្ធានុស្សតិ** មានពាក្យថា **អរហំ ឬ ពុទ្ធោ** ដោយវាចា ឯចិត្តនឹករក *អសុភៈ* ឬអាការ ៣២ ឬ **កសិណ** ទៅវិញ ដល់ពេលកើតនិមិត្ត ក៏កើតទៅតាមចិត្តនឹកគិតនោះៗ បើនឹកអសុភ ក៏បានឃើញនិមិត្តអសុភនោះ បើនឹកអាការ ៣២ ក៏ឃើញនិមិត្តអាការ ៣២ នោះ បើនឹក**កសិណ**ក៏ឃើញនិមិត្តរបស់**កសិណ**នោះ ដូច្នេះយោគីបានឈ្មោះថាជាអ្នកចម្រើន*អសុភ***កម្មដ្ឋាន** ឬ **កាយគតាសតិកម្មដ្ឋាន** ឬ **កសិណកម្មដ្ឋាន** តែម្យ៉ាង មិនបានឈ្មោះថាចម្រើនពុទ្ធានុស្សតិកម្មដ្ឋានឡើយ សេចក្តីសំរេចក្នុងការចម្រើនកម្មដ្ឋាននោះ គឺត្រង់ចិត្តនឹកគិតអារម្មណ៍កម្មដ្ឋាននោះឯង ។

ហេតុដូច្នេះយោគី កាលបើចិត្តនឹកគិតចំពោះ*អសុភ***កម្មដ្ឋាន** គប្បីបរិកម្មធ្វើទុកក្នុងចិត្តនូវ*អសុភ***កម្មដ្ឋាន**តែម្តង ពាក្យថា "**ឧទ្ធុមាតកំ បដិក្កូលំ**" ជាដើមទើបត្រូវល្អ ។ បើចិត្តនឹកគិតអំពីអាការ ៣២ មានសក់ជាដើម គប្បីបរិកម្មធ្វើទុកក្នុងចិត្តនូវអាការ ៣២ នោះៗ ឱ្យចំត្រង់តែម្តងទៅទើបត្រូវល្អ, បើចិត្តនឹកគិត**កសិណ** ១០ មាន**បឋវីកសិណ**ជាដើម គប្បីបរិកម្មធ្វើទុកក្នុងចិត្តនូវកសិណ

នោះៗ ឱ្យចំៗ ត្រង់តែម្តងទៅទើបត្រូវ ដើម្បីជៀសវាងការច្របូកច្របល់នូវអារម្មណ៍កម្មដ្ឋានដែលបានកើតឡើង ព្រោះថា **ពុទ្ធានុស្សតិកម្មដ្ឋាន** មានសភាពធម៌ជាអារម្មណ៍ ។ **អសុភ ១០** ក្តី **កាយគតាសតិកម្មដ្ឋាន** (អាការ ៣២) ក្តី **កសិណ ១០** ក្តី មាននិមិត្តជាអារម្មណ៍ ហើយ **ពុទ្ធានុស្សតិកម្មដ្ឋាន** ទៀតសោត មានអានុភាពឱ្យសម្រេចត្រឹម **ឧបចារជ្ឈាន** **អសុភកម្មដ្ឋាន ១០** ក្តី **កាយគតាសតិកម្មដ្ឋាន** ក្តី មានអានុភាពឱ្យសម្រេចដល់ **បឋមជ្ឈាន**(ឈានទី១)

**កសិណ ១០** មានអានុភាពឱ្យសម្រេចដល់ឈានទី ៤ ជាចតុក្កន័យ ឬ ឈានទី ៥ ជាបញ្ចកន័យដោយពិត ។

ឯក្នុង **អនុស្សតិ ៨** ទៀតនោះ ក៏មានបញ្ហា និងការបកស្រាយមានសភាពប្រហាក់ប្រហែលគ្នាដូចក្នុង **ពុទ្ធានុស្សតិ** ដែរ សូមជ្រាបចុះ ។

**បុច្ឆា** យោគីដែលចូលកាន់ **សមាធិ** ភ្លេចស្មារតី និងព្រះអរិយៈដែលលោកចូលកាន់ **សញ្ញាវេទយិតនិរោធ** តើដូចគ្នា ឬ ខុសគ្នា ?

**វិសជ្ជនា** ពិតជាខុសគ្នាស្រឡះមិនដូចគ្នាឡើយ ដ្បិតថាយោគីដែលចូលកាន់សមាធិដែលគ្មានស្មារតីនោះ កាយសង្ខារ គឺខ្យល់អស្សាសបស្សាសៈរលត់ស្ងប់ តែ *វេទនា* និង *សញ្ញា* នៅសោយ និងចងចាំអារម្មណ៍ផ្សេងៗ ដែលកើតឡើងទាំងមិនដឹងខ្លួនថា "ខ្លួនកំពុងតែចម្រើនកម្មដ្ឋាននោះឡើយ" ឯព្រះអរិយៈដែលលោកចូលកាន់ **សញ្ញាវេទយិតនិរោធ** នោះវិញ សង្ខារទាំង ៣ កាយសង្ខារ គឺខ្យល់ *អស្សាសបស្សាសៈ ១ វចីសង្ខារគឺ វិតក្កៈ និងវិចារៈ ១ ចិត្តសង្ខារ*

គឺ**វេទនា** និង**សញ្ញា** ១ ត្រូវរលត់អស់មិនមានសេសសល់អស់រយៈកាល ៧ ថ្ងៃ ទើបកើតឡើង សង្ខារដែលត្រូវរលត់នោះ គឺ**វចីសង្ខារ**រលត់មុន បន្ទាប់មកទើប**កាយសង្ខារ**រលត់ បន្ទាប់មកទៀត**ចិត្តសង្ខារ**ក៏រលត់ចុងក្រោយគេបង្អស់ នៅពេលដែលព្រះអរិយៈចេញចាកពីនិរោធនោះវិញ ចិត្តសង្ខារកើតមុន បន្ទាប់មកកាយសង្ខារទើបកើតឡើង បន្ទាប់មកទៀត ទើបវចីសង្ខារកើតតាមលំដាប់គ្នាដូច្នេះ

**មុច្ឆា** កាលបើ **សមាធិ** ភ្លេចស្មារតីនោះ មិនមែនជា **សញ្ញាវេទយិតនិរោធ** ទេ តើសមាធិនោះនឹងរាប់ចូលទៅក្នុង **ឧបចារសមាធិ** ឬ **អប្បនាសមាធិ** ឬក៏**មគ្គសមាធិ** ឬ **ផលសមាធិ** ឬរាប់ចូលទៅក្នុងក្រុមធម៌ណាវិញ?

**វិសជ្ជនា** **សមាធិ**ដែលគ្មានស្មារតីនោះ មិនបានរាប់ចូលទៅក្នុង**ឧបចារសមាធិ** ឬ **អប្បនាសមាធិ** ឬក៏**មគ្គសមាធិ** ឬ**ផលសមាធិ**ណាមួយឡើយ ព្រោះថា ឧបចារសមាធិក្តី ឬអប្បនាសមាធិក្តី ដែលបានមកពីការចម្រើននូវកម្មដ្ឋាន ៤០ ឬមគ្គសមាធិក្តី ឬ**ផលសមាធិ**ក្តី ដែលបានមកអំពីការចម្រើន**វិបស្សនា** សុទ្ធតែមាន**សតិ**និង**សម្បជញ្ញៈ**ជាគ្រឿងរលឹក ជាគ្រឿងដឹងខ្លួនទាំងអស់, ឯសមាធិមិនមានស្មារតីនោះ ពេលដែលយោគីកំពុងចម្រើន**កម្មដ្ឋាន**នោះមិនមាន**សតិ** មិនមាន**សម្បជញ្ញៈ**ជាគ្រឿងរលឹក ជាគ្រឿងដឹងខ្លួនក្នុងការចម្រើន**កម្មដ្ឋាន** នោះឡើយ ដូច្នេះទើបមិនរាប់ចូលក្នុងសមាធិទាំងនោះ ។

តែបើនឹងរាប់ចូលទៅក្នុងធម៌ណានោះ គឺត្រូវរាប់ចូលទៅក្នុងក្រុមបុគ្គលដែលភ្លឹកទៀបស្លាប់នោះទៅវិញទើបគួរ ។

**មុច្ឆា** ព្រោះហេតុអ្វី?

**ចម្លើយ** សូមយល់តាមសេចក្តីអធិប្បាយដូចតទៅនេះ៖

មុននឹងដឹងរឿងពួកបុគ្គលភ្លឹកទាំងនោះ សូមយល់អំពីនិមិត្តរបស់**កម្មដ្ឋាន** និងនិមិត្តរបស់បុគ្គលទៀបស្លាប់សិនទើបងាយយល់ ។ និមិត្តរបស់**កម្មដ្ឋាន**ក្នុងព្រះពុទ្ធសាសនានៃយើងនោះ មាន ៣ គឺ ១ **បរិកម្មនិមិត្ត** ២ **ឧគ្គហនិមិត្ត** ៣ **បដិភាគនិមិត្ត** ។ និមិត្តទាំង ៣ នេះ ព្រះយោគីត្រូវបានក្នុង**កម្មដ្ឋាន** ២២ គឺ **កសិណ ១០ អសុភ ១០ កាយគតាសតិ ១ អានាបានស្សតិ ១** ។

១- **បរិកម្មនិមិត្ត** និមិត្តក្នុងបរិកម្ម ដូចយោគីដែលត្រូវចម្រើន**បឋវីកសិណ** ត្រូវយករង្វង់ **កសិណ** ដែលលាបលនដោយផែនដីពណ៌ **អរុណរះ** ពេលព្រឹក មកតម្កល់អំពីមុខហើយ ធ្វើការសម្លឹងនូវពណ៌នៃ**កសិណ**នោះ បរិកម្មថា **បឋវី ដីៗ** ហើយបិទភ្នែក បរិកម្មរួចបើកភ្នែកសម្លឹងពណ៌**កសិណ**នោះទៀត បរិកម្មថា **ដីៗ** ការបរិកម្មដោយការសម្លឹងនូវពណ៌កសិណបែបនេះ ហៅថា **បរិកម្មនិមិត្ត** ។

២- **ឧគ្គហនិមិត្ត** និមិត្តដែលកើតឡើងប្រាកដដល់ចិត្តរបស់ព្រះយោគីមានពណ៌សណ្ឋានដូចរង់**កសិណ**នោះ បើកភ្នែកក្តី ធ្មេចភ្នែកក្តី ក៏ឃើញពណ៌កសិណនោះដូចគ្នា និមិត្តដែលកើតឡើងប្រាកដដល់ចិត្តរបស់យោគីយ៉ាងជាក់ច្បាស់យ៉ាងនេះ ហៅថា **ឧគ្គហនិមិត្ត** ។

៣- **បដិភាគនិមិត្ត** និមិត្តជាចំណែកប្រៀបដូចជាយោគីដែលចម្រើន **បឋវីកសិណ** ពេលដែល**ឧគ្គហនិមិត្ត**កើតឡើងហើយ យោគីនោះនៅតែមានព្យាយាមក្នុងការសម្លឹងនូវនិមិត្តនោះតាម**មនោទ្វារ**រឿយៗ រហូតដល់និមិត្តនោះឡើងបរិសុទ្ធស្អាតជាង **ឧគ្គហនិមិត្ត** ១ រយគុណ ១ ពាន់គុណ និមិត្តក្រោយនេះហាក់ដូចទម្លាយនូវ **ឧគ្គហនិមិត្ត** ចេញមកស្អាតបរិសុទ្ធ ប្រៀបដូចជាកញ្ចក់ដែលគេដកចេញពីស្រោមមក ឬដូចជាវង់ព្រះចន្ទដ៏បរិសុទ្ធដែលលេចពីពពកខ្មៅ និមិត្តក្រោយនេះមិនមានពណ៌សណ្ឋានដូចនិមិត្តដើមទេ និមិត្តនេះឯងហៅថា **បដិភាគនិមិត្ត** ។

និមិត្តទាំង ៣ នេះ ពេលយោគីចម្រើនឃើញសុទ្ធតែមានសតិស្មារតីដឹងខ្លួនថាខ្លួនកំពុងចម្រើន **កម្មដ្ឋាន** ដោយពិត ។

មុនពេលប្រារព្ធ ដើម្បីចំរើន **កម្មដ្ឋាន** ក៏មានស្មារតី ពេលកំពុងចម្រើនឃើញនិមិត្ត ក៏មានស្មារតី ពេលចាកចេញការចម្រើន **កម្មដ្ឋាន** ក៏មានស្មារតីទាំងអស់មិនមានភ្លេចស្មារតីទាល់តែសោះ ។ ឯនិមិត្តរបស់បុគ្គលឃើញនៅពេលទៀបស្លាប់មាន ២ គឺ **កម្មនិមិត្ត** ១ **គតិនិមិត្ត** ១ ដែលជានិមិត្តនៃអំពើល្អ ឬអាក្រក់ដែលខ្លួនធ្វើរួចហើយ ។

១- **កម្មនិមិត្ត** គឺជាអារម្មណ៍មួយកើតឡើងប្រាកដដល់បុគ្គលទៀបស្លាប់មាន ២ ប្រការគឺ **កម្មនិមិត្តជាកុសល** ១ **កម្មនិមិត្តជាអកុសល** ១ **កម្មនិមិត្តជាកុសល** នោះ កាលបើបុគ្គលពីដើមធ្លាប់ធ្វើអំពើល្អមានឱ្យទានដោយវត្ថុណា

រក្សាសីល ចម្រើនកម្មដ្ឋាន ស្តាប់ធម៌ទេសនា បូជាសក្ការៈចំពោះព្រះពុទ្ធជាដើម ដល់ពេលទៀបស្លាប់ក៏អារម្មណ៍នោះមកប្រាកដឱ្យឃើញ ហាក់ដូចជាខ្លួនកំពុងធ្វើនូវអំពើនោះ អារម្មណ៍នោះហៅថា **កម្មនិមិត្តជាកុសល** បើកាលពីខាងដើមបុគ្គលធ្លាប់សាងនូវអំពើបាប មានសម្លាប់សត្វដោយលំពែង ឬ ដាវ កាំបិត អាវុធណាមួយជាខាងដើម ដល់ពេលទៀបស្លាប់អារម្មណ៍នោះ ក៏មកប្រាកដឱ្យឃើញដាវ លំពែង កាំបិត អាវុធជាគ្រឿងសម្រាប់កាប់សម្លាប់ និងអំពើបាបនោះទៀត អារម្មណ៍នេះ ហៅថា **កម្មនិមិត្តជាអកុសល** ។

២- **គតិនិមិត្ត** គឺជាអារម្មណ៍មួយបានដល់ភពល្អ ឬអាក្រក់ដែលបុគ្គលត្រូវទៅកើតក្នុងទីនោះបន្ទាប់អំពីស្លាប់ទៅ កើតឡើងឱ្យឃើញប្រាកដដល់បុគ្គលដែលទៀបស្លាប់ មាន ២ យ៉ាងគឺ **សុគតិនិមិត្ត** ១, **ទុគ្គតិនិមិត្ត** ១ ។

**សុគតិនិមិត្ត** នោះ កាលបើពីខាងដើមបុគ្គលបានកសាងល្អ មានឱ្យទានរក្សាសីលជាដើម ហើយបន្ទាប់អំពីបែកធ្លាយ **ខន្ធបញ្ចកៈ** ទៅ ត្រូវទៅកើតក្នុង**សុគតិភព**ណាមួយ ក៏ដូចពេលទៀបស្លាប់ក៏ប្រាកដឱ្យឃើញនូវភពនោះ មានឃើញទេវតាក្នុងភពនោះៗ មកអញ្ជើញឱ្យទៅកើតជាមួយគេជាដើម អារម្មណ៍នេះ ហៅថា **សុគតិនិមិត្ត** តែបើពីខាងដើមធ្លាប់ធ្វើបាបកម្មមានបញ្ចវេរាជាដើម ហើយបុគ្គលនោះ លុះបន្ទាប់អំពីស្លាប់ទៅ ត្រូវទៅកើតក្នុងអបាយភូមិមាននរកជាដើម ដល់ពេលទៀបស្លាប់ក៏បណ្តាលឱ្យឃើញនូវភពអាក្រក់នោះ មាននិរយបាលមកចាប់ចងយកទៅជាដើម អារម្មណ៍នេះហៅថា **ទុគ្គតិនិមិត្ត** ។

បុគ្គលដែលទៀបស្លាប់តែងតោងយកនូវអារម្មណ៍ ២ យ៉ាងនេះឯង ចុតិទៅកើតសុគតិភព ឬទុគ្គតិភពទៅតាម **យថាកម្ម** របស់ខ្លួន ។

រីឯបុគ្គលដែលភ្លឹកទៅ ក៏តែងតោងយកនូវអារម្មណ៍គឺ **សុគតិនិមិត្ត** ឬ **ទុគ្គតិនិមិត្ត** តាមកម្មល្អ ឬអាក្រក់របស់ខ្លួនដែលបានកសាងទុករួចមកហើយនោះ។

ក៏ពួកបុគ្គលទាំងអស់នេះ កាលដែលកំពុងសោយអារម្មណ៍ជាទុក្ខ ឬជាសុខក្នុងភពនោះៗ ដែលឱ្យឃើញសុទ្ធតែជាបុគ្គលមិនមានស្មារតី និងញាណសម្រាប់រលឹកនិងដឹងខ្លួនឡើយ ស្មារតីនិងញាណរលត់អស់មិនបានដឹងនូវអារម្មណ៍ផ្សេងៗ ដែលមកប្រាកដដល់ទ្វារមានកូនយំទួញ ឬ ញាតិហៅរក ឬ លោកអាចារ្យឱ្យបាលី **ពុទ្ធោ** ជាដើមឡើយ ។

អារម្មណ៍ល្អនិងអាក្រក់ដែលកើតឡើង ដល់បុគ្គលទាំងអស់នោះ សុទ្ធតែកើតឡើងអំពីកម្មជាបច្ច័យមែនពិត ។

បុគ្គលអ្នកភ្លឹករលត់ស្មារតីក្នុងបច្ចុប្បន្ន ហើយឃើញអារម្មណ៍ផ្សេងៗ ដូចបានពោលមកហើយ ខុសអំពីបុគ្គលដែលស្លាប់ ព្រោះថាបុគ្គលអ្នកស្លាប់ កាលណា **ចុតិវិញ្ញាណ** កើតឡើង ហើយ **វិបាកវិញ្ញាណ** ត្រូវចាប់ **បដិសន្ធិ** ក្នុងភពខាងមុខបន្តទៅទៀតទៅតាមកម្មជាហេតុ ជាបច្ច័យ ព្រោះអាយុនិងបុណ្យដែលត្រូវបន្តការរស់នៅតទៅទៀតក្នុងបច្ចុប្បន្នភពនេះអស់ហើយ ឯបុគ្គលដែលភ្លឹកទៅហើយត្រូវដឹងខ្លួនរស់មកវិញ ព្រោះអាយុនិងបុណ្យសម្រាប់នៅក្នុងបច្ចុប្បន្នភពមិនទាន់អស់នៅឡើយដោយពិត ។

យោគីដែលចម្រើននូវកម្មដ្ឋានហើយរលត់ស្មារតី និងញាណ មិនដឹងខ្លួនថាខ្លួនកំពុងចម្រើន**កម្មដ្ឋាន** ហើយឃើញអារម្មណ៍ផ្សេងៗ មាននរក ឬទេវតាជាដើម ឃើញខ្លួនឯងកំពុងនៅរួមជាមួយនរក ឬ ទេវតាជាដើមនោះ ដោយអំណាចកម្មជាកុសលឬកម្មជាអកុសលដែលខ្លួនធ្លាប់សន្សំ ហើយជាគ្រឿងញ៉ាំងឱ្យឃើញប្រាកដឡើងដោយអំណាចចិត្តដែលឃើញ បន្ទាប់មកទើបដឹងខ្លួនឡើងវិញជាធម្មតាដោយខ្លួនឯង ឬក៏យោគីពួកខ្លះពេលដែលរលត់ស្មារតីទៅបានឃើញអារម្មណ៍ផ្សេងៗ ដូចបានពោលមកហើយ មិនអាចដឹងខ្លួនដោយខ្លួនឯងបាន លុះត្រាទាល់តែឃើញមានបុគ្គលណាម្នាក់គេដេញឱ្យចូលក្នុងរូប ដែលមានរូបភាពហាក់ដូចជាគល់ឈើ ឬវត្ថុអ្វីមួយតាមតែឃើញទើបដឹងខ្លួនឡើងវិញជាធម្មតាមែនពិត ។ ការចម្រើនសមាធិដែលរលត់ស្មារតី មានសភាពដូចបានពោលមកហើយ គឺជាដំណើរមួយមានសភាពដូចជាបុគ្គលដែលភ្លឹកដូច្នេះដែរ

**បុច្ឆា** ព្រោះហេតុអ្វីបានជាបុគ្គលអ្នកធ្វើសមាធិភ្លឹកនោះដឹងខ្លួន រស់ឡើងវិញ ?

**វិសជ្ជនា** ព្រោះបុគ្គលនោះអាយុក្តី បុណ្យក្តី មិនទាន់អស់ហើយភ្លើងធាតុក៏មិនទាន់រលត់ ឥន្ទ្រិយក៏មិនទាំងបែកធ្លាយនៅស្រស់ធម្មតា ។

**បុច្ឆា** តើអ្វីជាហេតុ អ្វីជាបច្ច័យ បានជាយោគីអង្គនោះចម្រើននូវ**សមាធិកម្មដ្ឋាន** បែរជារលត់ស្មារតីដូច្នោះ?

**ចិស្សជ្ជនា** មកតែអំពីការចម្រើននូវព្រះ**កម្មដ្ឋាន** មិនប្រព្រឹត្តទៅតាមសេចក្ដីពិតនៃ**កម្មដ្ឋាន**ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្ដែងហើយទុកជាមាគ៌ាដ៏ត្រឹមត្រូវនោះឯងជាហេតុជាប្ច័យ ។

**មុច្ឆា** កាលបើព្រះយោគី ដែលធ្លាប់បានចម្រើននូវ**ព្រះកម្មដ្ឋាន**ហើយចេះតែរលត់ស្មារតីដូច្នោះ តើនឹងមានឧបាយដូចម្ដេច ទើបនឹងជួយយោគីនោះក្នុងការចម្រើនព្រះ**កម្មដ្ឋាន**ឱ្យមានស្មារតីតាំងនៅប្រក្រតីឡើងវិញបានដែរឬ?

**ចិស្សជ្ជនា** មាន! ពិតជាមានមែន បើយោគីដែលធ្លាប់តែរលត់ស្មារតីក្នុងការចម្រើននូវ**ព្រះកម្មដ្ឋាន** មានបំណងនឹងឱ្យមានស្មារតីឡើងវិញជាប្រក្រតីក្នុងការចម្រើន ត្រូវប្រតិបត្តិដូចតទៅនេះ៖

យោគីគប្បីត្រូវរលឹកឡើងនូវ **អានាបានស្សតិកម្មដ្ឋាន** មួយ យកមកចម្រើនជាកំណត់ឱ្យបានជាទីពឹងនៃចិត្ត ព្រោះថា**កម្មដ្ឋាន**នេះមាន**ឧបការៈ**ច្រើនណាស់ សម្រាប់ធ្វើឱ្យបុគ្គលដែលមិនមានសតិ ចេះតែវង្វេង ភ្លេចច្រើនក្នុងកិច្ចការ គឺបុគ្គលដែលជា **មោហចរិត** ហ្នឹងឯង ធ្វើឱ្យបុគ្គលមានស្មារតី មានសេចក្ដីដឹងខ្លួនព្រម ក្នុងកិច្ចការឡើងវិញបានក្នុងកម្មដ្ឋាននេះ គឺព្រះយោគីត្រូវមានស្មារតីនិងញាណរលឹកដឹងឱ្យបានប្រាកដ ចំពោះខ្យល់ដកដង្ហើមចេញ និងខ្យល់ដកដង្ហើមចូល ឱ្យជាប្រក្រតីគ្រប់វារៈនៃខ្យល់ ដែលសញ្ចារឡើងចុះ និងគ្រប់ឥរិយាបថទាំង ៤ គឺឥរិយាបថ **ដេក ដើរ ឈរ** និង **អង្គុយ** ។

ឯសេចក្តីប្រតិបត្តិក្នុងការចម្រើននូវ **អានាបានស្សតិកម្មដ្ឋាន** នោះមានសេចក្តីដូចតទៅៈ ក្នុង **គម្ពីរវិសុទ្ធិមគ្គ** ភាគ ២ ព្រះពុទ្ធដីកាទ្រង់សម្តែងថាៈ

**ឥធ ភិក្ខវេ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារតោ វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា សោ សតោវ អស្សសតិ សតោ បស្សសតិ ។**

បានសេចក្តីថាៈ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី ត្រូវអង្គុយពែនភ្នែនតាំងកាយឱ្យត្រង់តម្កល់នូវស្មារតីឱ្យមានមុខឆ្ពោះទៅរក **កម្មដ្ឋាន** ភិក្ខុនោះមានស្មារតីមែនពិត ដកដង្ហើមចេញ មានស្មារតីដកដង្ហើមចូល ។

## សេចក្តីពន្យល់អំពីអនាបានស្សតិ

**អានាបានស្សតិ** មានន័យថា សេចក្តីរលឹកនូវខ្យល់ដកដង្ហើមចេញ ដកដង្ហើមចូល ។

ជនអ្នកឃើញភ័យក្នុងសង្សារវដ្តហៅថា ភិក្ខុ ។

ចិត្តមានន័យថា ធម្មជាតអ្នកគិត អ្នកត្រិះរិះពិចារណានូវអារម្មណ៍ ។ ចិត្តដែលគេមិនបានអប់រំហើយ តែងតែមានសភាពផ្លេងផ្លូង កម្រើកញាប់ញ័រទៅតាមអារម្មណ៍ជាធម្មជាតិ ពិបាករក្សាផ្ទុញផ្ទាល់បានដោយកម្រ ដោយកិរិយា

កើតនិងកិរិយារលត់ទៅវិញរហ័សជាទីបំផុត តែងមានកិរិយាធ្លាក់ចុះក្នុងអារម្មណ៍ជាទីប្រាថ្នានិងមិនជាទីប្រាថ្នាផ្សេងៗរឿយៗ ម្ល៉ោះហើយសេចក្តីទុក្ខគ្រប់យ៉ាងចេះតែចម្រើនឡើងជាភិយ្យោភាព. នៅពេលណាអារម្មណ៍ទាំងអស់មានរូបារម្មណ៍ជាដើមមកប៉ះនឹងទ្វារ មាន**ចក្ខុទ្វារ**ជាដើមម្តងៗ ចិត្តតែងស្ទុះទៅតាមទ្វារវិថីមាន**ចក្ខុទ្វារវិថី**ជាដើម ចេញទៅក្រេបជញ្ជក់សេពសោយនូវរសនៃអារម្មណ៍នោះ កាលបើអារម្មណ៍នោះ គួរឱ្យកើតនូវសេចក្តីរីករាយក៏ជាប់ជំពាក់ក្នុងអារម្មណ៍នោះយ៉ាងក្រៃលែង កាលបើអារម្មណ៍នោះគួរនាំមកកើតសេចក្តីថ្នាំងថ្នាក់ក៏ដល់នូវសេចក្តីទោមនស្សក្នុងអារម្មណ៍នោះយ៉ាងក្រៃពេក, បើដូច្នេះសត្វទាំងឡាយក៏ដល់នូវសេចក្តីទុក្ខឥតល្ហែជារៀងរាល់ថ្ងៃយប់ ។ ព្រោះហេតុដូច្នោះបុគ្គលអ្នកមានសេចក្តីត្រូវការរួចចាកទុក្ខចង់បានសេចក្តីសុខ គប្បីគ្រប់គ្រងទូន្មានចិត្តឱ្យបានស្អាតបរិសុទ្ធ ព្រះពុទ្ធដីកាទ្រង់សម្តែងថា:

**ចិត្តំ គុត្តំ សុខាវហំ** ចិត្តដែលគេគ្រប់គ្រងល្អហើយ តែងនាំមកនូវសេចក្តីសុខ ។ **ចិត្តំ ទន្តំ សុខាវហំ** ចិត្តដែលគេទូន្មានល្អហើយ តែងនាំមកនូវសេចក្តីសុខ ។

បុគ្គលដែលជា **អាទិកម្មិក** (អ្នកដែលទើបតែចាប់ផ្តើមរៀនសូត្រថ្មី) តែងតែមានចិត្តមិននឹងហ្ន៎ កាលបើទូន្មានចិត្តក្នុងទីច្របូកច្របល់ដែលជាទីច្រឡូកច្រឡំដោយពួកមានសំឡេងអឺងអាប់ មិនងាយនឹងទូន្មានចិត្តបានឡើយ ព្រោះចិត្តចេះតែរវើរវាយ រសាប់រសល់ ស្ទុះទៅកាន់យកនូវអារម្មណ៍តាមទ្វារ

ព្រោះហេតុដូច្នោះ ទើបព្រះសម្មាសម្ពុទ្ធជាព្រះបរមគ្រូនៃយើង ទ្រង់ត្រាស់សម្តែងនូវទីសេនាសនៈដ៏សមគួរដល់សមាធិភាវនាដល់យោគាវចរ អ្នកមានសេចក្តីត្រូវការក្នុងការអប់រំចិត្ត ។

ដូច្នេះ យោគាវចរជា **អាទិកម្មិក** បុគ្គលអ្នកមានសេចក្តីប្រាថ្នាដើម្បីចម្រើននូវ **អានាបានស្សតិ** គប្បីគេចចេញពីទីច្រឡូកច្រឡំដោយពួកគណៈ និងទីមានសម្លេងគឹកកងរំពង ចូលទៅអាស្រ័យពួននៅក្នុងព្រៃស្ងាត់ ឬទៀបគល់ឈើស្ងាត់ ឬក្នុងផ្ទះស្ងាត់ ឬក្នុងតូបវិហារ ឬទីណាមួយដែលស្ងាត់ ជាទីដែលអាចដើម្បីងាយស្រួលក្នុងការចម្រើន **កម្មដ្ឋាន** ព្រោះថាឈានមានសម្លេងជាបន្លាផងកន្លែងដែលស្ងាត់នោះជាទីងាយស្រួលក្នុងការចម្រើននូវ **សមាធិភាវនា** ដើម្បីកិរិយាត្រាស់ដឹងនូវគុណវិសេសផង កាលបើយោគាវចរស្វែងរកបាននូវសេនាសនៈដ៏សមគួរដល់**សមាធិភាវនា**ហើយត្រូវអង្គុយ ព្រោះឥរិយាបថអង្គុយនេះជាឥរិយាបថស្ងប់ ជាចំណែកនៃឥរិយាបថមិនរួញរានៃចិត្ត និងភាពនៃចិត្តមិនរវើរវាយ ។

អង្គុយ គឺអង្គុយផ្គត់ភ្នែនឱ្យមាំមួនល្អ ព្រោះការអង្គុយនេះ ជាឥរិយាបថមួយនាំមកនូវសេចក្តីស្រួលក្នុងការប្រព្រឹត្តិឡើងចុះនៃខ្យល់ **អស្សាសបស្សាស** (ខ្យល់ដកដង្ហើមចេញនិងខ្យល់ដកដង្ហើមចូល) ផង ជាឧបាយនៃកិរិយាកាន់យកដោយជុំវិញនូវអារម្មណ៍ផង ។

បន្ទាប់មកត្រូវតម្កល់កាយឱ្យត្រង់ល្អ ព្រោះថា ការតម្កល់កាយឱ្យត្រង់ល្អនាំឱ្យស្បែក សាច់ សរសៃមិនទ្រោមចុះ, វេទនាមានការចុកចាប់ជាដើមដែលកើតឡើងអំពីស្បែក សាច់ សរសៃទ្រោមចុះសង្កត់គ្នានោះ ក៏មិនកើតឡើង. កាលបើវេទនាមិនកើតឡើងដូច្នេះ ចិត្តក៏មានអារម្មណ៍មូលតែមួយល្អ **កម្មដ្ឋាន** មិនធ្លាក់ចុះ ក៏ចូលដល់នូវសេចក្ដីសម្រើនទូលំទូលាយល្អ ។ បន្ទាប់មកត្រូវតម្កល់ **សតិ** គឺស្មារតីឱ្យមានមុខឆ្ពោះទៅរកព្រះ**អាណាបានស្សតិកម្មដ្ឋាន** ដែលខ្លួនត្រូវចម្រើនតទៅ ។ ត្រង់វិធីនេះជាកិច្ចសំខាន់បំផុត ព្រោះថាការចម្រើនកម្មដ្ឋានបើយោគាវចរមានចិត្តរាយមាយអណ្ដែតអណ្ដូងនោះ ក៏ចម្រើនមិនបានសម្រេច ព្រោះហេតុនោះ មុននឹងប្រារព្ធដើម្បីនឹករកខ្យល់ដកដង្ហើមចេញ និងខ្យល់ដកដង្ហើមចូល យោគាវចរត្រូវប្រមូលចិត្តឱ្យមូល ដកចិត្តចេញអំពីអារម្មណ៍ផ្សេងៗ ហើយតម្កល់ស្មារតីឱ្យនឹងមាំល្អ ឯវិធីដកចិត្តចេញអំពីអារម្មណ៍ផ្សេងៗ នោះ មានរបៀបដូចតទៅនេះ ៖

## ការប្រមូលចិត្តឱ្យមានអារម្មណ៍មូលតែមួយ

បុគ្គលអ្នកចម្រើន **កម្មដ្ឋាន** គប្បីធ្វើទុកក្នុងចិត្តនូវហេតុទាំង ៥ ប្រការដូចតទៅ:

## ហេតុ ៥ ប្រការ គឺ

**១- ចេញចាកអកុសលវិតក្កៈ** ប្រកបដោយ ឆន្ទៈ លោភៈ ទោសៈ មោហៈ ខ្លះដោយហេតុដទៃជា **កុសលវិតក្កៈ** ។

**២- ចេញចាកអកុសលវិតក្កៈ** ដោយកំណត់ឃើញទោសនៃ **អកុសលវិតក្កៈ** នោះ ។

**៣- ចេញចាកអកុសលវិតក្កៈ** ដោយការមិនរលឹក និងមិនធ្វើទុកក្នុងចិត្ត ក្នុងអារម្មណ៍ដែលនាំឱ្យកើត **អកុសលវិតក្កៈ** នោះ ។

**៤- ចេញចាកអកុសលវិតក្កៈ** ដោយធ្វើទុកក្នុងចិត្តនូវ **វិតក្កសង្ខារសណ្ឋាន** គឺហេតុជាទីតាំងនៃ **វិតក្កៈ** ទាំងនោះ ។

**៥- ចេញចាកអកុសលវិតក្កៈ** ដោយយកអណ្ដាតទល់នឹងពិដានខាងលើហើយខាំធ្មេញ ដាក់ចិត្តក្នុងទ្រូងអត់ដង្ហើមសង្កត់សង្កិនដុតកំដៅនូវ **អកុសលចិត្ត** ដោយ **កុសលចិត្ត** ។

វិធីទី ៥ នេះ ជាកិច្ចឧក្រិដ្ឋក្នុងការប្រមូលចិត្តឱ្យមូល ការធ្វើតាមរបៀបអត់ដង្ហើមនោះ មិនមែនធ្វើរាប់ម៉ោងឱ្យទាល់តែថប់ខ្យល់ ដកដង្ហើមមិនរួចដល់ដាច់ខ្យល់ស្លាប់ ឬប្រកាច់នោះទេ ។ វិធីនេះគ្រាន់តែជារបៀបប្រមូលចិត្តឱ្យមូលមួយរំពេច ឬមួយខណៈៗ ឱ្យចិត្តមូលក្នុងអារម្មណ៍តែមួយប៉ុណ្ណោះ ព្រោះថា **អកុសលវិតក្កៈ** ដែលចេះតែចម្រើនឡើងរឿយៗ មក តែមានកាយសង្ខារ គឺខ្យល់ដកដង្ហើមចេញ និងខ្យល់ដកដង្ហើមចូល កាលបើទប់ចិត្តក្នុងទ្រូងបិទខ្យល់លែងឱ្យមានការប្រព្រឹត្តិឡើងចុះទៅ អកុសលវិតក្កៈ ក៏រលត់ភ្លាមមួយរំពេច។

បន្ទាប់មក កាលបើចិត្តមូលក្នុងទ្រូងល្អហើយ យោគាវចរត្រូវមានស្មារតីរលឹកនូវខ្យល់ដកដង្ហើមចេញ និងខ្យល់ដកដង្ហើមចូលតែម្យ៉ាងប៉ុណ្ណោះ ក្នុងន័យនេះសូមយល់ចុះថា អារម្មណ៍តែមួយចិត្តតែមួយ ដែលកំពុងប្រាកដក្នុងបច្ចុប្បន្ន.

អារម្មណ៍តែមួយ គឺខ្យល់ដកដង្ហើមចេញនិងខ្យល់ដកដង្ហើមចូល ចិត្តតែមួយគឺ ចិត្តរលឹកនូវខ្យល់ដកដង្ហើមចេញ និងខ្យល់ដកដង្ហើមចូលតែម្យ៉ាង ដែលកំពុងប្រាកដក្នុងបច្ចុប្បន្ន គឺខ្យល់ក្តី ចិត្តក្តី ដែលកំពុងប្រព្រឹត្តទៅក្នុងខណៈដែលកំពុងផ្គត់ភ្ជែនចម្រើននោះឯង មិនបានកំណត់យកអារម្មណ៍ និងចិត្តក្នុងអតីតៈ ឬ អនាគតណាមួយឡើយ ។

យោគាវចរ គប្បីជាអ្នកមានចិត្តស្ថិតនៅខាងក្នុងទ្រូងតាំងនៅមាំល្អ ហើយ **អកុសលធម៌** មិនអាចគ្របសង្កត់ចិត្តបាន កាលបើចិត្តតាំងនៅល្អយ៉ាងនេះ ហើយក៏គប្បីបញ្ជូនស្មារតីរលឹកតាមដានខ្យល់ដកដង្ហើមចេញ និងខ្យល់ដកដង្ហើមចូលតែម្យ៉ាងតទៅ ។

## ត្រកូលនៃខ្យល់

## ខ្យល់មាន ៤ ត្រកូលគឺ

១- **ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាតិ** ភិក្ខុកាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថាអាត្មាអញដកដង្ហើមចេញវែង ។

**ទីឃំ វា បស្សសន្តោ ទីឃំ បស្សសាមីតិ បជានាតិ** ភិក្ខុកាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថាអាត្មាអញដកដង្ហើមចូលវែង ។

២- **រស្សំ វា អស្សសន្តោ រស្សំ អស្សសាមីតិ បជានាតិ** ភិក្ខុកាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថាអាត្មាអញដកដង្ហើមចេញខ្លី ។

**រស្សំ វា បស្សសន្តោ រស្សំ បស្សសាមីតិ បជានាតិ** ភិក្ខុកាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថាអាត្មាអញដកដង្ហើមចូលខ្លី ។

៣- **សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវកាយ គឺខ្យល់ចេញទាំងពួង ហើយដកដង្ហើមចេញ ។

**សព្វកាយប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវកាយគឺខ្យល់ចូលទាំងពួងហើយដកដង្ហើមចូល ។

៤- **បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ** (ភិក្ខុ)សិក្សាថា អាត្មាអញនឹងរំងាប់នូវកាយសង្ខារ[80] ដកដង្ហើមចេញ ។

**បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ** (ភិក្ខុ)សិក្សាថា អាត្មាអញនឹងរំងាប់នូវកាយសង្ខារដកដង្ហើមចូល ។

## សេចក្តីបំភ្លឺអំពីរកច្បប្រគបត្តក្នុខខ្យល់ ៤ គ្រកូល

យោគាវចរ កាលបើតម្កល់ចិត្តក្នុងទ្រូងនឹងល្អហើយ បន្ទាប់មកត្រូវដកដង្ហើមចេញវែង ដកដង្ហើមចូលវែងរឿយៗ ទន្ទឹមនឹងការដកដង្ហើមចេញវែងចូលវែងនោះត្រូវមានស្មារតីរលឹក និងញាណ ដឹងនូវខ្យល់ដកដង្ហើមចេញវែងចូលវែងដែលកំពុងប្រព្រឹត្តឡើងចុះនោះផង ។ ការចម្រើនដោយការរលឹក និង

---

[80] កាយសង្ខារ គឺអស្សាសបស្សាសៈ ។

ដឹងនូវខ្យល់ដកដង្ហើមចេញ ចូលវែង គឺយោគាវចរចេះតែចម្រើនទៅ សេពទៅ, ធ្វើទៅ, ធ្វើឱ្យច្រើនរឿយៗ ទៅ. ក្នុងពេលចម្រើនបើសិន**សតិ** និង**ញាណ**រលត់ គេចចេញពីខ្យល់ចេញ-ចូល គប្បីទាញទប់ចិត្តឱ្យមានសតិ និងញាណកំណត់ដឹងនូវខ្យល់ចេញ-ចូលវិញ ។ មុនដំបូងការហាត់**សតិ** និង**ញាណ**កំណត់ដឹងនូវខ្យល់ចេញ-ចូល យោគាវចរអ្នកសិក្សាថ្មីៗ នៅមានរលត់**សតិ** និង**ញាណ**ក្នុងកាលខ្លះ មិនរលត់ក្នុងកាលខ្លះជាធម្មតា តែដល់យោគាវចរព្យាយាមហាត់រលឹក ហាត់ដឹងនូវខ្យល់ចេញ-ចូលរឿយៗទៅ **សតិ** និង**ញាណ** ក៏ដល់នូវការចាស់ក្លាបន្តិចម្តងៗ រហូតដល់**សតិ** និង**ញាណ**លែងរលត់សោះ អាចកំណត់ដឹងនូវខ្យល់ដកដង្ហើមចេញវែង-ចូលវែង បានគ្រប់វារៈប្រព្រឹត្តឡើងចុះជាប្រក្រតីបាន ។ កាលបើខ្យល់ដកដង្ហើមចេញវែង-ចូលវែង ប្រព្រឹត្តទៅបានស្រួលជាប្រក្រតី ជាអារម្មណ៍របស់សតិ និងញាណ បន្ទាប់ក្រោយមកខ្យល់នោះក៏ធ្លាក់ចុះមកមានភាពខ្លីប្រព្រឹត្តឡើងចុះ កាលបើខ្យល់ដកដង្ហើមចេញខ្លី ចូលខ្លីកើតឡើងហើយ យោគាវចរត្រូវមានស្មារតីនិងញាណ កំណត់ដឹងនូវខ្យល់ដកដង្ហើមចេញខ្លី-ចូលខ្លី ឈប់គិតអំពីខ្យល់ដកដង្ហើមចេញវែង-ចូលវែង ។

កាលបើយោគាវចរមាន**សតិ** និង**ញាណ** កំពុងតែកំណត់ដឹងខ្យល់ដកដង្ហើមចេញខ្លី-ចូលខ្លី ក្នុងពេលនោះ សភាពនៃខ្យល់ក៏កើតឡើងយ៉ាងសម្បើម ប្រព្រឹត្តទៅក្នុងករជកាយ ពួកខ្យល់ខ្លះប្រព្រឹត្តឡើងទៅលើខ្លះ ប្រព្រឹត្តចុះក្រោមខ្លះប្រព្រឹត្តកាត់ទទឹងកាយ, ខ្លះមានសភាពជាដុំស៊កសៀតណែនក្នុងកាយ ខ្លះ

រាយបែកផ្សាយទៅពេញកាយ បណ្តាលឱ្យរសេបរសឹប តឹងមុខមាត់ ណែនខ្លួន ដៃ ជើង ពោះទ្រូង ក ក្បាលជាដើម ពួកខ្យល់ទាំងនេះមានសភាពគ្រោតគ្រាត ជាពួកខ្យល់ប្រព្រឹត្តទៅក្នុងកាយមិនទៀងទាត់សោះឡើយ កាលបើខ្យល់មានសភាពគ្រោតគ្រាតកើតឡើងហើយ តែងតាក់តែងទុក្ខវេទនាឱ្យកើតឡើង កាលបើទុក្ខវេទនានេះកើតឡើងហើយ ក្នុងខណៈនោះយោគាវចរអង្គខ្លះត្អូញត្អែរអំពីរឿងលំបាកតាមផ្លូវកាយខ្លះ ភ័យតក់ស្លុតខ្លាចស្លាប់រហូតដល់ឈប់ចម្រើននូវធម៌ក៏មាន។ ក្នុងបញ្ហាដែលយោគាវចរដល់នូវភាពជាអ្នកសោយនូវទុក្ខវេទនាយ៉ាងខ្លាំង ឬ ល្មម ឬថាបន្តិច ជាអ្នកតក់ស្លុតរន្ធត់ខ្លាចរអាចិត្តរហូតដល់លះបង់កម្មដ្ឋានឈប់ចម្រើនព្រោះតែសេចក្តីអាល័យក្នុងជីវិតនោះ ក៏មកតែអំពីធ្វើទុកក្នុងចិត្តមិនត្រូវទំនងតាមឧបាយនៃបញ្ញាមែនពិត ។

សេចក្តីពិតថាៈ ក្នុង **គម្ពីរវិសុទ្ធិមគ្គ** ភាគ ២ មានសេចក្តីថា កាលបើយោគាវចរមាន**សតិ**និង**ញាណ**កំណត់នូវខ្យល់ដកដង្ហើមចេញនិងចូលទៅ កាលបើមានសភាពខ្យល់គ្រោតគ្រាតកើតឡើងក្នុងករជកាយយ៉ាងច្រើន យោគាវចរមិនត្រូវមានចិត្តទៅជាប់ជំពាក់ក្នុងខ្យល់ទាំងអស់នោះឡើយ ត្រូវតែមាន**សតិ**និង**ញាណ**កំណត់ដឹងខាងដើម កណ្តាល និងខាងចុងនៃកាយ គឺខ្យល់ **អស្សាសបស្សាសៈ** ឱ្យពិតប្រាកដ ហើយដកដង្ហើមចេញ-ចូលតែម្យ៉ាងបានហើយ, កាលបើ យោគាវចរប្រតិបត្តិយ៉ាងនេះមិនយូរប៉ុន្មាន ពួកខ្យល់ដ៏គ្រោតគ្រាតដែលកើតហើយក្នុងករជកាយទាំងនោះក៏បាត់ទៅក៏ស្ងប់ទៅដោយពិត ។

ខាងដើម កណ្ដាល ខាងចុងនៃខ្យល់ **អស្សាសៈ** គឺខ្យល់ដកដង្ហើមចេញ ត្រង់ផ្ចិតជាខាងដើម បេះដូងជាកណ្ដាល ចុងច្រមុះជាខាងចុង ។

ខាងដើម កណ្ដាល ខាងចុងនៃខ្យល់ **បស្សាសៈ** ខ្យល់ដង្ហើមចូល ត្រង់ចុងច្រមុះជាខាងដើមនៃខ្យល់ បេះដូងជាកណ្ដាលនៃខ្យល់ ផ្ចិតជាខាងចុងនៃខ្យល់ ។

បញ្ជាក់ន័យថែមទៀតថា: កាលបើខ្យល់គ្រោតគ្រាតកើតឡើងពាសពេញក្នុងករជកាយ ត្រូវយោគាវចរតម្កល់ស្មារតី និងញាណត្រង់ចំណុច ៣ មានខាងដើមនៃខ្យល់ជាដើម ឱ្យស្មើល្អ ហើយដកដង្ហើម ចេញ-ចូល មិនយូរប៉ុន្មានកងខ្យល់គ្រោតគ្រាត ក៏ស្ងប់រលត់បាត់ទៅ ។

កាលបើខ្យល់គ្រោតគ្រាត ក្នុងករជកាយទាំងអស់ស្ងប់រម្ងាប់រលត់បាត់ទៅហើយ កាលបើពិនិត្យមើលខ្យល់ក្នុងករជកាយទាំងអស់នឹងឃើញថា: ខ្យល់ **អស្សាសបស្សាសៈ** មានសភាពល្អិតៗ ស្ដើងៗ ប្រព្រឹត្តឡើងចុះ, ទន្ទឹមនឹងខ្យល់ **អស្សាសបស្សាសៈ** ល្អិតប្រព្រឹត្តឡើងចុះនោះ ភាពត្រជាក់ស្រួលក៏ផ្សាយចេញទៅក្នុងករជកាយបន្តិចម្ដងៗ រហូតដល់ពេញករជកាយទាំងមូលមានសភាពត្រជាក់ទាំងអស់ កាលបើភាពត្រជាក់ផ្សាយទៅពេញស៊ប់ក្នុងករជកាយយ៉ាងនេះ សុខវេទនាក៏កើតឡើង ក្នុងខណៈដែលសុខវេទនាកើតឡើង យោគាវចរខ្លះក៏ដល់នូវសេចក្ដីរីករាយ ស្រស់ស្រាយសប្បាយចិត្ត រហូតដល់សរសើរប្រាប់ដល់សព្រហ្មចារីដែលនៅប្រតិបត្តិធម៌ជាមួយគ្នា ហើយក៏ជាប់ចិត្តក្នុងសុខវេទនានោះ ។ ក្នុងបញ្ហាកាលដែលសុខវេទនាកើតឡើងហើយ យោគាវចរបែរជាសរសើរ ហើយជាប់ចិត្តក្នុងសុខវេទនានោះមកតែអំពីការធ្វើទុកក្នុងចិត្ត មិនត្រូវតាមឧបាយនៃបញ្ញាមែនពិត ។

ក្នុងសេចក្ដីប្រតិបត្តិនេះ កាលបើសុខវេទនាកើតឡើងហើយ ព្រោះការត្រជាក់ស្រួលកើតឡើងក្នុងករជកាយ យោគាវចរមិនត្រូវជាប់ចិត្តរីករាយក្នុងសុខវេទនានោះទេ គប្បីខំប្រឹងកំណត់នូវក្រុមខ្យល់ **អស្សាសបស្សាសៈ** ដ៏ល្អិតនោះរឿយៗ បន្តទៅទៀត ខ្យល់**អស្សាសបស្សាៈ** ដ៏ល្អិតដែលជាអារម្មណ៍របស់**សតិ**និង**ញាណ**នោះ ដែលយោគាវចរមាន**សតិ**និង**ញាណ**កំណត់ដឹង, ចម្រើន, សេព, ធ្វើឱ្យច្រើន ហើយកាន់តែល្អិតទៅៗ ហ្មត់ទៅៗ រហូតដល់ល្អិតក្រៃពេកមិនដល់នូវការប្រព្រឹត្តិឡើងចុះបានមែនពិត ។ កាលបើព្រះយោគីបានចម្រើននូវខ្យល់ **អស្សាសបស្សាសៈ** តាមលំដាប់នៃត្រកូលខ្យល់ទាំង ៤ បានល្អហើយត្រូវចម្រើននូវ**កម្មដ្ឋាន**នោះ ឱ្យបានស្ទាត់ជំនាញគ្រប់ឥរិយាបថទាំង ៤ គឺ ដេក ដើរ ឈរ អង្គុយ ថែមទៀត ដើម្បីធ្វើឱ្យស្ទាត់ជំនាញល្អ ។

ក្នុងខណៈ ដែលព្រះយោគីតាមដានខ្យល់**អស្សាសបស្សាសៈ** ល្អិតនោះរឿយៗនៅ ខ្យល់ល្អិតនោះក៏ដល់នូវការរលត់ទៅ សូន្យទៅ អស់ទៅម្ដងៗ ហើយកើតឡើងវិញញឹកញាប់ៗ, ចិត្តក្នុងខណៈនេះ ក៏ដល់នូវភាពនឹងល្អ ហៅថា**សមាធិ**ចិត្តដោយពិត មានអារម្មណ៍តែមួយ ។ រីឯសភាពនៃចិត្តក្នុងខណៈ ដែលមានខ្យល់ល្អិតៗ ជាអារម្មណ៍ ឬមានខ្យល់អស់សូន្យតាមខណៈៗ ជាអារម្មណ៍ ពេលខ្លះប្រកបដោយ**សោមនស្សវេទនា** ព្រោះមានសេចក្ដីសុខកើតឡើង ពេលខ្លះប្រកបដោយ**ឧបេក្ខាវេទនា** ជាចិត្តមានសភាពស្មើៗ កណ្ដាលៗ ប្រព្រឹត្តទៅព្រងើយកន្តើយ ព្រោះរលត់នូវ សុខវេទនា, ទុក្ខវេទនា សោមនស្សវេទនា, ទោមនស្សវេទនា, តែចិត្តប្រកបដោយ **ឧបេក្ខាវេទនា** ដែលកើតឡើងនោះ មុនដំបូងជាចិត្តទន់ស្រាលជាបរិត្តចិត្តកើតឡើង ១ ខណៈៗ ផ្សាយទៅហើយរលត់ទៅវិញ ។

# ការរក្សាឧបេក្ខាចិត្តឱ្យរឹងមាំ

យោគាវចរដែលបានចម្រើន **អានាបានស្សតិសមាធិ** បានសម្រេចនូវចិត្តមានសភាពជា **ឧបេក្ខា** ត្រូវហាត់បង្វឹកធ្វើចិត្តជា**ឧបេក្ខា**ឱ្យបានចាស់ក្លារឹងមាំដោយវសីទាំង ៥ ។

***វសី*** ការស្ទាត់ជំនាញ ៥ យ៉ាងគឺ

១- ***អាវជ្ជនវសី*** ស្ទាត់ក្នុងការនឹករកអង្គឈាន ។

២- ***សមាបជ្ជនវសី*** ស្ទាត់ក្នុងការចូលកាន់អង្គឈាន ។

៣- ***អធិដ្ឋានវសី*** ស្ទាត់ក្នុងការតម្កល់ទុកអង្គឈាន ។

៤- ***វុដ្ឋានវសី*** ស្ទាត់ក្នុងការចេញចាកអង្គឈាន ។

៥- ***បច្ចវេក្ខណវសី*** ស្ទាត់ក្នុងការពិចារណាលះបង់អង្គឈាន ។

ឯវិធីហាត់បង្វឹកចិត្តឱ្យបានជា**ឧបេក្ខា**បានឆាប់រហ័សទាន់ចិត្តនោះ គឺយោគាវចរត្រូវប្រតិបត្តិចម្រើនព្រះ **អានាបានស្សតិកម្មដ្ឋាន** តាមលំដាប់ខ្យល់ ៤ ត្រកូលនោះឯង គ្រប់ឥរិយាបថទាំង ៤ ចម្រើនរឿយៗ សេពរឿយៗ ធ្វើឱ្យច្រើនទៅ យូរៗ ទៅ យោគាវចរនោះ នឹងបាននូវចិត្តជា**ឧបេក្ខា**បានឆាប់រហ័សទាន់ចិត្តយ៉ាងពិតប្រាកដ ។

**ឧបេក្ខា**ចិត្ត ដែលស្ទាត់ជំនាញ តែងបានក្នុងខណៈចិត្តទី ៤ ឬ ទី ៥ បើជា **វិប្បាភិញ្ញា** បុគ្គល (បុគ្គលអ្នកត្រាស់ឆាប់)**ឧបេក្ខា**បានក្នុងខណៈចិត្តទី៤ ដូច្នេះ

គឺ **ឧបចារជវ័ន** ១ **អនុលោមជវ័ន** ១ **គោត្រភូជវ័ន** ១ **ឧបេក្ខាជវ័ន** ១។ បើជា **ឆន្ទាភិញ្ញា**បុគ្គល (បុគ្គលអ្នកត្រាស់ដឹងយឺត) **ឧបេក្ខា**បានក្នុងខណៈចិត្តទី ៥ គឺបរិកម្មជវ័ន ១ ឧបចារជវ័ន ១ អនុលោមជវ័ន ១ គោត្រភូជវ័ន ១ ឧបេក្ខាជវ័ន ១ ។

## សេចក្ដីពន្យល់
## អំពីការកើតឡើងនៃឧបេក្ខាចិត្ត

យោគីដែលជាឆន្ទាភិញ្ញាបុគ្គល កាលចម្រើននូវអានាបានស្សតិកម្មដ្ឋានរហូតបាន**ឧបេក្ខាចិត្ត** មានសភាពនៃចិត្តកើតឡើងដូច្នេះ គឺចិត្តដែលនឹករកខ្យល់ដកដង្ហើមចេញ-ចូល ហើយរលត់ទៅភ្លាមមួយរំពេច ហៅថា **បរិកម្មជវ័ន** ។

សភាពដែលចិត្តស្ទុះទៅ កើតអំពីបរិកម្មស្ងប់ប្រព្រឹត្តទៅ ដើម្បីបាន **ឧបេក្ខា** ហើយរលត់ភ្លាមមួយរំពេច ហៅថា **ឧបចារជវ័ន** ។

សភាពដែលចិត្តស្ទុះទៅដ៏សមគួរ ដើម្បីបាន **ឧបេក្ខា** ហើយរលត់ភ្លាមមួយរំពេច ហៅថា **អនុលោមជវ័ន** ។

សភាពនៃចិត្តដែលគ្របសង្កត់នូវចិត្តដទៃទៀត ហើយញ៉ាំង**ឧបេក្ខា**ឱ្យកើតឡើង ហើយរលត់ទៅវិញភ្លាមមួយខណៈ ហៅថា **គោត្រភូជវ័ន** ។

**ឧបេក្ខាជវ័ន** ចិត្តដែលសោយអារម្មណ៍ស្មើៗ កណ្ដាលព្រងើយកន្តើយ ។

រីឯដំណើរនៃ**ឧបេក្ខា**ចិត្តរបស់**ខិប្បាភិញ្ញា**បុគ្គល យោគីគប្បីជ្រាបតាមសេចក្ដីដែលបានពោលមកនេះចុះសេចក្ដីប្លែកនៃចិត្តរបស់**ខិប្បាភិញ្ញា**បុគ្គលគ្រាន់

តែគ្មាន**បរិកម្មដវែ**ប៉ុណ្ណោះ កាលបើយោគីជាអ្នកមាន**សតិ**និង**ញាណ**តាមដាន ខ្យល់ ៤ ត្រកូល ដូចបានពោលរួចមកហើយជាអ្នកមានស្មារតីរលឹកនិងដឹងគ្រប់វារៈ នៃខ្យល់ដែលប្រព្រឹត្តឡើងនិងចុះស្ថិតនៅដោយឥរិយាបថ ៤ បានយ៉ាងនេះហើយ, ហើយថែមទាំងកំណត់ដឹងរហូតដល់ក្រុមខ្យល់ដែលរលត់ និងកើតឡើងវិញដ៏ល្អិត សុខុមក្នុងកាយទៀតផង យោគីនោះនឹងជាអ្នកមានសតិនិងញាណកើតឡើងវិញ ក្នុងការចម្រើនព្រះកម្មដ្ឋានដោយពិតប្រាកដ ព្រោះថាយោគីនោះជាអ្នកអាចកំណត់ ដឹងនូវកាលទាំង ៣ បាន គឺកាលប្រារព្ធនឹងចម្រើនកម្មដ្ឋាន ១ កាលកំពុងចម្រើននូវ កម្មដ្ឋាន ១ កាលដែលចេញចាកកម្មដ្ឋាន ១ ។ កាលបន្ទាប់អំពីការចម្រើននូវ **អាណាបានស្សតិកម្មដ្ឋាន**មកបើយោគីមានសេចក្តីប្រាថ្នា ដើម្បីចម្រើននូវកម្មដ្ឋាន ដទៃទៀតនោះ ក៏គប្បីគោរពប្រតិបត្តិទៅតាមអត្ថន័យពិត ក្នុងកម្មដ្ឋានទាំងនោះ ដែលព្រះដ៏មានព្រះភាគ និងព្រះអដ្ឋកថាចារ្យ លោកបានសំដែងទុកមកហើយ ដោយប្រពៃ។

ការលើកឡើងនូវបញ្ហា និងការបកស្រាយចំពោះព្រះកម្មដ្ឋានទាំងប៉ុណ្ណោះ ដើម្បីគ្រាន់តែជាគ្រឿងជួយផ្តល់ដល់សតិប្រាជ្ញា នៃសាធុជនទាំងឡាយអ្នកមាន សេចក្តីប្រាថ្នាប្រតិបត្តិក្នុងការរើខ្លួនឱ្យផុតចាកសំសារៈទុក្ខប៉ុណ្ណោះឯង ។ បន្ទាប់អំពីនេះទៅនឹងពោលអំពីកិច្ចប្រតិបត្តិក្នុង **កម្មដ្ឋាន** ដទៃបន្តទៅទៀត ។

## មរណានុស្សតិ

កាលបើព្រះយោគាវចរកុលបុត្រមានប្រាថ្នា ដើម្បីចម្រើននូវ មរណានុស្សតិ **កម្មដ្ឋាន** គប្បីចូលទៅកាន់ទីដែលស្ងាត់ចាកអារម្មណ៍ផ្សេងៗ ហើយធ្វើទុកក្នុងចិត្ត

ដោយឧបាយថា **មរណំ ភវិស្សតិ ជីវិតិន្ទ្រិយំ ឧបច្ឆិជ្ជិស្សតិ** សេចក្តីស្លាប់គង់តែនឹងមាន **ជីវិតិន្ទ្រិយ** មុខជានឹងដាច់បង់ទៅ ឬថា **មរណំ មរណំ** សេចក្តីស្លាប់ៗ ដូចនេះក៏បាន ។

បើធ្វើទុកក្នុងចិត្ត ដោយឧបាយយ៉ាងនេះហើយ **នីវរណធម៌**ទាំង ៥ មិនទាន់ទ្រោមចុះ ស្មារតីមិនទាន់តាំងនៅ **កម្មដ្ឋាន**មិនទាន់ដល់នូវ**ឧបចារៈ** ត្រូវឱ្យរលឹកដល់សេចក្តីស្លាប់ ដោយអាការ ៨ យ៉ាងតទៅទៀត ។

## អាការ ៨ យ៉ាងគឺ

១- **វធកបច្ចុបដ្ឋានតោ** ត្រូវរលឹកថា សេចក្តីស្លាប់តាំងឡើងប្រាកដ ដូចជាសត្រូវដាដាវផ្គងដាក់លើក ។

២- **សម្បត្តិវិបត្តិតោ** ត្រូវរលឹកថា ធម្មតាសម្បត្តិក្នុងលោកសុទ្ធតែកន្លងនូវវិបត្តិពុំបាន ។

៣- **ឧបសំហរណតោ** ត្រូវរលឹកដល់ សេចក្តីស្លាប់របស់ខ្លួន ប្រៀបដោយសេចក្តីស្លាប់របស់អ្នកដទៃ ។

៤- **កាយពហុសាធារណតោ** ត្រូវរលឹកថា កាយនេះ ទូទៅដល់អន្តរាយច្រើនប្រការ មានត្រកូលនៃសត្វដង្កូវ ៨០ ជាដើម ។

៥- **អាយុទុព្វលតោៈ** ត្រូវរលឹកថា អាយុនេះមានកម្លាំងថយពន់ពេក ព្រោះថាជីវិតរបស់សត្វទាំងឡាយជាប់ទៅដោយខ្យល់អស្សាសបស្សាសៈជាដើម។

៦- **អនិមិត្តតោ** ត្រូវរលឹកថា "សេចក្តីស្លាប់មិនមានកំណត់ ព្រោះថាជីវិតជាដើមរបស់សត្វទាំងឡាយរកកំណត់មិនបាន"[81] ។

៧- **អទ្ធានបរិច្ឆេទតោ** ត្រូវរលឹកថា "ជីវិតរបស់មនុស្សក្នុងកាលឥឡូវនេះកំណត់យ៉ាងយូរបំផុតត្រឹម ១ រយឆ្នាំ[82] បើលើសក៏បន្តិចបន្តួច" ។

៨- **ខណបរិត្តតោ** ត្រូវរលឹកថា "ជីវិតក្ខណៈរបស់សត្វទាំងឡាយ បើពោលតាម **បរមត្ថ** តូចពេកណាស់ ប្រព្រឹត្តទៅបានតែត្រឹម ១ ខណៈចិត្តប៉ុណ្ណោះឯង" ។

បណ្តាអាការទាំង ៨ យ៉ាងនេះ ត្រង់អាការទី ៣ ដែលថាត្រូវរលឹកដល់សេចក្តីស្លាប់របស់ខ្លួន ប្រៀបដោយសេចក្តីស្លាប់របស់អ្នកដទៃនោះ ត្រូវប្រៀបដោយសេចក្តីស្លាប់របស់បុគ្គល ៧ ពួកគឺ

១- **យសមហត្តតោ** ប្រៀបដោយសេចក្តីស្លាប់របស់បុគ្គលមានយសបរិវារច្រើន មានស្តេច **មហាសម្មតិរាជ** និងស្តេច **មន្ធាតុ** ជាដើម ។

២- **បុញ្ញមហត្តតោ** ប្រៀបដោយសេចក្តីស្លាប់របស់បុគ្គលដែលមានបុណ្យច្រើន មានជោតិកសេដ្ឋី និងជដិលសេដ្ឋីជាដើម ។

---

[81] ធម៌ដែលកំណត់មិនបានក្នុងជីវលោកមាន ៥ យ៉ាងគឺ: ជីវិតៈ ១ ព្យាធិ ១ កាលៈ ១ ទេហនិក្ខេបនៈ ១ គតិ ១។

[82] កំណត់នេះតាមជំនាន់ដើម ។

៣- ជាមមហត្តតោះ ប្រៀបដោយសេចក្តីស្លាប់របស់បុគ្គល ដែលមានកម្លាំងច្រើន មានស្តេចវាសុទេវ និងស្តេចពលទេវជាដើម ។

៤- ឥទ្ធិមហត្តតោះ ប្រៀបដោយសេចក្តីស្លាប់របស់បុគ្គល ដែលមានឫទ្ធិច្រើន ដូចព្រះ មោគ្គលានត្ថេរ ។

៥- បញ្ញាមហត្តតោះ ប្រៀបដោយសេចក្តីស្លាប់របស់បុគ្គល ដែលមានប្រាជ្ញាច្រើន ដូចព្រះ សារីបុត្តត្ថេរ ។

៦- បច្ចេកពុទ្ធតោះ ប្រៀបដោយបរិនិព្វានរបស់ព្រះ បច្ចេកពុទ្ធ ។

៧- សម្មាសម្ពុទ្ធតោះ ប្រៀបដោយបរិនិព្វានរបស់ព្រះ សម្មាសម្ពុទ្ធ ។

**មុច្ឆា** ត្រូវប្រៀបធៀបដូចម្តេចសេចក្តីស្លាប់របស់បុគ្គលទាំង ៧ ពួកនេះ?

**ខស្សជ្ជនា** ត្រូវប្រៀបថា: "អម្បាលដូចបុគ្គលដែលថ្កើងថ្កានដល់ម្លោះ គង់កន្លងមិនផុតអំពីសេចក្តីស្លាប់ទៅបាន ចំណង់បើអាត្មាអញជាបុគ្គលថោកថយដល់ម្លេះ ដូចម្តេចនឹងកន្លងឱ្យផុតអំពីសេចក្តីស្លាប់ទៅបាន" ។

កាលបើព្រះយោគីរឭកដល់សេចក្តីស្លាប់ដោយអាការទាំង ៨ យ៉ាងដែលធ្វើទុកក្នុងចិត្តរឿយៗ ចិត្តក៏សេពនូវភាវនាដោយច្រើន ស្មារតីក៏តម្កល់នៅ មានសេចក្តីស្លាប់ជាអារម្មណ៍ **នីវរណធម៌**ក៏ទ្រោមចុះ អង្គឈានទាំង ៥ គឺ **វិតក្ក** ១ **វិចារ** ១ **បីតិ** ១ **សុខៈ** ១. **ឯកគ្គតា** ១, ក៏កើតឡើងប្រាកដ. តែក្នុងមរណានុស្សតិកម្មដ្ឋាន នេះមានអំណាចឱ្យសម្រេចបានតែត្រឹម**ឧបចារជ្ឈាន**ប៉ុណ្ណោះ មិនអាចឱ្យសម្រេចដល់អប្បនាឈានបានឡើយ, សេចក្តីស្លាប់ជាសភាវធម៌ផង ព្រោះភាពនៃសេចក្តីស្លាប់ជាធម្មជាតិគឺបុគ្គលគប្បីសង្វេគផង ទើប**កម្មដ្ឋាន**នេះលោកហៅថា "មរណស្សតិ" ព្រោះកើតឡើងដោយកម្លាំង **មរណស្សតិ** ។

# អានិសង្សនៃមរណស្សតិ

យោគីដែលមាន **មរណស្សតិ** ប្រកបរឿយៗ ហើយនិងជាអ្នកមិនប្រមាទ រមែងបានចំពោះនូវសេចក្តីមិនត្រេកអរក្នុងភពទាំងអស់, លះបង់នូវសេចក្តីប្រាថ្នាក្នុងជីវិត, ជាអ្នកតិះដៀលជាប្រក្រតីចំពោះអំពើបាប, ច្រើនដោយការមិនសន្សំទុក្ខនិងមិនមានសេចក្តីត្រេកអរក្នុងបរិក្ខារទាំងឡាយ, ជាអ្នកមានអនិច្ចសញ្ញា, ទុក្ខសញ្ញា អនត្តសញ្ញា សន្សំហើយ ។ ម្យ៉ាងទៀតយោគីនោះ ក្នុងពេលស្លាប់ជាបុគ្គលមិនមានភ័យ មិនវង្វេង ធ្វើមរណកាលទៅ ប្រសិនបើមិនទាន់បានត្រាស់ដឹងនូវអមតធម៌ក្នុងបច្ចុប្បន្នទេ បន្ទាប់អំពីបែកធ្លាយនូវកាយនិងមានសុគតិប្រព្រឹត្តទៅក្នុងខាងមុខ ព្រោះហេតុនោះទើបលោកចងគាថាទុកមកថា:

តស្មា ហវេ អប្បមាទំ     កយិរាថ សុមេធសោ
ឯវំ មហានុភាវាយ     មរណស្សតិយា សទា ។

បានសេចក្តីថា: ព្រោះហេតុនោះ យោគីអ្នកមានប្រាជ្ញាល្អ គប្បីធ្វើនូវសេចក្តីមិនប្រមាទតែម្យ៉ាងក្នុង **មរណស្សតិ** ដែលមានអានុភាពធំយ៉ាងនេះឱ្យបានសព្វកាល ។

# ឧបសមានុស្សតិ

កាលបើព្រះយោគាវចរកុលបុត្រមានប្រាថ្នា ដើម្បីចម្រើននូវ **ឧបសមានុស្សតិកម្មដ្ឋាន** គប្បីចូលទៅកាន់ទីស្ងាត់ចាកអារម្មណ៍ផ្សេងៗ ហើយរលឹកដល់គុណរបស់ព្រះនិព្វានដែលជាគ្រឿងរម្ងាប់បង់នូវសំសារទុក្ខទាំងពួង តាមលំអានព្រះ

បាលីដូចនេះជាដើមថា **យាវតា ភិក្ខវេ ធម្មា សង្ខតា វា អសង្ខតា វា វិរាគោ តេសំ ធម្មានំ អគ្គមក្ខាយតិ** ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងប៉ុន្មានទោះជា សង្ខត ក្តី ជា អសង្ខត ក្តី មានតែ វិរាគធម៌ គឺតួព្រះនិព្វានឯង ប្រាកដប្រសើរដោយវិសេសជាងធម៌ទាំងឡាយនោះ **យទិទំ មទនិម្មទនោ បិបាសវិនយោ អាលយសមុគ្ឃាតោ វដ្ដុ-បច្ឆេទោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ** វិរាគធម៌នេះ ជាគ្រឿងញុំាញីនូវសេចក្តីស្រវឹង ជាគ្រឿងបណ្តេញនូវសេចក្តីស្រេកឃ្លានក្នុងកាម ជាគ្រឿងដកនូវសេចក្តីអាល័យក្នុងកាមគុណ ជាគ្រឿងកាត់បង់**តេភូមិកវដ្ដ** ជាគ្រឿងអស់ទៅនៃតណ្ហា ជាគ្រឿងលាចាកតណ្ហា ជាទីរលត់ទៅនៃតណ្ហា ចេញរួចស្រឡះហើយចាកព្រៃស្បាតគឺតណ្ហា ។

ដោយអំណាចនៃយោគីនឹករលឹករឿយៗ នូវគុណនៃព្រះនិព្វាន តាមន័យដែលពោលមកយ៉ាងនេះ គុណវិសេសទាំងឡាយ មានចិត្តស្ងប់ចាកកិលេសមានរាគៈជាដើម កើតឡើងតាមលំដាប់រហូតដល់អង្គនៃ**ឧបចារជ្ឈាន** ក៏មានសភាពកើតឡើងដូចក្នុង **ពុទ្ធានុស្សតិកម្មដ្ឋាន** ដូចបានពោលខាងដើមរួចហើយដែរ ។

**កម្មដ្ឋាន** នេះ មានអានុភាពឱ្យសម្រេចត្រឹម **ឧបចារជ្ឈាន** ប៉ុណ្ណោះ មិនអាចនឹងឱ្យដល់ **អប្បនាឈាន** បានឡើយ ព្រោះ**ឧបសមគុណា**ជាគម្ភីរភាព យោគីមិនអាចរឭកឱ្យសព្វគ្រប់បាន ។

**កម្មដ្ឋាន** នេះ ឈ្មោះថា **ឧបសមានុស្សតិ** ព្រោះកើតឡើងដោយអំណាចនៃកិរិយារឭកនូវ **ឧបសមគុណ** ។

**កម្មដ្ឋាន** នេះ ដែលយោគីចម្រើនទៅឱ្យបានសម្រេចនូវគុណពេញលេញល្អ រមែងសម្រេចដល់ព្រះអរិយបុគ្គលតែម្យ៉ាង ។ រីឯ **អនុស្សតិ ៦** ខាងដើម មាន **ពុទ្ធានុស្សតិ** ១, **ធម្មានុស្សតិ** ១, **សង្ឃានុស្សតិ** ១, **សីលានុស្សតិ** ១, **ចាគានុស្សតិ** ១, **ទេវតានុស្សតិ** ១ ក៏មានគុណសម្រេចល្អនៃព្រះកម្មដ្ឋានដូចគ្នានឹង **ឧបសមានុស្សតិ** ដែរ ។ សូម្បី**ឧបសមានុស្សតិ**មានគុណសម្រេចពេញលេញល្អរមែងសម្រេចដល់ព្រះអរិយបុគ្គលតែម្យ៉ាងក៏ដោយ បុថុជ្ជនដែលធ្ងន់ក្នុងព្រះនិព្វាន ក៏គប្បីធ្វើទុកក្នុងចិត្តរឿយៗ ព្រោះថាសូម្បីត្រឹមតែអំណាចនៃការស្តាប់ប៉ុណ្ណោះ ក៏ចិត្តរបស់បុថុជ្ជនរមែងជ្រះថ្លាក្នុងព្រះនិព្វានទៅហើយដែរ ។

## អានិសង្សនៃឧបសមានុស្សតិ

យោគី ដែលមាន **ឧបសមានុស្សតិ** ប្រកបរឿយៗ ហើយ ។

- រមែងដេកជាសុខ
- រមែងភ្ញាក់ឡើងពីដេក ក៏ជាសុខ ។
- មានឥន្ទ្រិយស្ងប់រម្ងាប់ល្អ ។
- មានចិត្តស្ងប់ ។
- ប្រកបព្រមដោយ **ហិរិ** និង **ឧត្តប្បៈ** ។
- ជាបុគ្គលប្រកបដោយសេចក្តីជ្រះថ្លានៃមហាជន ។
- ជាបុគ្គលមានចិត្តលិចចុះក្នុងគុណដ៏ប្រណីត គឺព្រះនិព្វាន ។

- ជាទីគោរព និងជាទីសរសើរនៃសព្រហ្មចារី
- កាលមិនទាន់ត្រាស់ដឹងនូវ **ឧត្តរធម៌** រមែងមានសុគតិប្រព្រឹត្តទៅក្នុងខាងមុខ ។

ព្រោះហេតុនោះ ទើបលោកចងគាថាទុកមកថាៈ

**តស្មា ហវេ អប្បមត្តោ ភាវយេថ វិចក្ខណោ**
**ឯវំ អនេកានិសំសំ អរិយេ ឧបសមេ សតឹ ។**

បានសេចក្តីថាៈ ព្រោះហេតុនោះ អ្នកប្រាជ្ញជាអ្នកមិនមានសេចក្តីប្រមាទមែនពិត គួរចម្រើននូវសតិក្នុង**ឧបសមគុណ**ដ៏ប្រសើរដែលមានអានិសង្សច្រើនជាអនេកយ៉ាងនេះ ។

## អាហារេបដិកូលសញ្ញា

សញ្ញាដែលកើតឡើង ដោយអំណាចកាន់យកនូវអាការជាបដិកូលក្នុង**កពឡិង្ការាហារ**[83] ។

---

[83] អាហារ សព្ទប្រែថា សភាពដែលនាំមក ។ អាហារមាន ៤ គឺ កពឡិង្ការាហារ ១, ផស្សាហារ ១, មនោសញ្ចេតនាហារ ១, វិញ្ញាណាហារ ១ ។ កពឡិង្ការាហារនាំមកនូវឱជដ្ឋករូប, ផស្សាហារ នាំមកនូវវេទនា ៣, មនោសញ្ចេតនាហារនាំមកនូវបដិសន្ធិក្នុងភព ៣ វិញ្ញាណាហារនាំមកនូវរូបក្នុងបដិសន្ធិខណៈ ។ និកន្តិភយកើតក្នុងកពឡិង្ការាហារ ឧបគមនភយ កើតក្នុងផស្សាហារ, ឧបបត្តិកភយ កើតក្នុងមនោសញ្ចេតនាហារ. បដិសន្ធិភយ កើតក្នុងវិញ្ញាណាហារ ។ កពឡិង្ការាហារ ប្រៀបដូចសាច់របស់កូន, ផស្សាហារប្រៀបដូចមេគោឥតស្បែក មនោសញ្ចេតនាហារ ប្រៀបដោយភ្នក់នៃភ្លើង ងងើកភ្លើង, វិញ្ញាណាហារ ប្រៀបដោយមុខនៃលំពែង ។ (ក្នុងទីនេះសំដៅយកតែកពឡិង្ការាហារ) ។

ភាពជាបដិកូលដោយអាការ ១០ យ៉ាងគឺៈ

១- **គមនតោ:** បដិកូលដោយដំណើរដើរ ។

**អធិប្បាយថា:** គប្បីពិចារណាឱ្យឃើញថា អាហារនោះ ជាបដិកូលគួរខ្ពើម តាំងតែអំពីចុះចាកទីសេនាសនៈឆ្ពោះទៅកាន់ស្រុកជាទីគោចរ ដើរលុយកាត់ភក់ជ្រាំ ជាន់លើវត្ថុមិនស្អាតផ្សេងៗ មានមូត្រ និងករីសជាដើម ។

២- **បរិយេសនតោ:** បដិកូលដោយស្វែងរក ។

**អធិប្បាយថា:** គប្បីពិចារណាឱ្យឃើញថា អាហារនោះ ជាបដិកូលគួរខ្ពើមដោយដើរស្វែងរកតត្រុករុករាន សព្វសំយាបផ្ទះអ្នកស្រុក ប្រទះឆ្កែដេញ ខាំ គោក្របីដេញជល់ រុយខៀវហើរមកទុំលើក្បាល ក៏មានមនុស្សខ្លះឱ្យ ខ្លះមិនឱ្យ ខ្លះឱ្យតិច ខ្លះឱ្យច្រើន ខ្លះឱ្យបាយផ្អូម បង្អែមចាស់ ខ្លះធ្វើជាមិនឃើញ ខ្លះពោលពាក្យត្រគោះបោះបោក ផ្សេងៗ ជាដើម ។

៣- **បរិភោគតោ:** បដិកូលដោយបរិភោគ ។

**អធិប្បាយថា:** គប្បីពិចារណាឱ្យឃើញថា "អាហារនោះជាបដិកូលគួរខ្ពើមដោយបរិភោគចាប់កាន់ដោយម្រាមដៃ ញើសក្អែលហូរស្រក់ចូលទៅ ដល់ដាក់មកក្នុងមាត់ ទោះអាហារនោះប៉ុន្មានមុខក្តី ក៏ច្របល់លាយគ្នាទាំងអស់ហើយទំពាលំអិតដោយធ្មេញ គ្រលេវប្រមូលដោយអណ្តាត ផ្សើមដោយទឹកមាត់មានសណ្ឋានដូចជាកំអួតឆ្កែ ប្រឡាក់ប្រឡូកជាប់នៅដោយជើងធ្មេញជាដើមគួរឱ្យខ្ពើម រអើមក្រៃពេក" ។

**៤- អាសយតោ:** បដិកូលដោយទីអាស្រ័យ ។

**អធិប្បាយថា:** ទីអាស្រ័យ (**អាសយ**) មាន ៤ គឺ **បិត្តាសយ** ទីអាស្រ័យរបស់ប្រមាត់ ១, **សេម្ហាសយ** ទីអាស្រ័យរបស់ស្លេស្ម ១, **បុព្វាសយ** ទីអាស្រ័យរបស់ខ្ទុះ ១, លោហិតាសយ ទីអាស្រ័យរបស់ឈាម ១, ក្នុងអាសយទាំង ៤ យ៉ាងនេះ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងស្ដេចចក្រពត្តិមានមួយៗ, ឯបុគ្គលដែលមានបុណ្យតិច មានប្រាជ្ញាទន់ មានគ្រប់ទាំង ៤, ហេតុនោះ បើបុគ្គលណាដែលមានទីអាស្រ័យរបស់ប្រមាត់ច្រើន អាហារដែលបុគ្គលនោះលេបចូលទៅ ដូចជាប្រឡាក់ដោយប្រេងស្រគំយ៉ាងខាប់ គួរខ្ពើមក្រៃពេក, បុគ្គលដែលមានទីអាស្រ័យរបស់ស្លេស្មច្រើន ដូចជាប្រឡាក់ដោយរសនៃផ្លែខ្ទឹង ឬស្លឹកខ្ទឹង, បុគ្គលដែលមានទីអាស្រ័យរបស់ខ្ទុះច្រើន ដូចជាប្រឡាក់ដោយតក្កផ្អូម (ទឹកដោះគោមួយបែបដែលគេដាំ មួយភ្លើងហើយយកមកតម្កល់ទុកគឺទឹកដោះរូន), បុគ្គលដែលមានទីអាស្រ័យរបស់ឈាមច្រើន ដូចជាប្រឡាក់ដោយទឹកជ្រលក់គួរខ្ពើមក្រៃពេក. ព្រះយោគី គប្បីពិចារណាឱ្យឃើញថា អាហារជាបដិកូលគួរខ្ពើម ដោយទីអាស្រ័យ ដូចន័យដែលពោលមកនេះ។

**៥- និធានតោ:** បដិកូលដោយកន្លែង ដែលតម្កល់នៅក្នុងផ្ទៃ ។

**អធិប្បាយថា:** ព្រះយោគីពិចារណា នូវភាពជាបដិកូលរបស់អាហារ ដោយកន្លែងដែលតម្កល់នៅថា: អាហារដែលប្រឡាក់ដោយអាសយទាំង ៤ ណាមួយហើយចូលទៅកាន់ផ្ទៃនោះ មិនមែននៅតម្កល់នៅក្នុងភាជន៍មាសជាដើមឡើយ គឺបើបុគ្គលអ្នកលេបចូលទៅនោះអាយុបាន ១០ ឆ្នាំ ២០ ឆ្នាំ ។ល។ មួយរយឆ្នាំ ក៏ទៅតម្កល់នៅក្នុងឱកាសប្រាកដស្មើដោយរណ្ដៅលាមក (អាចម៍) ដែលគេខានលាងអស់ ១០ ឆ្នាំ ២០ ឆ្នាំ ។ល។

**៦- អបរិបក្កតោ:** បដិកូលដោយភាព ដែលមិនទាន់រលួយ ។

**អធិប្បាយ** ព្រះយោគីគប្បីពិចារណានូវភាពជាបដិកូលរបស់អាហារដែលមិនទាន់រលួយថា អាហារដែលចូលទៅហើយសូម្បីអាហារនោះទើបបរិភោគក្នុងថ្ងៃនោះក្តី បរិភោគក្នុងថ្ងៃម្សិលក្តី ក្នុងថ្ងៃមុនៗ មកក្តី ក៏ទៅផ្តុំនៅជាមួយគ្នាទាំងអស់រួបរឹតទៅដោយជុំស្លេស្ម ភ្លើងធាតុក្នុងកាយចំហុយ កម្តៅបែកទៅជាពពុះតូច ធំ អាប់អួដោយក្លិនអសុភផ្សេងៗ មុខគួរឱ្យខ្ពើមរអើមក្រៃពេក ។

**៧- បរិបក្កតោ:** បដិកូលដោយភាព ដែលរលួយហើយ ។

**អធិប្បាយ** ព្រះយោគីគប្បីពិចារណានូវភាពជាបដិកូលរបស់អាហារដែលរលួយហើយថា អាហារដែលភ្លើងធាតុក្នុងកាយ ដុតកម្តៅឱ្យរលួយហើយនោះក៏មិនមែនក្លាយទៅជាមាសឬប្រាក់ជាដើមឡើយ គ្រាន់តែបញ្ចេញនូវពពុះនិងក្រពេញតូច-ធំ ហើយណាដែលដល់នូវភាពជាអាហារចាស់ក៏ចូលទៅតម្កល់នៅក្នុងលំនៅនៃអាហារចាស់ ហាក់ដូចជាដីស្អិតមានពណ៌លឿងដែលគេកិនឱ្យជ្រាយហើយដាក់ចុះក្នុងបំពង់ ណាដែលដល់នូវភាពជាទឹកមូត្រក៏ជ្រាបចូលទៅដក់នៅក្នុងផ្លោកមូត្រប៉ុណ្ណោះគួរឱ្យខ្ពើមរអើមក្រៃពេក ។

**៨- ផលតោ:** បដិកូលដោយផល ។

**អធិប្បាយ** ព្រះយោគីគប្បីពិចារណានូវភាពជាបដិកូលរបស់អាហារដែលឱ្យផលមកថា អាហារនេះ ណាដែលរលួយទៅដោយល្អ ក៏ញ៉ាំងសាកអសុភទាំងឡាយ មានសក់និងរោមជាដើមឱ្យចម្រើនស្រស់ស្រោងឡើង ណាដែលមិនរលួយល្អ ក៏បណ្តាលឱ្យកើតទៅជារោគច្រើនប្រការមានកមនិងរមាស់ជាដើម ។

៩- **និស្សន្ទតោ:** បដិកូលដោយហូរចេញ ។

**អធិប្បាយថា:** ព្រះយោគីគប្បីពិចារណានូវភាពជាដិកូលរបស់អាហារ ដែលហូរចេញមកវិញថា អាហារនេះកាលដែលលេបចូលទៅតែតាមទ្វារ ១ ដល់ហូរចេញមកវិញតាមទ្វារច្រើនជាអនេក ណាដែលចេញតាមភ្នែក ហៅថាពពឹកភ្នែក ដែលចេញមកតាមត្រចៀកហៅថា អាចម៍ត្រចៀកជាដើម ពុំនោះសោតគប្បីពិចារណាឱ្យឃើញជាបដិកូលថា: អាហារនេះកាលដែលលេបចូលទៅអំពាវនាវរកគ្នាច្រើនមកជួបជុំបរិភោគរីករាយសប្បាយចិត្ត ដល់ក្លាយទៅជាឧច្ចារៈ និងបស្សាវៈជាដើម ហើយហូរចេញមកវិញក៏ទៅពួនសម្ងំបញ្ចេញម្នាក់ឯងក្នុងទីស្ងាត់មុខគួរឱ្យអៀនខ្មាស់ក្រៃពេក ។

១០- **សម្មក្ខនតោ:** បដិកូលដោយប្រឡាក់ប្រឡូស ។

**អធិប្បាយថា:** ព្រះយោគីគប្បីពិចារណានូវភាពជាបដិកូលរបស់អាហារដោយប្រឡាក់ប្រឡូសថា អាហារនេះកាលដែលបរិភោគ ក៏ប្រឡាក់ដៃនិងបបូរមាត់ជាដើម ដល់បរិភោគរួចហើយភ្លើងធាតុក្នុងកាយផាត់ច្រានទៅសព្វសរីរៈទាំងមូល ក៏ត្រូវប្រឡាក់នៅត្រង់ធ្មេញ ត្រង់អណ្តាត ទ្វារតូច ទ្វារធំជាដើម មុខគួរឱ្យខ្ពើមរអើមក្រៃពេក ។

កាលបើព្រះយោគីពិចារណាត្រិះរិះនូវភាពជាបដិកូល របស់អាហារដោយអាការទាំង ១០ ដូចបានពោលមកយ៉ាងនេះហើយ **កពឡិង្ការាហារ**ក៏នឹងប្រាកដឡើងដោយអាការបដិកូល ។ បើព្រះយោគី សេពនូវនិមិត្តនោះដោយច្រើន ចម្រើន

ឱ្យរឿយឡើងទៅ **នីវរណធម៌**ទាំងឡាយក៏ទ្រោមចុះទៅ ចិត្តក៏តម្កល់នៅមាំដោយ **ឧបចារសមាធិ** តែក្នុង**កម្មដ្ឋាន**នេះឱ្យសម្រេចតែត្រឹម**ឧបចារជ្ឈាន**ប៉ុណ្ណោះ មិនអាចឱ្យសម្រេចដល់**អប្បនាឈាន** បានឡើយ ព្រោះ**កពឡិង្ការាហារ**ជាគម្ភីរភាពជ្រាលជ្រៅតាមសភាពធម្មតា ។

**សញ្ញា** រមែងមានប្រាកដក្នុង**កម្មដ្ឋាន**ដោយអំណាចនៃកិរិយាកាន់យកនូវ**អាការបដិក្កូល** ព្រោះហេតុនោះ**កម្មដ្ឋាន**នេះ ក៏ដល់នូវការរាប់ហៅថា **អាហារេបដិក្កូលសញ្ញា** ។

## អានិសង្សនៃអាហារេបដិក្កូលសញ្ញា

ចិត្តរបស់យោគីដែលមាន**កម្មដ្ឋាន**នេះចម្រើនហើយ រមែងលាចេញចាកសេចក្ដីប្រាថ្នាក្នុងរស ។ យោគីនោះមិនមានសេចក្ដីស្រវឹងក្នុងកាលលេបចូលនូវអាហារដែលបរិភោគចូលទៅ ដើម្បីប្រយោជន៍ដល់កិរិយាចេញចាកទុក្ខ ដូចជាបុរសដែលមានសេចក្ដីត្រូវការឆ្លងចាកផ្លូវឆ្ងាយដាច់ស្រយាល ហើយស៊ីសាច់នៃកូនដូច្នោះ ។

យោគី ដែលមានការកំណត់ដឹងនូវ **កពឡិង្ការាហារ** ដែលមានសេចក្ដីលំបាកតិច តែងដល់នូវការកំណត់ដឹងនូវរាគៈដែលប្រកបដោយកាមគុណ ៥ មានរូបជាដើមបានពិត ។

យោគីនោះរមែងដឹងច្បាស់នូវគំនរនៃរូប ព្រោះកិរិយាកំណត់ដឹងនូវកាមគុណ ៥ នោះថែមទៀត ។

សូម្បី **កាយគតាសតិភាវនា** ក៏ឈ្មោះថាយោគីនោះដឹងនូវការពេញបរិបូរដោយអំណាចនៃបដិកូលភាពនោះ ។

ម្យ៉ាងទៀតព្រះយោគីនោះ នឹងជាអ្នកដល់នូវការបដិបត្តិដ៏សមគួរដល់ **អសុភសញ្ញា** ផង. កាលបើអាស្រ័យនូវការប្រតិបត្តិនេះហើយមិនទាន់បានត្រាស់ដឹង **ឧត្តរធម៌** ក្នុងបច្ចុប្បន្ននេះទេ ក៏នឹងបានប្រព្រឹត្តទៅក្នុងសុគតិខាងមុខដោយពិត ។

## ចតុធាតុវវដ្ឋាន

កិរិយាកំណត់នូវលក្ខណៈរបស់ធាតុទាំង ៤ ហៅថា **ចតុធាតុវវដ្ឋានកម្មដ្ឋាន** ។ ធាតុទាំង ៤ នោះ គឺ**បឋវីធាតុ** ធាតុដី ១, **អាបោធាតុ** ធាតុទឹក ១, **តេជោធាតុ** ធាតុភ្លើង ១, **វាយោធាតុ** ធាតុខ្យល់ ១។

ធាតុទាំង ៤ នេះ លោកសម្ដែងឱ្យពិស្ដារដោយអាការ ៤២ យ៉ាងគឺ **បឋវីធាតុ** មានអាការ ២០. **អាបោធាតុ** មានអាការ ១២, **តេជោធាតុ** មានអាការ ៤, **វាយោធាតុ** មានអាការ ៦ ។

## បឋវីធាតុ មានអាការ ២០ គឺ

**កេសា** សក់ទាំងឡាយ ១, **លោមា** រោមទាំងឡាយ ១, **នខា** ក្រចកទាំងឡាយ ១, **ទន្តា** ធ្មេញទាំងឡាយ ១, **តចោ** ស្បែក ១, **មំសំ** សាច់ ១, **ន្ហារូ** សរសៃទាំងឡាយ ១, **អដ្ឋិ** ឆ្អឹងទាំងឡាយ ១, **អដ្ឋិមិញ្ជំ** ខួរក្នុងឆ្អឹង ១, **វក្កំ**

តម្រងបស្សាវៈ ១, **ហទយំ** បេះដូង ១, **យកនំ** ថ្លើម ១, **កិលោមកំ** វាវ ១, **បិហកំ** ក្រពះ១, **បប្ផាសំ** សួត ១, **អន្តំ** ពោះវៀនធំ ១, **អន្តគុណំ** ពោះវៀនតូច ១, **ឧទរិយំ** អាហារថ្មី ១, **ករីសំ** អាហារចាស់ ១, **មត្ថលុង្គំ** ខួរក្នុងក្បាល ១ ។

## អាបោធាតុមានអាការ ១២ ឥ

**បិត្តំ** ប្រមាត់ ១, **សេម្ហំ** ស្លេស្ម ១, **បុព្វោ** ខ្ទុះ ១, **លោហិតំ** ឈាម ១, **សេទោ** ញើស ១, **មេទោ** ខ្លាញ់ខាប់ ១, **អស្សុ** ទឹកភ្នែក ១, **វសា** ខ្លាញ់រាវ ១, **ខេឡោ** ទឹកមាត់ ១, **សង្ឃាណិកា** ទឹកសម្បោរ ១, **លសិកា** ទឹករំអិល ១, **មុត្តំ** ទឹកមូត្រ ១ ។

## តេជោមានអាការ ៤ ឥ

១- សន្តប្បតិ ភ្លើងដែលញុំាងកាយឱ្យក្តៅសព្វ ។
២- ជីរីយតិ ភ្លើងដែលញុំាងកាយឱ្យចាស់គ្រាំគ្រា ។
៣- បរិឌយ្ហតិ ភ្លើងដែលញុំាងកាយឱ្យក្តៅពេលរាល ។
៤- សម្មា បរិណាមំ គច្ឆតិ ភ្លើងដែលញុំាងអាហារឱ្យទ្រោមទៅដោយល្អ

## វាយោធាតុមានអាការ ៦ ឥ

១- ឧទ្ធង្គមា វាតា ខ្យល់ដែលផាត់ឡើងទៅលើ ។

២- អធោគមា វាតា  ខ្យល់ដែលផាត់ទៅខាងក្រោម ។

៣- កុច្ឆិសយា វាតា  ខ្យល់ដែលផាត់ទៅនៅខាងក្រៅពោះវៀន ។

៤- កោដ្ឋាសយា វាតា ខ្យល់ដែលផាត់នៅខាងក្នុងពោះវៀន ។

៥- អង្គមង្គានុសារិនោ វាតា ខ្យល់ដែលផាត់ផ្សាយទៅសព្វសពាង្គកាយ ។

៦- អស្សាសបស្សាសា វាតា ខ្យល់ដកដង្ហើមចេញ-ចូល ។

## លក្ខណៈរបស់ធាតុ ៤ ដូចនេះគឺ

**បថវីធាតុ** មានលក្ខណៈរឹងគ្រោតគ្រាត, **អាបោធាតុ** មានលក្ខណៈរាវសម្រាប់ផ្សារទុកនូវកាយ, **តេជោធាតុ** មានលក្ខណៈក្តៅសម្រាប់ចម្អិនទុកនូវកាយ, **វាយោធាតុ** មានលក្ខណៈរហើយៗ សម្រាប់បក់ផាត់នូវកាយ ។

កាលបើព្រះយោគាវចរកុលបុត្រ មានប្រាថ្នាដើម្បីចម្រើននូវកម្មដ្ឋាននេះ គប្បីចូលទៅកាន់ទីដែលស្ងាត់ចាកអារម្មណ៍ផ្សេងៗ ហើយសន្សំមពិចារណាធ្វើទុកក្នុងចិត្ត តាមវិធីដែលនឹងពោលទៅក្នុងខាងមុខ ។ តែកម្មដ្ឋាននេះ មានវិធីចម្រើន ២ បែប តាមសមគួរដល់យោគី ដែលមានប្រាជ្ញាក្លានិងប្រាជ្ញាទន់ ។

បើព្រះយោគីដែលមានប្រាជ្ញាក្លា គប្បីនឹករំពឹងស្រាវយកនូវកាយរបស់ខ្លួនទាំងមូលមកពិចារណា ធ្វើទុកក្នុងចិត្តរឿយៗ ឱ្យឃើញគ្រាន់តែជាធាតុ ៤ មិនមែនសត្វ មិនមែនជីវិត តាមន័យយ៉ាងសង្ខេបដូចនេះថា នៅក្នុងកាយរបស់ណាដែលមានលក្ខណៈរឹង មានអាការគ្រោតគ្រាត ចាត់ទុកជាធាតុដី

ដែលមានលក្ខណៈសម្រាប់ផ្សារទុកនូវកាយ មានអាការរាវ ចាត់ទុកជាធាតុទឹក ដែលមានលក្ខណៈសម្រាប់ចម្អិននូវកាយ មានអាការក្តៅ ចាត់ទុកជាធាតុភ្លើង ដែលមានលក្ខណៈសម្រាប់បក់ផាត់នូវកាយ មានអាការរហើយ ៗ ចាត់ទុកជាធាតុខ្យល់, គ្រាន់តែព្រះយោគីព្យាយាមធ្វើទុកក្នុងចិត្តប៉ុណ្ណោះ ឧបចារសមាធិក៏នឹងកើតឡើង តែមិនដល់នូវអប្បនាសមាធិឡើយ ព្រោះកម្មដ្ឋាននេះ មានអារម្មណ៍ជាសភាវធម៌ ។

យោគីមានប្រាជ្ញាទន់ គប្បីរៀនយកនូវធាតុទាំង ៤ ឱ្យពិស្តារអំពីសំណាក់នៃអាចារ្យ ដោយអាការ ៤២ ដូចបានពោលហើយ គប្បីចម្រើនដោយអាការ ៤ យ៉ាងដូចតទៅនេះគឺ

១- **សសម្ភារសង្ខេបតោ** ចម្រើនដោយបំព្រួញតាមសម្ភាររបស់ខ្លួន ។

សេចក្តីថា: គប្បីកំណត់នូវអាការដែលរឹងក្នុងកោដ្ឋាសៈ ២០ ថាជាធាតុដី អាការដែលរាវសម្រាប់ផ្សារទុកនូវកាយ ក្នុងកោដ្ឋាសៈ ១២ ថាធាតុទឹក អាការដែលក្តៅ សម្រាប់ចម្អិននូវកាយ ក្នុងកោដ្ឋាសៈ ៤ ថាជា ធាតុភ្លើង អាការដែលរហើយ ៗ សម្រាប់បក់ផាត់នូវកាយក្នុងកោដ្ឋាសៈ ៦ ថាធាតុខ្យល់ ។

២- **សសម្ភារវិភត្តិតោ** ចម្រើនដោយកិរិយាចែកតាមសម្ភាររបស់ខ្លួន ។

សេចក្តីថា: គប្បីចម្រើនតាមវិធីឧគ្គហកោសល្ល ៧ យ៉ាង និងអប្បនា-កោសល្ល ១០ យ៉ាង (នឹងមានពោលក្នុងកាយគតាសតិកម្មដ្ឋានក្នុងខាងមុខ)

ប្លែកគ្នាខ្លះ តែត្រង់ក្នុង**កាយគតាសតិកម្មដ្ឋាន** ត្រូវធ្វើទុកក្នុងចិត្តដោយបដិកូលឯកម្មដ្ឋាននេះ ត្រូវធ្វើទុកក្នុងចិត្តដោយធាតុ និងក្នុង**កាយគតាសតិកម្មដ្ឋាន** មានអាការតែ ៣២ ឯក្នុង**កម្មដ្ឋាន**នេះ មានអាការ ៤២ ។

៣- ***សលក្ខណសង្ខេបតោ:*** ចម្រើនបំប្រួញតាមលក្ខណ: របស់ខ្លួន

**សេចក្តីថា:** ដូចក្នុងអាការទី ១ ប្លែកគ្នាតែថា ***អាការ*** និង ***លក្ខណ:*** ប៉ុណ្ណោះ។ គឺថាក្នុងអាការទី ១ ត្រូវកំណត់នូវអាការរឹងជាដើមក្នុង **កោដ្ឋាស:** នោះ ៗ ថាជាធាតុនោះ ៗ ។

៤- ***សលក្ខណវិភត្តិតោ:*** ចម្រើនដោយកិរិយាចែកតាមលក្ខណ: របស់ខ្លួន ។

**សេចក្តីថា:** គប្បីកំណត់នូវលក្ខណ:ដែលរឹង លក្ខណ:ដែលរាវ សម្រាប់ផ្សារទុកនូវកាយ លក្ខណ:ដែលក្តៅសម្រាប់ចម្អិនទុកនូវកាយ លក្ខណ:ដែលរហើយៗ សម្រាប់បក់ផាត់នូវកាយ ក្នុង**កោដ្ឋាស:**ទាំង ៣២ មានសក់ជាដើម កំណត់តែក្នុង**កោដ្ឋាស:**នីមួយៗ ឱ្យឃើញមានធាតុបួនៗ គ្រប់**កោដ្ឋាស:** ទាំង ៣២ ។

កាលបើព្រះយោគីបានចម្រើនអាការទាំង ៤ យ៉ាងដូចបានពោលមកយ៉ាងនេះហើយ ជួនកាលតែដោយអាការមួយៗ ក៏**ឧបចារសមាធិ**កើតឡើងបាន តែបើមិនទាន់កើតឡើង ក៏គប្បីធ្វើទុកក្នុងចិត្តដូចនូវធាតុទាំង ៤ ដោយអាការ ១៣ យ៉ាងតទៅទៀត ។

# អាការ ១៣ យ៉ាងគឺ

១- *វចនត្ថតោ* ត្រូវធ្វើទុកក្នុងចិត្តដោយតែអត្ថរបស់ពាក្យ ។

**សេចក្តីថា:** ធាតុទាំង ៤ មានសេចក្តីដោយឡែក អំពីគ្នាដូចនេះគឺ សភាពដែលក្រាសឬលាតត្រដាងហៅថា ***បឋវី*** សភាពដែលជ្រាបសើមទូទៅ ហៅថា ***អាបោ*** សភាពដែលក្តៅហៅថា ***តេជោ*** សភាពដែលបក់ផាត់ហៅថា ***វាយោ*** ធម្មជាតិដែលទ្រទ្រង់ទុកនូវលក្ខណៈរបស់ខ្លួន ដែលគាត់តែងសំសារទុក្ខ ឬបង្ហូរមកនូវទុក្ខប្រមាណមិនបាន ហៅថា ***ធាតុ*** ត្រូវធ្វើទុកក្នុងចិត្ត ដោយកែបទរបស់ពាក្យយ៉ាងនេះ ។

២- ***កលាបតោ*** ត្រូវធ្វើទុកក្នុងចិត្តដោយកលាប ។

**សេចក្តីថា:** គ្រប់***កោដ្ឋាសៈ*** ទាំងអស់ដែលលោកសន្មតឱ្យហៅថា សក់ រោមជាដើម សុទ្ធតែសន្មតដោយប្រជុំនៃធម៌ ៨ យ៉ាង គឺ ***វណ្ណៈ*** ១, ***គន្ធ*** ១, ***រសៈ*** ១, ***ឱជា*** ១, ***ធាតុ ៤*** ដូចគ្នាទាំងអស់ តែកោដ្ឋាសៈណាដែលជា***កម្មសមុដ្ឋាន*** នោះ លោកសន្មតដោយប្រជុំនៃធម៌ ១០ គឺថែម ***ជីវិតិន្ទ្រិយ*** ១, ***ឥត្ថីភាវៈ*** ឬ ***បុរិសភាវៈ*** ១ ទៀត ហើយដែលលោករាប់ថា ***បឋវីធាតុ អាបោធាតុ*** នោះ តាមដោយធាតុដែលផ្សាយឡើងច្រើន ត្រូវធ្វើទុកក្នុងចិត្តដោយកលាបយ៉ាងនេះ ។

៣- ***ចុណ្ណតោ*** ត្រូវធ្វើទុកក្នុងចិត្តដោយលំអិត ។

សេចក្ដីថា: បឋវីធាតុក្នុងសរីរៈនេះ បើកំណត់ត្រឹមពាក់កណ្ដាលមកខាងលើ ហើយលំអិតឱ្យម៉ត់ជាផង់ធូលីជាបរមាណុ[84] ទៅទៀតប្រមាណបាន ១ ទោណ[85] ប៉ុណ្ណោះ ហើយមាន**អាបោធាតុ**ប្រមាណកន្លះទោណប្រុងទុក **តេជោធាតុ** ជួយរក្សាទុក **វាយោធាតុ** ជួយបក់ផាត់ទុកមិនឱ្យខ្ចាត់ខ្ចាយទៅបាន, **អាបោធាតុ តេជោធាតុ** និង **វាយោធាតុ** តម្កល់នៅក្នុង **បឋវីធាតុ** ជួយប្រុងទុក រក្សាទុក បក់ផាត់ទុកនូវគ្នានិងគ្នា មិនឱ្យជ្រាបហូរទៅបាន ចម្អិនបក់ផាត់នូវកាយមិនឱ្យរលួយទៅបាន ត្រូវធ្វើទុកក្នុងចិត្តដោយលំអិតយ៉ាងនេះ ។

៤- **លក្ខណាទិតោ** ត្រូវធ្វើទុកក្នុងចិត្តដោយលក្ខណៈជាដើម ។

**សេចក្ដីថា: បឋវីធាតុ** មានភាពដែលរឹងគ្រោតគ្រាតជាលក្ខណៈ មានភាពដែលជាទីតម្កល់នៃសហជាតធម៌ជាកិច្ច មានកិរិយាទទួលរងទុកនូវសហជាតធម៌ជាផល ។

---

[84] ពាក្យថា បរមាណុ នេះជាវិធីវាប់មួយបែប ។ កេចិអាចារ្យពោលថា ភាគទី ៨ នៃអង្គុលិជា យវ ១, ភាគទី ៨ នៃយវជាឱកា ១, ភាគទី ៨ នៃឱកាជាលិក្ខា ១, ភាគទី ៨ នៃលិក្ខាជារថរេណុ, ភាគទី៨ នៃរថរេណុជាតជ្ជារី ១, ភាគទី ៨ នៃតជ្ជារីជាអណុ ១, ភាគទី ៨ នៃអណុជាបរមាណុ ១, ។ តែអដ្ឋកថាចារ្យពោលថា អង្គុលី ១ មានធញ្ញមាស ៧, ធញ្ញមាស ១ មានឱកា ៧, ឱកា ១ មានលិក្ខា ៧, លិក្ខា ១ មានរថរេណុ ៣៦, រថរេណុ ១ មានតជ្ជារី ៣៦, តជ្ជារី ១ មានអណុ ៣៦, អណុ ១ មានបរមាណុ ៣៦ ។

[85] ទោណ នេះជាវិធីវាល់ ឬថ្លឹងមួយបែបមានប្រមាណ ១៦ នាឡិប្រក្រតី ឬ ១២នាឡិ អ្នកមគធៈ ។ វិធីគិតប្រមាណដូចនេះ គឺក្តាប់ដោយប្រក្រតីជាកុឌុវ, ៤ កុឌុវជា ១ នាឡិ, ១៦ នាឡិ ជា១ ទោណ ។

**អាចោធាតុ** មានកិរិយាហូរទៅជាលក្ខណៈ មានកិរិយាចម្រើននូវសហជាតធម៌ជាកិច្ច មានកិរិយាប្រុងទុកនូវសហជាតធម៌ជាផល ។

**តេជោធាតុ** មានភាពដែលក្តៅជាលក្ខណៈ មានកិរិយាចម្អិនទុកនូវសហជាតធម៌កិច្ច មានកិរិយាប្រគល់ឱ្យនូវភាពដែលទន់របស់សហជាតធម៌ជាផល ។

**វាយោធាតុ** មានភាពដែលរបើយៗ ជាលក្ខណៈ មានកិរិយាបក់ផាត់នូវសហជាតធម៌ជាកិច្ច មានកិរិយានាំទៅនូវសហជាតធម៌ជាផល ត្រូវធ្វើទុកក្នុងចិត្តដោយលក្ខណៈជាដើមយ៉ាងនេះ ។

**៤- សមុដ្ឋានតោ** ត្រូវធ្វើទុកក្នុងចិត្តដោយ**សមុដ្ឋាន** ។

**សេចក្តីថា:** ក្នុង**កោដ្ឋាសៈ**ទាំង ៤២ មានសក់ជាដើម មានខ្យល់ដកដង្ហើមចេញចូលជាទីបំផុតនោះ អាហារថ្មី ១, អាហារចាស់ ១, ខ្ទុះ ១, ទឹកមូត្រ ១ ទាំង ៤ នេះមានរដូវជាដែនកើត, ទឹកភ្នែក ១, ញើស ១, ទឹកមាត់ ១, ទឹកសំបោរ ១ ទាំង ៤ នេះជួនកាលមានរដូវជាដែនកើត ជួនកាលមានចិត្តជាដែនកើត, **តេជោធាតុ** ដែលចំអិននូវអាហារ ដែលបុគ្គលបរិភោគចូលទៅ មានកម្មជាដែនកើត, ខ្យល់ដង្ហើមចេញ និង ចូល មានចិត្តជាដែនកើត . **កោដ្ឋាសៈ** សល់អំពីនោះ ៣២ មានរដូវ ចិត្ត កម្ម អាហារ គ្រប់ទាំង ៤ ជាដែនកើត ត្រូវធ្វើទុកក្នុងចិត្តដោយ**សមុដ្ឋាន**យ៉ាងនេះ ។

៦- **ឆានត្តេកត្តតោ** ត្រូវធ្វើទុកក្នុងចិត្ត ដោយភាពដែលផ្សេងៗ គ្នានិង ភាពដែលដូចគ្នា ។

**សេចក្ដីថា:** ធាតុទាំងនោះ មានលក្ខណៈ និងកិច្ច និងផលផ្សេងៗ គ្នា ក៏ពិត តែថាសុទ្ធតែបានឈ្មោះថា "*រូប*" ដូចគ្នា ព្រោះមិនកន្លងនូវលក្ខណៈដែលវិនាស បានឈ្មោះថា **មហាភូត** ដូចគ្នា ព្រោះហេតុដែលប្រាកដឡើងធំ ៗ ជាដើម[86] មានឈ្មោះថា "**ធាតុ**" ដូចគ្នា ព្រោះមិនកន្លងនូវធាតុលក្ខណៈ ដែលទ្រទ្រង់នូវលក្ខណៈរបស់ខ្លួន និងតាក់តែងនូវសំសារទុក្ខ ឬបង្ហូរមកនូវទុក្ខប្រមាណមិនបាន, បានឈ្មោះ "**ធម៌**" ដូចគ្នា ព្រោះទ្រទ្រង់ទុកនូវលក្ខណៈរបស់ខ្លួន ហើយទ្រទ្រង់ទុកតាមសមគួរដល់ខណៈរបស់ខ្លួន សុទ្ធតែមិនទៀងដូចគ្នា ព្រោះតែងតែអស់ទៅ ពុកផុយទៅ. សុទ្ធតែជាទុក្ខដូចគ្នា ព្រោះតែងតែប្រកបដោយភ័យ សុទ្ធតែមិនមែនជារបស់ខ្លួនដូចគ្នា ព្រោះមិនមានខ្លឹមសារសោះឡើយ ត្រូវធ្វើទុកក្នុងចិត្តដោយភាពដែលផ្សេងគ្នា និងភាពដែលត្រូវគ្នាយ៉ាងនេះ ។

---

[86] ធាតុទាំង ៤ បានឈ្មោះថា មហាភូត ដោយហេតុ ៥ យ៉ាងគឺ មហន្តបាតុភាវតោ កើតប្រាកដឡើងធំៗ ១ មហាភូតសាមញ្ញតោ ទូទៅដោយហេតុដែលមិនពិតច្រើនប្រការ ១ មហាបរិហារតោ ត្រូវរក្សាដោយបច្ច័យដ៏ច្រើន ១ មហាវិការតោ មានពិការច្រើន ១ មហត្តា ភូតត្តា ហៅថាមហា ព្រោះព្រះយោគី ត្រូវកំណត់ដោយព្យាយាមដ៏ធំ ហៅថា ភូត ព្រោះជារបស់មាននៅ ១ .

៧- **វិនិព្ភោគាវិនិព្ភោគតោ** ធ្វើទុកក្នុងចិត្តដោយភាពដែលបែកចាកគ្នានិងមិនបែកចាកគ្នា ។

**សេចក្តីថា:** ធាតុទាំង ៤ នេះ កាលកើតឡើងក៏កើតឡើងព្រមគ្នា កាលប្រព្រឹត្តទៅក៏ប្រព្រឹត្តព្រមគ្នា មិនដែលបែកចាកគ្នាក្នុងកលាបណាមួយឡើយ តែទុកណាដូចជានោះ ក៏គង់បែកចាកគ្នាដោយលក្ខណៈដែលផ្សេងគ្នា. ត្រូវធ្វើទុកក្នុងចិត្តដោយភាពដែលបែកចាកគ្នា និងមិនបែកចាកគ្នាយ៉ាងនេះ ។

៨- **សភាគវិសភាគតោ** ត្រូវធ្វើទុកក្នុងចិត្ត ដោយភាពដែលមានចំណែកស្មើគ្នា និងមិនស្មើគ្នា ។

**សេចក្តីថា:** បណ្តាធាតុទាំង ៤ នេះ ធាតុ ២ ខាងដើម **គឺបឋវីធាតុ**និង**អាបោធាតុ** មានចំណែកស្មើគ្នា ព្រោះមានភាពធ្ងន់ដូចគ្នា ធាតុ ២ ខាងចុង គឺ**តេជោធាតុ វាយោធាតុ** មានចំណែកស្មើគ្នា ព្រោះមានភាពស្រាលដូចគ្នា តែថាធាតុ ២ ខាងដើម និង ២ ខាងចុងមានចំណែកមិនស្មើគ្នា ព្រោះធាតុ ២ ខាងដើមមានភាពធ្ងន់ ឯធាតុ ២ ខាងចុងមានភាពស្រាល ត្រូវធ្វើទុកក្នុងចិត្ត ដោយភាពដែលមានចំណែកស្មើគ្នា និង មិនស្មើគ្នាយ៉ាងនេះ ។

៩- **អជ្ឈត្តិកពាហិរវិសេសតោ** ត្រូវធ្វើទុកក្នុងចិត្ត ដោយភាពដែលប្លែកគ្នារបស់ធាតុជាខាងក្នុង និងធាតុជាខាងក្រៅ ។

**សេចក្តីថា:** ធាតុខាងក្នុងជាទីអាស្រ័យរបស់ **វិញ្ញាណវត្ថុ** ៦[87] មាន **ចក្ខុវិញ្ញាណ**ជាដើមផង ជាទីអាស្រ័យរបស់វិញ្ញត្តិទាំង ២ គឺ**កាយវិញ្ញត្តិ** និង **វចីវិញ្ញត្តិ** ផង ជាទីអាស្រ័យរបស់**ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ** និង**ជីវិតិន្ទ្រិយ**ផង ហើយប្រកបដោយឥរិយាបថ មាន**សមុដ្ឋាន**ទាំង ៤ ឯធាតុខាងក្រៅមិនមែនដូច្នេះឡើយ ត្រូវធ្វើទុកក្នុងចិត្ត ដោយភាពដែលប្លែកគ្នារបស់ធាតុខាងក្នុង និងធាតុជាខាងក្រៅយ៉ាងនេះ ។

១០- *សង្គហតោ* ត្រូវធ្វើទុកក្នុងចិត្ត ដោយសង្គ្រោះ ។

**សេចក្តីថា:** ***បឋវីធាតុ***ណាដែលមានកម្មជាដែនកើត លោកសង្គ្រោះចូលជាមួយគ្នាដោយ ***អាបោធាតុ តេជោធាតុ វាយោធាតុ*** ណាដែលមានកម្មជាដែនកើត ព្រោះមានជាតិស្មើគ្នា, ***បឋវីធាតុ*** ណាដែលមានចិត្តជាដើមជាដែនកើតក៏លោកសង្គ្រោះចូលជាមួយគ្នាដោយ ***អាបោធាតុ តេជោធាតុ វាយោធាតុ*** ណាដែលមានចិត្តជាដើមជាដែនកើតដូចគ្នា ត្រូវធ្វើទុកក្នុងចិត្ត ដោយសង្គ្រោះយ៉ាងនេះ ។

១១- **បច្ចយតោ:** ត្រូវធ្វើទុកក្នុងចិត្តដោយបច្ច័យ ។

**សេចក្តីថា:** ***បឋវីធាតុ*** ដែល ***អាបោធាតុ*** ជួយប្រុងទុក ***តេជោធាតុ*** ជួយរក្សាទុក ***វាយោធាតុ*** ជួយបក់ផាត់ទុក ជាបច្ច័យ ជាទីពឹងផ្អែកនៃមហាភូតទាំង

---

[87] វិញ្ញាណដែលអាស្រ័យនូវវត្ថុទាំង ៦ មានចក្ខុវត្ថុជាដើម ហើយកើតឡើង ។

៣ ដ៏សេស. **អាបោធាតុ តេជោធាតុ** តម្កល់នៅក្នុង**បឋវីធាតុ** ជួយប្រុងទុក រក្សាទុក បក់ផាត់ទុកនូវគ្នានិងគ្នាជាបច្ច័យជួយផ្សារទុក ចម្អិនទុក បក់ផាត់ទុកនូវមហាភូតទាំង ៣ ដ៏សេសអំពីខ្លួន ត្រូវធ្វើទុកក្នុងចិត្តដោយបច្ច័យយ៉ាងនេះ ។

១២- **អសមន្នាហារតោ** ត្រូវធ្វើទុកក្នុងចិត្តដោយភាពដែលមិនដឹងនូវគ្នានិងគ្នា ។

**សេចក្តីថា:** **បឋវីធាតុ** មិនដឹងថា: អញជា**បឋវីធាតុ** អញជាបច្ច័យជាទីពឹងផ្អែកនៃមហាភូតទាំង ៣ សូម្បីមហាភូតទាំង ៣ ក៏មិនបានដឹងថា: **បឋវីធាតុ** ជាបច្ច័យ ជាទីពឹងផ្អែករបស់ខ្លួន ត្រូវធ្វើទុកក្នុងចិត្តដោយភាពដែលមិនដឹងនូវគ្នានិងគ្នាយ៉ាងនេះ ។

១៣- **បច្ចយវិភាគតោ** ត្រូវធ្វើទុកក្នុងចិត្តដោយកិរិយាចែកនូវបច្ច័យ ។

**សេចក្តីថា:** បច្ច័យរបស់ធាតុមាន ៤ គឺ[88] **កម្ម** ១, **ចិត្ត** ១, **អាហារ** ១, **ឧតុ** ១, ។ កម្មតែម្យ៉ាងជាបច្ច័យដែលមានកម្មជាដែនកើត. ចិត្តជាដើមតែម្យ៉ាងៗ ជាបច្ច័យដល់ធាតុដែលមានចិត្តជាដើមតែម្យ៉ាងជាដែនកើត:

---

[88] កម្ម សំដៅយកកុសលាកុសលកម្ម ដែលញ៉ាំងរូបឱ្យកើតបាន ។ ចិត្តសំដៅយកចិត្តណា ១ ដែលញ៉ាំងរូបឱ្យកើតបាន ។ អាហារដំដៅយកអាហារខាងក្នុងដែលញ៉ាំងរូបឱ្យកើតបាន ។ ឧតុ សំដៅយកតេជោធាតុ ។

**កម្ម, ចិត្ត អាហារ, ឧតុ** តែម្យ៉ាងៗ ជាជនកបច្ច័យ[89] ដល់ធាតុដែលមាន **កម្ម, ចិត្ត អាហារ, ឧតុ** តែម្យ៉ាងៗ ជាដែនកើត ហើយជាបច្ច័យដទៃមានឧបនិស្សយបច្ច័យដល់ធាតុដ៏សេសបានខ្លះ ដោយបរិយាយ[90] ត្រូវធ្វើទុកក្នុងចិត្ត ដោយកិរិយាចែកនូវបច្ច័យយ៉ាងនេះ ។

កាលបើព្រះយោគី នឹករំពឹងក្នុងចិត្តរឿយៗ ដោយអាការទាំង ១៣ យ៉ាងដូចបានពោលមកនេះ ធាតុទាំង ៤ ក៏នឹងប្រាកដឡើង ហើយតទៅ**ឧបចារសមាធិ** ក៏នឹងកើតឡើងដោយពិត ។

**កម្មដ្ឋាន** នេះ ដល់នូវការរាប់ថា **ចតុធាតុវវដ្ឋាន** ព្រោះកិរិយាកើតឡើងដោយអានុភាពនៃញាណនៃយោគី ជាអ្នកកំណត់នូវធាតុទាំង ៤ ។

## អានិសង្សនៃចតុធាតុវវដ្ឋាន

យោគីដែលបានប្រកបរឿយៗ ក្នុង **ចតុធាតុវវដ្ឋាន** ជាអ្នកមាន **បញ្ញាញាណ**ចុះស៊ប់ក្នុងសុញ្ញភាព (ភាពសូន្យ) រមែងដកឡើងនូវ **សត្តសញ្ញា** (សេចក្តីសំគាល់ថាសត្វមាន) បាន ។

កាលបើជួបភ័យដ៏ពន្លឹក យោគីនោះនឹងជាអ្នកអត់សង្កត់នូវភ័យដ៏ពន្លឹកនោះបាន អត់សង្កត់នូវសេចក្តីត្រេកអរយ៉ាងក្រៃលែងបាន និងមិនដល់នូវការ

---

[89] បច្ច័យ ញ៉ាំងធាតុនោះៗ ឱ្យកើត ។

[90] ក្នុងអាការនេះ លោកពោលដោយពិស្តារពេកណាស់ ដែលពោលមកនេះដោយ សង្ខេបក្រៃពេក ។

រើឡើងរើចុះក្នុងអារម្មណ៍ដែលជាទីគាប់ចិត្តនិងមិនជាទីគាប់ចិត្ត ។ ម្យ៉ាងទៀត ថែមទាំងមានបញ្ញាច្រើន ជាអ្នកមានអមតៈជាទីបំផុតនិងជាអ្នកមានសុគតិប្រព្រឹត្តទៅក្នុងខាងមុខមែនពិត ។ ព្រោះហេតុនោះ ទើបលោកចងជាគាថាទុកមកថា:

ឯវំ មហានុភាវំ យោគីវរសីហស្ស កីឡិតំ
ឯតំ ធាតុវវដ្ឋានំ និច្ចំ សេវេថ មេធាវី

បានសេចក្តីថា: យោគីជាអ្នកមានប្រាជ្ញាល្អ គប្បីសេពនូវកិរិយាកំណត់ដឹងនូវធាតុនោះ ដែលមានអានុភាពច្រើន ដែលសីហដ៏ប្រសើរ គឺ យោគីលេងហើយឱ្យជានិច្ចយ៉ាងនេះឯង ។

## ចតុធាតុវវដ្ឋាន ចប់

-----------------------------------------

យោគីពួកខ្លះ ក្នុងព្រះពុទ្ធសាសនានេះ ដែលជាអ្នកឃើញភ័យក្នុង **សំសារវដ្ដ** បួសហើយដោយសទ្ធា កាលបើបានធ្វើនូវសេចក្តីសង្រួមក្នុងសីលដ៏បរិសុទ្ធហើយ បន្ទាប់មកក៏ប្រារព្ធចម្រើននូវ **សមថកម្មដ្ឋាន** ក៏បានរម្ងាប់នូវ **នីវរណៈធម៌** ទាំង ៥ ដោយអំណាចនៃ**ឧបចារជ្ឈាន**ដែលខ្លួនបានធ្វើឱ្យកើតឡើងហើយក្នុងសន្តាន ជាអ្នកមាន **បីតិបាមោជ្ជ** ក៏ខ្លាំងក្លា បន្ទាប់មកប្រារព្ធចម្រើននូវ**វិបស្សនាកម្មដ្ឋាន** ក៏បានធ្វើឱ្យជាក់ច្បាស់នូវ**អរហត្តផល**ក៏មានខ្លះដែរក្នុងលោក ដូចជា **កណ្ឌអន្ធការវាសិបុស្សទេវត្ថេរ** ជាដើម ។ បានឮមកថា ព្រះថេរអង្គនោះបាន

ឃើញនូវពុទ្ធរូបដែលមានមារនិមិត្តហើយ ក៏បានចំពោះនូវបីតិ ដែលមាន **ពុទ្ធគុណ** ជាអារម្មណ៍ដោយការពិចារណាថាៈ អើហ្ន៎! ពុទ្ធរូបនេះប្រកបដោយ **រាគៈ ទោសៈ មោហៈ** មែនពិតក៏គង់សមរម្យល្អណាស់ទៅហើយ ចុះទម្រាំបើព្រះមានព្រះភាគពិតៗ នោះវិញ តើសមរម្យដូចម្តេចទៅ? បន្ទាប់មកព្រះថេរៈក៏ចម្រើននូវ **វិបស្សនា** បន្តទៅទៀត ក៏បានដល់**អរហត្តផល** ដែលជាទីបំផុតនៃព្រហ្មចរិយធម៌ ថែមទៀត ។

ហេតុដូច្នេះ សាធុជនទាំងឡាយជាអ្នកឃើញភ័យក្នុងសំសារវដ្ត ហើយមានបំណងនឹងប្រតិបត្តិធម៌ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាននេះ ក៏គប្បីធ្វើសេចក្តីសង្រួមក្នុងសីលដ៏បរិសុទ្ធស្អាត ហើយគប្បីជាអ្នកមានសតិនិងញាណ ធ្វើការចម្រើននូវ**សមថកម្មដ្ឋាន**ឱ្យបានសម្រេចនូវគុណវិសេស គឺ**ឧបចារជ្ឈាន** រម្ងាប់នូវនីវរណធម៌ទាំង ៥ នេះ បន្ទាប់មកគប្បីចម្រើននូវ **វិបស្សនាកម្មដ្ឋាន** ដោយសេចក្តីមិនប្រមាទក្នុងឥរិយាបថទាំង ៤ ក៏គង់នឹងបានសម្រេចនូវ**អគ្គុត្តធម៌**ក្នុងបច្ចុប្បន្ននេះមិនខានឡើយ ។

កាលបើមិនទាន់ត្រាស់ដឹងនូវអនុត្តរធម៌ទេនោះ ក៏គង់មានសុគតិប្រព្រឹត្តទៅក្នុងខាងមុខ ហើយនឹងត្រូវបានត្រាស់ដឹងនូវអមតធម៌ ក្នុងអនាគតជាតិមិនខានឡើយហោង ។

បន្ទាប់អំពីនេះ នឹងពោលអំពី**កម្មដ្ឋាន** ១១ ដែលមានអានុភាពឱ្យសម្រេចត្រឹមបឋមជ្ឈានតទៅ តែថាក្នុងសៀវភៅនេះមានពោលត្រឹមតែឧបចារជ្ឈានប៉ុណ្ណោះ ឯអប្បនាឈាន នឹងមានពោលក្នុងសៀវភៅ វិបស្សនាកម្មដ្ឋាន ថ្នាក់មធ្យមឯណោះ ។

# អសុភកម្មដ្ឋាន ១០

## ឧទ្ធុមាតកអសុភ

សូមលើកយក **ឧទ្ធុមាតកអសុភ** ពោលមុន បន្ទាប់ទើបពោលអសុភទាំង ៩ ។

កាលបើព្រះយោគាវចរ មានប្រាថ្នាដើម្បីនឹងចម្រើនយក **និមិត្ត** ក្នុង **ឧទ្ធុមាតកអសុភ** គប្បីចូលទៅកាន់សំណាក់កល្យាណមិត្ត ដូចន័យដែលពោលមកក្នុងខាងដើម រៀនយកនូវវិធីដូចតទៅនេះ៖

- វិធីដើរទៅកាន់ **អសុភនិមិត្ត** ។
- វិធីកំណត់នូវនិមិត្តជិតខាង ។
- វិធីកាន់យកនូវនិមិត្ត ។
- វិធីពិចារណាតាមផ្លូវដែលដើរទៅដើរមក រហូតដល់អប្បនាវិធី ទីបំផុតចេញទៅនៅក្នុងទីសេនាសនៈ ដ៏សមគួរដល់ **សមាធិភាវនា** ហើយសន្សឹមស្វែងរក **អសុភនិមិត្ត** នឹងចម្រើន ។

## សេចក្តីពន្យល់ក្នុងវិធីទាំងឡាយនោះ

- វិធីដើរទៅកាន់ **អសុភនិមិត្ត** ត្រូវរៀនឱ្យដឹងថា មុនដែលនឹងដើរទៅកាន់កន្លែងដែលរូបអសុភតម្កល់នៅ ត្រូវប្រាប់ដល់លោកដែលជាសង្ឃត្ថេរជាមុនសន្សឹមដើរទៅ មិនត្រូវដើរទៅ ២ រូប ឬ ៣ រូប ត្រូវធ្វើទុកក្នុងចិត្តនូវមូល**កម្មដ្ឋាន**ជានិច្ច ត្រូវកាន់ឈើច្រត់ដើរទៅដើម្បីការពារនូវអន្តរាយ មានផ្កែ

កាចជាដើម ត្រូវដើរប្រុងស្មារតី សង្រួមឥន្ទ្រិយទាំង ៦ ត្រូវកំណត់ឱ្យដឹងទិស ដឹងទ្វារ ដឹងផ្លូវ ដែលខ្លួនដើរចេញទៅ ត្រូវឱ្យដឹងខាងឆ្វេងខាងស្ដាំ នៅទីណាមានវត្ថុអ្វី មិនត្រូវដើរចូលទៅកាន់អសុភអំពីខាងក្រោមខ្យល់ ។

វិធីកំណត់និមិត្តជិតខាង ត្រូវរៀនឱ្យដឹងថា ពេលដែលចូលទៅដល់រូបអសុភហើយ មិនត្រូវសម្លឹងមើលរូបអសុភជាលើកដំបូងឡើយ ត្រូវកំណត់រកទិសដែលសម្លឹងទៅឃើញអសុភពិតប្រាកដ ត្រូវឈរក្នុងទីចន្លោះ មិនជាខាងក្រោមខ្យល់ខាងលើខ្យល់ មិនឆ្ងាយពេក ជិតពេក មិនបែរខាងក្បាលពេក បែរខាងចុងជើងពេក ត្រូវកំណត់ទីជុំវិញឱ្យដឹងថា ខាងណាមានវត្ថុអ្វី ថ្ម ឬ ដំបូកជាដើម, ធំ ឬ តូច ខ្ពស់ ឬទាបជាមុន ត្រូវធ្វើទុកក្នុងចិត្តនូវវត្ថុជិតខាងអែបជាមួយនឹងតួអសុភថា នេះថ្ម នេះអសុភ ជាដើម ។

វិធីកាន់យកនូវនិមិត្តនោះ ត្រូវរៀនឱ្យដឹងនូវវិធីកាន់យកនូវនិមិត្តដោយអាការ ១១ យ៉ាងគឺ ។

១- **វណ្ណតោ** កំណត់ឱ្យដឹងថានេះជាសរីរៈរបស់មនុស្ស សម្បុរស ឬខ្មៅជាដើម ។

២- **លិង្គតោ** កំណត់ឱ្យដឹងថា នេះជាសរីរៈរបស់មនុស្សស្ថិតនៅក្នុងបឋមវ័យ មជ្ឈិមវ័យ ឬបច្ឆិមវ័យ ។

៣- **សណ្ឋានតោ** កំណត់ឱ្យដឹងថា នេះជាសណ្ឋានក្បាល ឬ សណ្ឋានកជាដើម ។

៤- **ទិសតោ** ក្នុងសរីរៈនេះ តាំងអំពីផ្ចិតចុះទៅចាត់ជាទិសខាងក្រោម អំពីផ្ចិតឡើង ចាត់ជាទិសខាងលើ កំណត់ឱ្យដឹងថា នេះជាទិសខាងក្រោម នេះជាទិសខាងលើ ឬកំណត់ឱ្យដឹងថា អញឈរនៅក្នុងទិសនេះ អសុភនៅក្នុងទិសនេះ ។

៥- **ឱកាសតោ** កំណត់ឱ្យដឹងថា: ដៃនៅក្នុងឱកាសនេះ ជើងនៅក្នុងឱកាសនេះ ជាដើម ឬកំណត់ឱ្យដឹងថា អញឈរនៅក្នុងឱកាសនេះ អសុភនៅក្នុងឱកាសនេះ ។

៦- **បរិច្ឆេទតោ** កំណត់ឱ្យដឹងថា: សរីរៈនេះខាងក្រោមត្រឹមបាតជើង ខាងលើត្រឹមចុងសក់ ជុំវិញត្រឹមស្បែក ក្នុងចន្លោះនេះ ពេញដោយសោកអសុភ ៣២ ប្រការ ឬ កំណត់ឱ្យដឹងថា: ដៃត្រឹមនេះ ជើងត្រឹមនេះ ជាដើម ។

៧- **សន្ធិតោ** កំណត់ឱ្យដឹងទីតនៃសរីរៈទាំង ១៨០[91] ។

៨- **វិវរតោ** កំណត់ឱ្យដឹងទីចន្លោះរបស់អសុភ មានចន្លោះជើង ចន្លោះពោះជាដើម ។

---

[91] ទីត ១៨០ លោកមិនបានរាប់ចំនួនទាំងអស់ ។ តក្នុងទីនេះ លោករាប់តែទីតធំ ១៤ គឺក្នុងដៃស្តាំ ៣ ឆ្វេង ៣, ក ១, ចង្កេះ ១, ទីតក្នុងដៃស្តាំ ៣ នោះគឺ ត្រង់ស្មា ១, ជុំដៃ ១, កដៃ ១, ខាងឆ្វេងក៏ដូចគ្នា ។ ទីតក្នុងជើងស្តាំ ៣ នោះគឺ ត្រង់ត្រគាក ១, ជង្គង់ ១, កជើង ១, ខាងឆ្វេងក៏ដូចគ្នា ។

៩- **និន្នតោ** កំណត់ឱ្យដឹងទីទំនាបក្នុងសរីរៈរបស់អសុភ មានរណ្ដៅភ្នែកនិងក្នុងមាត់ជាដើម ឬកំណត់ឱ្យដឹងថា: អញឈរនៅមាត់ទំនាប ឯអសុភស្ថិតនៅក្នុងទីទួល ។

១០- **ឧន្នតតោ:** កំណត់ឱ្យដឹងទីខ្ពស់ ក្នុងសរីរៈរបស់អសុភ មានជង្គង់និងទ្រូងជាដើម ឬកំណត់ឱ្យដឹងថា អញឈរនៅក្នុងទីខ្ពស់ ឯអសុភស្ថិតនៅក្នុងទីទំនាប ។

១១- **សមន្តតោ:** ត្រូវបញ្ជូនញាណឱ្យប្រព្រឹត្តនៅសព្វក្នុងសរីរៈរបស់អសុភទាំងមូល បើត្រង់ណាតាំងឡើងប្រាកដ សន្សឹមកំណត់ធ្វើទុកក្នុងចិត្តត្រង់ណោះ ។ ក្នុងវិធីពិចារណាតាមផ្លូវដែលដើរទៅដើរមកនោះ ត្រង់វិធីពិចារណាតាមផ្លូវដែលបានដើរទៅ ដែលបានពោលមកហើយក្នុងវិធីដើរទៅកាន់អសុភនិមិត្តខាងដើម នឹងពោលតែវិធីពិចារណាតាមផ្លូវដែលដើរមក. ក៏ឯវិធីពិចារណាតាមផ្លូវដែលដើរមកនោះ គឺកាលដែលព្រះយោគីបានកាន់យកនូវនិមិត្តដ៏ប្រពៃហើយតែមិនទាន់បានសម្រេចកិច្ចដល់ទីបំផុតរបស់ភាវនា ត្រូវថយត្រឡប់មកកាន់ទីសេនាសនៈវិញ ក្នុងពេលដែលដើរមកនេះ ត្រូវធ្វើទុកក្នុងចិត្តនូវកម្មដ្ឋាននោះជាដរាប ត្រូវដើរប្រុងស្មារតី សង្រួមឥន្ទ្រិយទាំង ៦ ពេលដែលចេញចាកព្រៃស្មសានមក ត្រូវកំណត់ផ្លូវ កំណត់ទិស កំណត់វត្ថុជិតខាងឱ្យសព្វគ្រប់ដូចកាលដែលដើរ

ចូលទៅ, លុះមកដល់ទីសេនាសនៈហើយ បើនឹងចង្រ្កមក្តី តាក់តែងទីអង្គុយឱ្យបែរមុខឆ្ពោះទៅកាន់ទីដែលអសុភតម្កល់នៅ ហើយពិចារណាបញ្ជូនចិត្តនឹកទៅរកអសុភ ដែលខ្លួនបានចម្រើននោះ ។

**បុច្ឆា** វិធីដែលកំណត់នូវនិមិត្តជិតខាងជាដើមនេះ មានប្រយោជន៍យ៉ាងណាខ្លះ?

**វិស្សជ្ជនា** វិធីកំណត់និមិត្តជិតខាងនឹងមិនវង្វេងភ្លេចស្មារតី ក្នុងពេលដែលអសុភសម្តែងនូវអាការគួរស្បើម ។

វិធីកាន់យកនិមិត្តដោយអាការ ១១ យ៉ាង ដើម្បីនឹងចងក្រៀកទុកនូវកម្មដ្ឋានឱ្យជាបច្ច័យដល់**ឧគ្គហនិមិត្ត បដិភាគនិមិត្ត** និង**អប្បនាឈាន** ដរាបដល់ **អរហត្តផល** ជាទីបំផុត បើចម្រើននូវ **វិបស្សនា** តទៅទៀត ។

វិធីពិចារណាតាមផ្លូវដែលដើរទៅមក ដើម្បីញ៉ាំងវិន័យរបស់ **កម្មដ្ឋាន** ឱ្យសម្រេច ក្នុងពេលដែលព្រះយោគីចម្រើនបាននូវ**ឧគ្គហនិមិត្ត** ត្រឡប់ទៅកាន់ទីសេនាសនៈវិញ បើនិមិត្តនោះវិនាសបាត់ទៅ ហើយយោគីរលឹកតាមលំអាននោះក៏នឹងត្រឡប់កើតឡើងវិញ ។

កាលព្រះយោគីបានរៀនយកនូវវិធីទាំងពួង ដូចពោលមកនេះ ក្នុងសំណាក់នៃកល្យាណមិត្តសព្វគ្រប់ហើយ បើឃើញ ឬឮដំណឹងថាៈ អសុភដែលហើមប៉ោងពងឡើងមាននៅក្នុងទីណាក៏គប្បីដើរទៅកាន់ទីនោះ ប្រព្រឹត្តតាមលំអានដែលពោលមក លុះទៅដល់ហើយ ត្រូវចំរើនឈរ ឬអង្គុយក៏បាន កុំឱ្យ

ឆ្ងាយពេក ជិតពេក ឱ្យល្មមតែក្រឡេកមើលទៅអសុភឃើញច្បាស់ ត្រូវសង្ឃឹមថា: អញមុខជានឹងរួចចាកទុក្ខដោយបដិបទានេះដោយពិត ត្រូវសម្គាល់នូវអសុភហាក់ដូចជាដួងកែវ ត្រូវតាំងសេចក្ដីគោរពឱ្យណាស់ ត្រូវមានសេចក្ដីពេញចិត្តឱ្យណាស់ ត្រូវចងក្រៀកចិត្តទុកក្នុងអារម្មណ៍នោះ ហើយបើកភ្នែកសម្លឹងមើលកំណត់ធ្វើទុកក្នុងចិត្តថា "**ឧទ្ធុមាតកំ បដិក្កូលំ ឧទ្ធុមាតកំ បដិក្កូលំ** អសុភហើមពោរពងឡើង មុខគួរឱ្យខ្ពើមៗ" ហើយធ្មេចភ្នែកនឹករំពឹងកំណត់ធ្វើទុកក្នុងចិត្តដូចដែលពោលដល់ ១ រយចប់ ១ ពាន់ចប់ក្ដី ដរាបដល់កាន់នូវនិមិត្តបានដោយល្អ. **ឧគ្គហនិមិត្ត** កើតឡើង បើកភ្នែកក៏ឃើញ ធ្មេចភ្នែកចុះទៅវិញក៏ឃើញដូចគ្នា, លុះចេញចាកអំពីទីនោះទៅកាន់ទីសេនាសនៈរបស់ខ្លួនវិញក៏ត្រូវធ្វើទុកក្នុងចិត្តឱ្យរឿយៗ លុះត្រាតែ **បដិភាគនិមិត្ត** កើតឡើង ។

**ឧគ្គហនិមិត្ត** ក្នុង **ឧទ្ធុមាតកាសុភ** នេះ តាំងឡើងមានទំនងប្លែក មុខគួរឱ្យខ្ពើម សម្ដែងអាការគួរឱ្យស្ញើម ឯ**បដិភាគនិមិត្ត** ប្រាកដឡើងហាក់ដូចបុរសមានអវយវៈតូចធំ យ៉ាងថ្លោស បរិភោគឆ្អែតហើយដេកទៅ លំដាប់នោះនីវរណធម៌និងកិលេសរបស់ព្រះយោគីអង្គនោះ ក៏ទ្រោមស្ងប់ទៅជាលំដាប់ ចិត្តសោតក៏តម្កល់នៅមាំដោយ **ឧបចារសមាធិ**. កាលបើព្រះយោគីសេពនូវនិមិត្តនោះជារឿយៗ ពុំបានលះបង់ព្យាយាម ក៏នឹងបានសម្រេចដល់ **អប្បនាឈាន**. តែក្នុង **កម្មដ្ឋាន** នេះ មានអំណាចឱ្យសម្រេចបានតែត្រឹម **បឋមជ្ឈាន** ប៉ុណ្ណោះ មិនមានអំណាចឱ្យសម្រេចដល់ **អប្បនាឈាន** ជាន់លើបានឡើយ ទោះបីអសុភទាំង ៩ ខាងចុងក៏ដូចគ្នា ។

# ១វិនីលកអសុភ

បន្ទាប់មកអំពី **ឧទ្ធុមាតកអសុភ** និង ពណ៌នាក្នុងអសុភទាំង ៩ ខាងចុងតទៅ ។ ក៏ក្នុងអសុភទាំង ៩ នេះ មានវិធីទាំងពួងដូចគ្នានឹង**ឧទ្ធុមាតកអសុភ** ស្មើរតែនឹងទាំងអស់ នៅមានសេចក្តីដែលប្លែកបន្តិចបន្តួច ហេតុនោះនឹងពណ៌នាតែសេចក្តីណាដែលប្លែកគ្នាប៉ុណ្ណោះ ឯសេចក្តីឯទៀត គប្បីជ្រាបតាមន័យដែលពោលមកក្នុង **ឧទ្ធុមាតកអសុភ** ឯណោះចុះ ។

តែក្នុងអសុភទាំង ៩ នេះ នឹងពោលនូវ **វិនីលកអសុភ** ជាមុន ហើយទើបពណ៌នានូវអសុភដ៏សេសតរៀងទៅ ។

ក៏ក្នុង **វិនីលកអសុភ** នេះ ត្រូវបរិកម្មកំណត់ធ្វើទុកក្នុងចិត្តថា "**វិនីលកំ បដិក្កូលំ វិនីលកំ បដិក្កូលំ**" អសុភហើមប៉ោងមានពណ៌ខៀវ មុខគួរឱ្យខ្ពើមៗ **ឧគ្គហនិមិត្ត** ក្នុង**វិនីលកអសុភ**នេះប្រាកដឡើង នៅមានពណ៌ពពាលៗដោយច្រើន, ឬ**បដិភាគនិមិត្ត**ប្រាកដឡើងតាមពណ៌ដែលផ្សាយឡើងច្រើន ពណ៌ក្រហម ស ខៀវ ពណ៌ណាមួយផ្សាយឡើងក៏ប្រាកដដូចនោះ ។

# ១វិបុព្វកអសុភ

ក្នុងវិបុព្វកអសុភនេះ ត្រូវបរិកម្មកំណត់ធ្វើទុកក្នុងចិត្តថា "**វិបុព្វកំ បដិក្កូលំ វិបុព្វកំ បដិក្កូលំ**" អសុភហើមមានខ្ទុះ ហូរចេញទៅលើ ខាងក្រោមមុខគួរឱ្យខ្ពើម ។ **ឧគ្គហនិមិត្ត** ក្នុង**វិបុព្វកអសុភ**នេះ ប្រាកដឡើងដូចខ្ទុះកំពុងហូរចេញ ឯ**បដិភាគនិមិត្ត**ប្រាកដឡើង ទ្រង់ស្ងប់ច្រៀបមិនមានកម្រើក ។

## វិច្ឆិទ្ទកអសុភ

ក៏**វិច្ឆិទ្ទកអសុភ**នេះតែងមាននៅក្នុងមណ្ឌលនៃទីចម្បាំង ក្នុងដងព្រៃដែលចោរតែងនៅអាស្រ័យ ក្នុងទីដែលពិឃាតមនុស្សទោស ឬក្នុងព្រៃដែលជាលំនៅនៃសត្វសាហាវមានសីហជាដើម ហេតុនោះបើយោគីស្វែងរកបានក្នុងប្រទេសណាមួយ ហើយអសុភនោះដាច់ចេញឃ្លាតអំពីគ្នាឆ្ងាយ ត្រូវប្រមូលអារម្មណ៍ឱ្យមូលពិចារណារួមចូលជាមួយគ្នា ពុំនោះនឹងប្រើឱ្យគេប្រមូលឬនឹងប្រមូលខ្លួនឯង ឱ្យមូលគ្នាមកដោយឈើច្រត់ជាដើមក៏បាន កុំចាប់ពាល់ដោយដៃ[92] ហើយត្រូវបរិកម្មកំណត់ធ្វើទុកក្នុងចិត្តថា "**វិច្ឆិទ្ទកំ បដិក្កូលំ វិច្ឆិទ្ទកំ បដិក្កូលំ** អសុភដែលគេកាត់ដាច់ពាក់កណ្ដាលខ្លួន មុខគួរឱ្យខ្ពើមៗ" ។

**ឧគ្គហនិមិត្ត** ក្នុង**វិច្ឆិទ្ទកអសុភ**នេះ ប្រាកដឡើងហាក់ដូចជាដាច់ពាក់កណ្ដាល ឯ**បដិភាគនិមិត្ត**ប្រាកដដូចជាពេញបរិបូណ៌ឡើងវិញ ។

## វិក្ខាយិតកអសុភ

ក្នុង**វិក្ខាយិតកអសុភ**នេះ ត្រូវបរិកម្មកំណត់ធ្វើទុកក្នុងចិត្តថា "**វិក្ខាយិតកំ បដិក្កូលំ វិក្ខាយិតកំ បដិក្កូលំ**" អសុភដែលសត្វកកេរស៊ី មានសំណាមរលុះរលួយផ្សេងៗ មានមុខគួរឱ្យខ្ពើមៗ ។ **ឧគ្គហនិមិត្ត** ក្នុង **អសុភ** នេះ ប្រាកដឡើងនៅដូចស្នាមដែលសត្វកកេរស៊ីក្នុងទីនោះៗ ឯ**បដិភាគនិមិត្ត**ប្រាកដឡើងនៅពេញបរិបូណ៌ដូចដើម ។

---

[92] បើចាប់ពាល់ដោយដៃឯងនឹងទៅជាស្អិទ្ធស្នាលមិនកើតសង្វេគ ។

## ឆិទ្ទកអសុភ

ក្នុងវិច្ឆិទ្ទកអសុភនេះ ត្រូវបរិកម្មកំណត់ធ្វើទុកក្នុងចិត្តថា "វិច្ឆិទ្ទកំ បដិក្កូលំ វិច្ឆិទ្ទកំ បដិក្កូលំ អសុភដែលគេកាត់ដាច់ចេញអំពីគ្នាជាកំណាត់ៗ រាត់រាយទៅផ្សេងៗ មុខគួរឱ្យខ្ពើមៗ" ។

ឧគ្គហនិមិត្តវិច្ឆិទ្ទកអសុភ នេះ ប្រាកដឡើងនៅមានចន្លោះៗ នៃអវយវៈ ដែលប្រាកដ ឯបដិភាគនិមិត្តប្រាកដឡើងពេញបរិបូណ៌ដូចដើម ។

## ហតវិច្ឆិទ្ទកអសុភ

ក្នុង ហតវិច្ឆិទ្ទកអសុភ នេះ ត្រូវបរិកម្មកំណត់ធ្វើទុកក្នុងចិត្តថា ហតវិច្ឆិទ្ទកំ បដិក្កូលំ ហតវិច្ឆិទ្ទកំ បដិក្កូលំ អសុភដែលគេកាប់សាប់មានស្នាមសាំ រវាម មុខគួរឱ្យខ្ពើមៗ ។

ឧគ្គហនិមិត្ត ក្នុងហតវិច្ឆិទ្ទកអសុភនេះ ប្រាកដឡើងនៅមានស្នាមមុខ របួស ឯបដិភាគនិមិត្តប្រាកដឡើងពេញបរិបូណ៌ដូចដើម ។

## លោហិតកអសុភ

ក៏ឯលោហិតកអសុភនេះ ព្រះយោគីរមែងស្វែងរកបានក្នុងមណ្ឌល នៃ ទីចម្បាំងជាដើម ដូចពោលមកហើយក្នុងវិច្ឆិទ្ទកអសុភ តែត្រូវចម្រើនបានតែក្នុង ពេលដែលឈាមកំពុងហូរចេញអំពីមុខរបួសដែលគេប្រហារ ពុំនោះនឹងចម្រើន យកនិមិត្តក្នុងឈាមដែលហូរចេញអំពីមុខរបួស ឬពកដែលបែកធ្លាយជាដើម ក្រៅអំពីអសុភស្លាប់ក៏បាន ត្រូវបរិកម្មកំណត់ធ្វើទុកក្នុងចិត្តថា "លោហិតកំ បដិក្កូលំ លោហិតកំ បដិក្កូលំ អសុភមានឈាមហូរស្រោចស្រពមុខគួរ ឱ្យខ្ពើមៗ" ។

ឧគ្គហនិមិត្តក្នុងលោហិតកអសុភនេះ ប្រាកដឡើងមានអាការញ័រដូចជាផ្ទាំងសំពត់ មានពណ៌ក្រហមដែលខ្យល់បក់មកត្រូវ **ឯបដិភាគនិមិត្ត**ប្រាកដឡើងមានសភាពស្ងប់មិនកម្រើក ។

## បុឡុវកអសុភ

ក្នុង**បុឡុវកអសុភ**នេះ ត្រូវចម្រើនយកនិមិត្តក្នុងកាលដែលដង្កូវកំពុងហូរចេញតាមទ្វារទាំង ៩ ឬ ក្នុងកាលដែលសរីរៈអសុភៈនេះ រលួយបេះចេញចាកគ្នាអស់ហើយ នៅសល់តែដង្កូវផ្តុំគ្នាជាគំនរ ដូចគំនរបាយស្រូវសាលីដូចនោះក៏បាន ទុកណាជាសរីរៈនៃអសុភនោះជាសរីរៈរបស់ឆ្កែក្តី ចចកក្តី មនុស្សក្តី គោក្របី ដំរី សេះ ឬ ពស់ថ្លាន់ជាដើមក្តី ក៏គួរចម្រើនបានដូចគ្នា ត្រូវបរិកម្មកំណត់ធ្វើទុកក្នុងចិត្តថា: **បុឡុវកំ បដិក្កូលំ បុឡុវកំ បដិក្កូលំ** អសុភមានដង្កូវចោះហូរចេញតាមទ្វារទាំង ៩[93] មុខគួរឱ្យខ្ពើមៗ ។

**ឧគ្គហនិមិត្ត** ក្នុងបុឡុវកអសុភនេះ ប្រាកដឡើងទ្រង់ញ័រ **ឯបដិភាគនិមិត្ត** ប្រាកដឡើងទ្រង់ស្ងប់ដូចដុំបាយនៃស្រូវសាលី ។

## អដ្ឋិកអសុភ

ក៏ឯ**អដ្ឋិកអសុភ**នេះ ទោះបីនៅគង់ជារាងឆ្អឹងទាំងមូលក្តី ជ្រុះរង្គោះចេញទៅដោយឡែកៗ អំពីគ្នាក្តី សូម្បីនៅសល់តែឆ្អឹង ១ កំណាត់ ២ កំណាត់

---

[93] បើអសុភនោះនៅសល់តែគំនរដង្កូវ ត្រូវថា "អសុភនៅសល់តែគំនរដង្កូវ ដូចដុំបាយនៃស្រូវសាលី" ដូចនេះវិញ ។

ពុកផុយដូចម្ដេចក្ដី ក៏គួរចម្រើនយកនិមិត្តបានដូចគ្នាទាំងអស់ ត្រូវបរិកម្មកំណត់ទុកឆ្អឹងខ្ចាត់ខ្ចាយរាត់រាយទៅផ្សេងៗ មុខគួរឱ្យខ្ពើមៗ ។

**ឧគ្គហនិមិត្ត** ក្នុង**អដ្ឋិកអសុភ**នេះ ប្រាកដឡើងនៅមានចន្លោះៗ ឯ**បដិភាគនិមិត្ត** ប្រាកដឡើងពេញបរិបូណ៌[94] ។

ន័យម្យ៉ាងទៀតថា: **ឧគ្គហនិមិត្ត**ប្រាកដឡើងគួរឱ្យខ្ពើម គួរឱ្យខ្លាច ឯ**បដិភាគនិមិត្ត**ប្រាកដឡើង គួរឱ្យកើតបីតិ និងសោមនស្ស ។

**អសុភកម្មដ្ឋាន**ទាំង ១០ នេះ កាលបើព្រះយោគីចម្រើនបានដល់**បដិភាគនិមិត្ត** ក្នុងអសុភណាមួយហើយ **នីវរណធម៌**ទាំង ៥ ក៏ទ្រោមចុះ ក៏ព្រះយោគីអង្គនោះលះបង់បានជា **វិក្ខម្ភនប្បហាន**[95] ព្រមគ្នានឹង**បដិភាគនិមិត្ត**កើត ហើយអង្គឈានទាំង ៥ ក៏កើតឡើងផង ខណៈនោះព្រះយោគីក៏ចូលដល់**ឧបចារជ្ឈាន** ហើយតទៅទៀតនឹងអាចចូលបានដរាបដល់ **អប្បនាឈាន** តែចូលបានតែត្រឹម**បឋមជ្ឈាន** ប៉ុណ្ណោះ ទុកណាជាព្រះយោគីខំសង្វាតព្យាយាមចម្រើនតទៅទៀតដូចម្ដេចក៏មិនអាចនឹងចូលដល់**អប្បនាឈាន**ជាន់លើទៀតបាន មិនអាចញ៉ាំងគុណវិសេសមានទិព្វសោតនិងទិព្វចក្ខុជាដើមឱ្យកើតឡើងបានឡើយ គ្រាន់តែ

---

[94] និមិត្តប្រាកដឡើងបែបនេះ ចំពោះតែអសុភដែលសល់នៅតែរាងឆ្អឹងទាំងមូល បើអសុភដែលឆ្អឹងខ្ចាត់ខ្ចាយរាត់រាយទៅផ្សេងៗ ឬអសុភដែលសល់តែរាងឆ្អឹង ១ កំណាត់ ២ កំណាត់ប៉ុណ្ណោះ និមិត្តទាំង ២ យ៉ាងក៏ប្រាកដឡើងមិនប្លែកអំពីសណ្ឋានរបស់ឆ្អឹងនោះប៉ុន្មានឡើយ ។

[95] លះបង់សង្កត់ទុកមិនឱ្យផុសផុលឡើងបាន ។

ឃើញគំនរអសុភប្រាកដឡើងពេញផែនដីប៉ុណ្ណោះ តែបើព្រះយោគីយក**វិបស្សនា**មកចម្រើនអែបផងបានសម្រេចនូវ**លោកុត្តរធម៌** ដរាបដល់ព្រះ**អរហត្តផល**ជាទីបំផុត ។

កាលពោលមកហើយអំពីកិច្ចប្រតិបត្តិក្នុង**អសុភកម្មដ្ឋាន**នេះ បុព្វកិច្ចខាងដើមមានកម្មវិធីសិក្សាចម្រើនដែលត្រូវរៀនក្នុងសំណាក់នៃអាចារ្យ មានរៀនយកនូវវិធីដើរទៅកាន់**អសុភនិមិត្ត**ជាដើម កាលពោលមកនេះ គឺពោលសំដៅចំពោះទៅលើយោគាវចរជាអាទិកម្មិកបុគ្គល បានដល់យោគាវចរដែលទើបតែចាប់ផ្តើមរៀនថ្មីៗ ទើបតែចាប់ផ្តើមកសាង ក្នុងការចម្រើននូវកម្មដ្ឋានដំបូងក្នុងបច្ចុប្បន្នជាតិនេះឯង ឬថាជាបុគ្គលមានឧបនិស្ស័យនៅទន់ខ្វី មិនអាចធ្វើការនឹកគិត រាវរក ធ្វើទុកក្នុងចិត្ត បរិកម្មនូវ**អសុភកម្មដ្ឋាន**នោះ នឹងញ៉ាំង**ឧគ្គហនិមិត្ត** និង **បដិភាគនិមិត្ត** ឱ្យកើតបានឡើយ ។

រីឯយោគាវចរដែលមានអភិនីហារ ធ្វើការកសាងក្នុងការចម្រើនព្រះកម្មដ្ឋានទាំងនោះអំពីអតីតជាតិយូរណាស់មកហើយ ជាបុគ្គលមានឧបនិស្ស័យចាស់ក្លា មានបញ្ញាមោះមុត មិនចាំបាច់រៀនយកកម្មវិធីអ្វីច្រើនពេកទេ គ្រាន់តែប្រមូលចិត្តឱ្យមូលឱ្យមានអារម្មណ៍តែមួយ ហើយធ្វើទុកក្នុងចិត្តរឿយៗ នូវ**អសុភកម្មដ្ឋាន**មាន**ឧទ្ធុមាតកាសុភ**ជាដើម ក៏នឹងអាចញ៉ាំង**ឧគ្គហនិមិត្ត**និង**បដិភាគនិមិត្ត**ឱ្យកើតឡើងបានងាយ ពេលនោះ**នីវរណៈធម៌**ទាំង ៥ ក៏ស្ងប់រម្ងាប់ចិត្តក៏ស្ថិតនៅស៊ប់ក្នុងឧបចារជ្ឈានមែនពិត បន្ទាប់មកកាលបើយោគីនោះមាន

សេចក្តីព្យាយាមចម្រើននូវកម្មដ្ឋាននោះបន្តទៅទៀត ក៏នឹងអាចញ៉ាំងអប្បនាឈានគឺបឋមជ្ឈានឱ្យកើតឡើងថែមទៀត កាលបើយោគីបានញ៉ាំងឈានចិត្តឱ្យកើតឡើងហើយ បន្ទាប់មក ក៏ធ្វើការចម្រើនវិបស្សនាកម្មដ្ឋានបន្ត ក៏នឹងអាចបានសម្រេចបានមគ្គផលជាលោកុត្តរដោយពិតប្រាកដហោង ។ សេចក្តីពិស្តារនៃការកើតឡើងនៃបឋមជ្ឈានចិត្ត សូមចាំមើលក្នុងច្បាប់វិបស្សនាថ្នាក់មធ្យម ។

## កាយគតាសតិ

**ទ្វត្តឹំសាការកម្មដ្ឋាន** គឺកម្មដ្ឋានដែលត្រូវតម្កល់ស្មារតីចុះក្នុងអាការ ៣២ ដែលមាននៅក្នុងកាយដែលធ្វើទុកក្នុងចិត្តថាជាបដិកូលមុខគួរឱ្យខ្ពើម ហៅថា **កាយគតាសតិកម្មដ្ឋាន** ។

កាលបើព្រះយោគី មានប្រាថ្នាដើម្បីចម្រើននូវ**កាយគតាសតិកម្មដ្ឋាន**នេះគប្បីរៀនយកនូវ**ឧគ្គហកោសល្ល**វិធី គឺវិធីដែលឆ្លាសក្នុង**ឧគ្គហ** ៧ យ៉ាងក្នុងសំណាក់នៃអាចារ្យ ដែលជាកល្យាណមិត្តជាមុន ។

## ឧគ្គហកោសល្លវិធី ៧ យ៉ាង គឺ

១- **វចសា:** ឆ្លាសដោយវាចា ដែលស្វាធ្យាយតាមអាការទាំង ៣២ ។

២- **មនសា:** ឆ្លាសដោយចិត្តតម្កល់ស្វាធ្យាយតាមអាការទាំង ៣២ ។

៣- **វណ្ណតោ:** ឆ្លាសដោយកំណត់ពណ៌របស់អាការនោះៗ ។

៤- **សណ្ឋានតោ:** ឆ្លាសដោយកំណត់សណ្ឋានរបស់អាការនោះៗ ។

**៥- ទិសតោ:** ឆ្លាសដោយកំណត់ទិស ដែលអាការនោះតម្កល់នៅ ។

**៦- ឱកាសតោ:** ឆ្លាសដោយកំណត់ឱកាសដែលអាការនោះៗតម្កល់នៅ ។

**៧- បរិច្ឆេទតោ:** ឆ្លាសដោយកំណត់ទីជុំវិញរបស់អាការនោះៗ និងភាពដែលអាការនោះៗ មិនច្រឡំគ្នា ។

## សេចក្ដីអធិប្បាយ

ត្រង់**ឧគ្គហកោសល្ល**ទី ១ ត្រូវហាត់ស្វាធ្យាយដោយវាចាឱ្យស្ទាត់ក្នុងអាការទាំង ៣២ ។ ក៏អាការទាំង ៣២ នោះលោកចាត់ទុកជា ៦ ពួកគឺ

**ពួកទី ១** ឈ្មោះ **តចបញ្ចកៈ** មានអាការ ៥ គឺ **កេសា** សក់ទាំងឡាយ **លោមា** រោមទាំងឡាយ **នខា** ក្រចកទាំងឡាយ **ទន្តា** ធ្មេញទាំងឡាយ **តចោ** ស្បែក ។

**ពួកទី ២ វក្កបញ្ចកៈ** មានអាការ ៥ **មំសំ** សាច់ **ន្ហារូ** សរសៃទាំងឡាយ **អដ្ឋី** ឆ្អឹងទាំងឡាយ **អដ្ឋិមិញ្ជំ** ខួរក្នុងឆ្អឹង **វក្កំ** តម្រងបស្សាវៈ ។

**ពួកទី ៣** ឈ្មោះ **បប្ផាសបញ្ចកៈ** មានអាការ ៥ គឺ**ហទយំ** បេះដូង **យកនំ** ថ្លើម **កិលោមកំ** វៀវ **បិហកំ** ក្រពះ **បប្ផាសំ** សួត ។

**ពួកទី ៤ មត្ថលុង្គបញ្ចកៈ** មានអាការ ៥ គឺ **អន្តំ** ពោះវៀនធំ **អន្តគុណំ** ពោះវៀនតូច **ឧទរិយំ** អាហារថ្មី **ករីសំ** អាហារចាស់ **មត្ថលុង្គំ** ខួរក្នុងក្បាល ។

**ពួកទី ៥** ឈ្មោះ **មេទឆក្កៈ** មានអាការ ៦ គឺ **បិត្តំ** ប្រមាត់ **សេម្ហំ** ស្លេស្ម **បុព្វោ** ខ្ទុះ **លោហិតំ** ឈាម **សេទោ** ញើស **មេទោ** ខ្លាញ់ខាប់ ។

**ពួកទី ៦** ឈ្មោះ **មុត្តឆក្កៈ** មានអាការ ៦ គឺ **អស្សុ** ទឹកភ្នែក **វសា** ខ្លាញ់រាវ **ខេឡោ** ទឹកមាត់ **សង្ឃាណិកា** ទឹកសម្បោរ **លសិកា** ទឹករំអិល **មុត្តំ** ទឹកម្រូត ។

ត្រូវហាត់ស្វាធ្យាយក្នុងពួកទី ១ ជា**អនុលោមបដិលោម**ឱ្យបានស្ទាត់ជាមុន សន្សឹមឆ្លងចូលទៅក្នុងពួកទី ២ លុះបានស្ទាត់ក្នុងពួកទី ២ ហើយត្រូវស្វាធ្យាយភ្ជាប់មកនឹងពួកទី ១ ខាងដើមវិញជា**អនុលោមបដិលោម**ដូចគ្នា ស្វាធ្យាយភ្ជាប់ត្រាតែបានស្ទាត់ហើយ សន្សឹមឆ្លងចូលទៅក្នុងពួកខាងចុងៗ ទៀតជាលំដាប់ទៅ ។

ត្រង់**ឧគ្គហកោសល្ល**ទី ២ ត្រូវហាត់ស្វាធ្យាយដោយចិត្តឱ្យដូចជាស្វាធ្យាយដោយវាចាគឺថាត្រូវលើកចិត្តឡើងកំណត់នូវអាការនោះៗ តាមលំអានដែលស្វាធ្យាយដោយវាចាព្រោះថាស្វាធ្យាយដោយវាចាជាបច្ច័យដល់កិរិយាស្វាធ្យាយដោយចិត្ត។

**ត្រង់ទី ៣** ត្រូវរៀនកំណត់នូវពណ៌របស់អាការនោះៗ ឱ្យដឹងថា: "អាការនេះមានពណ៌ដូចនេះៗ" គ្រប់អាការទាំងអស់ .

**ត្រង់ទី ៤** ត្រូវរៀនកំណត់សណ្ឋានទ្រង់ទ្រាយរបស់អាការទាំងនោះឱ្យដឹងថា: អាការនេះមានសណ្ឋានបែបនេះៗ គ្រប់អាការទាំងអស់ ។

**ត្រង់ទី ៥** ត្រូវរៀនកំណត់ឱ្យដឹងថា: "អាការណាតម្កល់ក្នុងទិសណា ទិសខាងលើ ឬខាងក្រោម ព្រោះក្នុងសរីរៈប្រទេសនោះលោកចាត់ជាទិសមាន ២ គឺទិសខាងលើតាំងអំពីផ្ចិតឡើងទៅ ទិសខាងក្រោមតាំងអំពីផ្ចិតចុះមក" ។

**គ្រប់ទី ៦** ត្រូវរៀនកំណត់ឱ្យដឹងថា: អាការណាតម្កល់នៅក្នុងទីឱកាសចន្លោះណាៗ គ្រប់អាការទាំង ៣២ ។

**គ្រប់ទី ៧** ត្រូវរៀនកំណត់ឱ្យដឹងទីបំផុតជុំវិញរបស់អាការនោះៗ អាការណាមានទីបំផុតត្រឹមណា ទល់គ្នានឹងអាការណា ហើយនឹងរៀនកំណត់ឱ្យដឹងថាអាការទាំងនោះដោយឡែកៗ អំពីគ្នាមិនមានច្រឡំគ្នាឡើយ[96] ។

**មនសិការកោសល្ល** វិធីដែលឆ្លាសក្នុងមនសិការ ១០ យ៉ាងគឺ

១- **អនុបុព្វតោ** ត្រូវធ្វើទុកក្នុងចិត្តតាមលំដាប់នៃ**កោដ្ឋាស**[97] តាំងអំពីស្វាធ្យាយជាដំបូងរៀងទៅ មិនត្រូវធ្វើទុកក្នុងចិត្តផ្លោះៗ ដោយអន្លើៗ ឡើយ ។

២- **នាតិសីឃតោ** ត្រូវធ្វើទុកក្នុងចិត្តមិនឱ្យរហ័សរួសរាន់ពេក ។

៣- **នាតិសណិកតោ** ត្រូវធ្វើទុកក្នុងចិត្តមិនឱ្យយឺតយូរពេក ។

៤- **វិក្ខេបបដិពាហនតោ** កាលបើចិត្តលះបង់នូវ**កម្មដ្ឋាន** ហើយរាទៅរកអារម្មណ៍ដទៃជាខាងក្រៅ ត្រូវធ្វើទុកក្នុងចិត្តទប់មិនឱ្យចិត្តរាថយទៅវិញបាន។

---

96 គ្រង់ឧគ្គហកោសល្លទី ៧ នេះ លោកចែកចេញជា ២ គឺកំណត់ថា កោដ្ឋាសនេះ ខាងលើត្រឹមនេះ ខាងក្រោមត្រឹមនេះ ជុំវិញត្រឹមនេះ ហៅថា **សភាគបរិច្ឆេទ** ១, កំណត់ភាពដែលមិនច្រឡំគ្នាថា: សក់មិនមែនរោមៗ មិនជាសក់ជាដើម ហៅថា **វិសភាគបរិច្ឆេទ** ។

97 ពាក្យថា "**កោដ្ឋាស**" និងពាក្យថា "**អាការ**" ដូចគ្នា ។

**៥- បណ្ណត្តិសមតិក្កមតោ** ត្រូវធ្វើទុកក្នុងចិត្តកន្លងបញ្ញត្តិដែលលោកហៅថា សក់ រោម ជាដើម ហើយតាំងចិត្តទុកដាក់បដិកូលៗ ប៉ុណ្ណោះ ។

**៦- អនុបុព្វមុញ្ចនតោ** ត្រូវធ្វើទុកក្នុងចិត្តរៀងតាមលំដាប់នៃកោដ្ឋាស កាលបើកោដ្ឋាសៈណាមិនប្រាកដឡើង ត្រូវលះបង់ចេញ ហើយត្រូវធ្វើទុកក្នុងចិត្តតែកោដ្ឋាសៈណាដែលប្រាកដ ។

**៧- អប្បនាតោ** ត្រូវឱ្យដឹង**កោដ្ឋាសៈ**ដែលនាំមកនូវអប្បនា គឺត្រូវឱ្យដឹងថាអាការទាំង ៣២ មានសក់ជាដើម សុទ្ធតែមានអំណាចនឹងញុំាងអប្បនាចិត្តឱ្យកើតឡើងបានទាំងអស់ ។

**៨- អធិចិត្តតោ** ត្រូវឱ្យដឹងអធិចិត្តសូត្រ ដែលព្រះមានព្រះភាគ ទ្រង់សម្តែងថា ត្រូវធ្វើទុកក្នុងចិត្តសព្វៗកាល[98] នូវនិមិត្ត ៣ យ៉ាងគឺ **សមាធិនិមិត្ត ១, បគ្គហនិមិត្ត ១, ឧបេក្ខានិមិត្ត ១។**

**៩- សីតិភាវតោ** ត្រូវដឹងនូវសីតិភាវសូត្រ ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងថា ភិក្ខុដែលប្រកបដោយធម៌ ៦[99] គួរធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ។

---

[98] ត្រូវធ្វើទុកក្នុងចិត្តនូវសមាធិនិមិត្តតែម្យ៉ាង ចិត្តនឹងបែរទៅរកកោសជ្ជ ធ្វើទុកក្នុងចិត្តនូវបគ្គហនិមិត្តគឺផ្គងព្យាយាមតែម្យ៉ាង ចិត្តនឹងបែរទៅរកឧទ្ធច្ច ធ្វើទុកក្នុងចិត្តនូវឧបេក្ខានិមិត្តតែម្យ៉ាង ចិត្តនឹងមិនតម្កល់នៅមាំ ។

[99] ធម៌ទាំង ៦ យ៉ាងនោះគឺ សង្កត់ចិត្តក្នុងសម័យដែលគួរ ១ ប្រុងចិត្តក្នុងសម័យដែលគួរ ១, បង្អើលចិត្តក្នុងសម័យដែលគួរ ១, ស្ងប់ចិត្តក្នុងសម័យដែលគួរ ១, មានចិត្តឃោងចុះស៊ប់ក្នុងមគ្គ និង ផល ១ ត្រេកអរចំពោះព្រះនិព្វាន ១ ។

១០- **សត្តពោជ្ឈង្គកោសល្លសូត្រ** ដែលព្រះដ៏មានព្រះភាគទ្រង់សម្ដែងថា: ត្រូវឱ្យចម្រើននូវ **ពោជ្ឈង្គទាំង ៧ ពោជ្ឈង្គ** ណាមួយក្នុងពេលដែលចិត្តកំពុងរួញរាជាដើម ។

ព្រះយោគីកាលបើបានរៀនយកនូវ**ឧគ្គហកោសល្ល ៧** យ៉ាង និង **មនសិការកោសល្ល ១០** យ៉ាង ដូចពោលមកហើយ បានកំណត់ពណ៌ សណ្ឋាន ទិស ឱកាស និង បរិច្ឆេទគ្រប់កោដ្ឋាស: មានសក់ជាដើម រួចហើយត្រូវធ្វើទុកក្នុងចិត្តថាជាបដិកូលដោយស្ថាន ៥ យ៉ាង កុំឱ្យរហ័សពេកនិងយឺតយូរពេកជាដើម។

## បដិកូលដោយស្ថាន ៥ យ៉ាងនេះគឺ

១- **វណ្ណតោ** បដិកូលដោយពណ៌ ។

២- **សណ្ឋានតោ** បដិកូលដោយសណ្ឋាន ។

៣- **គន្ធតោ** បដិកូលដោយក្លិន ។

៤- **អាសយតោ** បដិកូលដោយទីអាស្រ័យនៅ ។

៥- **ឱកាសតោ** បដិកូលដោយឱកាសដែលប្រតិស្ឋាននៅ ។

កាលបើព្រះយោគី បានធ្វើទុកក្នុងចិត្តថាជាបដិកូលដោយស្ថាន ៥ យ៉ាងនេះ ដរាបដល់**កោដ្ឋាស:** ដែលមាននៅក្នុងកាយទាំងប៉ុន្មានតាំងឡើងប្រាកដស្មើគ្នាមិនមុនមិនក្រោយ គ្រាន់តែធ្វើមនសិការជាអនុលោមថា **កេសា** ប៉ុណ្ណោះ មនសិការ នោះក៏រត់ទៅទល់ដល់ **មុត្តំ** ជាទីបំផុត ធ្វើមនសិការជាបដិលោមថា

"**មុត្តំ**" ប៉ុណ្ណោះ មនសិការនោះក៏រត់មកដល់ "**កេសា**" ជាខាងដើមវិញ ស្ដូម្បីធ្វើមនសិការក្នុងកាយ របស់បុគ្គលដទៃជាខាងក្រៅ ក៏ប្រាកដឡើងដូចគ្នា បើមនុស្សនិងសត្វតិរច្ឆានជាដើម ដើរមកចំពោះមុខ ក៏លះបង់នូវអាការជាសត្វប្រាកដឡើង ជាគំនរនៃ**កោដ្ឋាសៈ**ទាំងអស់ ទឹក និងភោជនដែលសត្វទាំងនោះផឹកបរិភោគចូលទៅ ក៏ប្រាកដហាក់ដូចជាដាក់ចុះ ទៅក្នុងគំនរនៃ**កោដ្ឋាសៈ**ទាំង ៣២ ។

បើព្រះយោគីធ្វើទុកក្នុងចិត្តដោយបដិកូលភាពរឿយៗ តាម**មនសិការកោសល្ល**វិធីទាំង ១០ យ៉ាង លំដាប់មក**អប្បនាចិត្ត**ក៏កើតឡើង ។

**ឧគ្គហនិមិត្ត** ក្នុង**កាយគតាសតិកម្មដ្ឋាន**នេះឃើញអាការទាំង ៣២ តាំងឡើង ប្រាកដដោយពណ៌ សណ្ឋាន ទិស ឱកាស និង បរិច្ឆេទ **ឯបដិភាគនិមិត្ត**ប្រាកដឡើង ដោយបដិកូលភាពគ្រប់អាការទាំងអស់ ។

បើព្រះយោគីសេពដោយបដិភាគនិមិត្តនោះដោយច្រើន ចម្រើនឱ្យរឿយៗ ទៅ អប្បនាចិត្តក៏នឹងកើតឡើង តែកើតបានត្រឹមតែ**បឋមជ្ឈាន**ប៉ុណ្ណោះ ដូចក្នុង **អសុភកម្មដ្ឋាន** ដែរ ។

តែបើព្រះយោគីកាន់យកពណ៌ មានពណ៌ក្រហមរបស់សាច់ជាដើម ដែលតាំងឡើងមកប្រាកដជាអារម្មណ៍វិញនោះ ក៏នឹងអាចញ៉ាំង **ឧគ្គហនិមិត្ត** និងបដិភាគនិមិត្តឱ្យកើតឡើងបាន កាលព្រះយោគីសេពនូវបដិភាគនិមិត្តនោះ រឿយៗ ទៅ ក៏នឹងអាចញ៉ាំងឈានចំនួន ៥ ជា**បញ្ចកន័យ** ឬឈានចំនួន ៤ ជា**ចតុក្កន័យ** ឱ្យសម្រេចបានដោយពិត ។

តែថាក្នុងច្បាប់នេះ ពោលត្រឹមតែ**ឧបចារជ្ឈាន**ប៉ុណ្ណោះ ឯ**អប្បនាឈាន**នោះ នឹងមានពោលពិស្តារក្នុងច្បាប់**វិបស្សនាថ្នាក់មធ្យម**ឯណោះ ។

សេចក្តីដែលបានពោលមកហើយអំពីកិច្ចប្រតិបត្តិក្នុង **កាយគតាសតិកម្មដ្ឋាន** នេះជាសេចក្តីសង្ខេបពេកណាស់ ធ្វើឱ្យព្រះយោគីមានប្រាជ្ញាទន់ពិបាកយល់ពេក ។

លំដាប់អំពីនេះ ខ្ញុំសូមលើកឡើងជាបញ្ហាសួរ និងឆ្លើយខ្លះ ដើម្បីធ្វើការបំភ្លឺក្នុងកិច្ចប្រតិបត្តិដូចតទៅនេះ ៖

**បុច្ឆា** ចុះព្រះយោគីដែលត្រូវចម្រើន**កាយគតាសតិកម្មដ្ឋាន**នោះ តើមានគោលការណ៍សំខាន់មានប៉ុន្មានខដែលត្រូវប្រព្រឹត្តអ្វីខ្លះ ?

**វិសជ្ជនា** មានគោលការណ៍សំខាន់ក្នុងកិច្ចប្រតិបត្តិ ៤ ខដោយសង្ខេបគឺ

១- ការរៀនឱ្យបានចងចាំជាអនុលោមនិងបដិលោមនិងធ្វើទុកក្នុងចិត្តឱ្យស្ទាត់ជំនាញល្អចំពោះអាការ ៣២ មានសក់ជាដើម ។

២- ត្រូវស្ថិតនៅក្នុងទីស្ងាត់ ។

៣- ត្រូវសម្រេចក្នុងការចម្រើនដោយឥរិយាបថ ៤ មានឥរិយាបថអង្គុយជាប្រធាន ។

៤- ការចម្រើននូវអាការ ៣២ ។

**បុច្ឆា** សូមពន្យល់បំភ្លឺ អំពីគោលការណ៍ទាំង ៤ ខនោះមកមើល ?

**វិសជ្ជនា** គោលការណ៍ទាំង ៤ ខនេះ មានសេចក្តីអធិប្បាយដូចតទៅនេះ៖

**ខ ទី ១** ព្រះយោគីក្នុងសាសនានេះដែលជាអ្នកមានសេចក្ដីប្រាថ្នាដើម្បីចម្រើននូវអាការ ៣២ ត្រូវតែរៀនទន្ទេញចងចាំឱ្យបានល្អចំពោះអាការ ៣២ តាមផ្លូវវាចាតាមផ្លូវចិត្តឱ្យបានស្ទាត់ជំនាញល្អជាអនុលោម គឺរៀនបណ្ដោយចាប់ពីសក់រហូតដល់ទឹកមូត្រ បន្ទាប់មកត្រូវរៀនឱ្យចាំជាបដិលោមគឺរៀនបញ្ច្រាសចាប់ពីទឹកមូត្ររហូតដល់សក់វិញ កាលបើរៀនទន្ទេញជាអនុលោមបដិលោមបានចាំស្ទាត់ហើយ ត្រូវរៀនធ្វើទុកក្នុងចិត្តនូវអាការទាំង ៣២ នេះ តាមលំដាប់ដោយពណ៌ សណ្ឋាន ទិស ឱកាស បរិច្ឆេទឱ្យស្ទាត់ល្អ ក្នុងសំណាក់នៃកល្យាណមិត្រជាអាចារ្យរបស់ខ្លួនថែមទៀត ។

**ខ ទី ២** បន្ទាប់ពីបានសិក្សារៀនសូត្រអំពីសំណាក់អាចារ្យ នូវអាការទាំង ៣២ មក ព្រះយោគីគប្បីចូលទៅពួនសម្ងំក្នុងទីសេនាសនៈដ៏ស្ងាត់ចាកពួកគណៈ ដែលជាទីច្របូកច្របល់ ប្រកបដោយសំឡេងគឹកកងរំពង ជាទីធ្វើចិត្តរាយមាយ មិនបានសមាធិចិត្ត។ ទីស្ងាត់នោះទោះជាព្រៃស្ងាត់ក្ដី ទៀបគល់ឈើ ឬផ្ទះស្ងាត់ក្ដី ក៏សុទ្ធតែគួរដល់សមាធិភាវនាទាំងអស់ដោយពិត ព្រះយោគីដែលជាអាទិកម្មិកបុគ្គលកាលបើនៅរួមជាមួយពួកគណៈ ច្របូកច្របល់ដោយសំឡេងច្រើនហើយ មិនងាយនឹងចម្រើននូវកម្មដ្ឋាននេះឱ្យបានសម្រេច នូវគុណវិសេសបានឡើយ ព្រោះចិត្តចេះតែរាយមាយអណ្ដែតអណ្ដូងទៅកាន់អារម្មណ៍មានរូបជាដើម ដែលមកប៉ះទ្វារមានចក្ខុទ្វារជាដើម ។ ដូច្នេះយោគាវចរត្រូវស្វែងរកនូវទីសេនាសនៈដ៏ស្ងាត់ ដើម្បីចម្រើននូវកម្មដ្ឋានជាមុនឱ្យបានសម្រេចនូវគុណវិសេសសិន កាល

បើចម្រើនកម្មដ្ឋានបានសម្រេចនូវគុណវិសេសណាមួយហើយ សន្សឹមទៅសាកល្បងចម្រើនកម្មដ្ឋានក្នុងទីច្រប្ងូកច្របល់ជាខាងក្រោយថែមទៀត ព្រោះថាកម្មដ្ឋានដែលព្រះយោគីចម្រើនបានសម្រេចនូវគុណវិសេស ក្នុងទីច្រប្ងូកច្របល់នោះជាកម្មដ្ឋានអាចតាំងនៅស្ថិតស្ថេរអស់កាលជាយូរអង្វែងល្អ ។

**ខ ទី ៣** កាលបើយោគាវចរ បានស្ថិតស្ថេរក្នុងទីសេនាសនៈដ៏ស្ងាត់ដ៏សមគួរដល់**សមាធិភាវនា**ហើយ ត្រូវអង្គុយពែនភ្នែន តម្កល់កាយឱ្យត្រង់ល្អមានមុខឱនចុះបន្តិច ។

ឥរិយាបថ មាន ៤ គឺ **ដេក ដើរ ឈរ** និង **អង្គុយ** ចំណោមឥរិយាបថទាំង ៤ នេះ យោគាវចរគប្បីគំណត់យកឥរិយាបថអង្គុយ ធ្វើជាប្រធានក្នុងការចម្រើន**កម្មដ្ឋាន** ព្រោះថាការអង្គុយពែនភ្នែនតម្កល់កាយឱ្យត្រង់នេះ មានឧបការច្រើនដូចតទៅនេះ៖

ការតម្កល់កាយឱ្យត្រង់ល្អ ជាបច្ច័យនាំមកធ្វើឱ្យព្រះយោគីប្រាសចេញពីរងទុក្ខវេទនា ដែលកើតអំពីការអង្គុយសង្កត់ស្បែក សាច់ សរសៃ ការចុកចាប់ក្នុងជើងជាដើម និងនាំឱ្យបានចិត្តជា**ឯកគ្គតា** និងធ្វើកម្មដ្ឋានមិនឱ្យធ្លាក់ចុះរមែងដល់នូវការដុះដាលរីកចម្រើនឡើង ។ បន្ទាប់មកក៏គប្បីចម្រើនព្រះកម្មដ្ឋានដោយឥរិយាបថ ៣ គឺ ដើរចង្ក្រម ឈរ និងដេកឱ្យគ្រប់ឥរិយាបថទាំង ៤ និងគ្រប់ទីកន្លែងថែមទៀត ទើបឈ្មោះជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេសមានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានដោយពិត ទប់ស្កាត់សង្កត់សង្កិនបាមឃាត់មិនឱ្យអកុសលធម៌ មានលោភជាដើមគ្របសង្កត់ចិត្តបាន។

**ខទី ៤** កាលបើអង្គុយពែនភ្នែនតម្កល់កាយឱ្យត្រង់មានមុខឱនមុខចុះបន្តិច ហើយក៏គប្បីប្រមូលចិត្តញាត់ចូលទៅក្នុងទ្រូងទប់ចិត្ត កុំឱ្យគិតអំពីរឿងអ្វីៗទោះជារឿងអតីតក្តី អនាគតក្តី ឬបច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី ត្រូវឱ្យចិត្តនៅទំនេរមួយរយៈមួយរំពេចសិន កាលបើចិត្តស្ថិតនៅក្នុងដើមទ្រូងបានល្អហើយ អកុសលធម៌មិនអាចគ្របសង្កត់ចិត្តបានបន្ទាប់មកយោគាវចរក៏គប្បីធ្វើនូវភាវនាកម្មតទៅ ។

ក្នុងការធ្វើភាវនាកម្មនេះ ខ្ញុំសូមលើកយកមកអធិប្បាយ នូវបច្ចេកទេសដែលជាគោលសំខាន់ ២ យ៉ាងដែលក្នុងបច្ចុប្បន្នឥឡូវនេះដែលពួកជនធ្លាប់អនុវត្តមកបានទទួលលទ្ធផលល្អប្រសើរគឺ

១- ការកាន់យកនូវអាការខាងក្នុងខ្លួនហើយ ទើបកាន់យកនូវអាការដែលស្ថិតនៅខាងក្រៅខ្លួន គឺអាការរបស់បុគ្គលដទៃ បន្ទាប់មកក៏កាន់យកនូវអាការទាំង ២ ។

២- ការកាន់យកនូវអាការខាងក្រៅអំពីខ្លួនបានហើយ ទើបបង្អោនចិត្តមកកំណត់កាន់យកនូវអាការខាងក្នុងខ្លួនឯង បន្ទាប់មកក៏កំណត់កាន់យកនូវអាការទាំង ២ ថែមទៀត ។

## បច្ចេកទេសទី ១

យោគាវចរ ដែលត្រូវចម្រើននូវ **កាយគតាសតិកម្មដ្ឋាន** គឺអាការទាំង ៣២ កាលប្រមូលចិត្តដាក់ក្នុងដើមទ្រូងបានល្អហើយ បន្ទាប់មក ក៏បញ្ជូនចិត្តធ្វើការ **បរិកម្ម** នូវអាការ ៣២ បណ្តោយហើយបញ្ច្រាសសាចុះឡើងឱ្យបានថ្មីកល្អ

ហើយ បន្ទាប់មកក៏គប្បីធ្វើទុកក្នុងចិត្តនូវអាការមួយៗ តាមលំដាប់ប្រកបដោយពណ៌ សណ្ឋាន ទិស ឱកាស និងបរិច្ឆេទ ដូចបានពោលខាងដើម កាលបើអាការណាមួយប្រាកដឡើង ក៏គប្បីធ្វើទុកក្នុងចិត្តកំណត់នូវអាការមួយនោះឱ្យរឿយៗ ដដែលថែមហើយថែមទៀត លះបង់នូវការបរិកម្មចំពោះអាការដទៃសិន កាលបើអាការនោះតាំងនៅបានល្អប្រាកដដល់ចិត្តហើយ ព្រះយោគីក៏គប្បីលះបង់នូវពាក្យដែលជាពាក្យបញ្ញត្តិរបស់អាការនោះ មានពាក្យថាសក់ជាដើមចេញ ហើយធ្វើទុកក្នុងចិត្តនូវបដិកូលភាព ភាពខ្ពើមរអើម ប្រកបដោយសណ្ឋាន ៥ យ៉ាងពណ៌ សណ្ឋាន ក្លិន ទីអាស្រ័យ ឱកាសចំពោះអាការនោះ ។ ពេលនោះ បដិកូលភាពក៏ប្រាកដឡើងដល់ចិត្តរបស់យោគីមែនពិត ។

អាការដែលប្រាកដឡើង ប្រកបដោយពណ៌ សណ្ឋាន ទិស ឱកាស បរិច្ឆេទដល់ព្រះយោគី និមិត្តកើតឡើងប្រាកដនោះឈ្មោះថា**ឧគ្គហនិមិត្ត**ក្នុង**កាយគតាសតិកម្មដ្ឋាន** នេះ ឯភាពបដិកូលអាការដែលកើតឡើងប្រាកដដល់ព្រះយោគីនោះ និមិត្តនេះឈ្មោះ ថា **បដិភាគនិមិត្ត** ។

កាលបើព្រះយោគីបានញ៉ាំងឧគ្គហនិមិត្ត និងបដិភាគនិមិត្ត ក្នុងអាការ ១ ដែលកើតឡើងប្រាកដនោះបានសម្រេចហើយ បន្ទាប់មកគប្បីចម្រើនអាការដទៃបន្តទៅទៀត រហូតអាការទាំង ៣២ ឱ្យបានសម្រេចនូវ **ឧគ្គហនិមិត្ត** និង **បដិកូលនិមិត្ត** ដូចគ្នា ។ កាលបើបានចម្រើនអាការទាំង ៣២ ក្នុងអត្តភាពនេះរួមគ្នាឱ្យឃើញត្រឹមតែគំនរ អាការ ប្រាកដដោយបដិកូលភាព មិនឃើញមានសត្វ

បុគ្គល ជីវិត ប្រុសស្រីជាដើមឡើយ ។ ភាពចិត្តដែលកើតឡើងដំបូងជាចិត្តប្រាសចាកនីវរណៈ ៥ ឈ្មោះថាជាចិត្តប្រកបដោយ **ឧបចារជ្ឈាន** កាលបើយោគីសេពនូវ**បដិភាគនិមិត្ត**នោះរឿយៗ ក៏នឹងបានសម្រេចដល់**អប្បនាឈាន**គឺ**បឋមជ្ឈាន** ដោយពិត ។

កាលបើយោគី បានសម្លឹងធ្វើទុកក្នុងចិត្ត ក្នុងអត្តភាពនៃខ្លួន ឃើញត្រឹមតែគំនរអាការទាំង ៣២ ប៉ុណ្ណោះយ៉ាងណា បន្ទាប់មកត្រូវហាត់រៀនធ្វើទុកក្នុងចិត្តក្នុងអត្តភាពនៃបុគ្គលដទៃ ឱ្យឃើញត្រឹមតែគំនរអាការ ៣២ ប៉ុណ្ណោះដូចគ្នាក៏យ៉ាងនោះដែរ។ បន្ទាប់មកត្រូវហាត់រៀនធ្វើទុកក្នុងចិត្តក្នុងអត្តភាពទាំង ២ គឺអត្តភាពរបស់ខ្លួន ១ អត្តភាពអ្នកដទៃ ១ ឱ្យឃើញត្រឹមតែគំនរអាការ ៣២ ជាគំនរសាកសព ដែលគរជាគំនរ គួរបដិកូលក្រៃពេក មិនឃើញមានសត្វបុគ្គល ជីវិត ស្រីប្រុស ជាដើម ថែមទៀត ។

## បច្ឆេទទី ២

កិច្ចប្រតិបត្តិក្នុងការចម្រើននូវអាការទាំង ៣២ នេះ យោគាវចរ គប្បីទន្ទេញ ចងចាំឱ្យបានស្ទាត់ល្អទាំងបណ្តោយទាំងបញ្ច្រាស កាលបើបានស្ទាត់ជំនាញ អាចសូត្រ តាមផ្លូវចិត្តដូចន័យខាងដើមដែលបានពោលមកហើយ គប្បីប្រមូលចិត្តដាក់ក្នុងដើមទ្រូងឱ្យតាំងនៅល្អ អកុសលធម៌មិនអាចគ្របសង្កត់ចិត្តបាន បន្ទាប់មកគប្បីបញ្ជូនចិត្ត ធ្វើការបរិកម្មនូវអាការ ៣២ ជា **អនុលោមបដិលោម** សាទៅសាមករឿយៗ កាលបើបានឃើញនូវអាការណាមួយតាំងឡើងប្រាកដដល់ចិត្ត គប្បីកំណត់ ធ្វើទុកក្នុងចិត្តនូវអាការនេះរឿយៗ ត្រូវលះបង់នូវអាការដទៃសិន ។

បន្ទាប់មក គប្បីលះបង់បញ្ញត្តិមានពាក្យថា សក់ជាដើម ហើយធ្វើទុកក្នុងចិត្តនូវបដិកូលភាពចំពោះអាការដែលតាំងឡើងប្រាកដនោះ លំដាប់នោះបដិកូលភាព ចំពោះអាការដែលតាំងឡើងក៏ប្រាកដដល់ព្រះយោគីមែនពិត បន្ទាប់មកត្រូវចម្រើន នូវអាការដទៃបន្តទៅទៀត រហូតដល់បានគ្រប់ទាំង ៣២ មុខ ។

អាការដែលតាំងឡើង ប្រាកដដល់យោគីនោះ និមិត្តនេះឈ្មោះ **ឧគ្គហនិមិត្ត** ឯបដិកូលភាពដែលតាំងឡើងនិមិត្តនោះឈ្មោះ **បដិភាគនិមិត្ត** ។

ន័យម្យ៉ាងទៀត ព្រះយោគីពួកខ្លះបន្ទាប់ពីបានសិក្សាចងចាំនូវអាការ ៣២ សូត្រតាមផ្លូវចិត្តបាន នៅពេលចម្រើនកម្មដ្ឋានក៏ធ្វើបរិកម្មនូវអាការទាំង ៣២ ជាអនុលោម-បដិលោម បន្ទាប់មកក៏លើកយកអាការមួយៗ តាមលំដាប់មកធ្វើ **បរិកម្មភាវនា** ក៏អាចញ៉ាំង**ឧគ្គហនិមិត្ត** និង**បដិភាគនិមិត្ត**ឱ្យកើតឡើង ។ កាលបើយោគីចម្រើនអាការទាំង ៣២ ជាអនុលោមបានសម្រេចហើយ គប្បីចម្រើនអាការ ៣២ ជាបដិលោមទៀត ។

កាលបើព្រះយោគី បានចម្រើនអាការទាំង ៣២ ជា**អនុលោមបដិលោម** បានសម្រេចនូវ**ឧគ្គហនិមិត្ត** និង **បដិភាគនិមិត្ត**ហើយ ក៏គប្បីធ្វើការប្រមូលនូវអាការទាំង ៣២ ដែលខ្លួនបានឃើញហើយនោះ ឱ្យជាគំនរតែមួយប្រកបដោយបដិកូលភាពតែម្យ៉ាង ការធ្វើយ៉ាងនេះដើម្បីញ៉ាំងឈានដែលកើតឡើងធ្វើនេះឱ្យតាំងនៅមាំទាំល្អ ។ លំដាប់អំពីនោះ យោគីគប្បីបង្អោនចិត្ត នៃខ្លួនចូលមកកំណត់ធ្វើទុកក្នុងចិត្តនូវអាការទាំង ៣២ ដែលមានក្នុងខ្លួនតាមលំដាប់រហូតបាន

សម្រេចជា**ឧគ្គហនិមិត្ត និង បដិភាគនិមិត្ត** ជាអនុលោម-បដិលោម ។ កាលបើបានសម្រេចហើយ គប្បីសម្លឹងកំណត់ធ្វើទុកក្នុងចិត្តនូវអាការទាំង ៣២ ខាងក្នុងអត្តភាពនៃខ្លួន ប្រកបដោយបដិកូលភាព ឱ្យឃើញត្រឹមតែគំនរសាកសព គំនរអាការប៉ុណ្ណោះ មិនឃើញថាមានសត្វ បុគ្គល ជីវិតប្រុស ស្រីជាដើមឡើយ ។

កាលបើកំណត់ធ្វើទុកក្នុងចិត្តនូវអាការទាំង ៣២ ក្នុងខ្លួនបានហើយ គប្បីសម្លឹងកំណត់ធ្វើទុកក្នុងចិត្តនូវអាការទាំង ៣២ ក្នុងអត្តភាពនៃបុគ្គលដទៃប្រកបដោយបដិកូលភាព ឱ្យឃើញត្រឹមតែគំនរសាកសព គំនរអាការប៉ុណ្ណោះមិនឃើញថាមាន សត្វ បុគ្គល ជីវិត ប្រុស ស្រី ជាដើមឡើយ ។

កាលបើកំណត់ធ្វើទុកក្នុងចិត្តនូវអត្តភាពរបស់បុគ្គល សត្វដទៃផ្សេងអំពីខ្លួនឱ្យឃើញត្រឹមតែគំនរសាកសព គំនរអាការដូចគ្នាបានសម្រេចហើយបន្ទាប់មកទៀត គប្បីកំណត់ធ្វើទុកក្នុងចិត្តនូវអត្តភាពទាំង ២ គឺអត្តភាពនៃខ្លួន ១ អត្តភាពរបស់បុគ្គលដទៃ ១ ឱ្យឃើញត្រឹមតែគំនរសាកសព គំនរអាការដូចគ្នា មិនឃើញថាមានសត្វ ជីវិត ប្រុស ស្រី ជាដើមថែមទៀត ។

ឈានដែលកើតឡើងដំបូងនៅទន់ខ្សោយហៅ **ឧបចារជ្ឈាន** កាលបើយោគីសេពនូវ **បដិភាគនិមិត្ត** រឿយៗ ទៅនឹងបាន**អប្បនាឈានគឺបឋមជ្ឈាន**ដោយពិត ។ តែក្នុងសៀវភៅនេះ ពោលត្រឹម**ឧបចារជ្ឈាន**ប៉ុណ្ណោះ ឯ**អប្បនាឈាន** នឹងមានពោលដោយសេចក្តីពិស្តារក្នុងសៀវភៅវិបស្សនាថ្នាក់មធ្យម ។

**មុច្ឆា** គួរឱ្យឆ្ងល់ដែរ ក្នុងបច្ចេកទេសទី ២ នេះ កាលបើគង់នឹងកំណត់ធ្វើទុកក្នុងចិត្តនូវអាការទាំង ៣២ ខាងក្នុងអត្តភាពនៃខ្លួនទេ ចុះចាំបាច់ទៅស្វែងរកអាការទាំង ៣២ ខាងក្រៅឃើញហើយ ទើបមកកំណត់ធ្វើទុកក្នុងចិត្តនូវអាការ ៣២ ខាងក្នុងក្រោយវិញ ធ្វើយ៉ាងនេះនឹងនាំឱ្យយឺតយូរក្នុងកិច្ចប្រតិបត្តិក្នុង **កម្មដ្ឋាន** នេះទេដឹង?

**វិស្សជ្ជនា** ក្នុងបច្ចេកទេសទី ២ នេះមិនមែននាំឱ្យបង្កើតការយឺតយូរក្នុងកិច្ចប្រតិបត្តិនោះទេ តាមសេចក្ដីពិតបច្ចេកទេសនេះនាំមកការបានសម្រេចធម៌បានឆាប់រហ័សទៅវិញ ព្រោះថាប្រយោគីពួកខ្លះ មានអធ្យាស្រ័យមានសភាពបែបនេះឯង បើនឹងចម្រើន **កម្មដ្ឋាន** នេះតាមបច្ចេកទេសទី ១ តែម្ដងបែរជានាំឱ្យមានទើសទាល់នៃញាណមិនអាចញ៉ាំងឈានចិត្តឱ្យកើតឡើបាន ។

ដូច្នេះ យោគាវចរណាមានអធ្យាស្រ័យពេញចិត្ត តាមបែបបច្ចេកទេសណាក៏គប្បីកាន់យកចុះ ។

**មុច្ឆា** ចុះប្រសិនយោគីចម្រើន **កាយគតាសតិកម្មដ្ឋាន** នោះតាមរបៀបបច្ចេកទេសទាំង ២ ហើយមិនអាចញ៉ាំងគុណវិសេសឱ្យកើតឡើងបាន ព្រោះគ្មានពន្លឺសម្រាប់បញ្ចាំងមើលអាការ ៣២ នោះមានតែភាពងងឹតសូន្យសុងតែម្យ៉ាងប៉ុណ្ណោះទោះបីខំប្រឹងយ៉ាងណានោះ តើមានឫទ្ធិដទៃណាអាចជួយក្នុងការចម្រើន**កម្មដ្ឋាន**នេះ ឱ្យបានសម្រេចដែរឬទេ?

**ខស្សជ្ជនា** មាន! ពិតជាមានក្នុងកិច្ចប្រតិបត្តិចម្រើនកម្មដ្ឋាននេះគឺ យោគាវចរគប្បីចម្រើនកសិណ ១០[100] ណាមួយសិន ដើម្បីជួយឧបត្ថម្ភក្នុងការបង្កើតនូវពន្លឺសម្រាប់ឆ្លុះបញ្ចាំងមើលអាការទាំង ៣២ នោះ ព្រោះអាការ ៣២ ដែលយោគាវចរមើលមិនឃើញតាមផ្លូវចិត្តព្រោះគ្មានពន្លឺ កាលបើយោគាវចរបានចម្រើនកសិណា**ឧគ្គហនិមិត្ត** និង **បដិភាគនិមិត្ត**ឱ្យកើតឡើងហើយ យោគាវចរនោះ នឹងមានភ្នែក[101] អាចមើលអាការ ៣២ ដែលត្រូវចម្រើនបន្ទាប់អំពីកសិណនោះ បានដោយពិត ។ ហេតុដូច្នេះសាធុជនទាំងឡាយដែលមានសេចក្តីប៉ុនប៉ងប្រាថ្នា ដើម្បីចម្រើននូវអាការ ៣២ កាលបើចម្រើនអាការទាំង ៣២ មិនបានឃើញតាមផ្លូវចិត្តទេ ឬបានឃើញដែរតែមិនច្បាស់ប្រាកដ គប្បីចម្រើននូវកសិណ ១០ កសិណណាមួយចុះ មុខជានឹងបានពន្លឺភ្លឺស្វាងអាចឆ្លុះបញ្ចាំងមើលនូវអាការទាំង ៣២ នោះបានសម្រេចដូចបំណងមិនខានឡើយ ទុកជាការសន្សំនូវពន្លឺនោះប្រើពេលអស់កាលដ៏យូរទើបបានសម្រេចក៏ដោយ ក៏គប្បីមិនត្រូវលះបង់ក្នុងការចម្រើនកសិណនោះឡើយ ព្រោះកសិណទាំងនេះ ជាកម្មដ្ឋានមួយមានឧបការច្រើនក្នុងការបង្កើតនូវពន្លឺ ដូចតួយ៉ាងព្រះយោគីដែលបានទិព្វចក្ខុ អាចមើលឃើញនូវអ្វីៗ ក្នុងទីកំបាំងទាំងអស់បាន ក៏ព្រោះតែអាស្រ័យដោយការចម្រើនកសិណទាំងនេះឯង ។

[100] កសិណ ១០ ក្តី, កិច្ចប្រតិបត្តិក្នុងកសិណនោះក្តី នឹងមានសរសេរក្នុងទីខាងមុខ ។
[101] ភ្នែកក្នុងទីនេះ គឺភ្នែកចិត្តបានដល់បញ្ញាហ្នឹងឯង ។

**បុច្ឆា** ចុះព្រះយោគី ដែលបានចម្រើនដោយកំណត់នូវអាការទាំង ៣២ ស្ថិតនៅខាងក្រៅអត្តភាពនៃខ្លួន តើអាចនឹងឃើញនូវរូបផ្សេងចាកអាការ ៣២ ផ្សេងនោះដែរឬទេ? បើឃើញហើយ តើព្រះយោគីត្រូវប្រតិបត្តិដូចម្តេចទើបត្រឹមត្រូវតាមអារម្មណ៍របស់**កម្មដ្ឋាន**?

**វិសជ្ជនា** អាចឃើញ! ពិតជាឃើញដូច្នេះខ្លះ ក្នុងការចម្រើននូវអាការទាំង ៣២ នោះ ព្រះយោគីពួកខ្លះក៏ឃើញនូវអាការ ៣២ ដោយពិតៗ ត្រង់ៗ ចំៗ តែម្តង ។ ព្រះយោគីពួកខ្លះទៀត កាលធ្វើទុកក្នុងចិត្តបរិកម្មនូវអាការ ៣២ មិនឃើញអាការទាំង ៣២ ទេ បែរជាឃើញរូបផ្សេងទៅវិញក៏មាន។ រូបផ្សេងនោះ គឺរូបមានពណ៌ ខៀវ ខឿង ក្រហម ស តិច ច្រើន រូបល្អ អាក្រក់ រូបមានប្រមាណមិនបាន ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ហៅថា "រូបខាងក្រៅ" ។

រូបដែលជាអារម្មណ៍កើតឡើងតាមផ្លូវចិត្ត ក្នុងការចម្រើននូវព្រះ**កម្មដ្ឋាន** មាន ២ យ៉ាងគឺ រូបខាងក្នុង ១ រូបខាងក្រៅ ១ ។

- រូបខាងក្នុងបានដល់អាការទាំង ៣២ មានសក់ជាដើម ដែលស្ថិតនៅខាងក្នុងខ្លួន ។
- រូបខាងក្រៅបានដល់រូប ដែលផ្សេងអំពីអាការ ៣២ មាន រូប ពណ៌ ខៀវ លឿង ក្រហម ស ជាដើមនេះឯង ។

កាលបើព្រះយោគី ចម្រើននូវអាការទាំង ៣២ បានឃើញនូវអាការ ៣២ ដោយពិតៗ ត្រង់ៗ ចំៗ នោះ តែម្តងជាការប្រពៃ តែបើបែរជាឃើញនូវរូបខាងក្រៅទៅវិញ គប្បីលះបង់នូវអារម្មណ៍នោះចេញ ព្រោះមិនមែនជាអារម្មណ៍របស់**កម្មដ្ឋាន**នោះទេ ត្រូវខំព្យាយាមចម្រើនឱ្យទាល់តែបានឃើញនូវអាការទាំង ៣២ សម្រេចបាន ជា**ឧគ្គហនិមិត្ត** និង **បដិភាគនិមិត្ត** ទើបត្រឹមត្រូវ ព្រោះ**កម្មដ្ឋាន**នោះមាន **បដិភាគនិមិត្ត** ជាអារម្មណ៍ ។

ការលើកឡើងនូវបញ្ហាខ្លះៗ សួរ ឆ្លើយក្នុង**កាយគតាសតិកម្មដ្ឋាន**នេះ ដើម្បីគ្រាន់ជាគ្រឿងជំនួយដល់សតិប្រាជ្ញានៃព្រះយោគី ជាធម្មាចារ្យ ឬ សាធុជនអ្នកប្រតិបត្តិធម៌ក្នុង**កម្មដ្ឋាន**នេះ កាលបើគួរគប្បីកាន់យកចុះ កាលបើមិនសមគួរដល់ទិដ្ឋិទេគប្បីលើកទុកចុះ ។

-----------------------------

# ព្រហ្មវិហារ ៤

លំដាប់អំពីនេះ សូមពោលអំពីព្រហ្មវិហារបន្តទៅ ។

ព្រហ្មវិហារមាន ៤ យ៉ាងគឺ **មេត្តាព្រហ្មវិហារ** ១, **ករុណាព្រហ្មវិហារ** ១, **មុទិតាព្រហ្មវិហារ** ១, **ឧបេក្ខាព្រហ្មវិហារ** ១។

**ព្រហ្មវិហារ** ៣ ខាងដើម មានអានុភាពឱ្យសម្រេចបានឈានចំនួន ៤ ជាបញ្ចកន័យ ឬឈានចំនួន ៣ ជា ចតុក្កន័យ ឧបេក្ខាព្រហ្មវិហារមានអានុភាព

ឱ្យសម្រេចដល់ **បញ្ចមជ្ឈាន** គឺឈានទី ៥ ជាបញ្ចកន័យ ឬ**ចតុត្ថជ្ឈាន** គឺឈានទី៤ ជាចតុក្កន័យ **ឧបេក្ខាព្រហ្មវិហារ** លុះត្រាយោគាវចរបានចម្រើន**ព្រហ្មវិហារ** ៣ ខាងដើមដល់ឈានទី ៤ ជាបញ្ចកន័យ ឬឈានទី ៣ ជាចតុក្កន័យហើយ ទើបអាចចម្រើនបាន។ ដូច្នេះយោគាវចរដែលជាអាទិកម្មិកបុគ្គលមិនគប្បីរៀន**ឧបេក្ខាព្រហ្មវិហារ**មុនឡើយ ។ ត្រូវរៀន**ព្រហ្មវិហារ** ៣ ខាងដើមមុនព្រោះថា**ឧបេក្ខាព្រហ្មវិហារ**នោះ គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្ដែងចំពោះបុគ្គលដែលបានសម្រេចឈាន ក្នុងព្រហ្មវិហារខាងដើមហើយ ឯព្រហ្មវិហារខាងដើមគឺ ព្រះដ៏មានព្រះភាគទ្រង់សម្ដែងចំពោះអាទិកម្មិកបុគ្គលដោយពិត ។ តែក្នុងសៀវភៅ នេះសូមពោលអំពីរបៀបចម្រើននិងការកើតឡើងនូវគុណវិសេសត្រឹម**ឧបចារជ្ឈាន**ប៉ុណ្ណោះ ដើម្បីទុកសម្រាប់អ្នកសិក្សាថ្មីដំបូងគ្រាន់ជាទីពឹងពំនាក់ ។ ក្នុងការហាត់ទូន្មានចិត្តបានសម្រេចដល់ថ្នាក់ **អប្បនាឈាន** នឹងពោលក្នុងសៀវភៅ **វិបស្សនា** ថ្នាក់មធ្យម ។

## មេត្តាព្រហ្មវិហារ

កាលបើព្រះយោគាវចរកុលបុត្រមានប្រាថ្នា ដើម្បីចម្រើននូវមេត្តាព្រហ្មវិហារ គប្បីចូលទៅកាន់ទីដែលស្ងាត់ចាកអារម្មណ៍ផ្សេងៗ អង្គុយឱ្យស្រួលពិចារណានូវទោសក្នុងសេចក្ដីប្រទូស (ទោសៈ) និងអានិសង្សក្នុងសេចក្ដីអំណត់ (ខន្តី) ជាមុន ។

ទោសក្នុងសេចក្ដីប្រទូស្ដនោះ លោកពោលទុកថា បើបុគ្គលណាដែល **ទោសៈ**គ្របសង្កត់ហើយ បុគ្គលនោះអាចហ៊ានសម្លាប់សត្វជាដើមបាន ឯអានិសង្ស ក្នុងសេចក្ដីអំណត់នោះព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកដូចនេះជាដើមថា ខន្ដី សេចក្ដីអំណត់ចាត់ជា**តបៈ**ធម៌មួយយ៉ាង**ឧត្ដម** បានជាត្រូវពិចារណា ជាមុន ព្រោះថា**កម្មដ្ឋាន**នេះ ព្រះយោគីត្រូវចម្រើនដើម្បីនឹងលះបង់នូវ**ទោសៈ**ហើយនឹង បានខន្ដីប៉ុណ្ណោះ បើមិនបានពិចារណាឱ្យឃើញជាមុនសិន ក៏មិនអាចដើម្បីលះ បង់នូវទោសដែលមិនឃើញហើយបាននូវអានិសង្សដែលមិនដឹងនោះឡើយ ។

កាលដែលព្រះយោគីចម្រើននិងប្រារព្ធមុនដំបូង កុំអាលចម្រើនទៅរក បុគ្គលដែលជាទោស ៤ ពួកគឺ បុគ្គលដែលមិនជាទីស្រឡាញ់ ១, សម្លាញ់ដែល ជាទីស្រឡាញ់ក្រៃពេក ១, បុគ្គលដែលជាកណ្ដាល ១, បុគ្គលដែលមានពៀរ ដល់គ្នា ១, មិនតែប៉ុណ្ណោះសោតសូម្បីតែបុគ្គលដែលមានជាខេត្ត ២ ពួកគឺ បុគ្គល ដែលមានភេទខុសគ្នា[102] ១, បុគ្គលដែលធ្វើមរណកាលកន្លងហើយ ១ ក៏មិន គប្បីចម្រើនមេត្តាព្រហ្មវិហារទៅរកជាដំបូងឡើយ ។ ព្រោះថាបុគ្គលទាំងនោះ មានទោសដូចនេះគឺបុគ្គលដែលមិនជាទីស្រឡាញ់ លំបាកនឹងទាញយកមកតំកល់ ទុកជាទីស្រឡាញ់, សម្លាញ់ដែលជាទីស្រឡាញ់ក្រៃពេក លំបាកនឹងទាញយក មកតម្កល់ទុកឱ្យជាកណ្ដាល, បុគ្គលដែលជាកណ្ដាល លំបាកនឹងទាញយកមក

---

102 បុគ្គលដែលមានភេទខុសគ្នានោះសំដៅយកភេទបុរសនិងស្ត្រី គឺបើយោគីជាបុរស មិនត្រូវចម្រើនមេត្តាព្រហ្មវិហារទៅរកស្ត្រីដោយចំៗ បើយោគីជាស្ត្រីវិញ ក៏មិនត្រូវ ចម្រើនទៅរកបុរសដោយចំៗ ឡើយ ។

តម្កល់ជាទីគោរពនិងជាស្រឡាញ់, បុគ្គលដែលមានពៀរដល់គ្នា បើចម្រើនមេត្តាព្រហ្មវិហារទៅរកនឹងកើតសេចក្តីក្រោធ, បុគ្គលដែលមានភេទខុសគ្នានឹងកើតសេចក្តីតម្រេក បុគ្គលដែលមរណកាលកន្លងហើយ នឹងមិនដល់នូវអប្បនានិងឧបចារ ហេតុនោះទើបលោកហាមមិនឱ្យចម្រើនមេត្តាទៅរកជាដំបូង។

ព្រះយោគីអ្នកចម្រើនមេត្តាព្រហ្មវិហារនោះ ត្រូវចម្រើនមេត្តាចំពោះខ្លួនឯងជាមុន គឺត្រូវចម្រើនឱ្យរឿយៗ ថា **អហំ សុខិតោ ហោមិ និទ្ទុក្ខោ** សូមឱ្យអញ បានដល់នូវសេចក្តីសុខ កុំបីមានទុក្ខឡើយ ឬនឹងចម្រើនថា **អវេរោ អព្យាបជ្ឈោ អនីឃោ សុខី អត្តានំ បរិហរាមិ** សូមឱ្យអញជាបុគ្គលគ្មានពៀរ គ្មានទុក្ខ គ្មានទោស ឱ្យមានតែសេចក្តីសុខ សូមរក្សាខ្លួនឱ្យបានយ៉ាងនេះជាដរាបទៅ ដូចនេះក៏បាន ។

បើព្រះយោគីចម្រើននូវមេត្តាព្រហ្មវិហារ ចំពោះខ្លួនយ៉ាងនេះរឿយៗហើយ ឈានចិត្តគឺ**ឧបចារជ្ឈាន**នៅមិនទាន់កើតឡើង ក៏គប្បីតម្កល់ទុកនូវខ្លួនឱ្យជាបន្ទាល់ ហើយទាញយកចិត្តទាំងឡាយដទៃមកប្រៀបថា អញប្រាថ្នានូវសេចក្តីសុខ ខ្ពើមរអើមទុក្ខ ប្រាថ្នាចង់រស់ មិនចង់ស្លាប់យ៉ាងណា សត្វទាំងឡាយដទៃក៏ប្រាថ្នានូវសេចក្តីសុខ ខ្ពើមរអើមទុក្ខ ប្រាថ្នាចង់រស់ មិនចង់ស្លាប់យ៉ាងនោះដែរ រួចហើយ ត្រូវចម្រើនមេត្តា ចំពោះបុគ្គលដែលគួរគោរពមានអាចារ្យនិងឧបជ្ឈាយ៍ជាដើមឱ្យរឿយៗ ថា **ឯស សប្បុរិសោ សុខិតោ ហោតុ និទ្ទុក្ខោ** សូមឱ្យលោកជាសប្បុរសនុ៎ះ បានដល់នូវ សេចក្តីសុខកុំបីមានទុក្ខឡើយ ។

ដោយអំណាចដែលព្រះយោគីចម្រើននូវ **មេត្តាព្រហ្មវិហារ** ចំពោះបុគ្គលមានសភាពយ៉ាងនេះ អង្គនៃ**ឧបចារជ្ឈាន**ទាំង ៥ ពោលគឺ **វិតក្កៈ** ១, **វិចារ** ១, **បីតិ** ១, **សុខៈ** ១, **ឯកគ្គតា** ១ ក៏កើតឡើង ។

កាលបើចិត្តស្ថិតនៅស៊ប់ក្នុង**ឧបចារជ្ឈាន**ហើយ យោគីចេះតែចម្រើនមេត្តាព្រហ្មវិហារបន្តទៅទៀតព្រះយោគីក៏នឹងបានសម្រេចដល់អប្បនាឈានដោយពិត។

តែបើនៅមិនទាន់ដល់នូវសេចក្តីត្រេកអរដោយព្យាយាមទេ គប្បីចម្រើនចំពោះបុគ្គលដែលជាទីស្រឡាញ់ បុគ្គលដែលជាកណ្តាល បុគ្គលដែលមានពៀរដល់គ្នាតទៅទៀត ចម្រើនក្នុងកោដ្ឋាសនីមួយៗ ធ្វើចិត្តឱ្យគួរដល់កម្មទាញយកបុគ្គលដែលជាទីស្រឡាញ់មកដាក់ត្រង់កន្លែងបុគ្គលដែលជាកណ្តាលៗ មកដាក់ត្រង់កន្លែងបុគ្គលដែលមានពៀរដល់គ្នា បន្ទោបង់នូវបដិឃៈក្នុងបុគ្គលដែលមានពៀរដល់គ្នា លំដាប់មកទៀតគប្បីចម្រើនឱ្យរឿយៗ ញ៉ាំងចិត្តឱ្យប្រព្រឹត្តទៅស្មើដោយសីមសម្ភេទ[103] ក្នុង បុគ្គលទាំង ៤ ពួក គឺខ្លួនរបស់ព្រះយោគី ១, បុគ្គលដែលជាទីស្រឡាញ់ ១, បុគ្គលដែលជាកណ្តាល ១, បុគ្គលដែលមានពៀរដល់គ្នា ១, មិនឱ្យមានធ្ងន់មានស្រាលជាងគ្នា, សីមសម្ភេទនេះហើយដែលលោកហៅថានិមិត្តក្នុង**កម្មដ្ឋាន**នេះ ព្រោះថាក្នុងព្រហ្មវិហារទាំង ៤ មិនមាន

103 សីម ដែន ក្នុងទីនេះមាន ៤ គឺ បុគ្គលជាទីស្រឡាញ់ដែន ១, បុគ្គលជាកណ្តាលដែន ១, បុគ្គលដែលមានពៀរដែន ១, ខ្លួនព្រះយោគីដែន ១, ត្រង់ដែលផ្សាយមេត្តាចិត្តទៅក្នុងដែនទាំង ៤ ហៅថា សីមសម្ភេទ ។

**ឧគ្គហនិមិត្ត** និង **បដិភាគនិមិត្ត** ដូចក្នុងកសិណទាំង ១០ ជាដើមឡើយ មានតែ **សមថនិមិត្ត** ដែលប្រព្រឹត្តទៅដោយអំណាចនៃសីមសម្ភេទប៉ុណ្ណោះ ។

ឈានកើតដំបូងនៅទន់ឈ្មោះ **ឧបចារជ្ឈាន** តែបើព្រះយោគីសេព នូវនិមិត្តដោយច្រើន ចម្រើនឱ្យរឿយៗ ឡើងទៅ ក៏នឹងបានដល់ **អប្បនាឈាន** ដោយងាយមិនមានលំបាកឡើយ តែក្នុង **កម្មដ្ឋាន** នេះឱ្យសម្រេចបានតែត្រឹម **តតិយជ្ឈាន** ក្នុង **ចតុក្កន័យ** ឬ **ចតុត្ថជ្ឈាន** ក្នុង **បញ្ចកន័យ** ប៉ុណ្ណោះ ។

តែក្នុងសៀវភៅច្បាប់នេះពោលត្រឹម **ឧបចារជ្ឈាន** ប៉ុណ្ណោះសម្រាប់អ្នកទើបរៀនថ្មី ឯ **អប្បនាឈាន** នឹងពោលក្នុងសៀវភៅ **វិបស្សនា** ថ្នាក់មធ្យម ។

## ករុណាព្រហ្មវិហារ

កាលបើយោគាវចរកុលបុត្ត មានប្រាថ្នាដើម្បីចម្រើននូវករុណាព្រហ្មវិហារ គប្បីចូលទៅកាន់ទីដែលស្ងាត់ចាកអារម្មណ៍ផ្សេងៗ ពិចារណានូវទោសក្នុងសេចក្តីបៀតបៀននិងអានិសង្សក្នុងករុណាជាមុនសិនថា ផលរបស់សេចក្តីបៀតបៀន ធ្វើទុក្ខសត្វ ដោយដៃនិងដុំដី ដំបងជាដើមនេះ ដ៏លាមកក្រៃពេកទាំងក្នុងបច្ចុប្បន្ននេះនិងក្នុងបរលោកនាយ ផលរបស់ករុណា សេចក្តីអាណិតអាសូរសត្វទើបប្រសើរទាំងក្នុងបច្ចុប្បន្ននេះនិងក្នុងបរលោកនាយ ។

កាលបើព្រះយោគាវចរ ប្រារព្ធនឹងចម្រើននូវករុណាព្រហ្មវិហារនេះ កុំគប្បីចម្រើនចំពោះបុគ្គលដែលជាទោស ៤ ពួក និងបុគ្គលដែលមិនមែនថាខេត្ត

២ ពួក ដូចពោលមកហើយក្នុង**មេត្តាភាវនា**នោះឡើយ បើប្រទះឃើញបុគ្គលណាមួយដែលគួរឱ្យអាណិតដូចមនុស្សវិកលវិការ កំសត់ទុគ៌ត កំបុតដៃ កំបុតជើងជាដើម ក៏គប្បីញ៉ាំងករុណាព្រហ្មវិហារឱ្យប្រព្រឹត្តទៅ ក្នុងបុគ្គលនោះថា "**កិច្ឆំ វតាយំ សត្តោ អាបន្នោ អប្បេវ នាម ឥមម្ហា ទុក្ខា មុច្ចេយ្យ** ឱហ្ន៎! សត្វនេះដល់នូវសេចក្ដីលំបាក ធ្វើដូចម្ដេចហ្ន៎! នឹងគប្បីឱ្យរួចចាកទុក្ខនេះបាន" ។

បើរកបុគ្គលដែលគួរអាណិតបែបនេះពុំបាន គប្បីទាញយកបុគ្គលដែលកំពុងបាននូវសេចក្ដីសុខតែប្រព្រឹត្តធ្វើនូវបាបជាប្រក្រតី មកប្រៀបនឹងមនុស្សទោសដែលរាជអាជ្ញាត្រូវឱ្យសម្លាប់បង់ហើយ ញ៉ាំងករុណាព្រហ្មវិហារឱ្យប្រព្រឹត្តទៅថា "បុគ្គលនោះមានសេចក្ដីសុខតែក្នុងបច្ចុប្បន្នជាតិនេះទេ តទៅទៀតមុខជាសោយនូវទុក្ខទោសមនស្សជាពន្លឹកក្នុងអបាយភូមិមិនខាន ព្រោះមិនមានធ្វើកល្យាណកម្មដោយទ្វារណាមួយសោះឡើយ ដូចជាមនុស្សទោស ដែលរាជបុរសវាយខ្នោះជើងក្អែកបណ្ដើរទៅកាន់ទីដែលនឹងសម្លាប់ បើមានគេឱ្យនូវខាទនីយភោជនីយាហារបន្តិចបន្តួច ក៏បរិភោគសម្ដែងអាការដូចជាបាននូវសេចក្ដីសុខស្កប់ស្កល់ទៅដោយភោគៈ តែមិនមានបុគ្គលណាមួយ គេសម្គាល់ថាបានសុខឡើយ គេសម្គាល់ថាមុខជានឹងស្លាប់ដោយពិត" ។

តពីនោះមក គប្បីញ៉ាំងករុណាព្រហ្មវិហារដោយឧបាយនេះឱ្យប្រព្រឹត្តទៅក្នុងបុគ្គលដែលជាទីស្រឡាញ់ បុគ្គលដែលជាកណ្ដាល បុគ្គលដែលមានពៀរដល់

គ្នារៀងជាលំដាប់មក សូម្បីបុគ្គលនេះជាអ្នកធ្វើកុសលកម្មក្តី ក៏គប្បីប្រព្រឹត្តទៅថា "បុគ្គលនោះៗ គង់ដល់នូវសេចក្តីទុក្ខដោយពិត ព្រោះកន្លងនូវវដ្តទុក្ខមិនទាន់ផុត" លំដាប់មកគប្បីឱ្យប្រព្រឹត្តទៅក្នុងជនទាំង ៤ ពួក ធ្វើចិត្តឱ្យស្មើជាសីមសម្ភេទ ដូចក្នុងមេត្តាព្រហ្មវិហារ ហើយសេពនូវនិមិត្ត គឺសីមសម្ភេទនោះដោយច្រើន ចម្រើនឱ្យរឿយៗ ដរាបដល់បានសម្រេចនូវឈានចិត្ត ឈានដែលកើតឡើងដំបូង ជា **ឧបចារជ្ឈាន** កាលបើយោគីបានសម្រេចដល់ **ឧបចារជ្ឈាន** ក៏ចេះតែចម្រើន **ករុណាព្រហ្មវិហារ** នេះរឿយៗ ក៏នឹងបានសម្រេចដល់អប្បនាឈាន គឺឈាន ចំនួន ៣ ជាចតុក្កន័យ ឬឈានចំនួន ៤ ជាបញ្ចកន័យ តែក្នុងច្បាប់នេះពោលត្រឹម ឧបចារជ្ឈានប៉ុណ្ណោះ ឯ**អប្បនាឈាន** នឹងមានពោលក្នុងសៀវភៅ **វិបស្សនា** ថ្នាក់មធ្យម ។

## មុទិតាព្រហ្មវិហារ

កាលបើយោគាវចរកុលបុត្ត ប្រារព្ធដើម្បីចម្រើននូវ **មុទិតាព្រហ្មវិហារ** មុនដំបូងកុំគប្បីចម្រើនក្នុងបុគ្គលដែលជាទោស មិនមែនជាបទដ្ឋាននៃ**មុទិតាព្រហ្មវិហារ** ៣ ពួកគឺ បុគ្គលដែលជាទីស្រឡាញ់ ១, បុគ្គលដែលជាកណ្តាល ១, បុគ្គលដែលមានពៀរដល់គ្នា ១, និងបុគ្គលដែលមិនមែនជាខេត្តនៃ **មុទិតាព្រហ្មវិហារ** ២ គឺ បុគ្គលដែលមានភេទខុសគ្នា និងបុគ្គលដែលធ្វើមរណកាលកន្លងហើយនោះឡើយ គប្បីចម្រើនក្នុងបុគ្គលដែលជាទីស្រឡាញ់ក្រៃពេកជាមុន[104] ។

---

[104] សំឡាញ់ដែលប្រាកដស្មើដោយអ្នកលេង កាលប្រទះគ្នា សើចមុនទើបនិយាយស្តីខាងក្រោយ (សោណ្ឌសហាយ) ។

កាលបើបានឃើញ បានឮបុគ្គលដែលជាទីស្រឡាញ់ក្រៃពេកនោះកំពុងរីករាយបានដល់នូវសេចក្តីសុខ គប្បីញ៉ាំង **មុទិតាព្រហ្មវិហារ** ឱ្យកើតឡើងថា **មោទតិ វតាយំ សត្តោ អហោ សាធុ អហោ សុដ្ឋុ** ឱហ្ន៎! សត្វនេះរីករាយ ល្អពេក ប្រពៃពេក សូម្បីបុគ្គលនោះបានដល់នូវសេចក្តីសុខតែអំពីអតីតជាតិ ដល់មកក្នុងបច្ចុប្បន្នជាតិនេះជាអ្នកកំសត់ទុគ៌ត ក៏គប្បីរឭកដល់ភាពដែលបុគ្គលនោះដល់នូវសេចក្តីសុខអំពីអតីត កាន់យកអាការដែលបុគ្គលនោះរីករាយកន្លងទៅហើយ មកញ៉ាំង**មុទិតាព្រហ្មវិហារ**ឱ្យកើតឡើងថា: **ឯស អតីតេ ឯវំ មហាភោគោ មហាបរិវារោ និច្ចមុទិតា អហោសិ** បុគ្គលនុ៎ះអំពីអតីតជាអ្នកមានភោគៈច្រើនយ៉ាងនេះ មានបរិវារច្រើនយ៉ាងនេះ ជាអ្នករីករាយជានិច្ចយ៉ាងនេះ ។ ខាងអនាគតក៏ គប្បីញ៉ាំង**មុទិតាព្រហ្មវិហារ**ឱ្យកើតឡើងដូចគ្នា ។

តអំពីនោះមក គប្បីញ៉ាំង**មុទិតាព្រហ្មវិហារ**ឱ្យប្រព្រឹត្តទៅតាមន័យនេះក្នុងបុគ្គលដែលជាទីស្រឡាញ់ បុគ្គលដែលជាកណ្តាល បុគ្គលដែលមានពៀរដល់គ្នារៀងជាលំដាប់មកដរាបដល់រម្ងាប់នូវ**បដិឃៈ** ក្នុងបុគ្គលដែលមានពៀរបាន ដែលញ៉ាំង**មុទិតាព្រហ្មវិហារ**ឱ្យប្រព្រឹត្តទៅក្នុងជនទាំង៤ពួក ធ្វើចិត្តឱ្យស្មើជាសីមសម្ភេទដែលជាតួ**សមថនិមិត្ត**ក្នុងកម្មដ្ឋាននេះរួចហើយ គប្បីសេពនូវ**សមថនិមិត្ត**នោះឱ្យច្រើនចំរើនរឿយៗ ដរាប់ដល់ញ៉ាំងអប្បនាឱ្យចម្រើនឡើងដោយអំណាច

នៃ **តតិយជ្ឈាន** និងចតុត្ថជ្ឈាន ឈានខាងដើមដែលកើតឡើងមុនបឋមជ្ឈាន កើតឈ្មោះ**ឧបចារជ្ឈាន** មានអង្គ ៥ **វិតក្ក** ១, **វិចារ** ១, **បីតិ** ១, **សុខ** ១, **ឯកគ្គតា** ១, ក្នុងសៀវភៅនេះពោលត្រឹម**ឧបចារជ្ឈាន ឯអប្បនាឈាន** នឹងអធិប្បាយក្នុងច្បាប់ **វិបស្សនា** ថ្នាក់មធ្យម ។

លំដាប់អំពីនេះទៅ សូមពោលអធិប្បាយអំពី**កម្មដ្ឋាន ១១ គឺ កសិណ ១០ និង អនាបានស្សតិ ១** ដែលមានអានុភាពឱ្យសម្រេចបានឈានចំនួន ៥ ក្នុង**បញ្ចកន័យ** ឬឈានចំនួន ៤ ក្នុង**ចតុក្កន័យ**តទៅ តែក្នុងសៀវភៅច្បាប់នេះ សូមពោលអំពីរបៀបចម្រើនកម្មដ្ឋានទាំងនោះឱ្យបានសម្រេចនូវគុណវិសេសខាង ដើមគឺឧបចារជ្ឈានប៉ុណ្ណោះ សម្រាប់សាធុជនអ្នករៀនប្រតិបត្តិជាដំបូងក្នុងការអប់រំខ្លួនឱ្យបានល្អ, ឯរបៀបចម្រើនឱ្យកើតដល់អប្បនាឈាននិងគុណធម៌ទាំងនោះនឹងមានពោលអធិប្បាយក្នុង សៀវភៅច្បាប់វិបស្សនាថ្នាក់មធ្យម ។

## កសិណ ១០ បឋវីកសិណ

ព្រះយោគាវចរកុលបុត្ត ដែលជាអាទិកម្មិកបុគ្គលកាលបើមានប្រាថ្នា ដើម្បីនឹងចម្រើនយកនិមិត្តក្នុង**បឋវីកសិណ** គប្បីយកដីមកធ្វើជាវង់កសិណទុក ជាមុន[105] ឯវិធីដែលនឹងធ្វើនូវវង់កសិណនោះ មាន ២ យ៉ាង គឺ យកឈើមក

[105] ដែលត្រូវធ្វើវង់កសិណទុកយ៉ាងនេះ ចំពោះតែព្រះយោគីដែលជាអាទិកម្មិកម្យ៉ាង បើព្រះយោគីដែលមានអភិនីហារធ្លាប់សន្សំទុកមក លោកសម្លឹងមើលតែមណ្ឌលនៃ

ចងខ្វែងទុកជា ៤ ជ្រុង យកកំណាត់សំពត់ កំណាត់ស្បែក ឬកំណាត់កន្ទេលមកចងពាសភ្ជាប់ឱ្យណែនអំពីខាងលើ ហើយយកដីស្អិតមានពណ៌ក្រហមដូចព្រះអរុណមិនមានលាយដោយពណ៌ខៀវជាដើមមកលាបអំពីខាងលើធ្វើឱ្យមានវង់មូលទំហំកាត់ទទឹង ១ ចំអាម ៤ ធ្នាប់ ឬឱ្យធំជាងនេះទៅក្តី តាមសមគួរដល់ចរិត ដុសខាត់ឱ្យស្អាតស្មើដូចផ្ទៃស្គរ កុំឱ្យមានសម្រាម ឬ ស្មៅ ឬដុំគ្រួស និងដីខ្សាច់ជាដើមនៅលាយឡំ ដល់ពេលចម្រើនទើបនាំយកទៅតែម្តងក៏បាន ។

ពុំនោះនឹងបោះជាបង្គោល ៤ នៅត្រង់កន្លែងដែលស្ងាត់មានជ្រុងញកវិហារជាដើម ហើយយកកំណាត់សំពត់ កំណាត់ស្បែក ឬកំណាត់កន្ទេលទៅចងរឹតអំពីខាងលើ យកដីស្អិតមកលាបធ្វើជាវង់កសិណតម្កល់ទុកជាប់ជានិច្ចក្នុងទីនោះក៏បាន ។

ត្រូវមានតាំង ១ មានជើងកំពស់ ១ ចំអាម ៤ ធ្នាប់ សម្រាប់អង្គុយចម្រើន ដល់ពេលដែលបានបន្ទោបង់សេចក្តីស្រវឹងក្នុងភត្តដោយស្រួលហើយត្រូវនាំយកវង់កសិណនោះទៅកាន់ទីដែលកំបាំងតម្កល់ទុកអំពីខាងមុខចម្ងាយ ២ ហត្ថ ១ ចំអាម រៀបចំក្រាលតាំងឱ្យល្អឡើងអង្គុយពត់ភ្នែន តម្រង់កាយប្រុងស្មារតីឱ្យស្រួលហើយ ពិចារណានូវទោសរបស់កិលេសកាមនិងវត្ថុកាមឱ្យឃើញថាមានសេចក្តីត្រេកអរមានប្រមាណតិច មានទុក្ខទោសចង្អៀតចង្អល់ច្រើន មិនគួរ

---

លានជាដើមប៉ុណ្ណោះ ក៏អាចនឹងញ៉ាំងឧគ្គហនិមិត្ត និងបដិភាគនិមិត្តឱ្យកើតឡើងបានរហូតដល់អប្បនាឈាន ។

ឱ្យត្រេកអរដូចជារាងឆ្អឹងតែងដុតឱ្យក្ដៅក្រហាយរោលរាល ដូចគប់ភ្លើងធ្វើដោយស្មៅជាដើមហើយញ៉ាំងសេចក្ដីប្រាថ្នាក្នុងឈានឱ្យកើតឡើងព្រមថា **បដិបទា** នេះជាគ្រឿងរលាស់ចេញចាកកាមបាន ជាឧបាយឱ្យកន្លងបង់នូវទុក្ខទាំងពួងបានហើយត្រូវរឭកដល់**ពុទ្ធាទិគុណ**ឱ្យកើត**បីតិ** និង**បាមោជ្ជ**[106] ជាមុនហើយត្រូវមានសេចក្ដីគោរព ត្រូវសង្ឃឹមចំពោះសេចក្ដីប្រតិបត្តិរបស់ខ្លួនថា នេះជាដំណើរដែលព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងអរិយសសាវករាល់ព្រះអង្គតែងប្រតិបត្តិមកហើយអញមុខជានឹងបាននូវចំណែកនៃសេចក្ដីសុខក្នុងវិវេក ដោយសេចក្ដីប្រតិបត្តិនេះមិនខានឡើយ ហើយត្រូវញ៉ាំងឧស្សាហ៍ឱ្យកើតឡើងក្នុងខណៈនោះ ទើបបើកភ្នែកឡើងឱ្យល្មម កុំឱ្យតូចពេក ធំពេក សម្លឹងយកនិមិត្តរបស់កសិណនោះ តែមិនត្រូវពិចារណាពណ៌ មិនត្រូវធ្វើទុកក្នុងចិត្ត នូវលក្ខណៈរឹងឬទន់ជាដើមឡើយ ត្រូវទាញស្រាវយកពណ៌មក អែបទុកជានិស្ស័យ ហើយតាំងចិត្តទុកបញ្ញត្តិធម៌ដែលលោកសន្មតហៅថា "**ដី**" ដោយមានធាតុដីផ្សាយឡើងច្រើនប៉ុណ្ណោះ ហើយកំណត់ធ្វើទុកក្នុងចិត្តបរិកម្មថា "**បឋវី បឋវី ដីៗ**" ដូចនេះ បើសម្លឹងមើលវង់កសិណម្ដង ធ្មេចភ្នែកនឹកក៏ឃើញ យ៉ាងនោះដដែលៗ ត្រង់នោះត្រូវដឹងថា **ឧគ្គហនិមិត្ត** កើតឡើងហើយ ។

[106] សេចក្ដីអំណរដែលកើតភ្លាឡើងហៅថា បីតិ ដែលនៅទន់ស្ទើរហៅថា បាមោជ្ជ ។

កាលបើចម្រើនបាន**ឧគ្គហនិមិត្ត**ដូចនេះហើយ មិនត្រូវនៅក្នុងទីនោះទៀតឡើយ គប្បីថយទៅរកកន្លែងទីដទៃនឹងចម្រើនទៀត ត្រូវពាក់ស្បែកជើងផ្ទៃ ១, ជាន់ កាន់ឈើច្រត់ដើរទៅដើម្បីរក្សានូវនិមិត្តនោះ មិនឱ្យវិនាសទៅវិញ[107] ។ លុះត្រឡប់ដល់ទីសេនាសនៈរបស់ខ្លួនហើយ ត្រូវអង្គុយឱ្យស្រួល ហើយនឹកទាញស្រាវយក**ឧគ្គហនិមិត្ត**នោះមកកំណត់ទុកក្នុងចិត្តថា **"បឋវី បឋវី ជីៗ"** ដូចដើមដែលហាត់បង្ខឹកចម្រើនឱ្យវិសេសឡើងទៀត កាលបើព្រះយោគីកំណត់ធ្វើទុកក្នុងចិត្តរឿយៗ យ៉ាងនេះ ហើយនីវរណធម៌ ៥ ក៏ទ្រោមទៅ កិលេសក៏ស្ងប់ទៅជាលំដាប់ ចិត្តរបស់ព្រះយោគីសោតតម្កល់នៅមាំដោយ**ឧបចារសមាធិ** ខណៈនោះបដិភាគនិមិត្តក៏កើតឡើង ។

ក្នុង**បឋវីកសិណ**នេះ **ឧគ្គហនិមិត្ត**នៅមានលាយឡំដោយពណ៌ខៀវលឿងជាដើម ឯ**បដិភាគនិមិត្ត**ហាក់ដូចជាទម្លាយនូវឧគ្គហនិមិត្តចេញមកបរិសុទ្ធល្អិតសុខុម ១ រយគុណ ១ ពាន់គុណក្រៃពេកឡើងទៀត ឧបមាដូចជាមណ្ឌលនៃកញ្ចក់ដែលគេហូតចេញមកអំពីស្រោម ឬដូចជាសំបកនៃសង្ខដែលជាងខាត់យ៉ាងល្អ ពុំនោះដូចជាមណ្ឌលនៃព្រះចន្ទដែលទើបចេញមកពីចន្លោះពពក តែថា

[107] ពាក់ស្បែកជើងការពារមិនឱ្យបន្លាមុតឬប្រឡាក់ធូលីជាដើម ដែលជាហេតុនាំឱ្យកើតបលិពោធ កាន់ឈើច្រត់សម្រាប់ការពារអន្តរាយមានឆ្កែជាដើម ក្នុងទីនេះលោកពោលថាត្រូវពាក់ស្បែកជើងផ្ទៃ ១ ជាន់ តែថាប្រហែលជាលោកពោលចំពោះមជ្ឈិមប្រទេសទេដឹង? បើក្នុងបច្ចន្តប្រទេស តាមបរទេសបញ្ញត្តិពាក់បានរហូតដល់ ៤ ជាន់ មិនជាអ្វី ឬ នឹងទៅជាធ្ងន់នាំឱ្យកើតបលិពោធវិញ?

មិនមានពណ៌មិនមានសណ្ឋាន ទ្រង់ទ្រាយឡើយ លំដាប់នោះនីវរណធម៌ទាំង ៥ ក្តី កិលេសទាំងពួងក្តី ក៏ទ្រោមស្ងាត់បាត់ទៅ ចិត្តរបស់ព្រះយោគីសោតក៏តម្កល់នៅមាំដោយ**ឧបចារសមាធិ**ដដែល ព្រោះជា**កាមាវចរ** អង្គឈានទាំង ៥ មិនទាន់កើតឡើងមានកម្លាំងមែនពិត ។

តែបើព្រះយោគី ពុំបានលះបង់នូវលំដាប់នៃវិធីចម្រើន ក៏នឹងបានសម្រេចដល់អប្បនាឈានទាំង **ចតុក្កន័យ** និង **បញ្ចកន័យ** តែអប្បនាឈាននឹងមានពោលអធិប្បាយក្នុងច្បាប់ **វិបស្សនា** ថ្នាក់មធ្យម ។

## អាបោកសិណ

កាលបើព្រះយោគាវចរមានប្រាថ្នាដើម្បីនឹងចម្រើនយកនិមិត្ត ក្នុង**អាបោកសិណ** គប្បីត្រងយកទឹកភ្លៀងដែលទើបធ្លាក់ចុះមកអំពីអាកាស មិនទាន់ដល់ផែនដី ឬ ទឹក ឯទៀតក៏បាន ឱ្យតែថ្លាមានដូចនោះ យកសំពត់ត្រងស្អាតដាក់ក្នុងបាត្រឬកុណ្ឌីជាដើម វាស់ឱ្យពេញស្មើត្រឹមមាត់ នាំយកទៅតម្កល់ទុកជា**កសិណ**[108] ក្នុងទីដែលស្ងាត់ ឡើងអង្គុយលើតាំង បើកភ្នែកសម្លឹងមើលយកនិមិត្ត តែមិនត្រូវពិចារណាពណ៌ មិនត្រូវធ្វើទុកក្នុងចិត្តនូវខណៈដែលរាវជាដើម

---

108 វិធីដែលត្រូវធ្វើកសិណយ៉ាងនេះ ចំពោះតែព្រះយោគីដែលជាអាទិកម្មិកម្ប៉ាងបើព្រះយោគីដែលមានបុណ្យ មានអភិនីហារធ្លាប់ចម្រើនក្នុងកសិណនេះមកពីអតីតជាតិ លោកគ្រាន់តែសម្លឹងមើលទឹកក្នុងស្រះ ឬសមុទ្រជាដើមក៏អាចញុំាងនិមិត្តឱ្យកើតឡើងបាន ។ វិធីដែលសល់អំពីនេះ ដូចក្នុងបឋវីកសិណ ។

ឡើយ ត្រូវតាំងចិត្តទុកតែក្នុង**បញ្ញត្តិជម៌** គឺពាក្យ លោកសន្មតហៅថា "**ទឹក**" ដែលមានធាតុទឹកផ្សាយឡើងច្រើនប៉ុណ្ណោះ ហើយត្រូវបរិកម្មកំណត់ធ្វើទុកក្នុងចិត្ត "**អាបោ អាបោ ទឹកៗ**" ដូចនេះរហូតដល់**ឧគ្គហនិមិត្ត** និង **បដិភាគនិមិត្ត** កើតឡើង ។

**ឧគ្គហនិមិត្ត** ក្នុង **អាបោកសិណ** នេះ តាំងឡើងប្រាកដហាក់ដូចជាញ័ររំជួយ បើទឹកដែលយកមកធ្វើជាកសិណនោះមានច្រឡំគ្នាដោយផេះ ដោយរលក ឬពពុះ ក៏ប្រាកដដូចនោះ ឯបដិភាគនិមិត្ត ទ្រង់ដូចជាផ្សែងផ្សាយខ្ពុរព្រាចឡើងប្រាកដ ហាក់ដូចជាផ្ចិតជាវិការនៃកែវមណីដែលគេតម្កល់ទុកក្នុងអាកាស ពុំនោះប្រាកដហាក់ដូចជាមណ្ឌលនៃកញ្ចក់នៃកែវមណី[109] ។

## តេជោកសិណ

កាលបើយោគាវចរកុលបុត្រ មានប្រាថ្នាដើម្បីនឹងចម្រើនយកនិមិត្តក្នុងតេជោកសិណ គប្បីយកឧសក្រាក់ដែលខ្លឹមៗ មកពុះហាលថ្ងៃឱ្យស្ងួតចងធ្វើជាបាច់ៗ ឱ្យមូលៗ ដល់ពេលដែលត្រូវការនឹងចម្រើនគប្បីនាំយកទៅកាន់ទីឱកាសដែលស្ងាត់ដុតបង្កាត់ឱ្យមានជាអណ្តាត រួចយកកំណាត់សំពត់កន្ទេលក៏បានកំណាត់ស្បែកក៏បាន កំណាត់សំពត់ក៏បានណា ១ មកចោះធ្វើជាប្រហោងឱ្យមានរង្វង់មូលទំហំទទឹង ។

---

[109] វិធីដែលសល់អំពីនេះ ដូចក្នុងបឋវីកសិណ ។

១ ចំអាម ៤ ធ្លាប់[110] ។ ហើយយកទៅដាក់កំបាំងអំពីខាងមុខ ឱ្យមើលទៅឃើញតែអណ្ដាតភ្លើងដែលឆាបឡើងត្រង់ចន្លោះប្រហោងនោះ ហើយអង្គុយបើកភ្នែកសម្លឹង យកនិមិត្តត្រង់កណ្ដាលអណ្ដាតភ្លើងនោះ មិនត្រូវធ្វើទុកក្នុងចិត្តនូវស្មៅឬឧសជាខាងក្រោមសំណុំផ្សែងខាងលើ មិនត្រូវពិចារណាពណ៌ មិនត្រូវកំណត់ធ្វើទុកក្នុងចិត្តនូវលក្ខណៈដែលក្ដៅនោះឡើយ គប្បីទាញស្រាវយកពណ៌មកផ្ទេបធ្វើជានិស្ស័យហើយតាំងចិត្តទុកតែក្នុងបញ្ញត្តិធម៌ គឺពាក្យដែលលោកសន្មតហៅថា "**តេជ**" ដោយមានធាតុភ្លើងផ្សាយឡើងច្រើនប៉ុណ្ណោះ ហើយតាំងកំណត់បរិកម្មធ្វើទុកក្នុងចិត្តថា "**តេជោ តេជោ តេជៗ**" ដូចនេះ ជូនកាលបើកភ្នែកមើល ជូនកាលធ្មេចភ្នែកនឹករពឹងដរាបដល់ **ឧគ្គហនិមិត្តនិងបដិភាគនិមិត្ត** កើតឡើង ។ **ឧគ្គហនិមិត្តក្នុងតេជោកសិណ**នេះ ប្រាកដហាក់ដូចជាអណ្ដាតភ្លើងដាច់ៗ ធ្លាក់ចុះមកបើកសិណនោះមានអង្កត់ដុំងងើក ផេះ ឬផ្សែងក៏ប្រាកដឡើងយ៉ាងនោះ ឯបដិភាគនិមិត្តតាំងនៅនឹងថ្កល់ឥតមានកម្រើក ហាក់ដូចជាកំណាត់សម្ពត់កម្ពលមានពណ៌ក្រហម ដែលគេតម្កល់ទុកឰដ៏អាកាស ឬ ហាក់ដូចជាផ្លិតជាវិការនៃមាស ពុំនោះហាក់ដូចជាសសរមាស ដែលគេលើកបញ្ឈរឡើងឰដ៏អាកាស ។

---

[110] វិធីកសិណបែបនេះសម្រាប់ព្រះយោគីអាទិកម្មិក បើព្រះយោគីអ្នកមានអភិនីហារ សម្លឹងមើលតែអណ្ដាតប្រទីប ឬភ្លើងក្នុងចង្ក្រានជាដើមក៏បាន ។

# វាយោកសិណ

កាលបើព្រះយោគាវចរកុលបុត្រ មានប្រាថ្នាដើម្បីនឹងចម្រើនយកនិមិត្តក្នុងវាយោកសិណ គប្បីកំណត់ចុងអំពៅក្តី ចុងឫស្សីក្តី ដែលស្មើត្រឹមក្បាលឬសក់របស់មនុស្សក្តី ដែលមើលទៅឃើញខ្យល់បក់មកត្រូវរំភើយៗ ពុំនោះត្រូវអង្គុយនៅត្រង់ចន្លោះបង្អួច ឬត្រង់ប្រហោងជញ្ជាំង កាលបើខ្យល់ផាត់ចូលមកពាល់ត្រូវកាយបទេសត្រង់ណា គប្បីប្រុងស្មារតីទុកថា ខ្យល់បក់មកត្រូវត្រង់នេះ ហើយបរិកម្មកំណត់ ធ្វើទុកក្នុងចិត្តថា "**វាយោ វាយោ ខ្យល់ៗ**" ដូចនេះ ដរាបដល់ **ឧគ្គហនិមិត្ត** និង **បដិភាគនិមិត្ត** កើតឡើង ។

ក្នុង**វាយោកសិណ**នេះ **ឧគ្គហនិមិត្ត** ប្រាកដឡើងទ្រង់ញ័រ ហាក់ដូចជាសំណុំចំហាយនៃបាយាស ដែលទើបនឹងដាក់ចុះមកអំពីចង្ក្រាន ឯ**បដិភាគនិមិត្ត** ស្ងប់ឥតកម្រើកឡើយ ។

# នីលកសិណ

កាលព្រះយោគាវចរកុលបុត្រ មានប្រាថ្នាដើម្បីនឹងចម្រើនយកនិមិត្តក្នុង**នីលកសិណ**គប្បីយកផ្កាឈើដែលមានពណ៌ខៀវ មកដាក់ឱ្យពេញក្នុងប្រអប់ជាដើម ធ្វើឱ្យពេញស្មើត្រឹមកណ្តាប់មាត់ ហើយចងឱ្យស្មើដូចជាផ្ទៃស្គរ ពុំនោះនឹងយកវត្ថុអ្វីក៏បាន ឱ្យតែមានពណ៌ខៀវ ទោះបីនឹងយកទៅសៀតទុកនៅជញ្ជាំងជាដើមធ្វើជាកសិណក៏បាន កុំឱ្យតែលាយឡំដោយពណ៌ឯទៀតផ្សេងៗ ហើយបរិម្មកំណត់ធ្វើទុកក្នុងចិត្តថា "**នីលំ នីលំ ខៀវៗ**" ដូចនេះដរាបដល់**ឧគ្គហនិមិត្ត** និង**បដិភាគនិមិត្ត**កើតឡើង ។

ក្នុង**នីលកសិណឧគ្គហនិមិត្ត** តាំងឡើងប្រាកដនៅមានទម្រង់កេសរ ទងនិងចន្លោះនៃត្របកជាដើម ។ ឯ**បដិភាគនិមិត្ត**ប្រាកដហាក់ដូចជាផ្លិតជាវិការនៃកែវមណីមានពណ៌ខៀវ លេចចេញមកអំពីមណ្ឌលនៃកសិណទៅតាំងនៅពួធំអាកាស ។

## បីតកសិណ លោហិតកសិណ ឱទាតកសិណ

កាលព្រះយោគាវចរកុលបុត្រមានប្រាថ្នា ដើម្បីនឹងចម្រើនយកនិមិត្តក្នុង **បីតកសិណ លោហិតកសិណ ឱទាតកសិណ**ក្តី គប្បីយកផ្កាឈើជាដើមមកធ្វើជាមណ្ឌលកសិណដូចន័យដែលពោលមកហើយ ក្នុង**នីលកសិណ**ប្លែកគ្នាតែពណ៌គឺ **បីតកសិណ** ពណ៌លឿង **លោហិតកសិណ** ពណ៌ក្រហម **ឱទាតកសិណ**ពណ៌ស ហើយត្រូវបរិកម្ម កំណត់ធ្វើទុកក្នុងចិត្តតាមឈ្មោះរបស់កសិណនោះៗ ថា "**បីតកំ បីតកំ** លឿងៗ **លោហិតកំ លហិតកំ** ក្រហមៗ **ឱទាតំ ឱទាតំ** សៗ" ដូចនេះ ដរាបដល់**ឧគ្គហនិមិត្ត**និង**បដិភាគនិមិត្ត**កើតឡើង សូម្បីនិមិត្តទាំង ២ យ៉ាងនេះទៀតក៏ដូចគ្នានិង**នីលកសិណ** ប្លែកគ្នាខ្លះតែ **បដិភាគនិមិត្ត** គឺ **បីតកសិណ** បដិភាគនិមិត្ត តាំងឡើង ប្រាកដដូចផ្លិត ជាវិការនៃកែវមណីមានពណ៌លឿង ក្នុង**លោហិតកសិណ** ដូចផ្លិតជាវិការនៃកែវមណីមានពណ៌ក្រហម ឯក្នុងឱទាតកសិណ ដូចផ្លិតជាវិការនៃកែវមណី មានពណ៌ស ។

# អាលោកកសិណ

កាលបើព្រះយោគាវចរកុលបុត្រ មានប្រាថ្នាដើម្បីនឹងចម្រើនយកនិមិត្តក្នុង **អាលោកកសិណ** គប្បីកំណត់យកពន្លឺព្រះអាទិត្យ ឬព្រះចន្ទដែលចាំងឆ្លុះចូលទៅតាំងនៅជាមណ្ឌលព្ធដ៏ជញ្ជាំង ឬចាំងឆ្លុះតាមចន្លោះសំណុំស្លឹកឈើ មកតាំងនៅជាមណ្ឌលលើផែនដី ពុំនោះគប្បីយកក្អមមកចោះទំលុះឱ្យមានប្រហោងយ៉ាងមូលអុជប្រទីប ដាក់ចូលទៅក្នុងនោះ គ្របមាត់ឱ្យជិតនាំយកទៅដាក់បែរមុខផ្ទប់ទៅខាងជញ្ជាំង កាលបើពន្លឺប្រទីបនោះ ចាំងឆ្លុះជាមណ្ឌលមូលជាប់ទៅនឹងជញ្ជាំងហើយ គប្បីកំណត់បរិកម្ម កំណត់ធ្វើទុកក្នុងចិត្តថា **អាលោកោ អាលោកោ ពន្លឺៗ** ដូចនេះ ដរាបដល់និមិត្តទាំងពីរកើតឡើង ។

ក្នុង**អាលោកកសិណ**នេះ **ឧគ្គហនិមិត្ត**កើតឡើងប្រាកដដូចជាមណ្ឌលនៃពន្លឺដែលតាំងឡើងជាប្រក្រតីព្ធដ៏ជញ្ជាំង ឬផែនដី តាមទំនងនៃ**កសិណ** ឯ **បដិភាគនិមិត្ត** ប្រាកដដូចជាពន្លឺតាំងជាដុំយ៉ាងក្រាស់ហើយថ្លាវិសេស ហាក់ដូចជាពន្លឺដែលផ្សាយចេញអំពីសរីរៈកាយនៃព្រះដ៏មានព្រះភាគមានព្យាម ១ ជាប្រមាណ ។

# អាកាសកសិណ

កាលបើព្រះយោគាវចរកុលបុត្រ មានប្រាថ្នាដើម្បីនឹងចម្រើនយកនិមិត្តក្នុង **អាកាសកសិណ** គប្បីចោះជញ្ជាំងក៏បាន កំណាត់ស្បែកឬកំណាត់កន្ទេលជាដើមក៏បាន ធ្វើជាវង់កសិណមានប្រហោងមូលទំហំទទឹង ១ ចំអាម ៤ ធ្នាប់ ។

ហើយសម្លឹងយកអាកាសតាមចន្លោះប្រហោងនោះមកកំណត់ ធ្វើទុកក្នុងចិត្ត ជា **អាកាសោ អាកាសោ** ទទេៗ ដូចនេះដរាបដល់និមិត្តទាំងពីរកើតឡើង ។

ក្នុង**អាកាសកសិណ**នេះ **ឧគ្គហនិមិត្ត**តាំងឡើងជាវង់អាកាសនៅជាប់ដោយទម្រង់របស់**កសិណ** គឺប្រាកដដូចជាប្រហោងរបស់**កសិណ** ព្រមទាំងទីបំផុតនៃជញ្ជាំងជាដើម តែបើព្រះយោគីនឹងចម្រើនពង្រីកឱ្យធំឡើងទៀតពុំបាន ឯ**បដិភាគនិមិត្ត**តាំងឡើងប្រាកដដូចជាមណ្ឌលនៃអាកាសមិនមានទីបំផុតរបស់ជញ្ជាំងជាដើមឡើយ ហើយព្រះយោគីនឹងចម្រើនពង្រីកធំឡើងទៀតក៏ធំឡើងបាន ។

## អានាបានស្សតិ

**អានាបានស្សតិ** មានន័យថាសេចក្តីរលឹកនូវខ្យល់ដកដង្ហើមចេញ និងខ្យល់ដកដង្ហើមចូល ។

ការចម្រើននូវ **កម្មដ្ឋាន** នេះ ខ្ញុំសូមលើកឡើងនូវរបៀបក្នុងការចម្រើន ១ យ៉ាងមកពោលអធិប្បាយស្រាយបំភ្លឺទុកជាកិច្ចប្រតិបត្តិដល់សាធុជនទាំងឡាយដែលជាអ្នកហាត់រៀនដំបូង មានសេចក្តីប្រាថ្នាចម្រើននូវ**កម្មដ្ឋាន**នេះដូចតទៅ ។

### របៀបទី ១

កាលបើព្រះយោគាវចរកុលបុត្រ ដែលជា**អាទិកម្មិក**មានប្រាថ្នាដើម្បីនឹងចម្រើននូវ**អានាបានស្សតិកម្មដ្ឋាន** គប្បីធ្វើនូវបុព្វកិច្ច មានជម្រះសីលរបស់ខ្លួនឱ្យបរិសុទ្ធជាដើម ហើយរៀនយកនូវកម្មដ្ឋានឱ្យប្រកបដោយសន្ធិ ៥ យ៉ាងក្នុងសំណាក់នៃអាចារ្យ ដែលជាកល្យាណមិត្តជាមុនរួចហើយសន្សឹមចម្រើន ។

# សន្ធិ ៥ យ៉ាងនោះគឺ

១- **ឧគ្គហោ** ត្រូវរៀនយកនូវគម្ពីរដែលសម្ដែងអំពីកម្មដ្ឋាននេះឱ្យបានចេះដឹងសេចក្ដីអធិប្បាយសព្វគ្រប់ ។

២- **បរិបុច្ឆា** ត្រូវសាកសួរអាចារ្យឱ្យច្បាស់លាស់ ត្រង់សេចក្ដីណាដែលមាននៅសង្ស័យ ។

៣- **ឧបដ្ឋានំ** ត្រូវតម្កល់ទុកនូវនិមិត្តដែលចម្រើនបានកើតឡើងហើយ ។

៤- **អប្បនា** ត្រូវរៀនឱ្យដឹងថា ដែលនឹងដល់នូវ **អប្បនាឈាន** ក្នុង **កម្មដ្ឋាន** នេះនោះយ៉ាងម៉េច ។

៥- **លក្ខណំ** ត្រូវរៀនឱ្យដឹងនូវលក្ខណៈនៃ**កម្មដ្ឋាន**នេះថា ដែលនឹងអាចចម្រើនបានដល់នូវអប្បនានោះ ដោយអំណាចនៃ**គណនាវិធី អនុពន្ធនាវិធី** និង **ផុសនាវិធី** ។

លុះព្រះយោគី បានរៀនយកកម្មដ្ឋានប្រកបដោយសន្ធិទាំង ៥ ចេះស្ទាត់ហើយត្រូវចូលទៅកាន់សេនាសនៈដ៏សមគួរ អង្គុយនៅឱ្យស្រួល រឭកដល់គុណព្រះរតនត្រ័យញ៉ាំងចិត្តឱ្យជ្រះថ្លា ហើយសន្សឹមធ្វើទុកក្នុងចិត្តតាមលំអានដែលរៀនមកអំពីសំណាក់នៃអាចារ្យកុំភ្លេចបទណានីមួយឡើយ ។

វិធីធ្វើទុកក្នុងចិត្តតាមលំដាប់នៃធម៌ចម្រើនៈ ក្នុងការចម្រើន**អានាបានស្សតិកម្មដ្ឋាន**នេះ ចាប់តាំងអំពីផ្ដើមដំបូងនៃកិច្ចប្រតិបត្តិដរាបដល់បានសម្រេចមគ្គផលជា **លោកុត្តរ** ដែលលោកសម្ដែងទុកមកជាក្បួនច្បាប់សម្រាប់ធ្វើការប្រតិបត្តិដល់សាធុជនទាំងឡាយក្នុងព្រះពុទ្ធសាសនានេះ មាន ៨ យ៉ាងគឺ

១- **គណនា** កិរិយារាប់ខ្យល់ **អស្សាសបស្សាសៈ** ។

២- **អនុពន្ធនា** កិរិយាចងក្រៀកស្មារតីបញ្ជូនទៅតាមខ្យល់ **អស្សាសបស្សាសៈ** ។

៣- **ផុសនា** ទីដែលខ្យល់ **អស្សាសបស្សាសៈ** ពាល់ត្រូវ ។

៤- **ឋបនា** កិរិយាតម្កល់ចិត្តទុកក្នុងអារម្មណ៍ដោយប្រពៃបានដល់អប្បនា ។

៥- **សល្លក្ខណា** កិរិយាតម្កល់នូវ **អនិច្ចាទិលក្ខណៈ** បានដល់ **វិបស្សនាបញ្ញា** ។

៦- **វិវដ្ដនា** កិរិយាវិលត្រឡប់ចាកបវត្តធម៌និងនិមិត្តធម៌បានដល់មគ្គ ៤ ។

៧- **ចារិសុទ្ធិ** ភាវៈស្អាតដោយជុំវិញ ចាកសង្កិលេសធម៌បានដល់ផល ៤ ។

៨- **បដិបស្សនា** ប្រាជ្ញាដែលពិចារណាឃើញនូវលក្ខណៈតាមលំដាប់នៃ **វិបស្សនា** បានដល់ **បច្ចវេក្ខណញាណ** ១៩[111] ។

ក្នុងវិធី ៤ ខាងដើម លោកសម្ដែងទុកឱ្យយោគាវចរជា**អាទិកម្មិក**គោរពប្រតិបត្តិឱ្យកើតឡើង ឯវិធី ៤ ខាងចុងលោកសម្ដែងចំពោះព្រះយោគីដែលបានសម្រេចដល់**ចតុត្ថជ្ឈាន** និង **បញ្ចមជ្ឈាន** ហើយធ្វើការគោរពប្រតិបត្តិ ។

---

111 បច្ចវេក្ខណញាណ ១៩ លោករាប់យកមគ្គ ៤ ផល ៤ និព្វាន ១ និងកិលេសដែលសល់នៅហើយលះបង់បាន ១០ (សំដៅយកញាណដែល គប្បីពិចារណាដឹងក្នុងធម៌ទាំង ១៩ នោះ) ។

ដូច្នេះលំដាប់អំពីនេះទៅខ្ញុំសូមលើកយកតែវិធី ៤ យ៉ាងនេះខាងដើមប៉ុណ្ណោះ មកពោលអធិប្បាយទុកជាកិច្ចប្រតិបត្តិដល់យោគាវចរដែលជាអាទិកម្មិក (អ្នករៀនថ្មី)ដូចតទៅ:

## គណនាវិធីទី ១

**អធិប្បាយថា:** ព្រះយោគាវចរជា ***អាទិកម្មិក*** កាលដែលធ្វើទុកក្នុងចិត្តនូវ ***កម្មដ្ឋាន*** នេះ គប្បីធ្វើទុកក្នុងចិត្តដោយកិរិយារាប់ជាមុន ។

ក៏វិធីដែលរាប់នោះ មិនត្រូវរាប់ឱ្យតិចជាង ៥ ព្រោះជាឱកាសចង្អៀតចិត្ត និងញាប់ញ័រ មិនត្រូវរាប់ឱ្យច្រើនលើសជាង ១០ ព្រោះចិត្តនឹងអាស្រ័យនៅតែក្នុងវិធីរាប់ប៉ុណ្ណោះ មិនត្រូវបង្អង់ត្រង់ចន្លោះៗ ព្រោះចិត្តច្រាល់ ត្រូវរាប់ដើមដំបូងរង្វើលៗ គូបខ្យល់ចេញនិងខ្យល់ចូលរាប់ជាគូៗ ខ្យល់ណាដែលប្រាកដនៅត្រង់ក្តោងច្រមុះ ត្រូវចាប់រាប់ខ្យល់នោះ មុនគេថា មួយៗ ពីរៗ ។ល។ ប្រាំៗ.... ដប់ៗ ដរាបដល់ខ្យល់ ***អស្សាសបស្សាសៈ*** ប្រាកដឡើង ។

លុះដល់ខ្យល់ ***អស្សាសបស្សាសៈ*** ប្រព្រឹត្តទៅកាន់តែរហ័សឡើង ត្រូវរាប់ឱ្យកាន់តែញាប់ឡើងទៀត ហើយមិនត្រូវរាប់យកខ្យល់ដែលចេញមកអំពីខាងក្នុង និងចូលទៅអំពីខាងក្រៅមករាប់ឡើយ ត្រូវចាប់យកតែខ្យល់ប៉ះត្រូវដល់ទ្វារច្រមុះប៉ុណ្ណោះមករាប់ ថា "មួយ, ពីរ បី បួន ប្រាំ ។ មួយ ពីរ បី, បួន, ប្រាំ, ប្រាំមួយ ។ មួយ, ពីរ, ។ល។ ប្រាំមួយ, ប្រាំពីរ, ។ល។ ប្រាំពីរ ប្រាំបី ។ មួយ, ពីរ ។ល។ ប្រាំបី ប្រាំបួន ។ មួយ, ពីរ ។ល។ ប្រាំបួន ដប់" ។

កាលបើ **កម្មដ្ឋាន** ជាប់នៅដោយកិរិយារាប់យ៉ាងនេះហើយ ចិត្តក៏នឹងតម្កល់នៅមាំមានអារម្មណ៍តែមួយយ៉ាងឯក មិនតែប៉ុណ្ណោះ ដោយអំណាចដែលតម្កល់ទុកនូវស្មារតីចម្រើនត្រង់ឱកាសដែលខ្យល់*អស្សាសបស្សាសៈ* ប៉ះពាល់ត្រូវយ៉ាងនេះ ភាវនាក៏នឹងបានសម្រេចមិនខាន ។

## អនុពន្ធនាចធីទី ២

**អធិប្បាយថា:** កាលព្រះយោគាវចរធ្វើទុកក្នុងចិត្ត ដោយកិរិយារាប់រួចហើយ ត្រូវបញ្ឈប់ ហើយបញ្ជូនស្មារតីទៅតាមខ្យល់*អស្សាសបស្សាសៈ* ធ្វើទុកក្នុងចិត្តកុំឱ្យមានចន្លោះ តែមិនត្រូវធ្វើទុកក្នុងចិត្តដោយអំណាចខាងដើម និងពាក់កណ្តាល និងខាងចុងថា "ខ្យល់ដង្ហើមចេញ ផ្ចិតខាងដើម បេះដូងកណ្តាល ចុងច្រមុះជាខាងចុង ខ្យល់ដង្ហើមចូល ចុងច្រមុះជាខាងដើម បេះដូងជាកណ្តាល ផ្ចិតជាខាងចុង" ដូចនេះឡើយ ព្រោះជាហេតុ នាំឱ្យចិត្តរាយមាយ ។

## ផុសនាចធីទី ៣

មិនមែនជាការផ្សេងគ្នាចាក*គណនាវិធី* និង *អនុពន្ធនាវិធី* នោះឡើយគឺសំដៅយកត្រង់បញ្ជូនស្មារតីទៅតាមវិធីនៃកិរិយារាប់ ហើយស្ទង់ពិចារណាធ្វើទុកក្នុងចិត្តមិនឱ្យមានចន្លោះត្រង់ឱកាសដែលខ្យល់ *អស្សាសបស្សាសៈ* ពាល់ត្រូវហើយនោះប៉ុណ្ណោះឯង ។

# បឋនាខធីធី ៤

**អធិប្បាយថា:** កាលដែលព្រះយោគីរាប់នូវខ្យល់ **អស្សាសបស្សាស:**ត្រង់កន្លែងដែលប៉ះពាល់ត្រូវទ្វារ ហើយធ្វើទុកក្នុងចិត្តនូវខ្យល់នោះៗ ដោយរាប់ផងដោយកំណត់តែត្រង់ទីដែលខ្យល់មកប៉ះពាល់ត្រូវផង រួចហើយបង្អង់រាប់ក្នុងទីនោះតាំងបញ្ជូនស្មារតីទៅកាន់ខ្យល់**អស្សាសបស្សាស:** ទាំងនោះ បើនិមិត្តណាប្រាកដឡើងគួរល្មមញ៉ាំងអប្បនាចិត្តឱ្យកើតឡើងបាន ក៏តម្កល់ចិត្តទុកតែក្នុងនិមិត្តនោះប៉ុណ្ណោះ ។ និមិត្តកម្មដ្ឋាននេះមាន ២ **គឺឧគ្គហនិមិត្ត** ១, **បដិភាគនិមិត្ត** ១, និមិត្តទាំង ២ នេះ ដែលកើតឡើងក្នុងកម្មដ្ឋាននេះ លោកសម្តែងគួបចូលជាមួយគ្នាពុំបានញែកឱ្យឃើញដោយឡែកៗ អំពីគ្នាឡើយ ហើយនិមិត្តទាំងនោះ ដែលកើតឡើងដល់ព្រះយោគីមានសភាពផ្សេងៗ គ្នា ដូចតទៅនេះ ៖

ព្រះយោគីអង្គខ្លះ ដែលញ៉ាំងសុខសម្ផស្សឱ្យកើតឡើងបាន និមិត្តតាំងឡើងប្រាកដដូចប៉ុយគក៏មាន ដូចប៉ុយកប្បាសក៏មាន ដូចទខ្យល់ក៏មាន[112] ដូចដួងផ្កាយក៏មាន ដូចដួងកែវមណីក៏មាន ដូចដួងកែវមុក្តាក៏មាន បើព្រះយោគីអង្គខ្លះដែលញ៉ាំងសម្ផស្ស ឱ្យកើតឡើងរឹង និមិត្តតាំងឡើងប្រាកដដូចគ្រាប់កប្បាសក៏មាន ដូចជក់ធ្វើដោយឈើខ្លឹមក៏មាន ដូចសរសៃសង្វារកែវក៏មាន ដូចចង្កោមផ្កាក៏មាន ដូចសំណុំផ្សែងក៏មាន ដូចសរសៃពីងពាងក៏មាន ដូចផ្ទៃ

---

[112] នេះជាពាក្យកេចិអាចារ្យ

ពលាហកក៏មាន ដូចផ្កាឈូកក៏មាន ដូចកង់នៃរថក៏មាន ដូចមណ្ឌលនៃព្រះចន្ទក៏មាន ដូចមណ្ឌលនៃព្រះអាទិត្យក៏មាន[113] ។

ចាប់ដើមអំពីនិមិត្តកើតឡើងយ៉ាងនោះ នីវរណធម៌និងកិលេសរបស់ព្រះយោគីអង្គនោះក៏ទ្រោមស្ងប់ទៅ សតិក៏ប្រុងឡើង ហើយចិត្តសោតក៏តម្កល់នៅមាំដោយ **ឧបចារសមាធិ** ។

បើព្រះយោគីរក្សាទុកនូវនិមិត្តនោះ ឱ្យល្អដោយ**រក្ខណាវិធី** [114] ធ្វើទុកក្នុងចិត្តឱ្យរឿយៗ ដោយ **អប្បនាកោសល្លវិធី** [115] ហើយប្រកបព្យាយាមឱ្យស្មើ កុំតែធ្វើទុកក្នុងចិត្តដោយពណ៌ និងពិចារណាដោយលក្ខណៈ ក៏នឹងអាចញ៉ាំង **អប្បនាឈាន**ឱ្យកើតឡើង បានជា**ចតុក្កន័យ** និង **បញ្ចកន័យ** ដូចក្នុងកសិណដែរ តែក្នុងសៀវភៅច្បាប់នេះពោលត្រឹម**ឧបចារជ្ឈាន**ប៉ុណ្ណោះ **ឯអប្បនាឈាន** នឹងមានពោលក្នុងសៀវភៅច្បាប់វិបស្សនា ថ្នាក់មធ្យម ។

## របៀបទី ២

ក្នុងរបៀបទី ២ នេះ ការចម្រើននូវព្រះ **អានាបានស្សតិកម្មដ្ឋាន** ខ្ញុំបានដកចេញអំពី**មហាសតិដ្ឋាន**សូត្រខ្លះ **អានាបានស្សតិ**សូត្រខ្លះជាដើម យកមកពោលរៀបរៀងទុកក្នុងច្បាប់នេះ ។ ដើម្បីតម្រូវដល់សាធុជនដែលមានសេចក្តី

---

113 នេះជាពាក្យវិន័ច្ឆ័យក្នុងអដ្ឋកថា ។

114 ក្នុងវិបស្សនាថ្នាក់មធ្យម ។

115 នឹងមានក្នុងវិបស្សនាថ្នាក់មធ្យម ។

ត្រូវការចម្រើននូវព្រះ**កម្មដ្ឋាន**នេះ ក្នុង**អានាបានស្សតិ**សូត្រ លោកបានពោលនូវវិធីចម្រើនដោយសេចក្តីពិស្តាររហូតដល់អាការ ៣២ [116] ឯណោះ ក្នុងអាការ ៣២ នេះ អាការ ៨ ខាងដើមលោកពោលចំពោះសម្រាប់យោគាវចរដែលជា**អាទិកម្មិក** ឯអាការដ៏សេសពីនេះ លោកពោលសំដៅចំពោះបុគ្គលដែលបានឈានសម្រេចហើយ តែក្នុងសៀវភៅច្បាប់នេះ ខ្ញុំសរសេរពោលអធិប្បាយចំពោះយកតែកងខ្យល់ ៤ ត្រកូល ដែលជាអាការ ៨ នោះប៉ុណ្ណោះ ទុកសម្រាប់ជាកិច្ចប្រតិបត្តិដល់សាធុជនដែលទើបតែទទួលរៀនថ្មីៗ មិនទាន់មានការអប់រំចម្រើននូវ **កម្មដ្ឋាន** ណាមួយក្នុងព្រះពុទ្ធសាសនានេះ ។

## ខ្យល់ ៤ ត្រកូល

១- ទីឃំ វា អស្សសន្តោ ។ល។ បស្សសាមីតិ បជានាតិ [117] ។

២- រស្សំ វា អស្សសន្តោ ។ល។ បស្សសាមីតិ បជានាតិ [118] ។

៣- សព្វកាយប្បដិសំវេទី ។ល។ បស្សសិស្សាមីតិ សិក្ខតិ [119] ។

៤- បស្សម្ភយំ កាយសង្ខារំ ។ល។ បស្សសិស្សាមីតិ សិក្ខតិ [120] ។

សេចក្តីពន្យល់បំភ្លឺ អំពីកិច្ចប្រតិបត្តិក្នុងការចម្រើននូវ**អានាបានស្សតិកម្មដ្ឋាន** នេះក៏បានពោលរួចហើយដែរ [121] សាធុជនអ្នកមានសេចក្តីរាប់អានក្នុងការចម្រើននូវ**កម្មដ្ឋាន**នេះ សូមរកមើលផងចុះ ។

---

116 មើលក្នុងអានាបានស្សតិសូត្រក៏មាន ក្នុងគម្ពីរវិន័យបិដកភាគ ១ ឈ្មោះមហាវិភង្គក៏មាន ។ ក្នុងគិរិមានន្ទសូត្រក៏មាន ។

117 118 119 120 121 បានពោលក្នុងបញ្ហាសួរ ឆ្លើយត្រង់ទីបំផុតនៃអនុស្សតិ ៦ ។

បន្ទាប់អំពីនេះ សូមលើកយកបញ្ហាខ្លះៗ មកសួរ ឆ្លើយក្នុងរបៀប ទី ២ នេះ ដើម្បីជួយបំភ្លឺដល់សាធុជនទាំងឡាយ ដែលមានប្រាជ្ញាតិចផង ដើម្បីជួយផ្ដល់នូវសតិប្រាជ្ញានៃសាធុជនអ្នកប្រតិបត្តិនូវកម្មដ្ឋាននេះផង ដូចមានបញ្ហាដូចតទៅ:

**បុច្ឆា** ការចម្រើននូវ ***អាណាបានស្សតិ*** ដោយគ្មានសីលជាបាទ តើបានសម្រេចប្រយោជន៍ដែរឬទេ? ព្រោះហេតុអ្វី?

**វិសជ្ជនា** មិនបានសម្រេចប្រយោជន៍ពោលគឺគុណវិសេសអ្វីឡើយ ព្រោះវិប្បដិសារី (សេចក្ដីស្ដាយក្រោយ) ចេះតែកើតឡើងរឿយៗ គ្របសង្កត់ចិត្ត ។

ដូច្នេះ សាធុជនទាំងឡាយអ្នកចម្រើននូវ ***អាណាបានស្សតិកម្មដ្ឋាន*** គប្បីជាអ្នកមានសីលបរិសុទ្ធជាខាងដើម ។

**បុច្ឆា** ចុះក្នុងការចម្រើននូវ ***អាណាបានស្សតិកម្មដ្ឋាន*** តើមានធម៌ប៉ុន្មានជាគោលសំខាន់? ចូរអធិប្បាយ ។

**វិសជ្ជនា** មានធម៌ ៣ យ៉ាងជាគោលសំខាន់គឺ ***សតិ*** ១, ***ញាណ*** ១, ***អារម្មណ៍*** ១។

**អធិប្បាយថា:** ***សតិ*** ប្រែថាសេចក្ដីរលឹកបាន គឺរលឹកនូវខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូល ។

**ញាណ** ប្រែថាសេចក្ដីដឹងគឺដឹងនូវខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូល

**អារម្មណ៍** មានន័យថា ធម្មជាតិដែល**សតិ** និង**ញាណ**ត្រូវធ្វើការរលឹកដឹង ឬធម្មជាតិសម្រាប់**សតិ** និង**ញាណ**រលឹកដឹង ឬធម្មជាតិជាទីតោងទាញនៃ**សតិ** និង**ញាណ** ក្នុងទីនេះសំដៅយកខ្យល់**អស្សាសបស្សាសៈ**[122] ហ្នឹងឯងដូច្នេះព្រះយោគីក្នុងការចម្រើននូវ**អាណាបានស្សតិ** ត្រូវមាន**សតិ** និង**ញាណ**ឱ្យតាំងនៅស៊ប់ល្អក្នុងខ្យល់**អស្សាសបស្សាសៈ** គ្រប់វារៈនៃខ្យល់ប្រព្រឹត្តឡើងចុះទើបបានសម្រេចនូវគុណវិសេសដែលជាលទ្ធផលកើតអំពីការចម្រើនមែនពិត ។

**មុច្ឆា** ចុះយោគី ដែលចម្រើននូវ**អាណាបានស្សតិ**បែបទី ២ នេះ តើនឹងត្រូវបានកំណត់ដឹងនូវខ្យល់បានប៉ុន្មានពួក ? អ្វីខ្លះ?

**វិស្សជ្ជនា** បានកំណត់ដឹងនូវខ្យល់បាន ៤ ពួកគឺ

ពួកខ្យល់ **អស្សាសបស្សាសៈ** វែងប្រព្រឹត្តឡើងចុះ ១, ពួកខ្យល់ **អស្សាសបស្សាសៈ** ខ្លីប្រព្រឹត្តឡើងចុះ ១, ពួកខ្យល់ទាំងពួងប្រព្រឹត្តឡើងចុះផ្សាយទៅពេញករជកាយ ១, ពួកខ្យល់ស្ងប់ល្អិតប្រព្រឹត្តឡើងចុះ ១ ។

**មុច្ឆា** ពួកខ្យល់ទាំង ៤ ពួកនោះ តើកើតឡើងយ៉ាងដូចម្ដេច? ចូរអធិប្បាយមកមើល !

---

[122] ខ្យល់ដកដង្ហើមចេញ និងខ្យល់ដកដង្ហើមចូល ។

**វិសជ្ជនា:** កាលដែលព្រះយោគី ទើបចាប់ផ្ដើមចម្រើននូវ***អានាបានស្សតិ***ជាដំបូងខាងដើម ក្រុមខ្យល់***អស្សាសបស្សាសៈ***ទាំងនោះ មិនទាន់កើតឡើងទេ លុះដល់ព្រះយោគីមាន***សតិ***និង***ញាណ*** ធ្វើការចម្រើននូវ***អានាបានស្សតិ***យូរទៅ កងខ្យល់ទី ១ ក៏កើតឡើង កាលបើកងខ្យល់ទី ១ កើតឡើងហើយ បន្ទាប់មកកង ខ្យល់ទី ២ ក៏កើតឡើងទៀត ព្រោះអាស្រ័យព្រះយោគីមាន***សតិ***និង***ញាណ***ធ្វើការចម្រើនដោយសេចក្ដីព្យាយាមមិនដាក់ធុរៈ ក្នុងកងខ្យល់ទី ១ នោះ កាលបើកងខ្យល់ទី ២ កើតឡើងហើយ ព្រះយោគីក៏ចេះតែប្រឹងព្យាយាមរលឹកដឹងនូវកងខ្យលទី ២ នោះរឿយៗ ទៅ កងខ្យល់ទី ៣ ក៏កើតឡើងផ្សព្វផ្សាយទៅពេញកាយទាំងអស់តាមលំដាប់, កាលបើកងខ្យល់ទី ៣ កើតឡើងហើយយ៉ាងនេះ ព្រះយោគីក៏កំណត់ដឹងនូវខាងដើម កណ្ដាល ខាងចុងនៃខ្យល់ ***អស្សាសបស្សាសៈ***នោះ ហើយដកដង្ហើមចេញចូល មិនយូរប៉ុន្មានកងខ្យល់ទាំងពួងនោះក៏ស្ងប់រម្ងាប់អស់ ខ្យល់***អស្សាសបស្សាសៈ*** ប្រព្រឹត្តទៅក្នុងកាយក៏ល្អិតម៉ត់រហូតដល់មានការប្រព្រឹត្តិឡើងចុះមិនមាន ក្រុមខ្យល់ល្អិតស្ងប់ដែលកើតឡើងក្រោយនេះហៅថាក្រុមខ្យល់ទី ៤ ។

**បុច្ឆា** ចុះកាលបើកងខ្យល់ទី ៤ កើតឡើងហើយ ព្រះយោគីនៅតែខំប្រឹងចម្រើន***អានាបានស្សតិ***នោះទៀត តើបានជួបនូវក្រុមខ្យល់អ្វីទៀត ?

**វិសជ្ជនា** ពិតជាជួប។ គឺជួបក្រុមខ្យល់រលត់-កើត-រលត់ ។

**មុច្ឆា** ឆ្លើយប៉ុណ្ណេះ មិនទាន់យល់សោះ សូមអធិប្បាយផងមកមើល?

**វិសជ្ជនា** បើមិនទាន់យល់សូមអធិប្បាយដូចតទៅៈ

កាលបើព្រះយោគីឧស្សាហ៍មានសេចក្ដីព្យាយាមប្រពៃ កាលបើកងខ្យល់ស្ដើងនោះកើតឡើងហើយ ព្រះយោគីក៏ខំប្រឹងតម្រង់**សតិ** និង**ញាណ** ធ្វើការរលឹកនិងដឹងនូវក្រុមខ្យល់ល្អិតនោះ ហើយចម្រើន គឺធ្វើការដកដង្ហើមចេញចូលរឿយៗ ទៅ ក្រុមខ្យល់ល្អិតនោះ ក៏រឹតតែម៉ត់ក្រៃលែងរហូតដល់ស្ងប់អស់ទៅបែកធ្លាយទៅរលត់ទៅ បន្ទាប់មកក៏កើតឡើងវិញតាមហេតុបច្ច័យមែនពិត កាលបើក្រុមខ្យល់ល្អិតទាំងនោះកើតឡើងវិញហើយ ព្រះយោគីក៏តម្កល់នូវ **សតិ** និង **ញាណ** ធ្វើការរលឹកនិងដឹង ហើយចម្រើននូវក្រុមខ្យល់ទាំងនោះក៏ចាប់ផ្ដើមល្អិតៗ ទៅរហូតដល់រលត់អស់ម្ដងទៀត តែយ៉ាងនេះឯងរឿយៗទៅ ។

**មុច្ឆាៈ** ចុះគុណវិសេសអ្វីខ្លះដែលកើតក្នុងចិត្ត ក្នុងពេលដែលព្រះយោគីចម្រើននូវព្រះ*អានាបាណស្សតិ*រហូតដល់ខ្យល់ស្ងប់នោះ?ចូរអធិប្បាយមកមើល?

**វិសជ្ជនាៈ** ក្នុងកាលដែលព្រះយោគីចម្រើននូវ*អានាបានស្សតិ*រហូតដល់បានជួបប្រទះនូវក្រុមខ្យល់ស្ងប់នោះគុណវិសេសដែលកើតមានក្នុងចិត្តដូចតទៅ ៖

**បាមោជ្ជៈ ១, បីតិ ១, បស្សទ្ធិ ១, សុខ ១, សមាធិ ១,**

**អធិប្បាយថា:** កាលបើដែលព្រះយោគី ធ្វើការរលឹក និង ដឹង ហើយចម្រើននូវ**អាណាបានស្សតិ**រឿយៗទៅ **បាមោជ្ជៈ** គឺសេចក្ដីរីករាយទន់ក៏កើតឡើងធ្វើឱ្យក្នុងខ្លួនស្រឡះស្រួល សប្បាយចិត្ត កាលបើ**បាមោជ្ជៈ**ចេះតែចម្រើនឡើងៗ ពេញលេញល្អ បន្ទាប់មក **បីតិ** គឺសេចក្ដីឆ្អែតកាយនិងចិត្តក៏កើតឡើងមានសភាពធ្វើឱ្យកាយ ព្រឺរោម ស្បែក ព្រឺខ្វាកៗ ដូចផ្លេកបន្ទោរ ណែនកាយធ្វើកាយឱ្យស្រាល ហាក់ដូចជា អណ្ដែតឡើងឰដ៏អាកាស និងផ្សព្វផ្សាយភាពត្រជាក់ផ្សាយទៅពេញករជកាយទាំងមូល កាលណាបីតិចម្រើនឡើងពេញលេញបន្ទាប់មក **បស្សទ្ធិ** គឺសេចក្ដីស្ងប់កាយ[123] និងស្ងប់ចិត្ត [124] ក៏កើតឡើងកាលណាបស្សទ្ធិកើតឡើងចម្រើនពេញលេញហើយ បន្ទាប់មក **សុខៈ** គឺសេចក្ដីស្រួលកាលនិងសេចក្ដីស្រួលចិត្តក៏កើតឡើង កាលបើសុខ ចម្រើនឡើងហើយបន្ទាប់មក **សមាធិ** គឺកិរិយាតម្កល់ចិត្តនឹងល្អក៏កើតឡើងដោយពិត**សមាធិ**នឹងដែលកើតឡើងមួយអន្លើដោយសេចក្ដីស្ងប់ ។

**បុច្ឆា** ក្នុងការចម្រើន **អាណាបានស្សតិ** នោះ តើព្រះយោគីអាចជួបប្រទះនូវវេទនាចំនួនប៉ុន្មាន? អ្វីខ្លះ? ចូរអធិប្បាយមកមើល?

---

[123] ស្ងប់កាយ គឺស្ងប់ខន្ធ ៣ គឺវេទនាខន្ធ ១, សញ្ញាខន្ធ ១, សង្ខារខន្ធ ១,

[124] ស្ងប់ចិត្ត គឺចិត្តមិនរវើរវាយរសាប់រសល់ ក្ដៅប្រហល់ក្រហាយ ។

**ទស្សវជ្ជនាៈ** ក្នុងការចម្រើន **អានាបានស្សតិ** នេះ ព្រះយោគីអាចបានជួបប្រទះនូវ **វេទនា** ៥ ដែលកើតឡើង គឺ **ទុក្ខវេទនា** ១, **ទោមនស្សវេទនា** ១, **សុខវេទនា** ១, **សោមនស្សវេទនា** ១, **ឧបេក្ខាវេទនា** ១ ។

**អធិប្បាយថាៈ** **វេទនា** មានន័យថា ការសោយនូវអារម្មណ៍ រងនូវអារម្មណ៍ ទំពាស៊ីនូវអារម្មណ៍ ។

**ទុក្ខវេទនា** ការសោយអារម្មណ៍ជាទុក្ខលំបាក **វេទនា**នេះតែងកើតឡើងដល់យោគី ក្នុងសម័យដែលជួបប្រទះការលំបាក មានចុកចាប់ដៃជើង ឬកាយជាដើម ។

**ទោមនស្សវេទនា** ការសោយអារម្មណ៍ចង្អៀតចង្អល់ចិត្ត តូចចិត្តតែងកើតក្នុងសម័យដែល**ទុក្ខវេទនា**កើតឡើង **វេទនា**ទាំងពីរនេះមានសេចក្ដីផ្សេងគ្នាដូច្នេះ **ទុក្ខវេទនា** សោយអារម្មណ៍តាមផ្លូវកាយ ឯ**ទោមនស្សវេទនា** សោយអារម្មណ៍តាមផ្លូវចិត្ត។

**សុខវេទនា** ការសោយអារម្មណ៍ជាសុខ តែងកើតឡងក្នុងសម័យដែលភាពត្រជាក់ផ្សព្វផ្សាយនៅក្នុងកាយ ។

**សោមនស្សវេទនា** ការសោយអារម្មណ៍រីករាយ តែងកើតឡើងក្នុងសម័យដែល**សុខវេទនា**កើតឡើង កាលណាសុខស្រួលកាយហើយ ចិត្តក៏សប្បាយដែរវេទនាទាំង ២ នេះ មានសេចក្ដីផ្សេងគ្នាដូច្នេះ **សុខវេទនា** សោយអារម្មណ៍ តាមផ្លូវកាយ ឯ **សោមនស្សវេទនា** សោយអារម្មណ៍តាមផ្លូវចិត្ត ។

ឧបេក្ខវេទនា ការសោយអារម្មណ៍ជាកណ្តាលៗ ស្មើៗ វេទនានេះ តែងកើតឡើងក្នុងសម័យដែលយោគីបានលះបង់ នូវសុខសោមនស្សវេទនាក្នុងពេលចម្រើន នូវអានាបានស្សតិបានមែនពិត ។ ឧបេក្ខាវេទនាជាធម្មជាតិមួយដែលកើតឡើងក្នុងកាលខាងចុងនៃវេទនាទាំង ៤ មានទុក្ខវេទនាជាដើមដោយពិតកាលណាឧបេក្ខាវេទនាកើតឡើងហើយវេទនាទាំង ៤ ក៏រលត់បាត់ទៅ ហើយកើតឡើងមួយអន្លើដោយកុសលចិត្ត ដែលលោកពោលថាគុណវិសេសថ្នាក់សមាធិ ដែលកើតបន្ទាប់អំពីសុខ ។

កាលបើឧបេក្ខាវេទនាកើតឡើង វិសុទ្ធិ ២ យ៉ាងគឺ សីលវិសុទ្ធ ១, ចិត្តវិសុទ្ធ ១, ឈ្មោះថា បានសម្រេចដល់យោគីដោយពិតប្រាកដ ។

សីលវិសុទ្ធិ គឺសីលបរិសុទ្ធ ចិត្តវិសុទ្ធិ គឺចិត្តបរិសុទ្ធ សីលវិសុទ្ធិ ព្រោះចិត្តមិនបានប្រព្រឹត្តកន្លងនូវទុច្ចរិត ១០ មានសម្លាប់សត្វជាដើម ។ ចិត្តវិសុទ្ធិ ព្រោះចិត្ត ប្រាសចាកនីវរណធម៌ ៤ មានកាមឆន្ទៈជាដើម។ ហេតុដូច្នេះសាធុជនទាំងឡាយកាលបើឃើញគុណប្រយោជន៍ដែលកើតឡើងយ៉ាងនេះហើយ កាលបើចម្រើនអានាបានស្សតិបានជួបប្រទះនូវវេទនាទាំង ៤ ខាងដើម មានសុខវេទនាជាដើម តាមលំដាប់ហើយ គប្បីកុំជាប់ចិត្ត ត្រូវលះបង់នូវការជាប់ជំពាក់ក្នុងវេទនាទាំងនោះចេញ បន្ទាប់មកមុខជានឹងបានជួបនូវឧបេក្ខាវេទនាដោយពិត កាលបើមានចិត្តស្ថិតនៅស៊ប់ក្នុង ឧបេក្ខាវេទនាហើយ ក៏គប្បីហាត់បង្វឹកចម្រើន នូវឧបេក្ខាវេទនានោះឱ្យបានស្ទាត់ជំនាញ ឱ្យបានសម្រេចក្នុងខណៈចិត្ត[125] ទី ៤ ឬទី ៥[126] ព្រោះថាឧបេក្ខាវេទនានេះហើយ ដែលជាបាទរបស់វិបស្សនាហ្នឹងឯង ។

---

125 126 មានពោលក្នុងសៀវភៅនេះរួចហើយ .

# អានាបានស្សតិ ចប់

---------------------------------------

កម្មដ្ឋានទាំងឡាយ ៣៥ ដែលបានពោលរៀបរៀងហើយតាមអានុភាពនៃ**កម្មដ្ឋាន** ដែលឱ្យសម្រេចឈានខ្ពស់និងទាបជាងគ្នាតាមលំដាប់ហើយ**កម្មដ្ឋាន**ទាំងនោះបានពោលអធិប្បាយ ត្រឹមតែវិធីចម្រើនឱ្យសម្រេចត្រឹម**ឧបចារជ្ឈាន** ប៉ុណ្ណោះដើម្បីសង្គ្រោះដល់សាធុជនទាំងឡាយ ដែលហាត់រៀនអប់រំនូវចិត្តជាដំបូងក្នុងពុទ្ធសាសនានេះបានដល់សព្វគ្រប់ហើយ ។

លំដាប់អំពីនេះ នឹងពោលពន្យល់អំពីពាក្យថា **ឧបចារជ្ឈាន** ដូចតទៅ:

ពាក្យថា **ឈាន** មានន័យថា **ធម្មជាតិ** ដែលសម្លឹងនូវអារម្មណ៍របស់ខ្លួនមានពុទ្ធគុណជាដើម ឬដុតកម្លោចនូវបច្ចនីកធម៌ទាំងឡាយ មាននីវរណធម៌ ៥ ជាដើម មិនឱ្យកើតឡើងបាន ។

**ឧបចារជ្ឈាន** មានន័យថា ឈានដែលប្រព្រឹត្តទៅក្នុងទីជិតនៃ**អប្បនាឈាន** គឺជាបុព្វភាគនៃ **អប្បនា** ។

**អធិប្បាយថា:** កាលដែលព្រះយោគី សម្លឹងយកនូវ**ពុទ្ធគុណ**ជាដើមមកធ្វើជាអារម្មណ៍ ហើយពិចារណាធ្វើទុកក្នុងចិត្តដរាបដល់នីវរណធម៌និងកិលេសទាំងពួងទ្រោមស្ងប់ទៅជាលំដាប់ អង្គរបស់ឈានមាន **វិតក្កៈ** ជាដើម ក៏កើតឡើងតែមិនទាន់មានកម្លាំងខ្លាំងគ្រាន់តែប្រព្រឹត្តទៅ ក្នុងទីជិតនៃអប្បនាបាន ។ យ៉ាងនេះហៅថា "**ឧបចារជ្ឈាន**" ។

# ដំណើរដែលឧបចារជ្ឈានកើតឡើង

សេចក្តីថាៈ ក្នុងកម្មដ្ឋានឯទៀតលើកទុកមិនបានពោល នឹងពោលតែឈានដែលកើតឡើងដោយអំណាចនៃ**កសិណ** ១០ ទុកជាតួយ៉ាង តែសូម្បីតែក្នុងកម្មដ្ឋានឯទៀតៗ ក៏មានទំនងប្រហែលគ្នាល្មមឱ្យពិចារណាទៅយល់បាន ក៏ក្នុង**កសិណ**ទាំង ១០ នេះកាលបើព្រះយោគីសម្លឹងយក**កសិណ**ណាមួយមកជាអារម្មណ៍ ហើយបរិកម្មធ្វើទុកក្នុងចិត្តតាមឈ្មោះរបស់**កសិណ**នោះៗ បើកភ្នែកសម្លឹងមើលវង់កសិណម្តង ធ្មេចភ្នែកនឹករំពឹងម្តង ចម្លងអារម្មណ៍នោះមកចូលក្នុងមនោទ្វារឱ្យបានស្ទាត់ដរាបដល់ពេលដែលបើកភ្នែកឡើង ឃើញវង់**កសិណ**នោះយ៉ាងណា ដល់ធ្មេចភ្នែកទៅវិញក៏ឃើញដូចគ្នាដែលហៅថា **ឧគ្គហនិមិត្ត** កើតហើយហៅថា **តរុណសមាធិ** គឺសមាធិយ៉ាងខ្ចីក៏កើតឡើងផង លុះព្រះយោគីក្រោកចាកអាសនៈនោះទៅរកទីឱកាសឯទៀត អង្គុយទៅយ៉ាងស្រួលប្រមូលស្រាវយក**ឧគ្គហនិមិត្ត**នោះមកត្រិះរិះ បរិកម្មហាត់បង្វឹកតាមឈ្មោះរបស់កសិណនោះៗតទៅទៀត ពេលនោះនីវរណធម៌និងកិលេសទាំងពួង ក៏ទ្រោមស្ងប់ទៅជាលំដាប់ទើប**បដិភាគនិមិត្ត**កើតឡើង អង្គឈានទាំង ៥ ក៏កើតឡើងផង តែមានកម្លាំងខ្សោយដូចពោលមកហើយ ចិត្តក៏តម្កល់នៅមាំក្នុងឧបចារភូមិតែមិនទាន់សង្កត់នូវ**កាមាវចរគោត្រ** ស្ទុះចូលទៅកាន់**មហគ្គតគោត្រ**បាននៅឡើយគ្រាន់តែមានកម្លាំងវិសេសជាងកាមាវចរចិត្តប្រក្រតីប៉ុណ្ណោះ ត្រង់នេះព្រះយោគីក៏ចូលដល់ថ្នាក់ **ឧបចារជ្ឈាន** ដោយពិត ។

# នីវរណធម៌

**នីវរណធម៌:** មានន័យថា **ធម៌** ជាគ្រឿងរារាំងមិនឱ្យកើតប្រាជ្ញាក្នុងការចម្រើននូវ **វិបស្សនា** មាន ៥ យ៉ាងគឺ

១- **កាមច្ឆន្ទ** សេចក្តីផ្គងចិត្តចុះក្នុងកិលេសកាម និងវត្ថុកាម ។

២- **ព្យាបាទ** គំនុំអាឃាត ចំពោះអារម្មណ៍មិនជាទីប្រាថ្នា ។

៣- **ថីនមិទ្ធ** សេចក្តីធុញទ្រាន់និងងងុយជ្រប់ ឬថាសេចក្តីច្រអូសកាយច្រអូសចិត្ត ។

៤- **ឧទ្ធច្ចកុក្កុច្ច** មានសេចក្តីរាយមាយចិត្ត និងរំខានចិត្ត ឬថាសេចក្តីអណ្តែតអណ្តូងចិត្ត និងក្តៅក្រហាយចិត្ត ។

៥- **វិចិកិច្ឆា** សេចក្តីសង្ស័យមិនអស់មិនហើយក្នុងចិត្ត ។

# អង្គរបស់ឧបចារជ្ឈាន

## មានអង្គ៥គឺ

១- **វិតក្ក** សេចក្តីត្រិះរិះ លើកចិត្តដាក់ទៅក្នុងអារម្មណ៍របស់ **កម្មដ្ឋាន** ។

២- **វិចារ** សេចក្តីពិចារណាដុសខាត់នូវអារម្មណ៍របស់ **កម្មដ្ឋាន** ។

៣- **បីតិ** អំណរមានកម្លាំងក្លា អាចញ៉ាំងកាយនិងចិត្តឱ្យពេញសព្វទាំងអស់បានដល់ **ផរណាបីតិ** ។

៤- **សុខ** សេចក្តីស្រួលកាយ ស្រួលចិត្ត អាចកម្ចាត់បង់នូវអាពាធក្នុងកាយនិងចិត្តបាន ។

៤- **ចិត្តេកគ្គតា** ភាពរបស់ចិត្ត ដែលមានអារម្មណ៍តែមួយឯកឯង

កាលយោគាវចរ បានចម្រើនកម្មដ្ឋានមាន **ពុទ្ធានុស្សតិកម្មដ្ឋាន** ជាដើម បានគុណវិសេសដល់ថ្នាក់**ឧបចារសមាធិ**ហើយ គប្បីហាត់បង្វឹកចិត្តនោះឱ្យបានស្ទាត់ជំនាញល្អដោយ "**វសី**" ទាំង ៥គឺ:

១- **អាវជ្ជនវសី** ថ្មឹកក្នុងវិធីនឹករកអង្គរបស់ឈាន ។

២- **សមាបជ្ជនវសី** ថ្មឹកក្នុងវិធីចូលឈាន ។

៣- **អធិដ្ឋានវសី** ថ្មឹកក្នុងវិធីទប់ទុកនូវឈាន ។

៤- **វុដ្ឋានវសី** ថ្មឹកក្នុងវិធីចេញចាកឈាន ។

៥- **បច្ចវេក្ខណវសី** ថ្មឹកក្នុងវធីពិចារណានូវអង្គឈាន ។

## សេចក្តីពន្យល់ថា

ព្រះយោគីត្រូវការនឹករកនូវឈាន ដែលខ្លួនបានហើយនោះ ទោះបីនឹករកក្នុងប្រទេសណាក្តី ក្នុងពេលណា ត្រង់អង្គណាក្តី នឹកដល់ត្រឹមណាក្តី ក៏នឹកបានភ្លាមៗមួយរំពេច ពុំមានយឺតយូរ យ៉ាងនេះហៅថា "**អាវជ្ជនវសី**" ។

បើយោគីត្រូវការចូលឈាន ដែលបានហើយនោះ ទោះបីចូលក្នុងប្រទេសណាក្តី ក្នុងពេលណាក្តី ត្រង់អង្គណាក្តី ចូលមកដល់ត្រឹមណាក្តី ក៏ចូលបានភ្លាមៗមួយរំពេច ពុំមានយឺតយូរ យ៉ាងនេះហៅថា "**សមាបជ្ជនវសី**" ។

កាលព្រះយោគីចូលដល់ទៅក្នុងឈានហើយ បើត្រូវការចង់ទប់ទុកនូវឈាននោះមិនឱ្យប្រព្រឹត្តទៅដោយរហ័ស ក៏អាចទប់ទុកឱ្យតាំងនៅអស់កាលចំនួនផ្ទាត់ម្រាមដៃម្តង ឬ១០ ដង បានយ៉ាងនេះហៅថា "**អធិដ្ឋានវសី**" ។

ដល់ពេលយោគី ចេញចាកឈាននោះមកវិញ ក៏អាចចេញបានយ៉ាងរហ័សអស់កាលត្រឹមផ្ទាត់ម្រាមដៃម្តង ឬ១០ដងប៉ុណ្ណោះ ក៏អាចចេញមកបានយ៉ាងនេះហៅថា **វុដ្ឋានវសី** ។

ជវនដែលប្រព្រឹត្តទៅខាងមុខ បន្ទាប់អំពី **អាវជ្ជនចិត្ត** ដែលនឹករកនូវអង្គរបស់ឈាន មាន**វិតក្កៈ**ជាដើម តាមលំដាប់គ្នា ពុំមានយឺតយូរ ដោយភាពដែលថ្មីកក្នុងវិធីនឹកហៅថា "**បច្ចវេក្ខណវសី៍**" នេះ ប្រព្រឹត្តទៅបន្ទាប់គ្នានឹង **អាវជ្ជនចិត្ត** ។

**ឧបចារសមាធិ** ឯណាដែលព្រះយោគីបានហាត់បង្វឹកឱ្យថ្មីកល្អដោយ**វសី**ទាំង ៥ ហើយ **ឧបចារសមាធិ**នេះនៅពេលដែលព្រះយោគីនឹករក ក៏ប្រព្រឹត្តបានមួយរំពេចយ៉ាងឆាប់រហ័ស មិនបានយឺតយូរឡើយដោយពិត ។

ព្រះយោគី គប្បីហាត់**ឧបចារជ្ឈាន**ដែលខ្លួនបានហើយ ឱ្យថ្មីកល្អ ឱ្យបានគ្រប់ឥរិយាបថទាំង ៤ គ្រប់ទីកន្លែងទាំងអស់ ហាត់រហូតដល់គ្រាន់តែនឹករក **ឧបចារជ្ឈាន** មានអង្គ ៥ នោះ ក៏កើតឡើងគ្រប់ភ្លាមមួយរំពេចតែម្តង មិនបានយឺតយូរឡើយ ។

## ការចាត់ឈានជាថ្នាក់កុសល

ព្រះយោគាវចរជា**អាទិកម្មិក**ទើបតែរៀនដំបូង ដែលបានចម្រើន**កម្មដ្ឋាន**ទាំងឡាយមាន**ពុទ្ធានុស្សតិ**ជាដើម ហើយបានសម្រេចនូវគុណវិសេសត្រឹមថ្នាក់**ឧបចារជ្ឈាន**នោះ បើនឹងចាត់ជាកុសលហៅថា **កាមាវចរកុសល** ឬ **មហាកុសល** ដ៏វិសេស ។

**អធិប្បាយថា:** **កាមាវចរកុសល**ឬមហាកុសល ដែលកើតឡើង ព្រោះអាស្រ័យបុគ្គលប្រារព្ធបំពេញនូវ **បុញ្ញកិរិយាវត្ថុ** ១០ យ៉ាងគឺ:

១- **ទាន** ការឱ្យទេយ្យវត្ថុមានចីវរជាដើម ។

២- **សីល** មានការរក្សាសីល ៥, សីល ៨, ឬសីល ១០ ជាដើម ។

៣- **ភាវនា** ការចម្រើនអប់រំចិត្តដោយ**កម្មដ្ឋាន** ។

៤- **អបចាយន** គឺការប្រព្រឹត្តិឱនលំទោន ។

៥- **វេយ្យាវច្ច** ការធ្វើសេចក្តីខ្វល់ខ្វាយ ទំនុកបម្រុងក្នុងបុណ្យកុសល ។

៦- **ធម្មទេសនា** ការសម្តែងធម៌ ។

៧- **ធម្មស្សវន** ការស្តាប់ធម៌ ។

៨- **បត្តិទាន** ការចែកចំណែកបុណ្យ ។

៩- **បត្តានុមោទនា** ការត្រេកអរនឹងចំណែកបុណ្យ ។

១០- **ទិដ្ឋុជុកម្មំការោតិ** ការធ្វើ **ទិដ្ឋិ** ឱ្យត្រង់មានជំនឿ **កម្ម** និង **ផល** នៃ **កម្ម** ជាដើម ។

បណ្តា**កាមាវចរកុសល** ទាំងអស់ដែលកើតអំពីការបំពេញបុញ្ញកិរិយាវត្ថុ ទាំង ១០ យ៉ាង **កាមាវចរកុសល**ដែលប្រកបដោយ**ឧបចារជ្ឈាន**ហ្នឹងឯង លោកហៅថា **កាមាវចរកុសល** ដ៏វិសេស ឯ**កាមាវចរកុសល**ដទៃលោកហៅថា **កាមាវចរកុសល** ប្រក្រតី (**កុសលធម្មតា**) ។

ការពោលមកហើយក្នុងទីនេះ មិនបានពោលដល់**កាមាវចរកុសល**ថ្នាក់វិបស្សនានោះឡើយ គឺពោលត្រឹមតែ**កាមាវចរកុសល**ថ្នាក់ក្រោមប៉ុណ្ណោះ រីឯកាមាវចរកុសលថ្នាក់វិបស្សនានោះ លោកហៅថា**កាមាវចរកុសល**ថ្នាក់វិសេសបំផុតជាងកុសលថ្នាក់**ទាន សីល**និង**សមថភាវនា**ទាំងអស់ទៅទៀតដោយពិត ។

**កាមាវចរកុសល**ថ្នាក់**ឧបចារជ្ឈាន** ដែលវិសេសជាងកុសលថ្នាក់**ទាន សីល**ជាដើមនោះ ព្រោះ**ឧបចារជ្ឈាន** មានអានុភាពសង្កត់សង្កិននូវកិលេសទាំងឡាយមាន**រាគៈ**ជាដើម បានស្ងប់រម្ងាប់ប្រពៃជាងកុសលទាំងនោះ ហើយម្យ៉ាងទៀត ជាឫសគល់នៃ**វិបស្សនាបញ្ញា**ក្នុងការប្រតិបត្តិចម្រើន**វិបស្សនា**ដើម្បីធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាននោះឯង ។

## ធម៌ជាឫសគល់របស់វិបស្សនាបញ្ញា

នៅក្នុង **វិសុទ្ធិមគ្គ** ភាគ ៣ មានសេចក្តីបញ្ជាក់ប្រាប់ថា **វិសុទ្ធិ** ២ យ៉ាង គឺ**សីលវិសុទ្ធិ** ១, និង **ចិត្តវិសុទ្ធិ** ១, ជាឫសគល់របស់ **វិបស្សនា** ដោយពិត ។

**សីលវិសុទ្ធិ** សេចក្តីបរិសុទ្ធិនៃសីលបានដល់សីល ៤ យ៉ាងរបស់ភិក្ខុមាន**បាដិមោក្ខសំវរសីល**ជាដើម សូម្បីសីល ៥ សីល ៨ ឬ សីល ១០ ដែលបុគ្គលបានរក្សា ដុសខាត់ស្អាតល្អហើយ ក៏រាប់សង្គ្រោះចូលក្នុង**សីលវិសុទ្ធិ**ដែរ ។

**ចិត្តវិសុទ្ធិ** សេចក្តីបរិសុទ្ធិនៃចិត្ត បានដល់**សមាបត្តិ** ៨ [127] និង**ឧបចារជ្ឈាន**[128] ។

---

127 រូបាវចរឈាន ៤ និងអរូបាវចរឈាន ៤ ។

128 ឧបចារជ្ឈាន និងឧបចារជ្ឈាននៃឈាន ៨ ។

កាលដែលព្រះយោគីចម្រើននូវ**សមថកម្មដ្ឋាន** បានសម្រេចនូវគុណវិសេស ដល់ថ្នាក់**ឧបចារជ្ឈាន**ហើយ **វិសុទ្ធិ** ២ យ៉ាងគឺ **សីលវិសុទ្ធិ** ១, **ចិត្តវិសុទ្ធិ** ១ ក៏ឈ្មោះថា ព្រះយោគីបានសម្រេចដែរ ។

**សីលវិសុទ្ធិ** នោះ ព្រោះចិត្តមិនបានប្រព្រឹត្តកន្លងនូវសិក្ខាបទ មានសម្លាប់សត្វមានជីវិតជាដើម ។

**ចិត្តវិសុទ្ធិ** នោះព្រោះចិត្តស្ងប់រម្ងាប់ចាក **នីវរណធម៌** ៥ និងកិលេសដទៃទៀត ។

**អធិប្បាយថា:** កាលដែលឧបចារជ្ឈានកើតក្នុងសន្តាននៃព្រះយោគីតាំងនៅដោយប្រពៃហើយក្នុងសម័យណា សម័យនោះចិត្តរបស់ព្រះយោគីក៏ស្ងប់រម្ងាប់មិនបានគិតអាក្រក់ មានផ្តាច់ផ្តិលជីវិតរបស់សត្វជាដើម ទើបពោលថាព្រះយោគីនោះ បានសម្រេចនូវ **សីលវិសុទ្ធិ** ផង ម្យ៉ាងទៀតចិត្តរបស់ព្រះយោគីនោះសោតឈ្មោះថាជា **ចិត្តវិសុទ្ធិ** ។

ដូច្នេះសាធុជនទាំងឡាយក្នុងលោក ដែលជាអ្នកឃើញទោសក្នុង **បញ្ចក្ខន្ធ** ដែលប្រកបដោយទុក្ខគ្រប់យ៉ាង ហើយមានសេចក្តីប៉ុនប៉ងចង់ធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វានដែលជាទីរលត់បង់នូវសេចក្តីទុក្ខទាំងពួង ដោយការចម្រើន **វិបស្សនាកម្មដ្ឋាន**នេះ គប្បីជាអ្នកមិនមានសេចក្តីប្រមាទ ត្រូវឧស្សាហ៍ព្យាយាមរក្សានូវសីលឱ្យបរិសុទ្ធ ហើយធ្វើនូវសេចក្តីគោរពពាប់អាននូវ**សមថកម្មដ្ឋាន**ឱ្យណាស់ ដែលជាបច្ច័យនាំឱ្យមានគុណវិសេសគឺ **សមាបត្តិ** ព្រោះថាសីលស្អាត និងចិត្តស្អាតនោះឯង ដែលជាឫសគល់របស់ **វិបស្សនាបញ្ញា** មែនពិត ។

# ៥ បស្សនាកម្មដ្ឋាន

លំដាប់អំពីការពោលនូវ **សីល** និង **សមាធិ** នេះទៅ សូមពោលអំពី **វិបស្សនាកម្មដ្ឋាន** ដូចតទៅ:

ក្នុងគម្ពីរវិសុទ្ធិមគ្គភាគ ៣ ទំព័រ ៨៩១ មាត្រា ២៧១ មានសេចក្តីពោលអំពី **វិបស្សនាបញ្ញា** ថា:

**កថំ ភាវេតព្វា** ប្រែថា **បញ្ញា** (វិបស្សនាបញ្ញា) គឺព្រះយោគីគប្បីចម្រើនដូចម្តេច?

**យស្មា ឥមាយ បញ្ញាយ ខន្ធាយតនធាតុឥន្ទ្រិយសច្ចប្បដិច្ចសមុប្បាទាទិភេទា ធម្មា ភូមិ សីលវិសុទ្ធិ ចេវ ចិត្តវិសុទ្ធិ ចាតិ ឥមា ទ្វេ វិសុទ្ធិយោ មូលំ ទិដ្ឋិវិសុទ្ធិ កង្ខាវិតរណវិសុទ្ធិ មគ្គាមគ្គញាណទស្សនវិសុទ្ធិ បដិបទាញាណទស្សនវិសុទ្ធិ ញាណទស្សនវិសុទ្ធីតិ ឥមា បញ្ច វិសុទ្ធិយោ សរីរំ តស្មា តេសុ ភូមិភូតេសុ ធម្មេសុ ឧគ្គហបរិបុច្ឆាវសេន ញាណបរិចយំ កត្វា មូលភូតា ទ្វេ វិសុទ្ធិយោ សម្បាទេត្វា សរីរភូតា បញ្ច វិសុទ្ធិយោ សម្បាទេន្តេន ភាវេតព្វា ។**

បានសេចក្តីថា: ធម៌មានប្រភេទគឺ **ខន្ធ, អាយតនៈ, ធាតុ, ឥន្ទ្រិយ, សច្ចៈ បដិច្ចសមុប្បាទ** ជាភូមិរបស់បញ្ញា, វិសុទ្ធិ ២ គឺសីលវិសុទ្ធិ ១, ចិត្តវិសុទ្ធិ ១,

ជាឫសគល់របស់បញ្ញា, វិសុទ្ធិ ៤ គឺឧិដ្ឋិវិសុទ្ធិ ១, កង្ខាវិតរណវិសុទ្ធិ ១, មគ្គាមគ្គ-ញាណទស្សនវិសុទ្ធិ ១, បដិបទាញាណទស្សនវិសុទ្ធិ ១, ញាណទស្សនវិសុទ្ធិ ១, ជាសរីរៈ គឺតួរបស់បញ្ញានោះព្រោះហេតុណា ព្រោះហេតុនោះ វិបស្សនាបញ្ញា គឺព្រះយោគីកាលធ្វើនូវការសន្សំនូវញាណដោយអំណាចនៃការរៀននិងការសាកសួរក្នុងធម៌ដែលជាភូមិនោះ បន្ទាប់មកត្រូវញ៉ាំងវិសុទ្ធិ ២ ដែលជាឫសគល់ឱ្យដល់ព្រមហើយញ៉ាំងវិសុទ្ធិ ៥ ដែលជាសរីរៈឱ្យដល់ព្រមគប្បីចម្រើន។

សេចក្តីអធិប្បាយៈ កាលបើពិចារណាតាមផ្ទៃនៃបាលីនេះ ក្នុងការចម្រើននូវវិបស្សនានោះឱ្យឃើញថា មានគោលការណ៍សំខាន់ ៣ យ៉ាងគឺ ធម៌ជាភូមិ ១, ធម៌ជាឫសគល់ ១, ធម៌ជាតួបញ្ញា ១, គឺត្រូវព្រះយោគីអ្នកចម្រើន វិបស្សនាគប្បីសិក្សា ។

ភូមិរបស់វិបស្សនា មាន ៦ យ៉ាងគឺ ខន្ធ ១, អាយតនៈ ១, ធាតុ ១, ឥន្ទ្រិយ ១, សច្ចៈ ១, បដិច្ចសមុប្បាទ ១, កាលបើបែងចែកទៅតាមអារម្មណ៍មាន ៧៣ គឺ ខន្ធ ៥ [129] អាយតនៈ ១២ [130], ធាតុ ១៨[131] ឥន្ទ្រិយ ២២[132], សច្ច ៤[133] និងបដិច្ចសមុប្បាទ [134] ១២ រួមជា ៧៣ ។

កាលបើពោលរួបរួមនូវអារម្មណ៍ ៧៣ នេះឱ្យខ្លីចុះមានត្រឹម ២ គឺនាម ១, រូប ១ ។ តែបើរួមឱ្យកាន់តែខ្លីចុះថែមទៀត នៅត្រឹមតែ ១ គឺសង្ខារ ។

---

129 130 131 132 133 134 សេចក្តីពិស្តារក្នុងវិសុទ្ធិមគ្គភាគ ៣ ។

# ធម៌ជាឫសគល់

ឫសរបស់ **វិបស្សនា** មាន ២ យ៉ាងគឺ **សីលវិសុទ្ធិ** ១ និង **ចិត្តវិសុទ្ធិ** ១ ។

# ធម៌ជាសរីរៈរបស់វិបស្សនាបញ្ញា

**សរីរៈ** គឺតួរបស់ **វិបស្សនាបញ្ញា** មាន ៥ គឺៈ

១- **ទិដ្ឋិវិសុទ្ធិ** សេចក្ដីបរិសុទ្ធិនៃទិដ្ឋិ ។

២- **កង្ខាវិតរណវិសុទ្ធិ** សេចក្ដីបរិសុទ្ធិនៃញាណ ដែលឆ្លងផុតនូវសេចក្ដីសង្ស័យ។

៣- **មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ** សេចក្ដីបរិសុទ្ធិនៃញាណដែលដឹងច្បាស់ឃើញច្បាស់ថា ផ្លូវនិងមិនមែនផ្លូវ ។

៤- **បដិបទាញាណទស្សនវិសុទ្ធិ** សេចក្ដីបរិសុទ្ធិនៃញាណដែលដឹងច្បាស់ ឃើញច្បាស់ នូវផ្លូវប្រតិបត្តិ ។

៥- **ញាណទស្សនវិសុទ្ធិ** សេចក្ដីបរិសុទ្ធិនៃ **ញាណទស្សនៈ** ។

ព្រះយោគី ដែលត្រូវចម្រើន **វិបស្សនាកម្មដ្ឋាន** ដំបូងត្រូវរៀនសាកសួរឱ្យបានយល់ច្បាស់នូវធម៌ជាភូមិជាអារម្មណ៍របស់ **វិបស្សនាបញ្ញា** ក្នុងសំណាក់នៃអាចារ្យ ដែលជាកល្យាណមិត្តនៃខ្លួនសិន, កាលបើរៀនសាកសួរនូវធម៌នោះបានយល់ច្បាស់លាស់ល្អហើយ បន្ទាប់មកត្រូវញ៉ាំងធម៌ដែលជាឫសគល់របស់ **វិបស្សនា** នោះឱ្យកើតឡើងក្នុងចិត្ត, កាលបើសីល និងចិត្តដ៏បរិសុទ្ធ ដែលជាឫសគល់នោះកើតឡើងហើយក៏គប្បីចម្រើននូវ **វិបស្សនាបញ្ញា** តាមលំដាប់នៃវិសុទ្ធិ ៥ ដែលជាតួរបស់ **វិបស្សនាបញ្ញា** នោះតរៀងទៅ ។

# សង្ខារ

**សង្ខារ** មានន័យថា ធម្មជាតិដែលបច្ច័យប្រជុំតាក់តែងក្នុងទីជាមួយគ្នា វិគ្គហៈ ពោលថា **សំ ឯកតោ ករិយន្តីតិ សង្ខារា** [135] ប្រែថា ធម្មជាតិណាដែលបច្ច័យ ប្រជុំតាក់តែងក្នុងទីជាមួយគ្នា ធម្មជាតិនោះហៅថា **សង្ខារ** ។

**សង្ខារ** ន័យមួយទៀតថាធម្មជាតិអ្នកតាក់តែងនូវសង្ខតធម៌ វិគ្គហៈថា **សង្ខតមភិសង្ខរោន្តីតិ សង្ខារា** ប្រែថា ធម្មជាតិណាតាក់តែងនូវសង្ខតធម៌ [136] ធម្មជាតិនោះហៅថា **សង្ខារ** ។ វិគ្គហៈមួយទៀតពោលថា **រូបំ សង្ខរោន្តិ វេទនំ សង្ខរោន្តិ សញ្ញំ សង្ខរោន្តិ សង្ខារេ សង្ខរោន្តិ វិញ្ញាណំ សង្ខរោន្តីតិ សង្ខារា** ធម្មជាតិណាតាក់តែងនូវរូប, វេទនា, សញ្ញា, សង្ខារទាំងឡាយ, តាក់តែងនូវវិញ្ញាណ ធម្មជាតិនោះហៅថា **សង្ខារ** ។

## សេចក្តីអធិប្បាយ

សង្ខារគឺធម៌មួយដែលព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ហៅជំនួសនូវសង្ខតធម៌ទាំងអស់ជា **បរមត្ថ** សង្ខារមិនមែន **សត្វ បុគ្គល មនុស្ស ទេវតា** ជាដើម សង្ខារគឺត្រឹមតែជាសភាវធម៌ដែលកើតឡើងនិងរលត់ទៅវិញតាមហេតុ

---

[135] ធម៌ដែលបច្ច័យប្រជុំតាក់តែងបានដល់ខន្ធ ៥ ។

[136] សង្ខតធម៌ បានដល់ខន្ធ ៥ ។

បច្ច័យប៉ុណ្ណោះ ឯពាក្យថា សត្វ បុគ្គល មនុស្ស ទេវតា ព្រហ្ម ស្តេច សេដ្ឋីជាដើម គឺជាបញ្ញត្តិធម៌តែម្យ៉ាង ដែលមានត្រឹមតែឈ្មោះជាលោកវោហារ (សំដីក្នុងលោក) មិនមែនជា **សភាវបរមត្ថ** ដែលមានប្រាកដឡើយ ។

ពាក្យថា សត្វ បុគ្គល ជាដើមនោះ គឺជាពាក្យដែលលោកតែងតាំងឡើងសម្រាប់ហៅប្រើប្រាស់ក្នុងលោកទៅលើសង្ខារដែលកើតឡើង មានព្រះពុទ្ធដីកាពោលថា នៅពេលសង្ខារបែកធ្លាយម្តងៗ មិនឃើញមានជនណាម្នាក់ដែលស្លាប់សោះឡើយ ដូច្នេះជាដើម **ពុទ្ធវាចា** នេះជា **បរមត្ថធម៌** ជាការពោលតាមពិត ព្រោះថាពាក្យថាសត្វ បុគ្គល ជាដើម មិនមាននៅក្នុងលោក គេបែរជានិយាយថា ជនស្លាប់ មាតាបិតារបស់ខ្លួនស្លាប់ជាដើម ដូច្នេះទៅវិញ ។

ការពោលថា ជនស្លាប់ មាតាបិតារបស់ខ្លួនស្លាប់ដូច្នេះនេះ គឺជាសំដីដែលគេប្រើក្នុងលោក (លោកវោហារ) ដែលមហាជនតែងប្រើប្រាស់សព្វថ្ងៃ ។

ពពួកជនណាដែលមិនដឹងមិនយល់នូវ **បរមត្ថធម៌** ក៏តែងកាន់យកត្រឹមតែបញ្ញត្តិធម៌ក្នុងលោក ដោយអំណាចនៃសេចក្តីល្ងង់ខ្លៅ ហើយក៏ប្រកាន់ហួងហែងចំពោះសង្ខារធម៌ដែលមិនមែនជារបស់ខ្លួន សម្គាល់ថា ជារបស់ខ្លួន ម្ល៉ោះហើយនៅពេលសង្ខារធម៌នោះប្រែប្រួលឬបែកធ្លាយម្តងៗ ពពួកជននោះ ក៏ដល់នូវការយំរៀបរាប់ សោកសង្រេង ស្តាយស្រណោះអាឡោះអាល័យ រង្គិះរង្គួលខ្សឹកខ្សួលតានតឹងក្នុងឱរា ព្រោះតែសេចក្តីស្នេហាដែលកើតឡើងក្នុងសង្ខារធម៌នោះឯង ។

រីឯព្រះអរិយបុគ្គល ដែលលោកបានយល់បរមត្ថធម៌ហើយ កាលបើសង្ខារប្រែប្រួល បែកធ្លាយម្តងៗ លោកតែងដល់នូវសេចក្តីតក់ស្លុត នឿយណាយ ធុញទ្រាន់ចំពោះសង្ខារធម៌នោះ ក៏មានចិត្តឱនទេរទៅកាន់ព្រះនិព្វានដោយពិត ។

សង្ខារមានច្រើនយ៉ាង តែក្នុងទីនេះពោលសំដៅយកត្រឹមតែសង្ខារដែលមានន័យ ២ យ៉ាងប៉ុណ្ណោះគឺ:

១- **សង្ខារ** មានន័យថា **ធម្មជាតិ** ដែលបច្ច័យប្រជុំតាក់តែងក្នុងទីជាមួយគ្នា ។ ក្នុងទីនេះសំដៅយកសង្ខារ ២ យ៉ាងគឺ **ឧបាទិន្នកសង្ខារ** ១, **អនុបាទិន្នកសង្ខារ** ១ ។

សង្ខារដែលមានវិញ្ញាណគ្រប់គ្រងហៅថា **ឧបាទិន្នកសង្ខារ** បានដល់អត្តភាពរបស់មនុស្ស, សត្វ, ទេវតា, ព្រហ្មជាដើម. បច្ច័យរបស់សង្ខារនេះមាន ៤ យ៉ាងគឺ**អវិជ្ជា** ១, **តណ្ហា** ១, **កម្ម** ១, **អាហារ** ១ ។ សង្ខារដែលគ្មានវិញ្ញាណគ្រប់គ្រង ហៅថា**អនុបាទិន្នកសង្ខារ** បានដល់វត្ថុដែលលោកបញ្ញត្តហៅថាកុដិ, វិហារ, សាលា, កន្ទេល, មុង ភួយ, ព្រៃឈើ. ផ្កាឈូកជាដើម ដែលអាស្រ័យនៅក្នុងលោកធាតុ. បច្ច័យរបស់សង្ខារនេះមានបច្ច័យផ្សេងៗ ដូចគ្នាដូចតួយ៉ាងកុដិកើតឡើងព្រោះមាន សម្ភារៈ មានឈើ វល្លិ ដីឥដ្ឋ និងជាងអ្នកសាងសង់ជាដើម ទើបកើតឡើងបាន។ ម្យ៉ាងទៀតសង្ខារដែលមានន័យថាធម្មជាតិអ្នកតាក់តែងនូវសង្ខតធម៌ (**បញ្ចក្ខន្ធ**) ក្នុងទីនេះសំដៅយកសង្ខារ ៣ យ៉ាងគឺ **បុញ្ញាភិសង្ខារ** ១, **អបុញ្ញាភិសង្ខារ** ១, **អនេញ្ជាភិសង្ខារ** ១ ។

**បុញ្ញាភិសង្ខារ** សង្ខារជាបុណ្យបានដល់**កុសលចេតនា**ទាំង ១៣ [137] គឺ**កាមាវចរកុសលចេតនា** ៨ និង**រូបាវចរកុសលចេតនា** ៥, **អបុញ្ញាភិសង្ខារ** សង្ខារមិនមែនបុណ្យបានដល់**អកុសលចេតនាទាំង** ១២ [138] **គឺលោភមូល** ៨. **ទោសមូល** ២, **មោហមូល** ២ .

**អនេញ្ជាភិសង្ខារ** សង្ខារមិនញាប់ញ័រ បានដល់**អរូបាវចរកុសលចេតនា** [139] ៤ ។ **កុសលាកុសលចេតនាទាំង** ២៩ នេះតាក់តែងសត្វលោកឱ្យកើតក្នុង**សុគតិភព** [140] និង**ទុគ្គតិភព**[141] ទើបលោកហៅថាសង្ខារ ។

សូម្បីខ្យល់ **អស្សាសបស្សាសៈ** គឺខ្យល់ដកដង្ហើមចេញចូល ដែលកើតអំពីចិត្តក៏លោកហៅថា**សង្ខារ** គឺ**កាយសង្ខារ** ព្រោះអវយវៈមានជើងដៃ ឬសរីរៈទាំងមូល ដែលកម្រើកញាប់ញ័រទៅបាន អាស្រ័យមានខ្យល់**អស្សាសបស្សាសៈ** នេះតាក់តែងឱ្យកម្រើកឡើង ។

## នាម និង រូប

**នាម** ជាធម្មជាតិឱនទៅកាន់អារម្មណ៍ មានកិរិយាឱនទៅកាន់អារម្មណ៍ជាលក្ខណៈបានដល់ **អរូបក្ខន្ធ** ៤ ។

---

137 មានក្នុងអភិធម្មត្ថសង្គហៈ ។

138 139 មានក្នុងអភិធម្មត្ថសង្គហៈ ។

140 ភពមនុស្ស, ទេវតា, ព្រហ្ម, ហៅថា សុគតិភព ។

141 ភព នរក ប្រេត អសុរកាយ តិរច្ឆាន ហៅថាទុគ្គតិភព ។

**អរូបក្ខន្ធ** មានន័យថា ក្រុមអរូបមាន ៤ យ៉ាងគឺ **វេទនាខន្ធ** ១, **សញ្ញាខន្ធ** ១, **សង្ខារក្ខន្ធ** ១, **វិញ្ញាណក្ខន្ធ** ១ ។

**វេទនាខន្ធ**[142] ក្រុមសោយអារម្មណ៍ បានដល់វេទនាដែលកើតជាមួយចិត្ត ៨៩[143] ឬ ១២១ ដួង ។

**សញ្ញាខន្ធ**[144] ក្រុមចាំអារម្មណ៍បានដល់សញ្ញាដែលកើតជាមួយចិត្ត ៨៩, ឬ១២១ដួង ។

**សង្ខារខន្ធ**[145] ក្រុមតាក់តែងនូវអារម្មណ៍បានដល់ **ចេតសិក ៥០** គឺ **ចេតសិក**ទាំង ៥២ ដកយក**វេទនាចេតសិក** ១, **សញ្ញាចេតសិក** ១, ចេញនៅសល់ **៥០ ចេតសិក** ។

**វិញ្ញាណក្ខន្ធ**[146] ក្រុមដឹងច្បាស់នូវអារម្មណ៍ បានដល់ចិត្ត ៨៩ ឬ ១២១ដួង ។

**វេទនា សញ្ញា, សង្ខារ, វិញ្ញាណ** លោកហៅថា **នាមធម៌** ព្រោះជាធម្មជាតិតែងឱនទៅទេរជ្រេទៅ រេទៅកាន់អារម្មណ៍តាមទ្វារ ៦, នៅពេលដែលអារម្មណ៍មកប្រាកដដល់ទ្វារទាំងនោះ ។

---

142 មានក្នុងអភិធម្មត្ថសង្គហៈ និង វិសុទ្ធិមគ្គភាគ ៣ ។

143 144 145 146 មានក្នុងអភិធម្មត្ថសង្គហៈ និង វិសុទ្ធិមគ្គភាគ ៣ ។

# សេចក្ដីអធិប្បាយ

នៅពេលណារូបារម្មណ៍មកប្រាកដដល់ចក្ខុទ្វារ ពេលនោះអរូបធម៌ទាំងនោះក៏តែងស្ទុះទៅតាមទ្វារ ធ្វើការសោយចាំសន្សំដឹងច្បាស់នូវរូបារម្មណ៍នោះឯងទើបរលត់ទៅ ។

នៅពេលណាសម្លេង ។ល។ ក្លិន ។ល។ រស ។ល។

ផោដ្ឋព្វារម្មណ៍មកប្រាកដដល់កាយទ្វារ ពេលនោះអរូបធម៌ទាំងនោះ ក៏តែងស្ទុះទៅតាមទ្វារធ្វើការសោយ កត់សម្គាល់ សន្សំ ដឹងច្បាស់នូវផោដ្ឋព្វារម្មណ៍នោះហើយក៏រលត់ទៅ ។

នៅពេលណាធម្មារម្មណ៍មកប្រាកដដល់មនោទ្វារ ពេលនោះអរូបធម៌ទាំងនោះក៏តែងស្ទុះទៅកាន់យកនូវធម៌នោះមកជាអរម្មណ៍ ធ្វើការសោយកត់សម្គាល់សន្សំដឹងច្បាស់ ហើយក៏រលត់ទៅ ។

អរូបធម៌ទាំងនោះ តែងស្ទុះទៅឱនទៅ ទេរទៅ ជ្រេទៅ កាន់យកនូវអារម្មណ៍ តាមទ្វារទាំង ៦ មានសភាពដូចពោលមកហើយនេះឯង ទើបលោកហៅថា **នាមធម៌** ។

- **រូបធម៌** មានន័យថា ធម្មជាតិបែកធ្លាយ មានកិរិយាបែកធ្លាយជាលក្ខណៈបានដល់រូបក្ខន្ធ។ មានន័យថា ក្រុមរូបបានដល់រូប ២៨គឺ ។

**មហាភូតរូប ៤, ឧបាទាយរូប ២៤,** បណ្ដារូបទាំង ២៨ តែងមានលក្ខណៈ[147] ផ្សេងៗគ្នា មានលក្ខណៈរឹង, រាវ, ក្តៅ, ល្វើយៗជាដើម តាមរូបមួយៗ តែបើពោលពីលក្ខណៈរួមវិញ មានត្រឹមតែមួយមានកិរិយាបែកធ្លាយជាលក្ខណៈ ព្រោះថារូបទាំង ២៨ នោះ បើទុកជាមានលក្ខណៈផ្សេងគ្នាយ៉ាងណាក៏ដោយក៏គង់ត្រូវវិនាស ឬបែកធ្លាយដូចគ្នាទាំងអស់ដែរទើបពោលថា រូបក្ខន្ធនោះជា រូបធម៌ ។

## បញ្ញត្តិ និងបរមត្ថ

**បញ្ញត្តិ** មានន័យថា ការ**បញ្ញត្តិ**, សេចក្តី**បញ្ញត្តិ** សេចក្តីហាមប្រាម សេចក្តីតែងតាំង **វិគ្គហៈ**ថា **បញ្ញាបនំ ›បញ្ញត្តិ** ។

**បញ្ញត្តិ** បានដល់សេចក្តីតែងតាំងនាមទៅលើ វត្ថុ សត្វ សង្ខារ និងធម៌ដែលជា **បរមត្ថ** ។

**អធិប្បាយថា:** វត្ថុ គឺរបស់ មានពាក្យថា ផ្ទះ កុដិ វិហារ សាលា ពែង ប៉ាន់ សៀវភៅ ប៊ិចជាដើម ។

**សត្វ** គឺជនដែលគេជាប់ជំពាក់ក្នុងបំណងមានពាក្យ គោ ក្របី ជ្រូក មាន់ ទា ដង្កូវ ពូសុខ យាយសៅ ជាដើម ។

**សង្ខារ គឺឧបាទិន្នកសង្ខារ** សង្ខារដែលមានវិញ្ញាណគ្រប់គ្រង មានពាក្យថាបុគ្គល មនុស្ស ទេវតា ព្រហ្មជាដើម ។

---

[147] ក្នុងគម្ពីរវិសុទ្ធិមគ្គភាគ ៣

**សង្ខារ** **គឺអនុបាទិន្នកសង្ខារ** សង្ខារដែលគ្មានវិញ្ញាណគ្រប់គ្រង មានពាក្យថាដើមចេក ដើមដូង ដើមត្នោត ឈូក ព្រលឹត ផ្កាកុលាប ផ្កាម្លិះ ស្មៅជាដើម។

**បរមត្ថធម៌** ដែលមានសេចក្ដីល្អិតដ៏ក្រៃលែង មានពាក្យថា បឋវីធាតុ ធាតុដី, អាបោធាតុ ធាតុទឹក, តេជោធាតុ ធាតុភ្លើង, វាយោធាតុ ធាតុខ្យល់ ជាដើម បុគ្គលកាលដឹង ចងចាំ ឃើញ ពោលនូវពាក្យដែលជាឈ្មោះទាំងអស់នេះ លោកហៅថា កាលដឹង ចាំ ឃើញពោលនូវ **បញ្ញត្តិធម៌** ។

**បរមត្ថ:** បានដល់**បរមត្ថធម៌** ដែលមានន័យថា ធម៌ដែលមានសេចក្ដីដ៏ក្រៃលែង បរមត្ថនោះបានដល់ **រូបធម៌** ១, **នាមធម៌** ១, **រូបក្ខន្ធ** គឺក្រុមរូប ២៨ លោកហៅថា **រូបធម៌** ។

**អរូបក្ខន្ធ** ៤ និង**និព្វាន** ១ ជា ៥ លោកហៅថា **នាមធម៌** ។ **រូបធម៌**និង**នាមធម៌**[148] ហ្នឹងឯង ដែលជាអារម្មណ៍របស់**វិបស្សនាបញ្ញា** រីឯបញ្ញត្តិធម៌នោះ មិនមែនជាអារម្មណ៍របស់**វិបស្សនាបញ្ញា**ឡើយ តែលោកហៅថា ជាធម្មារម្មណ៍ ជាអារម្មណ៍ របស់ចិត្ត និង**ចេតសិក** ដែលកើតតាម**មនោទ្វារ** ។

## ទ្វារ ៦

**ទ្វារ** មានន័យ (**វត្ថុ** ឬ **សទ្ទ:**) ជាគ្រឿងបិទ **វិគ្គហ:**ថា **ទ្វារតិ សំវរតិ ឯតេនាតិ ›ទ្វារំ** ជនបិទ គឺថាសង្រួមដោយវត្ថុ (**បសាទរូប**) នោះ ដូច្នេះវត្ថុ នោះហៅថា **ទ្វារ** ។

---

148 អរូបក្ខន្ធ ៤ ។

## ទ្វារនោះមាន ៦គឺ

១- **ចក្ខុទ្វារ** ទ្វារភ្នែក សំដៅយក**បសាទរូប** ដែលសម្រាប់សម្រេចកិច្ចក្នុងការឃើញនូវរូប នៅពេលដែលរូបមកប្រាកដដល់ទ្វារភ្នែក ។

២- **សោតទ្វារ** ទ្វារត្រចៀក សំដៅយក**បសាទរូប** ដែលសម្រាប់សម្រេចកិច្ច ក្នុងការស្តាប់នៅពេលដេលសម្លេងមកប្រាកដដល់ត្រចៀក ។

៣- **ឃានទ្វារ** ទ្វារច្រមុះ សំដៅយក**បសាទរូប** ដែលសម្រាប់សម្រេចកិច្ចក្នុងការធុំក្លិន នៅពេលដែលក្លិនមកប្រាកដដល់ច្រមុះ ។

៤- **ជិវ្ហាទ្វារ** ទ្វារអណ្តាត សំដៅយក**បសាទរូប** ដែលសម្រាប់សម្រេចកិច្ចក្នុងការដឹងរសជាតិ នៅពេលដែលរសជាតិមកប្រាកដដល់អណ្តាត ។

៥- **កាយទ្វារ** ទ្វារកាយ សំដៅយក**បសាទរូប** ដែលសម្រាប់សម្រេចកិច្ចក្នុងការដឹងវត្ថុ នៅពេលដែលវត្ថុមកប៉ះផ្ទប់នឹងកាយ ។

៦- **មនោទ្វារ** ទ្វារចិត្តសំដៅយក**ភវង្គ** មានបាលី **មនោទ្វារំ បន ភវង្គន្តិ វុច្ចតិ** មានន័យថា **ភវង្គ**ហ្នឹងឯងគឺ លោកហៅថា **មនោទ្វារ** ។

## អារម្មណ៍ ៦

**អារម្មណ:** មានន័យថា ធម្មជាតិជាទីមកត្រេកអរនៃធម៌ **គឺចិត្ត** និង **ចេតសិក**, ម្យ៉ាងទៀត ធម្មជាតិជាទីត្រេកអរដោយក្រៃលែងនៃធម៌ **គឺចិត្ត** និង **ចេតសិក** ។

វិគ្គហថា **អាគន្ត្វា អាភូសោវា ចិត្តចេតសិកា ធម្មា រមន្តិ ឯត្ថាតិ› ធម៌ គឺចិត្ត និងចេតសិក** មកហើយត្រេកអរដោយក្រៃលែង ក្នុងធម្មជាតិនោះហៅថា **អារម្មណ៍** ។

អារម្មណ៍នោះមាន ៦គឺ:

១- ***រូបារម្មណ៍*** អារម្មណ៍គឺរូប មានកិរិយាប៉ះខ្ទប់នឹង**ចក្ខុបសាទ** ជាលក្ខណៈ បានដល់ ***វណ្ណរូប*** មានពណ៌ខៀវ លឿង ក្រហម ស ជាដើម ។

២- ***សទ្ទារម្មណ៍*** អារម្មណ៍គឺសំឡេង មានកិរិយាប៉ះខ្ទប់នឹង**សោតបសាទ** ជាលក្ខណៈ បានដល់សំឡេង ស្គរ ពិណ ទ្រអ៊ូ ជាដើម ។

៣- **គន្ធារម្មណ៍** អារម្មណ៍គឺក្លិន មានកិរិយាប៉ះខ្ទប់នឹង**ឃានបសាទ**ជាលក្ខណៈ បានដល់ក្លិនផ្កាឧប្បល ផ្កាម្លិះជាដើម ។

៤- ***រសារម្មណ៍*** អារម្មណ៍គឺ ***រសជាតិ*** មានកិរិយាប៉ះខ្ទប់នឹង **ជិវ្ហាបសាទ** ជាលក្ខណៈ បានដល់រសជាតិនៃដើម, ផ្លែ, មើមឈើជាដើម ។

៥- **ផោដ្ឋព្វារម្មណ៍:** អារម្មណ៍ គឺវត្ថុ ដែលប៉ះ ខ្ទប់នឹង**កាយបសាទ** បានដល់ធាតុ ៣គឺ ។

- **បឋវីធាតុ** ធាតុដី មានលក្ខណ:រឹង ។
- **តេជោធាតុ** ធាតុភ្លើង មានលក្ខណ: ក្តៅ ។
- **វាយោធាតុ** ធាតុខ្យល់ មានលក្ខណ:ល្ហើយៗ ។

៦- **ជម្មារម្មណ៍** អារម្មណ៍គឺធម៌ មានលក្ខណៈផ្សេងៗគ្នា តាមសភាពធម៌នោះ បានដល់ធម៌ ៦ **បសាទរូប**[149] ១, **សុខុមរូប**[150] ១, **ចិត្ត**[151] ១, **ចេតសិក**[152] ១, **និព្វាន** ១, **វិញ្ញត្តិ**[153] ១ ។

- **រូប** នឹងបានមកជាអារម្មណ៍របស់**ចិត្ត** និង**ចេតសិក** ដែលកើតតាមទ្វារ ២ គឺ **ចក្ខុទ្វារ** ១, **មនោទ្វារ** ១ ។

- **សម្លេង** នឹងបានមកជាអារម្មណ៍របស់**ចិត្ត** និង**ចេតសិក** ដែលកើតតាម**ទ្វារ** ២ គឺ **សោតទ្វារ** ១, **មនោទ្វារ** ១ ។

- **ក្លិន** នឹងបានមកជាអារម្មណ៍របស់**ចិត្ត** និង**ចេតសិក** ដែលកើតតាមទ្វារ ២ គឺ **ឃានទ្វារ** ១, **មនោទ្វារ** ១ ។

- **រស** នឹងបានមកជាអារម្មណ៍របស់**ចិត្ត** និង**ចេតសិក** ដែលកើតតាមទ្វារ ២ គឺ **ជិវ្ហាទ្វារ** ១, **មនោទ្វារ** ១ ។

- **រឹង ក្តៅ ល្ហើយ** នឹងបានមកជាអារម្មណ៍របស់**ចិត្ត** នឹង**ចេតសិក** ដែលកើតតាមទ្វារ ២ គឺ **កាយទ្វារ** ១, **មនោទ្វារ** ១ ។

- **ធម្មា** គឺក្រុមធម៌ មាន**បសាទរូប** និងសុខុមរូប ជាដើម នឹងបានមកជាអារម្មណ៍របស់**ចិត្ត** និង **ចេតសិក** ដែលកើតតាម **មនោទ្វារ** តែម្យ៉ាង ។

---

149 បសាទរូប ៥ ។
150 សុខុមរូប ១៦ ។
151 ចិត្ត ៨៩ ។
152 ចេតសិក ៥២ ។
153 វិញ្ញត្តិ ២ ។

**អធិប្បាយថា:** កាលដែលរូបារម្មណ៍មកប្រាកដដល់ចក្ខុទ្វារហើយ រូបនោះក៏បានមកជាអារម្មណ៍ដល់ **ចិត្ត** និង **ចេតសិក** ដែលកើតតាមចក្ខុទ្វារ ហើយក៏រលត់ទៅ បន្ទាប់មកក៏បានមកជាអារម្មណ៍ដល់**ចិត្ត**និង**ចេតសិក**ដែលកើតតាម**មនោទ្វារ**ថែមទៀត ព្រោះហេតុដូច្នេះ ទើបពោលថារូបនឹងបានមកជាអារម្មណ៍របស់ **ចិត្ត** និង **ចេតសិក** ដែលកើត តាមទ្វារ ២គឺ **ចក្ខុទ្វារ** ១, **មនោទ្វារ** ១ ។

កាលដែលសទ្ទារម្មណ៍ មកប្រាកដដល់**សោតទ្វារ** ។ល។ **គន្ធារម្មណ៍**មកប្រាកដដល់**ឃានទ្វារ** ។ល។ **រសារម្មណ៍** មកប្រាកដដល់ **ជិវ្ហាទ្វារ** ។ល។ **ផោដ្ឋព្វារម្មណ៍** មកប្រាកដដល់ **កាយទ្វារ** ហើយ**ផោដ្ឋព្វៈ**នោះ ក៏បានមកជាអារម្មណ៍ដល់**ចិត្ត**និង**ចេតសិក**ដែលកើតតាម**កាយទ្វារ** ហើយក៏រលត់ទៅ បន្ទាប់មកក៏បានមកជាអារម្មណ៍ដល់**ចិត្តចេតសិក** ដែលកើតតាម**មនោទ្វារ**ថែមទៀត ព្រោះហេតុដូច្នោះទើបពោលថា **ផោដ្ឋព្វៈ** នឹងបានមកជាអារម្មណ៍ របស់ **ចិត្ត** និង **ចេតសិក** ដែលកើតតាមទ្វារ ២ គឺ **កាយទ្វារ** ១, **មនោទ្វារ** ១ ។

រីឯធម៌ មាន**បសាទរូប**និង**សុខុមរូប**ជាដើម កាលដែលប្រាកដដល់**មនោទ្វារ**ហើយ ក៏បានមកជាអារម្មណ៍ដល់**ចិត្ត**[154] និង**ចេតសិក**[155] ដែលកើតតាម**មនោទ្វារ**តែម្យ៉ាងហើយក៏រលត់ទៅ ព្រោះហេតុដូច្នេះ ទើបពោលថាធម៌នឹងមកជាអារម្មណ៍របស់ **ចិត្ត** និង **ចេតសិក** ដែលកើតតាម**មនោទ្វារ**តែម្យ៉ាង ។

---

154 ចិត្ត ធម្មជាតិគិតពិចារណា ស្រាវជ្រាវនូវអារម្មណ៍ ។

155 ចេតសិក ធម្មជាតិមានកិរិយាកើតរលត់អារម្មណ៍វត្ថុជាមួយចិត្ត ។

- **ចិត្ត** និង **ចេតសិក** ដែលកើតតាម**បញ្ចទ្វារ** អាចទទួលកាន់យកអារម្មណ៍ជា**បច្ចុប្បន្ន**ៗ តាមទ្វាររៀងៗខ្លួន មិនអាចកាន់នូវអារម្មណ៍ក្នុង**អតីត** និង**អនាគត**បានឡើយ ។

ឯ**ចិត្ត** និង **ចេតសិក** ដែលកើតតាម**មនោទ្វារ** អាចកាន់យកនូវអារម្មណ៍ប្រាំមួយក្នុង **អតីត បច្ចុប្បន្ន** និង **អនាគត** បានទាំងអស់ ។

## ការកំណត់ដឹងនូវនាមនិងរូប

ក្នុងការចម្រើន**វិបស្សនា**ថ្នាក់ដំបូង ដើម្បីបំពេញនូវសេចក្តីត្រូវការនៃព្រះយោគីដែលជា**អាទិកម្មិក**បុគ្គល សូមលើកយក**រូបបរមត្ថ** និង **នាមបរមត្ថ**ខ្លះៗ មកបកស្រាយរៀបរៀងទុកជាក្បួនប្រតិបត្តិក្នុងការហាត់ពត់អប់រំចិត្តក្នុងព្រះពុទ្ធសាសនានេះ ។

រូបធម៌ទាំងអស់មានចំនួន ២៨[156] គឺ **មហាភូតរូប** ៤ និង**ឧបាទាយរូប** ២៤ តែក្នុងទីនេះសូមលើកយកតែរូបចំនួន ៩ មកតាំងទុកជាអារម្មណ៍របស់បញ្ញានៃព្រះយោគី ដែលជា **អាទិកម្មិក** បុគ្គលដូចតទៅ ។

### រូប ៩នោះគឺ

**បឋវីធាតុ** ១, **អាបោធាតុ**១, **តេជោធាតុ** ១, **វាយោធាតុ** ១, **វណ្ណៈ** ១, **គន្ធ** ១, **រស** ១, **ឱជ** ១, **រូប** ៨ នេះលោកហៅថា **សុទ្ធដ្ឋករូប** (រូបចំនួន ៨ សុទ្ធ) និង **សទ្ទៈ ១ ជា ៩** ។

---

156 ក្នុងវិសុទ្ធិមគ្គភាគ ៣ ។

- **បឋវីធាតុ** ធាតុដី មានលក្ខណៈ រឹង ។
- **អាបោធាតុ** ធាតុទឹក មានលក្ខណៈ ជ្រាបសើម ។
- **តេជោធាតុ** ធាតុខ្យល់ មានលក្ខណៈ ក្តៅ ។
- **វាយោធាតុ** ធាតុខ្យល់ មានលក្ខណៈ ល្ហើយៗ។
- **វណ្ណ** គឺរូបពណ៌ មានកិរិយាប៉ះខ្ទប់នឹងចក្ខុបសាទជាលក្ខណៈ។
- **សទ្ទ** គឺសម្លេងមានកិរិយាប៉ះខ្ទប់នឹង**សោតបសាទ**ជាលក្ខណៈ
- **គន្ធ** ក្លិន មានកិរិយាប៉ះខ្ទប់នឹង**ឃានបសាទ**ជាលក្ខណៈ ។
- **រស** គឺរសជាតិ មានកិរិយាប៉ះខ្ទប់ និង**ជិវ្ហាបសាទ** ជាលក្ខណៈ
- **ឱជ** គឺឱជាសំដៅយក**ឱជារស**, ដែលសម្រាប់ចិញ្ចឹមសរីរៈរាងកាយសត្វឱ្យមានជីវិត ប្រព្រឹត្តទៅក្នុងលោក, **ឱជៈ**នោះ ផ្សព្វផ្សាយទៅពេញរាងកាយសត្វទាំងមូលមាន **ឱជៈ** ជាលក្ខណៈ ។

- **វណ្ណរូប** នឹងបានមកជាអារម្មណ៍របស់ **ចិត្ត** និង **ចេតសិក** ដែលកើតតាម **ចក្ខុទ្វារ** និង **មនោទ្វារ** ។
- **សទ្ទរូប** នឹងបានមកជាអារម្មណ៍របស់ **ចិត្ត** និង **ចេតសិក** ដែលកើតតាម **សោតទ្វារ** និង **មនោទ្វារ** ។
- **គន្ធរូប** នឹងបានមកជាអារម្មណ៍របស់ **ចិត្ត** និង **ចេតសិក** ដែលកើតតាម **ឃានទ្វារ** និង **មនោទ្វារ** ។

- **រសរូប** នឹងបានមកជាអារម្មណ៍របស់ **ចិត្ត** និង **ចេតសិក** ដែលកើតតាម **ជិវ្ហាទ្វារ** និង **មនោទ្វារ** ។

- **បឋវីធាតុ** ១, **តេជោធាតុ** ១, **វាយោធាតុ** ១, និងបានមកជាអារម្មណ៍របស់**ចិត្ត**និង**ចេតសិក**ដែលកើតតាម**កាយទ្វារ** និង**មនោទ្វារ** ។

- **អាបោធាតុ** ១, **ឱជរូប** ១, នឹងបានមកជាអារម្មណ៍របស់**ចិត្ត** និង **ចេតសិក** ដែលកើតតាម**មនោទ្វារ**តែម្យ៉ាង ព្រោះរូបទាំងនេះជារូបល្អិត **ចិត្ត** និង **ចេតសិក** តាម **បញ្ចទ្វារ** មិនអាចឃើញបាន ។

នាមធម៌នោះមានច្រើន [157] បែបច្រើនយ៉ាងណាស់ តែក្នុង**វិបស្សនា**ថ្នាក់ **បឋម** នេះសូមលើកយកត្រឹមតែ ៥ មកតាំងទុកជាអារម្មណ៍របស់ប្រាជ្ញា ។

## នាមធម៌ ៥ នោះគឺ

**ផស្សៈ ១, វេទនា ១, សញ្ញា ១, ចេតនា ១, ចិត្ត ១។**

- **ផស្ស** ធម្មជាតិប៉ះនូវអារម្មណ៍ មានកិរិយាប៉ះនូវអារម្មណ៍ជាលក្ខណៈ ។
- **វេទនា** ធម្មជាតិសោយនូវអារម្មណ៍ មានកិរិយាសោយនូវអារម្មណ៍ជាលក្ខណៈ ។
- **សញ្ញា** ធម្មជាតិចាំនូវអារម្មណ៍មានកិរិយាចាំជាលក្ខណៈ ។
- **ចេតនា** ធម្មជាតិ គិតនូវអារម្មណ៍មានភាពគិត ឬចាត់ចែង ឬភាពសន្សំជាលក្ខណៈ ។

---

[157] ក្នុងគម្ពីរវិសុទ្ធិមគ្គភាគ ៣ ។

- **ចិត្ត** គឺ **វិញ្ញាណ** **វិញ្ញាណ** គឺធម្មជាតិដឹងច្បាស់នូវអារម្មណ៍ មានកិរិយាដឹងច្បាស់ជាលក្ខណៈ ។

ក្រុមធម៌ទាំងនេះ លោកហៅថា ពួក **ខន្ធ** មាន **៥ស្សះ** ជាគម្រប់ ៥ ។

ពួកធម៌ទាំង ៥ នេះតែងកើតឡើង តាមទ្វារទាំង ៦ មាន **ចក្ខុទ្វារ** ជាដើមកាន់យកអារម្មណ៍ ៦ មានរូបារម្មណ៍ជាដើម ក្នុងសម័យដែលប្រាជ្ញារបស់ព្រះយោគី បានកំណត់ដឹងនូវលក្ខណៈនៃសភាវធម៌ មានរូបជាដើមដែលមកប្រាកដដល់ទ្វារ មាន **ចក្ខុទ្វារ** ជាដើម ។

## កិច្ចប្រតិបត្តិក្នុងការកំណត់ដឹងនូវនាមនិងរូប

ការកំណត់ដឹងនូវ **នាម** និង *រូប* ដែលជាអារម្មណ៍របស់ ***វិបស្សនា*** នោះ ព្រះយោគី[158] គប្បីកំណត់ដឹងនូវ ***រូបខន្ធ*** ជាមុន ទើបកំណត់ដឹងនូវ **នាមខន្ធ** ដែលមានរូបនោះជាអារម្មណ៍ជាខាងក្រោយ ។

## សេចក្តីពន្យល់

ក្នុងការកំណត់ដឹងនូវ *នាម* និង *រូប* ក្នុង *វិបស្សនា* នេះ គឺព្រះយោគីដែលសុទ្ធវិបស្សនាយានិកក្តី, **សមថយានិក**ក្តី គប្បីកំណត់ដឹងនូវ**នាម** និង*រូប*នោះឱ្យ

---

158 ព្រះយោគីមាន ២ គឺ:

១- សុទ្ធវិបស្សនាយានិកោ ព្រះយោគីដែលមានវិបស្សនាសុទ្ធជាយាន ព្រះយោគីនេះក្នុងការចម្រើននូវវិបស្សនា មិនមានចម្រើនសមថឱ្យជាបាទមុន។

២- សមថយានិកោ ព្រះយោគី ដែលមានសមថជាយាន ព្រះយោគីនេះ បានចម្រើនសមថកម្មដ្ឋានឱ្យជាបាទមុន ទើបចម្រើនវិបស្សនាជាខាងក្រោយ ។

បានគ្រប់ទ្វារ, គ្រប់អារម្មណ៍, គ្រប់ឥរិយាបថ, គ្រប់ពេលវេលា, គ្រប់សម័យ និង គ្រប់ទីកន្លែងទាំងអស់ ។

- គ្រប់ទ្វារនោះគឺ គ្រប់ទ្វារទាំង ៦ មានចក្ខុទ្វារជាដើម ។
- គ្រប់អារម្មណ៍នោះគឺ គ្រប់អារម្មណ៍ទាំង ៦ មានរូបារម្មណ៍ជាដើម ។
- គ្រប់ឥរិយាបថនោះគឺ គ្រប់ឥរិយាបថទាំង ៤ មានដេក, ដើរ, ឈរ, អង្គុយ ។
- គ្រប់ពេលវេលានោះគឺ គ្រប់កាលទាំងអស់ ទោះពេលថ្ងៃក្តី យប់ក្តី ។
- គ្រប់សម័យនោះគឺ គ្រប់យាមទាំងអស់ ក្នុងពេលថ្ងៃក្តី យប់ក្តី ទោះ **បឋមយាមក្តី**[159] **មជ្ឈិមយាមក្តី បច្ឆិមយាមក្តី** ។
- គ្រប់ទីកន្លែងនោះគឺ គ្រប់ទីឋានទាំងអស់ដែលខ្លួនអាស្រ័យនៅ ទោះបីនៅក្នុងព្រៃក្តី, ស្រុកក្តី, ទីស្ងាត់ក្តី, ទីអ៊ូអរក្តី ឬទីណានីមួយក្តី តែព្រះយោគីដែលជាអ្នកសិក្សាថ្មីៗ ក្នុងការកំណត់ដឹងនូវ***នាម*** និង***រូប***នោះ មុនដំបូងមិនអាចកំណត់***នាម***និង***រូប*** នោះឱ្យបានគ្រប់ទ្វារ អារម្មណ៍ជាដើមនោះបានឡើយ លុះត្រាតែមានការហាត់បង្វឹកនូវសតិប្រាជ្ញាក្នុងការកំណត់ដឹងនូវ ***នាម*** និង ***រូប***នោះឱ្យរឿយៗទៅ ទើបពេលក្រោយ នឹងអាចចាក់ធ្លុះនូវ ***បរមត្ថធម៌*** នោះសព្វគ្រប់បាន ។

---

159 បឋមយាម ពីម៉ោង ៦ ដល់ម៉ោង ១០ ។
មជ្ឈិមយាម ពីម៉ោង ១០ ដល់ម៉ោង ២ ។
បច្ឆិមយាម ពីម៉ោង ២ ដល់ម៉ោង ៦ ។

ក្នុងសាសនា[160] នេះ កិច្ចប្រតិបត្តិកំណត់ដឹងនូវនាមរូបនោះមានច្រើនបែប ច្រើនយ៉ាងទៅតាមអធ្យាស្រ័យរបស់ព្រះយោគីដែលជាអ្នកចូលចិត្ត ក្នុងសម័យពុទ្ធកាលព្រះយោគីអង្គខ្លះបានកំណត់ដឹង នូវនាមរូបតាម**ចក្ខុទ្វារ**ជាហេតុក៏មាន អង្គខ្លះតាម **មនោទ្វារ** ជាប្រធានក៏មាន, អង្គខ្លះតាមទ្វារដទៃអំពីនោះ អង្គខ្លះកាន់យក **អារម្មណ៍** ក្រៅជាហេតុក៏សឹងមាន ។

តែក្នុងសៀវភៅច្បាប់នេះ សូមរៀបរៀងនូវកិច្ចប្រតិបត្តិ ដូចមានសេចក្តីដូចតទៅ:

ក្នុងការកំណត់ដឹងនូវ **នាម** និង **រូប** នោះ ព្រះយោគីគប្បីកំណត់ដឹងនូវរូបធម៌មុន កុំអាលកំណត់នូវ**នាមធម៌** លុះត្រាតែបានកំណត់ដឹងនូវ**រូបធម៌**បានជាក់ច្បាស់ហើយ ទើបកំណត់ដឹងនូវ**នាមធម៌**ជាខាងក្រោយ ព្រោះថាពួកធម៌[161] ដែលត្រូវកំណត់ដឹងថា**នាមធម៌**នោះ ពួកធម៌ទាំងនោះ លុះមានរូបធម៌ជាអារម្មណ៍ ទើបកើតឡើងបាន កាលបើមិនមានជា**រូបធម៌**ជាអារម្មណ៍ទេ មិនអាចកើតឡើងដោយខ្លួនឯងបានឡើយ ។

---

[160] ព្រះពុទ្ធសាសនា ។

[161] ធម៌មានផស្សៈជាគំរប់ ៥ ។

ម្យ៉ាងទៀតក្នុងការកំណត់ដឹងនូវរូបធម៌នោះ កាលបើ**អរូបធម៌**[162] ទាំងឡាយមិនទាន់កើតឡើងទេ ព្រះយោគីកុំគប្បីលះបង់នូវការកំណត់នូវ**រូបធម៌**នោះឡើយ ត្រូវតែព្យាយាមក្នុងការកំណត់ដឹងនូវរូបធម៌នោះឱ្យរឿយៗ រហូត លុះដល់**អរូបធម៌**ទាំងនោះកើតឡើងហើយ ទើបគួរលះបង់ការកំណត់ដឹងនូវ**រូបធម៌**ទៅកំណត់ដឹងនូវ**អរូបធម៌**ថាជា**នាមធម៌** ។ ក្នុង **វិសុទ្ធិមគ្គ** ភាគ ៤ មានសេចក្ដីបញ្ជាក់ថា **សចេ បនស្ស តេន តេន មុខេន រូបំ បរិគ្គហេត្វា អរូបំ បរិគ្គណ្ហតោ សុខុមត្តា អរូបំ ន ឧបដ្ឋាតិ តេន ធុរនិក្ខេបំ អកត្វា រូបមេវ បុនប្បុនំ សម្មសិតព្វំ មនសិកាតព្វំ បរិគ្គហេតព្វំ វវត្ថបេតព្វំ ។ យថា យថា ហិស្ស រូបំ សុវិក្ខាលិតំ ហោតិ និជ្ជដំ សុបរិសុទ្ធំ តថា តថា តទារម្មណា អរូបធម្មា សយមេវ ចាកដា ហោន្តិ ។**

មានសេចក្ដីថា: ក៏ប្រសិនបើ កាលដែលព្រះយោគីកំណត់ដឹងនូវ**រូបធម៌**តាមមុខនោះៗ ហើយទើបកំណត់ដឹងនូវ**អរូបធម៌**ជាខាងក្រោយ **អរូបធម៌**មិនទាន់តាំងឡើងទេ ព្រោះភាពនៃ**អរូបធម៌**ជាធម្មជាតិល្អិត ព្រះយោគីមិនត្រូវធ្វើនូវការដាក់ធុរៈក្នុងការកំណត់ដឹងនូវ**រូបធម៌**ឡើយ គប្បីពិចារណាធ្វើទុកក្នុងចិត្តកំណត់ដឹងនូវរូបនោះតែម្យ៉ាងឱ្យរឿយៗ ព្រោះថារូបដែលព្រះយោគីដុសខាត់

[162] ធម៌មានផស្សៈជាគម្រប់ ៥ ។

ល្អហើយ ជារូបគ្មានបណ្ដាញ ជារូបបរិសុទ្ធ កើតឡើងយ៉ាងណាៗ **អរូបធម៌**ទាំងឡាយដែលមានរូបនោះជាអារម្មណ៍ កើតឡើងប្រាកដដោយខ្លួនឯងតែម្យ៉ាងយ៉ាងនោះៗ ។

ម្យ៉ាងទៀត កាលដែលព្រះយោគីថ្មីៗ បានពិចារណាធ្វើទុកក្នុងចិត្តនូវលក្ខណៈនៃ**រូបធម៌**, **រូបធម៌**មួយ ឬពីរបានតាំងឡើងប្រាកដដល់ប្រាជ្ញានៃខ្លួនព្រះយោគីថ្មីៗ នោះ មិនត្រូវលះបង់ក្នុងការកំណត់ដឹងនូវលក្ខណៈនៃ**រូបធម៌** ហើយទៅពិចារណាកំណត់ដឹង នូវលក្ខណៈនៃ**អរូបធម៌**នោះភ្លាមឡើយ ព្រោះថាកាលបើរូបធម៌មួយ ឬពីរ បានតាំងឡើង ដល់ប្រាជ្ញានៃព្រះយោគីជាដំបូងហើយ ព្រះយោគីដែលទើបតែហាត់រៀនថ្មីៗ នោះចង់បានសម្រេចធម៌ឆាប់ៗ រួសរាន់ពេកក៏លះបង់នូវការពិចារណាកំណត់ដឹងនូវ **រូបធម៌** ទៅពិចារណាកំណត់ដឹងនូវ**អរូបធម៌**ថាជា**នាមធម៌**ភ្លាមនោះ ធ្វើដូច្នេះព្រះយោគីនោះត្រូវសាបសូន្យចាក**កម្មដ្ឋាន** **កម្មដ្ឋាន** មិនបានកើតរីកចម្រើនទូលំទូលាយឡើយ ។

ក្នុងវិសុទ្ធិមគ្គភាគ ៣ មានសេចក្ដីបញ្ជាក់ថា **សចេ ហិ ឯកស្មឹ វា រូបធម្មេ ឧបដ្ឋិតេ ទ្វីសុ វា រូបំ បហាយ អរូបបរិគ្គហំ អារភតិ កម្មដ្ឋានតោបិ បរិហាយតិ ។**

សេចក្ដីថាៈ ក៏ប្រសិនបើកាលដែល**រូបធម៌**មួយឬពីរ បានតាំងឡើងដល់ប្រាជ្ញានៃព្រះយោគី ព្រះយោគីក៏លះបង់នូវរូបហើយទៅប្រារព្ធកំណត់ដឹងនូវអរូបវិញ ក៏រមែងសាបសូន្យចាក **កម្មដ្ឋាន** ។

សុវិសុទ្ធរូបបរិគ្គហសេន បន អរូបបរិគ្គហាយ យោគំ ករោតោ កម្មដ្ឋានំ វុឌ្ឍឹ វិរុឡ្ហឹ វេបុល្លំ ចាបុណាតិ ។

ក៏ដែលព្រះយោគីធ្វើនូវសេចក្ដីព្យាយាម ដើម្បីកិរិយាកំណត់ដឹងនូវអរូប ដោយអំណាចនៃកិរិយាកំណត់ដឹងនូវរូបដ៏បរិសុទ្ធ **កម្មដ្ឋាន**ក៏រមែងដល់នូវសេចក្ដីរីកចម្រើនទូលំទូលាយឡើង ។

អាស្រ័យដោយហេតុសេចក្ដីនេះ ព្រះយោគីកាលបើធ្វើការកំណត់ដឹងនូវរូបដទៃទៀតឱ្យបានច្រើនតាមលំដាប់ រហូតលុះដល់ប្រាជ្ញាស្ទាត់ជំនាញក្នុងការកំណត់ដឹងនូវលក្ខណៈនៃរូប កាលបើព្រះយោគីធ្វើយ៉ាងនេះហើយ **អរូបធម៌**ដែលមានរូបនោះៗ ជាអារម្មណ៍ ក៏ផុសផុលកើតចម្រើនឡើងតាំងនៅដោយប្រពៃ **អរូបធម៌**ឯណាដែលកើតឡើងតាំងនៅដោយប្រពៃយ៉ាងនេះ **អរូបធម៌**នោះនឹងបានមកជាអារម្មណ៍នៃប្រាជ្ញា តាំងនៅមិនរលត់ ក្នុងខណៈដែលព្រះយោគីលះបង់នូវការកំណត់ដឹងនូវរូប ហើយមកកំណត់ដឹងនូវ **អរូបធម៌** វិញ ។

បន្ទាប់អំពីនេះទៅ សូមលើកនូវរបៀបប្រតិបត្តិដើម្បីកំណត់ដឹងនូវ **នាម** និង **រូប** ដូចតទៅៈ

ព្រះយោគីដែលបានចម្រើននូវព្រះ**អានាបានស្សតិកម្មដ្ឋាន** បានសម្រេចដល់គុណគឺ**ឧបេក្ខាចិត្ត**ក្ដី ព្រះយោគីដែលបានចម្រើន**កម្មដ្ឋាន**ដទៃមាន **ពុទ្ធានុស្សតិ**ជាដើម បានសម្រេចដល់គុណគឺ **ឧបចារជ្ឈាន** ក្ដី និងព្រះយោគីដែលជា**សុទ្ធវិបស្សនាយានិកក្ដី** ដែលត្រូវចម្រើននូវ **វិបស្សនាកម្មដ្ឋាន**នោះ ត្រូវប្រតិបត្តិដូចតទៅៈ

**សមថយានិក**យោគី គប្បីហាត់ឈានដែលខ្លួនបានហើយឱ្យស្ទាត់ជំនាញល្អដោយវសីទាំង ៥ កាលបើស្ទាត់ជំនាញល្អហើយ បន្ទាប់មកគប្បីចេញចាកឈាន គឺចេញចាកអារម្មណ៍របស់សមថ ដែលខ្លួនសម្លឹងហើយនោះ បង្វែរ**សតិ**និង**បញ្ញា** ធ្វើការរលឹកពិចារណានូវលក្ខណៈនៃ **រូបធម៌** ។

រីឯ**សុទ្ធវិបស្សនាយានិក**យោគី ដែលមិនបានចម្រើន**សមថកម្មដ្ឋាន** ជាមុនហើយចម្រើន**វិបស្សនា**តែម្តង ក៏គប្បីប្រមូលចិត្តដាក់នៅក្នុងដើមទ្រូងសង្កត់ចិត្តធ្វើចិត្តឱ្យស្ងប់រម្ងាប់ចាក**នីវរណធម៌** ឬក៏កិលេសទាំងពួងជាមុនសិនទើបគួរដល់ការចម្រើននូវ **វិបស្សនា** ព្រោះថាក្នុងសម័យដែលកិលេសកំពុងគ្របសង្កត់ចិត្តនោះសតិរលត់ ប្រាជ្ញាមិនកើត ។

**ព្រះពុទ្ធសម្តែងថា:**

- **សមយេ ចិត្តំ បគ្គណ្ហាតិ** ផ្គងចិត្តឡើងក្នុងសម័យដែលគួរ គឺចម្រើននូវ **ធម្មវិចយសម្ពោជ្ឈង្គ** **វិរិយសម្ពោជ្ឈង្គ** និង **បីតិសម្ពោជ្ឈង្គ** ក្នុងសម័យដែលចិត្តរួញរា ។
- **សមយេ ចិត្តំ និគ្គណ្ហាតិ** ផ្ចុញចិត្តក្នុងសម័យដែលគួរ គឺចម្រើននូវ **បស្សទ្ធិសម្ពោជ្ឈង្គ** **សមាធិសម្ពោជ្ឈង្គ** និង **ឧបេក្ខាសម្ពោជ្ឈង្គ** ក្នុងសម័យ ដែលចិត្តកំពុងរាយមាយ ។
- **សមយេ ចិត្តំ សម្បហំសេតិ** កម្លាចិត្តក្នុងសម័យដែលគួរ គឺញ៉ាំងឱ្យស្លុត ដោយពិចារណានូវសង្វេគវត្ថុ ៨ យ៉ាង ឬឱ្យជ្រះថ្លា ដោយរឭកដល់**ពុទ្ធាទិគុណ** ។

- **សមយេ ចិត្តំ អជ្ឈុបេក្ខតិៈ** ទប់ចិត្តតម្រង់ទុកក្នុងសម័យដែលគួរ គឺមិនខ្វល់ខ្វាយ ផ្គងឡើង ផ្ចុញចុះ ឬកម្លាឡើងក្នុងសម័យដែលចិត្តប្រព្រឹត្តទៅស្មើត្រង់តាមវិថីរបស់សមថៈហើយ ។

ក្នុងការរលឹកពិចារណានូវលក្ខណៈនៃសភាវធម៌នោះ មានដំណើរច្រើនបែបច្រើនយ៉ាងណាស់ ទៅតាមអធ្យាស្រ័យរបស់ព្រះយោគី តែក្នុងទីនេះសូមលើកយក របៀបប្រតិបត្តិតែមួយបែប មានសេចក្តីដូចតទៅៈ

ជាដំបូងព្រះយោគីគប្បីពិចារណាធ្វើទុកក្នុងចិត្ត ក៏កំណត់ដឹង កំណត់ទុករឿយៗ នូវលក្ខណៈរបស់ **វាយោធាតុ** ។

**វាយោធាតុ** ក្នុង **អភិធម្ម**មាន ៦ យ៉ាងគឺខ្យល់ ដែលផាត់ឡើងទៅខាងលើ ១, ខ្យល់ដែលផាត់ចុះខាងក្រោម ១, ខ្យល់ដែលផាត់នៅខាងក្រៅពោះវៀន ១, ខ្យល់ដែលផាត់នៅខាងក្នុងពោះវៀន ១, ខ្យល់ដែលផាត់ផ្សាយទៅសព្វសព៌ាង្គកាយ ១, ខ្យល់ដកដង្ហើមចេញនិង ខ្យល់ដកដង្ហើមចូល ១, ខ្យល់ទាំងនេះ បើពោលពីលក្ខណៈ មានតែមួយរួមគ្នា គឺល្ហើយៗ ព្រះយោគី គប្បីរលឹកពិចារណានូវលក្ខណៈរបស់**វាយោធាតុ**តែម្យ៉ាងប៉ុណ្ណោះ មិនគប្បីរលឹកពិចារណានូវប្រភេទនៃខ្យល់ ៦ នោះឡើយ ។

កាលបើព្រះយោគី ធ្វើការរលឹកពិចារណានូវលក្ខណៈ **វាយោធាតុ** នោះ មិនយូរប៉ុន្មានក៏នឹងអាចកំណត់ដឹងច្បាស់នូវ **លក្ខណៈវាយោធាតុ**នោះបានពិតប្រាកដ កាលបើធាតុខ្យល់ចេះតែផ្សាយឡើងពេញសព៌ាង្គកាយព្រះយោគីគប្បីសន្សំសន្សឹម ។

ក្នុងការកំណត់ដឹងនូវលក្ខណៈ**វាយោធាតុ**នោះ ឱ្យបានសព្វគ្រប់ចេះតែកំណត់ដឹង រហូតដល់បានឃើញជាក់ច្បាស់នូវ**លក្ខណៈវាយោធាតុ** ដែលផ្សាយនោះពេញសព៌ាង្គកាយទាំងអស់ ។

ក្នុងការកំណត់ដឹងនូវ**លក្ខណៈវាយោធាតុ**នោះ គឺព្រះយោគី គប្បីសន្សំក្នុងការដឹងឱ្យបានគ្រប់ឥរិយាបថទាំង ៤, គ្រប់កន្លែង, គ្រប់ពេលវេលាទាំងអស់ក្នុងយប់ ១ ថ្ងៃ ១ រហូតលុះដល់ប្រាជ្ញាភ្លឺស្វាងឃើញជាក់ច្បាស់នូវ**លក្ខណៈរូបវាយោធាតុ**នោះ ដោយឥតសង្ស័យស្ទាក់ស្ទើរក្នុងចិត្តកើតឡើង ។ កាលបើរូប ១ គឺ**វាយោធាតុ** ព្រះយោគីបានដឹងជាក់ច្បាស់ដោយប្រាជ្ញានៃខ្លួនហើយ បន្ទាប់មកគប្បីបង្វែរសតិនិងប្រាជ្ញា ធ្វើការរលឹកពិចារណា **បឋវីធាតុ អាបោធាតុ តេជោធាតុ** តាមលំដាប់មានរបៀបដូចដំណើរ ក្នុងការកំណត់ដឹងនូវ**លក្ខណៈវាយោធាតុ** បន្តទៅទៀត ។

កាលបើព្រះយោគី ធ្វើការរលឹកពិចារណានូវលក្ខណៈ មាន**បឋវីធាតុ**ជាដើមហើយមិនយូរប៉ុន្មាន ក៏នឹងអាចកំណត់ដឹងនូវលក្ខណៈនៃធាតុទាំងនោះបានជាក់ច្បាស់ ដោយពិតប្រាកដ ។

កាលបើលក្ខណៈ នៃធាតុទាំងនោះបានមកប្រាកដដល់ប្រាជ្ញានៃព្រះយោគីដោយពិតហើយ ព្រះយោគីគប្បីហាត់រលឹកកំណត់ដឹងនូវ**លក្ខណៈធាតុ**ទាំង ៤គឺ **ធាតុដី** ១, **ធាតុទឹក** ១, **ធាតុភ្លើង** ១, **ធាតុខ្យល់** ១ នោះឱ្យបានស្ទាត់ភ្លឺស្វាងជាក់ច្បាស់ល្អរហូតលុះដល់ប្រាជ្ញាអាចកំណត់ដឹងនូវលក្ខណៈ នៃធាតុណាមួយក្នុងធាតុទាំង ៤ ដែលតាំងប្រាកដឡើងដល់ប្រាជ្ញានៃខ្លួន ។

កាលបើព្រះយោគី មានប្រាជ្ញាសម្រេចល្អហើយដូច្នោះ បន្ទាប់មកព្រះយោគីគប្បីប្រមូលមកនូវរូបទាំងនោះដោយប្រាជ្ញា ហើយគប្បីពិចារណាធ្វើទុកក្នុងចិត្ត កំណត់ដឹងកំណត់ទុកថា រូបរាងកាយទាំងមូលនេះ មានត្រឹមតែធាតុ ៤ ប៉ុណ្ណោះ មិនមានតួសត្វ បុគ្គលជាដើមឡើយ ។

កាលដែលព្រះយោគី បានកំណត់ដឹងនូវលក្ខណៈនៃធាតុទាំង ៤ តាមលំដាប់នោះ **អរូបធម៌**ទាំងឡាយមាន**ផស្សៈ**ជាគម្រប់ ៥ ក៏តាំងឡើងប្រាកដតាមលំដាប់ដែរ ក្នុងទីបំផុតដែលព្រះយោគីបានសម្រេចនូវប្រាជ្ញាដែលឃើញច្បាស់ក្នុងរូបរាងកាយនេះមានត្រឹមតែធាតុៗ ប៉ុណ្ណោះ មិនមានតួសត្វបុគ្គលជាដើមឡើយ បន្ទាប់មកព្រះយោគីគប្បីរំពឹងពិចារណាវាវរកនូវអរូបធម៌ដែលមានរូបនោះជាអារម្មណ៍ ដែលកើតឡើងហើយមកជាអារម្មណ៍ម្តង ។

ព្រះយោគី គប្បីពិចារណាធ្វើទុកក្នុងចិត្ត កំណត់ដឹង កំណត់ទុកនូវលក្ខណៈនៃ**អរូបធម៌**មាន**ផស្សៈ** ជាដើមនោះ ឱ្យបានឃើញច្បាស់លាស់ទាំងអស់ កាលបើបានឃើញច្បាស់លាស់ហើយ ក៏គប្បីប្រមូលនូវ**អរូបធម៌**ទាំងនោះកំណត់ថាជា**នាមធម៌**ដោយ អត្ថថាឱនទៅកាន់អារម្មណ៍ ។

កាលបើព្រះយោគី មានប្រាជ្ញាសម្រេចហើយដោយការឃើញនូវ **នាមធម៌** ដូច្នេះ បន្ទាប់មកព្រះយោគី គប្បីពិចារណាកំណត់ដឹងធ្វើទុកក្នុងចិត្ត កំណត់ដឹង កំណត់ទុកបន្តទៅទៀតថា:

ក្នុងអត្តភាពនេះ មានត្រឹមតែរូប[163] **ធម៌** និង **នាម**[164] **ធម៌** ប៉ុណ្ណោះ មិនមានតួសត្វ បុគ្គល ប្រុសស្រី មនុស្ស ទេវតាជាដើមឡើយ ។

---

163 រូបដោយអត្ថថា បែកធ្លាយ ។

កាលបើព្រះយោគី បានកំណត់ដឹងនូវ**នាមនិងរូប**តាម**មនោទ្វារ**ដូចបានពោលដូច្នោះហើយគប្បីសិក្សា**វិបស្សនា**ដោយកំណត់ដឹងនូវ**នាមនិងរូប** តាមទ្វារទាំង ៦ បន្តទៅទៀត ។

សេចក្តីថាៈ កាលបើ ***វណ្ណរូប*** មកប៉ះខ្ទប់នឹងចក្ខុបសាទក្នុងខណៈណា ព្រះយោគីគប្បីកំណត់ដឹងនូវ ***វណ្ណរូប*** នោះ ដោយឃើញត្រឹមតែ***វណ្ណរូប***ប៉ុណ្ណោះ ដោយប្រាជ្ញានៃខ្លួនក្នុងខណៈនោះ ។

- កាលបើ ***សទ្ទរូប*** មកប៉ះខ្ទប់នឹង***សោតបសាទ***ក្នុងខណៈណា ព្រះយោគីកំណត់ដឹងនូវសំឡេងនោះ ដោយឃើញត្រឹមតែសំឡេងនោះប៉ុណ្ណោះ ដោយប្រាជ្ញានៃខ្លួនក្នុងខណៈនោះ ។

កាលបើ **គន្ធរូប** មកប៉ះខ្ទប់នឹង **ឃានបសាទ** ក្នុងខណៈណា ព្រះយោគីគប្បីកំណត់ដឹងនូវក្លិននោះ សោយឃើញត្រឹមតែក្លិនប៉ុណ្ណោះ ដោយប្រាជ្ញានៃខ្លួនក្នុងខណៈនោះ ។

- កាលបើ ***រសរូប*** មកប៉ះខ្ទប់នឹង **ជិវ្ហាបសាទ** ក្នុងខណៈណា ព្រះយោគី កំណត់ដឹងនូវ ***រស*** នោះ ដោយឃើញត្រឹមតែរសជាតិនោះប៉ុណ្ណោះ ដោយប្រាជ្ញានៃខ្លួនក្នុងខណៈនោះ ។

---

164 នាមដោយអត្ថថា ឱនទៅកាន់អារម្មណ៍ ។

កាលបើ **បឋវី** [165] **តេជោធាតុ** មកប៉ះខ្ទប់នឹង **កាយបសាទ** ក្នុងខណៈណា ព្រះយោគីគប្បីកំណត់ដឹងនូវ ដី ភ្លើង ខ្យល់ នោះ ដោយឃើញត្រឹមតែដី ភ្លើង ខ្យល់នោះប៉ុណ្ណោះ ដោយប្រាជ្ញានៃខ្លួនក្នុងខណៈនោះ ។

កាលបើ **អាបោធាតុ** ឬ **ឱជរូប** ឬថារូបដទៃ មកប្រាកដដល់ **ចិត្ត** ក្នុងខណៈណា ព្រះយោគីគប្បីកំណត់ដឹងនូវទឹក ឱជឬរូបដទៃនោះដោយឃើញត្រឹមតែទឹក-ឱជ-រូបដទៃនោះប៉ុណ្ណោះ ដោយប្រាជ្ញានៃខ្លួនក្នុងខណៈនោះ ។

កាលបើព្រះយោគី បានសិក្សាក្នុងការកំណត់ដឹងនូវ **បរមត្ថ** ដែលមកប្រាកដដល់ទ្វារទាំង ៦ បានយល់ជាក់ច្បាស់ហើយ គប្បីកំណត់ដឹងនូវ **នាមបរមត្ថ** ដែលមាន **បរមត្ថ** នោះជាអារម្មណ៍បន្ថែមទៀត មានសេចក្ដីដូចតទៅនេះ៖

ប្រាជ្ញានៃព្រះយោគីគប្បីកំណត់ដឹងឱ្យឃើញជាក់ច្បាស់ដូចតទៅនេះថា

**រូបពណ៌** ដែលមកប៉ះខ្ទប់នឹង **ចក្ខុបសាទ** ប្រាជ្ញាដឹងទាន់ថាជាតួរូបក្រុម **ធម៌** ដែលមាន **ផស្សៈ** ជាគម្រប់ ៥ ដែលមាន **រូបពណ៌** នោះជា **អារម្មណ៍** ប្រាជ្ញាកំណត់ដឹងទាន់ថាជាតួ **នាម** ។

សំឡេងមកប៉ះខ្ទប់នឹង **សោតបសាទ** ប្រាជ្ញាកំណត់ដឹងទាន់ថាជាតួ **រូប** ក្រុម **ធម៌** មាន **ផស្សៈ** ជាគម្រប់ ៥ ដែលមានសម្លេងនោះជាអារម្មណ៍ប្រាជ្ញាកំណត់ដឹងទាន់ថាជាតួ **នាម** ។

---

[165] បឋវីធាតុ តេជោធាតុ វាយោធាតុក្ដី ដែលស្ថិតនៅព្វដ៏ខាងក្រៅខ្លួន ។

**ក្លិន** ដែលមកប៉ះខ្ទប់នឹង **ឃានបសាទ** ប្រាជ្ញាកំណត់ដឹងទាន់ថាជាតួ **រូប** ក្រុម **ធម៌** មាន **ផស្សៈ** ជាគម្រប់ ៥ ដែលមានក្លិននោះជាអារម្មណ៍ ប្រាជ្ញាកំណត់ដឹងទាន់ថាជាតួនាម ។

**រសជាតិ** ដែលមកប៉ះខ្ទប់នឹង **ជិវ្ហាបសាទ** ប្រាជ្ញាកំណត់ដឹងទាន់ថាជាតួ **រូប** ក្រុម **ធម៌** មាន **ផស្សៈ** ជាគម្រប់ ៥ ដែលមាន **រស** នោះជាអារម្មណ៍ ប្រាជ្ញាកំណត់ដឹងទាន់ថាជាតួនាម ។

**ដីក្តី ភ្លើងក្តី ខ្យល់ក្តី** ដែលមកប៉ះខ្ទប់នឹង **កាយបសាទ** ប្រាជ្ញាកំណត់ដឹងទាន់ថាជាតួ **រូប** ក្រុម **ធម៌** មាន **ផស្សៈ** ជាគម្រប់ ៥ ដែលមានដីក្តី, ភ្លើងក្តី, ខ្យល់ក្តីជាអារម្មណ៍ ប្រាជ្ញាកំណត់ដឹងទាន់ថាជាតួ **នាមធម៌** ។

**ទឹកក្តី, ឱជក្តី** ឬរូបដទៃ ដែលមកប្រាកដដល់ **ចិត្ត** ប្រាជ្ញាកំណត់ដឹងទាន់ថាជាតួ **រូប** ក្រុម **ធម៌** មាន **ផស្សៈ** ជាគម្រប់ ៥ ដែលមានរូបនោះជាអារម្មណ៍ ប្រាជ្ញាកំណត់ដឹងទាន់ថាជាតួ **នាម** ។

ក្នុងការកំណត់ដឹងនូវ **រូបធម៌** នាមធម៌ដូចបានពោលមកហើយនេះ ក្នុងការកំណត់ដឹងនូវ **រូបធម៌** នោះ ខ្ញុំបានពោលពន្យល់នូវរបៀបរួចហើយ ក្នុងទីនេះសូមពន្យល់ នូវរបៀបក្នុងការកំណត់ដឹងនូវ **នាមធម៌** ម្តង ។

មានសេចក្តីថាៈ ក្នុងការកំណត់ដឹងនូវ **អរូបធម៌** ថាជា **នាមធម៌** នោះព្រះយោគី គប្បីធ្វើការសង្កេតពិចារណា ដោយប្រុងសតិប្រាជ្ញាត្រង់ទ្វារមួយៗតាមលំដាប់ដែលជាទីប៉ះខ្ទប់នៃរូបនោះ ឱ្យណាស់រង់ចាំមើលអរូបធម៌ដែលតាំងឡើងដោយមានរូបនោះជាអារម្មណ៍ មុនដំបូងកំណត់ដឹងទាន់ខ្លះ ដឹងមិនទាន់ខ្លះ

ដោយប្រាជ្ញានៅទន់ ព្រោះ **អរូបធម៌** ជាធម្មជាតិល្អិត តែបើយោគីឧស្សាហ៍ព្យាយាមក្នុងការដឹងនូវ **អរូបធម៌** នោះមិនយូរប៉ុន្មាន ក៏នឹងអាចដឹងដោយពិតប្រាកដបាន, **អរូបធម៌** កាលប្រាជ្ញានៅទន់ ព្រះយោគីកំណត់ដឹងទាន់ខ្លះ ដឹងមិនទាន់ខ្លះតែដោយការព្យាយាម ហាត់ក្នុងការដឹងញឹកៗ ញយៗ តាមទ្វារម្តងមួយៗ តាមលំដាប់ទ្វាររហូតដល់ទាំង ៦ ទៅ ប្រាជ្ញាក៏កាន់តែចាស់ក្លាបន្តិចម្តងៗ រហូតលុះដល់រលឹកដឹងទាន់នូវ **អរូបធម៌** នោះគ្រប់ទ្វារទាំងអស់បាន ។

កាលបើព្រះយោគី អាចនឹងកំណត់ដឹងនូវ **អរូបធម៌** ដែលមានរូបជាអារម្មណ៍ ដែលកើតតាមទ្វាទាំង ៦ បានសម្រេចហើយ បន្ទាប់មកព្រះយោគីគប្បីហាត់កំណត់ ដឹងនូវ ***រូប*** និង ***អរូប*** ទាំងពីរនេះតាមលំដាប់ទ្វារមួយៗ ថែមទៀត ។

***រូប*** និង ***អរូបធម៌*** នេះ កាលប្រាជ្ញានៅទន់ ព្រះយោគីកំណត់ដឹងទាន់ខ្លះ ដឹងមិនទាន់ខ្លះ តែដោយសេចក្តីឧស្សាហ៍ព្យាយាមហាត់រឿយៗទៅលុះដល់ប្រាជ្ញាចាស់ក្លា ព្រះយោគីអាចកំណត់ដឹងបានដោយធូរស្រួលមិនលំបាក ។

កាលបើព្រះយោគី បានប្រតិបត្តិតាមផ្លូវ **វិបស្សនា** ដូចបានពោលមកហើយយ៉ាងនេះ បន្ទាប់អំពីនេះទៅព្រះយោគីគប្បីកំណត់ដឹងធ្វើឱ្យជាក់ច្បាស់នូវនាមនិងរូបឱ្យបានគ្រប់ទ្វារ គ្រប់អារម្មណ៍ គ្រប់**ឥរិយាបថ** គ្រប់សម័យ និងគ្រប់ពេលវេលាបន្តថែមទៀត ។

កាលបើប្រាជ្ញាបានចាក់ធ្លុះនូវលក្ខណៈ សភាវធម៌ដូចបានពោលរួចមកហើយ បន្ទាប់មកព្រះយោគី គប្បីពិចារណាធ្វើទុកក្នុងចិត្ត កំណត់ដឹង កំណត់ទុកថាអត្តភាពក្នុងបច្ចុប្បន្នក្តី អត្តភាពក្នុងអតីតក្តី និងអត្តភាពក្នុងអនាគតក្តី

មានត្រឹមតែនាម និងរូបប៉ុណ្ណោះ មិនមានសត្វ បុគ្គល ស្រី ប្រុស មនុស្ស ទេវតា ជាដើមដូចគ្នាឡើយ ។

កាលបើព្រះយោគី បានកំណត់ដឹងនូវ **នាមរូប** ចំពោះសភាវធម៌ដែលមកប្រាកដតាមទ្វារទាំង ៦ ដូច្នេះហើយ ព្រះយោគីអង្គនោះក៏នឹងលះបង់នូវសេចក្ដីសម្គាល់ក្នុងលោកថា សត្វបុគ្គលជាដើមបាន ហើយបានដំកល់នូវចិត្តស្ថិតនៅស៊ប់ក្នុងភូមិដែលមិនវង្វេង ។

ព្រះយោគីអង្គនោះ ឈ្មោះថាជាអ្នកមានសម្មាទិដ្ឋិ បានលុះក្នុងវិបស្សនាបញ្ញាដោយពិត ។

## កំណត់ដឹងនូវបច្ច័យរបស់នាមរូប

ពេទ្យអ្នកឈ្លាសវៃ ឃើញនូវរោគអ្នកជម្ងឺ ក៏ស្វែងរកនូវ **សមុដ្ឋាន** នៃរោគនោះយ៉ាងណា បុរសអ្នកប្រកបដោយសេចក្ដីករុណា ឃើញនូវទារកដ៏ក្មេងខ្ចីកំពុងដេកផ្ងារ ក្នុងព្រៃស្មសានហើយក៏ធ្វើការពិចារណា ថាតើ **មាតាបិតា** របស់ទារកនេះមួយណាហ្ន៎យ៉ាងណា ព្រះយោគីកាលបើកំណត់ដឹងនូវ **នាមរូប** ហើយក៏ពិចារណារកនូវហេតុបច្ច័យរបស់នាមរូបនោះក៏យ៉ាងនោះដូចគ្នា, ការពិចារណារកនូវហេតុបច្ច័យរបស់នាមរូបក្នុងវិបស្សនានេះ ព្រះយោគីត្រូវពិចារណារកហេតុបច្ច័យរបស់ **រូបកាយ** ជាមុនសិនទើបពិចារណារកបច្ច័យរបស់ **នាមកាយ** ជាខាងក្រោយ ។

ហេតុបច្ច័យរបស់ **រូបកាយ** មាន ៥ គឺ **អវិជ្ជា** ១, **តណ្ហា** ១, **ឧបាទាន** ១, **កម្ម** ១, **អាហារ** ១ ។

- អវិជ្ជា សេចក្ដីល្ងង់ខ្លៅ ។
- តណ្ហា សេចក្ដីប្រាថ្នា, សេចក្ដីតក់ស្លុតក្នុងអារម្មណ៍ ។
- ឧបាទាន សេចក្ដីប្រកាន់មាំក្នុងអារម្មណ៍ ។
- កម្ម អំពើល្អ និង អំពើអាក្រក់ ។
- អាហារ **កវឡិង្ការាហារ** បានដល់ដុំបាយ ទឹក នំ ចំណី ជាដើម ដែលបុគ្គលបរិភោគលេបចូលទៅកន្លងបំពង់ក ។

## បច្ច័យនៃនាមកាយ៥

- **ចក្ខុវិញ្ញាណ** កើតឡើងព្រោះអាស្រ័យភ្នែកផង រូបទាំងឡាយផង ។
- **សោតវិញ្ញាណ** កើតឡើងព្រោះអាស្រ័យត្រចៀកផង សម្លេងផង ។
- **ជិវ្ហាវិញ្ញាណ** កើតឡើងព្រោះអាស្រ័យអណ្ដាតផង រសជាតិផង ។
- **កាយវិញ្ញាណ** កើតឡើងព្រោះអាស្រ័យកាយផង ផោដ្ឋព្វៈផង ។
- **មនោវិញ្ញាណ** កើតឡើងព្រោះអាស្រ័យចិត្តផង ធម៌ផង ។

ព្រះយោគី គប្បីពិចារណារកហេតុបច្ច័យរបស់ **នាមរូប** មានសេចក្ដីដូចតទៅនេះ៖ ត្រូវពិចារណា **រូបកាយ** កាលកើតឡើង រមែងមិនកើតឡើងក្នុងទីចន្លោះដ៏ល្អ មានក្លិនក្រអូប មានផ្កាឈូកជាដើម ឬក្នុងបន្ទប់នៃរតនវត្ថុ មានបន្ទប់កែវមណីជាដើមឡើយ ។

ធម្មទាន

តាមសេចក្ដីពិតនោះ **រូប** នោះរមែងកើតឡើងក្នុងទីចង្អៀត មានក្លិនអាក្រក់គួរខ្ពើមក្រៃពេក ស្ថិតនៅក្នុងចន្លោះក្រពះអាហារថ្មីនិងក្រពះអាហារចាស់មានមុខទៅឆ្អឹងខ្នងម្ដាយ មានខ្នងបែរទៅរកដំបារពោះម្ដាយរុំព័ទ្ធដោយពោះវៀនធំ ដូចជាហ្វូងដង្កូវកើតក្នុងរណ្ដៅលាមកជាដើម ដោយពិត **រូបកាយ** នេះកើតឡើងដោយ **ធម៌** ៤ យ៉ាងគឺ

**ធម៌** ៣ គឺ **អវិជ្ជា** ១, **តណ្ហា** ១, **ឧបាទាន** ១, ជាហេតុនាំឱ្យកើតឡើងនៃ **រូបកាយ** ទុកជា **មាតា** ជាទីចូលទៅអាស្រ័យនៃទារក ។

**កម្ម** ជាធម្មជាតិ ញុំាងរូបឱ្យកើតឡើងទុកដូចជា **មាតា** អ្នកបង្កើតនូវទារក។

អាហារជាបច្ច័យនៃរូបនេះ ទុកដូចជាមេនំ អ្នកបម្រើបីបមថែទាំផ្ដូតទឹកបក់ផាត់ ជាដើមដល់ទារក ។

កាលបើព្រះយោគីពិចារណា នូវហេតុបច្ច័យរបស់ **រូបកាយ** រួចហើយបន្ទាប់មកព្រះយោគីគប្បីពិចារណានូវបច្ច័យ របស់ **នាមកាយ** តទៅទៀត ។

ត្រូវពិចារណាថា **ចក្ខុវិញ្ញាណ** កើតឡើងព្រោះអាស្រ័យភ្នែកផង រូបទាំងឡាយផង ។ល។ **មនោវិញ្ញាណ** កើតឡើងព្រោះអាស្រ័យ **ចិត្ត** ផង **ធម៌** ផង ។

កាលបើព្រះយោគី បានធ្វើការពិចារណានូវហេតុបច្ច័យរបស់ **នាមរូប** ដូច្នេះហើយ បន្ទាប់មកត្រូវពិចារណានូវ **នាមរូប** ព្រមទាំងហេតុបច្ច័យប្រកបដោយកាលទាំង ៣ ថែមទៀត ។

ត្រូវពិចារណាថាៈ **នាម** និង **រូប** ក្នុងកាលបច្ចុប្បន្ននេះ កាលកើតឡើងក៏ព្រោះអាស្រ័យនូវហេតុបច្ច័យ ទើបកើតឡើងបាន កាលរលត់ទៅវិញក៏ព្រោះតែរលត់ទៅនៃហេតុបច្ច័យ, សូម្បី **នាម** និង **រូប** ក្នុងកាលជាអតីតក្តី អនាគតក្តី កាលកើតឡើងក៏ព្រោះអាស្រ័យនូវហេតុបច្ច័យ ទើបកើតឡើងបាន កាលរលត់ទៅក៏ព្រោះតែរលត់ទៅនៃហេតុបច្ច័យដូចគ្នា ។

នាមរូបនេះជាធម្មជាតិ កើតរលត់តាមហេតុបច្ច័យទាំងអស់ មិនមានជនណាម្នាក់ក្នុងលោកមានព្រះឥសូរ ព្រះអាទិទេពជាដើមជាអ្នកបង្កើតឡើយ ។

កាលបើព្រះយោគី បានពិចារណាឃើញនូវហេតុបច្ច័យរបស់ **នាមរូប** ដែលប្រព្រឹត្តទៅក្នុងកាលទាំងបី ដោយប្រាជ្ញានៃខ្លួនដូច្នេះហើយ ព្រះយោគីនោះក៏បានឆ្លងនូវសេចក្តីសង្ស័យ [166] ក្នុងជាតិកំណើត ក្នុងសំសារវដ្តទាំងអស់ដោយពិត ព្រះយោគី នោះនិងបានឈ្មោះថា "**ចុល្លសោតាបន្ន**" [167] ក្នុងព្រះពុទ្ធសាសនានេះហោង ។

## ការចម្រើនវិបស្សនា

កាលបើព្រះយោគី បានកំណត់ដឹងនូវ **នាមរូប** ព្រមទាំងបច្ច័យឆ្លងផុតនូវសេចក្តីសង្ស័យក្នុងកាលទាំង ៣ ហើយបន្ទាប់មកគប្បីចម្រើន **វិបស្សនា** ប្រកបដោយត្រៃលក្ខណ៍តាមទ្វារទាំង ៦ តទៅទៀត ។

---

166 វិសុទ្ធិមគ្គភាគ ៣ សេចក្តីសង្ស័យមាន ១៦ យ៉ាងគឺ ក្នុងអតីត ៥ ក្នុងបច្ចុប្បន្ន ៦ និងក្នុងអនាគត ៥ ។

167 សោតាបន្នបុគ្គលតូច ឬ ថាកូនសោតាបន្នបុគ្គល ។

ក្នុងសៀវភៅ **បឋមវិបស្សនា** នេះ ខ្ញុំសូមពោលអំពីវិធីចម្រើន **វិបស្សនា** ដោយសេចក្តីសង្ខេបដូចតទៅ:

## លក្ខណៈ ៣ យ៉ាង

លក្ខណៈដែលមានស្មើទូទៅដល់សង្ខារទាំងពួងមាន ៣យ៉ាងគឺ:

១- **អនិច្ចតា** ភាពជារបស់មិនទៀង ។

២- **ទុក្ខតា** សភាពជាទុក្ខ ។

៣- **អនត្តតា** សភាពមិនមែនជារបស់ខ្លួន ។

## សេចក្តីពន្យល់

**អនិច្ចំ** ដោយអត្ថថា **ខយំ** អស់ទៅ ព្រះយោគីគប្បីពិចារណាឱ្យឃើញថា **នាមរូប** ណាកើតឡើង **នាមរូប** នោះអស់ទៅ ។

**ទុក្ខំ** ដោយអត្ថថា **ភយំ** សេចក្តីភ័យខ្លាច។ ព្រះយោគីគប្បីពិចារណាឱ្យឃើញថា **នាមរូប** ជាធម្មជាតិនាំមកនូវសេចក្តីភ័យខ្លាច ។

**អនត្តតា** ដោយអត្ថថា **អសារំ** មិនមានខ្លឹមសារ ។ ព្រះយោគីគប្បីពិចារណាឱ្យឃើញថា ក្នុងអត្តភាពនេះមិនមានខ្លឹមសារអ្វីសោះ មានត្រឹមតែ **នាមរូប** ប៉ុណ្ណោះ **នាមរូប** នេះជាធម្មជាតិសោះសូន្យទទេ បែកធ្លាយងាយកើតរលត់តាមហេតុបច្ច័យមិនលុះក្នុងអំណាចនៃជនណា ។

# កច្ចប្រតបត្ត

ការចម្រើន **វិបស្សនា** តែងប្រព្រឹត្តទៅតាមទ្វារ ៦, គ្រប់ទ្វារ, គ្រប់អារម្មណ៍ គ្រប់ឥរិយាបថ, គ្រប់សម័យ និង គ្រប់ពេលវេលាទាំងអស់ ទើប **អកុសលធម៌** មិនងើបឡើងគ្របសង្កត់ចិត្តបាន ។

ដំបូងសូមលើកឡើងនូវកិច្ចប្រិបត្តិតាម **មនោទ្វារ** ១ ក្នុងឥរិយាបថអង្គុយ ក្នុងកាលដែលព្រះយោគីចម្រើននូវ **កម្មដ្ឋាន** មកពោលមានសេចក្ដីដូចតទៅនេះ ៖

ព្រះយោគី កាលដែលបានចម្រើននូវ **សមថកម្មដ្ឋាន** រហូតដល់បានគុណគឺចិត្តស្ងប់ឱ្យជាបាទបន្ទាប់មកបានកំណត់ដឹងស្គាល់ជាក់ច្បាស់នូវ **នាមរូប** ព្រមទាំងបច្ច័យដោយប្រាជ្ញានៃខ្លួនក្ដី ព្រះយោគីដែលមិនបានចម្រើននូវ **សមថកម្មដ្ឋាន** ឱ្យជាបាទ ជាយោគីមានចិត្តនឹងស្ងប់ មានប្រាជ្ញាឈ្លាសវៃ ដោយអាស្រ័យបានអប់រំចិត្តប្រមូលចិត្ត ញ៉ាំង**ចិត្តេកគ្គតា** (ភាពនៃចិត្ត ដែលមានអារម្មណ៍មូលតែមួយ) ឱ្យកើតឡើងបាន បានកំណត់ដឹងនូវ**នាមរូប**ព្រមទាំងបច្ច័យ ដោយប្រាជ្ញានៃខ្លួន តាមវិធីខាងដើមដែលបានពោលហើយ បន្ទាប់អំពីបានពិចារណាឃើញនូវ **នាមរូប** ព្រមទាំងបច្ច័យមក ព្រះយោគីគប្បីធ្វើការសង្កេតពិចារណានូវសភាវធម៌[168] ដែលកំពុងតាំងឡើងហើយអស់ទៅវិញតាមទ្វារក៏នឹងឃើញប្រាកដបានដោយពិត។

---

[168] នាមធម៌, រូបធម៌ ។

កាលបើព្រះយោគី បានឃើញនូវសភាវធម៌ដែលកំពុងតាំងឡើងហើយអស់ទៅវិញដោយប្រាជ្ញានៃខ្លួនបានជាក់ច្បាស់ហើយ ព្រះយោគីក៏គប្បីសិក្សាសន្សំក្នុងការដឹងនូវការកើត និងអស់ទៅនៃសភាវធម៌នោះបន្តទៅទៀត ដោយឥរិយាបថអង្គុយនោះ ដែលកំពុងប្រាកដនោះ ។

ក្នុងឥរិយាបថអង្គុយនោះ កាលបើព្រះយោគីបានសម្រេចនូវ **វិបស្សនា** តាមន័យដែលបានពោលហើយ បន្ទាប់អំពីនោះមក ព្រះយោគីគប្បីសង្កេតពិចារណានូវកិរិយាកើត និងកិរិយាអស់ទៅនៃសភាវធម៌ តាមទ្វារទាំង ៥ បន្តទៅទៀត ។

កាលបើព្រះយោគី ធ្វើសេចក្ដីឧស្សាហ៍ព្យាយាមសង្កេតពិចារណានូវកិរិយាកើត និងកិរិយាអស់ទៅនៃសភាវធម៌ ដែលមានប្រាកដដល់ទ្វារទាំង ៥ ពេលនោះក៏ នឹងឃើញប្រាកដបានដោយពិត ។

កាលបើព្រះយោគី បានសម្រេចនូវបញ្ញាមានសភាពបែបនេះហើយ ព្រះយោគីគប្បីពិចារណាធ្វើទុកក្នុងចិត្តនូវសភាវធម៌ ដែលអស់ទៅនោះកុំដាក់ធុរៈឡើយ ចេះតែចម្រើនរឿយៗ ទៅ ឱ្យបានគ្រប់ទ្វារ គ្រប់អារម្មណ៍ គ្រប់ឥរិយាបថគ្រប់សម័យ និងគ្រប់វេលា រហូតលុះដល់ប្រាជ្ញាបានឃើញជាក់ច្បាស់នូវសភាវធម៌ដែលតាំងឡើង ហើយអស់ទៅនោះ ក្នុងកាលណាប្រាជ្ញាបានឃើញ **នាមរូប** មិនទៀងពិតហើយ ក្នុងកាលនោះប្រាជ្ញាក៏នឹងឃើញ **នាមរូប** ជាទុក្ខថែមទៀត, ក្នុងកាលណាប្រាជ្ញាបានឃើញ **នាមរូប** ជាទុក្ខពិតហើយ ក្នុងកាលនោះប្រាជ្ញាក៏នឹង

ឃើញច្បាស់នូវ **នាមរូប** ជាធម្មជាតិគ្មានខ្លឹមសារដោយពិតប្រាកដ ។ សមដូចសេចក្តីក្នុង **វិសុទ្ធិមគ្គ** ភាគ ៣ ថា:

**យំ អនិច្ចំ, តំ ទុក្ខំ**

**យំ ទុក្ខំ, តំ អនត្តា**

ធម្មជាតិណាមិនទៀង ធម្មជាតិនោះជាទុក្ខ ។

ធម្មជាតិណាជាទុក្ខ ធម្មជាតិនោះជាអនត្តា ។

កាលបើប្រាជ្ញា បានពិចារណាឃើញច្បាស់នូវសភាពអស់ទៅ សភាពជាភ័យ និងសភាពគ្មានខ្លឹមសារដូចបានពោលមកហើយនេះ ព្រះយោគីឈ្មោះថាជាអ្នកបាន ឃើញនូវព្រះត្រៃលក្ខណ៍ដោយពិត ។

បន្ទាប់អំពីនោះ ព្រះយោគីក៏គប្បីចម្រើននូវ **វិបស្សនា** ដោយន័យថា

**នាមរូបំ អនិច្ចំ** នាមរូបមិនទៀង ។

**នាមរូបំ ទុក្ខំ** នាមរូបជាទុក្ខ ។

**នាមរូបំ អនត្តា** នាមរូបជាអនត្តា ។

ឱ្យត្រូវតាមអត្ថ ដូចបានពោលមកហើយក្នុងខាងដើមបន្តទៅទៀត ។

កាលបើព្រះយោគី បានព្យាយាមចម្រើននូវ **វិបស្សនា** រឿយ ៗ គ្រប់ទ្វារ, គ្រប់អារម្មណ៍, គ្រប់ឥរិយាបថទាំង ៤, គ្រប់ទីកន្លែង, គ្រប់សម័យ និងគ្រប់ពេលវេលា កាលបើបានជួបប្រទះនឹងធម៌ ១០ យ៉ាងគឺ **ឱភាស** ១, **ញាណ**

១, **បីតិ** ១, **បស្សទ្ធិ** ១, **សុខ** ១, **អធិមោក្ខ** ១, **បគ្គាហ** ១, **ឧបដ្ឋាន** ១, **ឧបេក្ខា** ១ និង **និកន្តិ** គប្បីលះបង់ចេញ កុំមានចិត្តជាប់ជំពាក់ក្នុងក្រុមធម៌ទាំង ១០ នោះឡើយ ត្បិតថាពួកធម៌ទាំងនេះជាឧបក្កិលេសរបស់ **វិបស្សនា** មែនពិត ។

កាលបើក្រុមធម៌ទាំង ១០ ធម៌ណាមួយកើតឡើងប្រាកដក្នុងសម័យណា ក្នុងសម័យនោះព្រះយោគីគប្បីធ្វើទុកក្នុងចិត្តថា:

**នេតំ មម** នេះមិនមែនរបស់អញទេ ។

**នេសោហមស្មិ** នុ៎ះមិនមែនជាអញទេ ។

**ន មមេសោ អត្តា** នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។

**វិបស្សនូបក្កិលេស** មានន័យថា ធម្មជាតិជាគ្រឿងចូលទៅសៅហ្មងដល់ **វិបស្សនា** មាន ១០ យ៉ាងគឺៈ

១- **ឱភាស** ពន្លឺភ្លឺស្វាងរបស់ **វិបស្សនា** គឺជាពន្លឺដ៏ក្រៃលែងជាងកាលមុនដែលព្រះយោគីមិនធ្លាប់បានជួបប្រទះក្នុងការចម្រើននូវ **សមថកម្មដ្ឋាន** ។

២- **ញាណ** ញាណរបស់ **វិបស្សនា** គឺ **បញ្ញា** កើតក្លៀវក្លាដូចព្រះខ័នពេជ្ររបស់ស្ដេច **អមរិន្ទ្រាធិរាជ** ។

៣- **បីតិ** បីតិក្នុង **វិបស្សនា** គឺសេចក្ដីឆ្អែតកាយឆ្អែតចិត្ត ។

៤- **បស្សទ្ធិ** សេចក្ដីស្ងប់ក្នុង **វិបស្សនា** សេចក្ដីស្ងប់កាយស្ងប់ចិត្ត គឺសេចក្ដីស្ងប់ពិសេសជាងកាលមុន ។

៥- **សុខ** សេចក្ដីសុខក្នុង **វិបស្សនា** គឺសេចក្ដីសុខកើតឡើងយ៉ាងឧត្ដម ។

៦- **អធិមោក្ខ** សទ្ធា គឺជំនឿស៊ប់មានកម្លាំងដ៏មាំ ។

៧- **បគ្គាហៈ** វីរិយគឺសេចក្ដីព្យាយាមមាំក៏កើតភ្លៀវភ្លាជា **សម្មប្បធាន** ។

៨- **ឧបដ្ឋាន** សតិ គឺស្មារតីតាំងនៅមាំភ្លៀវភ្លាជា **សតិសម្ពោជ្ឈង្គ** ។

៩- **ឧបេក្ខា** ឧបេក្ខាក្នុង **វិបស្សនា** គឺធម្មជាតិមានសភាពកណ្ដាលស្មើៗ ចំពោះសង្ខារទាំងពួង ដ៏មានកម្លាំងកើតឡើងភ្លៀវភ្លាជា **ឧបេក្ខាសម្ពោជ្ឈង្គ** ។

១០- **និកន្តិ** សេចក្ដីប្រាថ្នាក្នុង **វិបស្សនា** គឺ **សុខុមតណ្ហា** ឱ្យព្រះយោគីមានសេចក្ដីត្រេកអរក្នុង **រូបនិមិត្ត** ដែលជាអានិសង្សរបស់ **វិបស្សនាញាណ** ។

**ធម៌ ៩** ខាងដើម មានឱភាសជាដើមនេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅថា **ឧបក្កិលេស** ព្រោះភាពជាវត្ថុនៃ **ឧបក្កិលេស** មិនមែនទ្រង់ហៅថា **ឧបក្កិលេស** សោយភាពជា **អកុសលធម៌** ឡើយ ។

**និកន្តិ** ១ ទ្រង់ហៅថា **ឧបក្កិលេស** ផង និងវត្ថុនៃ **ឧបក្កិលេស** ផង ។

លំដាប់អំពីព្រះយោគី បានរួចចាក **ឧបក្កិលេស** ទាំង ១០ នោះមក ព្រះយោគី គប្បីចម្រើននូវ **វិបស្សនា** ដោយអំណាចនៃ **ឧទយព្វយានុបស្សនាញាណ** បន្តទៅទៀតក៏ នឹងបានសម្រេចនូវ **អនុបស្សនា ៧** ដោយពិតប្រាកដ ។

**សេចក្តីថា:** កាលបើព្រះយោគី បានរួចចាក **ឧបក្កិលេស** ទាំង ១០ ប្រការហើយ ព្រះយោគីគប្បីចម្រើននូវ **វិបស្សនា** ដែលខ្លួនបានឃើញច្បាស់នោះបន្តទៅទៀតថា:

- **សព្វេ សង្ខារា អនិច្ចា** សង្ខារទាំងឡាយទាំងពួងមិនមាន ។
- **សព្វេ សង្ខារា ទុក្ខា** សង្ខារទាំងឡាយទាំងពួងជាធម្មជាតិ បៀតបៀន ។
- **សព្វេ សង្ខារា អនត្តា** សង្ខារទាំងឡាយទាំងពួងមិនលុះក្នុងអំណាចនៃជនណា ។

## សេចក្តីពន្យល់

**អភាវដ្ឋេន អនិច្ចំ** មិនទៀងដោយអត្ថថា មិនមាន ។

សេចក្តីថា: សង្ខារទាំងអស់នោះកើតឡើងហើយចេះតែប្រែប្រួល មិនទៀងស្ថិតស្ថេរ រលត់ទៅ អស់ទៅ បែកធ្លាយសូន្យទទេទៅ មានហើយនឹងរកមានមិនបាន ទើបលោកពោលថា **អនិច្ចំ** ដោយន័យថា មិនមាន ។

**ឧប្បាទវយប្បដិបីឡនដ្ឋេន ទុក្ខំ** ទុក្ខដោយអត្ថថាបៀតបៀនដោយកិរិយាកើតនិងកិរិយារលត់ ទើបលោកពោលថា **ទុក្ខំ** ដោយន័យថាជាធម្មជាតិបៀតបៀន ។

**អវសវត្តនដ្ឋេន អនត្តា** អនត្តាដោយអត្ថថាមិនលុះក្នុងអំណាចនៃជនណា សង្ខារទាំងនេះ តែងកើតឡើងនិងរលត់ទៅវិញតាមហេតុ

តាមបច្ច័យ ជាធម្មតាជនណាម្នាក់ក្នុងលោកនឹងឃាត់ ឬអង្វរសង្ខារទាំងនោះឱ្យជាយ៉ាងនេះឱ្យជាយ៉ាងនោះមិនបានឡើយ ទើបលោកពោលថា:

**អនត្តា** ដោយន័យថា មិនលុះក្នុងអំណាចនៃជនណា ។

កាលបើព្រះយោគី បានឃើញជាក់ច្បាស់ សោយប្រាជ្ញានៃខ្លួនថាសង្ខារពិតជាមិនមានមែន សង្ខារពិតជាធម្មជាតិបៀតបៀនមែន, សង្ខារ ពិតជាធម្មជាតិកើត រលត់ តាមហេតុ តាមបច្ច័យ មិនលុះក្នុងអំណាចនៃជនណាមែនតាម **វិបស្សនាវិធី** ដូចបាន ពោលមកហើយនោះ ព្រះយោគីអង្គនោះ ឈ្មោះថា "**អារទ្ធវិបស្សកោ**"[169] ដូច្នេះ ។

កាលបើប្រាជ្ញា បានពិចារណាឃើញនូវកិរិយាកើត និងកិរិយារលត់នៃសង្ខារហើយ, បន្ទាប់មកព្រះយោគីគប្បីលះបង់នូវការពិចារណានូវកិរិយាកើតនៃសង្ខារ គប្បីពិចារណាធ្វើទុកក្នុងចិត្តនូវកិរិយាបែកធ្លាយ កិរិយារលត់នៃសង្ខារតែម្យ៉ាងបាន ។

កាលបើប្រាជ្ញា បានពិចារណាឃើញនូវកិរិយាបែកធ្លាយនៃសង្ខារហើយ ព្រះយោគី គប្បីបង្កើតនូវសេចក្តីព្យាយាមក្នុងការចម្រើន **វិបស្សនា** នោះឱ្យជាប្រក្រតី គ្រប់ទ្វារគ្រប់អារម្មណ៍ គ្រប់ទីកន្លែង គ្រប់សម័យ និងគ្រប់ពេលវេលាបន្តទៅ ក៏នឹងបានសម្រេចនូវ **អនុបស្សនា ៧** ដោយពិតប្រាកដ ។

---

[169] អារទ្ធវិបស្សកោ មានន័យថា បុគ្គលជាអ្នកមានវិបស្សនាប្រារព្ធហើយ ។

# អនុបស្សនា ៧ យ៉ាង

១- អនិច្ចានុបស្សនា       បញ្ញាឃើញសង្ខារមិនទៀង ។

២- ទុក្ខានុបស្សនា       បញ្ញាឃើញសង្ខារជាទុក្ខ ។

៣- អនត្តានុបស្សនា       បញ្ញាឃើញសង្ខារមិនមែនជារបស់ខ្លួន ។

៤- និព្វិទានុបស្សនា       បញ្ញានឿយណាយចាកសង្ខារ ។

៥- វិរាគានុបស្សនា       បញ្ញាប្រាសចាកតម្រេកក្នុងសង្ខារ ។

៦- និរោធានុបស្សនា: បញ្ញារលត់បង់នូវសមុទ័យ គឺហេតុនាំឱ្យកើតសង្ខារ ។

៧- **បដិនិស្សគ្គានុបស្សនា** បញ្ញារលាស់ចោលនូវ **ខន្ធ** ៥ និង អភិសង្ខារធម៌ ដែលជាបច្ច័យនាំឱ្យកើតនូវ **ខន្ធបញ្ចក** នោះក្នុងភព ។

# សិក្សាអំពីកលេស និងធម៌បន្ថែម

**១- ទុច្ចរិត ១០**

ទុច្ចរិត       មានន័យថា ប្រព្រឹត្តអាក្រក់មាន ៣ យ៉ាងគឺ:

១- កាយទុច្ចរិត       ប្រព្រឹត្តអាក្រក់ដោយកាយ ។

២- វចីទុច្ចរិត       ប្រព្រឹត្តអាក្រក់ដោយវាចា ។

៣- មនោទុច្ចរិត       ប្រព្រឹត្តអាក្រក់ដោយចិត្ត ។

## ១- កាយទុច្ចរិត ៣ យ៉ាងគឺ

ក- បាណាតិបាត សម្លាប់សត្វ ។

ខ- អទិន្នាទានា លួចទ្រព្យគេ ។

គ- កាមេសុ មិច្ឆាចារ ប្រព្រឹត្តខុសក្នុងកាម ។

## ២- វចីទុច្ចរិត ៤ យ៉ាងគឺ

ក- មុសាវាទា និយាយកុហកគេ ។

ខ- បិសុណាវាចា និយាយញុះញង់គេ ។

គ- ផរុសវាចា និយាយចាក់ដោយគេ ។

ឃ- សម្ផប្បលាប និយាយពាក្យឥតប្រយោជន៍ ។

## មនោទុច្ចរិត ៣ យ៉ាងគឺ

ក- អភិជ្ឈា សម្លឹងរំពៃចង់បានរបស់គេ ។

ខ- ព្យាបាទ ចងចិត្តប្រទុស្តគេ ។

គ- មិច្ឆាទិដ្ឋិ ឃើញខុសចាកគន្លងធម៌ ។

ទុច្ចរិត ៣ យ៉ាងនេះ ជាធម៌មិនគួរប្រព្រឹត្ត គួរលះបង់ចេញ ចាត់ជាថ្នាក់កិលេស គឺកិលេសគ្រោតគ្រាត ។

ធម៌ដែលផ្ទុយនឹងទុច្ចរិត គឺ សុចរិត ។

សុចរិត មានន័យថា ប្រព្រឹត្តល្អមាន ៣ យ៉ាងគឺ ។

១- កាយសុចរិត ប្រព្រឹត្តល្អដោយកាយ ។

២- វចីសុចរិត ប្រព្រឹត្តល្អដោយវាចា ។

៣- មនោសុចរិត ប្រព្រឹត្តល្អដោយចិត្ត ។

## ១- កាយសុចរិតមាន ៣ យ៉ាងគឺ

ក- វៀរចាកការសម្លាប់សត្វ ។

ខ- វៀរចាកការលួចទ្រព្យគេ ។

៣- វៀរចាកការប្រព្រឹត្តិខុសក្នុងកាម ។

## ២- វចីសុចរិតមាន ៤ យ៉ាងគឺ

ក- វៀរចាកការនិយាយកុហក ។

ខ- វៀរចាកការនិយាយញុះញង់គេ ។

គ- វៀរចាកការនិយាយចាក់ដោតគេ ។

ឃ- វៀរចាកការនិយាយពាក្យឥតប្រយោជន៍ ។

## ៣- មនោសុចរិតមាន ៣ យ៉ាងគឺ

ក- មិនសម្លឹងរំពៃចង់បានរបស់គេ ។

ខ- មិនចងចិត្តប្រទូស្តគេ ។

គ- ឃើញត្រូវតាមគន្លងធម៌ ។

សុចរិត ៣ យ៉ាងនេះ ជាធម៌គួរប្រព្រឹត្ត ។

## ២- នីវរណធម៌ ៥.

**នីវរណធម៌** ធម៌ដែលជាគ្រឿងរារាំងចិត្តមិនឱ្យបានលុះក្នុងសេចក្ដីល្អ មាន ៥ យ៉ាងគឺ **កាមច្ឆន្ទ** ១, **ព្យាបាទ** ១, **ថីនមិទ្ធ** ១, **ឧទ្ធច្ចកុក្កុច្ច** ១, **វិចិកិច្ឆា** ១ (សេចក្ដីប្រែ មានហើយ)។

**នីវរណធម៌** ទាំង ៥ នេះ កាលបើគ្របសង្កត់ចិត្តហើយ ធ្វើឱ្យសតិប្រាជ្ញាមិនកើតឡើង កាលបើសតិប្រាជ្ញារលត់ហើយ ព្រះយោគីសិក្សានូវ **វិបស្សនា** ក៏មិនបានសម្រេចនូវប្រយោជន៍ដូចបំណងឡើង ។

**នីវរណធម៌** ទាំង ៥ នេះ តែងស្ងប់រម្ងាប់ទៅដោយ **សមាធិក្ខន្ធ** ។

## ៣- កិលេស ៣ ផ្ទាំងលក្ខណៈ ៣ .

**កិលេស** ធម្មជាតិជាគ្រឿងសៅហ្មងចិត្តមាន ៣ គឺៈ

១- លោភៈ ចង់បានមិនចេះស្កប់[170] ។

២- ទោសៈ គិតប្រទូស្តគេ ។

៣- មោហៈ វង្វេងមិនដឹងការពិត ។

### លក្ខណៈ ៣ គឺ

១- **អនិច្ចលក្ខណៈ** សភាពមិនទៀងជាលក្ខណៈ ។

២- **ទុក្ខលក្ខណៈ** សភាពជាទុក្ខ ជាលក្ខណៈ ។

៣- **អនត្តលក្ខណៈ** សភាពមិនមែនជារបស់ខ្លួន ជាលក្ខណៈ ។

---

170 ការជាប់ជំពាក់ចិត្តដោយការចង់បានមិនចេះស្កប់ស្កល់ ។

## លោភ ចាំង អនិច្ចំ

**សេចក្តីថា:** កាលបើលោភៈកើតឡើងគ្របសង្កត់ចិត្តហើយក្នុងកាលណា បុគ្គលមិនឃើញនូវ ***អនិច្ចំ*** ក្នុងកាលនោះ ។

## ទោសៈ ចាំង ទុក្ខំ

**សេចក្តីថា:** កាលបើចិត្តមាន ***ទោសៈ*** ប្រទូស្តហើយក្នុងកាលណា បុគ្គលក៏មិនឃើញនូវសេចក្តី ***ទុក្ខ*** ក្នុងកាលនោះ ។

## មោហៈ ចាំង អនត្តា

**សេចក្តីថា:** កាលបើ ***មោហៈ*** កើតឡើងគ្របសង្កត់ចិត្តហើយក្នុងកាលណា បុគ្គលក៏មិនឃើញនូវ ***អនត្តា*** ក្នុងកាលនោះ ។

**៤- ធម៌ ៧ បដិបក្ខនឹងធម៌ ៧.**

**១**- កាលបើ ***អនិច្ចានុបស្សនា*** កើតឡើង ***និច្ចសញ្ញា*** ក៏រលត់ ។

**២**- កាលបើ ***ទុក្ខានុបស្សនា*** កើតឡើង ***សុខសញ្ញា*** ក៏រលត់ ។

**៣**- កាលបើ ***អនត្តានុបស្សនា*** កើតឡើង ***អត្តសញ្ញា*** ក៏រលត់ ។

**៤**- កាលបើ ***និព្វិទានុបស្សនា*** កើតឡើង ***នន្ទិ*** ក៏រលត់ ។

**៥**- កាលបើ ***វិរាគានុបស្សនា*** កើតឡើង ***រាគៈ*** ក៏រលត់ ។

**៦**- កាលបើ ***និរោធានុបស្សនា*** កើតឡើង ***សមុទ័យ*** ក៏រលត់ ។

**៧**- កាលបើ ***បដិនិស្សគ្គានុបស្សនា*** កើតឡើង ***អាទានៈ*** ក៏រលត់ ។

- និច្ចសញ្ញា មានន័យថា សេចក្ដីសម្គាល់ថា ទៀងក្នុងសង្ខារ ។
- សុខសញ្ញា មានន័យថាសេចក្ដីសម្គាល់ថាមានសេចក្ដីសុខក្នុងសង្ខារ
- អត្តសញ្ញា មានន័យថា សេចក្ដីសម្គាល់មានខ្លួនក្នុងសង្ខារ ។
- នន្ទិ មានន័យថា សេចក្ដីរីករាយក្នុងសង្ខារ ។
- រាគៈ មានន័យថា សេចក្ដីតម្រេកក្នុងសង្ខារ ។
- សមុទយៈ មានន័យថា កិលេសជាហេតុនាំឱ្យកើតសង្ខារ ។
- អាទាន មានន័យថា សេចក្ដីប្រកាន់មាំក្នុងសង្ខារ ។

**៥- បរិញ្ញា ៣.**

បរិញ្ញា បានដល់បញ្ញាហ្នឹងឯង ហើយមាន ៣ យ៉ាងគឺ.

១- ញាតបរិញ្ញា បញ្ញា គឺកំណត់ដឹង ។

២- តីរណបរិញ្ញា បញ្ញា គឺពិចារណា.... ។ល។

៣- បហានបរិញ្ញា បញ្ញា គឺលះបង់ ។

## សេចក្ដីអធិប្បាយ

១- ញាតបរិញ្ញា បញ្ញា មានសេចក្ដីថា កំណត់ដឹង គឺ បញ្ញា ដែលដឹងនូវលក្ខណៈ នៃសភាវធម៌មានកំណត់ថា សភាវៈនេះជា **រូបធម៌** សភាវៈនេះជា **នាមធម៌** ជាដើម និងកំណត់ដឹងនូវហេតុបច្ច័យរបស់ **នាមរូប** នោះ ។

២- **តីរណបរិញ្ញា បញ្ញា** មានសេចក្ដីថា ពិចារណា... ។ល។ គឺ **បញ្ញា** ដែលបានឃើញនូវព្រះត្រៃលក្ខណៈមានឃើញថា **រូបំ អនិច្ចំ** រូបមិនទៀងដូច្នេះជាដើម ។

៣- **បហានបរិញ្ញា បញ្ញា** មានសេចក្ដីថា លះបង់ គឺ **បញ្ញា** ដែលកើតឡើងហើយលះបង់នូវកិលេស បានដល់ **អនុបស្សនា ៧** មាន **អនិច្ចានុ-បស្សនា** ជាដើម ដែលលះបង់នូវសេចក្ដីសម្គាល់ខុសមាន **និច្ចសញ្ញា** ជាដើម ។

**ចប់ដោយបរិបូណ៌**